ចាន់ ដារា   អ៊ិត ថុងងួន   ប៉ែន នារាវី

Chan Dara   Ith Thong Nguon   Pen Nearovi

# កម្ពុជា

## និង

# សហព័ន្ធឥណ្ឌូចិន

*Le Kampuchea*

*et*

*La federation Indochinoise*



## សេចក្តី ថ្លែង អំណរ គុណ

ក្នុងនាម អ្នក សហនិពន្ធ របស់ខ្ញុំ ទាំងពីរនាក់ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ជូនលោក ឃុន ពីម៉ូច ដែលបានខិតខំ ចម្លងតាមខួរយន្ត (កុំព្យូទ័រ) ហើយផ្សាយតាម អ៊ីម៉ែល និង អាំងទែណេត នូវសៀវភៅ *កម្ពុជា និង សហព័ន្ធ ឥណ្ឌូចិន* ។ កិច្ចការនេះ ជាសក្ខីភាពនៃ សេចក្តីស្នេហា អក្សរសាស្ត្រជាតិ និង ប្រវត្តិសាស្ត្រជាតិ ពីសំណាក់លោក ឃុន ពីម៉ូច ហើយបង្ហាញថា ខេមរជនយើង អាចចេះសាមគ្គីគ្នា ក្នុង ករណី ពិសេស ម៉្យាងៗ ដើម្បីជាប្រយោជន៍ សាធារណៈ ទូរទៅ ។

ម៉ុងរ៉េអាល់ ថ្ងៃ ២៦ កញ្ញា ២០០៤

**ម៉ែន ណារី**

អតីត: ប្រធាន សហគមន៍ ខ្មែរ នៅ កាណាដា



# កម្ពុជា
# និង
# សហព័ន្ធឈ្មួញចិន

កំរងអត្ថបទ
អត្ថបទដើមជាភាសាបារាំងដោយ ចាន់ តារា ចុះក្នុងព្រឹត្តិប័ត្រ
សហគមន៍ខ្មែរនៅកាណាដា លេខ ២-៣-៧ និង ៨ៗ

ប្រែសំរួលដោយ ប៉ែន នារី និង អ៊ិត ចុង ធ្លួនៗ
ពិនិត្យឡើងវិញ កែ និង បន្ទ្រប់ដោយ ចាន់ ដារា
១៩៧៦ - ១៩៨៣

បោះពុម្ពនៅម៉ុងរេអាល់ កាណាដា
មេសា ១៩៨៣
ដំកល់ទុកតាមច្បាប់ – បណ្ណាល័យជាតិ នៃ កេបិក
លេខ D8300817

*តាំងពីយើងបានទទួលអារ្យធិមពីឥណ្ឌាមក រហូតដល់ផុតសម័យសិលាចារិក (សតវត្សរ៍ទី១៤) ភាសាខ្មែរជាភាសាទី២ (...)។ ឯភាសាដែលអ្នកចេះដឹងប្រើ (...) គឺភាសាសំស្ក្រឹត (...)។ យើងខំតុបតែងថែទាំទុកសំស្ក្រឹតឲ្យសប្រហែស មិនបានរៀបចំផ្ចិតផ្ចង់កំពង់ខ្មែរផង។*

*លុះមកដល់សតវត្សរ៍ទី ២០ (...) ចំណេះថ្មី គំនិតថ្មី (...) បានចូលមកកាន់ប្រទេសយើងដែរ តែចូលដោយអាស្រ័យភាសាបារាំង ជាយានផ្ទុកយកមក។ (...) ភាសាបារាំង គេក៏កាន់តែប្រើប្រាស់ក្នុងប្រទេសខ្មែរច្រើនឡើង (...)។ ក្នុងវេលាជាមួយនេះ ភាសាខ្មែរមានប្រើការកាន់តែតិចទៅ (...)។ ឯចំនួនអ្នកចេះភាសាបារាំងល្មមប្រើការបានមែនពិតនោះ បើទុកជាបង្កើតឲ្យច្រើនឡើងយ៉ាងណាក៏ដោយ កាលបើយកទៅប្រៀបនឹងចំនួនប្រជាជនខ្មែរទាំងមូលហើយ ក៏មិនខុសពីចំនួនគ្រាប់អង្ករមួយក្តាប់ ដែលប្រៀបទៅនឹងចំនួនអង្ករមួយតៅនោះទេ។ បើនឹងឧបមាមួយយ៉ាងទៀត គឺដូចជាគេស្រោចទឹកដាក់ជីឲ្យលូតលាស់តែដើមឈើ ៣-៤ ដើម ក្នុងឧទ្យានមួយដ៏ធំទូលាយ, ឯឈើដទៃទៀតក្នុងឧទ្យាននោះ ក៏នៅតឿដដែល ដូចក្នុងសតវត្សរ៍ទី ១៩ ថែមទាំងក្នុងឧទ្យាននោះ មានស្មៅបន្លាដុះរាំរពាសពេញទៀតផង។*

*កាលណាភាសាយើងមានប្រើការច្រើនឡើង ក៏នឹងត្រូវរៀនសូត្រភាសាយើងច្រើនឡើងដែរ។ កាលបើរៀនច្រើនឡើង ក៏នឹងមានមនុស្សចេះភាសាយើងកាន់តែច្រើនគ្នាឡើង កាន់តែជ្រាលជ្រៅទៅ។ អ្នកដែលស្វែងរកចំណេះបានមកពីភាសាក្រៅ មានភាសាបារាំងជាដើម កាលបើចេះភាសាខ្មែរជ្រាលជ្រៅហើយ ក៏នឹងអាចនាំយកវិជ្ជាដែលខ្លួនស្វែងបានមកនោះ មករៀបរៀងសរសេរជាភាសាខ្មែរ ចែកចាយផ្សាយដល់បងប្អូនរួមជាតិទាំងឡាយ ឲ្យបានចេះដឹងដោយសារផង។*

*អៀវ កើស, នៅឆ្នាំ ១៩៤៧*

*(ក្នុង "ភាសាខ្មែរ, ការល្បងពិនិត្យដោយរកហេតុផល" បោះពុម្ពផ្សាយនៅឆ្នាំ ១៩៦៧ ដោយបណ្ណាល័យ មិត្តសេរី, ភ្នំពេញ, កម្ពុជា)*

# មាតិការឿង

ទំព័រ

ភាគទីមួយ
ដើមកំណើតខ្មែរ ............................................................................ ៥
ភាគទីពីរ
ពី ការប៉ះលើកដំបូងនឹងបស្ចឹមប្រទេស ទៅ អាណានិគម ............................... ១២
ភាគទីបី
ពី អាណានិគម ទៅ សហភាពឥណ្ឌូចិន ........................................................ ១៩
ភាគទីបួន
ពី សហភាពឥណ្ឌូចិន ទៅ សហព័ន្ធឥណ្ឌូចិន ................................................ ២៩
ភាគទីប្រាំ
សហព័ន្ធឥណ្ឌូចិន ដើម្បីអ្វី? ........................................................................ ៧១
ទំព័រភ្ជាប់១
ការទាក់ទង ខ្មែរ-ចិន ........................................................................... ១២៦
ទំព័រភ្ជាប់២
វិភាគចុងក្រោយ ............................................................................... ១៣៣
ទំព័រភ្ជាប់៣
ផែនទី ............................................................................................... ១៤២
ទំព័រភ្ជាប់៤
លំដាប់ពេលនៃការពង្រីកទឹកដីយួន ........................................................... ១៥៦

# សេចក្តីផ្តើម

*ដើមកំណើតរបស់សៀវភៅនេះ គឺអត្ថបទមួយចំនួនដែលបានត្រូវបោះផ្សាយក្នុងចន្លោះខែវិច្ឆិកា ១៩៧៦ និងខែតុលា ១៩៧៧។ ភាគទី៥ ឈ្មោះ “សហព័ន្ធឥណ្ឌូចិនដើម្បីអ្វី?” គ្រាន់តែជាការសិក្សា និង ការវិភាគលើព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងក្នុងប្រទេសកម្ពុជាក្នុងរយៈពេលនោះ ដែលគេដឹងឮជាសាធារណៈ ពីអង្គការផ្សាយពិតមាន និងតាមសក្ខីភាពរបស់អ្នកភៀសខ្លួន។*

*ការពិត ការណ៍ពិតមែនទែនលើផ្នែកនយោបាយ អាចចេញតែពីមាត់ ឬពីស្លាបប៉ាក្ការបស់សាមីជនទេ គឺអតីតៈពួកដឹកនាំរដ្ឋកម្ពុជាប្រជាធិតេយ្យ។ អ្នករៀបរៀងដំកល់ទុកស្ទើរតែទាំងស្រុងនូវអត្ថបទដើម ហើយកែតែកន្លែងខ្លះដែលព្រឹត្តិការណ៍ក្រោយមកបានបំភ្លឺយ៉ាងច្បាស់។*

*លើផ្នែកពង្សាវតា អ្នកអាននឹងអាចឃើញថា សម័យមហានគរ សម័យពួកវ្ន័នដឹបវរ ពុំសូវបានរ៉ាយរ៉ាប់ច្រើនទេ។ ផ្ទុយទៅវិញ គេនឹងឃើញហេតុការណ៍ខ្លះដែលធ្វើឲ្យភ្ញាក់ ឲ្យអៀន ហើយឲ្យរិះគិត។ រយៈវេលាខ្លះទៀត គឺសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋ ក៏ពុំបានត្រូវបរិយាយជាវគ្គពិសេស ឬឲ្យបានក្បោះក្បាយវែងឆ្ងាយចប់សព្វគ្រប់នោះក៏ទេដែរ ហើយត្រូវមានគេសរសេរចារទុកជាសៀវភៅ សំរាប់សាធារណជនខ្មែរយើង។ ដូចឈ្មោះខ្លួនបានបង្ហាញស្រាប់ សៀវភៅនេះ កំរងអត្ថបទនេះ ល្បងសិក្សារកមូលហេតុខ្លះៗ ដែលបានធ្វើឲ្យស្រុកខ្មែរយើងធ្លាក់ខ្លួនមកក្នុងស្ថានភាពសព្វថ្ងៃ គឺស្ថានភាពជាប្រទេសក្រោមការអាណាព្យាបាលរបស់វៀតណាម ក្នុងវង្វង់ឥណ្ឌូចិន។ ចាប់ផ្តើមពីនោះទៅ “សហព័ន្ធឥណ្ឌូចិន” នេះ បានជាមានឈ្មោះជាក់ច្បាស់ដូច្នេះ ព្រោះមានកំណើតរួចម្តងទៅហើយ នៅក្នុងសម័យអាណានិគមបារាំង។ ដូច្នេះ គឺជាការធម្មតាដែលសៀវភៅនេះមានបីភាគ ដែលអធិប្បាយអំពីយុគអាណានិគម។*

*លើផ្នែកអក្សរសាស្ត្រ អ្នកអាននឹងចាប់កំហុសជាច្រើន ខាងវាក្យស័ព្ទ ខាងវេយ្យាករណ៍ និងខាងអក្ខរាវិរុទ្ធ។ នេះមកពីរបរនៃអ្នករៀបរៀងផង ដែលគ្មានទំនាក់ទំនងអ្វីសោះនឹងអក្ខរាសាស្ត្រ និងមកពីការខ្វះខាតផ្ទាល់របស់ភាសាយើងផង។ ជាពិសេស គេត្រូវអានយ៉ាងយឺតនូវការសូត្រឃ្លា (ស៊ីតាស្យុង) របស់អ្នកនិពន្ធបរទេស។ យើងជឿលើការយោគយល់របស់អ្នកអាន។*

*ជាបង្ហើយ ក្រុមអ្នករៀបរៀង ឥតអះអាងធ្វើសៀវភៅប្រវត្តិសាស្ត្រ ឬប្រវត្តិសាស្ត្រនយោបាយទេ ប៉ុន្តែគ្រាន់តែជូនទិដ្ឋិភាពមួយនៃកម្ពុជា ក្នុងកាលៈទេសៈទូទៅនៃឥណ្ឌូចិន ទិដ្ឋិភាពដែលខ្លួនយល់ថាមានប្រយោជន៍ ដល់ការត្រិះរិះពិចារណា រកមធ្យោបាយសំរាលវាសនាប្រទេសយើង និងប្រជាជនយើង។*

*ម៉ុងរ៉េអាល ខែមេសា ១៩៨៣ ។*

# ភាគទី១

# ដើមកំណើតនៃខ្មែរ

*កាយមិនសំខាន់ជាងព្រលឹងទេ*

*ពេលដែលបារាំងមកដល់កម្ពុជាក្នុងឆ្នាំ ១៨៦៣ ស្រុកខ្មែរបង្ហាញទិដ្ឋភាពមួយដែលធ្វើឲ្យខ្លោចផ្សារ។ កម្ពុជាសព្វថ្ងៃ, ប្រទេសមួយដែលស្ទើរតែអស់មនុស្សរលីង, ហៀបនឹងទៅជាខេត្តមួយរបស់អ្នកជិតខាងទិសឯលិចទៅហើយ គឺប្រទេសថៃ (សម័យនោះសៀម), ក្នុងពេលដែលអ្នកជិតខាងទិសឯកើត គឺប្រទេសវៀតណាម (សម័យនោះអណ្ណាម) បានយកធ្វើជារបស់ខ្លួនតាំងតែពីដំណាច់សតវត្សរ៍ទី ១៨ នូវខេត្តខ្មែរទាំងអស់ខាងទិសអាគ្នេយ៍ គឺ* ***កម្ពុជាក្រោម*។**

*សង្គ្រាមកំឡុង ៥០០ ឆ្នាំ, ដំបូងទល់នឹងការត្រួតត្រារបស់សៀម រួចមកទល់នឹងការត្រួតត្រារួម* (condominium) *របស់សៀម និងយួន (ការត្រួតត្រារួមដែលបានធ្វើឲ្យខ្មែរបែកបាក់គ្នាយ៉ាងខ្លាំង), បានធ្វើឲ្យបណ្ដាជនខ្មែរទ្រុឌទ្រោម រហូតដល់បាត់ចំណាំងទាំងអស់ជាមួយប្រវត្តិសាស្ត្រខ្លួន ហើយបង្រួញចំនួនប្រជាជនខ្មែរឲ្យនៅសល់តែ ៨០០ ០០០ នាក់។ ការធ្វើឲ្យទីដ្ឋានអង្គរមានជីវិតឡើងវិញ*[១] *ដោយអ្នកប្រាជ្ញបារាំងនៃសាលាបារាំងនៅចុងបូព៌ាប្រទេស*[២] *បានធ្វើឲ្យមនុស្សជាតិឃើញឡើងវិញនូវអច្ឆរិយវត្ថុ ដែលជាសំណល់ និងជាកស្តុតាងនៃអារិយធម៌មួយ ក្នុងចំណោមពពួកភ្លឺស្វាងជាងគេទាំងអស់នៃពិភពលោក៖* ***អារិយធម៌ខ្មែរ*** ។

*ការសិក្សាសិលាចារិក, ការរុករកដល់ប្រភពចិន, អារ៉ាប់, ព័រទុយហ្គេ និងបារាំង បើកឲ្យរៀបរៀងឡើងវិញបាននូវប្រវត្តិនៃប្រជាជាតិខ្មែរ, ប្រវត្តិមួយដែលធ្វើឲ្យភ្ញឹកផង, ពោរពេញទៅដោយទុក្ខ ភ័យផង, ធ្វើឲ្យខ្លោចចិត្តផង។ ក្នុងពេលនោះ កិច្ចការជួសជុលប្រាសាទអង្គរត្រូវធ្វើមុនអ្វីទាំងអស់។ ដោយហេតុនេះ ការពិនិត្យរក* ***បុព្វប្រវត្តិសាស្ត្រ***[*] *នៃប្រទេសទាំងបីនៃឥណ្ឌូចិន ពុំសូវបានត្រូវធ្វើច្រើនឡើយ បើថាគេពុំសូវយកចិត្តទុកដាក់លើក៏ស្ទើរតែបាន។ ទាល់តែដល់ដំណាច់ឆ្នាំ ១៩៣១ ទើបគេចាប់ឃើញទីស្រាវជ្រាវបុព្វប្រវត្តិសាស្ត្រជាង ៦០ នៅក្នុងឥណ្ឌូចិនបារាំង។ ការសិក្សាខាងមនុស្សសាស្ត្រ* (anthropologie) *បង្ហាញឲ្យឃើញថា កម្ពុជាក្នុងយុគថ្ម ជាអង្រឹងរបស់ជាតិសាសន៍មួយចំនួន ដែលអ្នកតពូជ*[៣] *នៅមានរហូតសព្វថ្ងៃក្នុងកោះស្រីលង្កា, នៅម៉ាឡេស៊ី, ហ្វីលីពីន, ឥណ្ឌូណេស៊ី*[៤] *និង នៅអូស្ត្រាលី។*

*ភាគអាគ្នេយ៍នៃទ្វីបអាស៊ី ជាទីរស់នៅនៃសាសន៍ធំពីរ គឺសាសន៍ម៉ុងហ្គោលខាងត្បូង និង សាសន៍ឥណ្ឌូណេស៊ីយែន*[៥]*។ ជាតិយួន ជាលទ្ធផលនៃការបង្កាត់សាសន៍ទាំងពីរ។ ឯជាតិថៃ និងជាតិភូមា ក៏ដូច្នោះដែរ។ ប៉ុន្តែចំពោះជាតិខ្មែរវិញ, ទោះបីសាវតាខ្លួនពោរពេញទៅដោយចំបាំងរាំងជល់មិនចេះចប់ មិនចេះហើយជាមួយអ្នកជិតខាង —ចំបាំងដែលធ្វើឲ្យមានការបង្កាត់គ្នាចុះឡើងជាច្រើនដង— ក៏លក្ខណៈនៃសាសន៍ស្បែកលឿង មិនលេចឡើងឲ្យជាក់ស្ដែង ដូចករណីប្រជាជាតិឯទៀត នៅអាស៊ីអាគ្នេយ៍*[៦]*៖ ស្បែកក្រម៉ៅជាង, ភ្នែក*

---

(*) ***បុព្វប្រវត្តិសាស្ត្រ*** (préhistoire) *គឺការសិក្សាប្រវត្តិមនុស្សលោក មុនពេលមានឯកសារសរសេរ។ គេអាចតាមដានបានដោយសិក្សាសំណល់ឆ្អឹង និងសំណល់ឧបករណ៍ផ្សេងៗ ដែលគេបានគាស់កាយឃើញ។ គេបែងចែកបុព្វប្រវត្តិសាស្ត្រជាបីយុគ ដែលមានដូចតទៅ៖*

*១-* ***យុគថ្មចាស់*** (paléolithique) *៖ ភាគច្រើននៃជីវិតទី ៤ នៃធរណី* (quaternaire) *មកដល់ឆ្នាំ ៨០០០ មុនគ.ស.។ ជីវិតទី ៤ នៃធរណី គឺសម័យដែលធាតុអាកាសចាប់ត្រជាក់ខ្លាំង ហើយទឹកកករីងទាំងអស់ (ចាប់ផ្ដើមពី ២ ទៅ ៣ លានឆ្នាំមុន)។ មនុស្សលោកកើតឡើងក្នុងជីវិតទី ៤ នៃធរណីនោះ។ ក្នុងយុគថ្មចាស់, មនុស្សគ្រាន់តែចេះធ្វើឧបករណ៍ផ្សេងៗ (វាយបំបែកថ្ម ហើយចាំងឲ្យស្រួច), ប្រើឆ្អឹងនឹងភ្លុក, មានសិល្បៈខ្វះ (គំនូរក្នុងរូងភ្នំឡាស្កូ, បារាំង) ។*

*២-* ***យុគថ្មកណ្ដាល*** (mésolithique) *ពីឆ្នាំ ៨០០០ មុន គ.ស. ដល់ ៣០០០ មុន គ.ស. ។ ហួសពីការរកចិញ្ចឹមជីវិតដោយបរបាញ់ គេឃើញលេចចេញនូវសេដ្ឋកិច្ចជាដំណាំដាំដុះ។ ការចេះប្រើប្រាស់ដែក ក៏ចាប់ផ្ដើមឡើងហើយ។*

*៣-* ***យុគថ្មថ្មី*** (néolithique) *ពី ៣០០០ មុន គ.ស. ដល់ ១៥០០ មុន គ.ស. ។ មនុស្សចេះកាត់សំលៀងថ្ម, ធ្វើថូ និង បំពង់ផ្សេងៗ ពីអិដ្ឋ, ចេះត្បាញ។ កសិកម្មកាន់តែចំរើន, រីឯខាងលោហធាតុ មនុស្សចេះប្រើមាស, ស្ពាន់ និងសំរិទ្ធ។*

ផ្ញៀងជ្រ គេពុំសូវមានឃើញទេ, សក់រួញអង្គាជី ឬមួយក្រញាញ់តែម្តង។ មួយចំណែកទៀត លក្ខណៈមនុស្សសាស្ត្រនៃជាតិខ្មែរ នៅតែជាទីទំនាស់នៃទ្រឹស្តីទាំងពួង។ អ្នកមនុស្សសាស្ត្រខ្លះ ភ្ជាប់ខ្មែរទៅនឹងពួក "ណេគ្រីតូ" (négrito, មនុស្សខ្មៅតូចនៅ ម៉ាឡេស៊ី)[៧], អ្នកខ្លះទៀត ភ្ជាប់ទៅជំពូក ឥណ្ឌូណេស៊ីយែន។

ឆ្អឹងក្បាល ដែលគេគាស់ចេញពីស្រទាប់ដី ចាស់ជាងគេ នៅរណ្តៅស្រាវជ្រាវ នៅសំរោងសែន ក្នុងប្រទេសកម្ពុជា នៅល្អាងភ្នំ ផូបិញយ៉ា និង លឿងកឹង ក្នុងវៀតណាមខាងជើង, នៅល្អាងភ្នំ មិញកាំ ក្នុងវៀតណាមខាងត្បូង, និងនៅអណ្តូងវ៉ែ ថាំហាង ក្នុងប្រទេសលាវ សុទ្ធតែនៅក្នុងចំពូក "ណេគ្រីតូ- មេឡាណេស៊ីយាង" ដែលប្រហែលគ្នានឹងឆ្អឹងក្បាលនៃមនុស្សខ្មៅនៅ អូស្ត្រាលី និងនៃពួក ប៉ាពូ នៅមេឡាណេស៊ី។ គេអាចរកចម្លើយខ្លះបាន បើគេដាក់កម្ពុជាក្នុងកាលៈទេសៈទូទៅនៃអាស៊ីអគ្នេយ៍។ ដូច្នេះមែន, ក្នុងភូមិភាគនេះ ដំណាក់ធំៗ នៃការវិវត្តន៍នៃសណ្តានសត្វបំបៅកូនដែលជឿនលឿនជាងគេ (primates) បានត្រូវគេបង្ហាញយ៉ាងច្បាស់ ដោយសារការរកឃើញឆ្អឹងនៃ "អូមីនីយាង" (hominien), សណ្តានសត្វស្វាស្ទើរមនុស្ស[៨]។ សំណល់ពីយុគថ្មចាស់ បានត្រូវគេរកឃើញនៅកោះជ្វា និងនៅលើទ្វីប។ សំណល់ទាំងនេះ ដូចគ្នានឹងសំណល់ដែលគេរកឃើញក្នុងភូមិភាគ ដែលនៅចន្លោះប្រទេសចិនខាងជើង និងអាស៊ីកណ្តាល។ ទីស្រាវជ្រាវនៅកោះជ្វា បានត្រូវគេសិក្សាយ៉ាងហ្មត់ចត់ជាងទីឯទៀតទាំងអស់[៩]។ នៅឆ្នាំ ១៨៩១ ឆ្អឹងក្បាលមួយភាគ នៃមនុស្ស-ស្វា (pithécanthrope) បានត្រូវគេគាស់ឃើញនៅកណ្តាលកោះជ្វា។ មនុស្ស-ស្វា នេះ ជាសត្វជឿនលឿនណាស់ហើយ ក្នុងសណ្តានសត្វបំបៅកូនជឿនលឿន (primates)។ ក្រោយមកទៀត នៅកណ្តាលកោះជ្វាដដែល, គេរកឃើញឆ្អឹងនៃ "អូមីទ្រាង" ដែលបានរស់នៅក្នុងយុគថ្មចាស់។ ឆ្អឹងខ្លះនៃជំពូកមនុស្សថ្មីជាងនេះ (១២០០០ ឆ្នាំ មុន គ.ស.) បានត្រូវគេរកឃើញនៅ វ៉ាជ្យាក់ លើឆ្នេរខាងត្បូងនៃកោះជ្វា។ ក្នុងឆ្នាំ ១៩៤២ នៅអូស្ត្រាលីគេរកឃើញឆ្អឹងក្បាលមួយ ដែលប្រហែលគ្នានឹងក្បាលនៅ វ៉ាជ្យាក់ ដែរ។ នៅប្រទេសលាវ អ្នកវិទ្យាសាស្ត្រខាងធរណី ហ្ស. ហ្វ្រូម៉ាហ្សេ រកឃើញក្នុងអណ្តូងវ៉ែ ថាំហាង, ថាំប៉ុង និង ថាំប៉ាឡយ នូវ ឆ្អឹង "អូមីទ្រាង" ដែលប្រហែលគ្នានឹងឆ្អឹង "មនុស្សចិន" (sinanthrope) ដែលគេកាយឃើញនៅប៉េកាំង ហើយនិងឆ្អឹងដែលគេគាស់ឃើញនៅ ម៉ុជជោគែតូ ក្នុងកោះជ្វា ហើយដែលសល់មកពីយុគថ្មចាស់។ បុព្វការីនៃមនុស្សលោកទាំងនេះ, ដែលបានរស់នៅក្នុងជីវិតទី៤ នៃធរណី, មិនទាន់ចេះធ្វើប្រដាប់ប្រដារប្រើនៅឡើយទេ។

នៅក្នុងយុគថ្មកណ្តាល គេឃើញការមកដល់ជាលើកទីមួយ នៃបណ្តាជនដែលនៅក្នុងជំពូក "អូស្ត្រាឡូអ៊ីដ–វេឌោអ៊ីដ" (australoïde-veddoïde)[១០] ដែលលក្ខណៈកាយមានជាអាទិ៍ គឺ ៖ ស្បែកក្រម៉ៅ និងសក់រួញអង្គាជី។ ដំណាងយ៉ាងបរិសុទ្ធ (ឥតកាត់) នៃបណ្តាជនសម័យដើមទាំងនេះ មាននៅឡើយរហូតសព្វថ្ងៃក្នុងអូស្ត្រាលី, ម៉ាឡេស៊ី (កន្ទ្រាញភ្នំ), កោះស៊ូម៉ាត្រា និងកោះស្រីលង្កា (កន្ទ្រាញ)។ បណ្តាជនយុគថ្មកណ្តាលនេះរស់នៅដោយត្រេចចររហូត ហើយចាប់ធ្វើឲ្យតែបានៗ ពីឆ្អឹង ពីថ្ម និងពីឈើ នូវឧបករណ៍ប្រើប្រាស់។ បណ្តាជនដែលមកដល់ជាលើកទី២ ក្នុងយុគថ្មកណ្តាល នៅក្នុងជំពូក "ណេគ្រីតូ"៖ មនុស្សខ្លួនទាប (ក្នុងក្រុម "ពិចមេ" pygmée), ស្បែកក្រម៉ៅ, សក់ក្រញាញ់, រោមខ្លួនពុំសូវមាន ឬគ្មានតែម្តង។ បណ្តាជនទាំងនេះ នៅមានយ៉ាងបរិសុទ្ធនៅឡើយ ក្នុងម៉ាឡេស៊ី, អូស្ត្រាលី និងហ្វីលីពីន។ បណ្តាជនដែលមកដល់ ជាលើកទីបង្ហើយក្នុងយុគដដែល នៅក្នុងជំពូក "មេឡាណេសូអ៊ីដ" (mélanésoïde, ដូចមនុស្សនៅម៉េឡាណេស៊ី) (សម័យខាងក្រោយនេះ គេច្រើនតែឲ្យឈ្មោះថា "សម័យហ្វាប៊ិញ" ដោយហេតុថា គេបានរកឃើញនៅ ហ្វាប៊ិញ, វៀតណាមខាងជើង, នូវឆ្អឹងក្បាលដែលដូចរបស់មនុស្សនៅម៉េឡាណេស៊ី)។ ដំណាងយ៉ាងបរិសុទ្ធនៃបណ្តាជនលើកក្រោយនេះ បានបាត់អស់ពីអាស៊ីភាគអគ្នេយ៍ទៅហើយ, ប៉ុន្តែនៅសល់ច្រើននៅឡើយ ក្នុងកោះ

*ម៉ាឡាណេស៊ី និងនៅអូស្ត្រាលី។ ពួកនេះបរិភោគមនុស្ស, នៅតែប្រើឧបករណ៍ធ្វើពីថ្ម ប៉ុន្តែចេះធ្វើថូអំពីអិដ្ឋ ហើយប្រើប្រាស់ទុកដើម្បីនេសាទ។*

*ទាល់តែមកដល់យុគថ្មថ្មី ទើបមនុស្សសាសន៍ ឥណ្ឌូណេស៊ីយែន ចុះពីទិសខាងជើង ហើយ ចូលមករស់នៅបន្តបន្ទាប់គ្នារហូតពេញ អាស៊ីភាគអគ្នេយ៍។ ឧបករណ៍ “ច្ងាត” ជាងមុនបានត្រូវគេឃើញមានឡើង។ បណ្តាជនទាំងនេះ សង់ផ្ទះ, ធ្វើទូក ហើយនាំចូលមកឥណ្ឌូចិននូវការដាំស្រូវ។ ជឿជាវត្ថុផ្សេងៗ មានព្រលឹងនៅខាងក្នុង, ពួកនេះគោរពអារក្ស អ្នកតា រូបបដិមាករជាច្រើន ហើយគោរពបូជាដល់ដូនតា បុព្វការី។ ប៉ុន្តែគេពុំដឹងថា មានការតទល់គ្នារវាងពួកសាសន៍ ឥណ្ឌូណេស៊ីយែន និងពួកបណ្តាជនដើម —ដូច្នេះ គ្មានការលាយបង្កាត់គ្នា— ឬមួយផ្ទុយទៅវិញ មានការបង្កាត់លាយគ្នារវាងសហាគមន៍ទាំងពីរ*[១១]*។ យុគសំរិទ្ធ* (âge de Bronzes) *មានឡើងរវាងឆ្នាំ ៣០០ មុន គ.ស. ។ កន្លែងទីមួយដែលមានឧស្សាហកម្មធ្វើសំរិទ្ធ បានត្រូវគេរកឃើញនៅដុងសឺង, ប្រទេសវៀតណាម។ សម័យនោះ ជាសម័យងងឹតស្លុងនៃប្រវត្តិសាស្ត្រខ្មែរ —យើងថា «នៃបុព្វប្រវត្តិសាស្ត្រខ្មែរ» ទៅចុះ— ដែលឥតមាននរណាដឹងរឿងហេតុអ្វីឡើយ ហើយដែលយើងសង្ឃឹមថា នឹងបានត្រូវបំភ្លឺក្នុងថ្ងៃណាមួយ។*

*ជនជាតិចិននិងជនជាតិឥណ្ឌា ទើបនឹងចូលមកដល់ដោយជាក់លាក់ក្នុងឥណ្ឌូចិន នៅដើមគ្រិស្តសករាជ។ ពួកឥណ្ឌា, ដោយនាំមកនូវអរិយធម៌ខ្លួន (សាសនា, អក្សរ, ការយល់ឃើញនយោបាយ ។ល។), បានបញ្ចូលប្រជាជាតិខ្មែរទៅក្នុងប្រវត្តិសាស្ត្រ។ ខ្មែរយើងចូលមកលើឆាកប្រវត្តិសាស្ត្រ ជាប្រជាជនចំណុះអាណាចក្រ ហ្វូ-ណន (នគរភ្នំ ក្នុងភាសាចិន) ដែលជាអាណាចក្រទីមួយនៅអាស៊ីអគ្នេយ៍ ហើយដែលស្តេចលើកដំបូង, តាមគេស្មាន, សុទ្ធតែជាជនជាតិឥណ្ឌា។ គឺរវាង គ.ស. ៥៤៥ ដែលនគរចិន-ឡា, ឈ្មោះចិននៃនគរពួកកម្ពុជា*[១២]*, ផ្តាច់ខ្លួនចេញពីអាណាចក្រហ្វូ-ណន ហើយច្បាំងដណ្តើមរហូតដល់ស្រូបបានអាណាចក្រទាំងមូល (ចិន-ឡា នេះលាតសន្ធឹងតាមដងទន្លេមេគង្គ ចាប់ពីក្រចេះនៅទិសខាងត្បូង ទៅដល់ ប៉ាក់សេ (លាវ) នៅទិសខាងជើង ហើយវាតទៅទិសខាងលិច លើភាគច្រើននៃដងទន្លេសេមូ៉ន ក្នុងប្រទេសថៃសព្វថ្ងៃ*[*]*។ តើចំបាំងនេះជាការដណ្តើមរាជ្យគ្នារវាងស្តេចនៃអាណាចក្រ ដូចដែលអ្នកប្រវត្តិសាស្ត្របានអះអាង, ឬមួយជាការបះបោរនៃជាតិសាសន៍មួយដែលគេជិះជាន់ ទល់នឹងអ្នកត្រួតត្រាខ្លួន? ចំណុចនេះត្រូវតែគេរកបំភ្លឺឲ្យច្បាស់។ ប៉ុន្តែ យើងអាចកត់សំគាល់ការរ៉ាយរ៉ាប់របស់ចិនម្នាក់ឈ្មោះ កាំង-តៃ, សមាជិកនៃគណៈបេសកកម្មចិនមួយដែលបានស្ថិតនៅក្នុង ហ្វូ-ណន (គ.ស. ២៤៥ – គ.ស. ២៥០), ដែលបានថែងដូចតទៅ អំពីជីវភាពនៅក្នុងប្រទេស (កុំច្រឡំ កាំង-តៃ ជាមួយ ចេវ តា ក្វាន់ ដែលបានមកដល់ក្នុងសម័យអង្គរ នៅ គ.ស. ១២៩៦)៖ «រាជធានីមានវិមានដ៏ធំធេងតធាយនៅព័ទ្ធជុំវិញ។ ព្រះរាជានិងនាម៉ឺនសព្វមុខមន្ត្រី រស់នៅក្នុងភាពថ្កុំថ្កើងរុងរឿង ហើយធ្វើដំណើរផ្សេងៗដោយប្រើដំរីជាយាន។ ប៉ុន្តែរាស្ត្រប្រជានៅខ្លួនទទេ, រូបអាក្រក់, ខ្មៅ ហើយសក់ក្រញាញ់។ ប្រជារាស្ត្ររស់នៅក្នុងផ្ទះធ្វើពីឫស្សី សង់លើបង្គោលសសរ...។»*

*ជាយោបល់បញ្ចប់, ប្រហែលជាមានការប្រវេសន៍នៃបណ្តាជននៅកម្ពុជាក្នុងយុគថ្ម ឆ្ពោះទៅកាន់កោះម៉ាឡាណេស៊ី, គាស្មានី និងអូស្ត្រាលី*[១៣]*។ ទ្រឹស្តីជាច្រើនគាំទ្រថា ការប្រវេសន៍នេះអាចធ្វើទៅបាន ក្នុងសម័យត្រជាក់ដ៏យូរលង់អន្លែងនៃជីវិតទី៤ នៃធរណី, សម័យដែលកោះទាំងអស់ ដូចជាជាប់នឹងទ្វីបដែរ ដោយសារការរីងទឹកសមុទ្រ (ស្រកចុះពី ២០០ ទៅ ៣០០ ម៉ែត្រ)*[១៤]* មួយចំណែកទៀត ជនជាតិខ្មែរសព្វថ្ងៃអាចជាលទ្ធផលនៃការលាយបង្កាត់រវាងសាសន៍ពីរ៖ មួយសាសន៍ជំនាន់ដើមនៅក្នុងស្រុក (ណេគ្រីតូ— មេឡាណេស៊ីយាង), មួយទៀត សាសន៍ ឥណ្ឌូណេស៊ីយែន*[១៥]* *។*

---

*(*) មើលផែនទី ទំព័រ ១៤៧ និង ១៥៧*

# អធិប្បាយ

(១)- អ្នកវិទ្យាសាស្ត្រធម្មជាតិបារាំងឈ្មោះ មូអូ បានប្រទះឃើញប្រាសាទអង្គរនៅឆ្នាំ ១៨៥៩។ អង្គរវត្ត, កសាងដោយព្រះបាទសូរិយាវរ្ម័នទី២ (១១១៣-១១៥០), បានត្រូវខ្មែរយើងបោះបង់ចោល តាំងពីឆ្នាំ ១៤៣២ (ស្ដេចពញាយ៉ាត)។

(២)- សាលាបារាំងនៅចុងបូព៌ាប្រទេស (Ecole Française d'Extrême-Orient) បានត្រូវបង្កើតដោយ ប៉ូល ឌូមែរ ក្នុងឆ្នាំ ១៨៩៨ នៅហាណូយ។ កូនសំអប់នៃអាណានិគមកម្មបារាំង, កម្ពុជាបានទទួលតិចណាស់ ពីការបរិច្ចាគនៃបារាំង ចំពោះវឌ្ឍនភាពវប្បធម៌នៃឥណ្ឌូចិន។

(៣) អ្នកតពូជនៃ "ខ្មែរយុគថ្ម" ទាំងអស់នេះ រស់នៅជាអាណិកជន ហើយនឹងផុតតំណនៅក្នុងអនាគត។

(៤) ម៉េឡាណេស៊ី (Mélanésie, កោះមនុស្សខ្មៅ): កោះមួយក្រុមនៅមហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូង ហើយដែលមានជាអាទិ៍: នូវែល ហ្គីណេ, សាឡូម៉ុង (ក្បាដាល់កាណាល់) នូវែល កាឡេដូនី ។ល។

(៥) គុណនាម "ឥណ្ឌូណេស៊ីយែន" នេះ បានត្រូវប្រើដោយអ្នកមនុស្សសាស្ត្រ ដោយមកពីលក្ខណៈដូចគ្នាជាមួយពួក ដាយ៉ាក់ នៅកោះ ប៊ រណេអូ និងពួក បាត់តាក់ និង អាត្យេះ នៅ ស៊ូម៉ាត្រា។

(៦) ពាក្យ "អាស៊ីភាគអគ្នេយ៍" នេះ មានដើមកំណើតជាអង់គ្លេស (អានទំព័រ ៣៩)។ ប្រទេសនៃអាស៊ីអគ្នេយ៍មាន : ភូមា ថៃ លាវ កម្ពុជា វៀតណាមទាំង២ សហព័ន្ធម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន។ អាស៊ីភាគអគ្នេយ៍ដែលធ្វើឲ្យកិតក័យ, ឲ្យស្រឡាញ់, ឲ្យអាណិត។ គឺជាផែនដីនៃភាពផ្សេងគ្នាផង នៃឯកភាពផង។ ផ្សេងគ្នាដោយជាតិ ដោយរបបនយោបាយ ដោយភាសា និងដោយសាសនា។ ឯកភាពដោយមកអំពីសាសនាស្បែកលឿងរបស់ខ្លួន ចំណីអាហាររបស់ខ្លួន ទីលំនៅរបស់ខ្លួន។

(៧) គេឃើញលក្ខណៈ "ណេគ្រីតូ" នេះ នៅរស់ច្រើនឬតិចក្នុងប្រជាកសិករយើង។ បណ្ដាជននៅតាមក្រុងនៅក្នុងជំពូកមួយផ្សេងទៀត ដែលដូចជាកាត់ទៅវិញ ភាគច្រើនគឺជំពូកខ្មែរកាត់ចិន។ ដូច្នេះមែន ជនជាតិចិនបានចាកចេញពីស្រុកកំណើតខ្លួន មករស់នៅក្នុងប្រទេសដទៃនៅទិសខាងត្បូង ដោយមកអំពីសង្គ្រាមដ៏ច្រើន ការមានប្រជាជនច្រើនហួសប្រមាណ និងការរហេមរហាម។ ចេញពីជំពូកកាត់នេះ គឺវណ្ណៈអ្នកក្រុងនៃសង្គមខ្មែរ។ ប្រជាកសិករខ្មែររស់នៅក្នុងអត្តសេដ្ឋកិច្ច (autarcie) មួយដ៏ពេញលេញហើយ, បើប្រៀបផ្ទឹមទៅសង្គមអ្នកក្រុងនិងអ្នកមាន, សង្គមកសិករ គឺជាសង្គមមួយដទៃ។ ចំពោះការបែកជាពីរនេះ តើគេត្រូវដាក់កំហុសលើការព្រងើយកន្តើយនៃរដ្ឋាភិបាលទាំងឡាយ ឬលើ "ការប្រកាន់ពិណសម្បុរ" នៃពួកអ្នកក្រុង? ការណ៍មួយដែលពិតគឺ ចាប់តាំងពីអាណាចក្រខ្មែរចុះអោនថយមក ប្រជាជនខ្មែរសុទ្ធ ដើរតួបំពេញធាកទេ ក្នុងនាដកសាលនយោបាយនិងសង្គម។

ថ្វីត្បិតតែបណ្ដាជនខ្មែរ (៧លាននាក់នៅឆ្នាំ១៩៧០) មានលក្ខណៈមូលតែមួយដែរ(*) ក្នុងភាពទូទៅ, ប្រទេសខ្មែរជាទីរស់នៅនៃក្រុមអាណិកជនក្នុងស្រុក (ខ្មែរលើ ៥០ ០០០ នាក់) និងនៃអាណិកជនអន្តោប្រវេសន៍បីក្រុម: ចិន (៤៥០ ០០០ នាក់), យួន (២២០ ០០០ នាក់, ២០០ ០០០ នាក់ បានត្រឡប់ទៅវៀតណាមវិញ ក្រោយខែមីនា ១៩៧០), ចាម (៨០ ០០០ នាក់)។

(* – មិនដូចប្រជាជនលាវ ឬ ប្រជាជនសឹង្ហបុរី ជាដើម។)

(៨) ក្នុងវាក្យស័ព្ទមនុស្សសាស្ត្រ, "អូមីនាំង" (hominiens) ជាក្រុមមនុស្សនិងបុព្វការីខ្លួន ក្នុងសណ្ដានសត្វបំបៅកូនជឿនលឿនជាងគេ។ សត្វដែលជាបុព្វការីចំនៃមនុស្ស ច្រើនតែគេឲ្យឈ្មោះថា "អូម៉ូសា

ព្យាង" (homosapiens, មនុស្សសព្វថ្ងៃ)។ អូមីទ្រានទី១ បានកើតឡើង កាលពី ៣ លានឆ្នាំមុន។ ចំណែកឯធរណី មានជីវិត ៤ ៥០០ លានឆ្នាំមកហើយ។

(៩) ទីស្រាវជ្រាវនៅកោះជ្វា បានត្រូវគេសិក្សាជ្រៅជ្រះណាស់ ពីព្រោះការរកឃើញមនុស្ស-ស្វា ដែលជាសត្វកើតមុន "អូម៉ូសាព្យាង"។ ចំណែកឯការស្រាវជ្រាវខាងមនុស្សសាស្ត្រ និងខាងបុរាណវិទ្យានៅឥណ្ឌូចិន បានត្រូវគេបញ្ឈប់សិនព្រោះសង្គ្រាម។

(១០) ពាក្យ "អូស្ត្រាឡូអ៊ីដ-វេឌោអ៊ីដ" បានត្រូវប្រើ ដោយមកពីពួកខ្មៅក្នុងស្រុកនៅអូស្ត្រាលី មានលក្ខណៈកាយដូចពួកវេឌៈ នៅកោះស្រីលង្កា។

(១១) តាមទ្រឹស្តីខ្លះ ជាតិខ្មែរអាចឲ្យគេសំគាល់ជាសាសន៍ឥណ្ឌូណេស៊ីយែន ដែលត្រូវគ្របដណ្តប់ដោយពួកមន-ខ្មែរ ។ ពួក មន-ខ្មែរ បានចាកចេញពីភ្នំ ហ៊ីម៉ាឡាយ៉ាខាងត្បូង ឆ្ពោះមកទិសឯកើត ហើយទុកចោលតាមផ្លូវនូវក្រុមជាច្រើន ដែលអ្នកតពូជនៅមានរហូតសព្វថ្ងៃ; ពួកខះស៊ី នៅស្រុកអស្សាំ (ចន្លោះបឹង្គលាទេស និង ភូមា), ពួកប៉ាឡុង និងពួកវ៉ា នៅប្រទេសភូមាខាងជើង, ពួកល្វ៉ា និងពួកវ៉ា នៅប្រទេសចិនខាងនិរតី និងនៅប្រទេសថៃខាងជើង, ពួកមននៅប្រទេសភូមាខាងត្បូង និងនៅប្រទេសថៃកណ្តាល, និងពួកខានៅប្រទេសលាវ។ ម្យ៉ាងទៀត ភាសាខ្មែរបានត្រូវរាប់បញ្ចូលក្នុងអំបូរភាសាមន-ខ្មែរ រួចមកហើយ។

ទ្រឹស្តី មន-ខ្មែរ ខាងលើនេះ បានត្រូវជំទាស់ដោយមនុស្សសាស្ត្រទំនើប ហោចណាស់ក៏ខាងមតិជីវសាស្ត្រដែរ។ បច្ចេកទេសមួយឈ្មោះ វិជ្ជារកជំពូកឈាម (hémotypologie) សិក្សាកត្តាឈាមទាំង ឡាយដែលខុសគ្នាតាមធាតុដែលផ្សំខ្លួនឡើង ពីជនម្នាក់ទៅជនម្នាក់ទៀត ពីប្រជាជនមួយទៅប្រជាជន មួយពីសាសន៍មួយទៅសាសន៍មួយ (មើលក្នុងទស្សនាវដ្តី "វិទ្យាសាស្ត្រ និងជីវិត (Science et Vie) " លេខ ៦៨៥ ខែតុលា ៧៤)។




ការសិក្សាបានបង្ហាញថា កម្ពុជានៅក្នុងផ្ទៃមនុស្សសាស្ត្រមួយយ៉ាងពិសេស។ ដូច្នេះមែន ស្ទើរតែមានតែខ្មែរទេ ដែលមានយ៉ាងច្រើនហូរហៀរនូវលក្ខឈាម (hémoglobine) ម្យ៉ាងដែលប្រែប្រួល (mutante) ហើយដែលនៅក្នុងជំពូក "អឺ"។ ដោយសារការសិក្សាលើកត្តាឈាម នៃបណ្តាជននៅអាស៊ី

ភាគអគ្នេយ៍ អ្នកស្រាវជ្រាវបានគូសឡើងវិញនូវព្រំដែន (មួយភាគ) នៃអាណាចក្រខ្មែរពីដើម។ គេពុំត្រូវឆ្ងល់ឡើយ ពីការណ៍ដែលកំរិតលក្ខ័ឈាម "អឺ" នៅកម្ពុជាក្រោមមាន ៣% ក្នុងពេលដែលនៅកម្ពុជា គឺ ២៨%។ ព្រោះថាបណ្ដាជន នៅកម្ពុជាក្រោមគឺ ... យួនខាងត្បូង។

(១២) "ពួកកម្ពុជា" ឬ ពួកកូនឥសីកម្ពុ : ស្ដេចប្រទេសចិនឡា តាំងខ្លួនជាអ្នកតវង្សឥសី កម្ពុ-ព្រះនាងមេរា។ ឈ្មោះវង្សស្ដេចនេះបានក្លាយទៅជាឈ្មោះប្រជាជន រួចមកទៅជាឈ្មោះប្រទេស។ រីឯព្រាហ្មណ៍កោណ្ឌញ្ញ និងព្រះនាងសោមា, ស្ដេចទីមួយនៃហ្វូណន, បានចូលក្នុងរឿងព្រេងជាព្រះថោងនាងនាគនៃនគរគោកធ្លក។

(១៣) ការប្រវេសន៍នៃ "ខ្មែរយុគថ្ម" :



(១៤) ក្នុងលក្ខណៈវិទ្យាសាស្ត្រធរណី កម្ពុជាជាដែនដីទើបនិងដុះថ្មី។ បឹងទន្លេសាបកាលពីដើមជាឈូងសមុទ្រមួយ។ បឹងមួយដែលមានត្រីច្រើនជាងបឹងឯទៀតទាំងអស់ក្នុងពិភពលោក, ទន្លេសាបបានចិញ្ចឹមបណ្ដាជនខ្មែរទាំងមូល ហើយថែមទាំងដឹកត្រីចេញទៅក្រៅទៀតផង។ វត្ថុជាទីចង់បាននៃអ្នកជិតខាង, គេនៅតែពុំដឹងថាបឹងទន្លេសាបនៅតែចិញ្ចឹមបណ្ដាជនខ្មែរដូចកាលមុន ឬមួយទៅជាយ៉ាងដូចម្ដេចឡើយ។

(១៥) អ្នកតពូជយ៉ាងបរិសុទ្ធនៃសាសន៍ឥណ្ឌូណេស៊ីយែន នៅកម្ពុជា លាវ និងយួន នៅមានរហូតសព្វថ្ងៃ ហើយរស់នៅជាក្រុមអាណិកជន។ កន្ទ្រាញទាំងនេះទំរក្សាជីវិតខ្លួនតទៅទៀត នៅតាមភូមិភាគដែល "ចាញ់" ជាងគេទាំងអស់នៃទ្វីប។ នៅកម្ពុជាមានពូជស្មៀង គួយ ក្នុង។ នៅលាវ ពួកខា។ នៅវៀតណាម ពួកយ៉ារ៉ាយ រ៉ាដេ។ កន្ទ្រាញទាំងអស់នេះ រស់នៅក្នុងតំបន់ "ព្រៃដែនបី" (តំបន់ទួលខ្ពស់) ហើយមានចំនួន ៥០ ០០០ នាក់ ក្នុងកម្ពុជា និង ៧០០ ០០០ នាក់ ក្នុងវៀត-ណាម (តាមទស្សនាវដ្ដី "ភូមិសាស្ត្រជាតិ" (National Geographic) ខែមករា ១៩៦៥)។ ប៉ុន្តែត្បិតតែគេដាក់ចោលក្នុងផ្ទៃទី២នៃជីវិតសង្គម អាណិកជនទាំងនេះបានត្រូវគេប្រើប្រាស់ក្នុងសង្គ្រាមទាំងឡាយនៃឥណ្ឌូចិន : ដំបូងដោយពួកបារាំង ក្រោយមកពួកអាមេរិកាំង (កន្ទឹបបៃតង), ដោយយួនខាងជើង និងដោយខ្មែរយើង (រណសិរ្សរួមតយុទ្ធនៃជាតិសាសន៍គេជិះជាន់, "ហ៊្វុលរ៉ូ")។ វាសនានៃសាសន៍ឥណ្ឌូណេស៊ីយែនទាំងនេះ មិនដឹងជាយ៉ាងណាដែរក្នុងអនាគត។

#####################

# ភាគទី ២

## ពី

# ការប៉ះលើកដំបូង
# នឹងបស្ចិមប្រទេស
## ទៅ
# អាណានិគម

*កូនអើយកេរ្តិ៍មេបា ចូររក្សាតែកេរ្តិ៍ល្អ ។*

*រហូតមកដល់ដំណាច់សតវត្សរ៍ទី១២, ការដឹងស្គាល់នៃបស្ចឹមប្រទេសលើទ្វីបអាស៊ី នៅត្រឹមតែការស្គាល់ប្រទេសចិន តាមការនិទានរ៉ាយរ៉ាប់នៃអ្នកដើរទេស ដែលបានទៅដល់ទីនោះដោយកាត់តាមអាស៊ីកណ្ដាល។ បន្ទាប់ពីការពង្រីកអំណាចយ៉ាងមហិមានៃពួកម៉ុងហ្គោល នៅសតវត្សរ៍ទី១៣ មក —ការពង្រីកដែលមាន ហ្សេង ហ្ស៊ិះ ខាន់ និងបន្ទាប់មក ចៅរបស់ខ្លួន, យូប៊ីឡៃខាន់ ជាអ្នកដឹកនាំ[១] ហើយដែលបានសាបព្រោះមហន្តរាយពាសពេញទ្វីប ចន្លោះអឺរ៉ុប-អាស៊ី រហូតដល់ដីវាលប្រទេសហុងគ្រី— ប្រទេសចិនបានទៅជាទីទាក់ទាញមួយចំពោះបស្ចឹមប្រទេស។*

*ដំណើរស្វែងរកពិនិត្យជាច្រើនបានត្រូវធ្វើឡើង ដូចដំណើរពីរដងដំរន្ទឺនៃ ម៉ារកូ ប៉ូឡូ នៅស្រុកចិនជាដើម[២]។ វាងដំណាច់សតវត្សរ៍ទី១៣, បន្ទាប់ពីការរកឃើញផ្លូវសមុទ្រមួយមកបូព៌ាប្រទេស, ពួកព័រទុយហ្គេសម្គោជយុគមែនទែននៃដំណើរស្វែងរកពិនិត្យ។ វ៉ាស្កូ ដឺ ហ្គាម៉ា មកដល់ កាលីគុត (កាល់កត្តា) នៅឆ្នាំ ១៤៩៨។ អាល់ប៊ូកែក យកបានកំពង់ផែ ហ្គោ (ឥណ្ឌា) នៅឆ្នាំ ១៥១០ រួចហើយកំពង់ផែ ម៉ាឡាក់កា (ឥណ្ឌូណេស៊ី) នៅឆ្នាំ ១៥១១, ហើយមកដល់ កង់តុង នៅឆ្នាំ ១៥១៧។ កូឈ្មួយម្នាក់របស់ អាល់ប៊ូកែក, អង់តូនីញ៉ូ ដឺ ហ្វារីយ៉ា ចូលមកក្នុងឆកសមុទ្រ ទូរ៉ាន (វៀតណាមខាងត្បូង) ហើយកត់សំគាល់ទីភូមិ ហៃហ្វូ ដែលក្រោយមកបានទៅជាកំពង់ផែតែមួយនៃឥណ្ឌូចិន[៣] ដែលបើកចំហរទៅបរទេស។ ការនិទានរ៉ាយរ៉ាប់នៃអ្នកស្វែងរកលើកដំបូងទាំងនេះ ទាក់ទាញពួកឈ្មួញ និងអ្នកផ្សាយសាសនាគ្រិស្តឲ្យមកអាស៊ី។*

*នៅឆ្នាំ ១៥៥៥ អ្នកបួស "ដូមីនីកាំង" ជាតិព័រទុយហ្គេ ឈ្មោះ ហ្គាស្ប៉ា ដឺ គ្រុយហ្ស៍ មកដល់រាជវាំងនៃស្ដេចអង្គចាន់ទី១ ។ កាលនោះកម្ពុជាកំពុងតែអោនថយពេញទំហឹង ដោយហិនហោចនឹងការចូលវាយនៃពួកសៀម[៤]។ តាមដានជើងនៃ ហ្គាស្ប៉ា ដឺ គ្រុយហ្ស៍, អ្នកបួស "ដូមីនីកាំង" និង "ហ្វ្រង់ ស៊ីស្គាំង" ព័រទុយហ្គេ ឯទៀតមកដល់កម្ពុជា[៥]។ ជនជាតិព័រទុយហ្គេសមួយក្ដាប់ ក៏បានចូលរួមជាមួយស្ដេចខ្មែរ ក្នុងការតយុទ្ធទល់នឹងពួកសៀម[៦], ការជួយតយុទ្ធដែលនឹងចប់នៅឆ្នាំ ១៦២៣ ព្រោះថា ក្រុមព័រទុយហ្គេទាំងឡាយនៅអាស៊ី ក៏ចុះសាបសូន្យខ្លួនឯងដែរ។ ពី គ.ស. ១៦២៣ ដល់ ១៦៨២ គឺដល់វេនពួក ហូល្លង់ដេ ម្ដង ដែលខិតខំដាក់ហាងជំនួញមួយនៅស្រុកខ្មែរ ប៉ុន្តែមិនបានសំរេចឡើយ។ ក្នុងចន្លោះពេលនោះ, ពួកអ្នកបួស "យេស៊ូីត", បន្ទាប់ពីបរាជ័យនៃពួក "ដូមីនីកាំង" ក្នុងការផ្សាយសាសនានៅកម្ពុជា បានសង់ទីផ្សាយសាសនាមួយនៅកំពង់ផែ ហៃហ្វូ ក្នុងឆ្នាំ ១៦១៥ ហើយសំរេចសង់មួយទៀតក្នុងឆ្នាំ ១៦២៥ នៅស្រុកតុងកឹង[៧]។ ក្នុងគោលដៅនេះ ពួក "យេស៊ូីត" តាំងអ្នកបួសបារាំងម្នាក់, អាឡេចសង់ដ្រ៍ ដឺ រ៉ូដ, ជាមេគណៈបេសកកម្ម។ ដឺ រ៉ូដ ខិតខំបំបាក់ភាពផ្ដាច់មុខនៃកិច្ចត្រួតត្រា (ផ្លូវសង្ឃ) កាតូលិកនៅបូព៌ាប្រទេស ដែលកាលនោះនៅក្នុងដៃពួកព័រទុយហ្គេ។ ពេលត្រឡប់មកស្រុកបារាំងវិញ, គាត់រុញច្រានមហាសន្និបាតសង្ឃបារាំងឲ្យធ្វើកិច្ចបង្ខិតបង្ខំក្រុងរ៉ូម ដើម្បីតែងតាំងមេគណ (អេវែត) បារាំងនៅឥណ្ឌូចិន[៨]។ នៅឆ្នាំ ១៦៦៣, ដោយមាន កុលប៉ែរ និង ស្ដេចល្វីទី១៤ គាំទ្រផង អង្គការមួយឈ្មោះ "* Société des Missions Etrangères *" (សមាគមក្រុមបេញផ្សាយសាសនានៅបរទេស) បានត្រូវបង្កើតឡើង ហើយដែលមានភារៈរើសរកអ្នកផ្សាយសាសនាជាតិបារាំងដើម្បីឥណ្ឌូចិន។*

*នៅសតវត្សរ៍ទី១៨ ឈ្មួញបារាំងលើកដំបូងមកដល់ឥណ្ឌូចិន។ ការប៉ុនប៉ងទីមួយរបស់ពួកនេះ ដើម្បីរស់នៅក្នុងអណ្ណាម និងក្នុងតុងកឹងឥតមានជោគជ័យទេ ដោយហេតុថា ការទាត់ចោល, ការមិនទទួលពីសំណាក់ជនជាតិយួន បានមានឡើងយ៉ាងពេញទំហឹង។ មកដល់ឆ្នាំ ១៧៧៣ ក៏មានបងប្អូនបីនាក់ ដែលមានដើមកំណើតនៅ តៃសឺង នាំយួនបះបោរទល់នឹងស្ដេចខាងជើងនិងស្ដេចខាងត្បូង។ ពួកនេះដណ្ដើមយកបល្ល័ង្កបាន, ហើយស្ដេចអណ្ណាមឈ្មោះ ហ្វេ វឿង ដែលភៀសខ្លួនទៅកម្ពុជាក្រោម បានត្រូវគេសម្លាប់នៅឆ្នាំ ១៧៧៧។ ក្មួយ*

*ស្តេចឈ្មោះ ង្វៀង អាន់, អ្នកបន្តរាជ្យ, កែនទ័ពដើម្បីច្បាំងបងប្អូន "តៃសឺង"។ ឆ្លៀតឱកាសពីការតយុទ្ធខាងក្នុងនេះ, មេគណនៅកម្ពុជាក្រោម, ពីញ៉ូដឺបេអែន, រុញម្ចាស់ ង្វៀង អាន់ ដែលខ្លួនបានធ្វើជាមិត្តយ៉ាងស្និទ្ធ ឲ្យសុំជំនួយបារាំង។ បន្ទាប់ពីបានច្បាំងធ្លាក់ ៥ ឆ្នាំដោយឥតជោគជ័យមក ង្វៀង អាន់ ព្រមតាមយោបល់មេគណ[៩]។ ដឺបេអែន, ដោយមានកូនច្បង ង្វៀង អាន់ អាយុ ៥ ឆ្នាំ មកជាមួយផង, ក៏ចុះសំពៅមកដល់ឡូរីយ៉ង់ (ស្រុកបារាំង) នៅឆ្នាំ ១៧៨៧។ នៅពេលនោះ បារាំងកំពុងតែបោះបង់ចោលអាណានិគមរបស់ខ្លួននៅអាមេរិក, កាណាដា ដែលពុំសូវជាទីពេញចិត្តនៃស្តេចល្វីទី១៦។ ម៉ុងម៉ូរ៉ាំង, រដ្ឋមន្ត្រីការបរទេស, ដែលឃើញថាឱកាសដើម្បីសងបំពេញការបង់ខាតនៅប្រទេសឥណ្ឌាមកដល់ហើយ, ក៏ចុះសន្ធិសញ្ញាសម្ពន្ធភាពទី១ ជាមួយអណ្ណាម នៅ វែរសៃ ក្នុងថ្ងៃ ២៨ វិច្ឆិកា ១៧៨៧[១០]។ ជំនួយសឹកមួយបានផ្តល់ឲ្យ ង្វៀង អាន់។ តបទៅវិញម្ចាស់យួននេះត្រូវឲ្យកោះត្រឡាច (ពូឡូកុងឌរ) និងកំពង់ផែ ទូរ៉ាន ទៅប្រទេសបារាំង ដែលត្រូវមានកម្មសិទ្ធផ្តាច់មុខខាងជំនួញទៀត។ ប៉ុន្តែពេលមេគណកាតូលិកត្រឡប់មកដល់កម្ពុជាក្រោមវិញ, ង្វៀង អាន់ យកបានព្រៃនគររួចទៅហើយ ព្រមទាំងដែនដីទិសខាងត្បូងទាំងអស់។ នៅឆ្នាំ ១៨០២, ង្វៀង អាន់ វាយឈ្នះ "តៃសឺង" ក្រោយបង្អស់នៅហាណូយ ហើយប្រកាសខ្លួនជាអធិរាជក្រោមឈ្មោះថា យ៉ាឡុង[១១]។*

*ចំណោទផ្សេងៗ នៃការបដិវត្តន៍ (១៧៨៩) បានធ្វើឲ្យបារាំងខ្វល់ខ្វាយ។ ការទាក់ទងជាមួយប្រទេសយួន ក៏បានត្រូវគេពុំសូវយកចិត្តទុកដាក់លើមួយរយៈទៅ។ ជនជាតិបារាំងមួយក្រុម, ភាគច្រើនជាអ្នកផ្សាយសាសនា, បានរស់នៅដោយសន្តិភាពដោយសារការគាំពារនៃយ៉ាឡុង។ អ្នកតរាជ្យនៃស្តេចនេះ, មិញម៉ាង រួចមក ទីឌឹក ចាប់ប្រទូស្តរ៉ាយនឹងបារាំងឡើងវិញ។ ការព្យាបាទធ្វើទុក្ខបុកម្នេញលើពួកអ្នកផ្សាយសាសនា ក៏កើតឡើងម្តងទៀត។ យកលេសថាដាក់ទណ្ឌកម្មលើអធិរាជយួន ទីឌឹក អំពីការសម្លាប់រង្គាលអ្នកផ្សាយសាសនាគ្រិស្ត, ណាប៉ូឡេអុងទី ៣ បញ្ជាឲ្យលើកទ័ពបារាំងមួយកងមកវាយយួន[១២]។ ថ្ងៃ ៣១ សីហា ១៨៥៨, សំពៅមួយកងដែលដឹកនាំបេសកៈយោធពលបារាំង-អេស្ប៉ាញ៉ុល ៣០០០ នាក់ ក្រោមបញ្ជានៃឧត្តមនាវីរីហ្គោ ដឺហ្សែនូយី, បោះយុថ្កានៅឆកសមុទ្រ ទូរ៉ាន។ ពី ទូរ៉ាន មេទ័ពបារាំងគិតគូរវាយរាជធានី ហ្វេ។ ប៉ុន្តែសំពៅបាញ់កាំភ្លើងធំរបស់ខ្លួន ពុំអាចចូលតាមស្ទឹងហ្វេបានឡើយ។ ក្រោយពីកងសំពៅបារាំងបាននៅនឹងថ្កល់យ៉ាងយូរ, ដឺហ្សែនូយីសំរេចប្តូរទីដៅ ៖ ឬមួយតុងកឹង ឬមួយកម្ពុជាក្រោម។ ខ្យល់រដូវរំងានាំសំពៅមកកម្ពុជាក្រោមដាច់ជាង។ កងសំពៅក៏ចុះមកខាងត្បូង ហើយឡើងតាមស្ទឹងព្រៃនគរ, ក្រុងដែលបានត្រូវវាយសំរុកនៅថ្ងៃ ១៧ កុម្ភៈ ១៨៥៩។ បារាំងបានស្នើសុំប្តូរកុងស៊ុលគ្នាជាមួយយួន ប៉ុន្តែ ចំពោះមុខចំនួនស្តួចស្តើងនៃទ័ពបារាំង, ទី ឌឹក ទាត់ចោលសំណើនេះ។ យ៉ាងណាមិញ កងទាហានបារាំងនិងអេស្ប៉ាញ៉ុល ដែលផ្តុំគ្នាក្នុងបន្ទាយមួយ ទប់ទល់បាននឹងការវាយបញ្ចេញទាំងប៉ុន្មានរបស់ទ័ពយួន។ នៅខែកុម្ភៈ ១៨៦០ នាវាចំបាំងបារាំង ៧០ គ្រឿង ចុះពីស្រុកចិនមក, ហើយមិនត្រឹមតែវាយបំបែកបាននូវការឡោមព័ទ្ធទេ ថែមទាំងកាន់កាប់ខេត្តបីនៅខាងជើងព្រៃនគរទៀត។ ថ្ងៃ ៥ កក្កដា ១៨៦២ ទី ឌឹក, ដោយរវល់នឹងការបះបោរនៅតុងកឹង, ចុះសន្ធិសញ្ញាមួយជាមួយឧត្តមនាវី បោណ្ណា ដែលនៅក្នុងនោះ អធិរាជយួនអនុញ្ញាតសេរីភាពកាន់សាសនាកាតូលិក ហើយឲ្យខេត្តបី (បៀងហ្វា, យ៉ាឌិញ និងវិញឡុង) និងកោះត្រឡាចទៅបារាំង[១៣]។*

*យក កូសាំងស៊ីន (កម្ពុជាក្រោម, អានលេខយោង២ ចំពោះដើមកំណើតនៃឈ្មោះនេះ) បានមិនទាន់អស់ពាក់កណ្តាលផង បារាំងបោលភ្នែកមកកម្ពុជា ដែលបានអស់ដីមួយជុំទៅហើយ។ ខែកញ្ញា ១៨៦២ ឧត្តមនាវី បោណ្ណា មកធ្វើទស្សនកិច្ចដល់ព្រះបាទនរោត្តមនៅឧដុង្គ ដែលកាលនោះជារាជធានី, ទស្សនកិច្ចដែលជាការស្ទាបស្ទង់មើល ក្រែងអាចទាញកម្ពុជាដាក់ក្រោមការគាំពារបារាំងបាន។ ដូច្នោះមែនក្នុងសម័យនោះ បារាំងរកផ្លូវមួយចូលមកក្នុងប្រទេសចិនខាងត្បូងដើម្បីធ្វើជំនួញ។ បើត្រួតត្រាកម្ពុជាបាន, បារាំងមិនគ្រាន់តែត្រួតត្រា*

*បាននូវទន្លេមេគង្គទេ ដែលអាចជាផ្លូវមួយចូលទៅដល់ប្រទេសចិនខាងត្បូង[១៤] គឺថែមទាំងភូមិភាគបង្អាទុកខាងមុខមួយទៀតសំរាប់ពេលណាមានការយាយីពីស្រុកសៀម ដែលបានត្រូវពួកអង់គ្លេសគាំទ្ររួចទៅហើយ។*

*ថ្ងៃ ១០ សីហា ១៨៦៣ ឧត្តមនាវី ដឺឡាក្រង់ឌ្យែរ, "គូវែន័រ" (ចៅហ្វាយ) ទី១ នៃកូសាំងស៊ីន ដែលមេគណកាតូលិក, មីស, មកជាមួយផង បានមកដល់ក្រុងឧដុង្គ ហើយ "ឲ្យ" ព្រះបាទនរោត្តម ចុះហត្ថលេខាលើសន្ធិសញ្ញាទទួលការគាំពារ (ប្រូតិកតូរ៉ា) ពីបារាំង[១៥], សន្ធិសញ្ញាដែលនឹងទទួលហត្ថលេខានៃ ណាប៉ូឡេអុងទី៣ នៅពេលខាងក្រោយ។ ការណ៍នេះ បានត្រូវធ្វើឡើងដោយសម្ងាត់ ហើយក្នុងពេលដែលពញារាជា — នាម៉ឺនសៀមដែលក្រុងទេព (បាងកក) ចាត់ឲ្យឃ្លាំមើលស្តេចខ្មែរ— មិននៅ។ ថ្ងៃ ៤ វិច្ឆិកា ១៨៦៤ សាស្ស៊ឺលូឡូបា, រដ្ឋមន្ត្រីក្រសួងនាវាចរ ដាក់សេចក្តីរាយការណ៍មួយទៅណាប៉ូឡេអុងទី៣, ដែលនៅក្នុងនោះ រដ្ឋមន្ត្រីបង្ហាញការចាំបាច់ត្រូវរក្សាទុកឥណ្ឌូចិន។ នៅឆ្នាំ ១៨៦៧ ដឺឡាក្រង់ឌ្យែរ យកខេត្តបីទៀតនៅ កូសាំងស៊ីន ៖ វិញឡុង, សុកត្រាង (ឃ្លាំង) និងចូដុក (មាត់ជ្រូក)។ គឺក្នុងពេលដែលខ្លួនធ្វើអន្តរាគមន៍សុំឲ្យអធិរាជយួនដោះលែងអ្នករត់ពន្ធអាវុធបារាំងម្នាក់ឈ្មោះ ហ្សង់ ឌុយពុយ្វី ដែលពួកបារាំងចូលក្នុងការច្បាំងយកតុងកឹង។ ការវាយដំបូងបានត្រូវដឹកនាំដោយ ហ្វ្រង់ស៊ីស ហ្គារនេ្ទ នៅថ្ងៃទី ២០ វិច្ឆិកា ១៨៧៣។ ប្រទេសចិនក៏គំរាមថានឹងធ្វើអន្តរាគមន៍តាមផ្លូវសឹក។ នាយករដ្ឋមន្ត្រី ហ្ស៊ុល ហ្វែរី ឲ្យសភាបោះឆ្នោតបើកឥណទាន ដើម្បីបញ្ជូនបេសកៈយោធាមួយកង, ដែលនឹងវាយផ្ទួនគ្នាលើអណ្ណាមផង លើតុងកឹងផង។*

*ការវាយប្រទេសអណ្ណាមធ្វើទៅដោយឥតចំណោទឡើយ ដោយស្តេច ទី-ឌឹក បានស្លាប់ក្នុងខែកក្កដា ១៨៨៣។ រដ្ឋាភិបាលយួនមិនទប់ទល់ទេ ហើយចុះក្នុងថ្ងៃ ២៥ សីហា នូវសន្ធិសញ្ញាទទួលការគាំពារ(ប្រូតិកតូរ៉ា) បារាំង លើប្រទេសអណ្ណាម។ ប៉ុន្តែការវាយប្រទេសតុងកឹង បាននាំឲ្យចិនធ្វើអន្តរាគមន៍។ ទាល់តែបារាំង (ឧត្តមនាវី គួ បេ) វាយបំភ័ន្ត (ឬព្រមាន) លើកោះហ្វ័រម៉ូស និងកោះ ប៉េស្កាឌ័រ* (Pescadoros) *ទើបចិនបញ្ឈប់ការប្រទូស្តរ៉ាយ ហើយចុះសន្ធិសញ្ញានៅ តៀនទ្សិន (៩ មិថុនា ១៨៨៥) ទទួលស្គាល់ការគាំពារនៃប្រទេសបារាំងលើអណ្ណាម និងលើតុងកឹង។*

# អធិប្បាយ

(១) នៅ គ.ស. ១២៨២ យូប៊ីឡៃ បញ្ជូនទ័ពមួយកងឲ្យមកកាន់កាប់ប្រទេសចំប៉ា និងប្រទេសកម្ពុជា (ជ័យវរ្ម័នទី៨ ឲ្យស្នួយសាអាករទៅពួកម៉ុងហ្គោលនៅឆ្នាំ ១២៨៥)។ ប៉ុន្តែទ័ពនេះបានត្រូវយួនវាយកំចាត់ មិនឲ្យឆ្លងតាមដងភ្នំអណ្ណាមបានឡើយ។

(២) រវាង គ. ស. ១២៨០ ម៉ារកូ ប៉ូឡូ ឈប់សំចតនៅតុងកឹង ហើយប្រើពាក្យ "កៅជីហ្គូ" (caugigu) ដើម្បីចង្អុលវាលត្រីកោណ ដែលទន្លេក្រហមហូរកាត់ចូលក្នុងសមុទ្រ។ ពួកដើរសំពៅជាតិចាម-ជ្វា ប្រើក្លាយជា "គុតជី" រួចមកពួកជប៉ុនថាជា "កូឈី"។ ក្រោយមក បារាំងប្រើជា "កូសាំង" ដោយបន្ថែម "ស៊ីន" នៅខាងចុងដើម្បីបញ្ជាក់ថា កូសាំងនៅខាងចិន (មិនមែនកំពង់ផែកូសាំងនៅឥណ្ឌា)។ បារាំងប្រឡំមួយជាន់ទៀត ដោយចង្អុលវាលត្រីកោណក្រោមបង្អស់ទៅវិញ គឺវាលត្រីកោណរបស់ទន្លេមេគង្គ ។

(៣) ពាក្យ "ឥណ្ឌូចិន" បានត្រូវបង្កើតឡើងជាលើកដំបូង ដោយអ្នកភូមិសាស្ត្រជាតិ ដាណឹម៉ាក ឈ្មោះ ម៉ាលតឺ-ប្រូង (Malte-Brun) នៅឆ្នាំ ១៨៥២។ ពាក្យនេះយកមូលដ្ឋានលើហេតុដែលដងភ្នំអណ្ណាមខ័ណ្ឌប្រទេសលាវនិងកម្ពុជា ដែលមានវប្បធម៌របៀបឥណ្ឌា ពីប្រទេសយួនដែលមានវប្បធម៌របៀបចិន។

(៤) សៀមវាយយកបានអង្គរកាលពីឆ្នាំ ១៣៥១ (ស្តេចលំពង់, ក្រុមញាតិតាត្រសក់ផ្អែម)។

(៥) ការណ៍ដែលគួរកត់សំគាល់ គឺបរាជ័យពេញទី នៃ "គ្រិស្តសាសនូបនីយកម្ម" លើកម្ពុជា។ ដោយមានសទ្ធាយ៉ាងជ្រៅលើពុទ្ធសាសនា ខ្មែរយើងទាត់ចោលការបញ្ចូនខ្លួននៃគ្រិស្តសាសនា មិនមែនតាមការព្យាបាទធ្វើបាបទេ ប៉ុន្តែតាមការមិនព្រមទទួលជំនឿថ្មី។ ក្នុងពេលដែលនៅប្រទេសវៀតណាម ក្រោយពេលអស់ការព្យាបាទមក ពួកអ្នកផ្សាយសាសនាគ្រិស្តបានទទួលបរិស័ទយ៉ាងច្រើន រហូតដល់ក្នុង ៨% នៃបណ្តាជន។

(៦) រយៈពេលបួនសតវត្សរ៍ ពីគ.ស. ១៤៧៤ (ការប្រជែងត្រីភាគី រាមាធិបតី-ធម្មោរាជា-សូរិយោទ័យ) ទៅគ.ស. ១៨៥៩ ជារយៈពេលខ្មៅគគ្រេចនៃប្រវត្តិសាស្ត្រខ្មែរ។ គឺជាសម័យនៃការដណ្តើមរាជ្យគ្នារវាងក្រុមញាតិស្តេច, នៃការធ្វើឃាដនយោបាយ, នៃការសម្លាប់រង្គាល, ក្នុងពេលដែលទឹកដីកម្ពុជាចេះតែរបេះរបោចទៅ ក្រោមការរុញច្រាននៃសៀមនិងយួន។ ពួកអ្នកចង់បានស្វេតឆ័ត្រ ខ្លះហៅសៀមមកជួយ ខ្លះហៅយួនមកពួតដៃ ក្នុងសង្គ្រាមកាតឃាដដើម្បីអំណាច (អានទំព័រ៣២ ដែរ, លេខយោង ៣, ប្រយោគទី ២)។

ក្នុងរាជ្យនៃអង្គនន់ទី២ (១៧៧៥-១៧៧៩) កម្ពុជាដកខ្លួនពីការត្រួតត្រារបស់សៀម ដើម្បីចូលក្រោមការគាំពាររបស់យួន។ ប៉ុន្តែប្រទេសយួន ដោយចុះខ្សោយព្រោះការបះបោរនៃពួកតៃសឺង ក៏បន្ធូរដៃវិញក្រោយបន្តិចមក ហេតុដែលបើកឲ្យសៀមត្រឡប់មកវិញ។ ក្នុងរាជ្យនៃអង្គចាន់ទី២ (១៨០៦-១៨៣៤) កម្ពុជាទៅជារណបយួន (ក្រោមយ៉ា-ឡុង)។ មិញ-ម៉ាង, តរាជ្យពី យ៉ា-ឡុង, ជន្លៀសក្សត្រីយានីអង្គម៉ី (កូនស្រីអង្គចាន់) និងនាម៉ឺនវាំងទាំងអស់មកព្រៃនគរ ហើយដូរឈ្មោះ កម្ពុជា ជា "ទឹកដី មី-ឡាំ"។ ម្ចាស់ខ្លួង, បងប្អូនបង្កើតម្នាក់របស់អង្គចាន់ទី២, ត្រឡប់មកពីប្រទេសសៀមវិញ ដែលខ្លួនបានរត់ទៅជ្រក ហើយបំបះបំបោរខ្មែរឡើងជាមួយជំនួយរបស់សៀម។ សង្គ្រាមមួយរវាងសៀមនិងយួនក៏ផ្ទុះឡើង ហើយបានចប់ដោយការព្រមព្រៀងគ្នាដាក់ម្ចាស់ខ្លួងក្រោមស្វេតឆ័ត្រ និងក្រោមការត្រួតត្រារួម យួន-សៀម។

ព្រះបាទអង្គឌួង, ដោយជឿជាក់ថា ប្រទេសកម្ពុជាមុខជានឹងត្រូវយួននិងសៀមហែកចែកគ្នា ដោយយកទន្លេមេគង្គជាព្រំដែនរួម, ក៏សំរេចអំពាវនាវដល់អធិរាជណាប៉ូឡេអុងទី៣ តាមរយៈ "មុង ស៊ីញ៉រ" មីស មេគណកាតូលិក។ ប៉ុន្តែ, ដោយមកពីការបិទមាត់មិនជិតនៃរដ្ឋមន្ត្រីទទួលបំពេញបេសកកម្មនៅប្រទេសចិននិងប្រទេសសៀម ដែលណាប៉ូឡេអុងទី៣ ចាត់ឲ្យចុះសន្ធិសញ្ញាសម្ពន្ធភាពជាមួយព្រះបាទអង្គឌួង, នាម៉ឺនសៀមដែលមានភារៈឃ្លាំមើលស្ដេចខ្មែរ ក៏បានដឹងរឿងអស់ ហើយបញ្ចេញកំហឹងរបស់ខ្លួន ដោយវាយក្បាលព្រះចៅអង្គឌួងនឹងស្បែកជើង។ បាក់មុខខ្លាំងណាស់ ប៉ុន្តែពុំហ៊ានធ្វើអ្វីគេ, អង្គឌួងក៏សុខចិត្តឈប់ហៅរកបារាំង។ បួនឆ្នាំក្រោយមក ព្រះបាទអង្គឌួងខំរកទាក់ទងម្ដងទៀតជាមួយបារាំងដែលមកកូសាំងស៊ីនទៅហើយ។ ប៉ុន្តែស្ដេចសុគតនៅជំណាច់ឆ្នាំ ១៨៥៩។ កូនប្រុសឈ្មោះ អង្គវង្ស ឡើងសោយរាជ្យបន្ត ក្រោមឈ្មោះថា **នរោត្តម**, ឈ្មោះដែលសៀមឲ្យក្នុងពេលអភិសេក។ ក្រោយមក ព្រះបាទនរោត្តមចុះសន្ធិសញ្ញា "ប្រូតិកតូរ៉ា" ជាមួយប្រទេសបារាំង, ការអាណាព្យាបាលដែលរំដោះកម្ពុជាចេញផុតពី "ការមើលខុសត្រូវ" សៀម រហូតមកដល់សព្វថ្ងៃនេះ។

(៧) តុងកឹង ក្រោយមកវៀតណាមខាងជើង ជាអង្រឹងនៃជាតិសាសន៍យួន។ ពីសតវត្សរ៍ទី១០ ទៅទី១៧ យួនចាប់ធ្វើការពង្រីកទឹកដីចុះមកខាងត្បូង។ នៅជំណាច់សតវត្សរ៍ទី១៧ ប្រទេសចំប៉ា, រាជាណាចក្រនៃពួកចាម (អានទំព័រ១១៦ ដែរ, លេខយោង៨), បានត្រូវយួនលេបអស់ទាំងមូល ហើយឲ្យឈ្មោះថ្មីថា អណ្ណាម។ បន្ទាប់ពីការយកបាននេះ យួនបានមកនៅជាប់នឹងខ្មែរ។ ប៉ុន្តែការរីកអំណាច និងរីកទឹកដីនេះ បានបំបែកឯកភាពយួន។ ការប្រកួតប្រជែងគ្នាកើតមានឡើងរវាងក្រុមទ្រិញ (ស្ដេចត្រាញ់ខាងជើង) និងក្រុមង្វៀង (ស្ដេចត្រាញ់ខាងត្បូង) ការបាក់បែកដែលនៅតែជាទីកត់សំគាល់ រហូតដល់សព្វថ្ងៃ។

នៅឆ្នាំ ១៦២៣ ស្ដេចជ័យជេដ្ឋាដែលបានរៀបការជាមួយម្ចាស់ស្រីយួនម្នាក់ ដើម្បីទប់ទល់នឹងការរុញច្រានរបស់សៀម សុំជំនួយពីស្ដេចយួននៃទិសខាងត្បូង ហៀន-វឿង។ ជាថ្នូរ ស្ដេចខ្មែរត្រូវបើកឲ្យជនជាតិយួនមកបើកហាងជំនួញនៅខេត្តព្រៃនគរ។ ការកកេរដីកម្ពុជាក្រោម ក៏ចាប់ផ្ដើមឡើងហើយបេះដូងនៃនគរ ហ៊្វូ-ណាន ក៏វិចវិលអស់នៅឆ្នាំ ១៧៧៥ ក្នុងជំណាច់រាជ្យស្ដេចឧទ័យទី២ (លើកលែងតែស្រុកឃ្លាំង ក្រោយមកខេត្តសុកត្រាំង ដែលយួនចូលកាន់កាប់ក្នុងឆ្នាំ ១៨៤០)។

(៨) "អេវ៉ែក" បារាំងលើកដំបូងនៅឥណ្ឌូចិន មិនមែនជាអេវ៉ែកពេញសមត្ថភាពរបស់ក្រុងវ៉ាទីកង់ទេ ប៉ុន្តែបានត្រូវគេហៅឲ្យមានតែឈ្មោះប៉ុណ្ណោះ (in partibus)។

(៩) ដំបូងឡើង ង្វៀង-អាន់ លំអៀងទៅកាន់ជំនួយសៀមមុន។ តាមបញ្ជារបស់ស្ដេចសៀម បេសកៈយោធពលខ្មែរមួយកង បានត្រូវបញ្ជូនទៅក្រុងហ្វេ នៅឆ្នាំ ១៨០០ ដើម្បីជួយច្បាំងតទល់នឹងពួកតៃ-សឺង។

(១០) ដោយមិនសូវលុះលង់ដែរ ម៉ុងម៉ុរ៉ាំង ឲ្យមកតាមសារសំងាត់មួយ នូវលទ្ធភាពពេញលេញ (carte blanch) ដល់ កុងវ៉ី មេបញ្ជាការកងទាហានបារាំងនៅឥណ្ឌា ដែលតាំងទីក្នុងក្រុងប៉ុងឌី សេរី ដើម្បីសំរេចបញ្ជូន ឬមិនបញ្ជូនទ័ពមួយកងទៅឥណ្ឌូចិន។ កុងវ៉ីមិនព្រម។ មេគណកាតូលិក ដឺ បេអែន ក៏រៀបចំខ្លួនឯងនូវការលើកទាហាននេះ ជាមួយប្រាក់កាសនៃគ្រួសារខ្លួន និងនៃពួកអាណានិគម នៅប៉ុងឌីសេរី។

(១១) យ៉ា-ឡុង ទទួលចុះចូលប្រទេសចិន ហើយបានត្រូវអភិសេកនៅហាណូយ ក្នុងឆ្នាំ ១៨០៤។ អធិរាជចិន គា គីង ដាក់ឈ្មោះឲ្យប្រទេសយួនថា "វៀត-ណាម" ដែលប្រមូលផ្ដុំតុងកឹង (បាក់គី) អណ្ណាម (ទ្រុងគី) និង កូសាំងស៊ីន (ណាមគី)។

(១២) នេះគ្រាន់តែជាលេសទេ។ តាមពិត ដោយឧស្សាហកម្មខ្លួនស្គាល់វឌ្ឍនភាពយ៉ាងខ្លាំង ពួកអឺរ៉ុបបោះខ្លួនក្នុងការដណ្តើមគ្នាយកផ្សារនៅអាស៊ី និងក្នុងការរកធនធានដើមថ្មីៗ បារាំងនិងអង់គ្លេស យកចិត្តទុកដាក់ជាពិសេសលើប្រទេសចិន។ ពួកអង់គ្លេសបានបើកយុគនៃអាណានិគមកម្មលើអាស៊ី ជាមួយ "សង្គ្រាមអាភៀន" នៅឆ្នាំ ១៨៤១ (ដើមអាភៀនដុះនៅប្រទេសឥណ្ឌា ពែរស៍ឬអ៊ីរ៉ង់ និងនៅទួរគី។ ពួកអឺរ៉ុបបាននាំចូលមកដាំក្នុងប្រទេសចិន)។ បារាំងនិងអង់គ្លេសដណ្តើមគ្នាយកកម្មសិទ្ធផ្តាច់មុខខាងជំនួញ។ ដោយចាញ់ពួកអង់គ្លេសស្ទើរតែគ្រប់ទីកន្លែង បារាំងលោតមកសង្គ្រប់លើឥណ្ឌូចិន។ ម្យ៉ាងទៀត ស្របគ្នានឹងការលើកទាហានមកកូសាំងស៊ីន ទាហានមួយកងបានត្រូវបញ្ជូនទៅប៉េកាំង ដើម្បីវាយ "ជាទណ្ឌកម្ម" និងបញ្ឈប់ការសំឡាប់រង្គាលពួកកាន់សាសនាគ្រិស្ត។

(១៣) ក្នុងសម័យនោះ កម្ពុជាក្រោមបានត្រូវស្តេចខ្មែរបោះបង់ចោលទៅហើយ បណ្តាជនខ្មែររៀបចំដោយខ្លួនឯង នូវការបះបោរទាំងឡាយទល់នឹងយួន។ បន្ទាប់ពីការក្តាប់កូសាំងស៊ីនទៅវៀត-ណាម ដែលប្រ-ទេសបារាំងបានសំរេចនៅថ្ងៃទី ២១ ឧសភា ១៩៤៩ ជនជាតិខ្មែរយើងនៅកម្ពុជាក្រោម បានក្លាយទៅជា "ពលរដ្ឋវៀតណាម ដើមកំណើតខ្មែរ" (វៀត ហ្គុក មៀន, ក្នុងភាសាយួន)។ តទៅនេះ គឺទីប្រជុំជនខ្មែរយើងខ្លះ ដែលគេនៅចាំឈ្មោះនៅឡើយ :




(១៤) គណៈបេសកកម្មបារាំងមួយ ដឹកនាំដោយ ឌូដា ដឺឡាហ្គ្រេ ឡើងតាមទន្លេមេគង្គ ដើម្បីស្វែងរកពិនិត្យនៅខែមិថុនា ១៨៦៦។

(១៥) ដោយលាក់មិនឲ្យ ព្រះបាទនរោត្តម ដឹង បារាំងនិងសៀមធ្វើសន្ធិសញ្ញាមួយទៀតនៅប៉ារីស ក្នុងឆ្នាំ ១៨៦៧។ ក្នុងនោះ សៀមលែងទាមទារសួយសារអាករពីខ្មែរ ប៉ុន្តែបានជាថ្នូរវិញនូវខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន ទន្លេរពៅ និងម្លូព្រៃ។ បន្ទាប់ពីការតវ៉ារបស់ហ្លួង នរោត្តម, ដឺឡា គ្រង់ឌ្យែរ ចចារបានពីសៀមវិញតែមាត្រាបន្ថែមមួយ : ខ្មែរអាចធ្វើនេសាទក្នុងបឹងទន្លេសាប ដូចសៀមបាន។

####################

# ភាគទី ៣

## ពី

# អាណានិគម

## ទៅ

# សហភាពឥណ្ឌូចិន

*ខ្លួនទាបឲ្យខំតោង ដៃខ្លីឲ្យខំឈោង ទើបយើងលូតលាស់ ។*

*ពីឆ្នាំ ១៨៦៣ ដែលព្រះបាទនរោត្តម[១] ចុះសន្ធិសញ្ញាទទួលការគាំពារពីបារាំង ដល់ឆ្នាំ ១៨៨៥ ដែលចិនទទួលស្គាល់តាមសន្ធិសញ្ញា តៀន-ទ្សិន ដល់ការគាំពារបារាំងលើអណ្ណាមនិងតុងកឹង, ព្រះរាជាណាចក្រក្រុងកម្ពុជា (ឈ្មោះជាផ្លូវការរហូតដល់រជ្ជកាលព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ-កុសមៈ) បានរង្កើដោយការបះបោរជាច្រើនៗ ក្នុងពីរឆ្នាំដំបូង (១៨៦៥- ១៨៦៧) នរោត្តមត្រូវប្រឈមមុខទល់នឹងការបះបោរពីរ ៖ មួយដឹកនាំដោយ អាចារ្យស្វា មួយទៀតដោយ ពោកំបោរ[២]។ ការបះទី១ បានត្រូវបង្ក្រាបយ៉ាងរហ័ស។ អាចារ្យស្វាបានត្រូវគេសំឡាប់នៅឆ្នាំ ១៨៦៦។ ប៉ុន្តែដើម្បីទប់ទល់នឹងពោកំបោរ ដែលប្រកាសថាខ្លួនជាកូនរបស់ អង្គចាន់ទី២, នរោត្តមត្រូវហៅកងទាហានអាណានិគម[៣] មកជួយ។ ដោយមានខ្មែរលើជួយផង ពោកំបោរ បំបះបណ្ដាជនដោយចាប់ផ្ដើមពីខេត្តក្រចេះ។ តែក្នុងរយៈពីរឆ្នាំប៉ុណ្ណោះ ចលនាពោកំបោរបានមកដល់ក្រុងឧដុង្គ។ នៅឆ្នាំ ១៨៦៧ ពោកំបោរបានត្រូវគេនាំចូលអន្ទាក់មួយ ហើយគេកាត់កនៅខេត្តកំពង់ធំ។ ការបះបោរមួយទៀតដែលធ្វើឡើងស្ទើរតែពេញរជ្ជកាលនៃ នរោត្តម បានត្រូវដឹកនាំដោយប្អូនស្ដេចបង្កើត គឺម្ចាស់ ស៊ីវត្ថា[៤]។*

*ក្រោយពីការស្លាប់នៃពោកំបោរ បារាំងគិតធ្វើការកែទំរង់ដល់រចនាសម្ពន្ធរដ្ឋបាលខ្មែរ ដែលបានត្រូវគេវិនិច្ឆ័យថាប្រហែលគ្នានឹងរបៀបព្រៃ[៥]។ នៅឆ្នាំ ១៨៨៤ ប្រទេសបារាំងហៅប្រទេសកម្ពុជាឲ្យចូលក្នុង <ផ្សាររួម> ម្យ៉ាងដោយបំបាត់ការយកពន្ធគយរវាងកម្ពុជា កូសាំងស៊ីន និងអណ្ណាម។ បន្ទាប់ពីការមិនព្រមនៃព្រះបាទ នរោត្តម <គូវែន័រ ហ្សេណេរ៉ាល់> (ចៅហ្វាយទូទៅ) នៃកូសាំងស៊ីន ឈ្មោះ សារិល ថុមសុន, ជាមួយការយល់ព្រមនៃនាយករដ្ឋមន្ត្រីបារាំង ហ្ស៊ុល ហ្វ៊ែរី, ឡើងគោកនៅឧដុង្គ ជាមួយទាហានជើងទឹកបារាំង ៤-៥ នាក់, ចូលមកយ៉ាងគំហុកក្នុងព្រះបរមរាជវាំង ហើយ —ចំពុះទុងកួងនឹងបំពង់ក— គំរាមព្រះនរោត្តមថានឹងបំបរបង់[៦]។ ដោយយ៉ាងនេះ បារាំងបានហែកទាញពីដៃស្ដេចខ្មែរនូវសន្ធិសញ្ញាមួយ ដែលធ្វើឲ្យកម្ពុជាក្លាយទៅជាអាណានិគម <តាមផ្លូវហេតុ> នៃប្រទេសបារាំង។ ក្នុងសន្ធិសញ្ញានេះ នរោត្តម យល់ព្រមទទួលយកទាំងអស់នូវការកែទំរង់រដ្ឋបាល ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលបារាំងយល់ឃើញថាមានប្រយោជន៍ដល់កម្ពុជា។ ជាពិសេសសន្ធិសញ្ញានេះតំរង់ទៅការលុបបំបាត់ទាសភាព[៧]។*

*ក្នុងឆ្នាំ ១៨៨៥, ឆ្នាំនៃសន្ធិសញ្ញា តៀន-ទ្សិន, បានចប់សម័យមួយនៃប្រវត្តិអាណានិគម ដែលគេឲ្យឈ្មោះថា «ពួកឧត្តមនាវី»។ ដូចនេះមែន សម័យនោះគឺជារយៈពេលនៃការចូលកាន់កាប់ស្រុកខ្មែរ និងស្រុកយួន តាមសកម្មកិច្ចយោធាសុទ្ធសាធ ដែលដឹកនាំដោយមេទ័ពជើងទឹក។ ចេញពីការវាយយកគេឯងធ្វើអាណានិគមនេះ (ទាំងនៅអាហ្វ្រិក ទាំងនៅអាស៊ី), នាយទាហានពីរនាក់, ល្យោតី និង ហ្គា ល្យេនី, បានត្រូវគេសំគាល់ជាមេទ័ពយ៉ាងចំណាន។ នៅឆ្នាំ ១៨៨៦ បារាំងដាក់អំណាចស៊ីវិលជំនួសអំណាចទាហាន ដោយតែងតាំង ប៉ូល ប៊ែរ ជា «រ៉េស៊ីដង់ ហ្សេណេរ៉ាល់» (របៀបជាអ្នកមើលខុសត្រូវទូទៅ) នៅអណ្ណាមនិងនៅតុងកឹងជំនួសលោកឧត្តមសេនីយ ដឺគួស៊ី (កូសាំងស៊ីន មាន គូវែន័រ ស៊ីវិលហើយ)។ ក្រោយ «ការធ្វើឲ្យមានសន្តិភាព» នៃពួកឧត្តមនាវី, សម័យនៃការស្វែងរក ហើយទាញយកកំរៃពីធនធានរ៉ែ និងធនធានកសិកម្មនៃប្រទេសក្រោមអំណាច ក៏ចាប់ផ្ដើមឡើង។ ធនធានដែលគេបានហៅក្នុងសម័យនោះថា «របស់របរអាណានិគម»* (denrées coloniales)*។ ដើម្បីអំពើនេះ បារាំងបានដាក់រចនាសម្ពន្ធដែលត្រូវការ ហើយប្រមូលផ្ដុំអំណាចទាំងអស់។ អាជ្ញាធរយួនជួយកំណកិច្ចការទាំងនេះ ដោយដឹងខ្លួនថានឹងអាចជំនួសបារាំងក្នុងថ្ងៃណាមួយ។*

*ក្រឹត្យមួយចុះថ្ងៃ ១១ វិច្ឆិកា ១៨៨៧ បង្កើត «សហភាពឥណ្ឌូចិន»* (Union Indochinoise) *ដោយបំបាត់ចោលនូវព្រំដែនរវាងស្រុកខ្មែរនិងស្រុកយួន (សម័យនោះ តុងកឹង, អណ្ណាមនិងកូសាំងស៊ីន)។ ប្រទេសទាំងពីរបានត្រូវគេបញ្ចូលគ្នាជារដ្ឋតែមួយថ្មី៖ ឥណ្ឌូចិនបារាំង (កាលនោះប្រទេសលាវ មិនទាន់បារាំងយកបាននៅឡើយទេ)។ នៅលើរដ្ឋនេះ មាន «គូវែន័រ ហ្សេណេរ៉ាល់» ម្នាក់ ដែលកាន់អំណាចទាំងអស់ ហើយដែល*

នៅក្រោមរដ្ឋមន្ត្រីក្រសួងអាណានិគមឯស្រុកបារាំង។ មន្ត្រីនេះចាត់ការរដ្ឋឥណ្ឌូចិន ជាមួយមេក្នុងស្រុកបួននាក់ (ជាតិបារាំងជាការធម្មតា) ៖ «គូវែនវ៉នៃកូសាំងស៊ីន, និងរ៉េស៊ីដង់ ស៊ូប៉េរីយ៉េរ» (អ្នកមើលខុសត្រូវជាន់ខ្ពស់) នៅតុងកឹង, នៅអណ្ណាម និងនៅកម្ពុជា[៨]។

ការចូលកាន់កាប់នៃបារាំងបានជួយ —ស្ទើរតែមិនទាន់— កម្ពុជាឲ្យពីការបាត់បង់។ ប៉ុន្តែនៅទិសខាងជើង, ប្រទេសលាវកំពុងតែស្គាល់វាសនា ដែលប្រទេសកម្ពុជាទើបនឹងគេចចេញរួចនៅឆ្នាំ ១៨៦៣ ៖ ការកកេរលេបទឹកដីពីសំណាក់សៀមនឹងយួន។ តាំងតែពីដើមសតវត្សរ៍ទី១៩, ប្រទេសសៀមបានយករាជាណាចក្រវៀងចន្ទន៍ ក្នុងពេលដែលយួនកាន់កាប់ «នគរ» សៀងខ្វាង និង «នគរ» ខាំមួន។ នៅ ឆ្នាំ ១៨៦៤ ពួក «ហូ», ក្រុមចោរចិនចុះពីយុនណាន, ចូលមកលុកលុយតុងកឹង និងលាវខាងជើង។ ការលុកលុយនេះ ធ្វើឲ្យមានអន្តរាគមន៍នៃយោធាប្រទេសសៀមដែល, ដោយឆ្លៀតឱកាសពង្រីកឥទ្ធិពលរបស់ខ្លួនផង, បញ្ជូនទ័ពមួយកងមកស្រុក ស៊ីម-សុងចៅ-ថៃ (ឡាយ-ចៅ, វៀតណាមខាងជើង) (១៨៨៣-១៨៨៥)។ ពួកបារាំង, ដែលបានមកតាំងទីនៅស្រុកខ្មែរនិងស្រុកយួនហើយ, សង្ស័យថាប្រទេសអង់គ្លេសចូលដៃជាមួយសៀម[៩] ដើម្បីមើលខុសត្រូវលើទន្លេក្រហម ដែលជាផ្លូវចេញចូលសំរាប់ជួញជាមួយប្រទេសចិនខាងត្បូង[១០]។ រដ្ឋការអាណានិគមបារាំងដែលចង់យកទន្លេមេគង្គធ្វើជាព្រំប្រទល់ធម្មជាតិនៃឥណ្ឌូចិនរបស់ខ្លួន ក៏សំរេចចូលប្រឡូកក្នុងរឿងលាវដែរ ក្រោមលេសថាជួយយួន ឲ្យដាក់អធិបតេយភាពខ្លួនលើប្រទេសលាវខាងជើងវិញ។ បារាំងរុញច្រានអធិរាជ ដុង ខាញ់ ឲ្យប្រាប់រឿងនេះទៅសៀម, ហើយក្នុងពេលស្របគ្នា ស្នើទៅសៀមសុំដាក់ទីកុងស៊ុលរងមួយនៅហ្លួងព្រះបាង។ ក្រុងទេព (បាងកក) យល់ព្រម។ អូហ្គុស ប៉ាវី, ភ្នាក់ងារជាន់ទាបម្នាក់នៃក្រសួងប្រៃសណីយនៅកំពត បានត្រូវតែងតាំងក្នុងមុខតំណែងនេះ។ ដោយឥតចាំសេចក្តីអនុញ្ញាតឲ្យបំពេញមុខងារ (exequatur) ពីសៀម, ប៉ាវីចេញដំណើរមកប្រទេសលាវ ជាមួយបារាំងប្រមាណ ៤០ នាក់ និងខ្មែរ ២-៣ នាក់ ដែលជាអ្នកបកប្រែភាសា។ ពេលមកដល់ហ្លួងព្រះបាង នៅខែកុម្ភៈ ១៨៨៧, ក្រុងនេះបានត្រូវកងទាហានសៀមកាន់កាប់ទៅហើយ។ ស្តេចលាវ អ៊ុនខាំ, ដោយមាន «ស្នងការ» សៀមនៅ «អម» ផង, លែងមានអំណាចអ្វីហើយ។

ខែឧសភា កងទាហានសៀមបោះបង់ហ្លួងព្រះបាងវិញ។ ថ្ងៃ ១០ មិនា, ពួក«ហូ» បី-បួនរយ នាក់ ចូលលុកលុយរាជធានីលាវ ដោយប្លន់និងសម្លាប់រង្គាលបណ្តាជន។ ស្តេច អ៊ុនខាំ, ដោយធ្វើអ្វីពុំកើតហើយផ្ញើខ្លួនឲ្យកម្មផល, រង់ចាំសេចក្តីស្លាប់លើរាជបល្ល័ង្ក(*), សេចក្តីស្លាប់ដែលប្រហែលជាជួបប្រទះមែន បើគ្មានខ្មែរដែលជាអ្នកបកប្រែភាសារបស់ ប៉ាវី ប្រអូសប្រទាញយកទៅចុះទូកជាមួយទេ។ ក្នុងពេលគេចខ្លួនជាមួយគ្នា, ព្រះចៅនិយាយទៅកុងស៊ុលរង ប៉ាវី សុំការគាំពារ (ប្រូតិកតូរ៉ា) ពីបារាំង។ ទំនាស់ទីមួយរវាងបារាំងនិងសៀមក៏ចាប់ផ្តើមឡើង។ កងទាហានសៀមត្រួតត្រាទន្លេមេគង្គ, កាន់កាប់ក្រុងអត្តពៅ (លាវខាងត្បូង) ហើយចូលមកក្នុងខេត្តស្ទឹងត្រែង។ ប៉ាវី (ដែលបានត្រូវគេតែងតាំងជាកុងស៊ុលប្រទេសបារាំងប្រចាំប្រទេសសៀម) ដាក់កំហិតឲ្យពីរដង (Ultimatum) ដល់ស្តេចសៀម។ ក្នុងពេលជាមួយគ្នា កងសំពៅបារាំងមួយឡើងតាមទន្លេម៉េណាមរហូតដល់ក្រុងទេព។ ការបញ្ចេញអានុភាពនាវាមួយនៅមុខរាជធានីសៀម, ហើយបន្ទាប់មក ការព័ទ្ធខ្ទប់ឆ្នេរសមុទ្រ បានធ្វើឲ្យសៀមចុះចាញ់ ហើយចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង-សៀម នៃថ្ងៃ ៣ តុលា ១៨៩៣, ថ្ងៃនៃការចូលមកក្នុងសហភាពឥណ្ឌូចិន នៃប្រទេសលាវ។ តាមសន្ធិសញ្ញានេះ, លក្ខខ័ណ្ឌដូចតទៅបានត្រូវបង្ខំឲ្យសៀមទទួល ៖

---

(*) ក្រោយមក, ក្នុងឆ្នាំ ១៩៥៣ ពេលដែលកងវៀតមិញព័ទ្ធជាប់ក្រុងហ្លួងព្រះបាង ព្រះចៅស៊ីសាវ៉ាងវង្ស ក៏ក្រាញនៅក្នុងរាជវាំងដែរ។

- *ប្រទេសសៀមត្រូវឈប់ចង់បានទឹកដីនៅត្រើយខាងឆ្វេងនៃទន្លេមេគង្គ (ទឹកដីលាវ) ហើយទទួលស្គាល់ជា «ភូមិភាគឥតកងទ័ព» ដែនដីមួយបន្ទះទទឹងប្រវែង ២៥ គម. នៅត្រើយ ខាងស្តាំនៃទន្លេមេគង្គ (ដែនដីសៀម)។*
- *ប្រទេសបារាំងកាន់កាប់ចន្ទបុរី (ចាន់តាប៊ុន) ជា «ការកក់បញ្ចាំ» រហូតដល់ពេលកងទាហានសៀមដកខ្លួនចេញអស់ពីត្រើយខាងឆ្វេងនៃទន្លេមេគង្គ។*
- *ប្រទេសសៀមមិនត្រូវមានកងទ័ពនៅបាត់ដំបងនិងសៀមរាប (ខេត្តទៅជាអព្យាក្រឹត) និងទូកសំពៅ ផ្សេងៗ លើបឹងទន្លេសាប (អានទំព័រ ១៨, លេខយោង ១៥)*

*ប៉ុន្តែការវិវាទទាំងនេះ ទាល់តែ ១៤ ឆ្នាំក្រោយមកបានចប់ជាមួយសន្ធិសញ្ញា និងកិច្ចសន្យាបារាំងសៀមមួយចំនួន ៖*

- *កិច្ចសន្យានៃឆ្នាំ ១៩០២ ៖ បារាំងលប់បំបាត់ភូមិភាគឥតកងទ័ពទទឹង ២៥ គ.ម. នៅត្រើយខាងស្តាំនៃទន្លេមេគង្គ។ តបមកវិញ, សៀមឲ្យមកកម្ពុជាវិញនូវខេត្តមូលព្រៃ និង ទន្លេរពៅ (មូលព្រៃ + ទន្លេរពៅ = កំពង់ធំនិងព្រះវិហារ)។ រីឯប្រទេសលាវបានទទួលខេត្ត បាសាក់។*
- *កិច្ចសន្យានៃឆ្នាំ ១៩០៤ ៖ កំពង់ត្រាត ហើយនិងទឹកដីនៅទិសខាងត្បូង, ព្រមទាំងកោះទាំងឡាយដែលនៅជិតឆ្នេរ ចាប់ពីឡែមស៊ីងទៅ បានត្រូវឲ្យមកឥណ្ឌូចិន ដែលទទួលស្រុកដានសៃទៀត។*
- *សន្ធិសញ្ញានៃឆ្នាំ ១៩០៧ ៖ ប្តូរជាមួយដានសៃ, ត្រាតនិងកោះទាំងឡាយដែលនៅខាងត្បូងជ្រោយឡែមស៊ីង, ប្រទេសសៀម (ដែលនឹងផ្លាស់ឈ្មោះជាប្រទេសថៃនៅឆ្នាំ ១៩៣៩)*[១១] *ឲ្យមកកម្ពុជាវិញនូវខេត្តសៀមរាប, បាត់ដំបង និងស៊ីសុផុន*[១២]*។*

*នៅថ្ងៃ ២៤ មេសា ១៩០៤, ព្រះបាទនរោត្តមចូលទីវង្គត់។ ដោយបំពានលើប្រពៃណីចំណាស់ពាន់ឆ្នាំក្រុមប្រឹក្សារាជសម្បត្តិ, ប្រជុំក្រោមអធិបតីភាពនៃ «រ៉េស៊ីដង់ ស៊ូប៉េរីយើរ» បារាំង, ចង្អុលប្អូនស្តេច, ម្ចាស់ស៊ីសុវត្ថិ ឲ្យសោយរាជ្យបន្ត*[១៣]

# អធិប្បាយ

*(១) ព្រះបាទនរោត្តម ទទួលមកុដនៅថ្ងៃទី ៣ មិថុនា ១៨៦៤ ជាមួយវត្តមាននៃតំណាងបារាំង ឌូដា ដឺ ឡាហ្គ្រេ និងតំណាងសៀម ពញារាជា។ នរោត្តម បានបង្កើតទង់ជាតិខ្មែរ (មុនទង់សាធារណរដ្ឋ) និងភ្លេងជាតិ, នគររាជ, ដែលទំនុកបទបានត្រូវតែងដោយវរសេនីយត្រី-ពេទ្យបារាំង ម្នាក់។*

*(២) គេពិបាកនឹងថាដែរ តើការបះបោរទាំងនេះ ប៉ុនប៉ងដេញបារាំង ឬមួយរំលំស្តេច។ តាមបារាំងអាណានិគមនិយម ការបះនេះគឺទល់នឹងស្តេច, ជាការណ៍ធម្មតា។ ក្នុងមេរៀននៅសាលាបឋមសិក្សាទៀតសោត ក៏គ្រូបង្រៀនគ្រាន់តែឲ្យកត់ "បះអាចារ្យស្វា", "បះពោកំបោ" ដោយឥតមាន (ឬហ៊ាន) វែកញែកទៅឆ្ងាយឡើយ។*

*(៣) ក្នុងសម័យនោះ គឺពួក "ទារ៉ៃយ័រ" យួន* (tirailleurs annamites) *ក្រោមបញ្ជានាយទាហានបារាំងម្នាក់។*

*(៤) ព្រះបាទអង្គឌួង មានកូនប្រុសបីនាក់ : នរោត្តម, ស៊ីវត្ថា និង ស៊ីសុវត្ថិ។ ពេលស្តេចសុគតនៅឆ្នាំ ១៨៥៩ កូនច្បង, នរោត្តម, ត្រូវឡើងសោយរាជ្យបន្ត។ ប៉ុន្តែ ក្នុងពេលរង់ចាំពិធីអភិសេក ស៊ីវត្ថា ចង់សោយរាជ្យដែរ។ ដោយភ័យនឹងការឡើងប្រជាប្រិយភាពនៃស៊ីវត្ថា, នរោត្តមរត់ទៅស្រុកសៀម ដោយយកមកុដនិងព្រះខាន់រាជ្យទៅជាមួយ។ បន្ទាប់ពីអន្តរាគមន៍នៃមេគណកាតូលិក មីស, តាមរយៈទីកុងស៊ុលបារាំងនៅក្រុងទេព (បាងកក), នរោត្តមបានត្រូវបញ្ជូនមកមាតុប្រទេសវិញនៅឆ្នាំ ១៨៦២។ ការប្រកួតរបស់ស៊ីវត្ថា បានក្លាយទៅជាសង្គ្រាមធ្ងន់ ទល់នឹងការកាន់កាប់នៃបារាំង ចាប់តាំងពីឆ្នាំ ១៨៨៥ ទៅ។ នៅឆ្នាំ ១៨៨៧ ស៊ីវត្ថា "រំដោះ" បានតំបន់មួយ ហើយបង្កើតជារាជាណាចក្រ (ភូមិភាគកំពង់ស្វាយ)។ ដោយបារម្ភនឹងការបែកបាក់នៃកម្ពុជានេះ ហើយដោយខ្លាចក្រែងសៀមធ្វើអន្តរាគមន៍ជួយស៊ីវត្ថា បារាំងជ្រើសរើសយកការចចារ ហើយគិត "ពលីកម្ម" នរោត្តម ដើម្បីស៊ីវត្ថាវិញ។ ឈ្មោះប៉ូល កុលឡា បានត្រូវចាត់ឲ្យបំពេញបេសកកម្មនេះ។ ប៉ុន្តែស៊ីវត្ថាបានសុគតទៅ ក្នុងពេលដែលការចចារហៀបនឹងត្រូវបញ្ឈប់ដែរ។*

*(៥) ពួកបារាំងអាណានិគមនិយមលើកដំបូង បានបញ្ចេញ, ចំពោះប្រជាជនយើង, នូវការមើលងាយយ៉ាងខ្លាំង—រហូតដល់ដល់អារិយធម៌។ យើងអាចវិនិច្ឆ័យលើការសរសេរខ្លះនៃពួកនេះ :*

*អ. បូនួរ ក្នុងសៀវភៅខ្លួនឈ្មោះ "ឥណ្ឌូចិន" ចេញនៅឆ្នាំ ១៩០០ : "ប្រជាជននៅកម្ពុជាប្រហែលជាខ្លាំងតាមផ្លូវកាយ ជាងប្រជាជននៅអណ្ណាមមែន ប៉ុន្តែខ្វះថាមពល ខ្វះសកម្មភាព។ ការរៀបចំលើផ្ទៃសង្គមនៅរាក់កំភែល ហើយស្រដៀងនឹងរបៀបព្រៃ។ គ្មានការបណ្តុះបណ្តាលគំនិតប្រាជ្ញាឡើយ (ក្នុងពេលដែលនៅអណ្ណាម យួនក្រយ៉ាងណាក៏ដោយ ហើយគ្រួសារខ្លួនតូចតាចយ៉ាងណាក៏ដោយ ក៏នៅតែមានការអប់រំសឹងតែគ្រប់គ្នា។ ភូមិយួនទាំងអស់ មានសាលាបង្រៀនឥតយកថ្លៃ បើមិនចង់ថា គេតំរូវឲ្យកូនក្មេងទៅរៀនគ្រប់គ្នា), គ្មានសាមគ្គីធម៌តាមផ្លូវចិត្តឡើយ ហើយដោយហេតុនេះឥតមានមនោសញ្ចេតនាជាតិបន្តិចបន្តួច ឥតយល់ថាមាតុភូមិជាអ្វីឡើយ។ ជនខ្មែរអន់ជាងជនយួនយ៉ាងឆ្ងាយក្នុងគ្រប់ផ្នែកទាំងអស់។ ប៉ុន្តែបើខ្មែរគ្មានគុណសម្បត្តិយួន ខ្មែរមានគុណវិបត្តិយួន រហូតដល់ទៅប្រាក់ចំណូលមែនទែននៃស្តេចខ្មែរ បានមកតែពីការយកតុងលើបនល្បែងស៊ីសងដែលចិនកាន់ ហើយដែលធ្វើឲ្យប្រទេសហិនហោច។.... ពាណិជ្ជកម្មទាំងមូលនៅក្នុងដៃបរទេស : យួន ចិន ចាម-ជ្វា។"*

និយាយពីការវិវត្តន៍នៃខ្មែរយើង, សៀវភៅ “ទំលាប់ និង ទំនៀមនៃខ្មែរ” ចេញនៅឆ្នាំ ១៩៣៨, ដោយ ហ្គី ប៉ូរ៉េ និង អេវ៉ឺលីន ម៉ាស្ប៉េរ៉ូ : “ខ្មែរទាំងឡាយដែលថាលូតលាស់ ច្រើនតែមិនសូវប្រាជ្ញា មិនសូវចេះដឹងអ្វីទេ ហើយឥតយកចិត្តទុកដាក់លើអ្វីទាំងអស់។ តាមពាក្យនិយាយរបស់សិស្សក្មេងម្នាក់នៃវិទ្យាល័យស៊ីសុវត្ថិ មួយពួកជា «ក្របីអត់ឃ្នាន» ដែលស៊ីប្រទេសឯង មួយពួកទៀតជា «ពពែល្ងីល្ងើ» ដែលចេះតែស្រែកតែពីសតែពាស ឥតដឹងខុសត្រូវ។

ពួកទី១ បើខ្លួនមានបងប្អូន ឬអ្នកគាំពារធំៗ បានមុខងារ «ខ្លាញ់» ជាអ្នករាជការ ហើយទាញយកកម្រៃឲ្យអស់ពីដៃ, យឺតស្លឹក ប្រាជ្ញាទាល ប៉ុន្តែស្មានតែខ្លួនវៃឆ្លាតៗ ពួកនេះមើលងាយ ជួនកាលជនជាតិអឺរ៉ុប ក្នុងនាមនៃប្រពៃណីអាថ៌កំបាំងអ្វីម្យ៉ាង ដែលយើងទៅមិនដល់ឡើយ ហើយដែលនៅក្រោយនោះ គេលាក់បាំងការល្ងង់ខ្លៅរបស់គេ ជួនកាល បងប្អូនរួមជាតិឯង ដែលគ្នាក្រីក្រហើយមិនលូតលាស់។ ការសំខាន់ចំពោះអស់លោកទាំងនេះ គឺមិនបាច់ធ្វើអ្វី មានឋានន្តរសក្តិមួយ (បណ្ណទូតក្នុងរដ្ឋការ សឹងតែជាងារអភិជនមួយហើយ) វាយឫក «ពូជអន្តរវត្ត» នៅមុខពួកអឺរ៉ុប ធ្វើត្រាប់តាមពួកជនជាតិអឺរ៉ុប ដើម្បីឲ្យអ្នកនៅក្រោមបង្គាប់ខ្លួនកោត ហើយនិងស្ទាបអង្អែលសន្ទឹកប្រាក់នៅគ្រប់ពេលណាបើកឱកាសឲ្យ។ ត្រង់កន្លែងនេះ ពួកនេះធ្វើតាមប្រពៃណីមួយយ៉ាងចាស់មកហើយ ហើយខ្ញុំយល់ថា កិច្ចការនៃជីដូនជីតាពួកនេះក្នុងសម័យអង្គរ នៅត្រឹមត្រង់ការៈយ៉ាងធ្ងន់នៃអ្នកទារលុយ។

ក្រុមទី២ ពួក «ពពែ» ដែលមានចំនួនធំជាងគេ មានច្រើនតែអ្នករងគ្រោះ។ ពិតហើយ ពួកនេះចង់បានជោគជ័យដូចពួកទី១ ដែរ ប៉ុន្តែគ្នាដឹងខ្លួនថាអស់កម្លាំងពេក ដើម្បីទៅដល់នោះរួចៗ តាមសំដីពួកនេះ ការខិតខំនៃជីដូនជីតាខ្លួនដែលជាជាង (កសាងអង្គរ) និងជាអ្នកច្បាំង បានធ្វើឲ្យខ្លួនហេវហើតហៃហេ។ ខ្លួនមិនអាចទៅជាវេជ្ជបណ្ឌិតកើតទេ សាស្ត្រាចារ្យក៏មិនកើត គិលានុបដ្ឋាកក៏មិនកើត អ្នកជំនួញក៏មិនកើត និយោជិតក៏មិនកើត កម្មករក៏មិនបាន អ្វីក៏មិនបានដែរ ក្រៅពីនាហ្មឺន ឬមួយបណ្ណទូត។”

ប៉ូល ឌូមែរ «គូវែនរ័ ហ្សេនេរ៉ាល់» នៃឥណ្ឌូចិន ពីឆ្នាំ ១៨៩៧ ទៅ ១៩០២ បានទៅរហូតដល់ការជេរត្មេះ។ ចូរយើងវិនិច្ឆ័យសំដីវា ក្នុងសៀវភៅឈ្មោះ «ឥណ្ឌូចិនបារាំង» ចេញនៅឆ្នាំ ១៩០៥ : “តើសាសន៍ (ខ្មែរ) នេះមាននៅសល់ទេ? សាសន៍នេះបានឃើញការចុះអាប់ឱននៃខ្លួនទេ? ជនាទុជនកម្ពុជាសព្វថ្ងៃ តើសៀមជាកូនរបស់ខ្លួនឬអ្វី? មិនមែនទេ។ ពួកអ្នកឈ្នះ មិនទៅត្រឹមតែយកទ្រព្យសម្បត្តិទេ គេបានកំទេចសាសន៍នេះលប់ចេញពីបញ្ជីមនុស្សរស់។ កស្តុតាង គឺនៅក្នុងជនាទុជនកម្ពុជាគ្មាននៅសល់ប្រពៃណីអ្វីមួយ អនុស្សាវរីយ៍អ្វីបន្តិច នៃកាសាខ្មែរ។ យើងបានឃើញពួកនេះឈរមើលជាទស្សនិកជនព្រងើយកន្តើយ និងឥតយល់អ្វី នៅមុខអច្ឆរិយភាពនៃស្ថាបត្យកម្មបុរាណ ឥតដឹងយល់អ្វីទាំងអស់ អំពីអក្សរចារិកលើថ្ម នៃសំណល់ប្រាសាទដ៏ឆ្នើមទាំងនេះ គឺជាបរទេសដូចយើងដែរ ចំពោះមុខមនុស្សដែលបានរស់នៅក្នុងទីនេះមុនខ្លួន ក្នុងជីវិតមួយដែលខ្ពស់ជាង។ គ្មានប្រជាជនណាមួយឡើយ ហើយសឹងតែគ្មានបុគ្គលណាម្នាក់ផង ដែលអាចអួតខ្លួនថាមានពូជអំបូរជាខ្មែរ។ ករណីជាតិខ្មែរនៅអាស៊ី គឺដូចជាករណីជាតិក្រិកនិងរ៉ូម៉ាំងនៅអឺរ៉ុបដែរ។”

“សេចក្តីស្លាប់បានផ្តាច់ជីវិតមនុស្សទាំងឡាយដែរ ក្នុងពេលជាមួយគ្នា ដែលខ្លួនបានផ្តាច់ជីវិតប្រជាជាតិទាំងពួង។ ក៏ប៉ុន្តែមានភូមិ២ ក៏ឆ្ងាយដាច់ស្រយាលក្នុងកម្ពុជា កប់បាត់ក្នុងព្រៃស្រោងធំចូលមិនចុះ ដែលមានបណ្តាជនក្នុងសាសន៍មួយខុសពីសាសន៍កម្ពុជា ហើយដែលនិយាយភាសាប្រាសាទបុរាណលែងពីរពេះអស់ទៅហើយ រយីករយាកអស់ហើយ ប៉ុន្តែដែលគេអាចស្គាល់បានភ្លាមៗ។ តើ

*មនុស្សមួយក្រុមតូចនេះ មានខ្មែរដ៏ឧត្តមជាបុព្វការីឬ? គ្រួសារមួយ ពីរ បី ក៏មិនដឹង ប្រហែលជាបានផុតខ្លួនពីការបំផ្លិចបំផ្លាញ ដែលបានត្រូវធ្វើឡើង កាលពី ៥ ឬ ៦ សតវត្សរ៍មុន ហើយនៅរស់រានមានជីវិត បន្ទាប់ពីបានភៀសខ្លួនទៅនៅទីតំបន់ព្រៃភ្នំ ហើយបន្តពូជរៀងរហូតមក ក្នុងភាពតោកយ៉ាក និងក្នុងភាពអាប់ឱននៃការភ័យខ្លាចជានិច្ចនិរន្តរ៍ៗ តើមនុស្សរបេមរហាមទាំងនេះ ជាកូនអ្នកចំបាំងដ៏ហំ ជាកូននៃសិល្បករដ៏ឧត្តម នៃរាជាណាចក្រដែលរលាយបាត់នោះឬ? ការណ៍នេះអាចពិតដែរៗ ប៉ុន្តែបើដូច្នោះមែន មិនដឹងជាឪពុកខ្លួន ដែលមើលឃើញកូនពីលើឋានសួគ៌ព្រះពុទ្ធនោះ ឈឺចិត្តចុកចាប់ក្នុងខ្លួនយ៉ាងណាទេ! ច្បាស់ជាគាត់ចង់ឲ្យការសំឡាប់រង្គាល (ដែលបានយកជីវិតគាត់នោះ) កុំទុកកូនគាត់ឲ្យនៅសល់ម្នាក់ ជាជាងទុកឲ្យសល់លើដីនូវអនុស្សាវរីយ៍របស់គាត់របៀបនេះ ឲ្យសល់ដំបូន្មានរបៀបនេះ ដល់ប្រជាជនទាំងឡាយណាដែលបោះបង់ខ្លួនចោលៗ”*

*ផលដែលចេញពីការមើលងាយនេះ គឺអាណានិគមបារាំង ឬមូលធននិយមបារាំងវិញត្រូវជាង បានវិនិច្ឆ័យថា កម្ពុជាជាកន្លែងមួយ «មិនសូវឲ្យចំណេញ» ហើយក៏ប្រមូលផ្តុំការខិតខំរបស់ខ្លួនដើម្បីជំរឿនវឌ្ឍនភាពសេដ្ឋកិច្ចនិងវប្បធម៌ ទៅលើវៀតណាមតែមួយៗ ប្រទេសនេះក៏បានទទួលវិជ្ជាស្ថាននិងមន្ទីរស្រាវជ្រាវជាច្រើន រហូតទៅដល់សាកលវិទ្យាល័យទៀត (១៩០៤)ៗ ក្នុងពេលដែលនៅកម្ពុជា គេបានរាប់ឃើញ, នៅឆ្នាំ ១៩៣៩, សិស្សចំនួន ៤ នាក់(!) ក្នុងមធ្យមសិក្សាភាគទី២, ៤ នាក់លើចំនួនបណ្តាជន ៣ លាន! បារាំងបានទៅរហូតដល់មិនព្រមប្រើនិយោជិតខ្មែរ ហើយនាំចូលនូវជនជាតិយួន ដើម្បីប្រើក្នុងរដ្ឋការខ្លួននៅស្រុកខ្មែរៗ ភាគច្រើននៃជនអន្តោប្រវេសន៍យួននេះ បានរស់នៅបន្តពូជរហូតក្នុងប្រទេសយើងៗ មានជនដើមកំណើតយួនជាច្រើននាក់ ដែលកាន់កាប់មុខការសំខាន់ៗក្នុងរដ្ឋការខ្មែរ រហូតដល់ខែមីនា ១៩៧០ (ពេលដែល លន់-នល់ និង សិរិមតៈ សំរេចធ្វើការបោសសំអាតមួយៗ បេសកកម្មបានត្រូវប្រគល់ឲ្យ លន់-ណុន ប្អូនរបស់ លន់-នល់ ហើយកិច្ចការនេះក៏ក្លាយទៅជាការកាប់សំឡាប់ៗ ក្រោយមក ក្នុងពេលដែលទាហានយួនខាងជើង ធ្វើឲ្យកម្ពុជាក្លាយទៅជារងើកភ្លើង កងទាហានយួនខាងត្បូងបានយកការសងសឹកជាបេសកកម្មរបស់ខ្លួន៖ ក្នុងរយៈពេលតែ ២-៣ ថ្ងៃប៉ុណ្ណោះ ភូមិភាគ «ចំពុះទា, ស្វាយរៀង» បានប្រែទៅជាភ្លើងអវចីចំពោះបងប្អូនយើងនៅទីនោះៗ*

(៦) *នេះមិនមែនជាការគំរាមចោលទេៗ អំណាចអាណានិគមប្រើប្រាស់ការបំបរបង់ ជាអាវុធចិត្តសាស្ត្រ សំរាប់បំបាក់ការប៉ុនប៉ងបះបោរទាំងពួង ដូចដែលយើងនឹងឃើញក្នុងពេលខាងមុខៗ*

(៧) *«ខ្ញុំគេ» សម័យនោះ (រហូតមកដល់ពេលថ្មីៗ នេះទៀត) ជាសម្បត្តិដាច់ថ្លៃរបស់ម្ចាស់ៗ គួរឲ្យខ្ពើមជាងទាសភាពអាមេរិកាំង ដែលយកមនុស្សខ្មៅពេញវ័យមកឲ្យដាំកប្បាស, ទាសភាពខ្មែរប្រើប្រាស់តាំងពីកូនក្មេង ដែលសង្គមមានអារិយធម៌ត្រូវការពារ ដោយឲ្យរៀនសូត្រៗ គួរឲ្យហួសចិត្តទៅទៀត ទាសភាពខ្មែរ ដែលបារាំងប៉ុនប៉ងលប់បំបាត់តាំងពីក្នុងរាជ្យស្តេចនរោត្តម បានឡើងដល់កំរិតមហាអស្ចារ្យ ក្នុងពេលដែល «អ្នកស្នេហាជាតិ» មួយក្តាប់បានយកប្រជាជនឯងធ្វើជា «ខ្ញុំរដ្ឋ»ៗ*

(៨) *ការបង្កើតនេះមានតែឈ្មោះទេ ព្រោះថាទាល់តែ ១០ ឆ្នាំក្រោយមក ទើបអង្គការផ្សេងៗ នៃសហភាពចាប់ដើរមែនទែនក្នុងរដ្ឋការនៃ ប៉ូល ឌូមែរៗ «រដ្ឋធានី» បានត្រូវតាំងនៅហាណូយៗ កូសាំងស៊ីន ដែលគេសំគាល់ជាអាណានិគមពេញទី (កូឡូនី) មានលក្ខន្តិកៈពិសេស ហើយនៅក្រោមការត្រួតត្រានៃ «គូវែន័រ» ម្នាក់ៗ កម្ពុជា អណ្ណាម និង តុងកឹង នៅក្រោមការចាត់ចែងនៃ «រ៉េស៊ីដង់ ស៊ុប៉េរីយ័រ» (ស្តេចទាំងឡាយ មានអំណាចដែលមានតែឈ្មោះ) ដែលភារៈធំគឺធ្វើបន្តិចម្តងៗ នូវការកែទំរង់រចនា*

*សម្ព័ន្ធរដ្ឋបាលនៃប្រទេសក្រោមអំណាច។ ក្រមច្បាប់ផ្សេងៗ បានត្រូវចម្លងតាមគំរូបារាំង។ ការបែងចែករដ្ឋបាល : ខេត្ត ស្រុក ខ័ណ្ឌ ឃុំ បានត្រូវប្រើប្រាស់រហូតដល់សព្វថ្ងៃ (ក្រោយមក បំណែង ខ័ណ្ឌ បានត្រូវលប់ចោលវិញ, ឧ. ខ័ណ្ឌ ពោធិចិនតុង)។*

(៩) *នៅសតវត្សរ៍ទី១៧ ល្ងីទី១៤ ស្ដេចព្រះអាទិត្យបារាំង មិនទាក់ចិត្តនឹងឥណ្ឌូចិនទេ ប៉ុន្តែនឹងប្រទេសសៀម។ តាំងពីឆ្នាំ ១៦៨៥ សៀមចុះសន្ធិសញ្ញាទី១ ខាងពាណិជ្ជកម្មជាមួយបារាំង។ ៣ ឆ្នាំក្រោយមក ជនជាតិក្រិកម្នាក់ឈ្មោះ កុងស្តង់ទីន ហ្វូលកុន ដែលធ្វើការជាកម្មករ (ម៉ាតឺឡូ) លើសំពៅបារាំងមួយ ឡើងបុណ្យសក្តិជាទីប្រឹក្សារបស់ស្ដេចសៀម។ ដោយមានអ្នកផ្សាយសាសនាជាតិបារាំងបីនាក់ជួយផង ហ្វូលកុនធ្វើការរកអ្នកឃុបឃិត ដើម្បីយកប្រទេសសៀមចូលក្រោមអំណាចបារាំង។ ប៉ុន្តែក្រោយបន្តិចមក (១៦៨៨) ការ «បដិវត្តន៍វាំង» មួយរំលំស្ដេចសៀម សម្លាប់ក្រិកហ្វូលកុន ហើយដេញបារាំងចេញ។ រដ្ឋប្រហារនេះ បានបញ្ចប់ឥទ្ធិពលរបស់បារាំងលើប្រទេសសៀម។*

*មួយសតវត្សរ៍កន្លះក្រោយមក នៅឆ្នាំ ១៨២៦ ស្ដេចសៀមរាមាទី៣ ចុះសន្ធិសញ្ញាពាណិជ្ជកម្មទី១ ជាមួយប្រទេសអង់គ្លេស។ ក្នុងឆ្នាំដដែល កងទាហានអង់គ្លេសចាប់ផ្ដើមចូលកាន់កាប់ប្រទេសម៉ាឡេស៊ី និងភូមា។ ថ្ងៃ ១៥ មករា ១៨៩៦ សន្ធិសញ្ញាបារាំង-អង់គ្លេសមួយ (កិច្ចសន្យាក្រុងឡុងដ៍) បែងចែកប្រទេសសៀមជាបីភូមិភាគ : ខាងកើត នៅក្រោមឥទ្ធិពលបារាំង ខាងលិច (ជាមួយជ្រោយម៉ាឡេស៊ី) ទៅជាសម្បត្តិអង់គ្លេស ចំណែកភូមិភាគកណ្ដាល គឺវាលតាមដងទន្លេម៉ែណាមចៅផ្រាយ៉ា ទៅជាមណ្ឌលអព្យាក្រឹត (ដូច្នេះ ប្រទេសសៀមមិនមែនមិនដែលបានត្រូវបរទេសត្រួតត្រាទេ គ្រាន់តែមិនពេញលើប្រទេសទាំងមូលប៉ុណ្ណោះ) ការតម្រែតម្រូវគ្នាសាឡើងវិញ រវាងអង់គ្លេសនិងបារាំង លើការចែកទឹកដីនេះ ចេញជាសន្ធិសញ្ញាឆ្នាំ ១៩០២ ១៩០៤ និង ១៩០៧។*

(១០) *ចេញពីឧដុង្គនៅខែមិថុនា ១៨៦៦ បេសកកម្ម ឌូដាដឺឡាហ្គ្រេ ដែលទៅស្វែងរកពិនិត្យទន្លេមេគង្គ បានឲ្យរកស្គាល់ថា ផ្លូវទឹកតែមួយដែលនាំពីសមុទ្រទៅក្នុងប្រទេសចិនខាងត្បូង គឺទន្លេក្រហម។ ដូច្នេះមែន ចាប់ពីក្រុងក្រចេះទៅ ចរាចរណ៍តាមទន្លេមេគង្គលែងអាចធ្វើបាន ពីព្រោះមានទឹកជ្រោះ និងទឹកធ្លាក់ជាច្រើន (ជាពិសេស ទឹកធ្លាក់ដ៏ល្អវិសាលនៅខូន លើព្រំដែនខ្មែរ-លាវ)។*

(១១) *រដ្ឋមន្ត្រីទីមួយថៃ ភិបុលសង្គ្រាម ដូរឈ្មោះប្រទេសសៀមជាប្រទេសថៃ ព្រោះមានបំណងចក្រពត្តិនិយម។ សាសន៍ថៃមាននៅក្នុងប្រទេសសៀម លាវ (ឡាវជាសាច់ឈាមថៃដែរ) វៀតណាម (កន្ទ្រាញ) និងចិន (យុនណាន) ចំណែកឯវប្បធម៌ថៃមាននៅក្នុង... ស្រុកខ្មែរ។ ពេលដែលជប៉ុនកំពុងលុកលុយចិន និងគំរាមបារាំងនៅឥណ្ឌូចិន ក្នុងឆ្នាំ ១៩៣៩ នោះ ភិបុលមានគំនិតប៉ុនប៉ងប្រមូល «ដី» ថៃទាំងនោះ។ ក្រោយមក សារិតថាណារ៉ាត់ បានត្រូវអ្នកពិតមានបស្ចឹមប្រទេសម្នាក់សួរថា តើចង់ផ្លាស់ឈ្មោះប្រទេសថៃជាប្រទេសសៀមវិញទេ? ចម្លើយសារិត : ខ្ញុំមិនដឹងថាលោកចង់និយាយអំពីអ្វីទេ។*

(១២) *បារាំងបានយល់ដល់ការក័ន្តប្រឡូរបស់ខ្លួន ដែលបានឲ្យទៅសៀមនូវខេត្តខ្មែរដ៏សម្បូណស្រូវទាំង៣ នេះ (៧០ ០០០ គម.ក្រឡា ក្នុងកាលនោះ)។ ក្នុងកិច្ចការរកប្រមូលទឹកដីមកវិញ នាយទាហាន ២ នាក់ ខាងភាគីបារាំង-ខ្មែរ ដឹកនាំគណកម្មការបោះបង្គោលព្រំដែន : បារាំងម្នាក់ វរសេនីយត្រី ប៉ែណា (បានសរសេរសៀវភៅមួយអំពីរឿងនេះ សៀវភៅដែលពិបាករកអានណាស់ ព្រោះគេលាក់) និងខ្មែរម្នាក់ អនុសេនីយឯក អ៊ុម។ ព្រំប្រទល់ខាងលិចនៃកម្ពុជាសព្វថ្ងៃ ក៏បានមានរូបរាងឡើងដោយយ៉ាងនេះឯង (១៩០៧)។*

ឆ្នាំ ១៩០៧ អាចឲ្យគេចាត់ទុកជាឆ្នាំបង្ហើយជោគជ័យ នៃអាណានិគមកម្មរបស់បារាំងលើឥណ្ឌូចិន ដែលយើងអាចសរុបដំណាក់ការ ដូចនៅតារាងក្នុងទំព័របន្ទាប់។

(១៣) ខែកញ្ញា១៩០៨ ព្រះបាទស៊ីសុវត្ថិទៅអតីតមហារាជធានីអង្គរ ដើម្បីទទួលយកខេត្តទាំងបីមកវិញ ដែលបាននៅក្រោមសៀម ៤០ ឆ្នាំ។ ដើម្បីរំលឹកព្រឹត្តិការណ៍នេះ ទីឋានអនុស្សាវរីយ៍មួយបានត្រូវលើកឡើងក្នុងទីក្រុងភ្នំពេញ រាជធានីថ្មី។ អ្នកផងតែងឃើញ, គង់លើចង្កេះភ្នំដូនពេញ ហើយសម្ងឹងទៅវិមានឯករាជ្យ, រូបសំណាកពីសរីទ្ធនិងតាមទំហំធម្មជាតិនៃស្តេចស៊ីសុវត្ថិ នៅចន្លោះផ្ទាំងសិលាពីរដែលចែងពីការបានមកវិញនូវខេត្តបីនេះ។ ផ្ទាំងសិលាមួយចំហៀង បានត្រូវគាស់យកមកឲ្យគេវាយថ្ងៃនៅហុងកុង ដោយឧត្តមសេនីយម្នាក់នៃសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)។

| ឆ្នាំ | ទឹកដី | សន្ធិសញ្ញា, សាម៉ីជន |
|---|---|---|
| ១៨៦២-៦៤ | ពាក់កណ្តាល កូសាំងស៊ីន ខាងជើង | ទីឌឹក- បោណ្ណា |
| ១៨៦៣ | កម្ពុជា | នរោត្តម, ដឺ ឡាក្រង់ឌ្យែរ |
| ១៨៦៧ | ពាក់កណ្តាល កូសាំងស៊ីន បង្ហើយ | ទីឌឹក, ដឺ ឡាក្រង់ដ្យែរ |
| ១៨៦៧ | (បារាំងឲ្យខេត្តបាត់ដំបង ស៊ីសុផុន សៀមរាប ទន្លេរពៅ និង មូ្លព្រៃ ទៅប្រទេសសៀម) | បារាំង-សៀម, (នរោត្តម) |
| ១៨៨៣-៨៥ | អណ្ណាម រួចមក តុងកឹង | រដ្ឋាភិបាលយួន ក្រោយទីឌឹក រួចមក តៀនទ្សិន (បារាំង-ចិន) |
| ១៨៩៣ | លាវ | អ៊ុនខាំ, បារាំង-សៀម |
| ១៩០២ | ខេត្តទន្លេរពៅ និង មូ្លព្រៃ | បារាំងសៀម, (នរោត្តម) |
| ១៩០៧ | កម្ពុជា បង្ហើយ (បាត់ដំបង ស៊ីសុផុន និង សៀមរាប) | បារាំង-សៀម, (ស៊ីសុវត្ថិ) |
| ៤៥ ឆ្នាំ | ឥណ្ឌូចិន | |

តារាង : ដំណាក់ការ នៃ អាណានិគមកម្ម

# ភាគទី ៤

## ពី

# សហភាពឥណ្ឌូចិន

## ទៅ

# សហព័ន្ធឥណ្ឌូចិន

*ប្រវត្តិសាស្ត្រជាផ្នូរកប់ការភ័ន្តច្រឡំនៃមនុស្ស។*

*(ប៉ូលវ៉ាឡេរី, ទស្សនវិទូ)*

*ដូច្នេះចូរយើងកុំខ្ចីមនឹងគាស់កាយមើល។*

*ព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧) ឡើងសោយរាជ្យដំណាលគ្នានឹងព្រឹត្តិការណ៍មួយយ៉ាងសំខាន់ គឺជ័យជំនះនៃជប៉ុនក្នុងសង្គ្រាមជប៉ុន-រុស្ស៊ី (១៩០៤-១៩០៥)។ ព្រឹត្តិការណ៍សំខាន់មួយទៀត ដែលកើតឡើងក្នុងរជ្ជកាលស៊ីសុវត្ថិនេះដែរ គឺការបដិវត្តន៍ចិននៃឆ្នាំ ១៩១១ (សាធារណរដ្ឋនៃ ស៊ុន-យ៉ាត សេន)។*

*ជ័យជំនះនៃជប៉ុនបានធ្វើឲ្យបាត់នូវជំនឿថា ជាតិស្បែកសពូកែលើសលុបពុំចេះចាញ់គេ។ ជ័យជំនះនេះបានធ្វើឲ្យអ្នកចេះដឹងយួនមានប្រតិកម្មភ្លាម ៖ អ្នកអក្សរសាស្ត្រឈ្មោះ ផាន់ បួយចូវ, ដោយមានម្ចាស់ គួង ដេ ដែលជាញាតិនៃអធិរាជ យ៉ា ឡុង និងអ្នកអក្សរសាស្ត្រ ៣-៤ នាក់ទៀតជូនទៅផង, បានទៅដល់ប្រទេសជប៉ុន ហើយក៏ចាប់បំបះបំបោរយួនពីទីនោះ។ ចាប់តាំងពីឆ្នាំ ១៩១២ ដែលគណបក្ស គួ មិន តាង (ចិនជាតិនិយម) កើតឡើង, ប្រទេសចិនក៏ទៅជាទីជំរកមួយនៃអ្នកជាតិនិយមយួនដែរ។ ក្នុងពេលសង្គ្រាមលោកឆ្នាំ ១៩១៤-១៩១៨ ពលទាហាន ១៣០ ០០០ នាក់ ដែលជាជនជាតិរបស់ប្រទេសទាំង៣ នៃឥណ្ឌូចិន បានត្រូវគេបញ្ជូនទៅអឺរ៉ុប (ក្នុងនោះមានខ្មែរយើងច្រើនកងវរសេនាតូច ដែលគេដាក់ទៅសមរភូមិមុខ, ខ្សែទី១[១]។ ទាញចេញពីពិភពសក្តិភូមិរបស់ខ្លួន ដាក់ចូលទៅក្នុងពិភពលោកមួយទៀត, អ្នកទាំងនោះបានជួបប្រទះនឹងគំនិតថ្មីៗទៀត៖ ប្រជាធិបតេយ្យ, សហជីព, សង្គមនិយម, កុម្មុយនិស្ត, មូលធននិយម និងការប្រកាន់ពណ៌សម្បុរ។ ការ «ប៉ះពាល់» នឹងបស្ចិមប្រទេសនេះ បានធ្វើឲ្យកើតឡើងនូវគណបក្សនយោបាយក្នុងស្រុកយួន ហើយគណបក្សទាំងនេះ ជាស្នូលនៃគំនិតប្រឆាំងនឹងការកាន់កាប់ត្រួតត្រានៃ* ***បារាំង**។*

*ប៉ុន្តែក្នុងប្រទេសកម្ពុជា ស្ថានការណ៍គឺម្យ៉ាងទៅវិញ។ ពេលដែលមកដល់ស្រុកខ្មែរ បារាំងបានឃើញប្រទេសមួយដែលហិនហោច, និងសំណល់នៃប្រជាជាតិមួយដែលទ្រុឌទ្រោម ព្រោះតែសង្គ្រាម និងការជិះជាន់ពីបរទេសជាប់រាប់សតវត្សរ៍។ សល់ពីស្តេចដែលមានអំណាចដូចព្រះអាទិទេព[២] និងសល់ពីប្រជាជនដែលរស់នៅជុំវិញភិក្ខុសង្ឃនិងអាចារ្យ, ចន្លោះសង្គមនៅប្រហោងទទេ ឥតមានខ្មែរបិទបំពេញ ៖ របរនេសាទ, របរចិញ្ចឹមសត្វ, ការរកស៊ីធ្វើជាង នៅក្នុងកណ្តាប់ដៃយួន, ចំណែកការធ្វើជំនួញ នៅក្នុងរង្វង់ក្រុចកចិន។ ការទំសាកល្បងបញ្ចូលខ្លួនក្នុងសង្គមខ្មែរ ពីសំណាក់អ្នកអន្តោប្រវេសន៍ទាំងនោះ[៣] បានធ្វើឲ្យមានអាពាហ៍ពិពាហ៍ចិន-ខ្មែរ ជាច្រើន។ ពួកកូនកាត់ដែលកើតឡើងជាបន្តបន្ទាប់មកនោះ បានត្រូវអ្នកនិពន្ធបារាំងឈ្មោះ ហ្វីលីព ដឺវីល្លេ កត់សំគាល់ថាជាជន «ពូកែ និងស្វាហាប់»។ ដោយយល់ឃើញដូច្នេះដែរ ទើបរដ្ឋការអាណានិគម, ដែលពីមុនបាននាំចូលមកស្រុកខ្មែរនូវអ្នកធ្វើការជាតិយួន, ចាប់រើសយកកូនកាត់ចិន-ខ្មែរ (តិចឬច្រើនតំណ) មកធ្វើជាក្របខ័ណ្ឌរដ្ឋការ។*

*ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិនិងមុនីវង្ស (១៩២៧-១៩៤១)[៤] ប្រទេសកម្ពុជាបានទទួលការកែទំរង់ជាច្រើន[៥] ដែលធ្វើឡើងដើម្បីបំបាត់បន្តិចម្តងៗ នូវស្ថាប័នចាស់នៃរដ្ឋ។*

*-នៅឆ្នាំ ១៩១០ ដើម្បីជំរុញការអប់រំឡើងវិញ ព្រះចៅស៊ីសុវត្ថិបញ្ជាឲ្យបង្រៀនភាសាខ្មែរ ដល់ក្មេងអាយុ ៨ ឆ្នាំឡើងទៅ ក្នុងគ្រប់ទីវត្តអារាមទាំងអស់។ យើងយល់ណាស់នូវកាយវិការ ព្រះស៊ីសុវត្ថិ ដែលបង្ហាញនូវបំណងត្រឹមត្រូវនៃប្រជាជាតិទាំងអស់ ដែលចង់ចេះដឹងនិងចំរុងចំរើនក្នុងភាសារបស់ខ្លួន។ ប៉ុន្តែស្របគ្នានឹងកាយវិការនេះ រដ្ឋការអាណានិគមក៏បានជួយជាច្រើនដែរ ដល់ការរីកចំរើននៃសាលា ដែលគេបានហៅថា «សាលារាជការ» ដែលគេបង្រៀនភាសាបារាំង និងមុខវិជ្ជាច្រើនទៀត ដែលឥតបង្រៀននៅសាលា «វត្ត»។ សាលា «រាជការ» ទាំងនោះ មាននៅតែក្នុងរាជធានី និងទីប្រជុំជនធំៗ ហើយកូនសិស្សស្ទើរតែជាកូនអ្នកមាន-អ្នកធំទាំងអស់ គឺថាចេញមកពីវណ្ណៈធូរស្រួល។ លទ្ធផលនៃការមានសាលាពីរយ៉ាងនេះ យើងបានឃើញគ្រប់គ្នាមកហើយ ៖ ប្រទេសទៅជាមានសង្គម២ ដែលខុសពីគ្នាទាំងស្រុង[៦]។ សង្គមមួយជាសង្គមនៃអ្នក «លូតលាស់» ដែលការអប់រំនិងចំណេះវិជ្ជាខ្លួនអនុញ្ញាតឲ្យប៉ះពាល់នឹងពិភពលោកខាងក្រៅ ហើយដើរទៅមុខតាមពិ*

*កពក្រៅនោះៗ អ្នកទាំងនេះខំប្រើគ្រប់មធ្យោបាយ ដើម្បីធ្វើជីវិតខ្លួនឲ្យទាន់សម័យៗ សង្គមមួយទៀត ជាសង្គម «អ្នកល្ងង់ខ្លៅ» ដែលជាគជាំយ៉ាងជ្រៅនឹងពុទ្ធសាសនា ហើយចូលចិត្តរស់នៅក្នុងពិភពលោកមួយពោរពេញទៅដោយជំនឿលើហេតុមហាអស្ចារ្យ ហើយដែលការគោរពទំនៀមទំលាប់ បានក្លាយទៅជាការនៅស្ងៀមមិនកំរើកៗ*

*- ក្នុងឆ្នាំ ១៩១២, «គូវែន័រ ហ្សេណេរ៉ាល់» អាល់បែរ សារ៉ូ បង្កើត «សភាឲ្យយោបល់អាយ» (Assemblée consultative indigéne) ដែលមានសមាជិកជ្រើសតាំង (១ភាគ៨) និងសមាជិកជាប់ឆ្នោត (អ្នកដែលគេឲ្យមានអំណាចបោះឆ្នោតរើសសភានេះ មានចំនួនតិចណាស់)ៗ សភាឲ្យយោបល់នោះ គ្រាន់តែជាការសាកល្បងមើលទេ ព្រោះមួយឆ្នាំធ្វើការតែ ១០ ថ្ងៃៗ*

*-នៅឆ្នាំ ១៩១៥ មុខងារជាចៅហ្វាយខេត្តបានត្រូវគេបង្កើតឲ្យមានឡើងសំរាប់ខ្មែរៗ ពីមុន ខេត្តត្រួតដោយបារាំងដែលមានងារជា «រ៉េស៊ីដង់»ៗ*

*-ក្នុងឆ្នាំ ១៩២០ សាលាបាលីជាន់ខ្ពស់បានកើតឡើងនៅភ្នំពេញ*[៧]*ៗ*

*-នៅឆ្នាំ ១៩២២ ទីប្រឹក្សាច្បាប់បារាំងម្នាក់ជួយណែនាំកិច្ចការបង្កើតសាលាឧក្រិដ្ឋ (នៅភ្នំពេញ) សំរាប់ជំនុំជំរះបទឧក្រិដ្ឋក្នុងប្រទេសទាំងមូលៗ*

*-ក្នុងឆ្នាំ ១៩៣០ (រាជ្យព្រះបាទមុនីវង្ស) ពុទ្ធសាសនបណ្ឌិត្យ បានកើតឡើងនៅភ្នំពេញ ដើម្បីបង្ហាត់គ្រូបង្រៀនសាលាបាលី (អាចារ្យសាលាបាលី)ៗ*

*-នៅឆ្នាំ ១៩៣៧, ប្រទេសយើងមានសាលាចំនួន ៩៥២ (ក្នុងនោះ ៨១៣ ជាសាលាវត្ត), សាលាអនុវត្តន៍ឧស្សាហកម្មមួយ, សាលាសិល្បៈខ្មែរមួយ និងសាលាច្បាប់និងរដ្ឋបាលមួយ*[៨]*ៗ*

*ចំណែកឯវឌ្ឍនភាពខាងសេដ្ឋកិច្ចវិញ គេឃើញមានការរីកចំរើននៃកសិកម្ម*[៩] *៖ ស្រូវ, ដើមកៅស៊ូ*[១០]*, ពោត, ម្រេច ។ល។ ការកើនឡើងនេះ គឺទាំងខាងទំហំផ្ទៃដាំ ទាំងខាងចំនួនផលិតផលតាមផ្ទៃដាំៗ ប៉ុន្តែ គេត្រូវតែទទួលស្គាល់ការមួយនេះ ៖ បើការកែទំរង់នៃសិក្សាធិការធ្វើឲ្យមានការបែកវណ្ណៈក្នុងសង្គម, វឌ្ឍនភាពសេដ្ឋកិច្ចធ្វើឲ្យចំរើនមែនទែន តែជនបរទេសមួយក្តាប់ ជាតិបារាំង, ចិន និងយួន ដែលផ្ញើលុយខ្លួនទៅប៉ារីស, ហុងកុង, សិង្ហបុរី និងព្រៃនគរៗ*

*គឺនៅក្នុងកាលៈទេសៈ (សង្គមសាស្ត្រ) នោះហើយ ដែលប្រទេសកម្ពុជាឈានជើងចូលមកក្នុង (ប្រវត្តិសាស្ត្រ) ពិភពលោកសព្វថ្ងៃៗ បើសង្គ្រាមលោកលើកទី១ ពុំបានធ្វើឲ្យអាណាចក្រអាណានិគមបារាំងប្រែប្រួលទេ សង្គ្រាមលោកលើកទី២ ជាសញ្ញានៃការចាប់ផ្តើមរលំនៃអាណាចក្រនោះៗ ឆ្លៀតឱកាសដែលបារាំងចុះអន់ខ្សោយ ដោយការលុកលុយអាល្លឺម៉ង់, ប្រទេសទាំងបីនៃឥណ្ឌូចិនយល់ឃើញថា ពេលវេលាមកដល់ហើយ ដើម្បីរកឯករាជ្យរៀងខ្លួនៗ*

*តទៅនេះ យើងត្រូវបែកព្រឹត្តិការណ៍ដែលកើតមានឡើងជាពីរចំពូក គឺ ៖*

*ក) **រឿងក្រៅប្រទេស**, គឺព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើង ដោយមកពីនយោបាយបរទេស, ប៉ុន្តែដែលមានឥទ្ធិពលយ៉ាងផ្ទាល់ មកលើប្រទេសកម្ពុជា (ហើយដែលនឹងថែងនៅទំព័រ ៣៦)*

*ខ) **រឿងក្នុងប្រទេស**, គឺការវិវត្តន៍នយោបាយក្នុងប្រទេសកម្ពុជា ដែលមានជាអាទិ៍ ទំនាក់ទំនងជាមួយបារាំង នឹងការសាកល្បងរបបប្រជាធិបតេយ្យមួយ តាមរយៈគណបក្សនយោបាយ (ថែងនៅទំព័រ ៥១)*

---------------------------

# អធិប្បាយ

(១) ដើម្បីរំលឹក និង ជាកិត្តិយសដល់ពលទាហានខ្មែរដែលបានស្លាប់ដើម្បីប្រទេសបារាំង ក្នុងសង្គ្រាមលោក ១៩១៤-១៨ នោះ ទីឋានមរណសញ្ញាមួយ បានត្រូវលើកឡើងក្នុងក្រុងភ្នំពេញ ក្បែរកីឡាឋាន «ស្តាដឡូប៊ែ» ហើយដែលមហាជនហៅថា «រូបពីរ» (រូបសំណាកបារាំងម្នាក់ និងខ្មែរម្នាក់)។ អ្នកផងតែងថា ខ្មែរនោះគឺ តាម៉ែន ដែលជានាយទាហានបញ្ជាកងពលទាំងនោះ។

(២) ចំពោះជនធម្មតាក្នុងប្រទេសកម្ពុជាយើង ពាក្យ «ស្តេច» និង «ជាតិ» មានន័យដូចគ្នា។ ក្បត់ស្តេច គឺក្បត់ជាតិហើយ។ គេដូចជាចាំថា អ្នកនយោបាយនៃសង្គមរាស្ត្រនិយម បានបំប៉ោងការយល់ឃើញនេះឲ្យកាន់តែខ្លាំងឡើង ដើម្បីពង្រឹងអំណាចខ្លួន។ តាមទំនៀមទំលាប់ដែលជាកេរ្តិ៍មរតកនៃព្រហ្មញ្ញសា-សនា ខ្មែរគ្រប់រូប លើកលែងតែភិក្ខុ ត្រូវលុតជង្គង់ក្រាបនៅមុខស្តេច។ ប៉ុន្តែក្នុងសម័យនេះ ការយល់ឃើញអំពីស្តេច លំអៀងទៅតាមពុទ្ធសាសនា។ បានឡើងសោយរាជ្យជាស្តេច គឺជារង្វាន់ផុតលេខចំពោះមនុស្សលោក ដែលកាលពីជាតិមុនបានកសាងតែអំពើល្អ ហើយកាន់យ៉ាងខ្ជាប់ខ្ជួននូវសីលនៃព្រះពុទ្ធ។ ស្តេចសឹងតែដូចអាទិទេព ដែលគេពុំអាចវិនិច្ឆ័យកាត់ទោស កាយវិការនិងអំពើបានឡើយ។ ព្រោះតែការយល់ឃើញនេះ ប្រជាជនខ្មែរពីមុន ជាប្រជាជនដែលចាំតែទទួលសុខ ទទួលទុក្ខ ទទួលបញ្ជា.....។

(៣) អ្នកប្រវត្តិសាស្ត្រ ដែលមកពិនិត្យរឿងហេតុនៅអាស៊ីភាគអគ្នេយ៍ ហើយដែលភ្លេចគិតទៅដល់កត្តាជាតិសាសន៍នៃមនុស្សក្នុងសង្គម ច្បាស់ជាមិនយល់ដោយត្រឹមត្រូវឡើយ ថាតើប្រទេសដែលខ្លួនពិនិត្យនេះនៅក្នុងកាលៈទេសៈអ្វី។ ហេតុដែលធ្វើឲ្យមានជនជាតិចិនចាកចេញពីស្រុកខ្លួន មកនៅស្រុកឯទៀតនៃអាស៊ីភាគអគ្នេយ៍ មាន២ ធំៗគឺ ចំបាំងរវាងគ្នាឯងក្នុងស្រុក និងការណ៍ដែលមានបណ្តាជនច្រើនហួស។ ភាគច្រើននៃអ្នកអន្តោប្រវេសន៍ទាំងនោះ មកពីខេត្ត៣ នៃប្រទេសចិនខាងត្បូង គឺក្វាងស៊ីក្វាងទុង និង ហ្វ៊ូគាន។ ប៉ុន្តែចិនទាំងនោះនិយាយទេសភាសាជាច្រើន ដែលគេចែកជា ៥ ក្រុមធំ គឺទេសភាសាហុកគាន ហាក់កា ហៃណាន់ កន្តាំង និងតេវជីវ។ ក្នុងឆ្នាំ ១៩៧០ ចិននៅស្រុកខ្មែរមានចំនួន ៤៣៥ ពាន់នាក់ គឺថា ៦,៤ % នៃបណ្តាជនស្រុកខ្មែរ ដែលមានចំនួន ៦ ៧០១ ០០០ នាក់ (តាមសៀវភៅរបស់ សូមើស ហាយឌូស)។ ៣០ % នៃចិនស្រុកខ្មែរ រស់នៅឯភ្នំពេញ។ ដែលហៅថាចិនស្រុកខ្មែរ គឺចិនអន្តោប្រវេសន៍ថ្មី និងជនដែលកើតពីឪពុកម្តាយចិន ហើយនិយាយនិងកាន់ទំនៀមទំលាប់ចិន។ នៅឆ្នាំ ១៩៧០ ពួកភាគច្រើនគឺពួកតេវជីវ ចុះមកគឺពួកកន្តាំង។

ពិបាកនឹងថាដែរ តើចិនចាប់ចូលមកនៅប្រទេសកម្ពុជាតាំងពីសម័យណា។ ប៉ុន្តែគេដឹងថា ចិនចាប់ចូលមកក្នុងឆាកនយោបាយខ្មែរ តាំងពីសតវត្សរ៍ទី ១៧។ ស្តេចបរមរាជាទី៤ (១៦៦០-១៦៧២) បានត្រូវស្តេចយួនបង្ខំឲ្យចុះសន្ធិសញ្ញាមួយ ព្រមទទួលឲ្យជនជាតិយួន និងជនជាតិចិន ៣ ០០០ នាក់ចូលមកនៅស្រុកខ្មែរ។ ជនភៀសខ្លួនចិននោះ ជាបក្សពួករាជវង្សមិង ដែលបានត្រូវរាជវង្សតាន់រំលំ។ គឺក្នុងពពួកចិនទាំងនោះហើយ ដែលអង្គនន់បានជ្រើសរើសទាហានស៊ីឈ្នួល ដើម្បីដណ្តើមបល្ល័ង្កពីបងប្អូនជីដូនមួយខ្លួន ស្តេចជ័យជេដ្ឋាទី៤ (អង្គសូរ)។ នៅឆ្នាំ ១៦៨៩ ជាមួយនឹងទាហានចិនស៊ីឈ្នួលខ្លួន និងទ័ពយួនដែលមកជួយអង្គនន់ដណ្តើមបានក្រុងភ្នំពេញ។ ជ័យជេដ្ឋាទី៤ ដែលរត់ទៅនៅកំពង់

ហ្វង់ ក៏ចុះសន្ធិសញ្ញាមួយទៀតជាមួយយួន ទទួលស្គាល់យួនជាចៅហ្វាយ។ នៅឆ្នាំ ១៧១០ គឺចិនម្នាក់ទៀត ឈ្មោះម៉ាក់គឺ ដែលខ្មែរឲ្យទទួលបន្ទុកការពារភូមិភាគពាម (សព្វថ្ងៃហាទៀង) ក្រមួនស (រ៉ាចស្យា) និងកោះត្រល់។ អ្នកពីងគឺអន្ត់អែម (កូនប្រសាស្តេចជ័យជេដ្ឋាទី៤) ដែលឈ្មោះគ្នានឹងជម្មោរាជា (កូនបង្កើតជ័យជេដ្ឋាទី៤) ដែលមានសៀមជាអ្នកគាំទ្រ។ ដោយហេតុនេះ ភូមិភាគឆ្នេរសមុទ្រទាំងនោះបាននៅក្រោមអំណាចម៉ាក់គឺ និងផៅសន្តានរបស់ខ្លួន រហូតដល់ឆ្នាំ ១៨៦៧ (១៥៧ឆ្នាំ!) ហើយចិននោះធ្វើការឲ្យយួន។

ចិនស្រុកខ្មែរ តែងតែបានទទួលអភ័យឯកសិទ្ធិពិសេស។ អ្នកដែលកើតនៅប្រទេសកម្ពុជា ហើយកាន់យកទំនៀមទំលាប់ប្រទេស គឺទៅជាពលរដ្ឋខ្មែរតែម្តង។ អ្នកដែលមិនព្រមបញ្ចូលខ្លួនក្នុងសង្គមខ្មែរ នៅក្រោមអំណាចចិនម្នាក់ដែលមានងារជា «ចៅទា» ហើយដែលតែងតាំងឡើងដោយស្តេចខ្មែរ ហើយចិនទាំងនោះ រាជការមិនអាចកែនយកទៅប្រើបានទេ (ក្រោមរបបអាណានិគម)។ ការអាណាព្យាបាលបារាំងបានបើកយុគនៃអាពាហ៍ពិពាហ៍ចិន-ខ្មែរ។ កត្តាធំជាដើមហេតុនៃអាពាហ៍ពិពាហ៍ (អន្តរសាសន៍) នេះ មាន២ : ការស្វាហាប់នៃសាសន៍ចិន ដែលធ្វើឲ្យចិនមាន និងការខ្វះស្រីចិន។ នៅឆ្នាំ ១៩២១ អ្នកនិពន្ធ ដាវិដ ស្តែងប៊ែក ឲ្យចំនួនកូនកាត់ចិន-ខ្មែរ ជាប្រហែល ៦៨ ០០០ នាក់។ ក្រោយពី ប្រទេសកម្ពុជាបានឯករាជ្យ ចំនួនអាពាហ៍ពិពាហ៍ប្រុសចិន-ស្រីខ្មែរ បានថយច្រើនណាស់។ ប៉ុន្តែ ក្នុងគោលបំណងនឹងពង្រីកអំណាចសេដ្ឋកិច្ចខ្លួន ចិនស្រុកខ្មែរប្រើចំណងគ្រួសារដើម្បីបំពុករំលួយរដ្ឋការខ្មែរ ដោយកម្វាអាពាហ៍ពិពាហ៍ស្រីចិន-ប្រុសខ្មែរ។ ចំពោះអ្នកសង្កេតការណ៍បរទេសជាច្រើន ការអន្តោប្រវេសន៍ចិន បាននាំមកឲ្យសង្គមខ្មែរនូវចរន្តស្វាហាប់ ហើយទោះបីប្រទេសកម្ពុជាមិនមែនជាសម្បត្តិរបស់ចិនសុទ្ធ ក៏កម្ពុជាជាសម្បត្តិដាច់មុខរបស់ខ្មែរកាត់ចិនដែរ (ហ៊ូ-យន់, ហ៊ុយ-និម, ខៀវ-សំផន ជាខ្មែរកាត់ចិន)។

ចំណែកឯខ្មែរកាត់យួនវិញ មានចំនួនតិចទេនៅប្រទេសកម្ពុជា មកពីហេតុដែលគេដឹងគ្រប់គ្នា។ ការអន្តោប្រវេសន៍យួន ដែលមានយ៉ាងខ្លាំងជាលើកដំបូងមកប្រទេសកម្ពុជា (ក្នុងព្រំដែនសព្វថ្ងៃ) គឺក្នុងសម័យអាណានិគមបារាំង។ យួនស្រុកខ្មែរភាគច្រើន រស់នៅតាមព្រំដែនខ្មែរ-យួន។ នេះជាសញ្ញាថាយួនទាំងនោះនៅតែបារម្ភ។ ក្នុងឆ្នាំ ១៩៥២ កាលសមាជជាតិអនុម័ត ការបញ្ញត្តិហាមជនបរទេសមិនឲ្យប្រកបរបរខ្លះ បញ្ញត្តិទាំងនោះតំរង់ទៅជាពិសេសដល់ពួកយួន។ ការមិនទុកចិត្តរបស់ខ្មែរលើយួនមាននៅគ្រប់កន្លែង គ្រប់ពេលវេលា។ រឿងខ្លីមួយ គួរលើកយកមកនិយាយ : កាលព្រឹត្តការណ៍ខែមីនា ១៩៧០ផ្ទុះឡើង ឧត្តមសេនីយ លន់-នល់, ជាមួយគ្នានឹងការសុំឲ្យយួនខាងត្បូង ជួយទប់ការវាយសំរុករបស់យួនខាងជើង, បានបំរុងបញ្ឈប់ពីតំណែង នាយទាហានទាំងអស់ដែលមានប្រពន្ធយួន។ លុះដល់ដឹងថា នាយទាហានជាទីទុកចិត្តគាត់ជាច្រើននាក់ នៅក្នុងស្ថានភាពនេះ គាត់ក៏ត្រូវបញ្ឈប់ការប្រុងប្រយ័ត្ននេះវិញទៅ។

(៤) ពេលជិតចប់រជ្ជកាលព្រះស៊ីសុវត្ថិ បារាំងចង់ដាក់រាជវង្ស នរោត្តម លើបល្ល័ង្កវិញ។ គេពេញចិត្តនឹងកូនព្រះនរោត្តមម្នាក់ ដែលជាអ្នកនិពន្ធយ៉ាងចំណាន ម្ចាស់ នរោត្តម-សុផារស។ ប៉ុន្តែដោយបានតវ៉ានៅក្រុងប៉ារីស អំពីការរំលោភខ្លះនៃអាជ្ញាធរអាណានិគម ម្ចាស់សុផារស ក៏ត្រូវគេដកវិញទៅ។ ជំរើសក៏តំរង់ទៅកូនម្នាក់ទៀតរបស់ស្តេចនរោត្តម ទ្រង់ភាណុវង្ស តែមិនដាច់ស្រេច។ សំរេចទៅ បល្ល័ង្កបានមកកូនស្តេចស៊ីសុវត្ថិ ម្ចាស់មុនីវង្ស ដែលបានធ្វើទាហានក្នុងកងទ័ពបារាំងនៅឆ្នាំ ១៩០៨។

(៥) *អំណាចអាណានិគមបារាំង មិនគ្រាន់តែបង្ខំឲ្យកែទំរង់ទេ ថែមទាំងរំធ្វើឲ្យការយល់ឃើញអំពី "ស្តេច" កែប្រែទៀតៗ ក្រោយឆ្នាំ ១៨៩៧ ដើម្បីបែងចែករំលែកអំណាចដែលរហូតមកដល់ពេលនោះនៅតែក្នុងដៃស្តេចម្នាក់ បារាំងបានបង្ខំស្តេចឲ្យទទួលស្ថាប័នថ្មីមួយ ដែលគេពុំដែលស្គាល់សោះក្នុងប្រទេសកម្ពុជា : រដ្ឋាភិបាលៗ ក្រឹត្យមួយបញ្ជាក់មុខការរដ្ឋាភិបាលនោះ : ប្រទេសត្រូវដឹកនាំដោយរដ្ឋាភិបាលដែលមានគណៈរដ្ឋមន្ត្រីមួយ (កុងស៊ី សេនាបតី) មានរដ្ឋមន្ត្រីប្រាំមួយនាក់ (សេនាបតី, ខ្មែរ) គណៈរដ្ឋមន្ត្រីត្រូវដឹកនាំដោយ រ៉េស៊ីដង់ស៊ុប៉េរីយ៉ែបារាំងៗ អំណាចអាណានិគមបង្ខំស្តេចឲ្យទុកនាទីជាអគ្គមហាសេនា (រដ្ឋមន្ត្រីទី១) ឲ្យមនុស្សដែលបានធ្វើជាអ្នកបកប្រែភាសា ក្នុងរដ្ឋការខ្លួនៗ ឯងារពួកសេនាបតីមានជាអាទិ : ក្រឡាហោម (នាវាចរ) យមរាជ (យុត្តិធម៌) ចក្រី (ការពារប្រទេស) វាំង និងអគ្គមហាសេនាៗ*

*អគ្គមហាសេនាមុនគេបង្អស់ គឺលោកអ៊ុម បន្ទាប់មកលោកប៉ុក ទាំង២នាក់ជាកូននាម៉ឺនៗ នៅឆ្នាំ ១៩០២ បារាំងឈប់តាមទំលាប់នេះ (ដែលទុកនាទីសេនាបតីឲ្យកូននាម៉ឺន) ដោយតែងតាំងលោកជួន (អ្នកបកប្រែភាសា) ជាសេនាបតីក្រសួងវាំងៗ លោក «វាំង» ជួន នៅកន្លែងនោះជាង ៣០ ឆ្នាំ រហូតដល់រាជ្យព្រះបាទមុនីវង្សៗ លោកជួននេះ បានទៅជាមនុស្សទំនុកចិត្តរបស់បារាំង —ភាសាសម័យថាចារបុរស, ហើយបានឲ្យបារាំងដឹងពីការបំរុងក្បត់ទំលាក់ស្តេចស៊ីសុវត្ថិ ពីសំណាក់ម្ចាស់មយូរ៉ា (កូននរោត្តម)ៗ នៅឆ្នាំ ១៩១៧ (មយូរ៉ាបានត្រូវគេបំបរបង់ទៅសៀងខ្វាង, ប្រទេសលាវ)ៗ លោក ប៉ែន-នុត បានចាប់ផ្តើមជីវិតនយោបាយដ៏វែងរបស់គាត់ ជាកូឈួយសេនាបតីក្រសួងវាំង នៅឆ្នាំ ១៩៤០ៗ*

(៦) *ហេតុភេទនេះ គេសង្កេតឃើញជាទូទៅ នៅក្នុងប្រទេសទាំងឡាយនៃលោកទី៣ (ប្រទេសក្រ ក្រៅពីលោកសេរី និងលោកកុម្មុយនិស្ត)ៗ ជីវិតរហេមរហាម នៅកកីតគ្នានឹងជីវិតធេតធាយៗ រាជធានីភ្នំពេញ ជាតំណាង «កម្ពុជាទំនើប»ៗ នៅជិតបង្កើយសោះ ពិភពកសិករ នៅតែរស់នៅតាមរបៀបបុរាណៗ នេះហើយជាចំណុចខ្សោយនៃប្រទេស ភាពផុយជ្រាយនៃប្រទេសៗ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ ១៩៥៤ សង្គ្រាមវាងវៀតណាមទាំង២ បានផ្តល់សន្តិភាពវាង ១៥ ឆ្នាំឲ្យកម្ពុជាៗ ក្នុងកំ-ឡុង ១៥ ឆ្នាំនោះ អ្នកដឹកនាំខ្មែរឥតមានសមត្ថភាពធ្វើឲ្យពិភពកសិករ មានអគ្គីសនីនិងទឹក «ម៉ាស៊ីន» ប្រើឡើយ : មិនគិតផ្តល់ឲ្យប្រទេសនូវសម្ភារៈការពារខ្លួនគ្រប់គ្រាន់ សំរាប់ពេលណាមានអាសន្ន អ្នកដឹកនាំទាំងនោះបែរជារើសយក «អព្យាក្រឹត», «បញ្ចសីលា» ទៅវិញៗ អព្យាក្រឹតខ្មែរបានទៅជាអសារឥតការ ឯសីល៥ ក៏ពុំបានធ្វើឲ្យខ្មែរសុខ ព្រោះខ្មែរ "សុំ" តែម្នាក់ឯងៗ*

(៧) *មុនឆ្នាំ ១៩២០ ព្រះសង្ឃខ្មែរត្រូវទៅបាងកក ដើម្បីរៀនឲ្យជ្រៅទៅទៀតនូវភាសាបាលីៗ នៅក្រុងនោះព្រះសង្ឃតែងជួបនឹងម្ចាស់យុគន្ធរ ដែលជាកូនម្នាក់ទៀតរបស់ស្តេចនរោត្តមៗ យុគន្ធរបានត្រូវស្តេចបញ្ជូនទៅស្រុកបារាំង ដើម្បីប្តឹងតវ៉ាដល់រដ្ឋាភិបាលបារាំង អំពីការរំលោភនៃអាជ្ញាធរអាណានិគម មកដល់ស្រុកបារាំងនៅខែសីហា ១៩០០ ម្ចាស់យុគន្ធរប្រគល់ឲ្យរដ្ឋាភិបាលបារាំង នូវកំណាត់ហេតុយ៉ាងវែងមួយ ពេញទៅដោយបណ្តឹងរបស់ហ្លួងនរោត្តមៗ ដោយមានអ្នកសារព័តមានបារាំងម្នាក់ឈ្មោះហ្សង់ ហេស្ស ជួយផង ទ្រង់យុគន្ធរទំលូកឲ្យដល់មតិមហាជនបារាំង រហូតដល់បានចុះអត្ថបទមួយក្នុងឯកទិន "ឡឺ ហ្វីហ្គារ៉ូ"ៗ មិនត្រឹមតែទិទៀនអាជ្ញាធរអាណានិគម យុគន្ធរហែកបង្ហាញ "ការឃុបឃិតរបស់បារាំងពុករលួយ" ជាមួយលោកអ៊ុម (អគ្គមហាសេនា) និងលោកជួន (បន្ទាប់មកសេនាបតីក្រសួងវាំង) ដើម្បីជញ្ជក់ឈាមប្រទេស* (exploiter le pays, sic) *និងបំបែកបំបាក់អ្នករាជការខ្មែរស្លូត*

*ត្រង់ៗ (រឿង អាឡិចស៊ិស ឈុន)ៗ រដ្ឋមន្ត្រីបារាំងក្រសួងអាណានិគម តបវិញយ៉ាងខ្លាំងដោយបញ្ជាឲ្យ រ៉េស៊ីដង់ស៊ុបេរីយ័រ បង្ខំស្តេចនរោត្តមឲ្យដាក់ទោសដល់ម្ចាស់យុគន្ធរ : កាលណាមកដល់វិញហើយ យុគន្ធរត្រូវសូមទោសជាសាធារណៈ ដល់សេនាបតី "ដែលត្រូវគេមួលបង្កាច់"ៗ ពុំនោះសោតម្ចាស់នេះនឹងអាចត្រូវគេបំបរបង់ ហើយរឹបអូសយកទ្រព្យសម្បត្តិៗ ចេញពីស្រុកបារាំងនៅជំណាច់ឆ្នាំ ១៩០០ យុគន្ធរ, ដោយក្រែងត្រូវទណ្ឌកម្មខ្លាំង, ក៏សុខចិត្តរស់នៅឯបាងកក រហូតដល់ពេលសុគតនៅឆ្នាំ ១៩៣៤ៗ ចេញពីក្រុងបាងកក ព្រះសង្ឃតែងតែនាំទៅភ្នំពេញវិញ នូវគំនិតបះបោរដែលផ្ដុំពីម្ចាស់យុគន្ធរៗ ដើម្បីខាយាំងព្រះសង្ឃពីគំនិតដ៏មានគ្រោះថ្នាក់នេះ គេក៏បង្កើតសាលាបាលីជាន់ខ្ពស់មួយនៅរាជធានីខ្មែរទៅៗ*

(៨) *សង្គ្រាមលោកលើកទី១ បានបន្ថយយ៉ាងច្រើននូវចំនួនជនជាតិបារាំង ដែលមករស់នៅក្នុងឥណ្ឌូចិនៗ បែរមករកអ្នកចេះធ្វើការ ក្នុងចំណោមជនជាតិដើមវិញ រដ្ឋការបារាំងបង្កើតសាលា "រដ្ឋបាល" ដើម្បីបង្ហាត់អ្នករាជការខ្មែរ (មុខងារជាទីចង់បានសម័យនោះ គឺ "ចីរ៉េស៊ីដង់" ដែលសំរាប់អ្នកណាបានជាប់ "ឌីប្លូម"ៗ ដូច្នេះហើយបានជា នៅឆ្នាំ ១៩៣៩ គេឃើញមានសិស្សតែ ៤ នាក់ ដែលរៀនបន្តយក "បាស្ទូ"ៗ គឺក្នុងសាលារដ្ឋបាលនោះហើយ ដែលដុះដាលវរជននយោបាយលើកទី១ នៃប្រទេសកម្ពុជាៗ ភាគច្រើននៃអតីតអ្នកដឹកនាំខ្មែរ ចេញពីសាលានោះៗ ក្រោយពេលបានឯករាជ្យ សាលារដ្ឋបាលបានប្តូរមុខការពីរដង : លើកទី១ គឺគ្រាន់តែជាកន្លែងផ្តល់កម្មសិក្សា បន្ថែមឲ្យអ្នករាជការចាស់ (ឧ. អ្នកក្របខ័ណ្ឌរដ្ឋបាល ដែលប្រឡងចេញជាប់លេខ១ នឹងបានត្រូវតែងតាំងជាអភិបាលខេត្ត) លើកបង្ហើយសមនឹងឈ្មោះថ្មី "សាលាភូមិន្ទរដ្ឋបាល" គឺសំរាប់និស្សិតដែលមានសញ្ញាប័ត្រខាងច្បាប់ហើយដែលគេនឹងបង្ហាត់ឲ្យទៅបំពេញមុខងារក្នុងក្រសួងនានាៗ ដោយប្រណែននឹង "ក្មេងៗ" ដែល "ឡើងបុណ្យសក្តិ" លឿនពេក អ្នករដ្ឋការចាស់ៗ ទាមទារឲ្យបិទសាលានោះៗ សាលាជាតិរដ្ឋបាលត្រូវបិទទ្វារនៅដំណាច់ឆ្នាំសិក្សា ១៩៧៥ ទ្វារដែលបានត្រូវបិទធាប់ជាងដូចបំរុងទុក ដោយសារការចូលមកនៃខ្មែរក្រហមៗ*

(៩) *មានតែកូសាំងស៊ីន (កម្ពុជាក្រោម) ទេ ដែលបានទទួលពីបារាំងច្រើនជាងគេ នូវបច្ចេកទេសខាងកសិកម្មៗ នៅកម្ពុជាយើង ការកើនឡើងនៃផលិតផលកសិកម្ម មកពីសន្តិភាពដែលមានឡើងវិញក្រោយចំបាំងរាំងជល់រាប់សតវត្សរ៍ៗ*

(១០) *ជាលើកទី១ ដើមកៅស៊ូបានត្រូវយកចេញពីប្រទេសម៉ាឡេស៊ី មកដល់ព្រៃនគរនៅឆ្នាំ ១៨៩៧ ដោយឱសថការីបារាំងម្នាក់ឈ្មោះ រ៉ាអ៊ូលៗ ចំពោះកម្ពុជានិងវៀតណាម កៅស៊ូបានទៅជាធនធានធំ១ ដែលនាំមកនូវរូបិយបណ្ណបរទេសៗ ប៉ុន្តែប្រទេសកម្ពុជាបានទទួលតិចណាស់នូវផលពីធនធាននេះ ព្រោះបារាំងម្ចាស់ចំការកៅស៊ូ បានធ្វើដីចំការរបស់ខ្លួនឲ្យទៅជា "ស្រុកបារាំង" មួយក្នុងស្រុកខ្មែរហើយៗ ជនជាតិខ្មែរយើង ចូលមិនចុះទេក្នុងសហគ្រាសនោះ ដែលប្រើតែជនជាតិយួន ទាំងជាអ្នកបច្ចេកទេសទាំងជាកម្មករៗ ស្ថានភាពនេះមានជាងកន្លះសតវត្សរ៍ នៅក្រោមភ្នែកស៊ាំគ្រលំ នៃអ្នកដឹកនាំខ្មែរៗ*

# រឿងក្រៅប្រទេស

*ក្នុងកំឡុង ១០ ឆ្នាំ មុនការផ្ទុះនៃសង្គ្រាមលោកលើកទី២, មហាអំណាចថ្មីមួយបានផុសឡើងបន្តិចម្តងៗ ពីទ្វីបអាស៊ី។ ការលាតសន្ធឹងឥទ្ធិពលនៃមហាអំណាចថ្មីនោះ មកលើអាស៊ីភាគអគ្នេយ៍ ក្រោយឆ្នាំ ១៩៤០, បានធ្វើឲ្យរលាយអាណាចក្រ អាណានិគមបារាំងនិងអង់គ្លេស។ មហាអំណាចថ្មីនោះគឺប្រទេសជប៉ុន។*

*សង្គ្រាមរវាងរុស្ស៊ីនិងជប៉ុន ដែលផ្ទុះឡើងក្នុងឆ្នាំ ១៩០៤ បានចប់ដោយជ័យជំនះ ជប៉ុន ដែលដណ្តើមយកបានក្រុង ព័រ-អារធួរ នៅថ្ងៃ ២ មករា ១៩០៥។ ក្រោមការសំរុះសំរួល នៃប្រធានាធិបតីអាមេរិកាំង តេអូឌរ រូស៊ីវែល, សន្ធិសញ្ញាចុះនៅ ពរស៍មូថ ឲ្យទៅជប៉ុន នូវប្រទេសកូរ៉េ និង ម៉ាន់ជូរីខាងត្បូង។ ថ្ងៃ ១៩កញ្ញា ១៩៣១ (២៦ឆ្នាំក្រោយមក) ជប៉ុនបានយកម៉ាន់ជូរីទាំងមូល, ហើយឆ្នាំក្រោយមក ក៏កាន់កាប់បានស្រុក យេហូល ទៀត (ខេត្តចិនពីដើម, ជាទ្វារចេញចូលទៅស្រុក ម៉ុងហ្គោល)។ ក្នុងពេលដែលចិន កួមិងតាង (ជាតិនិយម) និងចិនកុម្មុយនិស្ត កំពុងច្បាំងគ្នាឯង, ជប៉ុនចូលលុកលុយប្រទេសចិន នៅឆ្នាំ ១៩៣៧ ហើយយកបានក្រុងប៉េកាំងនៅខែកក្កដា, ក្រុងកង់តុង នៅខែតុលា ១៩៣៨, និងកោះហៃណាន់ ក្នុងខែកុម្ភៈ ១៩៣៩។ ដូច្នេះ នៅពេលដែលសង្គ្រាមលោកលើកទី២ ផ្ទុះឡើងនៅឆ្នាំ ១៩៣៩ នោះ, ឥណ្ឌូចិនរបស់បារាំងនៅចំក្រោមការគំរាមរបស់ជប៉ុន។ នៅទ្វីបអឺរ៉ុបវិញ, ខែមិថុនា ១៩៤០ បានឃើញសាធារណរដ្ឋទី៣ របស់បារាំង រមៀលក្រោមជើងដើរសង្វាក់ក្វាននៃពួកណាហ្ស៊ី។ ថ្ងៃ ១៦ មិថុនា សេនាប្រមុខ ប៉េតាំង ចុះហត្ថលេខាសុំចុះចាញ់។*

*ឆ្លៀតពេលដែលអំណាចបារាំងនៅឥណ្ឌូចិនកំពុងទ្រេះទ្រោះ, ជប៉ុនចាត់វិធានការណ៍បញ្ឈប់ការរត់ពន្ធអាវុធ ដែលយកមកឲ្យទ័ពរបស់ ជាងកាយជាក តាមកំពង់ផែយួន, ហៃ-ផុង (កំពង់ផែចិនទាំងឡាយត្រូវជប៉ុនព័ទ្ធជាប់)។ ថ្ងៃ ១៩ មិថុនា (១៩៤០) ជប៉ុនដាក់កំណត់ (ultimatum) ឲ្យ, ជាលើកទី១, ដល់ «គូវែន័រ ហ្សេណេរ៉ាល់» នៃ ឥណ្ឌូចិន, ឧត្តមសេនីយ កាទ្រូ ដែលទើបនឹងត្រូវតែងតាំងថ្មីៗ។ កាទ្រូ ខំសុំជំនួយពីអង់គ្លេស និង អាមេរិកាំង តែឥតបានឡើយ[១]។ ថ្ងៃ ២៩ មិថុនា ឧត្តមសេនីយជប៉ុន, នីស៊ីហារ៉ា, មកដល់ហាណូយ ហើយទាមទារឲ្យ បញ្ឈប់ចរាចរលើផ្លូវរទេះភ្លើង ដែលចូលទៅខេត្តចិន យុនណាន, និងឲ្យបិទព្រំប្រទល់ ចិន-យួនទាំងមូល (ដោយដាក់គណៈកម្មការត្រួតពិនិត្យមួយ)។ ការទាមទារ ដែល កាទ្រូ យល់ព្រមឲ្យទាំងអស់។ ថ្ងៃ ២០ កក្កដា បារាំងតែងតាំងឧត្តមនាវី ដឺគូ ជំនួសឧត្តមសេនីយ កាទ្រូ។ ថ្ងៃ ២ សីហា ជប៉ុនដាក់កំណត់ម្តងទៀត ដោយទាមទារឲ្យទ័ពខ្លួនចេញចូលតាមស្រុក តុងកឹង ដោយសេរី ព្រមទាំងឲ្យបារាំងដាក់វាលអាកាសយានជាច្រើននៅ តុងកឹង ឲ្យជប៉ុនប្រើ។ កិច្ចព្រមព្រៀងបារាំង-ជប៉ុនមួយ បានត្រូវធ្វើឡើង នៅថ្ងៃ ៣០ សីហា តាមរយៈរដ្ឋទូតបារាំង ដឺសាំងកិនតាំង, ដែលនៅក្នុងនោះ បារាំងព្រមធ្វើតាមការទាមទាររបស់ជប៉ុនទាំងអស់ ក្នុងរឿងយោធា ហើយទទួលស្គាល់ថា នឹងអាចមានលទ្ធភាពប្តូរសេដ្ឋកិច្ចគ្នា។ តបមកវិញ ជប៉ុនយល់ព្រម "គោរពអធិបតីភាពនៃបារាំងលើឥណ្ឌូចិន និងបូរណភាពទឹកដីខ្លួន"។ ប៉ុន្តែនៅឥណ្ឌូចិន ឧត្តមនាវី ដឺគូ ដែលមិនពេញចិត្តនឹងគំនិតឲ្យការសំរួលទាំងនោះទៅជប៉ុន ក៏សំរេចថាត្រូវរៀបចំទ័ពដើម្បីទប់ទល់។ នៅយប់ថ្ងៃ ៥ កញ្ញា កងវរសេនាតូចជប៉ុនមួយ ឆ្លងកាត់ព្រំដែនចិន-យួន នៅ ដុងដាង ជិតក្រុង ឡាង-សឺង។ ថ្ងៃ ១៩ កញ្ញា នីស៊ីហារ៉ា ដាក់កំណត់ឲ្យ ដឺគូ ម្តងទៀត ជាលើកទី៣ ជាមួយគ្នានឹងការសំឡុត ដោយបញ្ចេញអានុភាពកងទ័ពក្នុងឈូងសមុទ្រ តុងកឹង, នៅថ្ងៃ ២០ កញ្ញា។ រដ្ឋាភិបាលនៅ វីស៊ី (រដ្ឋាភិបាលដែលព្រមនៅក្រោមអំណាចអាល្លឺម៉ង់)*

កំបញ្ជាឲ្យ ដឺគូ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងបារាំង-ជប៉ុនមួយទៀត, ថ្ងៃ ២២ កញ្ញា នៅហាយផុង, ដែលគ្រាន់តែធ្វើឲ្យច្បាស់ឡើងនូវកិច្ចព្រមព្រៀងមុន[២] ទ័ពជប៉ុនអាចឆ្លងកាត់ស្រុក តុងកឹង បាន, ទុកយោធា ៦ ពាន់នាក់ នៅខាងជើងទន្លេក្រហម ហើយអាចប្រើប្រាស់វាលអាកាសយាន ៣ នៅតុងកឹង។

ការចាប់ផ្តើមឡើងអំណាចនៃជប៉ុនលើឥណ្ឌូចិន បានបញ្ចុះកិត្យានុភាពបារាំងខ្លាំងណាស់ ចំពោះមុខបណ្តាជននៃប្រទេសទាំងបី។ ប៉ុន្តែគឺប្រទេសថៃទេ ដែលបានឆ្លៀតយកចំណេញមុនគេ ពីការធ្លាក់កិត្យានុភាពនៃអាណានិគមនិយមបារាំងនេះ។ ទំនាក់ទំនងពិសេសរវាងសៀមនិងជប៉ុន[៣] បានធ្វើឲ្យបារម្ភដល់រដ្ឋាភិបាលបារាំង ដែលបានចុះកិច្ចព្រមព្រៀងមិនឈ្លានពានគ្នាមួយ ជាមួយរដ្ឋាភិបាលថៃនៅថ្ងៃ ១២ មិថុនា ១៩៤០។ ក្នុងខែកញ្ញា, ពេលដែលបារាំងកំពុងវិវាទជាមួយជប៉ុនក្នុងរឿង តុងកឹង, រដ្ឋាភិបាល វីស៊ី សុំឲ្យរដ្ឋាភិបាលបាងកក «ធ្វើឲ្យកិច្ចព្រមព្រៀងមិនឈ្លានពានគ្នា មានប្រសិទ្ធភាពឡើង ដោយមិនបាច់ប្តូរហត្ថលេខាគ្នា» (ព្រោះកិច្ចព្រមព្រៀងនេះបានធ្វើឡើងជាមួយរដ្ឋាភិបាលជប៉ុន, មិនទាន់ចាញ់អាល្លឺម៉ង់។ និយាយតាមពាក្យសាមញ្ញថា ៖ សុំថៃកុំមកឈ្លានពាន)។ ភិបុលសង្គ្រាម, រដ្ឋមន្ត្រីទី១ ថៃ, មិនយល់ទាស់ ប៉ុន្តែដល់ថ្ងៃទី ១៣ កញ្ញា បានទាមទារយកពីរដ្ឋាភិបាល វីស៊ី វិញនូវទឹកដីដែលបានឲ្យទៅឥណ្ឌូចិនបារាំង តាមសន្ធិសញ្ញាឆ្នាំ ១៩០៧ និងទឹកដីមួយភាគទៀត ដែលបារាំងសន្យាតាមសន្ធិសញ្ញាឆ្នាំ ១៩០៤ និង ១៩០៧ ថានឹងឲ្យទៅសៀមពេលណាខ្លួនឈប់ត្រួតត្រាឥណ្ឌូចិន។ ហើយ ថៃនៅតែរក្សាសិទ្ធិត្រួតត្រាប្រទេសលាវ និង កម្ពុជា! (មើលភាគទី៣, ទំព័រ ២២)។ ការមិនព្រមនៃរដ្ឋាភិបាល វីស៊ី រុញឲ្យសៀមប្រើកម្លាំង។ នៅដំណាច់ខែកញ្ញា ភិបុល បញ្ជាទ័ពឲ្យធ្វើទុក្ខបុកម្នេញ តាមព្រំដែនលាវនិងខ្មែរ។ បារាំងតបតវិញដោយទម្លាក់គ្រាប់បែកនៅពេលយប់ ទៅលើទីប្រជុំជនសៀមខាងភាគឦសាន។ ចាប់តាំងពីថ្ងៃ ១៩ វិច្ឆិកា កងយោធពលចំរុះបារាំង-ខ្មែរ ធ្វើប្រតិបត្តិការជើងគោក ការពារព្រំដែន, ប៉ុន្តែត្រូវទទួលបរាជ័យជាច្រើនដង[៤]។ ថ្ងៃ ៥ មករា ១៩៤១ កងយោធាសៀមចាប់ផ្តើមកាន់កាប់ភូមិខ្មែរជាច្រើនដែលនៅតាមព្រំដែន។ បរាជ័យនៅលើផ្ទៃគោក បញ្ជាឲ្យ "គូវែនរ័ ហ្សេណេរ៉ាល់" ដឺគូ — ដែលជានាយទាហានជើងទឹក— ធ្វើប្រតិបត្តិការមួយតាមសមុទ្រ។ កងឯកភាពនាវាបារាំងមួយដែលមាននាវាល្បាត "ឡាម៉ុត-ពីក្កេ" និងកប៉ាល់តូច ៤ ទៀត (ឡឺឌុយម៉ុងឌួកវិល, ឡាមីរ៉ាល់-សាក់នែ, ឡឺតាអួរ និងឡឺម៉ាន) ក្រោមបញ្ជាការនៃវរនាវីឯក បេរ៉ង់ហ្សេ បានទៅវាយកងទ័ពជើងទឹកថៃមួយភាគ ដែលបោះយុថ្កានៅកោះចង់, ពេលព្រលឹមស្រាងៗ ថ្ងៃ ១៧ មករា។ កប៉ាល់បារាំងបានបំផ្លាញនាវាក្រោះរក្សាឆ្នេរសៀម «ថុនបុរី» និងនាវាសំរាប់បំផ្លាញកប៉ាល់បាញ់គ្រាប់បែកទឹកជាច្រើនទៀត ដែលបីត្រូវលិចបាត់ (ជិត ៤០% នៃទ័ពជើងទឹកថៃត្រូវប្រើការលែងកើត)។

ថ្ងៃ ២១ មករា ជប៉ុនបង្ខំថៃ និងបារាំងឲ្យទទួលការសំរុះសំរួលរបស់ខ្លួន។ អ្នកតំណាងបារាំង, ជប៉ុន និងថៃ ប្រជុំគ្នាក្រោមអធិបតីភាពនៃឧត្តមសេនីយ ស៊ូមិត, ថ្ងៃ ៣១ មករា នៅព្រៃនគរ, ហើយចុះហត្ថលេខាព្រមឈប់បាញ់គ្នានៅលើនាវាល្បាតជប៉ុន "ណាតូរី"។ ការចចារដើម្បីសន្តិភាព ចាប់ធ្វើឡើងនៅថ្ងៃ ៧ កុម្ភៈ ឯក្រុងតូក្យូ ក្រោមអធិបតីភាព អ្នកតំណាងរដ្ឋាភិបាលជប៉ុន, ម៉ាត់ស៊ូកា។ ខាងបារាំងមានរដ្ឋទូតបារាំងនៅតូក្យូ, អាកសែន អង់រី និងខាងសៀមមានម្ចាស់ វ៉ាន់វៃថ្យាកន, ទីប្រឹក្សានៃរដ្ឋមន្ត្រីក្រសួងការបរទេស។ ការចចារនេះចប់និងការធ្វើកិច្ចសន្យាសន្តិភាពបារាំង-ថៃ នៅថ្ងៃ ៩ ឧសភា ១៩៤១ ដែលតាមកិច្ចនោះ បារាំងឲ្យទៅសៀម នូវខេត្តស៊ីសុផុន, បាត់ដំបង, ភាគខេត្តស្ទឹងត្រែង, កំពង់ធំ និងសៀមរាប ដែលនៅខាងជើងខ្សែ "ហ្គ្រាដ" លេខ ១៥ (កុំច្រឡំខ្សែស្របដែលជា "ដឺក្រេ" ហើយខ្ពស់ជាង) លើកលែងតែបរិវេណអង្គរ[៥]។ ការបាត់បង់ជាលើកទី២ នូវខេត្តសម្បូណ៌ស្រូវទាំងនេះ ធ្វើឲ្យដុនជាបសេដ្ឋកិច្ចខ្មែរ ជាហេតុធ្វើឲ្យប្រជាជនយើងវេទនាយ៉ាងខ្លាំង ក្នុងរយៈសង្គ្រាមលោកលើកទី២ ទាំងមូល។

ក្រោយមកទៀត, នៅស្រុកបារាំង, ជប៉ុនធ្វើកិច្ចព្រមព្រៀងមួយទៀតជាមួយបារាំង (ហៅកិច្ចព្រមព្រៀង ដារឡង់-កាតូ នៃថ្ងៃ ២៩ កក្កដា ១៩៤១) ដែលអនុញ្ញាតឲ្យទ័ពជប៉ុន «ស្នាក់នៅ» លើទឹកដីឥណ្ឌូចិនទាំងមូល។ គ្រាន់តែស្ទឹកឈើឯស្រុកបារាំងទុំហើយជ្រុះភ្លាម, កងអាកាសចរជប៉ុនក៏ចាប់ផ្តើមប្រើវាលចុះយន្តហោះនៅកម្ពុជានិងនៅកូសាំងស៊ីន, កិច្ចដែលឲ្យសញ្ញានៃការរៀបវាយប្រទេសថៃនិងប្រទេសកូមា។ ថ្ងៃ ៨ ធ្នូ ១៩៤១ គឺមួយថ្ងៃបន្ទាប់ពីការទម្លាក់គ្រាប់បែកលើ ភើលហ៊ែបបួរ, កងយោធាជប៉ុនចូលទៅស្រុកសៀមតាមស្រុកខ្មែរ[៦]។

ទោះបីជាជប៉ុនបានគោរពអធិបតីភាពបារាំងលើឥណ្ឌូចិនក៏ដោយ (រហូតដល់ខែមីនា ១៩៤៥), វត្តមាននៃកងទ័ពជប៉ុន បានឲ្យសន្ទុះមួយដល់ពួកអ្នកជាតិនិយមនៅឥណ្ឌូចិនទាំងអស់ ឲ្យហ៊ានចេញពីភាព ស៊ើរពួន-ស៊ើរចេញមុខរបស់ខ្លួន។ ប៉ុន្តែស្នូលនៃចលនាជាតិនិយមខ្មែរ បានកើតឡើងយូរមកហើយ មុន "ជប៉ុនចូល" ទៅទៀត[៧], បើបញ្ជាក់ឲ្យច្បាស់មែនទែន គឺក្នុងឆ្នាំ ១៩៣៩, ពេលដែលអាចារ្យបាលីម្នាក់ ឈ្មោះ ប៉ាច-ឈឺន និងមន្ត្រីម្នាក់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ឈ្មោះ សឺង ង៉ុកថាន់ បានបង្កើតសារព័ត៌មានទី១ ជាភាសាខ្មែរ ៖ កាសែត (ពេលនោះមិនទាន់មានពាក្យសារព័ត៌មាននៅឡើយទេ) «នគរវត្ត»។ នាមទាំង២ នេះ, ជាមួយនិងនាមមួយទៀត – ហែម ចៀវ, បានដក់ជាប់ក្នុងដួងចិត្តនិងក្នុងសតិនៃខេមរជនជាច្រើន ដែលសំគាល់អ្នកទាំង ៣ ថាជាអ្នកស្នេហាជាតិដោយសកម្ម។ គោលដៅដំបូងនៃកាសែតនគរវត្ត គឺ ញុះញង់បណ្តាជនឲ្យទាមទារស្វ័យភាពឲ្យបានកាន់តែច្រើន ពីអាណានិគមនិយមបារាំង, គឺថាឲ្យត្រឡប់មករបបមុន ដែលមិនសូវតឹងតែង ហើយដែលបានចែងក្នុងសន្ធិសញ្ញាឆ្នាំ ១៨៦៣ (មុនការ "ក្ដួងនីងចំពុះទុង" នៃឆ្នាំ ១៨៨៤)។ ក្នុងការតយុទ្ធនេះ លោក សឺង ង៉ុកថាន់[៨] នឹងទៅពឹងផ្អែកលើព្រះសង្ឃ, ដែលមិនមែនគ្រាន់តែជាកម្លាំងនៃព្រះពុទ្ធសាសនាដែលប្រជាជនខ្មែរបានរំលាយចូលជាពុម្ពមួយ ជាមួយប្រទេសនិងជាតិសាសន៍ខ្លួនទេ[៩], ព្រះសង្ឃជាកម្លាំងនយោបាយ១ ដោយសារសកម្មភាពក្នុងការអប់រំប្រជារាស្ត្រ។

ជាមួយនឹងភិក្ខុ ហែម ចៀវ, សាស្ត្រាចារ្យបាលី និងអាចារ្យនៃយោធភូមិទាហាន "ជើងក្រហម" ទាំងអស់[១០], លោក សឺង ង៉ុកថាន់ បង្កើតសមាគមមួយឈ្មោះ សមាគមពុទ្ធិមាមិកជន (មិត្តនៃពុទ្ធសាសនា) ដែលបើកឲ្យគាត់ទាក់ទងយ៉ាងស្រួល ជាមួយឧបាសកនិងព្រះសង្ឃនៃគណៈទាំង២, ធម្មយុត្តិ និងមហានិកាយ។ ថ្ងៃ ១៥ កក្កដា ១៩៤២ លោកអាចារ្យ ហែម ចៀវ ត្រូវគេចាប់ ក្រោមការចោទថា ចែកត្រាក់ប្រឆាំងនឹងបារាំង ហើយនិង "ទាក់ទងនឹងជប៉ុន"។ នៅក្នុងសាលជំនុំនៃគណៈរដ្ឋមន្ត្រី, ចំពោះមុខលោក ទា សាន, រដ្ឋមន្ត្រីក្រសួងធម្មការ, បារាំងឈ្មោះ បារ៉ូ ដែលជាអធិការកិច្ចការនយោបាយ បានដកស្បង់ចីពរចេញពីលោកអាចារ្យ ចៀវ ដែលរួចមក ត្រូវគេយកទៅឃុំឃាំង។ ថ្ងៃ ១៩ កក្កដា, ភិក្ខុ ១ ៥០០ អង្គដែលមកពីគ្រប់តំបន់នៃប្រទេស, ប្រជុំគ្នាកកកុញនៅមុខផ្ទះ "រ៉េស៊ីដង់ស៊ូប៉េរីយ័រ" ឈ្មោះ ដឺឡែម ដោយលើកបដា "ដោះលែងអាចារ្យ ចៀវ!"។ ការវាយតប់គ្នាបានកើតមានឡើង រវាងភិក្ខុនិងទាហានបារាំង (តាមសៀវភៅបារាំង) ដែលគេហៅមកបន្ថែម (ព្រោះទាហានខ្មែរពុំហ៊ានប្រមាថភិក្ខុ)។ បារាំងបានចង់ឲ្យការបង្ក្រាបបាតុកម្មទី១ ដែលប្រឆាំងនឹងខ្លួននេះ ទៅជាគំរូ។ គេក៏ឥតបានឃើញមានប្រតិកម្មឆ្លើយនឹងការបង្ក្រាបភិក្ខុនេះ ហើយចាប់តាំងពីថ្ងៃនោះមក ប្រទេសក៏ស្ងប់ស្ងាត់វិញ រហូតដល់ឆ្នាំ ១៩៤៥។ "អ្នកនាំអាទិ៍" បានត្រូវគេចាប់ឃុំឃាំង។ លោក សឺង ង៉ុក ថាន់ ដែលគេរកមុខ, ត្រូវទៅជ្រកនឹងទាហានជប៉ុន ដែលបញ្ជូនគាត់មកដល់តូក្យូ តាមរយៈស្ថានទូតជប៉ុននៅបាងកក។ តុលាការសឹកនៅព្រៃនគរ, ក្នុងថ្ងៃ ១៩ ធ្នូ, កាត់ទោសប្រហារជីវិតលោក ប៉ាច ឈឺន និង លោកអាចារ្យ ហែម ចៀវ។ ប៉ុន្តែនៅថ្ងៃ ១៥ មិថុនា ១៩៤៣, ទោសនោះបានត្រូវបន្ថយមកត្រឹមដាក់គុក១ជីវិតវិញ ហើយអ្នកទាំង២ ក៏ត្រូវគេ

យកទៅឃុំឃាំងឯកោះត្រឡាច[១១] ដែលនៅទីនោះ, ក្រោយមក លោកអាចារ្យ ហែម-ចៀវ បានសុគត (បើតាមវិន័យសង្ឃ ភិក្ខុ ហែម-ចៀវ ឥតបានត្រូវគេផ្សឹកទេ)។ នេះគឺក្នុងរាជ្យព្រះបាទ នរោត្តម សីហនុ។

ការចេះធ្លូលនៃគំនិតជាតិនិយមទាំងនេះ បានត្រូវកម្ចាដោយការឃោសនាជប៉ុនអំពីការបង្កើតឡើង, ក្នុងអនាគតកាល, នូវ «ពិភពសម្បូណ៌សប្បាយជាមួយគ្នានៅមហាអាស៊ីបូព៌ា»[១២]។ បារម្ភនិងការណ៍នេះ, ដឺគូ ប្រឹងប្រែងធ្វើឲ្យមានឡើងនូវគំនិត «សហព័ន្ធនិយម» ថ្មីមួយអំពីឥណ្ឌូចិន[១៣]។ ដើម្បីកិច្ចនេះ, វិធានការណ៍ខ្លះបានត្រូវចាត់ឡើងដោយអាជ្ញាធរបារាំង ៖ ពិនិត្យឡើងវិញនូវទំនាក់ទំនងផ្លូវមនុស្ស រវាងបារាំង និង ជនជាតិក្នុងស្រុក, តំកើងកិត្យានុភាពនៃស្តេចនៅឥណ្ឌូចិន[១៤], បង្កើតចលនាយុវជននិងកីឡា[១៥], ចំរើនអក្សរសាស្ត្រស្នេហាជាតិថ្មីមួយដើម្បីយុវជន, បង្កើតសភាសហព័ន្ធនៃឥណ្ឌូចិនមួយដែលមានសមាជិក៣០នាក់ ជាជនជាតិឥណ្ឌូចិន ទល់នឹង ២៣ ខាងបារាំង។ល។ នៅប្រទេសកម្ពុជា, «រេស៊ីដង់ ស៊ូប៉េរីយ័រ» ហ្គោជេ នៅតែបន្ទំឲ្យមានការកែទំរង់ដ៏តឹងតែង, ជាហេតុដែលខុសនឹងគំនិត «សហព័ន្ធនិយម» នៃ ដឺគូ។ រាជបញ្ញត្តិមួយ ចុះ ថ្ងៃ ១៣ សីហា ១៩៤៣ បង្គាប់ឲ្យប្រើអក្សររ៉ូម៉ាំង ដើម្បីសរសេរជាភាសាខ្មែរ (របៀបដូចអក្សរយួនសព្វថ្ងៃ។ ខ្មែរយើងជាច្រើននៅមានបញ្ជីជាតិ ឬបញ្ជីចុះអាពាហ៍ពិពាហ៍ដែលសរសេររបៀបនោះ)។ រាជបញ្ញត្តិមួយទៀត ថ្ងៃ ១៧ កក្កដា ១៩៤៥ បង្គាប់ឲ្យប្រើជាផ្លូវការនូវប្រែកតិទិន «បារាំង» (ហ្គោជេ បន្ទំឲ្យឈប់ប្រើប្រក្រតិទិនតាមចន្ទគតិ ព្រោះចង់បំបាត់បុណ្យចូលឆ្នាំខ្មែរ)។

ពេលដែលឧត្តមនាវី ដឺគូ, ពីឈូងសមុទ្រសៀម ទៅឈូងសមុទ្រតុងកឹង, កំពុងកាច់ចង្កូតទប់នាវាឥណ្ឌូចិនកុំឲ្យឃ្លីងឃ្លោង – នាវាឥណ្ឌូចិនដែលលើកទង់ជ័យបារាំងនៅឡើយ- ឧត្តមសេនីយ ដឺហ្គោល, ដែលនៅជាមួយអាវ៉ាប់ក្បែរវាលខ្សាច់សាហារ៉ា, កំពុងដោះស្រាយចំណោទផ្សេងទៀត។ ៣-៤ អាទិត្យក្រោយការកើតមាន «កងកម្លាំងបារាំងសេរី» មក, ដឺហ្គោល បង្កើត «សភាការពារអាណាចក្រ» ៖ ចំពោះ ដឺហ្គោល, ការរំដោះស្រុកបារាំងត្រូវធ្វើជាមួយគ្នានឹងការប្រុងប្រៀបកសាងឡើងវិញ នូវអាណាចក្រអាណានិគមបារាំង, ដែលអាចរលាយខ្ចាត់ខ្ចាយ ព្រោះតែការរលំនៃសាធារណរដ្ឋទី៣។ កសាងអាណាចក្រឡើងវិញ គឺធ្វើឲ្យស្រុកបារាំងទៅជាមហាអំណាចវិញ។ ថ្ងៃ ២២ កុម្ភៈ ១៩៤១ សភាការពារអាណាចក្រ ចេញសេចក្តីប្រកាសទី១ ថាខ្លួននឹងមិនទទួលស្គាល់ការបោះបង់ចោល (ទឹកដីអាណានិគម) ណាមួយឡើយ ពីសំណាក់រដ្ឋាភិបាល វីស៊ី, ជាពិសេសឥណ្ឌូចិន។ ដូច្នេះ ដឺហ្គោល នៅតែសម្លឹងមកឥណ្ឌូចិនជានិច្ច។ ខែមិថុនា ១៩៤៣ នៅក្រុងអាល់ហ្សេ, “គណៈកម្មការបារាំងរំដោះជាតិ” បានត្រូវប្រកាសឡើង។ ដឺហ្គោល មិនបានភ្លេចទេនូវការណ៍ដែលសម្ពន្ធមិត្តអង់គ្លេស និងអាមេរិកាំងរបស់គាត់ -ឈឺកឈិល និង រូសឺវែល- បានបែរទៅចចារជាមួយ ដារឡង់ និង ឧត្តមសេនីយ ហ្សីរ៉ូ វិញ (តំណាងរដ្ឋាភិបាល វិស៊ី) ក្នុងករណីដែលត្រូវដាក់ទ័ពលើ «ទឹកដីបារាំង» (ម៉ាដាហ្គាស្កា, អាល់ហ្សេរី)។ ការនេះបានមានឡើងក្រោយពេលដែលកងទាហានបារាំងសេរីទទួលបរាជ័យ ក្នុងការឡើងគោកលើប្រទេស ស៊ីរី។ មួយចំណែកទៀត ដឺហ្គោល ដឹងច្បាស់ថា ប្រ្វង់គ្លិន រូសឺវែល ឥតពេញចិត្តទាល់តែសោះ នឹងអាណានិគមនិយមរបស់បារាំង។ ហេតុនេះហើយបានជា ដឺហ្គោល មិនទុកចិត្តសម្ពន្ធមិត្តរបស់គាត់ ហើយយល់ថា ត្រូវតែជនជាតិបារាំងតយុទ្ធខ្លួនឯង ដើម្បីរក្សាអធិបតេយភាពលើឥណ្ឌូចិន។

នៅខែសីហា ១៩៤៣, សន្និសីទនៃក្រុងកេបិក សំរេចបើកឆាកប្រយុទ្ធមួយទៀត ដាក់ក្រោមបញ្ជាការឧត្តមនាវីអង់គ្លេស ម៉ោន បទ៉ឹន។ មណ្ឌលចំបាំងរបស់ ម៉ោន បទ៉ឹន ដែលទទួលឈ្មោះថា «បញ្ជាការអាស៊ីអគ្នេយ៍» (គឺក្នុងពេលនោះហើយ ដែលពាក្យថា "South East Asia" , អាស៊ីភាគអគ្នេយ៍, បានត្រូវប្រើជាលើកដំបូង)។ បេសកកម្មរបស់ ម៉ោន បទ៉ឹន គឺធ្វើ “វិទ្ធង្សនា” ផ្លូវសឹកនៅគ្រប់កន្លែងដែលជប៉ុនកាន់កាប់, ឥណ្ឌូចិន ក៏ដែរ។ គណៈកម្មការនៅ អាល់ហ្សេ របស់ ដឺហ្គោល ក៏ខំប្រឹងប្រែងធ្វើឲ្យគេបញ្ចូលកងឯកភាពបារាំងទៅក្នុង

បញ្ហាការអាស៊ីអគ្នេយ៍នោះ។ វរសេនីយត្រី ដឺឡង់ក្លាត (ក្រោយមកឡើងជាឧត្តមសេនីយ៍ត្រួតទ័ពជើងគោកនៅស្រុកខ្មែរមុនបានឯករាជ្យ) ដែលជាអ្នកទាក់ទងរវាងកងទាហានបារាំងនៅស្រុកចិន និងកងទាហានអង់គ្លេសនៅស្រុកឥណ្ឌា ពន្យល់ ម៉ោន បទ្ទីន អំពីប្រយោជន៍នៃយោធពលបារាំង ដែលស្គាល់ច្បាស់នូវទឹកដីឥណ្ឌូចិន។ ម៉ោន បទ្ទីន ដែលតាំងទីបញ្ជាការនៅក្នុងកោះស្រីលង្កា, ក៏ព្រមទទួលឲ្យបារាំងចូលរួមជាមួយ។ មិនយូរប៉ុន្មាន នាយទាហានបារាំងមួយក្រុមមកនៅក្រុងកាល់កុត្តា ហើយរៀបចំធ្វើការទាក់ទងតាមវិទ្យុជាមួយឥណ្ឌូចិន។ ដឺឡង់ក្លាត ទទួលការយល់ព្រមពី ដឺហ្គោល ឲ្យបង្កើត «ក្រុមសកម្ម» មួយ ដែលនឹងទៅរៀបចំបង្ក «ពួកក្នាក់ងារសម្ងាត់តស៊ូនឹងជប៉ុន» នៅឯឥណ្ឌូចិន[១៦]។

ប៉ុន្តែកិច្ចការសម្ងាត់នេះមិនមែនស្រួលទេ, ពីព្រោះឥណ្ឌូចិនរបស់ ដឺគូ មិនដែលលាក់ថាខ្លួនមិនចូលចិត្តនឹង "ពួក" ដឺហ្គោល ឡើយ។ ដឺគូ យល់ថាត្រូវតែទុកស្ថានការណ៍នៅឥណ្ឌូចិនឲ្យនៅដដែល (Statu Quo), កុំធ្វើកិច្ចអ្វីដែលអាចធ្វើឲ្យ ជប៉ុន មានប្រតិកម្មខ្លាំង, ប្រតិកម្មដែលអាចបញ្ចប់អធិបតេយភាពបារាំងលើឥណ្ឌូចិន។ ប៉ុន្តែមេទ័ពបារាំងនៅតុងកឹង, ឧត្តមសេនីយ៍ ម័រដង់, បានត្រូវគេខ្សឹបប្រាប់អំពីសកម្មភាពសម្ងាត់លើទឹកដីខ្លួន។ ធាប់ដឹងថាខ្យល់បក់មកពីខាងណា, ម័រដង់ វិនិច្ឆ័យថា ពេលវេលាមកដល់ហើយ ដែលត្រូវចុះចូលនឹងឧត្តមសេនីយ៍ ដឺហ្គោល។ ម័រដង់ ក៏ចាប់ប្តូរសារសម្ងាត់ជាមួយ "កាល់កុត្តា" ហើយសុំបញ្ជាពី ដឺហ្គោល។ ថ្ងៃ ៦ កក្កដា ១៩៤៤, គឺមួយខែគត់ ក្រោយការឡើងគោកនៅ នរម៉ង់ឌី របស់កងទ័ពសម្ពន្ធមិត្ត, ដឺឡង់ក្លាត លោតឆ័ត្រលើតុងកឹង ហើយជួបជាមួយ ម័រដង់ និងកូឈួយ, ឧត្តមសេនីយ៍ អែម៉េ, ឯហាណូយ។ ការនេះ ដឺគូ ឥតដឹងទេ។ បន្ទាប់ពីបានឃើញគំរោងការណ៍ផ្សេងៗ នៃ "ការតស៊ូ" ទល់នឹងជប៉ុនមក, ម័រដង់ និង អែម៉េ ក៏សុខចិត្ត "ចូលដៃ" ជាមួយទាំង២ នាក់។ ថ្ងៃ ២៥ សីហា, ដឺហ្គោល, នាយករដ្ឋាភិបាលបណ្តោះអាសន្ន, ដើរចូលក្រុងប៉ារីស —ដំណើរចូលដែលបានជាប់ក្នុងប្រវត្តិសាស្ត្របារាំង។ ថ្ងៃ ១២ កញ្ញា, ឧត្តមសេនីយ៍ ម័រដង់, ដែលបានចូល "រ៉ឺត្រែត" តាំងតែពីខែកក្កដា ហើយដែលឧត្តមសេនីយ៍ អែម៉េ ជំនួស, បានត្រូវរដ្ឋាភិបាលបណ្តោះអាសន្ន ដឺហ្គោល តែងតាំងដោយសម្ងាត់ជាអគ្គប្រតិភូនៃរដ្ឋាភិបាលបារាំងនៅឥណ្ឌូចិន។ នាទីថ្មី ហើយមិនទាន់បេញមុខនេះ នៅក្រោមបង្គាប់ផ្ទាល់របស់ «គណៈកម្មការសកម្មដើម្បីការរំដោះឥណ្ឌូចិន» ដែលគេបង្កើតឡើងស្របគ្នានៅស្រុកបារាំង, ហើយដែលរដ្ឋមន្ត្រីក្រសួងអាណានិគម រ៉ឺណេ ប្ល៉េវែន ដឹកនាំ។ ដល់ថ្ងៃ ២៤ តុលា ទើបរដ្ឋាភិបាលបណ្តោះអាសន្ន បានត្រូវទទួលស្គាល់ពីប្រទេសអង់គ្លេស, អាមេរិកាំង, រុស្ស៊ី និងកាណាដា (ពួកសម្ពន្ធមិត្ត)។ ៤ ថ្ងៃក្រោយមក អែម៉េ ឲ្យ ដឺគូ ដឹងអំពីរឿង ម័រដង់។ តូចចិត្តល្មមដែរ, ដឺគូ មិនព្រមនៅក្រោមបង្គាប់ ម័រដង់, ហើយក៏វាយទូរលេខសុំលាឈប់ ទៅរដ្ឋាភិបាលបណ្តោះអាសន្ន។ ប៉ុន្តែ បន្ទាប់ពីបានជួបគ្នា ២ដង ជាមួយ ដឺឡង់ក្លាត, ដឺគូ ក៏សុខចិត្ត "លេងជាមួយ" ៖ ដើម្បីកុំឲ្យជប៉ុនសង្ស័យ, ដឺគូ នៅតែធ្វើ "គូវែន័រ ហ្សេណេរ៉ាល់" ដដែល ប៉ុន្តែអំណាចមែនទែន ទាំងខាងស៊ីវិលទាំងខាងទាហាន ត្រូវកាន់កាប់ដោយ ម័រដង់។

តាំងពីខែតុលា មក (១៩៤៤), អាកាសយាននៃទ័ពជើងអាកាសអង់គ្លេសបានទម្លាក់តាមឆ័ត្រយោងនូវមនុស្សនិងអាវុធ លើស្រុកលាវ ស្រុកយួន និងស្រុកខ្មែរ[១៧]។ ប៉ុន្តែការណ៍ដែលឧស្សាហ៍ឃើញយន្តហោះអង់គ្លេសក្នុងអាកាសឥណ្ឌូចិន ដែលជារបស់បារាំង, ថែមទាំងការរើសបានឆ័ត្រយោងនិងសម្ភារៈ ដែលវាយោបានទាញឲ្យខុសពីទីដៅ, បានបំផុសការសង្ស័យរបស់ "កាំប៉េតៃ", ក្រសួងសម្ងាត់ជប៉ុន។ "កាំប៉េតៃ" នេះ បានទទួលការក្រែងរអាយ៉ាងខ្លាំង ពីសំណាក់បារាំង (នៅឥណ្ឌូចិន), អង់គ្លេស (នៅភូមានិងម៉ាឡេស៊ី) និងអាមេរិកាំង (នៅហ្វីលីពីន), ដោយសាររបៀបធ្វើការរបស់ខ្លួន ដែលអ្នកខ្លះថា មិនសូវខុសគ្នាពី «អិន.កា.វេ.ដេ.» រុស្ស៊ី, ឬតាមអ្នកខ្លះទៀតថាស្រដៀងនឹង «ហ្គេស្តាប៉ូ» អាល្លឺម៉ង់។ មិនយូរប៉ុន្មាន, ជប៉ុនក៏ដឹងអស់អំពី «ការដើរខ្សែលើ» របស់បារាំងនេះ។ ថ្ងៃ ២០ កញ្ញា ពលទាហានរបស់ឧត្តមសេនីយ៍ ម៉ាក់អារធួរ ឡើងគោកនៅ

*ហ្វីលីពីន ហើយថ្ងៃ ២៥ កុម្ភៈ ១៩៤៥ ដណ្ដើមបានក្រុងម៉ានីល។ ឥណ្ឌូចិនក៏បានលេចចេញមកដូចជាទីដៅមួយនៃការឡើងគោកលើកក្រោយរបស់ពួកអង់គ្លេស-អាមេរិកាំង។ ថ្ងៃ ៧ កុម្ភៈ, កងអាកាសចរអាមេរិកាំង ចេញពីមូលដ្ឋាននៅឥណ្ឌា ហើយទម្លាក់គ្រាប់បែកលើទីតាំងជប៉ុននៅឥណ្ឌូចិន[១៨] និងនៅប្រទេសថៃ។ ជប៉ុនក៏សំរេចថាទៅមុនដើងការណ៍ ហើយបង្ខំ ដឺគូ ឲ្យ "ទម្លាក់បៀ" របស់ខ្លួន។*

**ថ្ងៃ ៩ មិនា ១៩៤៥**, *ក្នុងវិមាន នរោត្តម (ទីស្ដីការ គូវែន័រ ហ្សេណេរ៉ាល់) ឯព្រៃនគរ, រដ្ឋទូតជប៉ុន ម៉ាត់ស៊ូម៉ូតូ ដាក់កំណត់ឲ្យ ដឺគូ ដោយទាមទារឲ្យកងទ័ពទាំងអស់នៅឥណ្ឌូចិន មកនៅក្រោមបញ្ជាការជប៉ុន។ ដឺគូមិនយល់ព្រម, ជប៉ុនក៏វាយភ្លាមៗ ក្នុងកំឡុងមួយយប់ប៉ុណ្ណោះ កងទ័ពបារាំងទាំងមូលនៅឥណ្ឌូចិន បានរលាយបាត់, ហើយជាមួយការណ៍នេះ គ្រឹះស្ថានអាណានិគមក៏បានរលំ។ លើកលែងតែយោធា ៣-៤ ពាន់នាក់, ក្រោមបញ្ជាការឧត្ដមសេនីយ៍ អាឡេះសង់ទ្រី និងសាបាដេ, ដែលបានចេញរួចទៅដល់ស្រុកចិន។ ដឺគូ និងមេទាហានទាំងអស់បានត្រូវគេយកទៅដាក់គុក។ នៅប្រទេសកម្ពុជា, កងទាហាន "ជើងក្រហម" ប្រមាណ ១០ យោធកូមិនោះ បានត្រូវជប៉ុនមកចាប់ដោយឥតទាំងដឹងខ្លួនបានបន្តិចឡើយ។ ស្អែកឡើង, តាមសេចក្ដីសុំរបស់ជប៉ុន ព្រះបាទនរោត្តម សីហនុ នៅភ្នំពេញ, ព្រះបាទស៊ីសាវ៉ាងវង្ស នៅវៀងចន្ទន៍,* ***ប្រកាសឯករាជ្យ*** *របស់ប្រទេសរៀងខ្លួន និងការបំបាត់ចោលនូវអាណានិគម (ប្រតិកត្តូរ៉ា) បារាំង។ ចំណែកឯអធិរាជ បាវ-ដាយ នៅក្រុងវ៉េ ក៏បានធ្វើដូច្នោះដែរ ១ ថ្ងៃក្រោយមក, ថ្ងៃ ១១ មិនា។*

*បណ្ដាជនទាំងឡាយនៅឥណ្ឌូចិន បានភ្ញាក់គ្រប់គ្នានឹងដំណឹងថាបានឯករាជ្យនេះ។ ប៉ុន្តែនៅស្រុកបារាំង, ឧត្ដមសេនីយ៍ ដឺហ្គោល យល់ថា ពេលវេលាមកដល់ហើយ ដែលត្រូវបង្ហាញឲ្យជាក់លាក់ នូវនយោបាយលើឥណ្ឌូចិន។ ថ្ងៃ ១៥ មីនា, ដឺហ្គោល និយាយទៅកាន់ប្រជាជនបារាំង ដោយបន្ទោសនយោបាយបោះបង់របស់ (រដ្ឋាភិបាល) វីស៊ី, ហើយអះអាងការសង្ឃឹមនិងចំណង់របស់ប្រទេសបារាំង ដែលចង់ឃើញឥណ្ឌូចិន "រំដោះ" ថ្ងៃ ២៤ មីនា រដ្ឋមន្ត្រីក្រសួងអាណានិគម ស្យាកុបប៊ី ប្រកាសថា កាលណាឥណ្ឌូចិន"រំដោះ" ហើយ គេនឹងបង្កើត «សហព័ន្ធឥណ្ឌូចិន» ដែលនឹងនៅក្នុង សហគាតពបារាំង[១៩], ហើយដែលបារាំងនឹងការពារផលប្រយោជន៍លើផ្ទៃអន្តរជាតិជំនួស។ ប៉ុន្តែ របនាសម្ពន្ធនៃសហព័ន្ធនោះ មិនទាន់បានរៀបចំនៅឡើយទេ មានតែពាក្យសន្យាខ្លះ ដូចតទៅនេះ ៖ «ជនជាតិនៅសហព័ន្ធនឹងទៅជាពលរដ្ឋឥណ្ឌូចិន និង ពលរដ្ឋនៃសហគាតពបារាំង។ អ្នកនោះនឹងអាចបំពេញមុខងារ (ក្នុងរដ្ឋ) សហព័ន្ធនៅឥណ្ឌូចិន និងនៅក្នុងសហគាតព។ សហព័ន្ធនឹងមានរដ្ឋាភិបាល (កណ្ដាល) មួយ ដឹកនាំដោយ គូវែន័រ ហ្សេណេរ៉ាល់ ម្នាក់។ ប្រទេសទាំង ៥ ដែលខុសគ្នាដោយអារិយធម៌, ជាតិសាសន៍, នឹងរក្សាទុកនូវលក្ខណៈផ្ទាល់របស់ខ្លួន នៅក្នុងសហព័ន្ធ»... ។ល។ ការប្រកាសនៃថ្ងៃ ២៥ សីហានេះ បានទៅជាមូលដ្ឋាននៃខ្សែនយោបាយបារាំងក្នុងឆ្នាំក្រោយៗ ទៀត។*

*យើងបានឃើញមកហើយថា ស្ថានភាពនៅឥណ្ឌូចិនកំពុងវិវត្តន៍ទៅតាមទិសមួយផ្សេងទៀត។ ការរលាយបាត់ភ្លាមនៃអំណាចបារាំង បានបំផុសឡើងភ្លាមដែរ នូវបញ្ហាទឹកដី, ជាពិសេសបញ្ហាកម្ពុជាក្រោម, កូសាំងស៊ីន។ ពេលដែលបារាំងឡើងគោកនៅឥណ្ឌូចិនជាលើកដំបូង, យួននិងសៀមកំពុងហែកចែកគ្នា នូវស្រុកខ្មែរ និងស្រុកលាវ។ ការបង្ខិតបង្ខំលើសៀមព្រមគ្នា, ពីសំណាក់បារាំងនិងអង់គ្លេស, បានធ្វើឲ្យសៀមដកដៃចេញមួយភ្លែតសិន ពីកម្ពុជាក្នុងព្រំដែនសព្វថ្ងៃ ដែលហៀបនឹងទៅជាខេត្តសៀមមួយទៅហើយ។ ប៉ុន្តែ កម្ពុជាក្រោម, ដែលយួនបានចូលមកនៅណែនណាន់តាន់តាប់ទៅហើយ, បានក្លាយទៅជាអាណានិគមពេញទី (កូឡូនី) របស់បារាំង ក្រោមឈ្មោះថា «កូសាំងស៊ីន», ដូចដែលអ្នកដើរសំពៅជាតិអឺរ៉ុបបានធ្លាប់ហៅមក។*

*ដល់ជាតិខ្មែរនិងជាតិយួនបាន «ឯករាជ្យ», បញ្ហាបញ្ជាក់ព្រំដែនរវាងប្រទេសទាំង២ ក៏ត្រូវតែមានឡើង។ ថ្ងៃ ១៧ មេសា (១៩៤៥) នៅប្រទេសវៀត-ណាម (ឈ្មោះជាផ្លូវការសេរសេរដូច្នេះ, កាលនោះ)*

*រដ្ឋាភិបាល ត្រឹងត្រួងគិម បានត្រូវតែងតាំងឡើង, ហើយក៏ចាប់គិតគូរ «បង្រួបបង្រួមប្រទេស» ភ្លាម គឺភ្ជាប់កូសាំងស៊ីនទៅវៀត-ណាម។ ថ្ងៃ ១៨ មិថុនា អធិរាជ បាវ-ដាយ ធ្វើសេចក្ដីថ្លែងការណ៍ បញ្ជាក់បំណងខ្លួនថា នឹងបង្កើយឯកភាពនៃវៀត-ណាម, ដោយប្រមូលមកដាក់ក្រោមការគ្រប់គ្រងនៃរដ្ឋាភិបាលក្រុងវេ, មិនត្រឹមតែទ្រុង-គី (អណ្ណាម) និង បាក់-គី (តុងកឹង) ទេ គឺថែមទាំងទឹកដីឯទៀតនៃអាណាចក្រ។ ព្រះចៅ សីហនុ យល់ច្បាស់ថាគេនិយាយពីកូសាំងស៊ីន, ក៏តបទៅវិញនៅថ្ងៃ ២៥ មិថុនា ៖ «ប្រទេសកម្ពុជាមិនអាចនៅព្រងើយកន្ដើយឡើយ ចំពោះការផ្លាស់ប្ដូរលក្ខន្តិកៈនៃដែនដីមួយ ដែលខ្លួននៅតែមានសិទ្ធិលើដរាប», ហើយក៏សុំឲ្យមានគណៈកម្មការមួយសំរាប់បញ្ជាក់ព្រំដែននៃប្រទេសទាំង២។ ជិតដាច់ខែកក្កដា, ត្រឹងត្រួងគិម បានធ្វើឲ្យជប៉ុនយល់ព្រមរំលាយការអភិបាលកណ្ដាលលើឥណ្ឌូចិន (របស់ គូវែន័រ ហ្សេណេរ៉ាល់), ហើយដាក់ តុងកឹងក្រោមឱវាទរដ្ឋាភិបាលក្រុងវេ ដោយតែងតាំងប្រតិភូអធិរាជម្នាក់នៅហាណូយ (ឯារយួនថា "ខាំ-សៃ")។ ប៉ុន្តែជប៉ុនទុកកូសាំងស៊ីនក្រោមឱវាទខ្លួនផ្ទាល់ ដោយតែងតាំងអភិបាលជប៉ុនម្នាក់ឈ្មោះ មីណូដា។ ព្រះបាទសីហនុបញ្ជូនលោក សឺង ង៉ុក ថាន់, ដែលពេលនោះជារដ្ឋមន្ត្រីការបរទេស ទៅព្រៃនគរ ដើម្បីនិយាយជាមួយជប៉ុន កុំឲ្យគេ "ឲ្យ" កូសាំងស៊ីនទៅយួន (កិច្ចប្រាស្រ័យជាមួយវរសេនីយឯក ហាយ៉ាស៊ី នៃក្រសួងនយោបាយជប៉ុន)។ មួយរំពេចនោះ ការតទល់គ្នារវាងខ្មែរក្រោមនិងយួន ក៏ផ្ទុះឡើងវិញ, ការតទល់គ្នាដែលបានត្រូវបញ្ឈប់ដោយដីឡាក្រង់ឡែរ ពីឆ្នាំ ១៨៨៣។ ខ្មែរក្រោមយើងទាំងក្រុមៗ, ប្រដាប់ដោយដាវនិងផ្គាក់, នាំគ្នាដើរជាជួរ ហើយប្រហារយួនទាំងអស់ដែលខ្លួនប្រទះតាមផ្លូវ។ នៅតាមភូមិខ្លះក្នុងកូសាំងស៊ីន, គេឃើញសាកសពជាច្រើន អណ្ដែតតាមបឹង, ស្ទឹង,ទន្លេ(២០)។*

*ក្នុងចន្លោះពេលនោះ សង្គ្រាមនៅតែឆេះខ្លាំងក្នុងមហាសមុទ្រ ប៉ាស៊ីហ្វិក។ ថ្ងៃ ១ មេសា ១៩៤៥ ការប្រយុទ្ធដ៏ខ្លាំងសាហាវដើម្បីកោះ អូគីណាវ៉ា បានចាប់ផ្ដើមឡើង។ ថ្ងៃ ១២ រូស៊ីវែល ស្លាប់, ហារី ទ្រូម៉ាន់ អនុប្រធានាធិបតី ឡើងជំនួស។ ថ្ងៃ ១៧ កក្កដា សន្និសីទនៅ ប៉ុតស្ដាំ ដើម្បីបែងពិភពលោកចែកគ្នា ចាប់ធ្វើឡើងដោយទ្រូម៉ាន់, ស្តាលីន និង ឈឺកឈិល (ដែលមកជាមួយ អាត់ទ្លី, បន្តិចទៀតរដ្ឋមន្ត្រីទីមួយ)។ រឿងឥណ្ឌូចិនដែលមិនបាននិយាយនៅយ៉ាល់តា បានត្រូវយកមកនិយាយឯ ប៉ុតស្ដាំ។ ទ្រូម៉ាន់ បន្តខ្សែនយោបាយនៃបុព្វការីខ្លួន (រូស៊ីវែល) ដែលមិនចង់ឲ្យបារាំងត្រឡប់មកឥណ្ឌូចិនវិញទេ(២១)។ ការណ៍នេះបានត្រូវបញ្ជាក់ឡើងដោយសេចក្ដីសំរេចរបស់សន្និសីទ ប៉ុតស្ដាំ ៖ កាលណាជប៉ុនចាញ់ហើយ, ឥណ្ឌូចិននឹងត្រូវបែងចែកជា ២ មណ្ឌល ដោយខ្សែស្របលេខ១៦ ដើម្បីទទួលការដាក់អាវុធចុះចាញ់ពីជប៉ុន។ ការដកអាវុធពីកងឯកភាពជប៉ុននៅស្រុកលាវនិងនៅស្រុកយួន ខាងលើខ្សែស្រប ព្រមទាំងការត្រួតត្រាបណ្ដោះអាសន្ននៃមណ្ឌលនោះ នឹងត្រូវប្រគល់ទៅឲ្យចិន (ជាងកាយជាក), ចំណែកនៅស្រុកខ្មែរ និងនៅភាគស្រុកយួន ក្រោមខ្សែស្រប, កិច្ចការដូចគ្នានឹងត្រូវប្រគល់ទៅឲ្យអង់គ្លេស។ ពីក្រុងប៉ុតស្ដាំ, ទ្រូម៉ាន់ គំរាមជប៉ុនឲ្យចុះចាញ់ ហើយដាក់ថ្ងៃ ៣ សីហា ជាថ្ងៃបង្ហើយ។ ថ្ងៃ ៦ សីហា (១៩៤៥) យន្តហោះ បេ-២៩ អាមេរិកាំងមួយ ទម្លាក់គ្រាប់បែកបរមាណូលើ ហ៊ីរ៉ូស៊ីម៉ា។ ថ្ងៃ ៨ សីហា ជប៉ុនផ្ទេរការត្រួតត្រាកូសាំងស៊ីន ទៅឲ្យ "ខាំ-សៃ", គឺថាឲ្យស្រុកកូសាំងស៊ីន ទៅវៀត-ណាម(២២)។ ថ្ងៃ ១៦ សីហា ជប៉ុនសុំចុះចាញ់។*

*************

*ក្នុងសន្និសីទនៅយ៉ាល់តា ក៏គេមិនហៅទៅ, នៅប៉ុតស្ដាំ ក៏គេមិនហៅទៅ, ដឺហ្គោល ទទួលការ «ក្មេចភ្នាំង» របស់សម្ពន្ធមិត្តគាត់នេះ ដូចជាត្រូវកំភ្លៀង ២-៣ ដៃ។ មួយថ្ងៃបន្ទាប់ពីការទំលាក់អាវុធនៃ "អាណាចក្រនៃព្រះអាទិត្យរះ" មក ដឺហ្គោល ថ្លែងសារមួយទៅកាន់សហភាពបារាំង៖ សាធារណរដ្ឋបារាំង "ប្រាថ្នាដាក់អធិតេយភាពខ្លួននៅឥណ្ឌូចិនឡើងវិញ"។ ការប្រាថ្នា (voeu) ដែលមានន័យយ៉ាងមុតតំរង់ទៅប្លុក អង់គ្លេស-អាមេរិ*

កាំង[២៣]។ ពេលដែលកងកម្លាំងអង់គ្លេសនិងចិន បានចាប់ផ្ដើមការរៀបចំខ្លួនទៅហើយ (គំរោងការណ៍ "ប៉ុតស្ដាំ"), ដឺហ្គោល ទើបតែតែងតាំងមេកើយរបស់គាត់ ៖ ជាមេបញ្ជាការនៃ "បេសកៈយោធពលបារាំងនៅចុងបូព៌ាប្រទេស", ឧត្ដមសេនីយ៍ ឡឺក្លែ ដែលថ្មីដៃក្នុងចំបាំងបានទៅជារឿងព្រេងទៅហើយ។ ជាអគ្គស្នងការនៃប្រទេសបារាំងនៅឥណ្ឌូចិន (នាទីដូច "គូវែន័រ ហ្សេណេរ៉ាល់" ដែលបានត្រូវបោះបោល) និង អគ្គមេបញ្ជាការកងកម្លាំងជើងគោក, ជើងទឹក និងជើងអាកាស, ដឺហ្គោលដាក់មេទ័ពសំណប់របស់គាត់ម្នាក់, ឧត្ដមនាវីផ្កាយ៥ ដាហ្សង់ល្យើ។ ឡឺក្លែ ត្រូវឡើងគោកឯឥណ្ឌូចិនតាមដានជើងពួកអង់គ្លេស។ ដាហ្សង់ល្យើ មានបេសកកម្មពីរផ្ទួនគ្នា ៖ ការគ្រប់គ្រងសហព័ន្ធឥណ្ឌូចិន ក្រោយពេលអស់សភាពជ្រួលច្របល់ និងការជុសលាងឥណ្ឌូចិនឲ្យអស់ «កំអែលវីស៊ី»។

នៅឥណ្ឌូចិន ព្រឹត្តិការណ៍ផុសឡើងបន្ដបន្ទាប់គ្នាយ៉ាងលឿន។ ថ្ងៃ ១៤ សីហា ១៩៤៥ លោក សឺង ង៉ុកថាន់ បានត្រូវតែងតាំងជារដ្ឋមន្ត្រីទី១ ហើយអំពាវនាវដល់ប្រទេសឲ្យប្រុងប្រៀបតយុទ្ធដើម្បីឯករាជ្យ។ នៅវៀត-ណាម, ពួកវៀតមិញ ដែលបានជួយជប៉ុនដេញបារាំងកាលពីខែមីនា, ចូលកាន់កាប់គ្រប់ក្រុងទាំងអស់, ហើយនៅថ្ងៃ ២៩ សីហា ហូជីមិញ ប្រកាសឡើងឯហាណូយ នូវ "សាធារណរដ្ឋប្រជាធិតេយ្យ វៀត-ណាម", បន្ទាប់ពីបានទទួលការដាក់រាជ្យនៃស្ដេចបាវ-ដាយ។ នៅវៀងចន្ទន៍ រដ្ឋមន្ត្រីទី១ ចៅ ផេត សារ៉ាត (មេចលនា "ឡាវ ឥស្សរា" ប្រកាសនៅថ្ងៃ ១ កញ្ញា, ថាការប្រកាសឯករាជ្យរបស់ស្ដេច ស៊ីសាវ៉ាងវង្ស នៅតែតំកល់ទុកដដែល។ ដូច្នេះ ឃើញថាបំណងនៃរដ្ឋាភិបាលនៃប្រទេសទាំងបីនៃឥណ្ឌូចិន មានសភាពច្បាស់លាស់ណាស់, ក្រោយពេលដែលជប៉ុនទទួលបរាជ័យ ៖ ឥតឲ្យនឹមបារាំងចូលមកវិញទេ។ ដើម្បីសំរេចបំណងនេះ, រដ្ឋាភិបាលទាំងបីក៏ខំប្រឹងប្រែងរៀងៗខ្លួន ឲ្យពួកសម្ពន្ធមិត្តទទួលស្គាល់តាមផ្លូវហេតុ (de facto)។ ថ្ងៃ ៦ កញ្ញា, កងទាហានអង់គ្លេស បញ្ជាដោយឧត្ដមសេនីយ ហ្គ្រេស៊ី ចាប់មកដល់ជាហូរហែឯព្រៃនគរ។ ថ្ងៃ ៧, ទាហានអង់គ្លេសមួយក្រុមមកដល់ភ្នំពេញ។ នៅស្រុកយួនភាគខាងជើង, កងទាហានចិន បញ្ជាដោយឧត្ដមសេនីយ លូហាន់ មកដល់ហាណូយ នៅថ្ងៃ ៩ កញ្ញា។ ក្នុងរយៈពេលនោះ ស្ថានភាពឥណ្ឌូចិនទាំងមូលមានសភាពច្រឡំបល់ មិនដឹងអ្នកណាជាអ្នកណា។ បើសិនជាក្នុងស្រុកខ្មែរ និងស្រុកលាវ គេឥតឃើញមានប្រតិកម្ម "ស្អប់បរទេស" ពីសំណាក់បណ្ដាជនទេ, នៅស្រុកយួន ផ្ទុយទៅវិញ, ការប៉ះទង្គិចគ្នារវាងយួននឹងជាតិបារាំង ដែលបានមករស់នៅយូរហើយ ធ្វើឲ្យមានការសំឡាប់រង្គាលនៅឯហាណូយ ក៏ដូចជានៅឯព្រៃនគរ។

ថ្ងៃ ៥ តុលា ឡឺក្លែ មកដល់ព្រៃនគរជាមួយទាហាន ៣៥ ០០០ នាក់ (ដាហ្សង់ល្យើមកដល់ថ្ងៃ ៣១)។ នៅទីនោះ "ការណ៍ល្អ" មួយនៅចាំគាត់ស្រាប់។ "ការណ៍ល្អ" នោះ គឺលោក ឃឹម-ទិត, នៃរដ្ឋាភិបាលខ្មែរ, ដែលយកមកឲ្យ ៖ ព្រះរាជាណាចក្រក្រុងកម្ពុជានៃព្រះបាទ នរោត្ដម សីហនុ យកខ្លួនមកឲ្យបារាំង ដោយឥតមានទាមទារយកអ្វីទៅវិញឡើយ (អាន រឿងក្នុងប្រទេស)។ នៅឆ្នាំ ១៨៦៣ ស្ដេច នរោត្ដម ពឹងបារាំងឲ្យមកទាញកម្ពុជាចេញពីក្រញាំសៀម។ ៨២ ឆ្នាំក្រោយមក, ចៅទួតពឹងម្ដងទៀត, ប៉ុន្តែលើកនេះ ដើម្បីជួយរបបរាជានិយមកុំឲ្យបាត់បង់។ ថ្ងៃ ១៦ តុលា ឡឺក្លែ ឈៀងចូលភ្នំពេញ ៤៥ នាទី, ពេលវេលាគ្រប់គ្រាន់ដើម្បីចាប់ សឺង ង៉ុកថាន់ យកទៅ។ ប្រទេសកម្ពុជាបានត្រូវយកបានមកវិញ ដោយមិនបាច់ប្រយុទ្ធ។ ទៅដល់ព្រៃនគរវិញ, ឡឺក្លែ ចាប់ផ្ដើមការ "ធ្វើឲ្យមានសន្តិភាព" នៅកូសាំងស៊ីន។ នៅពេលនោះ គណបក្សនយោបាយ និងក្រុមអ្នកកាន់សាសនាផ្សេងៗ នៅកូសាំងស៊ីន មានចំនួនច្រើនមិរដេរដាស ជាហេតុធ្វើឲ្យវៀតមិញមិនទាន់ខ្លាំងនៅឡើយ។ ដោយបានទទួលជំនួយពីអង់គ្លេសមកផង, ឡឺក្លែវាយបំបែកយ៉ាងធូរនូវការឡោមព័ទ្ធរបស់វៀតមិញ ដែលមានមនុស្សនិងសម្ភារៈតិចជាង។ ថ្ងៃ ២៨ មករា ១៩៤៦ កងទាហានអង់គ្លេសចេញពីព្រៃនគរ, ទុកបារាំងតែឯងនៅកាន់អំណាច។ ថ្ងៃ ៥ កុម្ភៈ ឡឺក្លែ អាចថ្លែងនៅមុខអ្នកសារព័តមានថា «ការធ្វើឲ្យមានសន្តិភាពនៅកូ

*សាំងស៊ីន និងនៅអណ្ដាមខាងត្បូង បានចប់សព្វគ្រប់ហើយ»។ ប៉ុន្តែ ចំពោះបុរសដែលបានដណ្ដើមយកបានក្រុងគូប្រ៊ា, ប៉ារីស, ស្ត្រាស្បួរ និង ប៊ែរ្គីះហ្កាឌឹន, សង្គ្រាមមួយបែបទៀតបានបញ្ចេញខ្លួនឡើង ៖ សង្គ្រាមធ្ងន់ៗ ឡឺគ្លែ យល់ឃើញថា ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសបារាំងនៅពេលនោះ ពុំអាចឲ្យខ្លួនឈមមុខតទល់នឹងសង្គ្រាមថ្មីនោះឡើយ។ សង្គ្រាមដែលនឹងធ្វើឲ្យបារាំងត្រហេបត្រហបយ៉ាងរហ័ស ហើយរហ័សខ្លាំងទៅទៀត ព្រោះខ្លួនត្រូវធ្វើឲ្យសេដ្ឋកិច្ចដើរឡើងវិញ ដើម្បីឡើងទៅកាន់អតីតៈ ឋានៈខ្លួនក្នុងអឺរ៉ុប។*

*កូសាំងស៊ីនបានសន្តិភាពហើយ, កម្ពុជាក៏បានមកវិញយូរហើយ ឡឺគ្លែ ដោះស្រាយបញ្ហា លាវ និងតុងកឹង។ ពេលនោះ, មាននៅពីមុខគាត់ មិនគ្រាន់តែអង្គការកណ្ដាលរបស់វៀតមិញទេ, គឺមានទាំងកងទ័ពចិន ៤ កងទៀត (ជាតិនិយម, ១៨០ ០០០ នាក់) ដែលកាន់កាប់ទឹកដីតាមការសំរេចនៅប៉ុតស្ដាំ។ ការទៅយកតុងកឹងវិញ មិនអាចធ្វើតាមរបៀប "ក្ដៅ" របស់ ហ្កាល្បេនី ឬ ល្បោគី បានឡើយ។ ឡឺគ្លែ ប្រើយុទ្ធសាស្ត្រមួយទៀត ៖ ការចចារ។ ការចចារត្រូវធ្វើលើផ្លូវ២ ៖ ផ្លូវទូតជាមួយចិន, និងផ្លូវនយោបាយជាមួយ ហូជីមិញ (ឡឺគ្លែប្រាប់អ្នកចចារបារាំងថាកុំញញើតនឹងប្រើពាក្យ "ឯករាជ្យ" ! )។ ថ្ងៃ ២៨ កុម្ភៈ ១៩៤៦, ឯជុង-គីង, បារាំងនិងចិនចុះសន្ធិសញ្ញាមួយ ធ្វើការប្ដូរដូចតទៅ ៖ ទ័ពចិនទាំងអស់នឹងចេញពីតុងកឹង និងពីលាវ, បារាំងប្រគល់សិទ្ធិខ្លួនទៅចិនវិញ ដែលខ្លួនធ្លាប់មាននៅសៀងហៃ, ជានទៀន, ហាន់កេវ និងកង់តុង, បារាំងឲ្យដីឈ្នួល ក្វាងចេវវ៉ាន់ទៅចិនវិញ, កំពង់ផែ ហៃផុង ឥតយកពន្ធអាករ លើផលិតផលចិន, ជនជាតិចិននៅឥណ្ឌូចិន នឹងបង់ពន្ធដារមិនលើសពីអ្នកឯទៀត ហើយនឹងមានឯកសិទ្ធដូចជនជាតិបារាំងក្នុងផ្លូវច្បាប់និងផ្លូវតុលាការ។ ថ្ងៃ ៦ មីនា នៅហាណូយ, សាំងតឺនី[២៤] និង ហូជីមិញ ចុះហត្ថលេខាលើកិច្ចសន្យាផ្ដើមសេចក្ដីបារាំង-យួន ដែលចែងថា ៖ "រដ្ឋាភិបាលបារាំងទទួលស្គាល់សាធារណរដ្ឋវៀត-ណាម ជារដ្ឋសេរី" ដែលមានរដ្ឋាភិបាល, រដ្ឋសភា, កងទ័ព និង ហិរញ្ញវត្ថុខ្លួន ហើយដែលនៅក្នុងសហព័ន្ធឥណ្ឌូចិន និងសហភាពបារាំង។ ចំពោះការបង្រួបបង្រួម «គី» ទាំងបី, បារាំងទទួលតាមការសំរេចរបស់បណ្ដាជន (ប្រជាមតិ)។ ពលទាហានបារាំង ១៥ ០០០ នាក់ នឹងអាចចូលទៅតុងកឹងដើម្បីជំនួសទាហានចិន, ប៉ុន្តែ ៥ ឆ្នាំក្រោយមកត្រូវចេញឲ្យអស់ ។ល។*

*ប៉ុន្តែ ដាហ្សង់ល្បឺ យល់ឃើញផ្ទុយទាំងស្រុងពី ឡឺគ្លែ ៖ ការយកឥណ្ឌូចិនមកដាក់ក្រោមអំណាចបារាំងវិញ ត្រូវធ្វើតែតាមកម្លាំង, ហើយរបបគ្រប់គ្រង គឺរបបអាណានិគមជំនាន់មុនៗ ដោយទ័ពបារាំងមានក្បាល២, ដាហ្សង់ល្បឺ ដឹងយឺតហួសទៅហើយ អំពីការចុះកិច្ចសន្យាជាមួយវៀតមិញនោះ, ហើយក៏អាចតែបញ្ចេញពាក្យប្រវត្តិសាស្ត្រនិងអក្សរសាស្ត្រខ្លះប៉ុណ្ណោះ។ ការប្រជែងរវាងគំនិតទាំង២ បានក្លាយយ៉ាងរហ័សទៅជាការប្រជែងរវាងមនុស្សទាំង២។ ប៉ុន្តែក្រោយបន្តិចមក ឡឺគ្លែបានស្លាប់ទៅក្នុងគ្រោះថ្នាក់យន្តហោះមួយ។ ដើម្បីផ្ចាញ់ ហូជីមិញ ដែលតយុទ្ធយ៉ាងស្វិតស្វាញរកភ្ជាប់កូសាំងស៊ីនទៅវៀត-ណាម, ដាហ្សង់ល្បឺ លេងសន្ទឹកបៀ «កូសាំងស៊ីនផ្សេង- វៀតណាមផ្សេង»។ សន្ទឹកបៀនេះ បានរុញប្រទេសបារាំងឲ្យបញ្ឆេះភ្នក់ភ្លើងមួយ ដែលប្រវត្តិសាស្ត្រពិភពលោកបានដាក់ឈ្មោះថា សង្គ្រាមទី១នៃឥណ្ឌូចិន។*

************

*សង្គ្រាមនេះ ទាល់តែឆ្នាំ ១៩៥៤ ទើបបានចប់ ហើយបានធ្វើឲ្យស្លាប់និងរបួសជាង ៧៧ ០០០ នាក់ គ្រាន់តែខាងបារាំងនិងសមាគតរដ្ឋ[២៥]។ នៅលើដីមួយដែលធ្លុះធ្លាយទៅហើយ អាមេរិកាំងមកជំនួសបារាំង។ ឥតព្រមចប់ សង្គ្រាមបន្តទៅមុខទៀតនូវការកំទេចនិងប្រហាររបស់ខ្លួន។ សាកសពខ្មែររាប់លាន និងសំរែកដង្ហោយព្រោះការឈឺចាប់ដ៏មហិមានៃប្រជាជនយើង ដែលយើងឮខ្សាវៗ ក្នុងពេលនេះ គឺជាហេតុផលត្រង់ៗនៃសង្គ្រាមនេះ។*

# អធិប្បាយ

*(១) រូស៊ីវែល មានបំណងខ្លាំងនឹងបំផ្លាញអាណានិគមនិយមបារាំង។ ក្នុងពេលដែលកិច្ចការចចារ អាមេរិកាំង-ជប៉ុន លើរឿងចិនកំពុងតែធ្វើ (តាំងពីដើមឆ្នាំ ១៩៤១), ទ័ពជប៉ុនចូលទៅប្រទេសយួនភាគខាងត្បូង និងប្រទេសកម្ពុជា (ខែកក្កដា ១៩៤១)។ អាមេរិកាំងសួរនាំជប៉ុនអំពីរឿងនេះបណ្ដើរ ស្នើទៅជប៉ុនអំពីការធ្វើឲ្យឥណ្ឌូចិនទៅជា “អព្យាក្រឹត” បណ្ដើរ។ ថ្ងៃ ២៦ កក្កដា រូស៊ីវែល បញ្ជាឲ្យផ្អឹបទ្រព្យសម្បត្តិជប៉ុនទាំងអស់ ទុកក្នុងសហរដ្ឋ។ កិច្ចនេះបានត្រូវធ្វើតាម ដោយអង់គ្លេសនិងប្រទេសទាំងអស់ក្រោមឱវាទខ្លួន។ ប៉ុន្តែកិច្ចការចចារនៅតែបន្តទៅទៀត។ ជប៉ុនសុំឲ្យសហរដ្ឋអាមេរិកបញ្ឈប់ការប្រុងប្រៀបរៀបចំការពារកោះហ្វីលីពីន, ឈប់ឲ្យជំនួយទៅអង់គ្លេសនិងហូឡង់ (ដែលយកទៅពង្រឹងការការពារទឹកដីខ្លួន ក្នុងសមុទ្រប៉ាស៊ីហ្វិក) ហើយ, លើសអ្វីទាំងអស់, ឈប់ជួយចិន។ ស.រ.អា. ឆ្លើយទៅវិញថា នឹងគ្មានការព្រមព្រៀងអ្វីទាំងអស់ បើជប៉ុនមិនព្រមបញ្ឈប់ការពង្រីកអំណាចខ្លួន។*

*ថ្ងៃ១៧តុលា រដ្ឋាភិបាលម្ចាស់ កូណូយេ ផ្ទេរតំណែងឲ្យរដ្ឋាភិបាលទាហានរបស់ឧត្តមសេនីយ៍ តូយោ។ តូយោ ខំបង្ហាញសុឆន្ទៈ ដោយបញ្ជូនទៅវ៉ាស៊ីងតោននូវរដ្ឋទូតដែលក្មេងជាងគេ, សាប៊ូរូ គូរូស៊ូ។ ថ្ងៃ ២០ វិច្ឆិកា សាប៊ូរូ ឲ្យទៅរដ្ឋលេខាធិការ គ័រដែល ហ៊ុល នូវការឲ្យថ្ងៃចុងក្រោយរបស់ជប៉ុន : “ បើ ស.រ.អា. ឈប់ផ្អឹបទុកសម្បត្តិជប៉ុន, បើកឲ្យមានការលក់សាំងឲ្យប្រទេសជប៉ុនវិញ ហើយ, លើសអ្វីទាំងអស់, ឈប់ជួយចិន, ជប៉ុននឹងដកខ្លួនពីកម្ពុជានិងពីវៀតណាមខាងក្រោម ហើយត្រឡប់មកទីតាំងខ្លួនឯតុងកឹងវិញ”។ ថ្ងៃ ២៦ ហ៊ុល ឆ្លើយថា ប្រទេសខ្លួនចង់និយាយពីចំណោទទូទៅនៅអាស៊ី ហើយសុំឲ្យជប៉ុនដកទ័ពចេញពីស្រុកចិន។ គឺថាដូចមនុស្សថ្លង់ជជែកគ្នា! ១១ ថ្ងៃក្រោយមក, ថ្ងៃ ៧ ធ្នូ, ជប៉ុនវាយកើលហ៊ែបបួរ។*

*(២) ដឹគូ បានត្រូវគេបញ្ជូនទៅមុខតុលាការជាន់ខ្ពស់ ដូចដែល ដឺហ្គោល បានគ្រោងទុកក្នុងវិធានការណ៍ “បោកលាង” របស់គាត់។ តុលាការបានកាត់ឲ្យរួចខ្លួន ដោយឥតច្បាប់ចោទ* (non-lieu)*។ ចំណែកឯកាទ្រូ បានត្រូវគេដេញចោលភ្លាមនៅពេលនោះ ហើយបន្ទាប់មកបានទៅចូលជាមួយ ដឺហ្គោល ទៅ។*

*(៣) កាលពីឆ្នាំ ១៩៣៣ ក្នុងសន្និសីទនៃ “សមាគមប្រជាជាតិ” (បុព្វការីរបស់អង្គការសហប្រជាជាតិសព្វថ្ងៃ) មានតែគណៈប្រតិភូថៃទេ ដែលបោះឆ្នោតអនុប្បវាទ លើការផ្ដន្ទាប្រទេសជប៉ុនដែលបានឈ្លានពានម៉ាន់ជូរី។ នៅឆ្នាំ ១៩៣៨ ប្រទេសថៃចុះសន្ធិសញ្ញាមួយជាមួយប្រទេសជប៉ុន អនុញ្ញាតិឲ្យជនជាតិជប៉ុនក្នុងប្រទេសថៃ មានសិទ្ធិដូចជនជាតិថៃ ក្នុងផ្លូវច្បាប់រដ្ឋប្បវេណី និងផ្លូវច្បាប់ពាណិជ្ជកម្ម។*

*(៤) តាមសៀវភៅបារាំងខ្លះ អនាគតសេនាប្រមុខ លន់ នល់ បានចូលរួមក្នុងកិច្ចប្រតិបត្តិការទាំងនោះ ក្នុងកងវរសេនាតូចលេខ១ “ទារ៉ៃយ័រ” (កងទាហានជើងក្រហម)។ ប៉ុន្តែ តាមសំដីឥស្សរជនយើងខ្លះ លោក លន់ នល់ ឥតបានធ្វើទាហានជើងក្រហមទេ ហើយអស់លោកដែលបានបញ្ជាក្នុងកងទារ៉ៃយ័រនោះ មាន : ឧ.ស. សូកាំខូយ, ឧ.ស. ដួង សំអុល, ឧ.ស. ធាយ ឡាយ, លោក អ៊ុំ កង, លោក ហ៊ឹម សេស និងលោក ស៊ីន ដែលបានត្រឡប់ចូលមកជីវិតស៊ីវិលវិញ។ កងទាហានបារាំងមួយផ្នែកទៀត ដែលអ្នកផងបានហៅថា ទាហានជើងខ្មៅនោះ គឺកងរក្សាឥណ្ឌូចិន* (Garde Indochinoise)*។ បានធ្វើទាហាន*

ជើងខ្មៅ : ដាប ឈួន និង ឱ.ស. ខ្ចូត ប៊ិតៗ ឯគុណនាម "ក្រហម" និង "ខ្មៅ" នោះ គឺមកពីពណ៌បន្ទះកំណាត់ ដែលរុំកំភួនជើងពលទាហានទាំងនោះ។

(៥) ជាថ្មីម្តងទៀត សៀមកាន់កាប់ខេត្តទាំងនេះ (កំឡុង ៥ ឆ្នាំ, អានទំព័រ ៦៥, លេខយោង ១៣) ហើយបានខិតខំផ្សព្វផ្សាយវប្បធម៌ខ្លួន (ជាពិសេស ភាសា) ដោយបញ្ជូនមកជាច្រើន នូវគ្រូបង្រៀនទាំងប្រុសទាំងស្រី។

(៦) ថ្ងៃ ២៥ មករា ១៩៤២ រដ្ឋាភិបាលថៃនៃភិបុលសង្គ្រាម ប្រកាសសង្គ្រាមទល់នឹងអង់គ្លេស និងអាមេរិកាំង (តាមអ្នកខ្លះថា ភិបុលចង់ទប់ទល់នឹងជប៉ុនដែរ ប៉ុន្តែសុំជំនួយពីអង់គ្លេសមិនបាន ព្រោះស្រុកនេះក៏កំពុងពិបាកដែរ)។ ព្រិឌី ភ្នំយង់ ដែល "ប្រឆាំង" នឹងនយោបាយ ភិបុល ត្រូវគេយកចេញហើយដាក់ឲ្យធ្វើជារាជានុសិទ្ធ។ ប៉ុន្តែរាជទូតថៃនៅវ៉ាស៊ីងតោន, សេនីប្រាមោជ្ជ, (រាជទូតនៅអង់គ្លេសក៏ធ្វើដូច្នេះដែរ) មិនព្រមបញ្ជូនសេចក្តីប្រកាសសង្គ្រាមទៅរដ្ឋាភិបាល ស.រ.អា. ហើយបង្កើតក្រុមមួយឈ្មោះ "ថៃសេរី" ដោយមាននិស្សិតថៃនៅសហរដ្ឋជួយផង។ គឺជាមួយពួក "ថៃសេរី" នោះហើយ ដែលក្នុងឆ្នាំ ១៩៤៥ ភិបុលទាក់ទងយ៉ាងសំងាត់តាមរយៈ ព្រិឌី។ ដោយបាក់ចិត្តនឹងកាយវិការនេះ អាមេរិកាំងបានឲ្យប្រទេសថៃរួចខ្លួន (ដោយមិនសំគាល់ជាបច្ចាមិត្រ) នៅពេលដែលជប៉ុនចាញ់។

(៧) តាំងពីឆ្នាំ ១៩៣៥ លោក សឺង ង៉ុកថាន់ និងលោក បួរ ហ៊ីង (ដែលជាសាច់ញាតិព្រះមហាក្សត្រីកុសមៈ) តែងជំនុំគ្នាជាមួយបញ្ញាវន្តក្មេងៗ មួយក្រុម ដែលចង់ឲ្យវង្ស នរោត្តម សោយរាជ្យជួសវង្ស ស៊ីសុវត្ថិ វិញ (គេថាវង្ស នរោត្តម ស្រឡាញ់ជាតិជាងវង្ស ស៊ីសុវត្ថិ)។ ពួក "រកក្បត់" នោះ ក៏ខំចុះ-ឡើង ម្ចាស់សុធារស និង សុរាម្រឹត។ ពេលស្តេចមុនីវង្សសុគត ដឺគូ ក៏ដូចជាបានសំរេចបំណងអ្នកទាំងនោះដែរ ដោយដាក់ម្ចាស់ នរោត្តម សីហនុ លើបល្ល័ង្ក។ ក្នុងសៀវភៅ "ឥណ្ឌូចិនឃើញពីប៉េកាំង" សម្តេចសីហនុ រ៉ាយរ៉ាប់ : " មុនដំបូង ពួកថាន់និយមសប្បាយរីករាយណាស់។ ឃើញថាបល្ល័ង្កបានមកស្តេចក្មេងមួយអង្គនៃវង្ស នរោត្តម ហើយ ស្តេចដែលខ្លួននឹងអាចដឹកនាំទៅកាន់ការតស៊ូ។ ពួកនេះនឹងបាត់ញញឹមយ៉ាងរហ័ស ហើយខ្ញុំក៏ដូចគ្នាដែរ។ ពេល ហ្គោដេ (រ៉េស៊ីដង់ ស៊ូប៉េរីយ៉េបារាំង) មកដល់ យើងក៏បានដឹងថា អ្វីជារបបរបស់ ប៉េតាំង...។ រាល់ថ្ងៃអាទិត្យនៅទីលានកីឡា អ្នកមើលខ្មែរត្រូវច្រៀងបទ " សេនាប្រមុខ, យើងមកដល់ហើយ" មុនពេលប្រកួតបាល់ទាត់។ ក្នុងនាទីជាស្តេច គេក៏ពិបាកឲ្យខ្ញុំច្រៀងដែរ ប៉ុន្តែខ្ញុំត្រូវតែក្រោកឡើងឈរផ្ទឹមជើង !"។

(៨) កើតនៅព្រះត្រពាំង (សព្វថ្ងៃត្រាយិញ) កុមារ សឺង ង៉ុកថាន់ ធ្វើមធ្យមសិក្សានៅព្រៃនគរ។ រួចមកចូលធ្វើ "បោយ" នៅលើកប៉ាល់បារាំងមួយ ដើម្បីមកស្រុកនេះ។ នៅស្រុកបារាំង សឺង ង៉ុកថាន់ បានធ្វើឧត្តមសិក្សាខ្លះ (តាមអ្នកខ្លះថា)។ មកដល់កូសាំងស៊ីនវិញ គាត់រកការធ្វើពុំបានសោះ ក្នុងរដ្ឋការអាណានិគម។ ពេលនោះហើយ ដែលគេបានហៅគាត់មកភ្នំពេញ ដែលនៅទីនោះមិត្តបារាំងខ្លះនឹងជួយគាត់ឲ្យបានការធ្វើ។ ដំបូង ធ្វើជាសុភានៅក្រសួងយុត្តិធម៌ រួចមក ផ្លាស់ទៅពុទ្ធសាសនបណ្ឌិត្យធ្វើជាអ្នកកាន់កាប់បណ្ណាល័យ។ នៅទីនោះ លោក សឺង ង៉ុកថាន់ ជួបស្គាល់លោកអាចារ្យ ហែម ចៀវ លោក ប៉ាច ឈឺន លោក ប៊ុណ្ណ ចន្ទម៉ុល ។ល។ បើសិនជាគាត់ឥតបានកើតនៅកម្ពុជាក្រោមទេ បើសិនជាឈ្មោះគាត់មិនមែន "ឈ្មោះយួន" ទេ បុរសនេះប្រហែលអាចបានទៅជា "ហូជីមិញខ្មែរ"។ពាក្យហៅខ្មែរក្រោម (មិនហៅ "ខ្មែរ" តែមួយម៉ាត់) ដែលគេប្រើដើម្បីនិយាយពីអ្នកដែលកើតនៅនិងរស់នៅឯកម្ពុជាក្រោម បង្ហាញឲ្យឃើញ "ការមិនទទួល" មួយហើយពីសំណាក់អ្នកហៅ។ ខ្មែរក្រោម ដែលគេបានបោះបង់ចោលឲ្យរស់តាមយថាកម្មខ្លួននៅសតវត្សរ៍ទី១៩, ខ្មែរក្រោម ដែលយួនទាំងលាន

នាក់មកគ្របដណ្តប់ដូចរលកផ្ទប់ច្រាំង រស់នៅយ៉ាងចង្អៀតក្នុងសហគមន៍ខ្លួន ហើយខំការពាររក្សាទុក យ៉ាងស្វិតស្វាញ នូវកេរ្តិ៍មរតកខ្លួន ទាំងវប្បធម៌ ទាំងសាសនា។

ការតយុទ្ធយ៉ាងយូរជាប់រាប់តំណនេះ បានបញ្ចូលការស្វាហាប់ទៅក្នុងជំនាន់មនុស្សដែលកើតបន្តបន្ទាប់មក ការស្វាហាប់ដែលទទួលការច្រណែនពីសំណាក់ខ្មែរកណ្តាល។ ថ្វីត្បិតតែមិនបញ្ចេញឲ្យគេដឹងការច្រណែននេះ, បូកចូលនឹងគំនិតកាន់បក្សពួក, បានបង្កើតសោកនាដកម្មនឹងការជូរចត់ជាច្រើនក្នុងពង្សាវតាខ្មែរក្រោមនៅកម្ពុជា។ ឧទាហរណ៍ជាក់ស្តែងមួយ គឺឃាដកម្មលើកងយោធាខ្មែរកម្ពុជាក្រោម ក្នុងសង្គ្រាមនៃប្រទេសកម្ពុជា (១៩៧០-១៩៧៥) : ដោយច្រណែននឹងការអង់អាចមុះមុតនៃកងយោធាខ្មែរក្រោម —ដែលជាជនរួមឈាមខ្លួនសោះ— ទីអគ្គមេបញ្ជាការនៃកងកម្លាំងជាតិខ្មែរបានបញ្ជូនទៅឲ្យស្លាប់ទទេៗ ខ្មែរកម្ពុជាក្រោមប្រមាណ ១០ ០០០ នាក់ នៃកងម៉ៃក៍ហ្វ៊ក (Mike Force) ដែលចេញពីវៀតណាមខាងត្បូង មកជួយ "បងប្អូន" ឯកម្ពុជា។

លោក ស៊ឺង ង៉ុកថាន់ បានមានជីវិតនយោបាយយ៉ាងយូរ ពីក្នុងរាជាណាចក្រទៅក្នុងសាធារណរដ្ឋ ហើយបានតទល់ ចូលដៃ ឬមិនរវីរវល់ ជាមួយប្រមុខរដ្ឋ ៦ នាក់ : ព្រះបាទស៊ីសុវត្ថិ មុនីវង្ស, ព្រះបាទនរោត្តម សីហនុ, ព្រះបាទនរោត្តម សុរាម្រឹត, សម្តេចនរោត្តម សីហនុ, លោក ចេង ហេង, និង សេនាប្រមុខ លន់ នល់។ ជីវិតនយោបាយដ៏វែង (១៩៣៥-១៩៧២) និងដែលកម្រមានចំពោះខ្មែរកម្ពុជាក្រោម (នៅកម្ពុជា) នេះ មានខ្ពស់មានទាបជាច្រើន ហើយបានចប់នៅទីក្រុងភ្នំពេញជាមួយ... គ្រាប់បែកប្លាស្ទិកមួយ !

(៩) អ្នកនិពន្ធខ្មែរយើងម្នាក់បានសរសេរថា បើគេបំបាត់ពុទ្ធសាសនានៅកម្ពុជា គេបំបាត់ព្រមគ្នានូវព្រលឹងខ្មែរ។ ក្នុងខែមេសា ១៩៧៥ សេចក្តីសន្និដ្ឋាននេះ បានបង្ហាញភាពត្រឹមត្រូវរបស់ខ្លួន។ ឥឡូវនេះ តើគេអាចអះអាងថា "បើព្រលឹងខ្មែរផុសឡើងវិញនៅកម្ពុជា នឹងផុសឡើងជាមួយគ្នានូវពុទ្ធសាសនា" បានទេ? ឆ្នាំនៃអារិយធម៌ខ្មែរ ព្រះសង្ឃបានចែកជាមួយស្តេច នូវអំណាចគ្រប់គ្រងប្រទេស ក្នុងកំឡុងកាលដ៏យូររាប់សតវត្សរ៍។

(១០) ក្នុងទ័ពបារាំង (និងទ័ពប្រទេសកាន់សាសនាគ្រិស្ត ជាទូទៅ) មានអ្នកបួស ធ្វើជាអាចារ្យសំរាប់យោធភូមិទាំងអស់ ឬដែលទៅជាមួយទាហានក្នុងពេលច្បាំង ហើយដែលបារាំងហៅថា "អូម៉ូនីញេ"។ (អានលេខយោង ៤ អំពីទាហានជើងក្រហម)។

(១១) បារាំងបានយកកោះត្រឡាច (ពូឡូកុងឌ័រ) ធ្វើជាគុកសំរាប់ដាក់មនុស្សទោសឧក្រិដ្ឋធំៗ និងមនុស្សទោសនយោបាយ។ លោក ប៉ាច ឈឿន (ដែលក្រោយមកបានត្រូវគេដោះលែងមកវិញ) តែងបង្ហាញដល់គេឯង នូវស្នាមកងដែកលើ កជើង គាត់ កងដែកដែលសំរាប់ចងភ្ជាប់មនុស្សទោសជាអល្វជ្ជី។ នៅភ្នំពេញ លោក ប៉ាច ឈឿន បានចូលរួមច្រើនដង ក្នុងរដ្ឋាភិបាល (ធម្មការ ឃោសនាការ ។ល។)។ ក្រោយខែមីនា ១៩៧០ រដ្ឋាភិបាលសាធារណរដ្ឋបានសុំមកវិញ នូវអដ្ឋិព្រះអាចារ្យ ហែម ចៀវ ហើយបានធ្វើបុណ្យរំលឹកវិញ្ញាណក្ខ័ន្ធ វីរៈបុរសនៃការតស៊ូទល់នឹងបារាំងនេះ។

(១២) ដូចពួកណាហ្ស៊ីអាល្លឺម៉ង់នៅអឺរ៉ុបដែរ ជប៉ុនចង់ធ្វើឲ្យប្រទេសអាស៊ីទាំងអស់ ទៅជារណបខ្លួន។ ប៉ុន្តែចំពោះប្រទេសនៃអាស៊ីអាគ្នេយ៍ ដែលនៅក្រោមអាណានិគមពួកស្បែកស ជប៉ុនជាអ្នករំដោះ ជាងជាអ្នកលុកលុយ។ ការចង់ចែកគ្នាចំរុងចំរើន តាមភូមិភាគរៀងខ្លួននៃពិភពលោក (ហៅភូមិភាគនិយម) បានត្រូវគេយកមកសិក្សាច្រើនគ្នានៅអាស៊ីអាគ្នេយ៍ ក្រោយសង្គ្រាមលោកលើកទី២។ ចាប់តាំងពីឆ្នាំ ១៩៤៣ រឿង "ពិភពសម្បូណ៌សប្បាយជាមួយគ្នា" (Sphère de co-prospérité) បានត្រូវ

*ជនជាតិឥណ្ឌាម្នាក់ឈ្មោះ ប៉ាន្និការ យកមកសិក្សាម្តងទៀតក្នុងសៀវភៅ "អានាគតនៃអាស៊ីភាគអគ្នេយ៍"។ ប៉ាន្និការ បានឲ្យយោបល់ថា គួរប្រទេសទាំងអស់នៅអាស៊ីភាគអគ្នេយ៍ ចូលរួបរួមគ្នាក្នុងសម្ពន្ធភាព "សេដ្ឋកិច្ច" មួយ ក្រោមការដឹកនាំនៃប្រទេសឥណ្ឌា (ក្រោយបរាជ័យនៃជប៉ុន)។ តែងតាំងជារដ្ឋទូតឥណ្ឌាប្រចាំប្រទេសចិននៅឆ្នាំ ១៩៤៩ ប៉ាន្និការ ធ្វើកំណត់ហេតុមួយ ដែលនៅក្នុងនោះ គាត់បន្ទើសភាពដុនដាបនៃស្ថានភាពនៅប្រទេសក្នុងអាស៊ីភាគអគ្នេយ៍ : "បើគ្មានជំនួយយ៉ាងរហ័ស ហើយសមតាមការត្រូវការ នៅលើផ្ទៃសេដ្ឋកិច្ចទេ របនាសម្ពន្ធនយោបាយនៃអាស៊ីភាគអគ្នេយ៍ គ្រាន់តែជារបងដ៏ស្តើងមួយ ទល់នឹងការពង្រីកខ្លួននៃលទ្ធិកុម្មុយនិស្ត"។ ដោយដឹងថាឥណ្ឌាមិនអាចផ្តល់ជំនួយនោះបាន ប៉ាន្និការ សុំឲ្យរដ្ឋទូតអង់គ្លេសនិងអូស្ត្រាលី ផ្ញើកំណត់ហេតុគាត់ទៅរដ្ឋាភិបាលទាំងឡាយនៃខម្មិនវែល (ប្រទេសក្រោមអំណាចអង់គ្លេសពីដើម)។ ឯកសារនេះ បានទៅជាមូលដ្ឋាននៃការពិភាក្សាគ្នា ដែលបានឲ្យកំណើតដល់ផែនការ កូឡុំបូ នៅឆ្នាំ ១៩៥០ (កម្ពុជាយើងបានចូលក្នុងផែនការនោះដែរជាមួយប្រទេស ២១ ទៀត)។ សម្ពន្ធកិច្ចខាងយោធានិងខាងសេដ្ឋកិច្ចឯទៀត ក៏ចេះតែកើតឡើងជាបន្ទាប់មកដែរនៅអាស៊ីអគ្នេយ៍ : សេអាតូ, សមាគមប្រជាជាតិនៅអាស៊ីភាគអាគ្នេយ៍* (ASEAN), *អូស្ត្រាលី-នូវែលហ្សេឡង់-អង់គ្លេស* (ANZUK), *អូស្ត្រាលី-នូវែលហ្សេឡង់-អាមេរិក* (ANZUS), *ក្រុមប្រឹក្សាអាស៊ីនិងប៉ាស៊ីហ្វិក*(ASPAC) *។ល។ "ពិភពសម្បូណ៌សប្បាយជាមួយគ្នានៅមហាអាស៊ីភាគបូព៌ា"* (Sphère de co-prospérité de la grande Asie orientale) *បានត្រូវគេយកមកនិយាយម្តងទៀត នៅដើមឆ្នាំ ១៩៧៨ នៅពេលដែលប្រទេសជប៉ុនងើបឡើងវិញ ទៅជាមហាអំណាចមួយយ៉ាងធំនេះ។*

*(១៣)* *គំនិតធ្វើឲ្យឥណ្ឌូចិនបារាំងមានលក្ខណៈជាសហព័ន្ធ បានមានឡើងជាលើកដំបូងនៅឆ្នាំ ១៩៣០ ក្រោមរដ្ឋាភិបាល ដាឡាឌៀ។*

*(១៤)* *ស្តេច នរោត្តម សីហនុ បានឃើញ-បានស្គាល់ ប្រទេសកម្ពុជា ដោយសារឧត្តមនាវី ដឺគូ (តាមសំដីសម្តេចសីហនុ ផ្ទាល់ ក្នុង "ឥណ្ឌូចិនឃើញពីប៉េកាំង")។*

*(១៥)* *ប្រហែលជាសាស្ត្រាចារ្យបារាំងម្នាក់ឈ្មោះ ហ្ស៊ែក ឡង់ ដែលជាដើមហេតុនៃការបង្កើតចលនាយុវជនទាំងនេះ។ ផ្លាស់ពីហាណូយមកភ្នំពេញ ហ្ស៊ែក ឡង់, ដើម្បីកំចាត់ការអផ្សុក, ក៏បង្កើតចលនាយុវជនមួយឈ្មោះ "ហ្ស៊ឺវេនីញ៉ា" ដែលធ្វើសកម្មភាពខាងកីឡានិងតូរ្យតន្ត្រី។ ដោយឃើញជោគជ័យនៃចលនានេះ ដឺគូ ក៏មាន "គំនិតប្រមែប្រមូលយុវជននៃប្រទេសទាំង៣ ដាក់ក្នុងចលនាមួយឈ្មោះ "យុវជនឥណ្ឌូចិន" ក្រោមការដឹកនាំនៃទាហានបារាំងឈ្មោះ ឌុយក្លូវ៉ា។ ក្រៅពីកីឡានិងតូរ្យតន្ត្រី គេអប់រំបំផុសគំនិតជាតិនិយមនៃយុវជនទាំងនោះ ដើម្បីបញ្ចៀសពីការទាក់ទាញនៃជប៉ុន។ ជាការណ៍ធម្មតា ដឺគូ ក៏បានសំលៀងកាំបិតមុខពីរដោយមិនដឹងខ្លួន។ ព្រោះបន្ទាប់ពីការប្រើកម្លាំងនៃជប៉ុន (ចាប់បារាំង) នៅថ្ងៃ ៩ មីនា ១៩៤៥ គឺក្នុងចំណោមសមាជិកនៃចលនានោះហើយ ដែលលោក សឺង ង៉ុកថាន់ រើសយកអ្នកស្ម័គ្រចិត្ត ទៅរំលំរដ្ឋាភិបាលចូលបារាំងនៃលោក អ៊ឹង អ៊ី។ នៅស្រុកយួន មេចលនាយុវជន (ឈ្មោះថ្មីថា ថាន់ ញៀន ទាង ផុង, យុវជនជួរមុខ), វេជ្ជបណ្ឌិត ផាំ ង៉ុក ថាច់, ជាសមាជិកសម្ងាត់នៃគណបក្សកុម្មុយនិស្តឥណ្ឌូចិន ហើយក្រោយមក បានទៅជារដ្ឋមន្ត្រីក្រសួងអនាម័យ នៃរដ្ឋាភិបាលបណ្តោះអាសន្នយួនខាងជើង! ឥស្សរជនខ្មែរយើងខ្លះ នៅចាំនៅឡើយអំពីការស្នាក់អាស្រ័យនៅផាន់ធាក ក្នុងជំរំសម្រាប់បង្ហាត់មេ "យុវ័ន"។ នៅផាន់ធាក (វៀតណាមខាងត្បូង) គេបង្ហាត់ឲ្យច្រៀងបទដំណើរនៃចលនានោះ ដែលបានទៅជា, ដូចជាចៃដន្យ, បទភ្លេងជាតិនៃសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម!*

(១៦) តាំងពីខែកញ្ញា ១៩៤៣ ឧត្តមសេនីយ៍ ដឺហ្គោល បញ្ជាឲ្យ ឧ. ស. ប្លេហ្ស រៀបចំទ័ពមួយកងដើម្បីបញ្ជូនទៅចុងបូព៌ាប្រទេស។ ដល់កងឯកភាពទាំងឡាយកើតមានហើយ រដ្ឋាភិបាលបារាំងសុំឲ្យគេបញ្ជូលកងទាំងនោះ ក្នុងបញ្ហាការអាស៊ីភាគអគ្នេយ៍របស់ ម៉ោន បទ៊ីន។ ពួកអង់គ្លេស-អាមេរិកាំង មិនព្រមដោយសំអាងថាឥណ្ឌូចិននៅក្នុងឆាកប្រយុទ្ធ "ចាយណា" ដូច្នេះ នៅក្រោមការត្រួតត្រារបស់ ជាងកាយជាក។ ថ្ងៃ ២២ ឧសភា ១៩៤៥ រដ្ឋាភិបាលបារាំងបញ្ជូន ឧ. ស. ហ្ស៊ូវ៉ាំង (ក្រោយមកសេនាប្រមុខ), នាយអគ្គសេនាធិការទ័ពបារាំង, ទៅវ៉ាស៊ីងតោនដើម្បីស្ទង់មើលចិត្តអាមេរិកាំង ក្រែងមានការឡើងគោកលើឥណ្ឌូចិន។ ហ្ស៊ូវ៉ាំង ក៏បានដឹងថា ការវាយសំរុកលើកក្រោយនឹងត្រូវធ្វើលើប្រទេសជប៉ុនតែម្តង។ បារាំងក៏ស្នើការប្តូរគ្នាយក "អធិបតីភាពបារាំងលើឥណ្ឌូចិន" ទល់នឹងការបូជាកងពលធំពីរ ក្រោមបញ្ជាការ ឧ. ស. ឡឺក្លែ ទៅឲ្យអាមេរិកាំងប្រើក្នុងការវាយសំរុក។ អាមេរិកាំងមិនព្រម។ ថ្ងៃ ៦ សីហា គ្រាប់បែកបរមាណូក៏ផ្ទុះឡើង។

(១៧) ១៥ ថ្ងៃ ក្រោយការប្រើកម្លាំងពីសំណាក់ជប៉ុននៅថ្ងៃ ៩ មីនា (១៩៤៥) មក មេ "តស៊ូ" និងទាហានប្រមាណ ៥០ នាក់ នៃ "កងកម្លាំងបារាំងសេរី" (F.F.L.) ដែលបានលោតឆ័ត្រលើស្រុកខ្មែរនោះ បានត្រូវជប៉ុនចាប់បានទាំងអស់ ហើយយកទៅដាក់ក្នុងគុកធំ ក្រោយវត្តឧណ្ណាលោម ឯភ្នំពេញ។

(១៨) នៅថ្ងៃនោះ (៧ កុម្ភៈ ១៩៤៥) ទីក្រុងភ្នំពេញបានស្គាល់ការទំលាក់គ្រាប់បែកទី១ នៃប្រវត្តិសាស្ត្រខ្លួន។ យន្តហោះអាមេរិកាំងបានធ្វើឲ្យបែកបាក់ ឬលិចខ្ទេចខ្ទីនូវ ទូកនិងកប៉ាល់ស៊ីវិល នៅកំពង់ផែចតុមុខ (នៅមុខវត្តឧណ្ណាលោម) ហើយបានធ្វើឲ្យស្លាប់និងរបួសបណ្តាជនជាច្រើនរយនាក់។ តាមការនិយាយនៃមហាជន ឮថាជប៉ុនបានស្នើសងជម្ងឺចិត្តលើការខូចខាតពីព្រោះសង្គ្រាម ដែលខ្លួនជាអ្នកដើមហេតុនេះដែរ ប៉ុន្តែព្រះចៅសីហនុថាមិនបាច់ឲ្យសង ដោយ "ដឹងគុណ" ជប៉ុន។ ការណ៍មួយដែលពិត គឺការទំលាក់គ្រាប់បែក "នៅមាត់ទន្លេ" នេះ បានធ្វើឲ្យគេជឿកាន់តែខ្លាំង លើរូបបដិមាករមួយ (ហៅព្រះគំលង់ ឬស្តេចគំលង់) ដែលឥតបានខូចខាតអ្វីឡើយ ក្នុងពេលដែលចេតិយនិងសំណង់ខ្លះទៀតក្នុងវត្តបានត្រូវបាក់បែកខ្ទេចខ្ទី។ គេពុំបានដឹងពិតប្រាកដដែរ អំពីវាសនានៃបដិមាករនេះ ក្រោយខែមេសា ៣០ ឆ្នាំក្រោយមក។

(១៩) "សហភាពបារាំង" នេះ (១៩៤១) គឺចម្លងមកទាំងត្រដរ ពី "ខម្មិនវែល" អង់គ្លេស (១៩៣១)។ បារាំងធ្វើសហភាពបារាំងនេះ ដើម្បីខំឱបក្រសោបអាណាចក្រខ្លួនកុំឲ្យរលាយ ក្នុងពេលដែលខ្លួនត្រូវដោះលែងបន្តិចម្តងៗ នូវប្រទេសអាណានិគមដែលកំពុងងើបឡើង។ លក្ខន្តិកៈនៃសហភាពបារាំង បានទៅជារឿង "ឈ្លោះគ្នា" យ៉ាងតឹងមាត់ ក្នុងរដ្ឋសភា (តែងរដ្ឋធម្មនុញ្ញ) ពីរ, សភាឆ្នាំ ១៩៤៥ និង ១៩៤៦។ ពិតណាស់ទៅហើយ បញ្ហាពលរដ្ឋបានត្រូវលើកយកមកនិយាយ : តើពលរដ្ឋនៃសហភាព ជាពលរដ្ឋបារាំងដែរឬអ្វី? ជាការណ៍ធម្មតា ឥតមានរឿងឃើញខ្មែរម្នាក់ ឬអាហ្វ្រិកម្នាក់ មកធ្វើតំណាងរាស្ត្រនៅស្រុកបារាំងទេ! គេក៏រកបានសេចក្តីសំរុះសំរួលមួយ (Compromis)។ អត្ថន័យនៃសហភាពបារាំងបានត្រូវឲ្យក្នុងសេចក្តីផ្តើម នៃរដ្ឋធម្មនុញ្ញបារាំងឆ្នាំ ១៩៤៦: "សហភាពបារាំងមានប្រជាជាតិនិងប្រជាជនទាំងឡាយ ដែលដាក់មកជាមួយគ្នា នូវធនធានរបស់ខ្លួន និងការប្រឹងប្រែងរបស់ខ្លួន ដើម្បីចំរើនអារិយធម៌ខ្លួន ពង្រីកភាពសុខសប្បាយរបស់ខ្លួន និងសន្តិសុខរបស់ខ្លួន"។ សភាមួយនៃសហភាពបារាំង បានត្រូវបង្កើតឡើង ដែលនៅក្នុងនោះ ពួកប្រតិភូ "នៃប្រទេសសមាជិក មានសិទ្ធិស្មើគ្នានឹងប្រតិភូបារាំងដែរ។ ប៉ុន្តែ ច្បាប់ដែលបានត្រូវសំរេច, តាមធម្មតា, ដោយសភាអាយក្នុងប្រទេសសមា-

ជិក ត្រូវយកទៅដាក់ឲ្យសភានៃសហភាពពិនិត្យ។ របៀបរៀបចំដ៏ស្មុគ្រស្មាញនេះ បានត្រូវព្រះបាទសីហនុវិនិច្ឆ័យថា ផុយនឹងវិចារណញ្ញាណ (absurde)

(២០) នាម៉ឺនយួនឈ្មោះ ង៉ោ ឌិនយៀម បានចង់គំនុំទុកយ៉ាងជុំ។ ពេលដែលខ្លួនឡើងកាន់អំណាចក្នុងឆ្នាំ ១៩៥៥ (១០ ឆ្នាំក្រោយមក) យៀម ចាប់បើកយុគនៃការព្យាបាទខ្មែរកម្ពុជាក្រោម។ ក្នុងពេលនោះ រាជរដ្ឋាភិបាលបានប្ដឹងទៅអង្គការសហប្រជាជាតិ។ គឺក្នុងពេលដែលខ្មែរយើងបះសម្លាប់យួននៅឆ្នាំ១៩៤៥ នោះហើយ ដែលយួនបានចាំឡើងវិញនូវពាក្យ "ម៉ា តុំ" (រាវបង្កង) ដូចដែលខ្មែរយើងចាំមិនភ្លេចនូវពាក្យ "កំពប់តែអុង"។

(២១) មរណភាពនៃ រូស៊ីវែល បានបង្វែរផ្លូវនៃសាវតាប្រទេសទាំងបីនៃឥណ្ឌូចិន។ គេជឿជាក់ថា បើសិនជាប្រធានាធិតីអាមេរិកាំង នៅរស់នៅឡើយក្នុងពេលនោះ បារាំងមិនអាចដាក់ជើងលើដីឥណ្ឌូចិនវិញបានឡើយ។

(២២) កត្តាដែលសំរេចចិត្តពួកជប៉ុន (និងបន្ទាប់មកពួកបារាំង) ឲ្យប្រគល់កូសាំងស៊ីនឲ្យទៅយួន មាន២ : ទស្សនៈប្រាកដនិយម និងការមើលងាយ។ ប្រាកដនិយម ព្រោះខ្មែរនៅកូសាំងស៊ីនជាជនជាតិភាគតិច។ ការមើលងាយ ជានាមតែមួយដែលគេអាចប្រើ ដើម្បីចង្អុលអាកប្បកិរិយានៃបារាំងអាណានិគមនិយមចំពោះមុខស្ដេចខ្មែរយើងទាំងឡាយ ហើយតាមនោះ ចំពោះប្រទេសយើងទាំងមូល។ ការណ៍ដែលស្ដេចយើងរស់នៅក្នុងចំណោមស្រីស្នំទាំងហ្វូង ភីលៀងនិងអាមាត្យទាំងកង ហើយដែលកិច្ចជំនុំរឿងរ៉ាវប្រទេស មានតែការគោលហៅពីសំណាក់នាម៉ឺន "ដែលមានងារជាឃុន ជាហ្លួង ជាព្រះ ជាឧកញ៉ា... ប៉ុន្តែដែលគ្មានចេះអ្វី ក្រៅពីលុតជង្គង់ចុះក្រាបថ្វាយបង្គំ ហើយដើរទាចូលទៅតែប៉ុណ្ណោះ, ការណ៍នេះ រូបភាពនេះ ជាដើមហេតុនៃការមើលងាយប្រទេសជាតិយើង ពីសំណាក់បារាំងអាណានិគមនិយម។

(២៣) ឧត្តមសេនីយ៍ ដឺហ្គោល, បុរសដែលសម្ដេចសីហនុគោរពជាងអ្វីទាំងអស់ បន្ទាប់ពីព្រះសមណៈគោតម (ក្នុង "ឥណ្ឌូចិនឃើញពីប៉េកាំង"), បានធ្វើសុន្ទរកថាមួយទៀត ២១ ឆ្នាំក្រោយមក នៅទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៦៦។ ចំពោះត្រចៀកអាមេរិកាំង ដែលកំពុងទប់ទល់នឹងកុម្មុយនិស្ត ក្នុងវៀតណាមខាងត្បូងនិងតាមព្រំដែនខ្មែរយើង សុន្ទរកថានៅភ្នំពេញនេះ ឲ្យតំបូន្មានផ្ទុយទាំងស្រុង ពីតំបូន្មានដែលលេចចេញពីការ "ប្រាថ្នា" នៃថ្ងៃ ១៧-៨-៤៥។ ហើយបើ រូស៊ីវែល ឮ ប្រហែលជាគាត់ប្រែខ្លួនក្នុងផ្នូរគាត់ហើយ (តាមពាក្យនិយាយមួយរបស់បារាំង)។

(២៤) បីថ្ងៃមុនសុំការចុះចាញ់នៃជប៉ុន "កាល់កត្តា" បានឲ្យទំលាក់តាមឆ័ត្រយោងលើឥណ្ឌូចិន នូវភ្នាក់ងារសម្ងាត់មួយក្រុម ជាមួយគ្នានឹង ហ្សង់ សេឌីល និង ព្យែរមេះស្មែ ដែលគេបំរុងឲ្យធ្វើជា ស្នងការនៃសាធារណរដ្ឋប្រចាំតុងកឹង។ ក្រៅពី សាំងតឺនី ដែលបានមកដល់ហាណូយដោយចេញពីស្រុកចិន តាមកប៉ាល់ហោះអាមេរិកាំង, ពួកលោតឆ័ត្រទាំងអស់ បានត្រូវវៀតមិញចាប់ទុក។ ឥស្សរជនបារាំងទាំងនេះ បានមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើនយោបាយបារាំងលើឥណ្ឌូចិនជាពិសេស នឹងលើអតីតៈប្រទេសអាណានិគមបារាំងជាទូទៅ។

(២៥) សមាគតរដ្ឋ ឬរដ្ឋ "ហ៊ុន" នឹងបារាំង (Etats associés) មានប្រទេសដែលនៅក្នុងសហភាពបារាំង (អានលេខយោង ១៩)។ កាលយើងមិនទាន់បានឯករាជ្យ អ្នកផងឧស្សាហ៍ឃើញ, ក្រៅពីទាហានបារាំង, នូវទាហាន "អាព្រិច" និងទាហាន "អាមារ៉ុក" ដើរឆ្វាត់ឆ្វែងតាមផ្លូវនៅភ្នំពេញ។ ក្នុងពពួក សេណេហ្កាឡេ និង ម៉ារ៉ូកាំង ទាំងនោះ មានមួយចំណែកធំដែលបានស្លាប់ ក្នុង "ចំការកិត្តិយស" ឥណ្ឌូចិនក្នុងចំបាំងជាមួយវៀតមិញនេះ។៚

# រឿងក្នុងប្រទេស

រជ្ជកាលនៃព្រះចៅស៊ីសុវត្ថិ (១៩០៤-១៩២៧) និង មុនីវង្ស (១៩២៧-១៩៤១) មានសភាពស្ងប់ស្ងាត់, ហើយក្នុងកំឡុងពេលនោះ បារាំងបាននាំមកនូវការកែទំរង់ជាច្រើនៗ មុនពេលសុគតនៃព្រះមុនីវង្សបន្តិច, ប្រទេសកម្ពុជាបានបាត់បង់ម្តងទៀត នូវខេត្តបាត់ដំបង, ស៊ីសុផុន និងភាគមួយយ៉ាងធំ នៃខេត្តសៀមរាប, កំពង់ធំ និងស្ទឹងត្រែងៗ ពេលឃើញថា ជីវិតព្រះមុនីវង្សជ្រាលជ្រៅហើយ, ដឺគូ ក៏គិតទៅដល់ដំណនៃរាជ្យៗ ម្ចាស់មុនីរ៉េត, កូនច្បងនៃព្រះមុនីវង្ស ហើយដែលត្រូវឡើងសោយរាជ្យ តតាមទំនៀមទំលាប់, ធ្វើឲ្យ ដឺគូ បារម្ភ ព្រោះមានគំនិត "ឯករាជ្យនិយម"ៗ នៅស្រុកបារាំង, ម្ចាស់មុនីរ៉េត និងប្អូន, មុនីពង្ស, បានចូលធ្វើទាហានក្នុងកង "ឡេស្យុង" ទាហានជាតិក្រៅៗ ក្រោយពេលដាក់អាវុធឈប់បាញ់គ្នា (បារាំង-អាល្លឺម៉ង់) នៅឆ្នាំ ១៩៤០, ម្ចាស់មុនីរ៉េត ត្រឡប់មកស្រុកខ្មែរវិញជាមួយគំនិតថ្មីៗៗ នៅក្នុងឥណ្ឌូចិនមួយ ដែលការទាក់ទងជាមួយប្រទេសបារាំង "ជាម្តាយ" បានប្រែប្រួលលែងដូចសព្វដង ដឺគូ ខំការពារទុកឲ្យបានយូរបំផុត នូវអធិបតីភាពបារាំង ដែលកាន់តែបានទទួលការគំរាមកំហែងច្រើនឡើង, តាំងអំពីជប៉ុនបានឡើងមកលើធាកឥណ្ឌូចិនដែរ (រឿងតុងកឹង, ការបាត់បង់ខេត្តខ្មែរ)ៗ ដើម្បីប្រុងជើងការណ៍ទុក ពេលណាមានការបះបោរ, ដឺគូ ត្រូវការដាក់លើបល្ល័ង្កទាំងបីនៃឥណ្ឌូចិន, មនុស្សដែលខ្លួនស្រណុកក្តោបបំបត់បំបែនៗ ព្រះមុនីវង្សសុគតនៅថ្ងៃទី ២៣ មេសា ១៩៤១ៗ ម្ចាស់មុនីរ៉េត ដែលឥតសមនឹងសេចក្តីត្រូវការរបស់គេ, ក៏បានត្រូវ ដឺគូ ទាញចេញទៅៗ "គូវែន័រ ហ្សេណេរ៉ាល់" នៃឥណ្ឌូចិន ជ្រើសយកម្ចាស់នរោត្តម សីហនុ វិញ ដែលឥតបានដឹងខ្លួនមុនឡើយៗ នៅពេលនោះ អាយុ ១៨ ឆ្នាំ, ក្មួយនៃម្ចាស់មុនីរ៉េត កំពុងបញ្ចប់មធ្យមសិក្សានៅ "លីសេ" សាស្ស៊្រែលូ-ឡូបា ឯព្រៃនគរៗ ថ្ងៃ ២៨ តុលា ១៩៤១, នៅក្នុងពិធីដ៏ធំមួយ, ដឺគូ បំពាក់មកុដឲ្យម្ចាស់សីហនុ ហើយអភិសេកធ្វើជាព្រះចៅក្រុងកម្ពុជាៗ ដូចជាជីតានិងជីទួតដែរ, ព្រះចៅសីហនុនឹងឃើញយ៉ាងរហ័សថា ស្តេចខ្មែរគ្រាន់តែជាអាយ៉ងដែល "រ៉េស៊ីដង់ ស៊ុបេរីយ័រ" បារាំងទាញខ្សែប៉ុណ្ណោះ[១]ៗ ស្តេចសីហនុ ដែលកាលនោះចូលចិត្តនារី និង តូរ្យតន្ត្រីជាងនយោបាយប្រទេស, ក៏បត់បែនបន្ទន់ខ្លួនយ៉ាងធូរ តាមការត្រូវការរបស់បារាំង ដូចដែល ដឺគូ បានប៉ង់ប្រាថ្នា, ហើយស្ថានភាពនេះមានរហូតដល់ឆ្នាំ ១៩៤៥ៗ

ការ "ប្រើកម្លាំង" នៃជប៉ុន នៅថ្ងៃទី ៩ មីនា ១៩៤៥ បានបោសកំចាត់ក្នុងរយៈពេលតែមួយយប់, សឹងតែមួយសតវត្សរ៍នៃអំណាចបារាំងៗ ជប៉ុនបាននិយាយនឹងមហាសេដ្ឋីចិនខ្មែរ តាន់ ប៉ា, ឲ្យព្រមទទួលភារៈដឹកនាំរដ្ឋាភិបាលទី១ នៃយុគក្រោយអាណានិគមៗ តាន់ ប៉ា មិនទទួល, ជប៉ុនក៏ទុករចនាសម្ព័ន្ធរដ្ឋាភិបាលចាស់ (អគ្គមហាសេនា អ៊ុំ អ៊ី)ៗ នាទីជានាយករដ្ឋមន្ត្រីដែលពីមុននៅលើដៃ "រ៉េស៊ីដង់ ស៊ុបេរីយ័រ", ក៏ត្រឡប់មកក្នុងដៃស្តេចវិញ ដែលទទួលការឃ្លាំមើលពី "អគ្គទីប្រឹក្សា" ជប៉ុនម្នាក់ៗ ៤ ថ្ងៃក្រោយការរំលាយអំណាចបារាំង, លោក មាស ណាល់, រដ្ឋមន្ត្រីក្រសួងសិក្សាធិការ, បញ្ជាក្នុងថ្ងៃ ១៣ មីនា ឲ្យប្រើឡើងវិញ នូវប្រក្រតីទិនចន្ទគតិ, បំបាត់ការសរសេរជាភាសាខ្មែរដែលប្រើដោយអក្សរ រ៉ូម៉ាំង, ហើយបង្គាប់ឲ្យប្រើភាសាខ្មែរ ក្នុងកិច្ចការរដ្ឋបាលៗ លោក ប៉ាច ឈឺន បានត្រូវដោះលែងពីកោះត្រឡាច នៅថ្ងៃ ២១ មីនា[២], ហើយបង្កើតឡើងវិញនូវសារព័ត៌មាន នគរវត្តៗ នៅដើមខែឧសភា, លោក សឺង ង៉ុកថាន់ ត្រឡប់មកពីប្រទេសជប៉ុនវិញ, ហើយបានត្រូវតែងតាំងនៅថ្ងៃ ១ មិថុនា ជារដ្ឋមន្ត្រីក្រសួងការបរទេស, តាមសេចក្តីសុំរបស់ជប៉ុនៗ នៅពេលនោះហើយ

*ដែលគេបានឃើញមានឡើង នូវការប្រេះស្រាំជាលើកដំបូងនៃសង្គមខ្មែរ, ដោយហេតុមានលំនាំនយោបាយ២ ដែលយូរមកបានក្លាយទៅជាលំនាំមនោគមវិជ្ជា, ហើយដែលការតទល់គ្នាបានចប់ ជា សោកនាដកម្ម, នៅខែមេសា ១៩៧៥។*

*លំនាំទី១ប្រមូលផ្តុំ ពួកដែលចង់បំបាត់របបរាជានិយម, ដែលខ្លួនឃើញថាជាឧបករណ៍ដែលអាណានិគម (ហើយក្រោយមកអាណានិគមនិយមជំនាន់ថ្មី) ប្រើប្រាស់ ដើម្បីក្រញាំក្តោបប្រទេសខ្លួន។ លំនាំនយោបាយនេះ[៣] រំលាយការតយុទ្ធទល់នឹងស្តេច ចូលជាមួយការតយុទ្ធទល់នឹងអាណានិគមនិយម។ លំនាំទី២ គឺរបស់ពួកព្រូនសង្គម ដែលយកបុណ្យសក្តិខ្លួនធ្វើជាដើមទុន ប្រមូលទ្រព្យសម្បត្តិ, បុណ្យសក្តិដែលស្តេចចែកឲ្យ តាមការប៉ិនប្រសប់របស់ខ្លួនខាងលុតក្រាប។ ពួកព្រូនសង្គមនេះ គឺក្រុមនាហ្មឺន[៤]។ ជាការធម្មតា ពួកនេះប្រាថ្នាឲ្យរបបរាជានិយមមានអាយុយឺនយូរតទៅទៀត។ ដោយម្យ៉ាង គូវិវាទទាំងពីរក្រុមមើលងាយការទូន្មាននៃប្រវត្តិសាស្ត្រ, ដោយម្យ៉ាងទៀត មហាជនស្អិតឥតកំរើក រកខ្លួនប្រមូលជាកម្លាំងនយោបាយពុំបាន, ពួកទាំងពីរក្រុមនេះ រត់រកបរទេសរាល់ដង ដើម្បីជួយខ្លួនឲ្យឈ្នះក្នុងការវិវាទនេះ — ការវិវាទដែលក្រោយមក គ្រាន់តែជាកញ្ចក់ឆ្លុះសង្គ្រាមត្រជាក់នៃមហាអំណាចទាំងឡាយ។ លែងនឹកឃើញថា ប្រទេសខ្លួននៅក្នុងកាលៈទេសៈភូមិសាស្ត្រនយោបាយមួយដែលជួរចត់, ខាងណាក៏ដូចខាងណា ពុំដែលព្រមរកសេចក្តីសំរុះសំរួល (compromis) ឬរកជជែកគ្នាម្តងណាឡើយ។ ព្រោះតែការដណ្តើមអំណាចទាំងកំរោលងងឹតមុខនេះ, ប្រជាជនខ្មែរបានសងកំហុស នឹងកំពុងតែសងកំហុស ដោយបង់តំលៃមួយដ៏ធ្ងន់ធ្ងរអំពី — ដូចពាក្យអ្នកនិពន្ធបារាំង ប៉ែរណា ហាម៉ែល— ឈាមនិងទឹកភ្នែក[៥]។*

*ព្រះបាទសីហនុ, នៅក្មេងហើយធាប់តាមគេ, ទទួលជំនួយក្នុងកិច្ចការពីសំណាក់ពួក "ទីប្រឹក្សា" ដែលជាអ្នកការពារដោយម៉ឺងម៉ាត់ នូវរបបរាជានិយម។ ពេលដែលលោក សឺង ង៉ុកថាន់ ឡើងមកលើឆាកនយោបាយវិញ, ព្រះចៅបានបង្កើតមុខការមួយហៅថា "ទីប្រឹក្សានៃរាជរដ្ឋាភិបាល" ហើយតែងតាំងនៅថ្ងៃ ៧ មិថុនា (១៩៤៥) ក្នុងនាទីនេះ, សម្តេចមុនីរ៉េត ដែលនឹងមានសម្លេងពិភាក្សាក្នុងគណៈរដ្ឋមន្ត្រីទៀត។ ដើម្បីកាន់កាប់ដោយស្វាត់ៗ នូវការចាយវាយរបស់រដ្ឋាភិបាល, ស្តេចសីហនុ ដាក់ទីប្រឹក្សាពីរនាក់, លោក ប៉ែន នុត ជារដ្ឋមន្ត្រីរងក្រសួងហិរញ្ញវត្ថុ និងលោក ផូ ព្រឿង ជាអធិការហិរញ្ញវត្ថុ។ ក្នុងកាលនោះ, ការខ្វល់ខ្វាយធំៗ នៃរដ្ឋាភិបាល គឺជួយជប៉ុនក្នុងសង្គ្រាមរបស់ខ្លួន, និងដោះស្រាយបញ្ហាដ៏ពិបាកនៃលក្ខន្តិកៈរបស់ កូសាំងស៊ីន (សូមអានរឿងក្រៅប្រទេស)។ មហន្តរាយនៃ ហ៊ីរ៉ូស៊ីម៉ា និង ណាហ្គាសាគី បានធ្វើឲ្យចប់សុបិន "មហាអាស៊ីភាគបូព៌ា" ក្រោមអធិបតីភាពនៃ "អាណាចក្រព្រះអាទិត្យរះ"។ នៅថ្ងៃ ១៩ សីហា ១៩៤៥, ៤ ថ្ងៃក្រោយការផ្ទុះគ្រាប់បែកបរមាណូទី១, លោក សឺង ង៉ុកថាន់ បង្កើតរឿងក្លែងបន្លំមួយ ហើយឲ្យគេចាប់រដ្ឋមន្ត្រីទាំងអស់ដែលគាត់យល់ថាចូលចិត្តបារាំង។ អ្នកដែលទៅចាប់រដ្ឋមន្ត្រីទាំងនោះ សុទ្ធតែសមាជិកនៃចលនា "យុវជនឥណ្ឌូចិន" ដែលគេបានដាក់ឈ្មោះថ្មីថា "យុវនកម្ពុជរដ្ឋ"។ ថ្ងៃ ១៤ សីហា, លោក សឺង ង៉ុកថាន់ បានត្រូវតែងតាំងជារដ្ឋមន្ត្រីទី១ ហើយនៅតែកាន់ក្រសួងការបរទេស។ លោក ប៉ែន នុត ទទួលក្រសួងហិរញ្ញវត្ថុ, លោក ញ៉ឹក ជូឡុង ក្រសួងសេដ្ឋកិច្ចជាតិ, លោក ប៉ាច ឈឺន ក្រសួងផ្តល់ស្បៀង និងកស្តុភារ, លោក ស៊ុម ហៀង ក្រសួងមហាផ្ទៃ, លោក ឃឹម ទិត ទទួលក្រសួងការពារប្រទេស ត្រួតគ្នានឹងក្រសួងសុខាភិបាល។ នៅថ្ងៃ ៨ កញ្ញា, កងទាហានអង់គ្លេសមួយកងមកដល់ភ្នំពេញ ដើម្បីទទួលការដាក់អាវុធពីទាហានជប៉ុន ហើយដោះលែងឈ្លើយសង្គ្រាមជាតិអឺរ៉ុប តាមកិច្ចព្រមព្រៀងនៅ ប៉ុតស្តាំ ។ មកជាមួយកងឯកភាពអង់គ្លេសនោះ, មាននាយទាហានបារាំងម្នាក់, វរសេនីយត្រី ហ្កាល់ល្វ៉ា ដែលមាន "បេសកកម្មពិសេស"។ លោក សឺង ង៉ុកថាន់ ប្រាប់យ៉ាង*

*ច្បាស់ទៅនាយទាហាននោះថា រាជរដ្ឋាភិបាលខ្មែរនឹងធ្វើការចចារជាមួយបារាំង តែលើមូលដ្ឋានមួយ, គឺការទទួលស្គាល់ឯករាជ្យនៃប្រទេសកម្ពុជា។*

*ដោយចង់បង្ហាញ, មួយផ្នែកទៅបារាំងនូវការគាំទ្ររដ្ឋាភិបាលគាត់ពីសំណាក់ប្រជាជន, មួយផ្នែកទៀតទៅពួកសម្ពន្ធមិត្ត ថាគាត់ឥតជាប់ជំពាក់អ្វីជាមួយជប៉ុនទេ, សឺង ង៉ុកថាន់ បង្គាប់ឲ្យធ្វើការស្ទង់មតិប្រជាពលរដ្ឋ១* (plébiscite) *នៅថ្ងៃ ៣ តុលា*[៦]*។ គាត់ឥតបានដឹងទេថា នៅក្រោយខ្នងគាត់ រដ្ឋមន្ត្រីខ្លះកំពុងរៀបចំរំលំគាត់។ នៅថ្ងៃ ២៣ កញ្ញា, ស្ដេចសីហនុ ដែលគាំទ្រតាមផ្លូវការនូវនយោបាយនៃរាជរដ្ឋាភិបាល, បានបញ្ជូនលោក ឃឹម ទិត —យ៉ាងសម្ងាត់— ទៅជួបអាជ្ញាធរបារាំងឯព្រៃនគរ។ ថ្ងៃ ៥ តុលា ឧត្តមសេនីយ ឡឺគ្លែ មកដល់ព្រៃនគរ។ ថ្ងៃ ១៦, ដោយមានវរសេនីយឯក អ៊ុយវ៉ារ និងទាហានឥណ្ឌា ៣-៤ នាក់ នៃទ័ពអង់គ្លេសជូនមកផង, ឡឺគ្លែ មកដល់ភ្នំពេញ ហើយឲ្យចាប់លោក សឺង ង៉ុកថាន់ (ដែលព្រមឲ្យគេចាប់ឥតមានតទល់) ក្រោមការចោទថា “ធ្វើសកម្មភាពប្រឆាំងនឹងពួកសម្ពន្ធមិត្ត”។ ឃុំឃាំងឯព្រៃនគរ, សឺង ង៉ុកថាន់ បានត្រូវគេវិនិច្ឆ័យក្ដាម ហើយទទួលទោសធ្វើការជាទម្ងន់ក្នុងវេលា ២០ ឆ្នាំ, ហើយឥតច្បាប់សំចត (ក្នុងស្រុកខ្មែរ) ក្នុងវេលា ២០ ឆ្នាំ។ ជាមួយពរសេព្ទសាធុការ នៃសក្តិ៥ បារាំង អ៊ុយវ៉ារ ដែល ឡឺគ្លែ ឲ្យមើលខុសត្រូវលើវាសនាប្រទេសកម្ពុជា, រាជរដ្ឋាភិបាលថ្មីមួយបានត្រូវតែងតាំងឡើង ក្រោមការដឹកនាំនៃសម្ដេចមុនីរ៉េត។ ម្ចាស់មុនីពង្ស (ក្រោយមករាជទូតនៅប៉ារីស), លោក ឃឹម ទិត, ញឹក ជូឡុង, ស៊ុម ហៀង និង វ៉ា កាម៉ិល នៅក្នុងនោះដែរ។ មកដល់ព្រៃនគរបាន ៣-៤ ថ្ងៃ, ឧត្តមនាវី ដាហ្សង់ល្បើ (អគ្គស្នងការ) ជួបសម្ដេចមុនីរ៉េត ឯព្រៃនគរ, ហើយគូសខ្សែនយោបាយបារាំងឲ្យធ្វើតាម ៖ អនុវត្តន៍សេចក្ដីថ្លែងការណ៍នៃថ្ងៃ ២៥ មីនា ១៩៤៥ អំពីសហព័ន្ធឥណ្ឌូចិន, ដាក់ឡើងវិញយ៉ាងឆាប់រហ័ស នូវការអាណាព្យាបាល (ប្រតិកតូរ៉ា) បារាំង លើប្រទេសកម្ពុជា (ថ្ងៃ ៤ ធ្នូ ១៩៤៥, ស្ដេចសីហនុ ព្រមឲ្យអនុវត្តន៍ជាបណ្ដោះអាសន្ន នូវសន្ធិសញ្ញានិងកិច្ចសន្យា ឆ្នាំ ១៨៦៣ និង ១៨៨៤), តែងតាំងគណៈកម្មការធ្វើកិច្ចសិក្សាបារាំង-ខ្មែរមួយ ដើម្បីចចារធ្វើសន្ធិសញ្ញាថ្មីរវាងប្រទេសកម្ពុជា និងប្រទេសបារាំង។*

*ប៉ុន្តែបន្ទាប់ពីការចាប់ សឺង ង៉ុកថាន់ យកទៅ, ខ្មែរជាច្រើននាក់យល់ឃើញថា ស្ដេចបានយកប្រទេសទៅឲ្យបារាំង។ អ្នកទាំងនោះវិនិច្ឆ័យថា កម្លាំងជាមធ្យោបាយតែមួយដើម្បីយកឯករាជ្យ, ហើយក៏នាំគ្នាចូលព្រៃ, ខ្លះទៅព្រំដែនខ្មែរ-សៀម, ខ្លះទៅព្រំដែនខ្មែរ-យួន។ ពួកចូលព្រៃនេះបង្កើតចលនាមួយឈ្មោះ“ខ្មែរឥស្សរៈ”*[៧]*។ នៅទិសខាងជើង ខ្មែរឥស្សរៈទទួលជំនួយពីរដ្ឋាភិបាលថៃ របស់ ព្រិឌី ភ្នំយង់ (ដែលខ្លាចពួកបារាំងធ្វើអន្តរាគមន៍មួយ ក្នុងពេលខាងមុខ ដើម្បីយកខេត្តខ្មែរទៅវិញ (ខេត្តដែលសៀមបានពីសន្ធិសញ្ញា ក្រុងតូក្យូឆ្នាំ ១៩៤១)។ ឈ្មោះពីរលេចចេញពីចលនានៅទិសខាងជើងនេះ ៖ ដាប ឈួន និង កៅ តក់។ ចំណែកនៅទិសខាងត្បូង, ក្នុងខេត្តកំពត, លោក ប៉ាច ឈឺន ទទួលជំនួយពីយួន តាមរយៈ សឺង ថៃ ង៉ៀង*[៨]*, ប្អូនរបស់លោក សឺង ង៉ុកថាន់។*

*ថ្ងៃ ៧ មករា ១៩៤៦, សម្ដេចមុនីរ៉េត ចុះកិច្ចព្រមព្រៀងសំរេច “របៀបរស់នៅ” មួយ* (Modus Vivendi) *ជាមួយឧត្តមសេនីយ អាឡេះ សង់ទ្រើ, ស្នងការនៃសាធារណរដ្ឋ (ឆារថ្មីរបស់រ៉េស៊ីដង់ ស៊ូប៉េរីយ័រ)។ ក្នុងសេចក្ដីរបស់ “មូឌុស វីវេនឌី” នោះ (រូបមន្តនេះបារាំងចូលចិត្តណាស់, ប៉ុន្តែពួកអង់គ្លេសថាពិបាករស់នៅតាម) ប្រទេសកម្ពុជា ជា “រដ្ឋស្វយ័ត” នៅក្នុងសហព័ន្ធឥណ្ឌូចិន (ដែលរូបរាងមិនទាន់ច្បាស់លាស់នៅឡើយទេ) ដែលខ្លួនឯងនៅក្នុងសហភាពបារាំងទៀត។ ក្នុងកិច្ចការផ្ទៃក្នុងសុទ្ធ, ប្រទេសកម្ពុជាមានសេរីភាពពេញទី។ ដើម្បីឲ្យប្រទេសចាប់ដើរឡើងវិញ, បារាំងផ្ដល់ជំនួយលើផ្នែររដ្ឋបាល និងបច្ចេកទេស ដោយបញ្ជូនមកនូវ “ទីប្រឹក្សា” ដែលនឹងអប់រំបុគ្គលិកខ្មែរ។ កងទ័ពខ្មែរ មួយនឹងត្រូវបង្កើតឡើង។ ការបង្ហាត់បង្រៀនកងទ័ពនេះ នឹងត្រូវទទួលបន្ទុកដោយគណៈបេសកកម្មយោធាបារាំងមួយ*[៩] *ក្រោមបង្គាប់ទីប្រឹក្សាបារាំងម្នាក់ អមរដ្ឋមន្ត្រីក្រសួងការពារ*

ប្រទេស។ ប៉ុន្តែក្រសួងរតនាគារ, គយ, សន្តិសុខ, អន្តោប្រវេសន៍, ទូរគមនាគមន៍, អយស្ម័យយាន ។ល។ នៅលើដៃរដ្ឋាភិបាលសហព័ន្ធ ហើយនឹងត្រូវលើកទៅអគ្គស្នងការដ្ឋាន ឯព្រៃនគរ។ និយាយមួយម៉ាត់, ការអាណាព្យាបាល ត្រឡប់មកលើប្រទេសកម្ពុជាវិញ, ព្រោះ "ម៉ូឌុស វិវេនឌី" ឥតនាំអ្វីថ្មីមកឡើយ, ក្រៅពីពាក្យពីរម៉ាត់ៗ ប៉ុន្តែជំហានវែងមួយ ក៏បានបោះទៅមុខដែរ ៖ គណៈកម្មការធ្វើកិច្ចសិក្សា បានត្រូវគេឲ្យបន្ទុកធ្វើគំរោងរដ្ឋធម្មនុញ្ញមួយ, គ្រឿងដែលត្រូវមានខានពុំបាន ដើម្បីបន្ថយរបៀបគ្រប់គ្រងផ្តាច់ការលើកមុន ឲ្យមានប្រជាធិតេយ្យខ្លះៗ។ សម្តេច "ក្រុមព្រះ" មុនីរ៉េត ប្រឆាំងយ៉ាងខ្លាំងនឹងគំរោងការនេះ, ដោយសំអាងថាប្រជារាស្ត្រឥតមានការអប់រំនយោបាយទាល់តែសោះ, ហើយចង់ឲ្យត្រឡប់មករបបផ្តាច់ការវិញ —ការយល់ឃើញដែលព្រះចៅស្រុបតាមដែរ។

*

*       *

យោបល់របស់ មុនីរ៉េត បានត្រូវប្រឆាំងដោយពួកបញ្ញវន្តក្មេងៗ ប្រមាណម្ភៃនាក់ ដែលទើបនឹងត្រឡប់មកពីស្រុកបារាំងថ្មីៗ ហើយដែលសុំឲ្យបង្កើតសភាផ្សេងៗ ជ្រើសរើសដោយការបោះឆ្នោត ព្រមទាំងធ្វើឲ្យរបបនយោបាយក្នុងប្រទេសមានលំនាំ ដូចរបបនៅបស្ចឹមប្រទេស គឺមានរដ្ឋសភាត្រួតត្រារដ្ឋាភិបាល។ ជាមួយនឹងកិត្យានុភាព "មកពីស្រុកបារាំង" របស់ខ្លួន, ចេះយ៉ាងស្ទាត់នូវវាក្យសព្ទប្រជាធិតេយ្យបស្ចឹមប្រទេស, ពួកនេះប្រមូលផ្តុំបានយ៉ាងរហ័សនូវបញ្ញវន្តក្នុងប្រទេស (សម័យនោះសិស្សវិទ្យាល័យស៊ីសុវត្ថិ), អ្នករាជការទាំងអស់, ហើយជាពិសេសបក្សពួកលោក សឺង ង៉ុកថាន់។ ក្នុងចំណោមពួកបញ្ញវន្តមួយក្តាប់នោះ ឈ្មោះពីរបានលេចចេញមក ៖ ឈាន វ៉ម និង ស៊ីសុវត្ថិ យុត្តិវង្ស។ បន្ទាប់ពីបានដឹងអំពីកិច្ចសន្យា បារាំង-យួន ដែលចុះនៅហាណូយក្នុងថ្ងៃ ៦ មីនាមក (សាំងតឺនី-ហូជីមិញ, អានរឿងក្រៅប្រទេស), មតិនៅភ្នំពេញកាន់តែទិតៀនស្តេចឡើង ដែលគេបន្ទោសថាបានចាញ់បោកបារាំង។ ប្រទេសកម្ពុជាដែលបានលើកខ្លួនទៅឲ្យបារាំង, ឥតទទួលមកវិញនូវកំរៃ ដូចដែល ហូជីមិញ ទាញយកបានដោយប្រើអាវុធ។ ទឹកដីខ្មែរដែលបារាំងឲ្យទៅសៀមតាមសន្ធិសញ្ញាក្រុងតូក្យូ ឆ្នាំ ១៩៤១ (ខេត្ត ៥) ក៏នៅតែក្រោមអំណាចសៀម, ក្នុងពេលដែលពួកអង់គ្លេស, តាំងពីថ្ងៃ ១ មករា ១៩៤៦, បានយកពីសៀមទៅឲ្យភូមា និង ម៉ាឡេស៊ីវិញ នូវទឹកដីដែលសៀមបានកាន់កាប់។ ការមិនសប្បាយចិត្តមានជាទូទៅ។ សម្តេច មុនីរ៉េត និងព្រះចៅ សីហនុ ក៏យល់ឃើញថាត្រូវតែធ្វើដំណើរមួយទៅស្រុកបារាំង ដើម្បីបង្ហាញចំណោទទាំងអស់ទៅរដ្ឋាភិបាលបារាំង[១០]។

រដ្ឋាភិបាល មុនីរ៉េត ត្រូវគេកាន់តែពុំចូលចិត្តឡើង ព្រោះរបៀបយកអំណាច ក្នុងការគ្រប់គ្រងរបស់ខ្លួន, និងពីព្រោះ —តាមអ្នកនិពន្ធ ហ្វីលីព ដឺវីល្លែ— ការមិនហ្នឹងនររបស់ខ្លួន។ បារាំងក៏ចាប់គិតគូរផ្លាស់រដ្ឋាភិបាលនោះ។ ការពេញចិត្តបានទៅលើអ្នកស្រឡាញ់បារាំងម្នាក់, ម្ចាស់ នរោត្តម នរិន្ទ្រតេជ ដែលជាមាម្នាក់នៃព្រះចៅ។ ម្ចាស់ នរិន្ទ្រតេជ, ដោយមានអ្នករាជការនៅតាមខេត្តគាំទ្រផង, កំពុងប្រឹងប្រែងយ៉ាងសកម្ម តំលើងគណបក្សនយោបាយមួយឈ្មោះ "គណបក្សសេរីភាព"។ គណបក្សនេះ ស្នើរបបរាជាធិបតេយ្យមួយ ដែលគោរពរដ្ឋធម្មនុញ្ញ, ហើយដែលវិវត្តន៍បន្តិចម្តងៗ ទៅកាន់ប្រជាធិបតេយ្យ, ដោយធ្វើការកែទំរង់ច្រើនឡើងៗ ក្រោមការឧបត្ថម្ភ និង "ដឹកនាំ" របស់បារាំង។ ពេញចិត្តយ៉ាងខ្លាំងនឹងខ្សែនយោបាយនេះ បារាំងក៏ជួយតាមអាចធ្វើបាន។ ពេលចេញដំណើរទៅស្រុកបារាំង, ថ្ងៃ ១៣ មេសា, ព្រះចៅឲ្យដឹងអំពី ៖ ការបំបាត់ចោលក្នុងពេលខាងមុខ នូវរាជាធិបតេយ្យផ្តាច់ការ។ គំរោងរដ្ឋធម្មនុញ្ញមួយ នឹងត្រូវយកទៅឲ្យរដ្ឋសភាបណ្តោះអាសន្នមួយពិនិត្យ។ អ្នកបោះឆ្នោតនៅគ្រប់ឃុំនៃព្រះរាជាណាចក្រ នឹងជ្រើសរើសតាមការបោះឆ្នោតដោយមិនចំ (suffrage indirect) នូវអ្នកជំណាងក្នុងរដ្ឋសភាបណ្តោះអាសន្ននោះ។ រាជបញ្ញត្តិមួយចុះថ្ងៃ ១៥ មេសា ១៩៤៦ បើកឲ្យមាន

សេរីភាពធ្វើសមាគម, និងសេរីភាពធ្វើការប្រជុំ និងការឃោសនាក្នុងរយៈពេលរៀបចំបោះឆ្នោត។ មិនយូរឡើយ, គណបក្សនយោបាយ ៣ បានកើតឡើង ៖ គណបក្សសេរីភាព នៃម្ចាស់ នរិន្ទុតេជ, គណបក្សជឿនលឿន (បកប្រែ) នៃម្ចាស់ នរោត្តម ម៉ុងតាណា ដែលជាពូម្នាក់ទៀតនៃព្រះចៅ[១១] និង គណបក្សប្រជាធិបតេយ្យ នៃម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស។ គណបក្សជឿនលឿន ចង់ឲ្យមានរបបរាជាធិបតេយ្យដែលគោរពរដ្ឋធម្មនុញ្ញ ដូចគណបក្សសេរីភាពដែរ។ ចំណែកឯគណបក្សប្រជាធិបតេយ្យ, កម្មវិធីនយោបាយ គឺដាក់របបប្រជាធិបតេយ្យ ដែលមានរដ្ឋសភាជាធំ, ហើយជាពិសេសទៅទៀត, គឺមានការតយុទ្ធ (នយោបាយ) ដើម្បីយកឯករាជ្យពេញទី។ គណបក្សនេះ ក៏ទទួលយ៉ាងឆាប់រហ័ស នូវការគាំទ្រនៃពួកអ្នកជាតិនិយមទាំងអស់, និងការឧបត្ថម្ភយ៉ាងខ្លាំងពីសំណាក់ព្រះសង្ឃ ដែលឥតចង់បានឲ្យបារាំងត្រឡប់មកវិញសោះឡើយ។

ថ្ងៃ ៣១ ឧសភា ក្រុមប្រឹក្សារាជានុសិទ្ធិ (ព្រោះស្តេចមិននៅ) ប្រកាសឲ្យប្រើច្បាប់បោះឆ្នោតមួយ ដែលរៀបរៀងឡើងដោយគណៈកម្មការធ្វើកិច្ចសន្យាបារាំង-ខ្មែរ ៖ រដ្ឋសភាបណ្តោះអាសន្ន នឹងត្រូវជ្រើសតាំងឡើងដោយការបោះឆ្នោតជាសាកល និងដោយចំពោះ។ ថ្ងៃ ១ កញ្ញា ១៩៤៦ ការបោះឆ្នោត ជាសាកលបានធ្វើឡើងជាលើកទី១ នៅប្រទេសកម្ពុជា[១២]។ ផុយអំពីលទ្ធផលដែលបារាំងរង់ចាំ, ជ័យជំនះបានទៅលើគណបក្សប្រជាធិបតេយ្យ ដែលបានទទួល ៦០% នៃសម្លេងទាំងអស់។ ក្នុងចំនួនកៅអី ៦៧ ដែលសភាមាន, ៥០ បានមកពួកប្រជាធិបតេយ្យ, ១៤ បានទៅពួកសេរីភាព និង ៣ ទៅពួកឯកច័ន្ទ។ ការជំនុំទី១ នៃរដ្ឋសភា បានធ្វើឡើងនៅ ថ្ងៃ ២៥ កញ្ញា នៅចំពោះមុខព្រះរាជា។ សភាមិនព្រមបំពេញមុខការត្រឹមតែពិនិត្យពិភាក្សាច្បាប់, ហើយប្រកាសខ្លួនឡើង — តាមផ្លូវហេតុ — ជាសភាតែងរដ្ឋធម្មនុញ្ញ។ មានសម្លេងភាគច្រើននៅក្នុងសភា, គណបក្សប្រជាធិបតេយ្យ ទាមទារយកការដឹកនាំរដ្ឋាភិបាល, ដែលជាទម្លាប់ក្នុងប្រទេសប្រជាធិបតេយ្យបស្ចឹមទិស។ ខែ ធ្នូ ១៩៤៦, ជាមួយនឹងខេត្តទាំង ៥ ដែលបារាំងទើបនឹងយកបានពីសៀមមកវិញ[១៣], រដ្ឋាភិបាលមុនីរ៉េត ផ្ទេរដំណែងទៅរដ្ឋាភិបាលយុត្តិវង្ស។ ចំនួនពេល ៣-៤ អាទិត្យប៉ុណ្ណោះ បានគ្រប់គ្រាន់ដល់រដ្ឋាភិបាលយុត្តិវង្ស ដើម្បីបញ្ចេញគំរោងរដ្ឋធម្មនុញ្ញមួយ។

ថ្ងៃ ៦ ឧសភា ១៩៤៧, រដ្ឋធម្មនុញ្ញ បានត្រូវព្រះរាជាផ្តល់ទៅឲ្យប្រជារាស្ត្រខ្មែរ។ ចម្លងស្របតាមគំរោងរដ្ឋធម្មនុញ្ញបារាំងនៃឆ្នាំ១៩៤៦[១៤], អ្នករៀបរៀងបន្ថែមការឈ្វេងយល់ជំនាន់នោះខ្លះ ដូចជាមាត្រា ២១ ៖ (អំណាចទាំងអម្បាលមាណចេញមកពីព្រះរាជា) និងមាត្រា ២៥ ៖ (បល្ល័ង្កនៃប្រទេសកម្ពុជា ជាកេរ្តិ៍មរតកនៃអ្នកតពូជភេទប្រុសនៃព្រះបាទអង្គឌួង) (បកប្រែ)។ ផុយនឹងចំណង់របស់គណៈកម្មការធ្វើកិច្ចសិក្សា, រដ្ឋធម្មនុញ្ញនេះឲ្យអំណាចខ្លាំងណាស់ទៅរដ្ឋសភា។ ពិតហើយ ការដឹកនាំកិច្ចការរដ្ឋនៅលើនាយករដ្ឋមន្ត្រី ដែលព្រះចៅតែងតាំង, ហើយដែលរើសយករដ្ឋមន្ត្រីខ្លួនឯង។ ប៉ុន្តែនាយករដ្ឋមន្ត្រីនេះ, ជាមួយនឹងរដ្ឋាភិបាលទាំងមូល, ត្រូវទទួលការទុកចិត្តពីរដ្ឋសភាទៀត (ដែលមានអាណត្តិ ៤ ឆ្នាំ)។ សភាជាន់ខ្ពស់មួយបានត្រូវបង្កើតឡើង ៖ ចម្លងស្របតាមក្រុមប្រឹក្សាសាធារណរដ្ឋបារាំង, ក្រុមប្រឹក្សាព្រះរាជាណាចក្រមានតែមុខការខាងពិគ្រោះ ពិភាក្សាសុទ្ធសាធ លើរឿងច្បាប់។ ក្រុមប្រឹក្សានេះ មានសមាជិកជ្រើសតាំង និងសមាជិកជាប់ឆ្នោត (ដែលបោះដោយសង្ខេប) ហើយសមាជិកទាំងអស់ត្រូវមានអាយុយ៉ាងតិច ៤០ ឆ្នាំ។

ពេលដែលខ្លួនកំពុងតែចាប់ផ្តើមកម្មវិធីនយោបាយរបស់ខ្លួន, គណបក្សប្រជាធិបតេយ្យបាត់បង់មួយរំពេចនូវអ្នកដឹកនាំរបស់ខ្លួន។ នៅថ្ងៃ ១៨ កក្កដា, ម្ចាស់ យុត្តិវង្ស សុគតយ៉ាងចំលែកនៅឯកែប (គេថា យុត្តិវង្ស បានត្រូវគេសម្លាប់)។ ការបោះឆ្នោតត្រឹមត្រូវ (ព្រោះរដ្ឋសភាបណ្តោះអាសន្ន) នឹងត្រូវធ្វើឡើងនៅខែវិច្ឆិកា ១៩៤៧, ព្រះចៅនិងបក្សពួករៀបចំតទល់ម្តងទៀត នឹងពួកប្រជាធិបតេយ្យ។ ប្រើល្បិច "បែងចែកសម្លេង", ឥស្សរជនពីរនាក់ខាងពួកស្តេច បង្កើតគណបក្សនយោបាយថ្មីពីរទៀត ៖ លោក ញឹក-ជូឡុង ដឹកនាំ

គណបក្សខេមរបុណ្ណការ (ជាមួយលោក លន់ នល់, សម សារី, គូ រុន ។ល។[១៥], លោក យ៉ឹម ទិត ដឹកនាំគណបក្សរួមជាតិ (Union Nationale)។ ប៉ុន្តែការខិតខំនេះ នៅតែឥតបានផល ព្រោះសម្លេងភាគច្រើន នៅតែបានមកពួកប្រជាធិបតេយ្យម្តងទៀត ៖ កៅអី ៥៤ ក្នុងចំណោមកៅអីទាំងអស់ ៧៥។ ២១ បានទៅពួកសេរីភាព, ចំណែកខេមរបុណ្ណការ និងរួមជាតិ (Union Nationale) ឥតបានកៅអីមួយឡើយ។ ថ្ងៃ ១១ កុម្ភៈ ១៩៤៨ លោក ឈាន វ៉ម, អគ្គលេខាធិការនៃគណបក្សប្រជាធិបតេយ្យ, ទទួលដឹកនាំគណៈរដ្ឋមន្ត្រី។

*

*          *

ក្នុងពេលដែលអ្នកនយោបាយខ្មែរ កំពុងធ្វើសង្គ្រាមគណបក្សនៅភ្នំពេញ, អសន្តិសុខបានកើតមានឡើងលើផ្ទៃប្រទេស។ ដោយកងទាហាននៅកម្ពុជា (កងទាហាននៃសហភាពបារាំង) បានត្រូវគេបញ្ជូនទៅស្រុកយួន ដើម្បីជួយបារាំងច្បាំងវៀតមិញ, ចលនាឥស្សរៈ ត្រួតត្រាយ៉ាងពេញលេញ លើភាគខាងជើងនៃប្រទេស។ ការហៅឲ្យចុះចូលដោយលើកលែងទោសឲ្យ កាលពីឆ្នាំ ១៩៤៧, បាននាំមកតែមនុស្ស ៣-៤ នាក់ ដែលចូលក្លាមមួយរំពេច ក្នុងគណបក្សប្រជាធិតេយ្យ។ នៅខាងត្បូង និងនៅខាងកើតនៃប្រទេស, ពួកវៀតមិញ បានចាប់ផ្តើមតាំងទីក្នុងស្រុកខ្មែរ។ ជាមួយនឹងពូកខ្មែរក្រោមដែលខ្លួនបញ្ចុះបញ្ចូលបាន, វៀតមិញបង្កើត "កងទ័ពប្រជាជនខ្មែររំដោះ" (បកប្រែ)។ ខ្មែរក្រោមទាំងនេះ នឹងបានទៅជាស្នូលលើកដំបូងបង្អស់នៃវៀតមិញ នៅប្រ-ទេសកម្ពុជា។ ដោយបារម្ភនឹងអសន្តិសុខ ដែលកាន់តែខ្លាំងឡើងផង, ដោយឥតអំណាចលើកងទ័ពផង, ដោយពួកប្រជាធិបតេយ្យទិតៀនថា ស្ងួតពេកក្នុងការទាមទារផង, ព្រះចៅសីហនុសំរេចចិត្តសុំឲ្យបារាំងពិនិត្យឡើងវិញ នូវទំនាក់ទំនងបារាំង-ខ្មែរ។ ក្នុងសំបុត្រមួយចុះថ្ងៃ ៧ វិច្ឆិកា ១៩៤៧ ផ្ញើទៅឲ្យរដ្ឋាភិបាលបារាំង, ព្រះចៅទាមទារឲ្យបានត្រួតត្រាកាន់តែច្រើនលើកងទ័ព, នឹងឲ្យបានស្វ័យភាពកាន់តែធំឡើងក្នុងរឿងសន្តិសុខក្នុងប្រទេស (បារាំងមិនសូវសប្បាយចិត្តនឹងការលើកលែងទោសឲ្យពួកឥស្សរៈទេ)។ ថ្ងៃ ៥ មិថុនា ១៩៤៨ នៅឆកសមុទ្រ អាឡុង, អគ្គស្នងការថ្មី ប៊ុលឡាអែរ ចុះកិច្ចព្រមព្រៀងមួយជាមួយស្តេច បាវដាយ (ហូជីមិញបានចូលព្រៃហើយ) ទទួលស្គាល់ឯករាជ្យនៃប្រទេសវៀតណាម[១៦]។ ថ្ងៃ ២៥ តុលា, ព្រះចៅសីហនុផ្ញើសំបុត្រមួយទៀតទៅរដ្ឋាភិបាលបារាំង, ទាមទារសិទ្ធិផ្សេងៗ ដូចដែលបារាំងបានយល់ព្រមឲ្យទៅ បាវដាយ។ នៅឱកាសបុណ្យតាំងតុ, ថ្ងៃ ៩ វិច្ឆិកា ១៩៤៨, ព្រះចៅនិយាយទៅអគ្គស្នងការ ឡេអុងពីញ៉ុង អំពីឯករាជ្យ, ការណ៍ដែលមានជាលើកទី១ ៖ "ខ្ញុំនិយាយអំពីឯករាជ្យ ពីព្រោះខ្ញុំជឿជាក់ថា ពាក្យនេះជាកូនសោដោះស្រាយចំណោទទាំងអស់របស់យើង។"...

ការណ៍ដែលបារាំងឥតយល់អ្វីសោះ អំពីការទាមទារទាំងនេះ, បានជួយលើកឲ្យកាន់តែខ្ពស់ឡើងនូវកិត្យានុភាពនៃគណបក្សប្រជាធិតេយ្យ ដែលលេងសន្ទឹកបៀជាតិនិយម។ ចាប់តាំងពីឆ្នាំ ១៩៤៨, ពួកតំណាងរាស្ត្រប្រជាធិបតេយ្យ ផ្ទុះច្បាប់ទាំងអស់ ដែលស្តេចដាក់មករដ្ឋសភា។ ការតទល់គ្នារវាង "និតិ" និង "ប្រតិ-បត្តិ", លាយនឹងការកាន់បក្សពួកក្នុងគណបក្សប្រជាធិបតេយ្យ ធ្វើឲ្យមានវិបត្តិគណៈរដ្ឋមន្ត្រី (រដ្ឋាភិបាល ឈាន វ៉ម, រដ្ឋាភិបាល ប៉ែន នុត ។ល។...) ដោយពុំអាចឈ្នះពួកប្រជាធិបតេយ្យក្នុងការបោះឆ្នោត, ស្តេចប្រើល្បិចមួយទៀត ៖ ធ្វើឲ្យមាន "ការបែកចេញ" នៅក្នុងផ្ទៃគណបក្សនោះតែម្តង។ គឺ "អ្នកបែកចេញ" ម្នាក់ពីគណបក្សប្រជាធិបតេយ្យ, លោក យ៉ែម សំបូរ, ដែលបានទទួលការដឹកនាំរដ្ឋាភិបាលនៅខែកុម្ភៈ ១៩៤៩។ រដ្ឋាភិបាល យ៉ែម សំបូរ ចាប់ផ្តើមកិច្ចការក្នុងពេលពិបាកបន្តិច ព្រោះថានៅថ្ងៃ ២១ ឧសភា ១៩៤៩, រដ្ឋសភាបារាំងបានបោះឆ្នោតសំរេចភ្ជាប់ កូសាំងស៊ីន ទៅប្រទេសវៀតណាម ដោយឥតបានពិគ្រោះជាមុន ជាមួយប្រទេសកម្ពុជា[១៧], ហើយដោយឥតមានធ្វើលក្ខន្តិកៈពិសេសអ្វីឲ្យដល់ខ្មែរកម្ពុជាក្រោម (ទោះបីព្រះចៅបានទាម

*ទារជាច្រើនដងមកហើយក្តី)។ ការប្រឆាំងនៃរដ្ឋសភាចំពោះរដ្ឋាភិបាល ក៏ចេញមុខខ្លាំងក្លាក្លាម។ លើសពីនោះ, លោក ប៉ែម សំបូរ ទទួលកេរ្តិ៍ដំណែលនៃរដ្ឋាភិបាលមុនៗ នូវចំណោទធំ២ ៖ រឿងឥស្សរៈ និងរឿងវៀតមិញ។ ដោយខ្វះកងទាហានដើម្បីបង្ក្រាបពួកទាំងនោះ, រដ្ឋាភិបាលធ្វើការអំពាវនាវមួយដល់ចលនាឥស្សរៈ ដើម្បីការរួបរួមគ្នានៃខ្មែរទាំងអស់ ឆ្ពោះមុខទៅពួកវៀតមិញ, ហើយធានាថានឹងលើកលែងទោសឲ្យទាំងអស់ ដូចកាលពីមុនៗ ខែកញ្ញា ១៩៤៩, លោក ប៉ែម សំបូរ ទទួលជ័យជំនះមួយ ជាមួយការសុំចុះចូលនៃមេឥស្សរៈ ដាប ឈួន ដែលនាំមកនូវពលជាច្រើនពាន់នាក់ (ការចុះចូលនេះ បានធ្វើឲ្យបារាំងលែងទុកចិត្តលើលោក ប៉ែម សំបូរ)។ ដោយជំហរបានរឹងប៉ឹង ពីការចុះចូលរបស់ ដាប ឈួន, ព្រះចៅចាប់ចចារជាមួយបារាំងទៀត។ ថ្ងៃ ៨ វិច្ឆិកា ១៩៤៩, ជាមួយគ្នានឹងការចុះហត្ថលេខាយល់ព្រមលើរដ្ឋធម្មនុញ្ញខ្មែរ ដោយប្រធាននៃសហភាពបារាំង (ប្រធានាធិបតីប្រទេសបារាំង), សន្ធិសញ្ញាបារាំង-ខ្មែរ មួយក៏បានត្រូវធ្វើឡើងដែរ។ សន្ធិសញ្ញានេះទទួលស្គាល់, តាមផ្លូវច្បាប់នូវ “ឯករាជ្យ“ នៃប្រទេសកម្ពុជា។ “សាធារណរដ្ឋបារាំងទទួលស្គាល់ព្រះរាជាណាចក្រក្រុងកម្ពុជាជារដ្ឋឯករាជ្យ។“, គេអាចអានក្នុងមាត្រា ១ នៃសន្ធិសញ្ញានេះ។ ប៉ុន្តែ ចុះមកក្រោមមក, ការបង្ខាបង្ខាំងចេះតែមានឡើង ៖ ប្រទេសកម្ពុជានឹងអាចដាក់ចំណងទូតជាមួយប្រទេសឯទៀតបាន(១៨) ទាល់តែរដ្ឋាភិបាលបារាំងយល់ព្រម។ ខ្មែរទទួលការត្រួតត្រាលើកងទ័ព និងនគរបាល, ប៉ុន្តែក្នុងពេលណាមានសង្គ្រាម បញ្ជាការទាហានត្រូវដាក់មកក្រោមបារាំងវិញ។ ជនជាតិបារាំងក្នុងស្រុកខ្មែរ នៅតែមានអភ័យឯកសិទ្ធិពិសេស ដូចជាមិននៅក្រោមច្បាប់របស់រដ្ឋខ្មែរ។ល។*

*ដោយស្មានតែបានទទួលជ័យជំនះមួយទៀត, លោក ប៉ែម សំបូរ យកសន្ធិសញ្ញាទៅរដ្ឋសភា ដើម្បីសុំការយល់ព្រម។ រដ្ឋសភា មិនត្រឹមតែមិនយល់ព្រម, ថែមទាំងបោះឆ្នោតដកសេចក្តីទុកចិត្តពីរដ្ឋាភិបាលទៀត, ក្រោមការជំរុញនៃពួកតំណាងរាស្ត្រ ប្រជាធិបតេយ្យ ដែលចោទថារដ្ឋាភិបាលបានក្បត់។ ដោយតូចចិត្តដែរ, លោក ប៉ែម សំបូរ សុំឲ្យរដ្ឋសភាដកសេចក្តីមិនទុកចិត្តនោះទៅវិញ, បើពុំនោះទេ នឹងសុំឲ្យព្រះរាជារំលាយ។ រដ្ឋសភានៅតែហ្នឹងដដែល, ប៉ែម សំបូរ ធ្វើឲ្យស្តេចយល់ព្រមរំលាយ, ហើយក៏សុំលាឈប់ជាមួយរដ្ឋាភិបាលទាំងមូល។ ជាលើកដំបូងបង្អស់, ព្រះចៅ នរោត្តម សីហនុ ប្រើមាត្រា ២១ (អំណាចទាំងអស់អម្បាលមាណចេញមកពីព្រះរាជា) ហើយចុះរាជក្រឹត្យមួយ រំលាយរដ្ឋសភា(១៩)។ ដើម្បីរង់ចាំការបោះឆ្នោតថ្មី, អំណាចទាំងប៉ុន្មានបានត្រូវផ្ទេរមកស្តេចវិញដោយប្រធានរដ្ឋសភា, លោក អៀវ កើស (អគ្គលេខាធិការ គណបក្សប្រជាធិបតេយ្យជំនួសលោក ឈាន វ៉ម) ដែលយល់ឃើញថា អសន្តិសុខដែលមាននៅក្នុងប្រទេស ពុំអាចឲ្យការបោះឆ្នោតធ្វើទៅដោយរៀបរយបានឡើយ។ ដោយសំគាល់ថា សន្ធិសញ្ញាថ្ងៃ ៨ វិច្ឆិកា ជាជោគជ័យលើកដំបូងក្នុងកិច្ចចចារទារយកឯករាជ្យ, ព្រះចៅហៅលោក ប៉ែម សំបូរ មកធ្វើជានាយករដ្ឋមន្ត្រីវិញ ហើយ “អនុញ្ញាត្តិ” ឲ្យដឹកនាំរដ្ឋាភិបាល ដោយមិនបាច់មានរដ្ឋសភា។ លោក ប៉ែម សំបូរ ថ្វីដ្បិតតែមិនបានធ្វើឲ្យរដ្ឋសភាយល់ព្រមទទួលសន្ធិសញ្ញាថ្ងៃ ៨ វិច្ឆិកា, ក៏នៅតែបន្តកិច្ចចចារជាមួយបារាំងទៀត, ហើយចាប់និយាយគ្នា អំពីរបៀបចាត់ចែងការអនុវត្តន៍។ មិនដឹងជាមកពីហេតុអ្វីដែរ, បារាំងស្រាប់តែដកយកទៅវិញ នូវការយល់ព្រមខ្លះដែលខ្លួនបានឲ្យលើរឿងតុលាការ និងរឿងកងទ័ព។*

*

* *

*ក្នុងពេលដែលកិច្ចចចារកំពុងធ្វើទៅទាំងត្រដាបត្រដួស, ពួកវៀតមិញក៏ខំពង្រឹងតាំងទីរបស់ខ្លួននៅប្រទេសកម្ពុជាដែរ។ តាមរយៈ “កងទ័ពប្រជាជនខ្មែររំដោះ” ដែលនៅក្រោមបញ្ជាការ សឺង ង៉ុកមិញ ហើយដែលបញ្ចុះបញ្ចូលបានខ្មែរឥស្សរៈខ្លះនោះ(២០), វៀតមិញប្រកាសការកើតឡើងនៃ “រណសិរ្សជាតិរួបរួមគ្នានៃខ្មែរ*

សេរី, FNUK”។ ថ្ងៃ ១៤ មករា ១៩៥០ នៅភ្នំពេញ, អ្នកដឹកនាំប្រជាធិបតេយ្យ អៀវ កើស បានត្រូវគេសម្លាប់នឹងគ្រាប់បែកដៃមួយ, នៅក្នុងទីស្នាក់ការគណបក្ស។ ការប្រឆាំងនៃពួកប្រជាធិបតេយ្យទល់នឹងលោក យ៉ែម សំបូរ ក៏កាន់តែខ្លាំងឡើងៗ។ ការរំជើបរំជួលមានរហូតទៅដល់ក្នុងវិទ្យាល័យ។ រដ្ឋាភិបាលត្រូវហៅកងរក្សាឥណ្ឌូចិន (ជើងខ្មៅ) មកបង្ក្រាបពួកដែលធ្វើឲ្យជ្រួលច្របល់។ ខែមីនា ១៩៥០, សឺង ង៉ុកមិញ[២១] “អញ្ជើញ“ គណៈកម្មាការប្រតិបត្តិវៀតមិញ នៃ ណាម-បូ (កូសាំងស៊ីន) ឲ្យខំប្រឹងប្រែងជាមួយ “កងទ័ពប្រជាជនខ្មែររំដោះ“ ដើម្បីតយុទ្ធនឹងចក្រពត្តិនិយមបារាំង, ហើយប្រកាសការបង្កើត “រដ្ឋាភិបាលបណ្ដោះអាសន្ននៃកម្ពុជាសេរី“។ អសន្តិសុខ ក៏ឡើងដល់កំរិតខ្ពស់បំផុត។ ចរាចរតាមផ្លូវជាតិនានា ត្រូវធ្វើឡើងក្រោមការការពារនៃក្បួនរថយន្តទាហាន (កុងវ័រ)។ នៅតាមស្រុកស្រែចំការ, ពួកឥស្សរៈ - វៀតមិញ ត្រួតត្រាដូចជារដ្ឋាភិបាល “ទន្ទឹម” មួយដែរ[២២]។ បណ្ដាជនត្រូវបង់ពន្ធអាករមួយទៅឲ្យ “កងទ័ពប្រជាជន” តាមរយៈគណៈកម្មការហិរញ្ញវត្ថុមួយរបស់ “កងទ័ព” នេះ។ ចំពោះមុខស្ថានការណ៍គួរឲ្យភ័យបារម្ភនេះ យ៉ែម សំបូរ តឿនបារាំងឲ្យធាប់ផ្ដល់អាវុធយុទ្ធភ័ណ្ឌគ្រប់គ្រាន់ ដើម្បីកែនទាហាន ៥ ០០០ នាក់។ ដាច់ខែមេសា, ដើម្បីឆ្លើយតបនឹង “សេចក្ដីអញ្ជើញ” របស់ សឺង ង៉ុកមិញ, ទាហាន ៣ ០០០ នាក់ នៃកងទ័ពមែនទែនរបស់វៀតមិញ នៃ ណាម-បូ ផ្លាស់មកតាំងទីក្នុងខេត្តព្រៃវែង។ ដោយភ័យបារម្ភ, បារាំងទាមទារឲ្យលោក យ៉ែម សំបូរ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្ដោះអាសន្នមួយ ដាក់កងខេមរភូមិន្ទក្រោមបញ្ជាការបារាំង។ យ៉ែម សំបូរ មិនព្រម, បារាំងបង្ខិតបង្ខំព្រះរាជាឲ្យផ្លាស់រដ្ឋាភិបាល។ ដោយមួយចំណែកទៀត ការបង្ខិតបង្ខំដូចគ្នានេះ ស្ដេចបានទទួលពីសំណាក់ពួកប្រជាធិបតេយ្យដែរ —ដែលឆេះធួលខ្លាំងបន្ទាប់ពីឃាដកម្មលើលោក អៀវ កើស— ស្ដេចក៏បញ្ឈប់រដ្ឋាភិបាល យ៉ែម សំបូរ ទៅ, នៅថ្ងៃ ៣ ឧសភា ១៩៥០។

បន្ទាប់មក ក៏មានរយៈពេលជាដំណាក់មួយ ពីឆ្នាំ ១៩៥០[២៣] ទៅឆ្នាំ ១៩៥១ ដែលនៅក្នុងនោះ វិបត្តិគណៈរដ្ឋមន្ត្រី កើតមានជាបន្តបន្ទាប់គ្នា (ម្ចាស់ “ក្រុមហ្លួង” មុនីពង្ស, វេជ្ជបណ្ឌិត សុន ម៉ម, លោក អ៊ុំ ឈាងស៊ុន)។ ក្នុងរយៈពេលនោះ, ព្រះចៅខំនិយាយផ្សះផ្សារឲ្យបាត់ទំនាស់ ប្រកែប្រកាន់គ្នា, ហើយខំពន្យល់ឲ្យគណបក្សទាំងអស់ ចូលរួបរួមគ្នាក្នុងរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយ ក្រោមការដឹកនាំនៃលោក យ៉ែម សំបូរ, ប៉ុន្តែឥតបានការឡើយ។ ការបោះឆ្នោតនៅថ្ងៃ ៥ កញ្ញា ១៩៥១ ឲ្យជ័យជំនះម្ដងទៀត, ជាលើកទី៣ ជាប់គ្នា, ទៅគណបក្សប្រជាធិបតេយ្យ ៖ ៥៤ កៅអី ក្នុងចំនួនកៅអីទាំងអស់ ៧៨, ទល់នឹង ១៨ ទៅគណបក្សសេរីភាព។ ថ្ងៃ ១២ តុលា, រដ្ឋាភិបាលប្រជាធិបតេយ្យ នៃលោក ហ៊ុយ កន្ធុល ទទួលសេចក្ដីទុកចិត្តពីរដ្ឋសភា។ ជាថ្មីម្ដងទៀត ការតទល់គ្នារវាង និតិ និង ប្រតិបត្តិ ក៏ចាប់ផ្ដើមឡើង[២៤]។

ជាមួយនឹងការសង្ឃឹមថា នឹងបានអ្នក “កណ្ដាល” ម្នាក់ ដែលអាចជជែកជាមួយពួកប្រជាធិបតេយ្យ ព្រមទាំងបញ្ចុះបញ្ចូលពួកឥស្សរៈ ទល់នឹងវៀតមិញ, ព្រះចៅសុំឲ្យបារាំងលែងលោក សឺង ង៉ុកថាន់ មកវិញ, ដែលគេបំបរបង់នៅឯស្រុកបារាំង។ ថ្ងៃ ២៩ តុលា, លោក សឺង ង៉ុកថាន់ មកដល់ភ្នំពេញ, ទទួលដោយអ្នកគាំទ្រ ៥ ០០០ នាក់ ដែលសប្បាយរីករាយយ៉ាងខ្លាំង។ ទោះបីគាត់បានសន្យា (តាមអ្នកខ្លះថា) ថានឹងមិនប្រឡូកក្នុងរឿងនយោបាយក៏ដោយ, សឺង ង៉ុកថាន់ ចាប់ធ្វើសាជាថ្មី នូវការពន្យុះឲ្យប្រឆាំងនឹងបារាំង។ ដើម្បីកិច្ចនេះ, គាត់បង្កើតសារពិតមានមួយនៅភ្នំពេញ ឈ្មោះ “ខ្មែរក្រោក”, ហើយធ្វើការឃោសនានៅតាមខេត្ត។ ក្នុងកិច្ចសន្ទនាជាសាធារណៈមួយនៅក្រុងតាកែវ, លោក សឺង ង៉ុកថាន់ ដែលមានលោក ប៉ាច ឈឺន (រដ្ឋមន្ត្រីក្រសួងឃោសនាការនៃរដ្ឋាភិបាល ហ៊ុយ កន្ធុល) ជូនមកផង, បញ្ចេញចំណាងជើងនៃការតយុទ្ធរបស់គាត់ ៖ «ប្រទេសកម្ពុជាត្រូវទាមទារឲ្យបារាំងដកទ័ពខ្លួនចេញទៅទាំងអស់, ទើបអាចធ្វើឲ្យមានឯករាជ្យពេញទី នឹងឲ្យជីវិតនយោបាយដើរដូចធម្មតាវិញ»។ បារាំងវិនិច្ឆ័យថា សកម្មភាពលោក សឺង ង៉ុកថាន់ អាចឲ្យគ្រោះថ្នាក់ដល់

*សន្តិសុខខ្លួន (អធិបតីភាព), ក៏ឲ្យបិទសារព័ត៌មាន ខ្មែរក្រោក នៅខែកុម្ភៈ ១៩៥២។ សឺង ង៉ុកថាន់ ក៏ជ្រើសរើសមាគ៌ាដែលនៅសល់ ៖ ចូលព្រៃ[២៥]។ ថ្ងៃ ៩ មីនា, ដែលជាថ្ងៃខួប ឯករាជ្យ ចំពោះអ្នកបង្កើត សារព័ត៌មាន* ***នគរវត្ត*** *និង* ***ខ្មែរក្រោក****, សឺង ង៉ុកថាន់ ធ្វើសេចក្តីអំពាវនាវដល់ប្រទេស ឲ្យកាន់អាវុធប្រយុទ្ធ យកឯករាជ្យ, តាមសំលេងស្ថានីយវិទ្យុលួចលាក់មួយ[២៦] នៅក្នុងដងរែក។ ដោយមានអ្នករាជការខាងគយម្នាក់យ៉ាងស្វាហាប់ —លោក អៀវ ស៊ីចូវ— ជួយធ្វើការផង, សឺង ង៉ុកថាន់ ខំប្រមែប្រមូលពួកក្រុមឥស្សរៈ ដែលមិនទាន់ចុះចូលនឹងរាជរដ្ឋាភិបាលនៅឡើយ (មាន កៅ តក់ ជាដើម), ហើយបង្កើតគណៈកម្មការខ្មែររំដោះជាតិមួយទៀត។ មិនយូរឡើយ, ការស៊ីគ្រលំគ្នាក៏កើតមានឡើង រវាងគណបក្សប្រជាធិបតេយ្យ និង ចលនាឥស្សរៈ។ តាំងតែពីកើតមក រាជាធិបតេយ្យពុំដែលទទួលការគំរាមកំហែងដូច្នេះឡើយ។ ដើម្បីជំរុញឲ្យរដ្ឋាភិបាល ហ៊ុយ កន្ធុល ទម្លាក់បៀរបស់ខ្លួន, ព្រះចៅប្រាប់រដ្ឋាភិបាលឲ្យចាត់វិធានការណ៍ជាចាំបាច់ ទល់នឹងចលនាឥស្សរៈ។ មិនត្រឹមតែមិនធ្វើតាមស្តេច, លោក ហ៊ុយ កន្ធុល ថែមទាំងឲ្យចាប់មិត្តស្តេចពីរនាក់ទៀត ៖ លោក យ៉ែម សំបូរ និង លន់ នល់។ ១-ដោយចោទពួកតំណាងរាស្ត្រប្រជាធិបតេយ្យ ថាប្រឡំយកប្រយោជន៍គណបក្សខ្លួន ជាប្រយោជន៍ប្រទេសខ្លួន, ២-យកលេសលើការចាប់លោក យ៉ែម សំបូរ និង លន់ នល់, ព្រះចៅបញ្ឈប់រដ្ឋាភិបាល ហ៊ុយ កន្ធុល នៅថ្ងៃ ១៥ មិថុនា ១៩៥២, ហើយកាន់នាទីនាយករដ្ឋមន្ត្រីខ្លួនឯង។*

*បន្ទាប់ពី "រដ្ឋប្រហារត្រូវច្បាប់" នេះមក, ព្រះចៅសុំទៅរដ្ឋសភាឲ្យអនុមត្តិប្រគល់មកនូវអំណាចពិសេសក្នុងវេលាបីឆ្នាំ, ដោយសន្យាថានឹងយកឯករាជ្យពេញទីឲ្យបានក្នុងរយៈពេលបីឆ្នាំនេះ។ ដើម្បីទល់នឹងចលនាឥស្សរៈ, ស្តេចដាក់ទៅរដ្ឋសភានូវគំរោងថវិកាមួយដែល ៣០% ទុកដំកល់ទិញគ្រឿងអាវុធ, ហើយដែលសុំតំលើងពន្ធអាករទាំងឡាយ។ សេចក្តីសុំនេះធ្វើទៅរដ្ឋសភាហើយ, ស្តេចចេញទៅសៀមរាប ហើយនាំអតីតមេឥស្សរៈ ដាប ឈួន ធ្វើប្រតិបត្តិការមួយរកចាប់ សឺង ង៉ុកថាន់។ នៅដំណាច់ឆ្នាំ ១៩៥២ ព្រះចៅត្រឡប់មកភ្នំពេញវិញ ដោយឥតបានជោគជ័យអ្វីឡើយ។ ក្នុងរាជធានី ព្រះចៅបានដឹងថា រដ្ឋសភាបានទាត់ចោលទាំងអស់នូវការសុំឲ្យទទួលសន្និសញ្ញា ថ្ងៃ ៨ វិច្ឆិកា ១៩៤៩ សំណុំអំណាចពិសេស និងគំរោងថវិការ។ លើសពីនេះ ពួករដ្ឋមន្ត្រី (ដែលច្រើនតែក្រុមញាត្តិស្តេច ៖ ម្ចាស់ សុង ដេត, សិរិមតៈ, ប៉េងប៉ោះយុគន្ធរ ។ល។ ប្រាប់ស្តេចឲ្យដឹងពីការបំរុងក្បត់មួយដែលចង់រំលាយរាជាធិតេយ្យ។ ការរំជើបរំជួលក៏បានទៅដល់ពួកសិស្សវិទ្យាល័យទៀត ដែលនាំគ្នាធ្វើកូដកម្ម ចាប់តាំងពីថ្ងៃ ៨ ធ្នូ ១៩៥២, កូដកម្មដែលជាប់រហូតជាងមួយខែ។ លើកនេះព្រះចៅប្រើពាក្យចោទ ៣ ៖ ១- ថាពួកប្រជាធិបតេយ្យខ្លះទាក់ទងនឹងវៀតមិញ[២៧], ២- ថាគណៈកម្មការនាយកនៃគណបក្សប្រជាធិតេយ្យបានបង្កើត "គណកម្មការធ្វើឃាតកម្ម" មួយ (តំណាងរាស្ត្រ ៩ នាក់ បានត្រូវចាប់ឃុំឃាំង), ៣- ថាគេប្រើហិបការទូតរបស់បាងកក ដើម្បីទាក់ទងនឹង សឺង ង៉ុកថាន់។ រួចហើយ ស្តេចក៏ប្រើជាលើកទី២ នូវមាត្រាទី ២១ នៃរដ្ឋធម្មនុញ្ញ, ដោយចុះរាជក្រឹត្យមួយរំលាយរដ្ឋសភានៅថ្ងៃ ១៣ មករា ១៩៥៣ [២៨] និងក្រឹត្យមួយទៀតប្រកាសប្រើច្បាប់អាជ្ញាសឹក នៅថ្ងៃជាមួយគ្នា។*

*និយាយទៅកាន់អ្នកសារព័ត៌មានម្នាក់, ព្រះចៅថា ៖ "រដ្ឋសភាបានក្លាយទៅជាទីជំរករបស់ការក្បត់។ បើបារាំងចេញពីឥណ្ឌូចិន យើងនឹងបានឯករាជ្យ, ប្រាកដហើយ, ប៉ុន្តែបានប៉ុន្មានឆ្នាំ? ខ្ញុំធ្វើសហប្រតិបត្តិការផ្លូវសឹកជាមួយបារាំង ដើម្បីការពារសេរីភាពយើង។ ក្នុងពេលជាមួយគ្នា ខ្ញុំចចារជាមួយបារាំងក្នុងបរិយាកាសមួយស្មោះត្រង់ ដើម្បីដោះស្រាយទំនាស់ខ្លះ។ នេះជាជំហររបស់ខ្ញុំ!" (សារព័ត៌មាន "ឡឺម៉ុង"), ថ្ងៃ ១៨-១៩ មករា ១៩៥៣)។ ដោយឃើញជាងថ្នាយក្រោយពួកប្រជាធិតេយ្យ ដែលជាគូប្រជែង, ស្តេចទើបនឹងយល់ន័យពិតប្រាកដរបស់បំណងនៃប្រជារាស្ត្រ ៖ ឯករាជ្យ! ។ ដើម្បីប្រមែប្រមូលទាក់ទាញប្រជារាស្ត្រ, ស្តេចនៅសល់តែមធ្យោបាយមួយទេ, គឺត្រូវតែរកឲ្យបាននូវឯករាជ្យនេះ។ ពុំនោះសោត រាជាធិតេយ្យនឹងត្រូវបាត់បង់ដោយ*

ចៀសពុំរួច បើសិនជាចលនាខ្មែរឥស្សរៈ (ជាមួយ សឺង ង៉ុកថាន់ និង គណៈកម្មការខ្មែររំដោះជាតិ) ឬ ចលនាខ្មែរ-វៀតមិញ (ជាមួយនឹង សឺង ង៉ុកមិញ និងរដ្ឋាភិបាលបណ្ដោះអាសន្ននៃកម្ពុជាសេរី) ដណ្ដើមយកឯករាជ្យបានមុនៗ

*

*  *

ដូច ហូជីមិញ ដែរ, ព្រះចៅចង់ចចារយកឯករាជ្យនេះ ឆ្ងាយពីបរិយាកាសអាណានិគមនិយមៗ ថ្ងៃ ៩ កុម្ភៈ ១៩៥៣, បន្ទាប់ពីបានផ្ទេរតំណែងនាយករដ្ឋមន្ត្រីទៅលោក ប៉ែន នុត និងដាក់ក្រុមប្រឹក្សារាជានុសិទ្ធិ ក្រោមការដឹកនាំរបស់សម្ដេច នរោត្ដម សុរាម្រិត ដែលត្រូវជាឪពុក, ព្រះបាទ សីហនុ ចេញពីភ្នំពេញទៅស្រុកបារាំងៗ គឺជាការចាប់ផ្ដើមរយៈពេលប្រវត្តិសាស្ត្រ ដែលពួកអ្នកនយោបាយសង្គមរាស្ត្រនិយមបានដាក់ឈ្មោះថា "ព្រះរាជបូជនីយកម្មដើម្បីឯករាជ្យ"ៗ តាំងពីពេលចុះសំចតនៅក្រុងរ៉ូម, ព្រះចៅផ្ញើសារមួយទៅលោក វ៉ាំងសង់ អូរីយ៉ូល (ប្រធានាធិតីទី១ នៃសាធារណរដ្ឋទី៤ បារាំង) បង្ហាញការយល់ឃើញនៃព្រះចៅ លើការធ្វើឲ្យមានឯករាជ្យនៅប្រទេសកម្ពុជាៗ មកដល់ស្រុកបារាំង ព្រះបាទសីហនុស្នាក់នៅឯ ឡាណាពូល (កូតដាហ្ស៊ួ) ហើយផ្ញើពីទីនោះ នូវសំបុត្រជាច្រើនទៅ វ៉ាំងសង់ អូរីយ៉ូល, ទាមទារឲ្យផ្ទេរអំណាចទាហាន និងតុលាការមកខ្មែរវិញៗ ថ្ងៃ ២៥ មីនា ទើបគេទទួលព្រះរាជានៅវិមាន អេលីហ្សេៗ កិច្ចសន្ទនា សីហនុ-អូរីយ៉ូល ឥតចេញជាអ្វីទាំងអស់, ព្រោះអូរីយ៉ូលធ្វើជាមិនឮតែម្ដងៗ ត្រឡប់មកនៅឯ ហ្វុងតែនប្លូ, ព្រះចៅខំធ្វើឲ្យកិច្ចចចារទៅមុខឡើងវិញ, ដោយទាក់ទងនឹងអ្នកទទួលខុសត្រូវបារាំងជាច្រើនៗ ប៉ុន្តែការទាមទារទាំងនេះ ឥតបានត្រូវគេទទួលឮឡើយៗ

ដោយតូចចិត្តដែរ, ព្រះចៅនឹកឃើញដល់សហរដ្ឋអាមេរិក ដែលជាអ្នកផ្ដល់អាវុធច្រើនជាងគេ (បន្ទាប់ពីចិនបានក្លាយទៅជាកុម្មុយនិស្ត) ដល់ទ័ពបារាំងនៅឥណ្ឌូចិនៗ បន្ទាប់ពីបានទុកសហការីមួយចំនួន ឲ្យនៅចាំធ្វើកិច្ចចចារជាមួយបារាំង (លោក ប៉ែន នុត និង សម សារី), ព្រះរាជាបានមកដល់ ម៉ុងរ៉េអាល់ នៅថ្ងៃ ១២ មេសា ១៩៥៣, ហើយស្នាក់នៅ កាណាដា មួយអាទិត្យ ដើម្បីធ្វើឲ្យពួកសារពិតមាន កាណាដា ជ្រួតជ្រាបខ្លះ អំពីរឿងខ្មែរៗ ថ្ងៃ ១៩ មេសា ព្រះបាទសីហនុបានត្រូវទទួលនៅ វ៉ាស៊ីងតោន ដោយលោក រីឈើត និចសុន (អនុប្រធានាធិបតីអាមេរិកាំង)ៗ បន្ទាប់មក ព្រះចៅជួបសន្ទនាក្នុងពេលមួយម៉ោង ជាមួយរដ្ឋលេខាធិការ ដល្លឹសៗ ទៅមេនៃកិច្ចការទូតអាមេរិកាំង ព្រះចៅនិយាយថា ៖ "បើមិនរកការដោះស្រាយខាងផ្លូវនយោបាយទេ ការប្រឹងប្រែងខាងយោធា, ទោះបីអាមេរិកាំងជួយម្ដេចក៏ដោយ, ក៏នឹងមិនអាចឈ្នះដែរៗ ជ័យជំនះ មិនអាចយកបានឡើយ បើប្រជារាស្ត្រមិនចូលរួមក្នុងការតយុទ្ធ ដោយមានជំនឿថាខ្លួនតយុទ្ធដើម្បីប្រយោជន៍ខ្លួនៗ ឲ្យឯករាជ្យពិតប្រាកដដល់ប្រទេសទាំងឡាយនៅឥណ្ឌូចិន គឺធ្វើឲ្យប្រទេសទាំងនេះយល់កាន់តែច្បាស់ ដល់ការទទួលខុសត្រូវរបស់ខ្លួនក្នុងសង្គ្រាមនេះ, សង្គ្រាមដែលការឈ្នះចាញ់ ទទួលយកចិត្តទុកដាក់ ពីលោកប្រជាធិបតេយ្យទាំងមូលៗ" ចម្លើយរបស់ ដល្លឹស ៖ "ទូលបង្គំសន្យានឹងព្រះអង្គថា កាលណាគ្រោះថ្នាក់កុម្មុយនិស្តអស់ពីប្រទេសព្រះអង្គហើយ, យើងនឹងធ្វើអ្វីទាំងអស់ដែលអាចធ្វើទៅបាន ដើម្បីឲ្យបារាំងទទួលស្គាល់ឯករាជ្យយ៉ាងពេញលេញរបស់ (ប្រទេស) ព្រះអង្គៗ ប៉ុន្តែដរាបណាសត្រូវរួមរបស់យើង (វៀតមិញ) មិនទាន់បរាជ័យទេ — ហើយព្រះអង្គជ្រាបច្បាស់ថាវាមានសមត្ថភាព និងបោសកំចាត់ចោលរាជាធិបតេយ្យខ្មែរ ព្រមទាំងទំនៀមទំលាប់ដ៏ត្រកាលរបស់ (ប្រទេស) ព្រះអង្គ, អារិយធម៌ ដ៏ចាស់យូរអង្វែង ហើយនិងប្រជាធិតេយ្យដ៏ក្មេងរបស់ព្រះអង្គ — ដរាបណាគ្រោះថ្នាក់ដ៏ធំនេះ ដែលអាចជាគ្រោះថ្នាក់ដល់ជីវិតរបស់ (ប្រទេស) ព្រះអង្គមិនទាន់កំចាត់បានទេ យើងមិនអាចធ្វើឲ្យបារាំងអស់ចិត្តអស់កម្លាំងបានឡើយ (...)ៗ ទំនាស់រវាងព្រះអង្គនិង

បារាំង នឹងបំរើតែប្រយោជន៍សត្រូវរួមយើងទេ។" (ស្រង់ចេញពី "នយោបាយក្រៅប្រទេសកម្ពុជា" ដោយ រ៉ូហ្សេស្មិថ)។

ដោយអាមេរិកាំងលាយផលប្រយោជន៍ខ្លួន ជាមួយផលប្រយោជន៍បារាំង, ព្រះចៅក៏បានខកចិត្តម្តងទៀត។ មុននឹងចេញពីញូវយ៉កមកភ្នំពេញវិញ ដោយកាត់តាមតូក្យូ ព្រះចៅធ្វើសេចក្តីថ្លែងការណ៍មួយទៅសារពិតមានញូវយ៉កថែម ៖ តាំងពីប៉ុន្មានឆ្នាំមកហើយ, គំនិតថាវៀតមិញតយុទ្ធដើម្បីឯករាជ្យនៃប្រទេស កាន់តែមានគេជឿច្រើនឡើង ក្នុងពពួកវរជនខ្មែរ។ បើបារាំងមិនឲ្យឯករាជ្យកាន់តែច្រើនឡើងទៅខ្មែរទេ, ក្នុង ៣-៤ ខែខាងមុខនេះ ខ្មែរអាចរួបរួមមែនទែនជាមួយវៀតមិញ។ សេចក្តីថ្លែងការណ៍នេះ ធ្វើឲ្យគេភ្ញាក់ផ្អើលគ្រប់គ្នាក្នុងចំណោមអ្នកនយោបាយបារាំង, ហើយខ្លះស្រែកថាជា "កាំបិតភ្ជង់ក" (chantage)។ បន្ទាប់ពីការគំរាមនេះ, បា-រាំងបន្ធូរឥរិយាបថបន្តិច, ហើយកិច្ចចចារបារាំង-ខ្មែរ ក៏ចាប់ធ្វើឡើងវិញ នៅដំណាច់ខែមេសា។ ថ្ងៃ ៩ ឧសភា ១៩៥៣, លោក ប៉ែន នុត និងលោក ដឺម៉ុងសែល, រដ្ឋមន្ត្រីក្រសួងសហគតរដ្ឋ, ចុះកិច្ចព្រមព្រៀង បារាំង-ខ្មែរមួយ ដែលនៅក្នុងនោះ ខ្មែរនៅតែមិនបានទទួលឲ្យពេញចិត្តមែនទែន។ បារាំងមិនព្រមឲ្យស្តេចធ្វើ ជាអគ្គមេបញ្ជាការ កងកម្លាំងប្រឆាំងវៀតមិញ ដោយមានឧត្តមសេនីយបារាំងម្នាក់ជាទីប្រឹក្សា, ប៉ុន្តែព្រមទុកឲ្យនៅក្រោមការទទួលខុសត្រូវពេញទីនៃកងខេមរភូមិន្ទ ភូមិភាគទាំងឡាយ ដែលនៅខាងលិចទន្លេមេគង្គ (ហៅភូមិភាគស្វយ័ត)។ ចំណែកដែនដីដែលនៅចន្លោះទន្លេមេគង្គ និងព្រំដែនខ្មែរ-យួន (ដែលនៅក្នុងនោះ វៀតមិញដាក់ទ័ពជាង ១០ ០០០ នាក់) ទីបញ្ជាការបារាំងទុកសំរាប់ខ្លួន (កងទ័ពខ្មែរមាន ១២ កងវរសេនាតូច ដែល ៦ ជារបស់បារាំង)។ ចិននៅស្រុកខ្មែរចូលមកក្រោមនិតិបញ្ញត្តិខ្មែរ ប៉ុន្តែជនជាតិបារាំងនៅតែមានអភ័យឯកសិទ្ធិ មិនចូលក្រោមច្បាប់ខ្មែរទៀត។ ការទាស់ខ្វែងគ្នា លើរឿងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច នៅសល់ទាំងស្រុង, ហើយទាស់កាន់តែខ្លាំងទៅទៀត ដោយរដ្ឋាភិបាលបារាំង សំរេចតែម្នាក់ឯង នៅថ្ងៃ ១១ ឧសភា ឲ្យបញ្ចុះតម្លៃប្រាក់ "ប្យ៉ាស" ដែលចាយជាមួយគ្នាក្នុងប្រទេសទាំង៣ នៃឥណ្ឌូចិន (អានលេខយោង ២៣)

ថ្ងៃ ១២ មិថុនា, បន្ទាប់ពីបានផ្ទេរដំណែងទាំងអស់ម្តងទៀត ទៅលោក ប៉ែន នុត, ព្រះចៅសំរេចចិត្តទៅបាងកក ហើយប៉ងនៅទីនោះ ដើម្បីបង្កើតរដ្ឋាភិបាលក្រៅប្រទេស (en exil) មួយ។ ថ្ងៃ ១៦, ដោយមានអ្នកមក ជាមួយ ២៦ នាក់ផង (ក្នុងនោះមានម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ, រដ្ឋមន្ត្រីក្រសួងការពារប្រទេស), ព្រះចៅមកដល់បាងកក ទទួលដោយឧត្តមសេនីយ ផាវ ស្រីយ៉ាណន, មេនគរបាលថៃ។ នៅភ្នំពេញ, ក្រោយពេលស្តេចចេញដំណើរ, វិទ្យុជាតិផ្សាយសាររបស់ព្រះចៅទៅបារាំង ៖ "ដោយចង់ចៀសវាងចម្បាំង ឬ ការបះបោរទល់នឹងប្រទេសបារាំង —ចម្បាំង ឬ ការបះបោរដែលខ្មែរកាន់តែច្រើនឡើងៗ ចង់ធ្វើ— ខ្ញុំចាកចេញពីមាតុភូមិដើម្បីយកឲ្យបាននូវឯករាជ្យដែលប្រជាជាតិខ្មែរចង់បាន, ដោយមិនចាំបាច់ឲ្យការទាក់ទងជាភាតរភាពជាមួយប្រទេសបារាំងមានគ្រោះថ្នាក់ជាស្ថាពរឡើយ។ ប្រទេសបារាំងធ្វើឲ្យគេយល់ឃើញ, តាមអាកប្បកិរិយានិងការរារែករបស់ខ្លួន, ថាខ្លួនមិនចង់ឲ្យឡើយ ទោះក្នុងបច្ចុប្បន្ន ទោះក្នុងអនាគត នូវឯករាជ្យពិតប្រាកដ, ដែលជាវត្ថុតែមួយអាចធ្វើជាដើមទី នៃសហប្រត្តិបត្តិការផ្លូវសីកដ៏ស្មោះ និងដែលមានប្រយោជន៍ រវាងប្រទេសយើងទាំង២ ហើយដើម្បីកសាងការរួបរួមរបស់យើង ក្នុងសហភាពបារាំង។

នៅប្រទេសថៃ, ព្រះចៅ ដែលអាជ្ញាធរថៃសំគាល់ថាជាអ្នកភៀសខ្លួននយោបាយ បានត្រូវសៀមហាមមិនឲ្យធ្វើសកម្មភាពនយោបាយអ្វីទាំងអស់។ ព្រះបាទសីហនុ ព្រមទាំងអ្នកទៅជាមួយ ក៏ត្រឡប់មកបាត់ដំបងវិញ ដែលបានទទួលស្វ័យភាពហើយ។ ក្នុងចន្លោះពេលនោះ នៅភ្នំពេញ, សភាពតានតឹង ក៏កើតមានឡើងរវាងខ្មែរនិងបារាំង។ ឧត្តមសេនីយ ដឺឡង់ក្លាត, មេបញ្ជាការទ័ពជើងគោកនៅកម្ពុជា, ហៅកងទាហានជំនួយមកពីស្រុកយួន ដើម្បីការពារស៊ីវិលបារាំង ប្រមាណ ៦០០ នាក់ ទៅស្រុកខ្មែរ។ កងការពារនៃសហភាពដែលមាន

*បារាំង, យួន, ម៉ារ៉ូកាំង និងអាល់ហ្សេរីយាង និងមានកងកាំភ្លើងធំ ចាំជួយគាំទ្រផង, រាយគ្នាដាក់គ្រប់កន្លែងយុទ្ធសាស្ត្រនៅក្រុងភ្នំពេញ។ ចំណែកខាងខ្មែរ, កងទាហាននៃវរសេនីយត្រី ពុត ឆាយ (អតីតមេឥស្សរៈចុះចូលពីខែឧសភា ១៩៥៣) កាន់កាប់អាគាររាជការទាំងអស់។*

*ពីក្រុងបាត់ដំបង ព្រះចៅប្រាប់បារាំងថារដ្ឋាភិបាលខ្មែរទាត់ចោលកិច្ចព្រមព្រៀង ថ្ងៃ ៦ ឧសភា ហើយសុំឲ្យធ្វើកិច្ចចចារថ្មី ដែលក្នុងនោះ ខ្មែរទាមទារលក្ខន្តិកៈមួយដូច "ដូមីនីញ៉ុង" របស់ប្រទេសប៉ាគីស្ថង់ ចំពោះមុខប្រទេសអង់គ្លេស។ ថ្ងៃ ២ កក្កដា ព្រះរាជាអំពាវនាវតាមរាជសារមួយទៅប្រជាជាតិ ហៅប្រមូលកម្លាំងរស់រវើកទាំងអស់នៃប្រទេស ដើម្បីចាំរក្សាទុកឯករាជ្យ ដោយបង្កើត កងជីវពល និង នារីក្លាហាន ។ ភ្លាមមួយរំពេច បុរសនិងនារី ២០ ០០០ នាក់ ឆ្លើយតបនឹងការអំពាវនាវនេះ, ហើយប្រជុំគ្នានៅក្រុងសៀមរាប និងបាត់ដំបង។ ស្អែកឡើងថ្ងៃ ៣ កក្កដា, រដ្ឋាភិបាលបារាំងរបស់ ឡានីញែល ប្រជុំគណៈរដ្ឋមន្ត្រី ហើយឲ្យកំណត់កិច្ចមួយទៅអគ្គស្នងការប្រចាំសមាគតរដ្ឋទាំងបី, ដែលនៅក្នុងនោះរដ្ឋាភិបាលបារាំងស្នើថានឹងឲ្យ ឯករាជ្យក្រោយកិច្ចចចារថ្មីទៀត។ ដើម្បីបង្ហាញសុឆន្ទៈរបស់ខ្លួន បារាំងដាក់អ្នកការទូតម្នាក់, ម៉ូរីស ដឺហ្សង់, ជាអគ្គស្នងការនៅឥណ្ឌូចិន។ ក្នុងបរិយាកាសមួយដែលតឹងដែរ, កិច្ចចចារបារាំង-ខ្មែរ ចាប់ធ្វើឡើងនៅថ្ងៃ ៣១ កក្កដា នៅភ្នំពេញ រវាងលោក ប៉ែន នុត និងលោក ដឺហ្សង់។ កិច្ចចចារនេះ បានចេញជាការព្រមព្រៀងជាលើកដំបូងមួយ នៅថ្ងៃ ៩ សីហា, លើការផ្ទេរមកខ្មែរវិញនូវអំណាចតុលាការ និងនគរបាល។ ថ្ងៃ ១៧ តុលា ១៩៥៣, សេនាប្រមុខ ហ្ស៊ូ វ៉ាំង, ក្នុងឋានៈជាតំណាងនៃកងទ័ពបារាំង, ធ្វើពិធីផ្ទេរអំណាចទាហានមកប្រទេសកម្ពុជា, ហើយបង្ហូតចុះមកជាស្ថាពរនូវទង់ជាតិបារាំង, កិច្ចដែលបញ្ចប់ ៩០ ឆ្នាំនៃអាណានិគមកម្មរបស់បារាំង។ ថ្ងៃ ៨ វិច្ឆិកា ១៩៥៣, ព្រះចៅសីហនុ ធ្វើដំណើរចូលដ៏មានជោគជ័យក្នុងក្រុងភ្នំពេញ, ហើយសម័យមួយទៀតក៏ចាប់បើកទំព័រឡើង, សម័យសង្គមរាស្ត្រនិយម(២៩) សម័យនៃអំណាចផ្ទាល់ខ្លួន។*

---

# អធិប្បាយ

(១) រឿងសត្វសេក និង រឿងកូនចាប ដែលសម្តេចសីហនុថ្លៃងក្នុង "ឥណ្ឌូចិន ឃើញពីប៉េកាំង" បញ្ជាំងយ៉ាងច្បាស់នូវស្ថានភាពនេះ។

(២) លោក ប៉ាច ឈឿន បានត្រូវគេ (ជប៉ុន) ដោះលែងពីកោះត្រឡាច ក្រោយពីបានជាប់ឃុំឃាំងចំនួនពីរឆ្នាំ។ ក្នុងសៀវភៅ "កម្ពុជាក្នុងសង្គ្រាមនៅអាស៊ីភាគអគ្នេយ៍" ឡឺក ហោតាន់ និង ម៉ាលខុម ខាត់វែលសរសេរថា លោកអាចារ្យ ចៀវ ដែលជាប់ជាមួយគ្នានឹងលោក ប៉ាច ឈឿន បានសុគត "ក្រោមទារុណកម្ម ឬដោយគេយកទៅប្រហារជីវិត"។

(៣) ពួកដែលតទល់នឹងរាជាធិបតេយ្យនេះ បែកជាពីរចំណែកទៅទៀត : ពួកទី១, ដែលគេបានហៅថាពួក "ខាងស្តាំ", ប្រមូលផ្តុំអ្នកដែលបានជោគជាំច្រើន នឹងតម្លៃបស្ចិមទិស ហើយដែលចង់ឃើញប្រទេសខ្លួន មានស្ថាប័ននយោបាយនិងសង្គមកិច្ច ដូចដែលមាននៅបស្ចិមប្រទេស។ ពួកទី២, "ខាងឆ្វេង" ជានិមិត្តរូបនៃការបះបោររបស់ទ្វីបអាស៊ីទល់នឹងបស្ចិមទិស។ មនុស្សដែលនៅក្នុងពួកទី ២ នេះ ច្រើនតែបានទទួលចំណេះវិជ្ជា និងការអប់រំនៅបស្ចិមប្រទេស។ ប៉ុន្តែអ្នកទាំងនេះ ទាត់ចោលទាំងស្រុងនូវតម្លៃបស្ចិមប្រទេស ដែលខ្លួនយល់ថាជាដើមហេតុ នៃការពុករលួយនិងទ្រុឌទ្រោមរបស់សង្គមខ្លួន។ ពួកនេះជាកម្លាំងនៃរបបរួមសំបាច់នៅអាស៊ី។

(៤) ប្រៀបប្រដូចទៅប្រទេសវៀតណាម រដ្ឋការអាណានិគមបានព្រងើយកន្តើយទាំងស្រុង ចំពោះការអប់រំនៅប្រទេសកម្ពុជា។ នៅឆ្នាំ ១៩៣៩ ពេលដែលប្រទេសកម្ពុជាមានសិស្សតែបួននាក់ក្នុងមធ្យមសិក្សាភាគទី២ ប្រទេសវៀតណាមមានសាកលវិទ្យាល័យមួយទៅហើយ (១៩០៤)។ ក្នុងឆ្នាំ ១៩៣៧ នៅប្រទេសថៃ មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ ឋាម្ម៉ាសាត បានបើកទ្វារឡើង ដើម្បីអប់រំអ្នកនយោបាយ និងអ្នកការទូត។ ពេលដែលថ្អឹងខ្នងរបស់វៀតណាមមានសុទ្ធតែអ្នកពហុបច្ចេកទេស បណ្ឌិត វិស្វករ អ្នកនិតិសាស្ត្រ ។ល។ ប្រទេសកម្ពុជានៅពីក្រោយឆ្ងាយណាស់។ ដោយឥតមានការមើលងាយ យើងត្រូវតែបើកភ្នែកឲ្យឃើញថា រដ្ឋមន្ត្រីទី១ រដ្ឋមន្ត្រី ឧត្តមសេនីយ តំណាងរាស្ត្រ ទូត ។ល។ លើកលែងតែមួយចំនួនតូច មានកំរិតការអប់រំត្រឹមតែមធ្យមសិក្សា។ អតីតសិស្សសាលារដ្ឋបាលទាំងនោះ (សាលាដែលបារាំងបង្កើតដើម្បីធ្វើឲ្យម៉ាស៊ីនរដ្ឋការអាណានិគមខ្លួនដើរ) ត្រួតត្រាយ៉ាងដាច់មុខលើប្រទេសកម្ពុជា ក្នុងរយៈវេលាជាង ២៥ ឆ្នាំ។ ពេលដែលយុវជនចេញពីមហាវិទ្យាល័យមកដល់លើឆាកជីវិតប្រទេស ទំនាស់រហូតដល់រវាងជំនាន់មនុស្ស (conflit de génération) ក៏កើតមានឡើង។ បាតុភូត ហ៊ុយ និម-ហ៊ូ យន់-ខៀវ សំផន ជាលទ្ធផលនៃទំនាស់នោះ។ ដើម្បីក្រញាំបុណ្យសក្តិខ្លួនឲ្យជាប់ នាហ្មឺនផុប់មិនឲ្យឡើងក្មេងណា ដែលមិនព្រមចូលក្នុងគ្រឿងយន្តពុករលួយរបស់ខ្លួន។ ដូចពួកចិនដែរ នាហ្មឺនប្រើចំណងអាពាហ៍ពិពាហ៍ ដើម្បីទាក់ក្មេងឲ្យមកជាមួយខ្លួន។ មហាវិយោគនៃប្រជាជនខ្មែរសព្វថ្ងៃ ជាការក្លាយមួយនៃដំបៅសង្គមនេះ។

(៥) សុទ្ធ ប៉ូលីន និង ប៊ែណា ហាម៉ែល បានសរសេរសៀវភៅមួយឈ្មោះ "សក្ខីភាពអំពីមនុស្សឃោដនៅកម្ពុជា" ដែលនៅក្នុងចំណោមសៀវភៅមុនគេទាំងអស់ (១៩៧៦) ដែលបានប្រាប់មតិអន្តរជាតិ អំពីមហាវិយោគខ្មែរ។

(៦) អ្នកបោះឆ្នោត ត្រូវឆ្លើយនឹងសំនួរ៥ :

១) ប្រជាជនចង់ឲ្យប្រទេសបានឯករាជ្យពេញទី ឬទេ?

២) ប្រជាជនចង់ប្រឆាំងនឹងការវិលត្រឡប់មកវិញ នៃបារាំង ឬទេ?

៣) ប្រជាជនពេញចិត្តនឹងការបង្កើតមុខងារជានាយករដ្ឋមន្ត្រីទី១ ឬទេ?

៤) ប្រជាជនទុកចិត្តឬទេ លើរដ្ឋាភិបាលសព្វថ្ងៃ ដែលមានលោក សឺង ង៉ុកថាន់ ជាអ្នកដឹកនាំ ហើយដែលមានបេសកកម្មដ៏ខ្ពស់ ត្រូវការពារនិងរក្សាទុកជាស្ថាពរ នូវឯករាជ្យនិងសេរីភាពប្រទេស?

៥) ប្រជាជនចង់បានឬទេ នូវការការពារពីសំណាក់មហាអំណាចបរទេសណាមួយ? (បកប្រែ)។

ក្នុងចំណោម អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំង ៦៧៤ ០៤៨ នាក់ អ្នកដែលបានបោះមានចំនួន ៥៤១ ៤៧០ នាក់ ហើយបានឆ្លើយ ១០០% ថា "ចង់" ទៅសំនួរទី១និងទី២, ថា "ពេញចិត្ត" ទៅសំនួរទី៣, ថា "ទុកចិត្ត" ទៅសំនួរទី៤, ហើយថា "ទេ" ទៅសំនួរទី៥ (ដកចេញពី "សាវតានៃអាស៊ីអាគ្នេយ៍" ដោយ ហ្វីលីព ដឺវីល្លេ)។

(៧) តាមអ្នកនិពន្ធ ជាវិឌ ស្តែងប៊ែក ចលនាខ្មែរឥស្សរៈ ដែលលោក សឺង ង៉ុកថាន់ ជាអ្នកបង្កើត បានមានឡើងតាំងពីឆ្នាំ ១៩៤១ (?) គឺមុនពេលដែល សឺង ង៉ុកថាន់ ត្រូវបារាំងរកចាប់ ហើយភៀសខ្លួនមកបាងកក រួចមកតូក្យូ។ ចលនានេះចាប់បដិសន្ធិលើទឹកដីដែលបារាំងឲ្យទៅសៀម តាមសន្ធិសញ្ញាក្រុងតូក្យូឆ្នាំ ១៩៤១។ តាមអ្នកនិពន្ធដដែល, ក្នុងចន្លោះឆ្នាំ ១៩៤១ និង ១៩៤៥ ពួកអ្នកជាតិនិយមមួយក្រុមក្រោមការដឹកនាំនៃ សឺង ង៉ុកថាន់ ហើយដែលបានភៀសខ្លួនទៅនៅប្រទេសថៃ បានធ្វើការរៀបចំរចនាសម្ព័ន្ធនៃចលនានេះ ដោយមានសៀមជួយផង (លោក ថាន់ ចុះ-ឡើង បាងកក-តូក្យូ ឬ អ្វី?)។ ថ្ងៃ ៨ សីហា ១៩៤៦ កងឥស្សរៈចូលវាយក្រុងសៀមរាប កាន់កាប់អង្គរវត្ត ហើយបាញ់ចោលនាយទាហានបារាំងពីរនាក់នៅទីនោះ។ ពេលដែលសៀមឲ្យខេត្តទាំង ៥ មកខ្មែរវិញនៅខែវិច្ឆិកា ១៩៤៦ (អានលេខយោង ១៣) ពួកមេឥស្សរៈត្រូវត្រឡប់ទៅនៅបាងកកវិញ ដែលនៅទីនោះពួកអ្នកជាតិនិយមឯទៀតៗ ចេះតែមកបន្តបន្ទាប់គ្នា។ ខែកញ្ញា ១៩៤៧ ពួកនៅបាងកកប្រកាសការកើតឡើងនៃ "រដ្ឋាភិបាល នៃ កម្ពុជាសេរី" ដែលបានត្រូវទទួលស្គាល់ដោយរដ្ឋាភិបាលថៃរបស់ ព្រិឌី ភ្នំយង់។ ប៉ុន្តែ ដល់ភិបុលសង្គ្រាម ត្រឡប់មកកាន់អំណាចវិញ ខ្មែរឥស្សរៈបានត្រូវគេហាមឃាត់ មិនឲ្យធ្វើសកម្មភាពលើទឹកដីសៀម។

ត្រឡប់មកប្រទេសកម្ពុជាវិញ អ្នកដឹកនាំឥស្សរៈប្រមាណ ១២ នាក់ បង្កើតគណៈកម្មាធិការខ្មែររំដោះជាតិមួយ ក្រោមអធិបតីភាពរបស់ ដាប ឈួន។ គណៈកម្មាការនេះឥតបានមានប្រសិទ្ធភាព ព្រោះមេៗ រកត្រូវគ្នាពុំកើត ហើយម្នាក់ៗ ធ្វើតាមការយល់ឃើញរៀងខ្លួន ក្នុងទឹកដីម្តុំៗ ដែលខ្លួនក្រញាំបាន គឺជាឥតមានដើរតាមខ្សែនយោបាយរួមអ្វីមួយឡើយ។ មេភាគច្រើន ធ្វើចោរកម្មប្លន់រាស្ត្រតែម្តង។ អ្នកផងអាចនៅចាំអំពីក្រុមឥស្សរៈដ៏សាហាវ ដឹកនាំដោយឈ្មោះ សៀប, តក់, យី ។ល។ ក្រុមចោរនេះប្រព្រឹត្តយ៉ាងសកម្មតាមព្រំដែនខ្មែរ-ថៃ ជាហេតុធ្វើឲ្យអោក់អួលខ្លាំង ដល់ការរត់ពន្ធអាវុធដែលវៀតមិញទិញពីស្រុកសៀម យកទៅឲ្យកងឯកភាពនៅយួនខាងត្បូង។ តាមរយៈ "កងទ័ពប្រជាជនខ្មែររំដោះ" (APKL) របស់ខ្លួន វៀតមិញខំបញ្ចុះបញ្ចូលពួកមេឥស្សរៈ។ ក្នុងពួកនេះ ខ្លះក៏ព្រមដើរជាមួយ ខ្លះទៀតមិនព្រមហើយក៏វាយវៀតមិញដែរ។ ឆ្លើយតបនឹងការហៅឲ្យចុះចូលនៃរាជរដ្ឋាភិបាល អ្នកដែលមកមុនគេ គឺ ដាប ឈួន (ក្រោយមក ឧត្តមសេនីយ ឈួន ម្ជុលពេជ្រ, ក្បត់ហើយបានត្រូវគេសំឡាប់នៅឆ្នាំ ១៩៥៩) ក្នុងខែកញ្ញា ១៩៤៩, រួចហើយ ជាបន្តបន្ទាប់ មាន : ពុត-ឆាយ និង អ៊ុំចនិល

*ពេជ្រ នៅខែឧសភា ១៩៥៣, នរោត្តម ចន្ទរង្សី និង សាវ៉ាងវង្ស នៅខែកុម្ភៈ ១៩៥៤ (ក្រោយបានឯករាជ្យ)។ ក្នុងខែកុម្ភៈ ១៩៥៤ ដដែល អៀ ស៊ីចូវ មកដល់ភ្នំពេញដើម្បីចចារការចុះចូលនៃ សឺង ង៉ុកថាន់។ មិនដឹងជាមកពីហេតុអ្វីដែរ ការចចារនេះឥតបានចេញជាអ្វី ហើយ សឺង ង៉ុកថាន់ ក៏មិនព្រមចូលនឹងស្តេច។*

(៨) *មានខ្មែរកម្ពុជាក្រោមយើងជាច្រើន ដែលបានកាន់កាប់មុខងារធំៗ ក្នុងរដ្ឋការវៀតណាមខាងត្បូង (ជាពិសេសក្រោយង៉ោឌិនយៀម) ទាំងស៊ីវិលទាំងទាហាន។ លោក សឺង ថៃ ង្វៀង ដែលគេស្គាល់ណាស់នៅកម្ពុជាក្រោម   នៅក្នុងចំណោមខ្មែរកម្ពុជាក្រោមដែលបានធ្វើជាសមាជិកព្រឹទ្ធសភាវៀតណាមខាងត្បូង។*

(៩) *តាមកិច្ចព្រមព្រៀងនៅហ្សឺណែវឆ្នាំ ១៩៥៤ កងទាហានបរទេសទាំងអស់ ទាំងវៀតមិញ ទាំងបារាំងត្រូវចេញពីប្រទេសកម្ពុជា។ តាមសំណុំនៃរាជរដ្ឋាភិបាល មហាអំណាចធំៗ ព្រមឲ្យប្រទេសកម្ពុជាទទួលសម្ភារៈសឹក និងបុគ្គលិកទាហានបរទេស (ចំនួនមានកំរិត) ដើម្បីការពារទឹកដីខ្លួន។ ដូអេនឡាយ ដែលខ្លាចក្រែងប្រទេសខ្មែរនិងប្រទេសលាវធ្លាក់ក្រោមឥទ្ធិពលអាមេរិកាំង បានយល់ព្រមឥតជំទាស់ពេលដែលគាត់ដឹងថា រដ្ឋាភិបាលខ្មែរងាកទៅរកបារាំងម្តងទៀត ដើម្បីកសាងកងទ័ពខ្លួន។ គណៈបេសកកម្មយោធាបារាំងនៅតែបន្តសកម្មភាពទៅទៀត រហូតដល់ខែមីនា ១៩៧០។*

(១០) *ព្រះចៅមកដល់ស្រុកបារាំង នៅថ្ងៃ ១២ ឧសភា ១៩៤៦ ចំពេលដែលគេកំពុងធ្វើការឃោសនាបោះឆ្នោត។ ស្តេចបានទៅជួបនឹង ហ្វេលិច ហ្គូវ៉ាំង ដែលជំនួស ដឺហ្គោល ដែលបានលាឈប់។ ថ្ងៃ ២៦ មិថុនា ដោយឥតមានភ្ញៀវភ្ញាត់ក្តុងក្តាំងដូចកាលមកដល់ដែរ ព្រះចៅចេញពីស្រុកបារាំងមកស្រុកខ្មែរ។ ក្នុងចន្លោះពេលនោះ ហ្សក ប៊ីដូ បានជាប់ឆ្នោតជានាយករដ្ឋាភិបាលបណ្តោះអាសន្ន។*

(១១) *តាម មិលតុន អុសស្ប៊ន គណបក្សជឿនលឿន របស់ម្ចាស់ ម៉ុងតាណា បានត្រូវតម្លើងដោយពួកគហបតីខ្មែរ-ចិន នៅភ្នំពេញ។*

(១២) *អ្នកបោះឆ្នោតជំនាន់នោះ សុទ្ធតែភេទប្រុសទាំងអស់ ព្រោះនារី ដែលកាលនោះ គេដាក់ទុកក្នុងថ្នាក់ទី២ នៃផែនសង្គម ឥតទាន់មានសិទ្ធិបោះឆ្នោតនៅឡើយ។ ម្យ៉ាងទៀត ការបោះឆ្នោតសម័យនោះ ឥតមានចូលទៅដល់ពិភពកសិករទេ ឈ្នះចាញ់គឺនៅលើទីក្រុងនិងទីប្រជុំជនទាំងអស់។ ប៉ុន្តែក្នុងកាលៈទេសៈសព្វថ្ងៃនេះ បន្ទាប់ពីបានឃើញការពុករលួយនៃគ្រួសារខ្មែរជាច្រើន -ការពុករលួយដែលបាននាំខ្មែរក្រហមមកកាន់អំណាច, សំនួរមួយត្រូវតែចោទឡើង : ទោះបីខ្លួនគួរមានសិទ្ធិបោះឆ្នោតក៏ដោយ តើនារីខ្មែរចង់នៅត្រឹមតែភរិយា ឬចង់ទៅជាពលរដ្ឋដែរ?*

(១៣) *ក្រោមការទាមទាររបស់បារាំង ដើម្បីយកពីសៀមវិញនូវទឹកដីខ្មែរនិងលាវ ដែលសន្ធិសញ្ញាក្រុងតូក្យូឆ្នាំ ១៩៤១ បានឲ្យទៅសៀម រដ្ឋាភិបាលថៃរបស់ សេនីប្រាមោជ្ជ យល់ព្រមជជែកជាមួយតំណាងរដ្ឋាភិបាលបណ្តោះអាសន្នបារាំង នៅព្រៃនគរក្នុងថ្ងៃ ៩ មេសា ១៩៤៦។ ដោយការជជែកនេះឥតចេញជាអ្វីឲ្យជាក់លាក់ ឧប្បត្តិហេតុតាមព្រំដែនក៏កើតមានឡើង ចាប់ពីខែឧសភា។ ថ្ងៃ ២៤ សីហា, ៤ ថ្ងៃមុនពេលដែលអង្គការសហប្រជាជាតិ ត្រូវពិភាក្សាលើបេក្ខភាពនៃប្រទេសថៃ, បារាំងប្រាប់ទៅរដ្ឋាភិបាលអាមេរិកាំងថា ខ្លួននឹងមិនយកការទាមទារទឹកដីនេះ ទៅដាក់មុខតុលាការអន្តរជាតិនៅ ឡាអេយ ទេ (ដូចដែលថៃបានស្នើ) ប៉ុន្តែខ្លួននឹងបន្តសង្គ្រាមជាមួយប្រទេសថៃ ហើយនឹងប្រើសិទ្ធិមិនព្រមដាច់អហង្កា* (veto) *របស់ខ្លួន ទល់នឹងការចូលនៃប្រទេសថៃក្នុង អ.ស.ប.។ ជាមួយនឹងការសំរុះសំរួលរបស់រដ្ឋាភិបាលអាមេរិកាំង ការជជែកគ្នាបារាំង-ថៃ ក៏ចាប់ធ្វើឡើងវិញ ក្នុងខែកញ្ញា ម្តងនេះនៅ*

*ក៉ាស៊ីនតោនៗ កិច្ចចចារបានត្រូវនាំដោយម្ចាស់ ក៉ានវ៉ៃថ្យាកន ខាងសៀម និងដោយលោក ហ្ស៊ែកពីកូ (រដ្ឋទូតនៅ វ៉េណេហ្ស៊ូអេឡា) ខាងបារាំងៗ ថ្ងៃ ១៧ វិច្ឆិកា ១៩៤៦ កិច្ចសន្យាបារាំង-ថៃ មួយក៏បានត្រូវធ្វើឡើង ដោយលប់សន្ធិសញ្ញាក្រុងតូក្យូឆ្នាំ ១៩៤១ៗ ៣ អាទិត្យក្រោយមក កងទាហានបារាំងក៏ចូលកាន់កាប់ បាត់ដំបងវិញៗ*

(១៤) *រដ្ឋធម្មនុញ្ញដែលបារាំងប្រើរហូតដល់ពេលចប់សង្គ្រាម បានត្រូវធ្វើឡើងតាំងពីឆ្នាំ ១៨៧៥ (សាធារណរដ្ឋទី៣)ៗ ក្នុងខែតុលា ១៩៤៥ ក្រោមការស្នើយោបល់នៃឧត្តមសេនីយ ដឺហ្គោល ប្រជាជនបារាំងបានបោះឆ្នោតព្រមផ្លាស់រដ្ឋធម្មនុញ្ញ ហើយរើសក្នុងពេលជាមួយគ្នានូវសភារៀបរៀងរដ្ឋធម្មនុញ្ញមួយ ដែលឲ្យអំណាចទាំងអស់ទៅរដ្ឋសភា (មានការរើសប្រធានាធិបតីជាដើម)ៗ ដាក់ទៅឲ្យប្រជាជនសំរេចតាមប្រជាមតិ នៅខែឧសភា ១៩៤៦ គំរោងនេះបានត្រូវបារាំងទាត់ចោលក្នុងភាគ ៥៣% ទល់នឹង ៤៧% ៗ គំរោងរដ្ឋធម្មនុញ្ញនេះ បានត្រូវខ្មែរយកមកធ្វើជាគំរូៗ អ្នកសិក្សានយោបាយខ្លះ បានល្បោកពិនិត្យរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ ១៩៤៧ៗ លោក ឡាកសេ ចុះក្នុងនិក្ខេបបទគាត់ថា "រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានត្រូវធ្វើឡើងដោយយុវជនខ្មែរមួយក្រុម ដែលមិនបានដឹងច្បាស់នូវការត្រូវការពិតប្រាកដនៃប្រទេសៗ ពេលខ្លះ អ្នកទាំងនោះច្រើនតែប្រឡូកយកផលប្រយោជន៍នៃវណ្ណៈខ្លួន, វណ្ណៈថ្មីមួយនៃអ្នកដែលមានកំព្វជាងគេ, ជាប្រយោជន៍របស់ប្រជាជនៗ ហើយក្រុមនេះ គឺផ្នែកដឹកនាំនៃគណបក្សប្រជាធិបតេយ្យ"ៗ* (M. Larché) *ៗ*

*លោក កួង តុន ក្នុង "និក្ខេបបទលើការវិបត្តិខ្មែរ" សរសេរថា ៖ រដ្ឋធម្មនុញ្ញនៃឆ្នាំ ១៩៤៧ ជាស្នាដៃនៃវណ្ណៈអ្នកមានមធ្យមនៃប្រជាជាតិ* (Bourgeoisie nationale) *ដែលដោយចង់ឡើងកាន់អំណាច, បានឆ្លៀតឱកាសល្អក្រោយពេលចប់សង្គ្រាមលោកលើកទី២ ដើម្បីសរសេរសេចក្តីចែងច្បាប់មួយដែលបំរើប្រយោជន៍ខ្លួនៗ ដូច្នេះ របបរាជាធិបតេយ្យថ្មីដែលមានរដ្ឋសភានេះ គ្រាន់តែទទួលស្គាល់ជាផ្លូវការ និងការពារការមានប្រៀបនិងអភ័យឯកសិទ្ធិដែលយកបានដោយវណ្ណៈមានកំព្វទាំងឡាយ ៗ ... រដ្ឋធម្មនុញ្ញខ្មែរថ្មី ថ្វីតែយកគំនិតតាមគំរូប្រជាធិបតេយ្យមួយ, បានយកចិត្តទុកដាក់មិនឲ្យដោយច្បាស់នូវអធិបតីភាពទៅប្រជាជាតិ, ដូចដែលបានធ្វើរដ្ឋធម្មនុញ្ញភាគច្រើន ដែលប្រកបដោយប្រជាធិបតេយ្យនិងសេរីភាព នៃប្រទេសអាស៊ីភាគអគ្នេយ៍, ឧទាហរណ៍ មាត្រា ៣ នៃរដ្ឋធម្មនុញ្ញថៃនៃឆ្នាំ ១៩៤៩ ៖ "អំណាចជាអធិបតីចេញមកពីប្រជាជនសៀមៗ ព្រះរាជា ក្នុងឋានៈជាប្រមុខរដ្ឋ ប្រើអំណាចនេះតាមសេចក្តីចាត់ចែងនៃរដ្ឋធម្មនុញ្ញៗ" ដូចគ្នាដែរ រដ្ឋធម្មនុញ្ញលាវនៃឆ្នាំ ១៩៤៧ មាត្រា ៣ ៖ អធិបតីភាពជាតិចេញមកទាំងមូលពីប្រជាជនលាវៗ*

(១៥) *ក្រោយមក លោក ញឹក ជូឡុង ឲ្យគណបក្សខេមរៈបុណ្ណការ ទៅលោក លន់ នល់ កាន់កាប់ៗ បានបុណ្យបានស័ក្តិក្រោមម្លប់លោក ជូឡុង, លោក លន់ នល់ ចូលមកយ៉ាងរមទម្យ ក្នុងឆាកនយោបាយខ្មែរ ដោយដឹកនាំគណបក្សនេះ ដែលសមាជិកច្រើនតែខ្មែរកម្ពុជាក្រោមៗ នាំទៅគាល់ព្រះចៅដោយអ្នកគាំពាររបស់ខ្លួន —លោក ជូឡុង— មន្ត្រីខាងនគរបាល លន់ នល់ បានត្រូវគេចាប់បោះទៅលើជាវរៈសេនីយទោ ហើយតែងតាំងជាអ្នកទទួលខុសត្រូវក្នុងខេត្តបាត់ដំបង លើការតយុទ្ធទល់នឹងពួកឥស្សរៈរបស់ សឺង ង៉ុកថាន់ ក្នុងខែធ្នូ ១៩៥២ៗ មួយខែក្រោយពីបានឯករាជ្យ ព្រះបាទ សីហនុ ធ្វើប្រតិបត្តិការ "សាមគ្គី" ក្នុងខេត្តបាត់ដំបង, នៅខែធ្នូ ១៩៥៣, ដើម្បីរកវាយវៀតមិញៗ គឺនៅក្នុងប្រតិបត្តិការ "សាមគ្គី" នេះហើយ, ដែលសាមគ្គីភាព លន់ នល់ — សីហនុ បានកើតឡើងៗ សាមគ្គីភាព ដែល ១៧ ឆ្នាំក្រោយមកបានរលាយ, ហើយក្លាយទៅជាមហាគោលាហលចំពោះប្រជាជាតិខ្មែរៗ*

*លោក លន់ នល់, ខ្មែរកម្ពុជាក្រោមកើតនៅរាកដារ៉ា (តាយនិញ), បានទទួលផ្កាយទី១ របស់គាត់នៅឆ្នាំ ១៩៥៥, ឆ្នាំដែលគាត់បានត្រូវតែងតាំងជានាយអគ្គសេនាធិការ នៃកងខេមរៈភូមិន្ទ។*

(១៦) *គ្រាប់បែកដែលធ្លាក់លើកំពង់ផែ ហាយផុង នៅថ្ងៃ ២៤ វិច្ឆិកា ១៩៤៦ បានកំទេចកិច្ចសន្យា សាំងតឺនី ហូជីមិញ។ ថ្ងៃ ១៩ ធ្នូ, ការបះបោរនៅហាណូយឲ្យសញ្ញានៃការចាប់ផ្ដើមសង្គ្រាមលើកទី១ នៃឥណ្ឌូចិន។ ខែមីនា ១៩៤៧ ដាហ្សង់លៀ បានត្រូវជំនួសដោយ បុលឡាអែរ។ ដើម្បីរកមធ្យោបាយបញ្ចប់សង្គ្រាម, បុលឡាអែ លេងសន្លឹកបៀបាវដាយ, ដែលនៅឯហុងកុង ក្រោមឈ្មោះជាម្ចាស់ វិញ ធុយ។ បាវដាយ វាយតម្លៃក្លាម ៖ ភ្ជាប់កូសាំងស៊ីនមកវៀតណាម។ រដ្ឋសភាបារាំងបោះឆ្នោតភ្ជាប់ កូសាំងស៊ីន ទៅវៀតណាម នៅថ្ងៃ ២១ ឧសភា ១៩៤៩។*

(១៧) *និយាយឲ្យពិត, ដោយខ្វល់នឹងចំណោទក្នុងស្រុកខ្លាំងពេក បញ្ហាលក្ខន្តិកៈនៃកូសាំងស៊ីន មិនសូវបានទទួលការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលប៉ុន្មានទេ។ នៅថ្ងៃទី ១១ មីនា ១៩៤៨ សភានៃសហភាពបារាំងពិនិត្យគំរោងការបង្កើតក្រុមជំនុំមួយនៅកូសាំងស៊ីន ដែលមានភារៈបោះឆ្នោត "យល់ព្រមឬប្រឆាំង" និងការភ្ជាប់កូសាំងស៊ីនមកវៀតណាម។ គំរោងការនេះលើលាទាំងស្រុង ឬមើលងាយខ្មែរពន់ពេក ព្រោះក្នុងសមាជិក ៦៤ នាក់ ដែលគេបំរុងឲ្យមានក្នុងក្រុមជំនុំនោះ, ៤៨ នាក់ ជាជនជាតិយួន ១៦ នាក់ ជាជនជាតិបារាំង។ ក្នុងកិច្ចពិភាក្សាលើគំរោងការលើលានេះ, គណៈប្រតិភូខ្មែរដែលដឹកនាំដោយម្ចាស់ក្សត្រី ពីង ពាងយុគន្ធរ ឥតបានសូវមាត់កទេ, ហើយដល់ពេលបោះឆ្នោត គណៈប្រតិភូបានបោះ ... អនុប្បវាទ។*

(១៨) *បន្ទាប់ពីអង់គ្លេស និងសហរដ្ឋអាមេរិក, ប្រទេសកាណាដា ទទួលស្គាល់ប្រទេសកម្ពុជារដ្ឋឯករាជ្យ នៅថ្ងៃទី ៣០ ធ្នូ ១៩៥៣។*

(១៩) *ក្នុង "សាវតានៃអាស៊ីអាគ្នេយ៍", ហ្វីលីព ដឺ វីល្លេ បញ្ជាក់ថ្ងៃ ១៨ កញ្ញា ១៩៤៩ តែមិនឲ្យដើមហេតុនៃការរំលាយរដ្ឋសភានេះទេ។ បើតាម រ៉ូហ្ស៊ែស្មិថ "ក្នុងនយោបាយក្រៅប្រទេសកម្ពុជា", ការរំលាយនេះបានត្រូវធ្វើឡើងក្រោយសន្និសញ្ញានៃខែវិច្ឆិកា ១៩៤៩។*

(២០) *តាំងពីខែមករា ១៩៤៧, តំណាងខ្មែរឥស្សរៈជាមួយគ្នានឹងតំណាងលាវសេរី និងតំណាងវៀតណាមសេរី, បានបង្កើតគណៈកម្មការចំរុះអចិន្ត្រៃយ៍មួយ ដើម្បីធ្វើឲ្យមានឡើងនូវសហប្រតិបត្តិការពិតប្រាកដ ហើយមានប្រសិទ្ធភាពលើផ្នែកនយោបាយ, សេដ្ឋកិច្ច, យោធា និងទូតក្នុងការតយុទ្ធរួមទល់នឹងចក្រពត្តិនិយមបារាំង។ គណៈកម្មការនេះបានផ្ញើសេចក្ដីអំពាវនាវមួយទៅរដ្ឋាភិបាល ស.រ.អា. (សារព័តមានឡឺម៉ុងដ៍, ថ្ងៃទី ៧/១/៤៧)។*

(២១) *ពិតពេកទៅហើយ, "សឺង ង៉ុកមិញ" ជាឈ្មោះបង្កើតដោយពួកវៀតមិញ។ គ្រាន់តែពួកគេសង្ស័យក្លាមថាក្រែងបងប្អូន សឺង ង៉ុកថាន់។ បារាំងឥតបានចាំយូរឡើយ ដើម្បីចោទ សឺង ង៉ុកថាន់ ថាចូលជាមួយវៀតមិញ ពេលដែលគាត់ចូលព្រៃនៅខែមិនា ១៩៥២។*

(២២) *នៅក្នុងក្រុងទាំងឡាយ, វៀតមិញក៏មានសកម្មភាពខ្លាំងដែរ។ ក្នុងពពួកយួនអន្តោប្រវេសន៍, វៀតមិញរើសមនុស្សធ្វើក្រុមភ្នាក់ងារសម្ងាត់ក្នុងកិច្ចផ្ដល់ស្បៀង អង្គាសលុយ, ទិញថ្នាំ, ទិញអាវុធ ។ល។ ដល់ឈ្មោះថា "វៀតមិញ" បានបាត់ជាមួយការដើរចេញទៅរបស់បារាំង, ឈ្មោះថា "វៀតកុង" ក៏កើតមានឡើងជាមួយការចូលមកនៃអាមេរិកាំង។ ប៉ុន្តែគឺក្រុមភ្នាក់ងារសម្ងាត់ដដែលហ្នឹង, ដែលគេដាស់ឲ្យធ្វើសកម្មភាពឡើងវិញក្នុងសង្គ្រាមទី២ នៃឥណ្ឌូចិន។*

(២៣) *នៅឆ្នាំ១៩៥០, ក្រោមការរៀបចំរបស់បារាំង, ប្រទេសឥណ្ឌូចិនទាំងបីជំនុំគ្នានៅក្រុងប៉ូដើម្បីធ្វើលក្ខន្តិកៈនៃ "សហគតរដ្ឋ"។ ប្រទេសសមាជិកទាំងនេះព្រមព្រៀងធ្វើឲ្យមានតែមួយនូវក្រដាសប្រាក់, កិច្ចការធនាគារនិងគយ ដោយមានការចែកគ្នានូវចំណូលពន្ធគយ កំពង់ផែព្រៃនគរបានទៅជាផែស្វយ័ត។ អ្នកផងអាចចាំបានអំពីក្រដាសប្រាក់ ១០០ ដែលមានរូបនារីខ្មែរ លាវ និងយួន, ហើយដែលចាយបាននៅវៀងចន្ទន៍ ឬព្រៃនគរដូចជានៅភ្នំពេញដែរ។ ក្នុងការចែកគ្នានូវចំណូលពន្ធគយ, អ្នកកាន់សេដ្ឋកិច្ចខ្មែរ ពេលនោះបានបណ្ដោយឲ្យយួនមានព្រៀបជាង, ដោយប្រទេសកម្ពុជាយកតែ ២៣% ក្នុងពេលដែលខ្លួនជាអ្នកផ្ដល់វត្ថុធាតុដើមទាំងអស់ —ជាពិសេសខាងកសិកម្ម— ទៅឲ្យស្រុកយួនដែលបញ្ចេញតាមឧស្សាហ៍កម្មទៅជាផលិតផលសម្រាប់លក់តទៅទៀត។ ខែឧសភា ១៩៥៣, រដ្ឋាភិបាលបារាំងស្រាប់តែតែបញ្ចុះតែម្នាក់ឯងនូវតម្លៃប្រាក់ "ប៉ាស" នោះ, ការបញ្ចុះតម្លៃដែលធ្វើឲ្យប្រទេសទាំងបីមិនសប្បាយចិត្តជាខ្លាំង។ ថ្ងៃ ២៥ កុម្ភៈ ១៩៥៤, បីខែក្រោយឯករាជ្យ, បារាំងទទួលស្គាល់គោលគំនិតនៃអធិបតីភាពខ្មែរខាងរឿងសេដ្ឋកិច្ច, ក្រដាសប្រាក់, គយនិងហិរញ្ញវត្ថុ។ ដើម្បីជំរុញសេដ្ឋកិច្ចខ្លួនដែលកំពុងមានការពិបាក, ប្រទេសកម្ពុជា ទារយកចំណែកខ្លួនខាងចំណូលពន្ធគយដែលឡើងដល់ ៨០០ លាន ប៉ាស។ ដូចគេអាចរង់ចាំ, យួនផ្ទុយការងារនេះដោយពុតធ្វើជាឈ្លោះជាមួយខ្មែរ។ បន្ទាប់មក ដៀន បៀនភូ, ហ្សឺណែវ, សង្គ្រាមឥណ្ឌូចិនទី២ ធ្វើឲ្យការទារ "ជាច្រើនលើកច្រើនដង" របស់ខ្មែរឥតបានផលអ្វីទាំងអស់។ បារាំង, ឆ្លៀតឱកាសពីជម្លោះខ្មែរ—យួននេះ, បានយកប្រាក់ទាំងលាននេះប្រើប្រាស់ទៅ។ ប្រាក់ដែលជារបស់រដ្ឋខ្មែរនេះ នៅក្នុងធនាគាបារាំងរហូតសព្វថ្ងៃ។*

(២៤) *ពិតហើយ, ក្នុងប្រទេសមួយដែលចាប់តាំងពីកើតឡើង បានស្គាល់តែរបបនៃស្ដេចជាម្ចាស់ជីវិត, ការយល់ឃើញអំពីគណបក្សនយោបាយ ពិបាកជ្រួតជ្រាបឲ្យច្បាស់ទៅក្នុងស្រទាប់រាស្ត្រប្រជាដែរ។ ប៉ុន្តែជោគជ័យនៃគណបក្សប្រជាធិបតេយ្យ ពិតជាជោគជ័យនយោបាយមួយហើយ ព្រោះគណបក្សនេះតាងលំនាំភាគច្រើននៃប្រទេស ៖ លំនាំឯករាជ្យនិយម។ ការវិនិច្ឆ័យរបស់បរទេសម្នាក់លើគណបក្សប្រជាធិតេយ្យ, គួរយើងយកមកពិនិត្យដែរ ៖ "រដ្ឋសភាមិនសម្រេចការ លើនយោបាយខ្មែរ ជាងគណៈកម្មការនាយកនៃគណបក្សប្រជាធិបតេយ្យទេ។ គណៈកម្មការនេះជាអង្គការអាថ៌កំបាំងមួយ, ឥតទទួលខុសត្រូវចំពោះមុខអ្នកណាឡើយ, ប៉ុន្តែត្រួតត្រាលើការសម្រេចនៃរដ្ឋមន្ត្រីទាំងអស់និងលើសកម្មភាពនៃអ្នករាជការធំៗ។ ពួកប្រជាធិបតេយ្យដឹកនាំរដ្ឋដោយរបៀបកាន់បក្សពួក, បញ្ចុះបញ្ចូលរកដៃជើងរបស់ខ្លួនក្នុងពួកអ្នករាជការ, ធ្វើឲ្យកិច្ចការរាជការច្របូកច្របល់បាត់សណ្ដាប់ធ្នាប់, បង្កើតឡើងដោយហេតុនេះ នូវការមិនសប្បាយចិត្តជាច្រើន, ហើយជាញឹកញយ, មិនទាំងចុះសំរុងរវាងគ្នាឯងផង។ ... មែនទែនទៅ, ដោយហេតុថាលក្ខណៈខ្លួននិងគោលដៅខ្លួន នៅតែឥតទំនាក់ទំនងអ្វីជាមួយមហាជនដែលជាប្រជាកសិករ, គណបក្សទាំងឡាយខិតខំតែធ្វើខ្លួនឲ្យទៅជា "សមាគមនៃអ្នកមានភ័ព្វ" ដែលខ្វល់ខ្វាយតែរកមុខរបរនិងរកកៅអីឲ្យសមាជិកខ្លួន។ ពួកប្រជាធិបតេយ្យបានធ្វើរដ្ឋធម្មនុញ្ញ, ប៉ុន្តែក្នុងការស្រេកឃ្លានអំណាចរបស់ខ្លួន ហើយដោយស្មានថានឹងអាចរក្សាទុកបានយូរនូវការដឹកនាំកិច្ចការទាំងឡាយ, ពួកនេះបានភ្លេចថានៅក្នុងសតិរបស់រាស្ត្រ ស្ដេចនៅតែមានន័យថា "ជាតិ", ស្ដេចជាទីពឹងពំនាក់ ជាអ្នកការពាររាស្ត្រធំបំផុត។ គេភ្លេចថាពេលណាមានវិបត្តិ, មហាជននិងសេចក្ដីសង្ឃឹមរបស់ខ្លួននឹងងាកទៅរកស្ដេចទេ, មិនមែនងាកទៅរកគណបក្សឡើយ។ ដោយខ្លួនប្រឆាំងនឹងស្ដេច, គណបក្សប្រជាធិបតេយ្យប្រហែលជាបានឲ្យព្រហ្មលិខិត កាត់វាសនាខ្លួនហើយ។" (ហ្វីលីព ដឺ វីល្ល៍)។*

(២៥) លោក សឺង ង៉ុកថាន់ បានត្រូវតាមដោយបញ្ញាវន្តមួយចំនួនធំ ដែលនៅក្នុងនោះមានលេខាធិការផ្ទាល់របស់គាត់, លោក ហង្ស ធុនហាក់ អនាគតរដ្ឋមន្ត្រីទីមួយនៃសាធារណរដ្ឋខ្មែរ។ ក្រោយឆ្នាំ ១៩៥៤, អ្នកទាំងនោះបានចុះចូលមកស្តេចជាច្រើនគ្នាដែរ, ហើយបានត្រូវនគរបាលសម្ងាត់កត់សំគាល់ក្រោមឈ្មោះថា "ពួកដងវែក"។ ក្រោយមក, ដល់ពេលកើតរឿង "ខ្មែរសេរី", ពួកចាស់ៗ នៃក្រុមដងវែក លើកលែងតែលោក ហង្ស ធុនហាក់ បានត្រូវគេចាប់ឃុំឃាំងទាំងអស់, ហើយអ្នកដែលគេយល់ថាខ្លាំង បានត្រូវគេសំលាប់ចោល។

(២៦) ថ្ងៃ ១ តុលា ១៩៤៩ នៅប៉េកាំង, ម៉ៅ សេទុង ប្រកាសកំណើតនៃសាធារណរដ្ឋចិនប្រជាមានិត។ សហរដ្ឋអាមេរិកដែលរហូតមកដល់ពេលនោះ ពុំត្រេកអរនឹងអាណានិគមនិយមបារាំងទេ, ស្រាប់តែបែរក្រោយភ្លាមបន្ទាប់ពីការ "ខាតបង់" ប្រទេសចិននេះ។ ជាមួយនឹងការកើតឡើងនៅដើមឆ្នាំ ១៩៥០, នៃគំនិតប្រឆាំងយ៉ាងហួសហេតុនឹងកុម្មុយនិស្ត ដែលផ្សព្វផ្សាយដោយម៉ាក់កាធី, នៃទ្រឹស្តី "ល្បែងដូមីណូ", និងនៃសង្គ្រាមនៅកូរ៉េ, ស.រ.អា. នឹងតំរង់ការប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅទ្វីបអាស៊ី ដើម្បីទប់ទល់ការពង្រីកខ្លួននៃលទ្ធិរួមសំបាច់ដែលចេញពីប្លុក ចិន-រុស្ស៊ី។ ពីឆ្នាំ ១៩៥០ ទៅឆ្នាំ ១៩៥៤, អាមេរិកាំងជាអ្នកផ្តល់អាវុធដល់បេសកៈយោធពលបារាំងនៅឥណ្ឌូចិន ៨០% នៃចំណាយក្នុងសង្គ្រាមឥណ្ឌូចិនទីមួយ ជាបន្ទុករបស់ ស.រ. អា. ។ ក្នុងចន្លោះឆ្នាំ ១៩៥១ និង ១៩៥៤, អាមេរិកាំងបានឲ្យ ២៥ លានដុល្លារទៅបារាំង ដើម្បីជួយកម្ពុជា។ ចាប់តាំងពីឆ្នាំ ១៩៥០ គណៈបេសកកម្មអាមេរិកាំងជាច្រើនបានចូលមកបន្តបន្ទាប់គ្នាក្នុងស្រុកខ្មែរ។ លើកនេះ, លោក សឺង ង៉ុកថាន់ បែរទៅរកអាមេរិកាំង, ហើយប្រហែលគាត់លេងសន្ទឹកបៀ "ប្រឆាំងកុម្មុយនិស្ត" បានជាគាត់ទទួលជំនួយពី សេ.អ៊ី.អា. នៅបាងកក។

(២៧) ពួកឃាតករនៃប្រជាជនខ្មែរ, ដែលសព្វថ្ងៃកាន់អំណាចនៅភ្នំពេញ, ជាផលិតផលនៃពួកខ្មែរវៀតមិញ។ តាំងពីវាកើតមក, វៀតមិញជាគ្រោះថ្នាក់មួយចំពោះប្រទេសកម្ពុជា។ តែគួរឲ្យស្តាយ, អ្នកដឹកនាំខ្មែរពីមុនបានយកលេសនេះ ដើម្បីកំចាត់អ្នកដែលបានស្រែកប្រឆាំងនឹងអយុត្តិធម៌។ អ្នកដឹកនាំបានធ្វើឲ្យប្រជាជនបាត់ជំនឿថា វៀតមិញនេះអាចជាគ្រោះថ្នាក់ដល់ជីវិតនៃប្រទេស។

(២៨) ក្នុងវេលានោះ ហ៊ូ យន់ នៅរៀនឯស្រុកបារាំង។ ពេលដែលដឹងថារដ្ឋសភាបានត្រូវរំលាយ, ហ៊ូ យន់ ផ្ញើសំបុត្រមួយទៅស្តេចដើម្បីថា៖ ព្រះអង្គលែងជាស្តេចខ្ញុំហើយ។ (ឥណ្ឌូចិនឃើញពីប៉េកាំង)។

(២៩) ក្រោយថ្ងៃប្រកាសឯករាជ្យ (៩ វិច្ឆិកា, ដែលចំដួចជាថៃជន្មលើថ្ងៃចំរើនអាយុព្រះចៅសីហនុ, តាំងតុ), ព្រះចៅសំរេចបង្កើយគ្នាជាមួយគណបក្សប្រជាធិបតេយ្យ។ ថ្ងៃ ២៥ មករា ១៩៥៥ ស្តេចឲ្យការយល់ព្រមទៅរដ្ឋាភិបាល ឡេង ង៉ែត ដែលកៅអីទាំងឡាយបានត្រូវចែកដល់គណបក្សទាំងអស់ លើកលែងតែគណបក្សប្រជាធិបតេយ្យ។ ថ្ងៃ ៧ កុម្ភៈ, ប្រជាមតិមួយបានត្រូវធ្វើឡើង ដែលនៅក្នុងនោះសំនួរគឺ៖ ព្រះរាជបេសកកម្មបានធ្វើឡើងជាទីពេញចិត្តនៃប្រជារាស្ត្រយើងឬទេ?។ អ្នកបោះឆ្នោត ៩២៥ ៨១២ នាក់បានឆ្លើយ "ពេញចិត្ត" ក្នុងភាគ ៩៩,៨% ។

ថ្ងៃ ១៩ កុម្ភៈ ព្រះចៅប្រាប់ឲ្យដឹងអំពីការកែទំរង់រដ្ឋធម្មនុញ្ញ ដែលឲ្យនាយករដ្ឋមន្ត្រីទទួលខុសត្រូវចំពោះមុខស្តេច, លែងចំពោះមុខរដ្ឋសភាដូចមុន កិច្ចនេះបានត្រូវជំទាស់ឡើងដោយគណៈកម្មការអន្តរជាតិខាងកិច្ចត្រួតត្រា សេ.អ៊ី.សេ., ដែលយល់ថាខុសនឹងរដ្ឋធម្មនុញ្ញ។ ថ្ងៃ ២ មីនា ១៩៥៥ ព្រះចៅដាក់រាជ្យផ្ទេរទៅឪពុក, សម្តេច នរោត្តម សុរាម្រិត។ ខែមេសា, សម្តេច "ឧបយុវរាជ" សីហនុ បង្កើតសង្គមរាស្ត្រនិយមជាមួយ "មិត្តភក្តិ" ខ្លះ ៖ លោក សម សារី, យ៉ែម សំបូរ, ឃីម ទិត ។ល។

*ឆ្លើយនឹងសេចក្តីអំពាវនាវឲ្យចូលមករួបរួមក្នុងសង្គមរាស្ត្រនិយម, គណបក្សទាំងអស់បានរំលាយខ្លួនហើយចូលទៅ, លើកលែងតែគណបក្សប្រជាជន —ជាការណ៍ធម្មតា— ដែលជារបស់ខ្មែរវៀតមិញ, គណបក្សសេរីភាពនិងប្រជាធិបតេយ្យ។ ថ្ងៃ ១១ កញ្ញា ១៩៥៥, ការបោះឆ្នោតបានធ្វើឡើង, ហើយអ្នកឈ្នះធំ គឺ "គណបក្សសង្គមរាស្ត្រនិយម" ដែលយកបានកៅអីទាំង ៩១ ដែលនឹងមានក្នុងរដ្ឋសភា។ ហិបប្រាក់សង្គមរាស្ត្រនិយមបានត្រូវជួយបំពេញដោយ តាន់ ប៉ា និងសេដ្ឋីឯទៀត ដែលបានមិនព្រមទទួលដឹកនាំរដ្ឋាភិបាលនៅខែមិនា១៩៤៥, ប៉ុន្តែដែលនឹងជួយដឹកនាំនយោបាយសេដ្ឋកិច្ចនៃ "សម្តេចឪ" ដោយសារកាយវិការនេះ។*

*គណបក្សសេរីភាពបានត្រូវរំលាយខ្លួននៅខែកក្កដា ១៩៥៦។ ចំណែកគណបក្សប្រជាធិបតេយ្យបានកើតឡើងវិញ ១៥ ឆ្នាំក្រោយមក ក្នុងកាលៈទេសៈមួយផ្សេងទៀត។ ខែមិនា ១៩៧០, ប្រទេសកម្ពុជាបានត្រូវវាយលុកលុយដោយទ័ពយួនខាងជើង។ មិនគិតរួបរួមគ្នាដើម្បីឈមមុខទល់នឹងគ្រោះថ្នាក់, អ្នកនយោបាយខ្មែរបែរជាបង្កើតគណបក្សទៀត ដើម្បីដណ្តើមអំណាចគ្នា។ លទ្ធផលនៃការមើលងាយតំបូន្មានប្រវត្តិសាស្ត្រនេះ, យើងទាំងអស់គ្នាបានឃើញនិងកំពុងតែឃើញនេះហើយ។*

# ភាគទី ៥

# សហព័ន្ធឥណ្ឌូចិន ដើម្បីអ្វី?

*គេពុំអាចស្រឡាញ់ ជាតិ បានទេ បើគេស្អប់ ជន នៃជាតិខ្លួន ។*

*ភាគទី ៥ មានទំរង់ជា សំនួរ-ចំឡើយ។ អត្ថបទដើមបានត្រូវសរសេរចប់ និងផ្សាយនៅដំណាច់ខែ តុលា ១៩៧៧។ ដូច្នេះព្រឹត្តិការណ៍ទាំងឡាយដែលកើតក្រោយមក នឹងយកទៅសិក្សាក្នុង "វិភាគចុងក្រោយ" នៅក្នុងទំព័រភ្ជាប់២ ។ រីឯ ទំនាក់ទំនងខ្មែរចិន ក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ បានត្រូវយកទៅថែងក្នុងទំព័រភ្ជាប់ ១។*

សំនួរ ទំព័រ

ឯក- *សហព័ន្ធឥណ្ឌូចិន ដើម្បីអ្វី?* ........ ៧៣

ទោ- *ហេតុអ្វី ក៏ចាំបាច់ធ្វើឲ្យអស់មនុស្ស? បើប្រទេសទាំង៣ នាំគ្នាដដែកវែកញែករកការដោះស្រាយមួយប្រកបដោយយុត្តិធម៌ទៅ តើធ្វើកើត ឬ ពុំកើត?* ........ ៧៥

ត្រី- *ខ្មែរនិងយួនមិនទុកចិត្តគ្នាទៅវិញទៅមកយ៉ាងខ្លាំង។ ហេតុម្តេចបានជាយួនអាចបញ្ចុះបញ្ចូលបង្វឹកខួរខ្មែរក្រហមបាន?* ........ ៨០

ចត្វា- *បើដូច្នេះ តើមុខការនិងឥទ្ធិពលរបស់ប្រទេសចិនក្នុងមហាវិយោគខ្មែរនៅត្រង់ណា?* ........ ៩០

បញ្ច- *ដំណើរដ៏មានជោគជ័យនៃ ប៉ុល ពត ទៅប៉េកាំង អាចជាសញ្ញានៃការបន្ទន់របបខ្មែរក្រហមឬទេ? គឺថាប្រជាជនខ្មែរអាចនឹងបានស្រាកស្រាន្តខ្លះទេ?* ........ ១០៣

ឆ- *ដូច្នេះ តើប្រជាជនខ្មែរនឹងទៅជាយ៉ាងណាក្នុងអនាគត? តើអន្ទាក់នៅត្រង់ណា, សំណាងនឹងរស់នៅត្រង់ណា?* ........ ១០៤

សប្ត- *រហូតដល់កំរិតណា កម្ពុជាប្រជាធិបតេយ្យអាចសង្ឃឹមលើសាធារណរដ្ឋចិនប្រជាមានិត?* .... ១១១

អដ្ឋ- *ដោយវាយប្រទេសថៃជាច្រើនដង ក្រែងខ្មែរក្រហមចង់យកទឹកដីចាស់វិញទេឬ? ដូច្នេះគេមិនជាអ្នកជាតិនិយមខ្លាំង?* ........ ១១៨

នព្វ- *តើប្រជាជនខ្មែរ លាវ និងវៀតណាម អាចចាំទទួលអ្វីខ្លះបានពីលោក «សេរី», ជាពិសេសពីសហរដ្ឋអាមេរិក?* ........ ១១៨

ទស- *ចំពោះប្រទេសកម្ពុជាយើង, ចំពោះសំណល់នៃប្រជាជនយើងលើដីខ្មែរ, តើយើង ខ្មែរនៅបរទេស អាចធ្វើអ្វីជូន?* ........ ១២០

## សហព័ន្ធឥណ្ឌូចិន ដើម្បីអ្វី?

អាណានិគមកម្មរបស់បារាំងលើឥណ្ឌូចិននៅសតវត្សរ៍ទី ១៩ បានបញ្ឈប់យ៉ាងត្រឹមនូវសន្ទុះរបស់យួន ដែលបានបោះខ្លួនជាប់ ៩ សតវត្សរ៍មកហើយ ក្នុងការខិតខំពង្រីកទឹកដីៗ ដល់បាត់វត្តមាននៃបស្ចិមប្រទេសទៅ, ឥណ្ឌូចិនសព្វថ្ងៃ ត្រឡប់មកក្នុងកាលៈទេសៈភូមិសាស្ត្រនយោបាយនៃសតវត្សរ៍ទី ១៩ វិញ ប្លែកតែមានមហាអំណាចអាស៊ីថ្មីមួយ ដែលលាតសន្ធឹងស្រមោលអាថ៌កំបាំងខ្លួនមកលើៗ មហាអំណាចថ្មីនេះ គឺសាធារណរដ្ឋចិនប្រជាមានិតៗ

នៅសតវត្សរ៍ទី ១០, បន្ទាប់ពីបានរំដោះខ្លួនពីឥទ្ធិពលចិនមក, យួនត្រូវឈមមុខទល់នឹងចំណោទថ្មី១ ៖ ការបែកសាយនៃចំនួនប្រជាពលកររបស់ខ្លួនៗ ដោយនៅកង្វៀនក្នុងដងជន្ទង់ទន្លេក្រហមដែលជាដីរាបមួយតូច, ស្រុកយួនត្រូវការលាតខ្លួនទៅរកទីឯទៀត ដើម្បីរស់ៗ នៅដំណាច់សតវត្សរ៍ទី ១៦ យួនលេបបានស្រុកចំប៉ា, ហើយ ៣០០ ឆ្នាំក្រោយមក ដំណើរចុះមកទិសខាងត្បូងរបស់យួន បានចប់នឹងការយកបានកូសាំងស៊ីន, កម្ពុជាក្រោមរបស់ខ្មែរៗ គឺនៅពេលខ្លួនចាប់ដើរឆ្ពោះទៅទិសខាងលិច ដែលយួនជួបប្រទះថៃ មុខទល់នឹងមុខ, ថៃ ដែលបានត្រូវម៉ុងហ្គោលដេញចេញពីយុនណាន ហើយដែលបានចុះមកខាងត្បូង ចាប់តាំងពីសតវត្សរ៍ទី ១៣, ដោយរុញច្រានខ្មែរ និងលាវ ដែលនៅលើផ្លូវរបស់ខ្លួនៗ ថៃនិងយួន ជៀសវាងការប្រទូស្តរ៉ាយគ្នា ហើយរើសយកមធ្យោបាយត្រជាក់មួយ គឺការចែកគ្នានូវទឹកដីខ្មែរនិងលាវៗ អាណានិគមកម្មរបស់បារាំង មិនត្រឹមតែខាឃាំងការបែងចែកនេះ, ថែមទាំងជប់រដ្ឋទាំងពីរឲ្យរស់ឡើងវិញៗ

ជាប់ជិតមួយសតវត្សរ៍, យួនតយុទ្ធឥតស្រាកស្រាន្ត ដើម្បីរំដោះខ្លួនពីក្រញាំបារាំងៗ ជាមួយគ្នានឹងការតយុទ្ធនេះ គំរោងពង្រីកទឹកដីក៏ត្រូវបានធ្វើដែរៗ ឈ្មោះ "គណបក្សកុម្មុយនិស្តឥណ្ឌូចិន" ដែល ហូជីមិញ ដាក់ឲ្យចលនាបដិវត្តន៍យួននៅឆ្នាំ ១៩៣០ បង្ហាញឲ្យឃើញច្បាស់នូវគោលបំណងរបស់អ្នកដឹកនាំយួននេះៗ សេចក្តីថ្លែងធនុះលើកទី១ របស់វៀតមិញ[១] ដែលបានធ្វើឡើងនៅខែតុលា ១៩៤១ កាន់តែជាក់លាក់ទៅទៀត ៖ "បង្រួបបង្រួមស្រទាប់សង្គមទាំងអស់, អង្គការបដិវត្តន៍ទាំងអស់, អាណិកជនជាតិទាំងអស់ៗ សម្ពន្ធកិច្ចវាងប្រជាជនទាំងអស់ ដែលគេជិះជាន់នៅឥណ្ឌូចិន"ៗ ក្នុងការតយុទ្ធដើម្បីឯករាជ្យនៃប្រទេសខ្លួន ហូជីមិញ មើលឃើញរួចទៅហើយ នូវចំណោទ —ដែលចៀសពុំរួច— នៃការណ៍មានប្រជាជនច្រើនហួសនៅវៀតណាមៗ ហូជីមិញ គិតឃើញថា បើបារាំងអាចបង្រួបបង្រួម កម្ពុជា លាវ និងវៀតណាម ឲ្យទៅជារដ្ឋមួយ ដោយកម្លាំងកាំភ្លើង និងទោះបីមានគំនុំឈឺចាប់នៃប្រជាជនក៏ដោយ, ប្រទេសវៀតណាមរិតតែស្រួលឧបក្រសោបកម្ពុជា និងលាវ ជាមួយមុខការខ្លួនជា "អ្នករំដោះ" និងជា "អ្នកផ្សព្វផ្សាយមនោគមវិជ្ជា"ៗ នៅឆ្នាំ ១៩៤៥, ពេលដែលបារាំង, ក្នុងការខំឈានជើងរបស់ខ្លួនមកឥណ្ឌូចិនវិញ, បានស្នើដល់ប្រទេសទាំង "ប្រាំ" នូវរូបមន្ត សហព័ន្ធឥណ្ឌូចិន, ហូជីមិញ ឥតដែលប្រកែកម្តងណាឡើយៗ ចំបាំងរាំងជល់ លាយនឹងការដឹកជញ្ជូនមនុស្សឲ្យមកនៅលើដីទំនេរ បានហួសសម័យទៅហើយ (?) ៗ ដើម្បីលេបយកកម្ពុជានិងលាវ, វៀតណាមនៅសល់តែមធ្យោបាយមួយទេ, មធ្យោបាយដែលអាចចៀសវាងការផ្តន្ទាទោសរបស់មតិអន្តរជាតិ គឺការឆ្លងកាត់តាមដំណាក់មួយ ដែលជាសហព័ន្ធនៃរដ្ឋទាំងបីៗ រូបភាពគួរឲ្យរន្ធត់នៃការអត់ឃ្លាន, នៃមហន្តរាយសេដ្ឋកិច្ច ដែលមកអំពីការមានប្រជាជនច្រើនហួស តែងតែធ្វើឲ្យអ្នកដឹកនាំប្រទេសវៀតណាមកិតភ័យជានិច្ចៗ ចំពោះ ហូជីមិញ ដូចជាចំពោះបុព្វការីខ្លួន និងចំពោះអ្នកបន្តតំណែងខ្លួន, មានតែការពង្រីកទឹកដីទេ ដែលអាចទាញប្រទេសវៀតណាមចេញ

*ផុតពីគ្រោះថ្នាក់នៃការមានប្រជាជនច្រើនហួសនេះ។ ដូច្នេះមែន, ២ភាគ៣ នៃផ្ទៃប្រទេសវៀតណាម សុទ្ធសឹងតែជាភ្នំថ្មច្រើន (មើលផែនទីទំព័រ ១៤២-១៤៣) ដូច្នេះអត់ដាំអ្វីដុះ (គេច្រើនតែប្រៀបភូមិសាស្ត្រប្រទេសវៀតណាម ទៅនឹងភូមិសាស្ត្រប្រទេស ស៊ីលី ដែលមានដីរាបតែមួយបន្ទះយ៉ាងចង្អៀត បណ្ដោយតាមឆ្នេរសមុទ្រ។ យួនរស់នៅយ៉ាងចង្អៀតចង្អល់លើដីរាបដែលខ្លួនអាចធ្វើស្រែចំការបាន។ នៅឆ្នាំ ១៩៧០ ប្រទេសវៀតណាមមានបណ្ដាជនជិត ៥០ លាននាក់ ដែលរស់នៅលើតែ ១ភាគ៣ នៃផ្ទៃប្រទេសទាំងមូល, គឺថាលើផ្ទៃ ដីមួយដែលតូចជាងកម្ពុជាទៅទៀត! ហើយនៅលើផ្ទៃដីតែ ១ភាគ៣ នេះ មានតែវាល "ត្រីកោណ" ដែលទន្លេមេគង្គនិងទន្លេក្រហមហូរកាត់ចាក់ចូលសមុទ្រទេ ដែលជាផលិតករនៃស្រូវ។ គេប៉ាន់ថានៅឆ្នាំ ២០០០ បណ្ដាជនយួននឹងឡើងដល់ ៧៥ លាន! ជាការពិតណាស់ ដែលធនធានកសិកម្មនៃប្រទេសនឹងខ្វះថ្ងៃណាមួយពុំខាន ចំពោះមាត់យួនទាំងអស់ (ការខ្វះនេះចាប់មានបណ្ដើរទៅហើយ។ នៅឆ្នាំ ១៩៧៦ យួនបានត្រូវការស្រូវ ១,២ លានតោនថែមទៀត)។*

*ចំពោះការត្រូវការពង្រីកទឹកដីនេះ, កម្ពុជាជាទីដៅមួយយ៉ាងប្រណីត។ ព្រោះថាវាលដីដុះ ដែលពុំសូវមានមនុស្សនៅនេះ ពោរពេញទៅដោយសម្បត្តិធម្មជាតិដែលឥតទាន់មានគេប៉ះពាល់។ ផ្ទុយគ្នាស្រឡះពីបណ្ដាជននៅវៀតណាម, ខ្មែរយើងបានស្គាល់ភាពសម្បូណ៌សប្បាយរហូត។ ថ្វីដ្បិតតែរដ្ឋគ្មាននយោបាយត្រឹមត្រូវខាងការប្រើប្រាស់ទឹក, ថ្វីដ្បិតតែយើងធ្វើស្រែតាមរបៀបបុរាណ, ហើយទោះបី ផ្ទៃដីដែលបានត្រូវភ្ជួររាស់គាស់ដាំមានទំហំតិចតួចក៏ដោយ, កម្ពុជាមុនសង្គ្រាម ជាប្រទេសដឹកស្រូវចេញទៅក្រៅ។ ពិតហើយ បើគេមើលប្រទេសនៅឥណ្ឌូចិនមួយម្ដងៗ ដាច់ពីគ្នា, ប្រទេសទាំងនោះពុំសូវមានទេ។ ប៉ុន្តែបើដាក់មកជាមួយគ្នានូវធនធានខាងរ៉ែ, ខាងកសិកម្មនិងខាងទឹក, ប្រទេសទាំងបីរួមគ្នាមានសភាពជា "ប្រទេស" មួយមាន, ហើយច្បាស់ជានៅក្នុងចំណោមប្រទេសដែលសម្បូណ៌ជាងគេនៅអាស៊ីភាគអគ្នេយ៍ (មើលផែនទី)។*

*សន្និសីទនៅហ្សឺណែវ ឆ្នាំ ១៩៥៤ គ្រាន់តែជាឧប្បត្តិហេតុអាក្រក់មួយ ដែលខាយាំងមួយភ្ញាក់ស្មារតី មិនឲ្យសុបិនរបស់ ហូជីមិញ ក្លាយទៅជាការពិត។ អ្នកដឹកនាំយួនសព្វថ្ងៃគ្រាន់តែដើរតាមផ្លូវដែល ហូ បានគូសទុកឲ្យ។ សោកនាដកម្មជាទីរន្ធត់និងជាទីខ្លោចផ្សា នៃប្រជាជនខ្មែរសព្វថ្ងៃនេះ គ្រាន់តែជាលទ្ធផលនៃភាគទី១ នៃគំរោងការរបស់យួនកុម្មុយនិស្ត។ ភាគទី១ នៃគំរោងការនេះ គឺការធ្វើឲ្យអស់មនុស្សពីកម្ពុជា, កិច្ចដែលជាជំហានទី១ ដែលយួនត្រូវបោះ មុននឹងចូលមកក្នុងសហព័ន្ធមួយនៃរដ្ឋនៅឥណ្ឌូចិន។*

*ហេតុអ្វីក៏ចាំបាច់ធ្វើឲ្យអស់មនុស្ស? បើប្រទេសទាំងពីរនាំគ្នាជជែក*
*រកញែករកការដោះស្រាយមួយប្រកបដោយយុត្តិធម៌ទៅ តើធ្វើកើត ឬ ពុំកើត?*

*តបនឹងសំនួរនេះ អ្នកនិពន្ធបារាំង អង់ជ្រេ ម៉ាស់សុង បានឲ្យចម្លើយមួយរួចទៅហើយ ៖ "ឥណ្ឌូចិនជាការផ្តុំគ្នានៃប្រជាជនមួយចំនួន ដែលគេពុំអាចលាយចូលគ្នាបានឡើយ បើមិនប្រើកម្លាំងឃោរឃៅ និងការឲ្យអ្នកឈ្នះលេបយកអ្នកចាញ់"។ ពិតហើយ គេពុំសូវឃើញភាពស្រដៀងគ្នា រវាងអារិយធម៌ខ្មែរនិងអារិយធម៌យួនទេ។ ប៉ុន្តែការខុសគ្នារវាងវប្បធម៌ និងរវាងទស្សនៈលើជីវិតរស់នៅនេះ ពុំអាចពន្យល់ឲ្យអស់តែម្នាក់ឯងទេ ថាហេតុអ្វីបានជាសហគមន៍ទាំង២ លាយចូលគ្នាពុំកើត។ ដូច្នេះមែន, ការខកចិត្តជាប់រាប់សតវត្សរ៍ ដែលមកអំពីការត្រួតត្រារបស់បរទេស បានបង្កើតក្នុងទ្រូងខ្មែរនូវចំណង់យ៉ាងខ្ជាប់មួយ នឹងការពារអត្តភាពជាតិសាសន៍ និងវប្បធម៌របស់ខ្លួន។ សន្ទុះចិត្តការពារនេះ ដែលគេច្រើនតែសំគាល់ដោយខុសថាជាគំនុំ រវាងសាសន៍និងសាសន៍, បញ្ចេញខ្លួនឡើងជាការប្រឆាំងយ៉ាងស្វិតស្វាញ នឹងការប៉ុនប៉ងលាយបញ្ចូល ឬបង្អាត់ពីសំណាក់បរទេសទាំងអស់ ទោះជាយួន ឬមិនមែនយួនក៏ដោយ។*

*ម្យ៉ាងទៀត យើងអាចសង្កេតឃើញថា ការខ្វល់ខ្វាយធំបំផុត ដែលលេចចេញពីនយោបាយក្រៅប្រទេសនៃកម្ពុជា ក្នុងកំឡុង ២៥ ឆ្នាំមុននេះមានតែមួយទេ ៖ ការរួចជីវិតនៃប្រទេស។ ក្នុងរយៈពេលនេះ មនុស្សទាំងមួយជំនាន់ បានត្រូវជ្រួតជ្រាបយ៉ាងជ្រៅនឹងចំណោទនៃជីវិតប្រទេសនេះ, ចំណោទដែលមែនទែនទៅ ជាស្នូលនៃគំនិតជាតិនិយមខ្មែរ។ មិនសំខាន់ទេ របបនយោបាយដែលមនុស្សមួយជំនាន់នេះត្រូវទទួលយក, ប៉ុន្តែមនុស្សទាំងនេះនឹងទាត់ចោលឥតខានឡើយ នូវការធ្វើសហព័ន្ធជាមួយរដ្ឋឯទៀត។ លក្ខខ័ណ្ឌ <u>ខានពុំបាន</u>* (sine qua non) *ដែលត្រូវបំពេញមុននឹងទាញកម្ពុជាចូលក្នុងសហព័ន្ធមួយជាមួយយួន (និងលាវ) គឺការបំបាត់ត្រង់ៗ នូវមនុស្សទាំងមួយជំនាន់នេះ ដែលជាគ្រឿងយន្តនៃប្រទេស។ ការនេះឥតពិបាកធ្វើសោះឡើយ។ គឺគ្រាន់តែចាក់ពួក "អ្នកក្រ" ឲ្យបះទល់នឹងពួក "អ្នកមាន" ទៅបានហើយ។ "អ្នកក្រ" លើសពីអ្នកអកុ័ត ដែលឥតធនធាន ឥតចំណេះវិជ្ជា ឬ ឥតគ្រួសារ, មានពួកចោរ និងពួកប្រមឹកទៀត, និយាយមួយម៉ាត់ គឺពួកអ្នកដែលបានខកចិត្ត និងបានត្រូវបោះបង់ចោលដោយសង្គម។ ពួក "អ្នកមាន" គឺមិនត្រឹមតែពួកដែលបានភ្ជួរស្រែលើខ្នងរាស្ត្រទេ ថែមទាំងពួកដែលមានចំណេះវិជ្ជា ទោះតិចតួចស្តួចស្តើងក្តី, ព្រោះចំណេះវិជ្ជានេះបានត្រូវសំគាល់ថាជាសញ្ញានៃការមាន។*

*ដើម្បីធ្វើការចាក់បំបះនេះ យួនកុម្មុយនិស្តមាន "អាត់" ពីរសន្លឹកដែលសុទ្ធតែខ្លាំងៗ ៖ ១, ការបែកបាក់គ្នាខាងក្នុង (រវាង លន់ នល់ និង នរោត្តម សីហនុ) ដែលឲ្យលេសដល់សង្គ្រាមបដិវត្តន៍, ២, ពួកខ្មែរវៀតមិញ។*

---

*សំនួរទី ៣ ៖ ខ្មែរនិងយួនមិនទុកចិត្តគ្នាទៅវិញទៅមកខ្លាំងណាស់។ ហេតុម្តេចបានជាយួនអាចបញ្ចុះបញ្ចូលបង្វឹកខ្លួនខ្មែរក្រហមបាន?* *(នៅទំព័រ ៨០)*

# អធិប្បាយ

*(១) ដោយយើងពុំសូវទាក់ចិត្តនឹងការដឹងអំពីសាវតារបស់ប្រទេសជិតខាងយើង, ដើមកំណើតនៃវៀតមិញនៅតែជាសំនួរមួយមិនទាន់មានចំឡើយចំពោះខ្មែរយើងជាច្រើនៗ អ្នកនិពន្ធ ក្នុងកិច្ចសន្ទនាជាមួយអ្នកនយោបាយយើងខ្លះ ដែលបានស្គាល់យុគវៀតមិញ, សង្កេតឃើញថាអស់លោកទាំងនោះដូចជាច្រឡំថា គណបក្សកុម្មុយនិស្តឥណ្ឌូចិនជាវៀតមិញៗ ចំពោះមិត្តអ្នកអាន យើងសូមជូនឡើងវិញនូវសាវតាសង្ខេបនៃវៀតមិញៗ អង្គការយោធ: -នយោបាយនេះមិនត្រឹមតែបានដេញបារាំងចេញពីឥណ្ឌូចិនទេ, ថែមទាំងបានបង្វែរផ្លូវប្រវត្តិសាស្ត្រនៃប្រទេសយើងទៀត ព្រោះថា —ចូរយើងកុំភ្លេច— ពួក សាឡុតសរ, អៀង សារី, សុន សេន, សូ ភឹម ។ល។ គ្រាន់តែជាផលិតផលលើកទី២ របស់វៀតមិញទេៗ សាវតានៃវៀតមិញពុំអាចទាញចេញឲ្យដាច់ពីជីវប្រវត្តិរបស់អ្នកបង្កើតខ្លួនឡើយ, គឺរបស់ ហូ ជីមិញ (សៀវភៅដែលនិយាយពីរឿងនេះមានច្រើនណាស់, ប៉ុន្តែដែលល្អជាងគេ គឺរបស់ ហ្វីលីព ដឺ វីល្លែ, "សាវតានៃវៀតណាម ពី ១៩៤០ ទៅ ១៩៥២", ហាងបោះផ្សាយ ស៊ឺយ ១៩៥២)ៗ*

*ជ័យជំនះនៃជប៉ុនលើរុស្ស៊ី នៅឆ្នាំ ១៩០៥ ធ្វើឲ្យបាត់ជំនឿថាពួកស្បែកស ពុំចេះចាញ់ៗ អាស៊ីភាគអគ្នេយ៍ទាំងមូល, ដែលពួកស្បែកសបានយកធ្វើជាអាណានិគម ចាប់កំរើកឡើងៗ ញាតិស្តេចយួនម្នាក់ឈ្មោះ គួង ដេ, ដោយមានអ្នកអក្សរសាស្ត្រ ផាន់ បូយចូវ ដែលជាឪពុកនៃការបដិវត្តន៍យួនជូនទៅផង, ភៀសខ្លួនទៅនៅប្រទេសជប៉ុនក្នុងឆ្នាំ ១៩០៦, ហើយពីទីនោះនាំគ្នាញុះញង់យួនឲ្យបះបោរទល់នឹងបារាំង គួង ដេ សរសេរសំបុត្រជាច្រើនជាមួយនឹងឈាមខ្លួនៗ ក្រោយការបដិវត្តន៍ចិននៃឆ្នាំ ១៩១១ ស៊ុន យ៉ាតសេន, ផាន់ បូយចូវ មកនៅឯកង់តុង ដើម្បីឲ្យបានជិតវៀតណាមៗ ក្នុងឆ្នាំ ១៩១២ នៅកង់តុង ចូវ ប្រមែប្រមូលបានអ្នកជាតិនិយមយួនខ្លះក្នុងក្រុម "កិច្ចសាមគ្គីដើម្បីកសាងវៀតណាមឡើងវិញ" (វៀតណាម ភិក ក្វឹក ដុងមិញហូយ, ភុក ក្វឹក), ហើយរៀបចំរដ្ឋាភិបាលក្រៅប្រទេសមួយជាមួយម្ចាស់ គួង ដេៗ ចម្បាំងរវាងគ្នាឯងក្នុងស្រុកចិន ខាឃាំងពួកជាតិនិយមយួនលើកដំបូងនេះ មិនឲ្យទៅមុខបានឆ្ងាយ ក្នុងសកម្មភាពខ្លួន ចូវបានជាប់គុករួចលែងមកវិញដោយ ស៊ុន យ៉ាតសេនៗ បន្ទាប់ពីសាធារណរដ្ឋចិនបានទទួលបរាជ័យជាច្រើនដង ក្នុងការប្រយុទ្ធជាមួយពួក "មហាមេចម្បាំង" ដែលពុំទាន់ចុះចូលនៅទិសខាងជើង, គណបក្ស គួមិនតាង (ចិនជាតិនិយម) ដែលមានមូលដ្ឋាននៅកង់តុង ក៏រៀបចំបក្សខ្លួនឡើងវិញ ដោយមិនព្រមឲ្យពួកកុម្មុយនិស្ត (ម៉ៅ, ជូ ។ល។) ចូលមកជាមួយ, ហើយមួយចំណែកទៀតកែប្រែកងទ័ពរបស់ខ្លួនតាមគំរូរុស្ស៊ីៗ ឧត្តមសេនីយ ជាង កាយជាក បានត្រូវគេបញ្ជូនទៅសហភាពសូវៀតៗ ពេលត្រឡប់មកវិញ, គេក៏សម្រេចបង្កើតបណ្ឌិតសភាយោធាមួយនៅ វ៉ាមប៉ូ ក្នុងខែមករា ១៩២៤ៗ បណ្ឌិតសភានេះ មានទីប្រឹក្សារុស្ស៊ីជាអ្នកបង្ហាត់បង្រៀន (ដឹកនាំដោយ មិខៃ បូរ៉ូឌីន និងឧត្តមសេនីយ វ៉ាស់ស៊ីលី ប៊្លូឈែ)ៗ ផាន់ បូយចូវ និយាយនឹងចិនឲ្យព្រមទទួលយួន ៤០ នាក់ ក្នុងបណ្ឌិតសភាយោធា វ៉ាមប៉ូៗ នៅកង់តុងក្បែរគ្នានឹងក្រុម "កុកក្វឹក" របស់ចូវ, អ្នកជាតិនិយមយួនមួយពួកទៀតផ្តុំគ្នាក្នុងក្រុម "តាំតាំសា" នៅឆ្នាំ ១៩២៣ៗ ក្នុងឆ្នាំ ១៩២៤ "តាំតាំសា" បញ្ជូនសមាជិកខ្លួនម្នាក់, ផាំ ហុងថៃ, ឲ្យទៅសម្លាប់ "គូវែរនែរ ហ្សេណេរ៉ាល់" ម៉ែឡាំងៗ ដោយខ្លួនបំពេញបេសកកម្មពុំចប់, ផាំ ហុងថៃ ក៏សម្លាប់ខ្លួននៅកង់តុងៗ លើកជាវីរៈបុរសនៃវៀតណាម, ផាំ ហុងថៃ បានឃើញផ្នូររបស់ខ្លួនក្លាយទៅជាទីសក្ការៈបូជាមួយៗ*

*នៅឆ្នាំដែលបណ្ឌិតសភា វ៉ាំមប៉ូ បានត្រូវបង្កើតឡើង, ហូ ជីមិញ, ហៅ លីធុយ, មកដល់កង់តុង នៅខែធ្នូ ១៩២៤, ដោយកាត់តាម ម៉ូស្គូ បន្ទាប់ពីដំណើរជុំវិញពិភពលោកមួយ។ ឈ្មោះពីកំណើត ង្វៀង ស៊ិញគុង, ក្រោយមកហៅ ង្វៀង តាតថាញ់, រួចហើយ ង្វៀង អាយក្វឹក, ហូជីមិញ កើតនៅឆ្នាំ ១៨៩០ ក្នុងស្រុក ញ៉េ អាន់ (អណ្ណាមខាងជើង)។ បន្ទាប់ពីបានធ្វើមធ្យមសិក្សានៅក្រុងហ្វេ, រួចហើយរៀនខាងជំនួញបាន ៣-៤ ខែ នៅព្រៃនគរ, ហូ ចូលធ្វើបោយនៅកប៉ាល់ "ឡាមីរ៉ាល់ឡាទូស -ត្រេវីល", នៅឆ្នាំ ១៩១២, ដើម្បីមកទ្វីបអឺរ៉ុប។ នៅឆ្នាំ ១៩១៣, គាត់ចុះជើងក្រុងឡុងដ្រ៍ ហើយរស់នៅទីនោះ ៤ ឆ្នាំ ដោយធ្វើការជាអ្នកលាងចានក្នុងសណ្ឋាគារ កាលតុន។ នៅឆ្នាំ ១៩១៧, ហូ មកដល់ប៉ារីស, គាត់ចូលស៊ុបក្នុងនយោបាយ។ នៅឆ្នាំ ១៩១៩, យកគំនិតតាមសេចក្តីស្នើ មាន ១៤ ខ នៃប្រធានាធិបតីអាមេរិកាំង វិលសុន, គាត់ទៅ វែរសៃ ដើម្បីបង្ហាញកម្មវិធីមាន ៨ ខ របស់គាត់ដើម្បីឲ្យសេរីភាពទៅវៀតណាមអាណានិគម, ហូ បានជួបស្គាល់អ្នកដឹកនាំសង្គមនិយមបារាំង, ម៉ាកសែល កាសាំង និង ម៉ារីយុស ម៉ុងតេ។ នៅឆ្នាំ ១៩២០, គណបក្សសង្គមនិយមបារាំងបញ្ជូន ហូ ឲ្យទៅជាប្រតិភូនៅសមាជក្រុង ទួ។ ឆ្នាំ ១៩២១, ហូ ជីមិញ បង្កើតសារពត៌មានមួយឈ្មោះ "ឡឺប៉ារីយ៉ា" ដែលប្រែមកថា អ្នកតោកយ៉ាក។ ក្នុងឆ្នាំដដែល គាត់ទៅ ម៉ូស្គូ ចូលរួមក្នុងសមាជទី ៤ នៃកូមិនទែន (ពាក្យកាត់នៃកុម្មុយនិស្តអន្តរជាតិ។ កុំប្រទ្បំនីង គួមិនតាង ចិន)។ ឆ្នាំបន្ទាប់មក, គាត់ទៅក្រុងនោះម្តងទៀត, លើកនេះគណបក្សកុម្មុយនិស្តបារាំងបញ្ជូនគាត់ទៅរៀបចំចលនា "កសិករអន្តរជាតិ" (ក្រេស្ទិនទែន) ដែលនៅក្នុងនោះគាត់បានជាប់ឆ្នោតជាសមាជិកគណៈកម្មាការប្រតិបត្តិ។ ក្រោយកិច្ចជំនុំហើយ, ហូ នៅតែក្នុង ម៉ូស្គូ រួចចុះឈ្មោះរៀនក្នុងសាកលវិទ្យាល័យនៃអ្នកធ្វើការនៃបូពាទិសក្នុងឆ្នាំ ១៩២៤។ រួចហើយគាត់ក៏ចេញពីម៉ូស្គូ មកកង់តុង ដោយធ្វើការជាអ្នកបកប្រែភាសានៅកុងស៊ុលសូវៀត។ នៅកង់តុង ហូ ជីមិញ ជួបជាមួយក្រុមអ្នកជាតិនិយមយួនទាំងឡាយ។ គាត់ពន្យល់អ្នកបង្កើតក្រុម "តាំតាំសា", ហូទុងម៉ាវ និង ឡេហុងផុង, ឲ្យព្រមធ្វើបដិវត្តន៍, ហើយអ្នកទាំងពីរក៏ដាក់ឈ្មោះថ្មីឲ្យចលនាខ្លួនថា "សមាគមយុវជនបដិវត្តន៍វៀតណាម" (វៀតណាម កាក ម៉េញ ថាញ់-ញៀន ដុង ជីហូយ, ឬ ថាញ់-ញៀន)។ នៅឆ្នាំ ១៩២៥ ហូ ធ្វើកិច្ចកំចាត់គូប្រជែងរបស់ខ្លួន, ផាន់ បូយចូវ ដែលកំពុងតែរៀបចំបង្កើតគណបក្សមួយ, "គណបក្សជាតិនិយមវៀតណាម" (វៀតណាម ក្វឹក ដាន់ ដាង, VNQDD)។ ចូវ បានត្រូវគេនាំទៅចូលក្នុងអន្ទាក់មួយ ដែលនាំគាត់ទៅឲ្យនគរបាលបារាំងនៅសៀងហៃ (ដែលកាលនោះគេបែងចែកគ្នាត្រួតដូចក្រុងប៉ែឡាំង) (អ្នកដាក់អន្ទាក់បានទទួលរង្វាន់ខាន់ខៅ ១០ម៉ឺន ប្យ៉ាស)។ ប៉ុន្តែទោះជាគ្មាន ផាន់ បូយចូវ, គណបក្សជាតិនិយមវៀតណាមបានត្រូវគេបង្កើតឡើងនៅហាណូយ ក្នុងឆ្នាំ ១៩២៧។ យកគំរូតាម គួមិនតាង ចិន, គណបក្សនេះបានត្រូវដឹកនាំដោយ ង្វៀង ថៃហុក, ហើយបានទៅជាគូប្រជែងរបស់សមាគម "ថាញ់-ញៀន"។ នៅកង់តុង, តាមរយៈក្រុមថាញ់-ញៀន, ហូ ជីមិញ ប្រមែប្រមូលរកសាវកខ្លួន ដោយបញ្ចុះបញ្ចូលលទ្ធិ ម៉ាក្ស ឡេនីន។ គាត់បោះផ្សាយព្រឹត្តិប័ត្ររាល់អាទិត្យ មួយឈ្មោះ "ថាញ់ញៀន" (យុវជន) ដែលតាមនោះគាត់ផ្សព្វផ្សាយគំនិតប្រឆាំងនឹងអាណានិគមនិយម និងគំនិតបដិវត្តន៍។ ពីខែមិថុនា ១៩២៥ ទៅមេសា ១៩២៧, ព្រឹត្តិប័ត្រចេញបាន ៨៨ លេខ។ ហូ ចាំដល់លេខ ៦០ ទើបគាត់ប្រាប់សាវកថា សង្គ្រាមដើម្បីឯករាជ្យ ត្រូវធ្វើជាមួយគ្នានឹងសង្គ្រាមដើម្បីអំណាចផ្តាច់ការនៃវណ្ណៈកម្មករ-កសិករ ក្រោយរយៈពេលបញ្ចូលលទ្ធិ ៤ ខែ, ហូ ជ្រើសយកអ្នកពូកែជាងគេឲ្យជួយធ្វើការគាត់, យកអ្នកខ្លះទៅផ្តាំផ្ញើនឹងបណ្ឌិតសភាយោធា វ៉ាំមប៉ូ, ហើយបញ្ជូនពួកនៅសល់ទៅប្រទេសវៀតណាម ដើម្បីផ្សព្វផ្សាយនូវគំនិតគាត់ (សាវក ២០០ នាក់ក្នុងចន្លោះឆ្នាំ ១៩២៥ និង ២៧)។*

*នៅឆ្នាំ ១៩២៧, ក្រោយពីបានចូលគ្នាក្នុងរយៈមួយយ៉ាងខ្លី, ពួក គួមិនតាង និងពួកកុម្មុយនិស្តចិន បែកគ្នាវិញ។ ហូជីមិញ, បូរ៉ូឌីន និងទីប្រឹក្សារុស្ស៊ីឯទៀតត្រូវចេញពីស្រុកចិន។ ហូ ទុងម៉ាវ ដែលដឹកនាំសមាគម*

*ថាញ់-ញៀន បានត្រូវ គួមិនតាង ចាប់, ក្រោយបន្តិចមក។ ក្រុម ថាញ់-ញៀន រត់មកនៅហុងកុង, ដែលនៅទីនោះ ឡាំ ឌឹកធឺ ទទួលដឹកនាំ។ នៅឆ្នាំ ១៩២៨, ចលនា កូមិនទែន បញ្ជូន ហូ ទៅប្រទេសអាល្លឺម៉ង់, ហើយឆ្នាំបន្ទាប់មក ទៅប្រទេសថៃ ដែលនៅក្នុងនោះមានយួន ២ ម៉ឺននាក់រស់នៅ។ ក្រោមឈ្មោះថា ថាង ជិន, ហូ ជីមិញ ដើរជួបសហគមន៍យួននៅ ឧដន, ភិជិត, សាកុន និងណាខុន, ដោយទាក់ទងជានិច្ច ជាមួយក្រុម ថាញ់-ញៀន ឯហុងកុង។ ខែឧសភា ១៩២៩, ពួក ថាញ់-ញៀន ធ្វើជាសមាជមួយនៅហុងកុង ដែលគិតគូររៀបចំគណបក្សកុម្មុយនិស្តយួនមួយ។ ប៉ុន្តែប្រតិភូដែលមកពីកន្លែងជាច្រើននៅវៀតណាម, ដោយឆ្អែតចិត្តនឹងជីវិតធើតធាយរបស់ ឡាំ ឌឹកធឺ, មេ ថាញ់-ញៀន, ក៏ពុំព្រមចូលរួមក្នុងសមាជនោះ។ ត្រឡប់មកស្រុកយួនវិញ អ្នកទាំងនោះបង្កើត "គណបក្សកុម្មុយនិស្ត" ជាច្រើននៅតាមភូមិភាគខ្លួន។ ពេលនោះហើយដែល កូមិនទែន បញ្ជូន ហូជីមិញ មកហុងកុងវិញដើម្បីបង្រួបបង្រួមពួក "គណបក្សកុម្មុយនិស្ត" អាយទាំងអស់។ ដូច្នេះហើយទើបគណបក្សកុម្មុយនិស្តឥណ្ឌូចិន (ដុង ដឿង កុង សាង ដាង) បានកើតឡើងនៅហុងកុងក្នុងថ្ងៃ ៦ មករា ១៩៣០។ ក្នុងស្រុកចិន នៅឆ្នាំ ១៩៣០, ក៏មានគណបក្សយួនពីរប្រជែងគ្នា, ប៉ុន្តែដែលតយុទ្ធនឹងសត្រូវតែមួយ គឺអាណានិគមនិយមបារាំង ៖ គណបក្សជាតិនិយមវៀតណាម, ចាស់ជាងហើយមិនមែនកុម្មុយនិស្ត ដែលពួក គួមិនតាង គាំពារ, គណបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលគាំពារដោយពួកកុម្មុយនិស្តចិន, ជាការណ៍ធម្មតា។*

*មុនគេ, ពួកជាតិនិយមសម្រេចវាយ។ ក្នុងយប់នៃថ្ងៃ ៩ ទៅ ១០ កុម្ភៈ, ការបះបោរមួយ (ដែលឮរន្ទឺខ្លាំងនៅសម័យនោះ) កើតឡើងនៅទីប្រជុំជន យ៉េន បាយ។ ទាហាននៃយោធភូមិបះបោរឡើងហើយសម្លាប់ពួកនាយទាហានបារាំង។ បារាំងបញ្ជាឲ្យយន្តហោះធ្វើអន្តរាគមន៍ ហើយការបះបោរក៏បានត្រូវបង្ក្រាបយ៉ាងរហ័ស។ មេនៃគណបក្សជាតិនិយម, ង្វៀង ថៃហុក បានត្រូវគេចាប់បាន ហើយសម្លាប់ចោលទៅ។ ក្រោយព្រឹត្តិការណ៍នៅ យ៉េន បាយ នេះ, ក្រសួងសន្តិសុខបារាំងនៅឥណ្ឌូចិន តាមរកចាប់ពួកជាតិនិយមទាំងអស់។ ប៉ុន្តែគណបក្សកុម្មុយនិស្តទាំងអស់ក៏សំរេច ធ្វើឲ្យមានការបះបោរមួយដែរ។ ខែកក្កដា ១៩៣០ នៅ ញ៉េ-អាន (ស្រុកកំណើត ហូ ជីមិញ), ពួកកុម្មុយនិស្តយួនប្រកាសបង្កើត "មូលដ្ឋានបដិវត្តន៍" សូវៀត នានាក្នុងស្រុក ញ៉េ-អាន ដោយមានឈ្មោះថា "សូវៀត ញ៉េ-អាន"។ មូលដ្ឋានទាំងនេះមានក្រុមអ្នកស្រុកកាន់កាំភ្លើងការពារភូមិឯង, មានតុលាការប្រជាជន ហើយធ្វើកិច្ចចែកដីគ្នា (ចម្លងតាមមូលដ្ឋានចិនកុម្មុយនិស្ត)។ ថ្ងៃ ១២ កញ្ញា ១៩៣០, កសិករ ៦ ពាន់នាក់ នាំគ្នាដើរតំរង់ទៅក្រុង វិន, ដែលជាទីប្រជុំខេត្ត។ កងទាហានធ្វើអន្តរាគមន៍ ហើយបំបែកបាតុកម្មនេះ។ មេដឹកនាំខ្លះដែលមាន ផាំ យ៉ាំងដុង, តុង ឌឹកថាង និង យ៉ ង្វៀងយ៉ាប់ បានត្រូវគេចាប់បញ្ចូលគុក។ តាមគេថា, ហូ ជីមិញ ឥតបានចូលរួមក្នុងបាតុកម្មនេះទេ ហើយនៅឯហុងកុង។*

*ថ្ងៃ ១០ មិថុនា ១៩៣១, នគរបាលអង់គ្លេសឡោមព័ទ្ធការិយាល័យ កូមិនទែន នៅហុងកុង ហើយចាប់ ហូ ជីមិញ នៅទីនោះ។ បានស្នាក្តីអង់គ្លេសម្នាក់ឈ្មោះ លោស៍បាយ ការពារ, ហូ បានត្រូវគេដោះលែងវិញនៅដើមឆ្នាំ ១៩៣៣។ ឡើងកប៉ាល់មកស្រុកអង់គ្លេស, ហូ បានត្រូវគេចាប់ម្តងទៀតនៅសិង្ហបូរី ដោយឥតលិខិតឆ្លងដែន, ហើយយកមកដាក់គុកហុងកុងវិញ។ លើកនេះតាមរឿងនិទានខ្លះ, ហូ រត់ចេញពីគុកបាន, ហើយមកដល់ស្រុកចិន ដែលនៅទីនោះ គាត់ខំរកទាក់ទងជាមួយកុម្មុយនិស្តចិន ដែលកំពុងមានការណ៍ពិបាកដែរ។ ក្រោយមក ហូ ឡើងកប៉ាល់រុស្ស៊ីមួយមក វ្ល៉ាឌីវ៉ូស្តុក, ហើយមក ម៉ូស្គូ។ នៅម៉ូស្គូ គាត់ចូលរៀននៅសាកលវិទ្យាល័យឡេនីន ហើយរកការធ្វើបានក្នុងវិជ្ជាស្ថានស្រាវជ្រាវនៃការសិក្សាអាណានិគម។ នៅក្នុងពេលនោះ ការបង្ក្រាបពួកសមាជិកនៃគណបក្សកុម្មុយនិស្តឥណ្ឌូចិន ដោយនគរបាលបារាំងកំពុងតែបន្តទៅទៀតនៅឥណ្ឌូចិន។ នៅឆ្នាំ ១៩៣៥, គណបក្សកុម្មុយនិស្តឥណ្ឌូចិនបញ្ជូនប្រតិភូពីរនាក់, ឡេ ហុងផុង (អ្នកបង្កើតម្នាក់នៃ "ថាញ់-ញៀន") និង ង្វៀង ធីមិញខៃ ទៅសមាជទី៧ នៃកូមិនទែន ឯម៉ូស្គូ។ ក្នុងឱកាសនោះ, ឡេ ហុងផុង បានជាប់ឆ្នោតជាសមា*

ជិកគណៈកម្មការប្រតិបត្តិនៃចលនាកូមិនទែន។ ដូច្នេះ ហូ ជីមិញ បានត្រូវគេលែងរាប់អាន, ហើយការណ៍នេះប្រហែលជាទណ្ឌកម្មអំពីបរាជ័យក្នុងបាតុកម្ម សូវៀត ញ៉េ-អាន កាលពីឆ្នាំ ១៩៣០។ ក្នុងឆ្នាំ ១៩៣៦ នៅស្រុកបារាំង, គេកំពុងតែលើកតម្កើង "រណសិរ្សប្រជាមានិត"។ នៅឥណ្ឌូចិន អ្នកបដិវត្តន៍យួនជាច្រើននាក់បានត្រូវគេលែងពីគុកវិញ។ ជាថ្មីម្តងទៀត ការបោះពុម្ពផ្សាយផ្សេងៗ របស់ពួកកុម្មុយនិស្ត និងពួកជាតិនិយមយួន ចាប់ផ្ដើមឡើងវិញ។ នៅឆ្នាំ ១៩៣៧, ជប៉ុនចូលលុកលុយប្រទេសចិន។ ជាថ្មីម្តងទៀត, គួ មិនតាង និងចិនកុម្មុយនិស្តចាប់ដៃគ្នាឡើងវិញ។ សហភាពសូវៀតអែបខ្លួនមកជិតប្រទេសចិន ហើយចុះកិច្ចចងមេត្រីភាពជាមួយចិន ដោយមានការឲ្យខ្ចីប្រាក់ ២៥៩ លានដុល្លារ។ ហូជីមិញ អាចត្រឡប់មកស្រុកចិនវិញដោយឥតមានការពិបាក។ លើកនេះ ហូ ចូលទៅចូលជាមួយពួកកុម្មុយនិស្តចិនឯក្រុងស្យ៉ាន, នៅជំណាច់ឆ្នាំ ១៩៣៨។ ពីស្រុកចិន, គាត់ទំទាក់ទងឡើងវិញជាមួយគណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្តឥណ្ឌូចិន។ ខែវិច្ឆិកា ១៩៣៩ ទ័ពជប៉ុនកាន់កាប់បានខេត្ត ក្វាងស៊ី។ ទន្ទឹមគ្នានឹងការរលំនៃសាធារណរដ្ឋទី៣ បារាំង, ជប៉ុនចូលកាន់កាប់វៀតណាមខាងជើង នៅខែ កញ្ញា ១៩៤០។

នៅឥណ្ឌូចិន, "គូវែន័រ ហ្សឺណេរ៉ាល់" ដឺគូ, ដោយខ្លាចចលនាបដិវត្តន៍យួនទាំងអស់មត់គ្នាធ្វើការបះបោរ, សំរេចវាយឲ្យបានមុន ៖ ជនជាតិយួនជាច្រើនពាន់នាក់, ទោះបានត្រូវគេសំគាល់ជាកុម្មុយនិស្ត ឬក៏ឥតសោះ, ក៏បានត្រូវគេចាប់ឃុំឃាំង។ ឡេ ហុងផុង, អគ្គលេខាធិការនៃបក្សកុម្មុយនិស្តឥណ្ឌូចិន, និងសមាជិកគណៈកម្មការប្រតិបត្តិខ្លះទៀត បានត្រូវគេសំឡាប់ចោល។ ដូច្នេះ គណបក្សកុម្មុយនិស្តឥណ្ឌូចិនបានខ្ចាត់ខ្ចាយមួយពេលទៅ។ ប៉ុន្តែសមាជិកជាច្រើនបានភៀសខ្លួនរួចទៅដល់ស្រុកចិន, ជាពិសេសនៅខេត្ត យុន ណាន។ ហូ ជីមិញ ដែលម្តងនេះទទួលជំនួយជាប្រាក់កាសយ៉ាងច្រើនពីចិនកុម្មុយនិស្ត, ខិតខំប្រមែប្រមូលយួនទាំងឡាយដែលភៀសខ្លួនមកនៅប្រទេសចិន។ កិច្ចប្រមែប្រមូលទាំងនេះនាំគាត់ឲ្យជួបអ្នកដឹកនាំយួនច្រើននាក់ ដែលមាននាយទាហានម្នាក់ក្នុងទ័ពចិន គួមិនតាង ឈ្មោះ ហូ ង៉ុកឡាំ។ នាយទាហានយួននេះក៏កំពុងប្រមែប្រមូលគ្នីគ្នាមកក្នុងចលនាខ្លួនឈ្មោះ "សមាគមដើម្បីកិច្ចសាមគ្គីដើម្បីឯករាជ្យវៀតណាម" (វៀតណាម ដុកឡាប់ ដុងមិញ ហូយ) ដែលបានត្រូវបង្កើតឡើងតាំងពីឆ្នាំ ១៩៣៥ នៅ ណានគិង។ ដោយបាន ហូ ង៉ុកឡាំ ជួយផង, ហូ ជីមិញ បានត្រូវគេនាំឲ្យជួបអ្នកដឹកនាំ គួមិនតាង ម្នាក់នៅ ក្វាយលិន ឈ្មោះ លី ជីសេន។ អ្នកដឹកនាំចិននេះកំពុងរកមនុស្សម្នាក់ដែលព្រមទៅស៊ើបការណ៍លើទីតាំងទ័ពជប៉ុននៅវៀតណាមខាងជើង, ហើយគូសគំរោងផ្លូវចូលមួយក្នុងអនាគតសម្រាប់ទ័ពចិន។ ហូ ឆ្លៀតឱកាសក្ខាម ហើយដាក់បេក្ខភាពរបស់ខ្លួន។

នៅខែតុលា ១៩៤០, ហូ ជីមិញ ស្នើដល់ក្រុមយួនទាំងអស់ឲ្យចូលក្នុងរណសិរ្សរួបរួមមួយ, ហើយនាំគ្នាមកនៅតាមព្រំដែនចិន-យួន។ "ក្រុមវៀតណាម ដុកឡាប់ ដុងមិញហូយ" របស់ ហូ ង៉ុកឡាំ ក៏ចូលគ្នាជាមួយពួកគណបក្សកុម្មុយនិស្តឥណ្ឌូចិន ក្នុងរណសិរ្សថ្មីមួយឈ្មោះថា "វៀតណាម ដុកឡាប់ ដុងមិញ" (កិច្ចសាមគ្គីដើម្បីឯករាជ្យនៃវៀតណាម), ឈ្មោះដែលបារាំងហៅកាត់ថា វៀតមិញ។ ហូ ង៉ុកឡាំ បានជាប់ឆ្នោតជាមេចលនា។ ឯ ផាំ យ៉ាំងដុង ជាប់ជាកូឈួយ, ហើយវៀតមិញក៏បានកើតឡើងដោយយ៉ាងនេះឯង។ ជាមួយចលនាវៀតមិញ, ហូ ជីមិញ ត្រឡប់ចូលមកប្រទេសកំណើតវិញ ដើម្បីតយុទ្ធតាមសង្គ្រាមធ្មក់ទប់ទល់នឹងបារាំង។ សង្គ្រាមបដិវត្តន៍មែនទែនក៏ចាប់ផ្តើមឡើងចំពោះអ្នកនយោបាយ ហូ ជីមិញ ដែលបានរង់ចាំឱកាសនេះ ២១ ឆ្នាំមកហើយ, តាំងពីខ្លួនបានទៅ វែរសៃ នៅឆ្នាំ ១៩១៩។

*ខ្មែរនិងយួនមិនទុកចិត្តគ្នាទៅវិញទៅមកខ្លាំងណាស់។ ហេតុម្តេចបានជាយួនអាចបញ្ចុះបញ្ចូលបង្កើតខ្លួរខ្មែរក្រហមបាន?*

*ពួកឃាតករនៃប្រជាជនខ្មែរដែលកាន់កាប់អំណាចជាងបីឆ្នាំនៅស្រុកខ្មែរពុំដែលបានត្រូវបង្កើតខ្លួរដោយជនជាតិយួនទេ ប៉ុន្តែបានត្រូវបញ្ចុះបញ្ចូលដោយពួកដែលសម្តេច សីហនុ បានឲ្យឈ្មោះថា "ខ្មែរ-វៀតមិញ"។ ដើម្បីយល់ថាហេតុម្តេចបានជាជនជាតិខ្មែរក្លាយទៅជា ខ្មែរ-វៀតមិញ កើត ហើយពិនិត្យមើលការវិវត្តន៍នៃពួកនេះ យើងត្រូវត្រឡប់មកក្រោយចំនួន ៣០ ឆ្នាំវិញ។*

*ជាដំបូងយើងត្រូវដឹងថា កូនសោដែលបើកឲ្យវៀតមិញបានទទួលជោគជ័យ គឺពួកអាណិកជនជាតិផ្សេងៗ នៃឥណ្ឌូចិន។ ទោះបីការណ៍នេះ ឲ្យគេរកជឿពុំកើត, កងទាហានលើកដំបូងរបស់វៀតមិញឥតមានជនជាតិយួនទេ, ប៉ុន្តែមានសុទ្ធតែពួក "ថូ"⁽¹⁾ ដែលស្អប់យួនរាប់ជំណារ ដូចជនជាតិខ្លះដែរ។ ដូច្នេះមែន, ឆ្លៀតឱកាសពីការបះបោរមួយរបស់ពួកកន្ទ្រាញ ថូ ទល់នឹងអំណាចអាណានិគមក្នុងឆ្នាំ ១៩៤០, យ៉ ង្វៀងយ៉ាប់ រៀបចំតម្លើងមូលដ្ឋានមួយ ដែលនឹងទៅជាទីដើមនៃការតយុទ្ធដំយូរទល់នឹងបារាំង។ តទៅនេះ គឺការរ៉ាយរ៉ាប់នៃអ្នកនិពន្ធបារាំងឈ្មោះ ហ្សេរ៉ា ឡេ ក្វាង អំពីបច្ចេកទេសដែល យ៉ាប់ បានប្រើ ដើម្បីចូលទៅក្នុងពួក ថូ (ក្នុងសៀវភៅ "យ៉ាប់ ឬសង្គ្រាមនៃប្រជាជន" បណ្ណាគារ ដឺណូអែល ១៩៧៣) ៖*

*"តាមដំបូន្មាននៃ ហូជីមិញ, យ៉ាប់ រៀនទេសភាសាពួកអ្នកស្រុកភ្នំ ហើយចេះនិយាយល្មមក្នុងពេលខ្លីបន្តិចដែរ។ គាត់ឲ្យគេបង្រៀនដល់មនុស្សគាត់ទៀត។ ដោយយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការឃោសនា គាត់ឲ្យធ្វើកម្មសិក្សានយោបាយ ទៅតាមទំនៀមអ្នកស្រុក៖ "ជាមួយពួក ម៉ាន់ ស (កន្ទ្រាញស្រុកភ្នំមួយ) (មានពួក ម៉ាន់ ខ្មៅ, ក.ក.ន.) យើងត្រូវហូតគូររូបទៀត ដើម្បីឲ្យគេយល់គំនិតយើង, គាត់បាននិយាយប្រាប់ក្រោយមក។ ដើម្បីឲ្យយល់ថា បារាំងនិងជប៉ុន ជញ្ជក់ឈាមប្រជាជនយើង, យើងគូររូបបារាំងម្នាក់និងជប៉ុនម្នាក់វាយយួន, ឬរូបកសិករម្នាក់ សង្កត់ដោយទម្ងន់ពន្ធដារនិងកំណែន។ យើងធ្វើគំនូរ១ទៀត ដែលមាន គិន ម្នាក់ (អាណិកជនមួយក្រុមទៀត), ម៉ានម្នាក់ ឬ ថូម្នាក់ ដើរកាន់ដៃគ្នា ដើម្បីបង្ហាញការចាំបាច់នៃការរួបរួមជាតិទល់នឹងពួកលុកលុយ"។ យ៉ាប់បានដឹកនាំអ្នកបង្ហាត់មួយក្រុម ដែលធ្វើការក្នុងភូមិភាគ ហ្វាអាន ង្វៀងប៊ិន។ គាត់រ៉ាយរ៉ាប់ថា ដើម្បីធ្វើឲ្យបណ្តាជនទុកចិត្ត គាត់បានបញ្ជាឲ្យមនុស្សរបស់គាត់បន្ទន់ខ្លួនទៅតាមទំនៀមទំលាប់របស់គេ ហើយនិងធ្វើពិធីស្បថ ពេលណាចូលទៅក្នុងភូមិ ម៉ាន មួយៗល។ ដោយយ៉ាងនេះឯងដែលបានត្រូវសាងឡើង ក្រោមសន្ទុះរបស់ យ៉ាប់ និងស្របតាមគំនិតរបស់ ហូជីមិញ, នូវគោលគំនិតមួយក្នុងចំណោមគោលគំនិតនយោបាយឯទៀតនៃរបបថ្មី ៖ ការជួយគាំទ្រពួកអាណិកជន ដែលគេនឹងគោរពជំនឿ និងទំនៀម។*

*ឧត្តមសេនីយបីនាក់នៃកងទ័ពវៀតមិញ ជាជនជាតិថូ។ កងពលធំលេខ ៣១២ និង ៣១៦ ដែលបានចូលរួមក្នុងការប្រយុទ្ធនៃ ដៀន បៀន ភូ មានសុទ្ធតែជនជាតិថូ (២០ ០០០ នាក់, គឺ ២០% នៃយោធា វៀតមិញនៅឆ្នាំ ១៩៥៤)។ រដ្ឋមន្ត្រីក្រសួងការពារប្រទេស ក្នុងរដ្ឋាភិបាលបណ្តោះអាសន្នទី១ នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម, ជូយ៉ាងតាង, ជាជនជាតិថូ។ ពេលដែលវៀតមិញ ចាប់ចូលមកក្នុងវៀតណាមខាងត្បូង វាក៏បានធ្វើមូលដ្ឋានជាទីដើមមួយ ដោយប្រើពួកអាណិកជនដែលរស់នៅឯ "ទីទួលខ្ពស់" ដែរ⁽²⁾។ ដូចគេអាចរង់*

ចាំ, ខ្មែរក្រោម *ដែលតយុទ្ធតាំងពីសតវត្សរ៍ទី ១៩ ដើម្បីរក្សាអត្តភាព ជាតិសាសន៍ និងវប្បធម៌ខ្លួន ក៏វៀតមិញពុំបានបំភ្លេចដែរ។ ដូចអាណិកជនជាតិឯទៀត គេបបួលបងប្អូនយើងឲ្យប្រយុទ្ធតទល់នឹងបារាំង ដោយសន្យាថានឹងឲ្យស្វ័យភាពទូលំទូលាយ ពេលណាឥណ្ឌូចិនរលាស់ខ្លួនពីបារាំងអាណានិគមនិយម។*

*តាំងពីឆ្នាំ ១៩៤៦, ហូជីមិញ ចាប់យកចិត្តទុកដាក់នឹងប្រទេសកម្ពុជា។ គោលដៅពីរយ៉ាងច្បាស់លាស់មានក្នុងគំនិតអ្នកដឹកនាំយួន។ ទី១, សំរាប់ប្រើការភ្លាមៗ គឺស្ពាបនាផ្លូវចេញចូលមួយ ដើម្បីដឹកនាំកាំភ្លើងដែលទិញដោយរត់ពន្ធពីស្រុកថៃ យកមកវៀតណាមខាងត្បូង ហើយដើម្បីរកស្បៀងបញ្ជូនមកស្រុកនេះ (ស្រូវបាត់ដំបង, ត្រីទន្លេសាប ។ល។)។ កិច្ចការនេះបានត្រូវប្រគល់ឲ្យកងឯកភាពវៀតមិញ[៧]។ ទី២, សំរាប់ពេលខាងក្រោយ គឺធ្វើឲ្យប្រទេសកម្ពុជាទៅជារណប ពេលណាឥណ្ឌូចិនរួចពីក្រញាំបារាំងហើយ, ដោយប្រើគណបក្សកុម្មុយនិស្ត "ជាបងប្អូន" មួយ ដែលមានសុទ្ធតែខ្មែរដែលប្រុងប្រៀបខ្លួនជំនួសបារាំង។ កិច្ចការនេះបានត្រូវទុកឲ្យខ្មែរ (ដែលលើកដំបូងសុទ្ធតែខ្មែរកម្ពុជាក្រោម) ហើយនិងខ្មែរកាត់យួន ឬយួនដែលកើតនៅស្រុកខ្មែរ ហើយដែលបានចូលស៊ុបក្នុងសង្គមខ្មែរ។ អ្នកនិពន្ធ ប៉ែណាហ្វល់, ក្នុងសៀវភៅរបស់ខ្លួនឈ្មោះ "វៀតមិញ" (បណ្ណាគារ អារម៉ង់កូឡាំង, ១៩៦០) បានបង្ហាញទំរង់ទំរាយនៃខ្មែរវៀតមិញ ហើយពន្យល់ក្នុងពេលជាមួយគ្នា នូវបច្ចេកទេសបញ្ចូលខ្លួនរបស់វៀតមិញ មកក្នុងកម្ពុជា ៖*

*«ប៉ុន្តែប្រទេសអាស៊ីពីរបានទទួលយ៉ាងធំ ក្នុងកំឡុងច្រើនឆ្នាំមកហើយ នូវឥទ្ធិពលនៃនយោបាយក្រៅប្រទេសនៃ ស.ប.វ. (សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម) ៖ លាវនិងកម្ពុជា។ ដោយកត់សំគាល់សភាពទន់ខ្សោយខាងចំនួនប្រជាពលករ ខាងកងទ័ព និងខាងសេដ្ឋកិច្ចនៃប្រទេសពីរនេះ ចំពោះមុខ ស.ប.វ., គេគួរពិនិត្យឲ្យយូរ នូវទំនាក់ទំនងរវាងប្រទេសពីរនេះ និង ស.ប.វ.។*

*»អតីត: សមាជិកនៃសហព័ន្ធឥណ្ឌូចិនដូចជាវៀតណាមដែរ ប្រទេសពីរនេះមានជាមួយអ្នកជិតខាងយួនខ្លួន មិនត្រឹមតែការពិសោធន៍លើអាណានិគមនិយមបារាំងទេ ថែមទាំងប្រវត្តិមួយដ៏វែង នៃការរស់នៅជាមួយគ្នាដែល, ជាញឹកញយ, ពុំសូវប្រកបដោយសន្តិភាព, ហើយដែលរដ្ឋតូចទាំងពីរច្រើនតែជាអ្នកបង់ខាត។ ការដកយកភាពអាណានិគមចេញពីកម្ពុជានិងលាវ បានធ្វើឡើងតាមរបៀបមួយស្រួលបួលដែរ ហើយពុំគួរទៅជាហេតុមួយដែលធ្វើឲ្យមានអន្តរាគមន៍យួនទេ។ ប៉ុន្តែចំពោះរឿងនេះ, ស.ប.វ. ដូចជាបានលាយមនោគមវិជ្ជាម៉ាក្សនិយម របស់ខ្លួនចូលគ្នានឹងគោលបំណងមួយដែលថាទំនៀមទំលាប់ (សិទ្ធិ) ជាតិនិយមយួន។ ព្រោះថាទឹកដីយួនទាំងអស់ដែលនៅក្រោមខ្សែស្របលេខ ១៨ និងនៅខាងលិចនៃស៊ីងខ្មៅ គ្រាន់តែជាទឹកដីដែលខ្លួនចូលមកនៅលើទេ, ហើយចំពោះ (ទឹកដី) វៀតណាមខាងត្បូង អាណានិគមកម្មនេះនៅថ្មីៗ នៅឡើយ។ សាយហ្គន ទើបនឹងទៅជាយួននៅឆ្នាំ ១៦៨៨ ទេ, ហើយហាទៀង ដែលនៅខាងនិរតីនៃជ្រោយ (ឥណ្ឌូចិន) ទៅជាយួននៅឆ្នាំ ១៧១៤ គឺជាតិចជាង ១៥០ ឆ្នាំ មុនពេលដែលបារាំងមកដល់។ ប៉ុន្តែ គឺតាំងពីមុនឆ្នាំ ១៨៥០ ទៅហើយ ដែលមួយភាគធំនៃប្រទេសលាវ បាននៅក្រោមអំណាច (ប្រូតិកតូរ៉ា) ស្តេចអណ្ណាម, ហើយនៅឆ្នាំ ១៨៤៦ ប្រទេសសៀមនិងប្រទេសអណ្ណាម បែងចែកកម្ពុជាជាភូមិភាគផ្សេងៗ ដែលខ្លួនសន្ទឹងឥទ្ធិពលលើ។ ជាលើកបង្អើយ, គឺការចូលមកតាំងទីនៃបារាំងទេ ដែលប្រាកដជាបានស្រង់ប្រទេសទាំងពីរចេញពីការបាត់បង់ទាំងមូល, ការបាត់បង់ដែលរាជាណាចក្រចាម បានស្គាល់កាលពី ២ សតវត្សរ៍មុន។*

*»ការរំលឹកសាវតានេះ ជាការចាំបាច់ ដើម្បីយល់អាកប្បកិរិយារបស់យួនកុម្មុយនិស្ត ឬមិនកុម្មុយនិស្ត, ចំពោះមុខលាវ និងកម្ពុជា —គឺគ្រាន់តែជាទឹកដីពីរដែល, "តាមច្បាប់", ត្រូវសំគាល់ថាដូចជារបស់វៀតណាមទៅហើយ, ហើយប្រហែលជានឹងទៅដូច្នេះមែន បើគ្មានឧបសគ្គនៃអាណានិគម (បារាំង)។ មែនទែនទៅ ចំពោះទំនាក់ទំនងរវាងកម្ពុជានិងវៀតណាមខាងត្បូង, ការដក (ឥណ្ឌូចិន) ចេញពីការកក់បញ្ចាំ (នឹងបារាំង) អាណា*

និគម បានបញ្ចេះចំណោទរវាងប្រទេសទាំងពីរ— សាយហ្គន់ចោទភ្នំពេញថាបានឲ្យជំរកដល់ពួកយួនដែលប្រឆាំងនឹងរដ្ឋាភិបាលខ្លួន, ភ្នំពេញចោទសាយហ្គន់ថាធ្វើទុក្ខបុកម្នេញដល់ពួកអាណិកជនខ្មែរដ៏ច្រើន (៤៤០ ០០០ នាក់!) ដែលរស់នៅតាមកាត់ក្រោមនៃទន្លេមេគង្គ, ហើយជួយគាំទ្រពួកខ្មែរដែលប្រឆាំងនឹងសម្តេចសីហនុ ។

»ចំណែកឯទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនិងកម្ពុជាវិញ, ច្រើនតែជាការបន្តនយោបាយដែលជាទំនៀមទំលាប់របស់យួន ដើម្បីចូល (ក្នុងទឹកដីខ្មែរ)។ នយោបាយនេះ បានត្រូវអនុវត្តន៍យ៉ាងច្រើនក្នុងចន្លោះឆ្នាំ ១៩៥០ និង ១៩៥៤ ព្រោះថាស្ថានការណ៍ខាងក្នុងរបស់ខ្មែរ ដូចជាបើកឱកាសឲ្យណាស់។ នៅខែមីនា ១៩៤៥ អ្នកនយោបាយខ្មែរម្នាក់ដែលមានដើមកំណើតនៅស្រុកយួន, សឺង ង៉ុកថាន់, គាំពារដោយ ជប៉ុន, ប្រកាសឯករាជ្យពេញទីនៃកម្ពុជា ក្រោយការប្រើកម្លាំងនៃជប៉ុន ដែលបោសកំចាត់រដ្ឋការបារាំង។ ក្នុងនាទីជារដ្ឋមន្ត្រីទី១ គាត់ទំប្រឆាំងនឹងការវិលត្រឡប់មកវិញនៃបារាំង ប៉ុន្តែបានត្រូវកងឯកភាពនៃឧត្តមសេនីយ ឡឺក្លែ ចាប់យ៉ាងរហ័ស ហើយបានត្រូវបំបរបង់។ ដោះលែងមកវិញតាមការទទូចសុំនៃព្រះចៅ (ឥឡូវនេះសម្តេច) សីហនុ នៅឆ្នាំ ១៩៥១ គាត់ត្រឡប់មកកម្ពុជា ដើម្បីគ្រាន់តែបោះខ្លួនម្តងទៀតទៅក្នុងការប្រឆាំងនឹងស្តេចគាត់ ក៏ដូចជាប្រឆាំងនឹងបារាំងដែរ។

»ប៉ុន្តែ វៀត-មិញ ឥតបានរង់ចាំការត្រឡប់មកវិញនៃ សឺង ង៉ុកថាន់ ទេ ដើម្បីប្រមូលមកទុកក្រោមដៃរបស់ខ្លួន នូវពួកខ្មែរមិនចុះចូលទាំងក្រុមដែលមានពពួកក្រុម "សែលលុល" និងកងឯកភាពពិសេសវៀតមិញចាំជួយព្រួតដៃផង។ តាំងពីថ្ងៃ ១៩ មិនា ១៩៥០ ទៅហើយ គឺមិនទាន់ទាំងបានមួយខែផង ក្រោយការបង្កើតគណបក្ស ឡាវ-ដុង (គណបក្សអ្នកធ្វើការ, សព្វថ្ងៃកាន់អំណាចនៅវៀតណាម, ក.ក.ន.), ពិធីសម្ពោធនៃ "គណៈកម្មការកណ្តាលនៃការរំដោះប្រជាជនខ្មែរ" បានត្រូវធ្វើឡើង, ហើយដែលទៅជារណបសុទ្ធសាធនៃ ស.ប.វ. (សាធារណរដ្ឋប្រជាធិបតេយ្យវៀត-ណាម)។ ក្នុងការឃោសនាវៀតមិញនៅកម្ពុជា គេពូនិយាយពីខ្មែរម្នាក់យ៉ាងអាថិកំបាំងឈ្មោះ សឺង ង៉ុកមិញ។ ប៉ុន្តែមែនទែនទៅ ប្រតិបត្តិការវៀតមិញនៅកម្ពុជា នៅក្រោមបង្គាប់នៃនាយ "ការិយាល័យកណ្តាលនៃទក្សិណទិស", កូនកាត់ខ្មែរ-យួនម្នាក់ឈ្មោះ ស៊ីវ ហេង។

»ដោយហេតុថា នៅប្រទេសកម្ពុជាមានការធ្វើល្បាតនៃបេសកៈយោធពល (បារាំង) តិចជាងនៅប្រទេសវៀតណាម, ទីបញ្ជាការនានានៃវៀតមិញនៅទិសខាងត្បូង ក៏ចាប់ផ្តើមធ្វើចលនាមកប្រទេសកម្ពុជាក្នុងរដូវក្តៅ (អេតេ) ឆ្នាំ ១៩៥០។ ក្នុងពេលយ៉ាងខ្លី ប្រទេសកម្ពុជាក៏ជាប់ចូលក្នុងរបៀបរៀបចំរដ្ឋបាលវៀតមិញមួយដែរ, ហើយកិច្ចនេះត្រូវតែគេសំគាល់ថាជារដ្ឋាភិបាលទាហានមួយលើទឹកដីកាន់កាប់ ព្រោះធ្វើឡើងនៅក្នុងដីបរទេស។ កម្ពុជាទាំងមូលបានត្រូវចែកជាបីភូមិភាគ (មៀន), ជាប៉ែក (វង់) ហើយជាឯកភាព និងជាក្រុម "សែលលុល" អាយ (ស្រុក, ឃុំ, ភូមិ)។ គណៈកម្មការក្របខ័ណ្ឌ (ប៉ាំងកាងស៊ី) បានត្រូវដាក់ពីលើភូមិភាគខ្មែរទាំងបី, គណៈកម្មការសំរាប់ភូមិភាគនិរតីឥតមានខ្មែរទេ, ហើយពីរទៀត មួយៗ មានតែខ្មែរម្នាក់ក្នុងចំណោមសមាជិកទាំង៧ នៃគណៈកម្មការ។

»នៅថ្ងៃ ២២ វិច្ឆិកា ១៩៥០, សន្និសីទទីមួយរវាងអ្នកដឹកនាំវៀតមិញ និងពួកមិនចុះចូលនៃកម្ពុជានិងលាវ បានត្រូវធ្វើឡើង។ លទ្ធផលនៃសន្និសីទនេះ គឺសេចក្តីថ្លែងការណ៍មួយ ចុះហត្ថលេខាដោយ តុង ឌឹកថាង ដើម្បីវៀតមិញ, ស៊ីវ ហេង ដើម្បីកម្ពុជា និងម្ចាស់មិនចុះចូល សុផានុវង្ស ដើម្បីលាវ, ហើយដែលចង់ធ្វើកម្មវិធីដូចតទៅ ៖ សម្ពន្ធភាពមួយរវាងប្រទេសទាំង៣ ដោយយកជាមូលដ្ឋាននូវ "សមភាព និង ការគោរពទៅវិញទៅមកនូវអធិបតីភាព និងបូរណភាពទឹកដីនៃប្រទេសនិមួយៗ", ទិតទំដើម្បី "លប់បំបាត់ការប្រកាន់ពូជសាសន៍ (គឺថាទឹកចិត្តប្រឆាំងយួននៃលាវនិងខ្មែរ) ដែលបារាំងអាណានិគមនិយមបានធ្វើឲ្យមាន", រួចជាបង្កើយ សុំឲ្យប្រជាជនទាំង៣ រួបរួមគ្នាឲ្យកាន់តែជិតស្និទ្ធិឡើងដើម្បីប្រយុទ្ធ។ ការរៀបចំដោយស្របគ្នានូវ "រណសិរ្សរួបរួម"

របស់ខ្មែរ និង របស់លាវ ដែលចំឡងតាមគំរូ លៀន-វៀត ក៏ចេះតែដើរទៅមុខ, ហើយនៅថ្ងៃ ១១ មីនា ១៩៥១ សន្និសីទមួយទៀតក៏ធ្វើឡើង ដែលប្រជុំពួកតំណាង លៀន-វៀត របស់ ស.ប.វ. (តុងឌីកថាង) និងពួកតំណាងរណសិរ្សជាតិរួបរួមខ្មែរ (FNUK, ក.ក.ន.) និងពួកតំណាងរណសិរ្សជាតិរួបរួម ប៉ាថេតឡាវ។ លើកនេះ សេចក្តីសំរេចចិត្តដែលបានត្រូវគេបោះឆ្នោត មានគោលខ្លះនៃកម្មវិធីមួយច្បាស់លាស់ទៅហើយ ៖ កិច្ចការជាគោលជំនៃការបដិវត្តន៍នៃប្រទេសទាំងបី គឺដេញចេញពួកអាណានិគមនិយមបារាំង និង (សម្ព័ន្ធជួងថ្មីមួយ) ពួកអន្តរាគមន៍និយម អាមេរិកាំង។ "គណៈកម្មការនាយកអចិន្ត្រៃយ៍មួយបានត្រូវបង្កើតឡើង ដែលមានឈ្មោះថា "គណៈកម្មការនៃសម្ពន្ធភាពនៃប្រជាជន វៀត-ណាម, ខ្មែរ និង ប៉ាថេតឡាវ"។

» ឥឡូវនេះ វៀតមិញប្រុងរួចជាស្រេចនឹងដាក់គណបក្សជាមូលដ្ឋានមួយដែលចាប់ពីទីនោះ គេអាចតម្លើងអង្គការកុម្មុយនិស្តខ្មែរមួយ, ព្រោះថាពួក "ខ្មែរសេរី" (ខ្មែរឥស្សរៈ) ចូលចិត្តធ្វើការដោយឥតសណ្តាប់ធ្នាប់ពេក, តាមតែចិត្តពួកមេក្នុងស្រុក។ គណៈកម្មការមួយទៀតបានត្រូវបង្កើតឡើងដែលមានឈ្មោះយ៉ាងវែងថា "គណៈកម្មការកណ្តាលដើម្បីរត់កិច្ចការដើម្បីបង្កើតគណៈបក្សបដិវត្តន៍នៃប្រជាជនខ្មែរ" (បាងយ៉ាងដុងថាន់ឡាប់ដាងញ៉ាងដាងកាកម៉ាងកាវ-មាន)។ ត្រង់នឹងក៏ដែរ គេពុំបានធ្វើដោយខ្ជីខ្ជាទេ, ព្រោះថាកម្មវិធីនៃគណបក្សថ្មីនេះ បានត្រូវសរសេរឡើងដោយអ្នកឯកទេសយួនតែម្តង ដើម្បីចែកបន្តទៅឲ្យខ្មែរ តាមក្រុមវៀតមិញក្នុងស្រុក។ របៀបដែលត្រូវធ្វើតាមបានត្រូវប្រាប់យ៉ាងច្បាស់ក្នុងកំណត់ពន្យល់ដែលភ្ជាប់ជាមួយលក្ខន្តិកៈ នៃគណបក្សថ្មី ហើយដែលបានចែកផ្សាយជាមួយគ្នា ៖

ដល់សមមិត្តទាំងអស់,

នេះជាឯកសារពីរដែលទាក់ទងនឹង ៖

១- ខ្សែនយោបាយនៃគណបក្ស។

២- លក្ខន្តិកៈនៃគណបក្សបដិវត្តន៍នៃប្រជាជនកម្ពុជា។

លក្ខន្តិកៈ បានត្រូវអនុមត្តិជាឯកច្ឆ័ន្ទ ដោយប៉ាំងកាងស៊ុី នៃកម្ពុជា។ ចំណែកខាងខ្សែនយោបាយនៃគណបក្ស ប៉ាំងកាងស៊ុី បានអនុមត្តិតែខ្សែបន្ទាត់ធំៗ ទេ ដែលមិត្តនឹងយកទៅធ្វើជាមូលដ្ឋាននៃកិច្ចការរបស់មិត្ត និង នៃការបង្ហាត់បង្ហាញដល់អ្នកចូលថ្មីក្នុង "គណបក្សបដិវត្តន៍នៃប្រជាជនខ្មែរ"។ ដោយឯកសារនេះបានត្រូវសរសេរឡើងយ៉ាងលឿន, គេត្រូវប្រើពេលវេលាខ្លះ ដើម្បីសិក្សាឲ្យហ្មត់ចត់និងជ្រៅ។...

យើងសូមឲ្យ (គណៈកម្មការ) ភូមិភាគ បកប្រែ ជាខ្មែរ រួចចែកផ្សាយនៅក្នុងក្រុមទាំងឡាយ។ យើងសង្ឃឹមថាក្នុងរយៈពេលរត់កិច្ចការ ដើម្បីរើសរកអ្នកចូល និងដើម្បីរៀបចំសែលលុលទាំងឡាយដែលគណបក្សនឹងពឹងផ្អែកទៅលើ ដើម្បីកើតឡើងឲ្យត្រឹមត្រូវតាមច្បាប់, មិត្តនឹងបង្គ្រប់ឯកសារនេះជាមួយមតិរបស់មិត្ត ដែលមិត្តនឹងធ្វើឡើងឲ្យបានដល់គណៈកម្មការកណ្តាល ដើម្បីរត់កិច្ចការក្នុងកំឡុងខែកុម្ភៈ ១៩៥២។ គណៈកម្មការនឹងប្រមូលផ្តុំមតិទាំងអស់ ហើយនឹងយកគំនិតតាមដើម្បីធ្វើសេចក្តីថ្លែងគោលបំណងនយោបាយជាផ្លូវការនៃគណបក្ស។ សេចក្តីថ្លែងគោលបំណងនេះ នឹងបានត្រូវចែកចាយជាផ្លូវការ ក្នុងចំណោមប្រជាជនតែពេលណាដែល ប៉ាំងកាងស៊ុី នឹងបានយល់ព្រមហើយ។

(ហត្ថលេខា) ថ្ងៃ ៥ សីហា ១៩៥១

គណៈកម្មការកណ្តាលដើម្បីរត់កិច្ចការដើម្បីបង្កើតគណបក្សបដិវត្តន៍ នៃ ប្រជាជនខ្មែរ។

»លក្ខន្តិកៈនៃគណបក្សប្រជិវត្តន៍នៃប្រជាជនខ្មែរ ដែលបានត្រូវរៀបរៀងឡើងដោយទីបញ្ជាការវៀតមិញនៅកម្ពុជានេះ មិនជាអ្វីក្រៅពីសេចក្ដីសង្ខេបនៃលក្ខន្តិកៈរបស់ ឡាវ-ដុង ទេ។ ការខុសគ្នាមានមួយកន្លែងហើយយ៉ាងសំខាន់ ៖ ពព មាននិយាយពី "លទ្ធិធំៗ នៃ ម៉ាក្ស, អិនហ្គិល, ឡេនីន និង ម៉ៅ-សេទុង" ទេ។ ការនិយាយពីលទ្ធិនយោបាយ មាននៅតែក្នុងឃ្លាមួយដែលមិនអស់សេចក្ដី ៖ "លទ្ធិនៃ គណបក្ស ជាលទ្ធិប្រជាធិតេយ្យប្រជាមានិត។[៤]

»ចាប់តាំងពីពេលនេះទៅ, ការរីកចំរើននៃការបះប្រចាំងខ្មែរ ធ្វើឡើងយ៉ាងឥតល្អៀងតាមគំរូយួនរបស់ខ្លួនៗ នៅឆ្នាំ ១៩៥២, គណៈកម្មាការជាតិនៃការរំដោះខ្មែរ ប្រែខ្លួនទៅជា "រដ្ឋាភិបាលខ្មែរតស៊ូ" ដឹកនាំដោយ សឺង ង៉ុកមិញ ហើយដែលបានត្រូវ "ទទួលស្គាល់" ភ្លាម ពី ប៉ាថេតឡាវ និងពី ស.ប.វ. ក្រៅពីនេះ ឥតរដ្ឋឯណាទៀតទទួលស្គាល់ឡើយ។ "រដ្ឋាភិបាលតស៊ូ" នេះ មានសារៈសំខាន់បន្តិច នៅពេលជិតធ្វើសន្និសីទ ហ្សឺណែវ, ព្រោះថាបើ ស.ប.វ. ធ្វើឲ្យគេទទួលស្គាល់បាននូវវត្តមានជាផ្លូវហេតុ នៃរបបទាំងពីរនេះ ដែលខ្លួនគាំពារ, ជំហររបស់ខ្លួនចំពោះមុខបារាំងនឹងរឹងប៉ឹងយ៉ាងខ្លាំង។ ក្នុងពេលដែលជោគជ័យខាងទាហានរបស់ខ្លួនមានឡើងជាបន្តបន្ទាប់គ្នា នៅលាវនិងកម្ពុជា ពីខែធ្នូ ១៩៥៣ ទៅខែមេសា ១៩៥៤, អ្នកដឹកនាំ ស.ប.វ. ក៏និយាយញឹកញយឡើង និងខ្លាំងឡើងអំពី "រដ្ឋាភិបាល" នៃ សឺង ង៉ុកមិញ និង សុផានុវង្ស។ ការប្ដូរបេសកកម្មគ្នា ក៏មានឡើង, ហើយរហូតមានទៅដល់សេចក្ដីថ្លែងការណ៍នៃ "រដ្ឋមន្ត្រីក្រសួងការបរទេស" នៃរបប សឺង ង៉ុកមិញ, កេមុនី, ដែលតវ៉ានៅថ្ងៃ ២០ មីនា ១៩៥៤ ទល់នឹង "អន្តរាគមន៍អាមេរិកាំងនៅស្រុកខ្មែរ" ហើយចោទព្រះចៅសីហនុ —ដែលបានទទួលពីបារាំងនូវឯករាជ្យនៃប្រទេស នៅខែតុលា ១៩៥៣— ថាជាតុក្កតា។

»ប៉ុន្តែការបង្កើត "រដ្ឋាភិបាលតស៊ូខ្មែរ" ជាការបន្តុបបន្ថែងពេក។ ប្រជាជនខ្មែរភាគច្រើននៅស្មោះត្រង់នឹងស្ដេចខ្លួន ហើយនិងស្ដាប់តាមទំនៀមទំលាប់ខ្លួន។ ហើយគេឃើញច្បាស់ពេកនូវដៃបរទេស —យួន— ដែលនៅពីក្រោយសេចក្ដីប្រកាសនិងសុន្ទរកថាទាំងឡាយនោះ ដែលជាញឹកញយ បានត្រូវបកផ្ទាល់ពីភាសាយួន។ ប្រទេសកម្ពុជា និងប្រទេសលាវពុំព្រមអង្គុយនៅ ហ្សឺណែវ ក្រោយតុ ជាមួយ "រដ្ឋាភិបាលបីសាច" ទាំងនោះ ហើយប៉ុកកុម្មុយនិស្ត ក៏បន្ទន់ខ្លួនតាម។ ក្នុងរយៈពេលតិចជាងពីរខែ, របនាសម្ពន្ធរដ្ឋាភិបាលវៀតមិញនៅកម្ពុជាបាត់អស់ ដូចជាត្រូវមន្តអាគម។ សឺង ង៉ុកថាន់ ធ្វើសកម្មភាពម្ដងទៀតជាមួយស្ដេចខ្លួន —ប៉ុន្តែគ្រាន់តែដើម្បីជាប់ប្រឡាក់ម្ដងទៀតក្នុងការប៉ុនប៉ងរំលំស្ដេចនេះ ក្នុងឆ្នាំ ១៩៥៩។ សឺង ង៉ុកមិញ —តើមនុស្សនេះមានមែន ឬមួយជា ស៊ីវ ហេង?— ចេញទៅជាមួយកងឯកភាពវៀតមិញ ដែលត្រឡប់ទៅវៀតណាមខាងជើងវិញ ក្រោយកិច្ចព្រមព្រៀងឈប់ច្បាំងគ្នា។ ស.ប.វ. ចាញ់ទឹកទីមួយនៅកម្ពុជា។

»ការភ័ន្តច្រឡំដែលបានធ្វើ ត្រូវតែកែឡើងវិញ។ មែនទែនទៅ ការកែនេះនឹងស្រួលធ្វើជាងការ ដែលគេមានសង្ឃឹមទុកនៅហាណូយ។ ដោយបានទទួលទុក្ខបុកម្នេញខ្លាំងពីអ្នកជិតខាងមិនកុម្មុយនិស្ដខ្លួនពីរនាក់ គឺប្រទេសវៀតណាមខាងត្បូងនិងថៃ, កម្ពុជាឃើញលេចចេញមកវិញ នូវឧបាយកលរួមតាមទំនៀមទំលាប់ ដែលធ្វើឲ្យខ្លួនបានបាត់ឯករាជ្យកាលពីអតីតៈ។ កម្ពុជាក៏បែរកេទ្វារទាំងអស់ដែលបើកឲ្យខ្លួនរួចពីគ្រោះថ្នាក់... ហើយហាណូយជាទ្វារមួយដែរ។ ស.ប.វ. លែងមានព្រំដែនជាមួយនឹងកម្ពុជាហើយ, ហើយសារពត៌មានខ្លួននិងវិទ្យុខ្លួនការពារប្រយោជន៍ខ្មែរ, មិនមែនដោយសេចក្ដីស្រឡាញ់ពិសេសលើរាជាធិបតេយ្យខ្មែរទេ, ប៉ុន្តែពីព្រោះអ្នកជិតខាងរបស់ខ្មែរជាសម្ពន្ធមិត្តយ៉ាងជិតស្និទ្ធនឹងសហរដ្ឋអាមេរិក។ សម្ដេចសីហនុ —ស្ដេចនឹងដាក់រាជ្យឲ្យឪពុកម្ដាយនៅឆ្នាំ ១៩៥៥— លែងទទួលការជេរត្មះតិះដៀលជាអល្ងដ្ឋីពីវិទ្យុហាណូយហើយ, ផ្ទុយស្រឡះទៅវិញ។ ប៉ុន្តែសម្ដេចនៅចាំ ហើយខ្មែរក៏មិនភ្លេច ការចូលលុកលុយវៀតមិញក្នុងប្រទេសកម្ពុជា នៅខែកុម្ភៈ ១៩៥៤,

*ហើយកិច្ចការទាក់ទងដែលមានឡើងរវាងភ្នំពេញ និង ហាណូយ គ្រាន់តែសមរម្យ, ឥតលើសពីនេះឡើយ។ អ្នកតំណាងផ្លូវទូតខ្មែរម្នាក់ទៅនៅឯ សាយហ្គន ប៉ុន្តែគ្មានតំណាងខ្មែរនៅហាណូយទេ (រហូតដល់ឆ្នាំ ១៩៦០)។*

*»ដល់ខែវិច្ឆិកា ១៩៥៨ ទើបគណៈប្រតិភូយួនខាងជើងមួយមកដល់ភ្នំពេញ, ប៉ុន្តែមុននឹងមកដល់ ខ្មែរបានប្រាប់រួចស្រេច ហើយយ៉ាងច្បាស់ថា ក្នុងពេលឥឡូវនេះឥតមានរឿងទទួលស្គាល់រដ្ឋាភិបាលហាណូយទេ។ កិច្ចចចារនៅត្រឹមតែ ធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយ ចុះថ្ងៃ ២០ វិច្ឆិកា ដែលតាមនោះ ស.ប.វ. នឹងផ្ដល់ដល់កម្ពុជានូវធ្យូង, ជាតិជីហ្វូសស្វាត, អំបោះ និងក្រណាត់ ហើយនិងតែ ប្ដូរគ្នានូវផលិតផលកសិកម្ម។ កិច្ចព្រមព្រៀងនេះមាននិយាយដែរអំពី "ការសេរីម" នឹងធ្វើឲ្យមានទំនាក់ទំនងខាងប្រៃសណីយ៍ និងខាងវប្បធម៌, ដូច្នេះគេដូចជាអាចឲ្យយោបល់បញ្ចប់ថា ស.ប.វ. បានលែងអនុវត្តន៍ —យ៉ាងហោចណាស់ក៏ក្នុងពេលឥឡូវនេះដែរ— នូវនយោបាយយកកម្ពុជាធ្វើ "រណប", ព្រោះនយោបាយនេះបានខូចខាតម្ដងទៅហើយ។»*

(ចប់ការដកស្រង់)

*ដូច្នេះតាំងពីឆ្នាំ ១៩៥០ រចនាសម្ពន្ធពេញលេញជាគណៈកម្មការ-ក្របខ័ណ្ឌ (ប៉ាំងកាងស៊ី) បានត្រូវធ្វើឡើងពេញរាជាណាចក្រ, ហើយនៅក្រោមការត្រួតត្រារបស់វរសេនីយឯក ង្វៀង ថាត់សឹង (ហៅ ហនៈលៈគិរី) នៃកងទ័ពវៀតមិញ[៥]។ ចំណែកខាងរបៀបរៀបចំពួកក្រុមក្រោមមកទៀត បានត្រូវចំឡងឥតខ្ចោះពីគំរូ វៀតមិញ នៅវៀតណាម[៦]។ នៅថ្ងៃ ១១ មិថុនា ១៩៥០ សាលាមួយសំរាប់អប់រំនយោបាយដល់ពួកក្របខ័ណ្ឌ (ថ្នាក់ឃុំ, ស្រុក) បានត្រូវបង្កើតឡើងនៅភូមិកាគនិរតី ដែលមានឈ្មោះថា សាលាអាចារ្យ ហែម-ចៀវ (!)។ សិស្សជំនាន់ទីមួយមាន ១៤០ នាក់ ដែលមកពីគ្រប់ទីតំបន់នៃរាជាណាចក្រ[៧]។ នៅក្នុងតំបន់ "រំដោះ" មួយ, កងទ័ពប្រជាជនខ្មែររំដោះ (APKL, មើលភាគទី៤, រឿងក្នុងប្រទេស) សម្ពោធនៅថ្ងៃ ១៤ សីហា ១៩៥០ សាលាទាហានមួយសំរាប់បង្វឹកបង្វឹនខ្មែរ ដែលចូលក្នុងជួរខ្លួន (ជំនាន់ទី១ មាន "ប៉ាកទីសង់" ខ្មែរ ១០០ នាក់)។*

*រដ្ឋាភិបាលមួយសុទ្ធសាធ ដែលមានគ្រប់ក្រសួងបំរើការទាំងអស់ (នគរបាល, ឃោសនាការ, សេដ្ឋកិច្ច, សិក្សាធិការ ។ល។ មកតាំងទីនៅតាកែវ។ ក្នុងសន្និសីទនៅ ហ្សឺណែវ ឆ្នាំ១៩៥៤, ផាំយ៉ាំងដុង, ថ្វីត្បិតតែខ្លួនពូកែថ្លៃងស៊ុំ, ឥតបានធ្វើឲ្យគេយល់ព្រមទទួលខ្មែរ-វៀតមិញ នៅក្រោយតុជំនុំទេ។ ពេលដែលវៀតមិញដកទ័ពខ្លួនចេញពីកម្ពុជា[៨] ស្របតាមកិច្ចព្រមព្រៀង ហ្សឺណែវ, ក្របខ័ណ្ឌខ្មែរទាំងអស់ដ៏មានតម្លៃ ព្រមទាំងក្មេងខ្មែររាប់ពាន់នាក់ទៀត ដែលចូលចិត្ត ឬពុំសូវចូលចិត្តនឹងខ្លួន ក៏វៀតមិញពុំបានភ្លេចដឹកជញ្ជូនទៅដែរ។ ខ្មែរទាំងពាន់នាក់នេះ (៥០០០ នាក់, តាមប៉ែណាហាម៉ែល), ដែលបានទៅតាម ឬទៅដោយគេបង្ខំជាមួយវៀតមិញ ក្នុងការត្រឡប់មកផ្ទះរបស់ពួកនេះ, បានត្រូវគេបញ្ជូនមកកម្ពុជាវិញ ក្រោយព្រឹត្តិការណ៍នៃខែមីនា ១៩៧០។*

*ខ្មែរក្រហមពុំដែលបានត្រូវបញ្ចុះបញ្ចូលដោយជនជាតិយួនទេ, ប៉ុន្តែដោយជនជាតិដែលមានស្បែកដូចខ្លួន គឺពួកខ្មែរ-វៀតមិញ។ ទុក្ខសោកខ្មែរយើងទាំងអស់ គឺនៅត្រង់ហ្នឹង!*

---

*សំនួរទី៤ ៖*

*បើដូច្នេះ តើមុខការ និង ឥទ្ធិពលរបស់ប្រទេសចិន*

*ក្នុងមហាវិយោគខ្មែរ នៅត្រង់ណាខ្លះ? (ទំព័រ ៩០)*

# អធិប្បាយ

(១) ពាក្យ "ថូ" ក្នុងភាសាយួន ប្រែមកថាអ្នកស្រុកដើម។ ដូច្នេះខ្មែរកម្ពុជាក្រោមក៏បានត្រូវហៅថា ថូ ដែរ។ សព្វថ្ងៃនេះ ជនជាតិថូ ជាក្រុមអាណិកជនធំជាងគេនៅវៀតណាមខាងជើង (៤០០ ០០០ នាក់) តាម ជន ម៉ាក់អាលិស្ទែ (ក្នុង "អាណិកជនស្រុកភ្នំនិងវៀតណាម ៖ កូនសោមួយបើកបង្ហាញសង្គ្រាម ឥណ្ឌូចិន", ហាងបោះផ្សាយ ពីទែ គុនស្ដាខ៊), ពួកថូបានប៉ុនប៉ងជណ្ដើមយកបល្ល័ង្កយួនដែរ, នៅសត-វត្សរ៍ទី ១៦, តែយកពុំបាន។ បន្ទាប់ពីការបះបោរនេះ, យួនបានសម្រេចលាយបញ្ចូលបង្កាត់ពួកថូ ដោយនាម៉ឺនទាំងឡាយដែលនៅត្រួតត្រាថូ។ នាម៉ឺនយួនទាំងនោះបានរៀបការជាមួយស្រីថូ ហើយកូនខ្លួនដែលកើតបន្តបន្ទាប់មក, ហៅថា ថូ-ទី, បានកជាវណ្ណៈវរជនថូ។ ពេលដែលបារាំងមកដល់ឥណ្ឌូចិន ពួកថូ, ដែលលក្ខណៈរូបកាយដូចខ្មែរណាស់ (ជាពិសេសសម្បុរស្រឯម), បានបាត់អស់រលីងនូវភាសាដើមរបស់ខ្លួន។

(២) បារាំងបានយល់ដោយយឺតណាស់ដល់សារៈសំខាន់នៃអាណិកជនជាតិផ្សេងៗ។ ឧត្ដមនាវី ដាហ្សង់ល្យើ, ក្រោយពេលមកដល់កូសាំងស៊ីនបន្តិចមក, បានបង្កើតតំបន់ស្វយ័តពួកម៉ូយខាងត្បូង (ZAMS) ដើម្បីឲ្យបារាំងត្រួតត្រាជនជាតិនេះដោយផ្ទាល់ (កិច្ចដែលអាមេរិកាំងបានធ្វើដែរក្រោយមក)។ ការរៀបចំកងធ្លាក់ក្នុងពួកអាណិកជនបានត្រូវទុកដាក់ឲ្យក្រុម "កុម្ម៉ង់ដូ" ចំរុះឆ័ត្រយោង (GCMA) ដែលខ្លួនឯងនៅក្រោមបង្គាប់ក្រសួងសម្ងាត់បារាំង (SDECE)។ ប៉ុន្តែការរៀបចំទាំងនេះបានត្រូវធ្វើឡើងដោយយឺតណាស់ (១៩៥៣ - ៥៤)។

(៣) មេវៀតមិញនៃ ណាម-បូ (យួនខាងត្បូង) ឈ្មោះ ង្វៀង-ប៊ិន, ហៅ "ភ្នែកមួយ", ឈ្មោះដែលបានត្រូវស្គាល់ខ្លាំងពីទាហានបារាំងដែលបាន "វាយ" នៅឥណ្ឌូចិន។ ល្បីល្បាញដោយសារកេរ្ដិ៍កម្មរបស់ខ្លួន, ឈ្មោះនេះបានធ្វើឲ្យ "យ៉ាប់" ដល់កងឯកភាពបារាំងនៅវៀតណាមខាងត្បូង។ មនុស្សអានាធិបតេយ្យ, ង្វៀង-ប៊ិន បានត្រូវព្រមានដោយ ហូជីមិញ។ ប្រហែលជាខ្លួនពុំបានធ្វើតាមបញ្ជាខ្លះរបស់ ហូ, ឈ្មោះនេះបានត្រូវគេកោះហៅទៅវៀតណាមខាងជើងនៅឆ្នាំ ១៩៤៦។ តាមផ្លូវរបស់ខ្លួន, ង្វៀង-ប៊ិន បានត្រូវទទួលបង្គាប់ឲ្យឆ្មៀងចូលមកដីខ្មែរ ដើម្បីរិះរកផ្លូវចេញចូលមួយសម្រាប់ដឹកអាវុធទិញពីស្រុកសៀម។ ង្វៀង-ប៊ិន បានងាប់ដោយចៃដន្យក្នុងការពួនស្ទាក់របស់កងឯកភាពខ្មែរមួយនៅក្រចេះ (មើលទស្សនាវដ្ដី "អ៊ិសស្តូរីយ៉ា", លេខពិសេស ២៤)។ គេអាចចាត់ទុកឆ្នាំ ១៩៤៦ ជាឆ្នាំដែលវៀតមិញចាប់ចូលខ្លួនមកប្រទេសកម្ពុជា។

(៤) បងប្អូនភៀសខ្លួនយើងនិងយោធាខ្មែរក្រហមបានបញ្ជាក់ថា ខ្លួនឥតដែលបានឮនិយាយពីលទ្ធិ ម៉ាក្សទ្បេនីន ឬ ម៉ៅ សេទុង ទេ។ "ពាក្យគណបក្សកុម្មុយនិស្តខ្មែរ" ទើបនឹងចេញពីមាត់ ប៉ុល-ពត កាលខ្លួនទៅប៉េកាំង។ ក្នុងសៀវភៅដែលគាត់សរសេរ ១៥ ឆ្នាំមុនខ្មែរក្រហមចូលមកយកអំណាច, ប៊ែណាហ្វល់ បញ្ជាក់អំពីវត្ថុដែលក្នុងស្រុកខ្មែរសព្វថ្ងៃនោះហៅថា "អង្គការ"។ អង្គការនេះមិនជាអ្វីក្រៅពី "គណបក្ស" ក្នុងសម័យខ្មែរវៀតមិញទេ។ ចម្លងតាមគំរូដើមនៃរបៀបរៀបចំ ខ្មែរ-វៀតមិញ, រចនាសម្ពន្ធនៃអង្គការខ្មែរក្រហមជារបៀប "រុក្ខជាតិដុះ" (គល់, មែក, ធាង ។ល។) ៖




ម ហា ជ ន

( "គ" ស្គាល់តែ "ខ", ឥតស្គាល់ "ក" ទេ)

ការប្រឌិតរបស់វៀតមិញនេះ មានប្រសិទ្ធិភាពឥតល្ហោយ ដើម្បីលាក់បាំងនឹងការពារពួកអ្នកដឹកនាំខ្លួនៗ ដើម្បីដឹងថាតើបញ្ជាមួយមកពីណា, ហើយអ្នកណាជាអ្នកឲ្យ, គេត្រូវរុករកតាមមែកធាងទាំងអស់ៗ ការនេះធ្វើទៅពុំរួចឡើយ ព្រោះជនទាំងឡាយឥតស្គាល់គ្នាទាំងអស់ទេ, ហើយម្យ៉ាងទៀតដោយមានក្រុមតិញទន្ទឹមមួយដែល "បានការ" ណាស់ៗ បើបញ្ជាមួយពុំបានត្រូវធ្វើតាម, អង្គការស្រណុករកទេកន្លែងណាដែលបានថ្ធោះធ្លោយៗ យើងបានឃើញហើយនូវរបៀបដែលមេខ្មែរក្រហមពិតប្រាកដ បានប្រើដើម្បីលាក់បាំងខ្លួនៗ ពេលដែលបានអំណាចហើយ "គណបក្ស" គ្រាន់តែធ្វើខ្លួនឲ្យទៅជាអង្គការ, ហើយរបៀបរៀបចំតាមខ្មែរ-វៀតមិញ ក្នុងភូមិភាគនានា យកឈ្មោះថា "គណៈក្តាប់រដ្ឋអំណាច" ដែលជារចនាសម្ពន្ធតាមភូមិភាគនៃអង្គការៗ របៀបរៀបចំដើមនៃវៀតមិញ បានត្រូវអ្នកនិពន្ធ ហ្វីលីព ដឺវីល្លែ រ៉ាយរ៉ាប់ដូចតទៅនេះ ៖

"ដើម្បីផ្សព្វផ្សាយកម្មវិធីខ្លួននិងលាតសន្ធឹងឥទ្ធិពលខ្លួន, វៀតមិញមានតាំងពីដើមកំណើតខ្លួននូវរបៀបរៀបចំនៃគណបក្សកុម្មុយនិស្តឥណ្ឌូចិនៗ ង្វៀង អាយក្វឹក (ហូជីមិញ) ឆ្លៀតឱកាសនៃសមាជនៅក្រុង ទ្សិន ទ្សី (Tsin Tsi) ដើម្បីធ្វើការរៀបចំសាជាថ្មីៗ ច្បាស់ណាស់ការណ៍ដែលវៀតមិញ, ដូចជាគណបក្សកុម្មុយនិស្តឥណ្ឌូចិនដែរ, នឹងអាចធ្វើការលើទឹកដីឥណ្ឌូចិនបានតែដោយលាក់បំពួនខ្លួនៗ ដូច្នេះ ត្រូវតែខិតខំរៀបចំអង្គការមួយដែលលាក់ខ្លួនបាន, ខំរិះរករបៀបថ្មីនិងឧបាយថ្មី ដែលសម្រួលតាមកម្មវិធីថ្មីនេះៗ ការអត់ធ្មត់យ៉ាងស្វិតស្វាញរបស់ ង្វៀង អាយក្វឹក បានទទួលផលក្នុងពេលនេះហើយៗ អ្នកដឹកនាំទាំងអស់នៃគណបក្សបានយល់ដល់ភាពអសារបង់នៃកិច្ចការទាំងឡាយដែលឥតបានត្រូវរៀបចំឲ្យហ្មត់ចត់មិនឲ្យធ្លោយឡើយៗ ហើយជោគជ័យនៃវៀតមិញ នឹងមកអំពីការណ៍ដែល, ក្នុងរយៈពេល៤ឆ្នាំ, ខ្លួននឹងរៀបចំសម្រួលឥតស្រាកស្រាន្តនូវអង្គការរបស់ខ្លួន ទៅតាមសកម្មភាពថ្មីណាដែលនឹងអាចធ្វើបាន, ហើយនិងពង្រីងឥតឈប់ឈរនូវប្រសិទ្ធិភាពនៃពួកក្រុម ដែលមានមកហើយៗ តើអង្គការនេះជាអ្វី?"

"នៅខាងក្រោមមាន សែលលុល (ជី-បូ), តូចៗទេ, ប្រមូលផ្តុំមនុស្សដែលមានអ្វីជាមួយគ្នាខ្លះហើយ ដូចជារបររកស៊ី, ឋានៈសង្គម ឬ កន្ទ្រាញជាតិសាសន៍ៗ សែលលុលទាំងឡាយ, ដែលមាន

*មុខងារបង្កពួកក្រុម, មានសភាពបិទជិតណាស់, ដោយឥតទាក់ទងគ្នាពីមួយទៅមួយឡើយ។ មានតែមេសែលលុលទេ ដែលទាក់ទងជាមួយអ្នកនៅខាងលើខ្លួន"។*

*"សែលលុលនិមួយៗ នៅក្នុងរចនាសម្ពន្ធមួយ (ដែលយើងនឹងហៅថា "ត្រង់ឡើងលើ") ដែលតាមធម្មតាសកម្មភាពលាតសន្ធឹងពេញលើប្រទេសវៀតណាម ហើយដែលប្រមូលផ្តុំសែលលុលដូចគ្នាទាំងអស់ គឺថាដែលមនុស្សក្នុងនោះមានរបររកស៊ីដូចគ្នា, ឋានៈសង្គមដូចគ្នា ឬ កន្ទ្រាញជាតិសាសន៍ដូចគ្នា។ រចនាសម្ពន្ធ "ត្រង់ឡើងលើ" ទាំងនោះមានតាមធម្មតានូវឃើហៅតែមួយថា "សមាគមយួនដើម្បីស្រោចស្រង់ប្រទេស" (វៀតណាម គឺ ក្វឹកហួយ)។ នៅឆ្នាំ ១៩៤៤, វៀតមិញបានហៅមកឡិនឡ៊ី នូវពួកតំណាងសមាគមយុវជន (ថាញ់ញៀន), នារី (ភូនូ), កម្មករ (កុងសាង), យោធា (ប៊ិនស៊ី)។ នៅក្នុងមណ្ឌលនិមួយៗ, ការដឹកនាំរចនាសម្ពន្ធ "ត្រង់ឡើងលើ" និមួយៗនៅក្នុងបន្ទុកគណៈកម្មការជាប់ឆ្នោតមួយដែលរើសយកមេខ្លួនឯង។"*

*"ប៉ុន្តែសេចក្តីត្រូវការនៃការតយុទ្ធទាំងខាងទាហាន ទាំងខាងនយោបាយ នាំឲ្យប្រមូលផ្តុំមធ្យោបាយទាំងអស់សម្រាប់ឃោសនានៃសែលលុលនានាតាមភូមិភាគនិមួយៗ, ហើយដាក់ក្រោមបញ្ជាការមេតែម្នាក់ ដែលតាំងឡើងដោយគណៈកម្មការកណ្តាលនៃគណបក្ស ហើយដែលធ្វើតាមការណែនាំនៃគណៈកម្មការនេះ។ ដូច្នេះ, ចំពោះមុខតំណាងទាំងអស់ដែលបានជាប់ឆ្នោត, ការចាត់ចែងសកម្មភាពមានតែមួយហើយដែលមកពីលើ។"*

*"ដោយហេតុនេះស្រុកយួនបានត្រូវចែកជាបី "បូ", ឬប្រទេស (បាក់បូ ឬតុងកឹង, ទ្រុងបូ ឬអណ្ណាម, ណាមបូ ឬកូសាំងស៊ីន)។ បូ និមួយៗ បានត្រូវបែងជាខេត្ត, ស្រុក, ឃុំ, ភូមិនិងសង្កាត់។ បំណែងទឹកដីនិមួយៗ នៅក្រោមការទទួលខុសត្រូវនៃគណៈកម្មការមួយដែលមានប្រតិភូជាប់ឆ្នោតបោះដោយពពួករចនាសម្ពន្ធ "ត្រង់ឡើងលើ", ហើយគណៈកម្មការនេះត្រូវដឹកនាំដោយមេម្នាក់ដែលតាំងដោយមេបំណែងទឹកដីខាងលើ។ មេគណៈកម្មការមានអំណាចសម្រេចការយ៉ាងទូលំទូលាយ ហើយឲ្យឱវាទតែម្នាក់ឯងលើបំណែងទឹកដីទាំងមូល, ពួកសមាជិកគណៈកម្មការគ្រាន់តែមានសម្លេងក្នុងការពិគ្រោះ ហើយធ្វើជាអ្នកប្រតិបត្តិ។"*

*"របៀបរៀបចំនេះហ្មត់ចត់ណាស់នៅក្នុង "បូ" និមួយៗ, មេបំណែងទឹកដីទាំងឡាយត្រូវធ្វើឲ្យស្របតាមការបញ្ជានិងកិច្ចណែនាំនៃអាជ្ញាធរដែលនៅលើខ្លួន។ ផ្ទុយទៅវិញ, ដោយមកពីការពិបាកខាងការទាក់ទង, "បូ" ទាំងបីបានទទួលស្វ័យភាពធំល្មមដែរ។ មែនទែនទៅ, មធ្យោបាយធ្វើឥទ្ធិពលចំៗទៅលើគណបក្ស នៅក្នុងកណ្តាប់ដៃគណៈកម្មការ "បូ" ទាំងបី, ដែលមានសេរីភាពល្មមដែរ ចំពោះមុខគណៈកម្មការកណ្តាល។ ជាពិសេសគណៈកម្មការណាមបូមានសេរីភាពស្ទើរតែពេញទី ក្នុងសកម្មភាពខ្លួន, ដោយព្រមទទួលពីគណៈកម្មការកណ្តាលតែកិច្ចការណែនាំទូទៅខាងនយោបាយ។"*

*"ជាបង្ហើយ, នៅពីលើអង្គការវៀតមិញ មានគណៈកម្មការកណ្តាលដែលដាក់លទ្ធិតែមួយនឹងកិច្ចចាត់ចែងតែមួយឲ្យតាម។" (ចប់ដកស្រង់)*

*ផ្ទឹមទៅនឹងរចនាសម្ពន្ធវៀតមិញ, របៀបរៀបចំរដ្ឋបាលនៃកម្ពុជាប្រជាធិតេយ្យ, លើកលែងតែកន្ទែងបំផ្លែកខ្លះ, ដូចគ្នាបេះបិទ។ ហើយមានអ្នកនិពន្ធខាងបស្ចឹមប្រទេសជាច្រើនដែលសរសេរប្រាប់គេឯងថាជារបៀបរៀបចំថ្មី !*

(៥) អន្តការលើសម័យនោះ គឺ វរៈសេនីយ៍ឯក ឡៀង ថាន់សឺង ដែលបានយកឈ្មោះខ្មែរ (បាលីទៅទៀត!) ជា "ហនៈលៈគីរី"។ ក្រោយសន្និសីទហ្សឺណែវ ឡៀង ថាន់សឺង, ដែលបានបញ្ចេញមុខខ្លួន, នាំទ័ពវៀត មិញចូលស្រុកកំណើតវិញ។

(៦) តាំងពីកាលនោះ, មិនត្រឹមតែរបៀបរៀបចំទេ ដែលបានត្រូវចម្លងតាមវៀតមិញ, ប៉ុន្តែរបៀបនិយាយ —ភាសា— កុម្មុយនិស្តខ្មែរមួយក៏បានត្រូវបង្កើតដែរ។ ប៉ុន្តែដោយគ្មានឯកសារ, យើងពុំអាចអះអាង បានទេថា "ភាសា" ខ្មែរក្រហមសព្វថ្ងៃ នៅតែដដែលដូចកាលពីសម័យវៀតមិញ។

(៧) ពួក ប៉ុល ពត, នួន ជា, នង សួន, សូ ភឹម ។ល។ គឺមិនសុទ្ធតែបានរៀននៅសាលានេះ?

(៨) លោក លន់ នល់ បានត្រូវរាជរដ្ឋាភិបាលដាក់ឲ្យនៅអមគណៈកម្មការអន្តរជាតិ (សេ.អ៊ី.សេ.), ដើម្បី ត្រួតមើលការចាកចេញនៃទ័ពវៀតមិញ។ គាត់បានឮគេនិយាយជាលើកដំបូងពីឈ្មោះ "កែវ មាស" ម្នាក់ដែលនឹងអាចជាអ្នកតំណាងនៅ ហ្សឺណែវ នៃ "រដ្ឋាភិបាល" របស់ សឺង ង៉ុកមិញ, បើសិនជារដ្ឋាភិ បាលនេះនឹងបានត្រូវទទួលស្គាល់ពីមហាអំណាច។ ក្រោយមកទៀតឈ្មោះ "កែវ មាស" នេះបានត្រូវ គេឮម្តងទៀត, ថាជាអ្នកបង្កើតម្នាក់នៃគណបក្សប្រជាជន។ ប៉ុន្តែគ្មាននរណាបានឃើញមុខ ឬរូបថត កែវ មាស នេះទេ។

## *បើដូច្នេះ តើមុខការ និងឥទ្ធិពលរបស់ប្រទេសចិន ក្នុងមហាវិយោគខ្មែរ នៅត្រង់ណាខ្លះ?*

*ម្ចូករបៀបចិនដែលខ្មែរក្រហមពាក់, វត្តមាននៃអ្នកឯកទេសចិននៅកម្ពុជា, ការដេញពួកទូតរុស្ស៊ីចេញនៅខែមេសា ១៩៧៥ សុទ្ធតែជាការណ៍តូចៗ ដែលធ្វើឲ្យអ្នកខ្លះស្មាន រហូតដល់ថាប្រជាជនខ្មែរ បានត្រូវចិនយកទៅធ្វើការពិសោធន៍ "សង្គមថ្មី" មួយ។ សេចក្ដីឧបមាទាំងនេះ, ដែលមកពីការរវើរវាយរករឿងអស្ចារ្យដើម្បីឧស្សាហកម្មលក់ពត៌មាន, បានត្រូវបញ្ចេញមកដោយរហ័សពេក។ គេគ្រាន់តែទស្សនាក្នុងពេលនេះនូវអធិករណ៍ទី២ ក្នុងរឿងខ្មែរ រវាងចិននិងយួន។*

*អធិករណ៍ទី១ បានកើតឡើងកាលពីសន្និសីទនៅហ្សឺណែវក្នុងឆ្នាំ ១៩៥៤[១], ដែលជាការណ៍បង្ហាញប្រទេសចិនជាមហាអំណាចមួយលើក្ការអុកនយោបាយអន្តរជាតិ។ តាំងពីក្នុងសុន្ទរកថារបស់ខ្លួនលើកទី១ នៅហ្សឺណែវ, ផាំ យ៉ាំងដុង ដែលតាំងខ្លួនជា "អ្នកនាំពាក្យនៃប្រជាជនទាំងបីនៃឥណ្ឌូចិន", ទាមទារឲ្យខ្មែរវៀតមិញ (រដ្ឋាភិបាលនៃ សឺង ង៉ុកមិញ) និងពួកតំណាង ប៉ាថេតឡាវ មានសិទ្ធិចូលរួមក្នុងសន្និសីទ, សំណូមដែលរដ្ឋមន្ត្រីបារាំង ហ្ស៊ែក ប៊ីដូ ប្រញាប់ប្រញាល់នឹងទាត់ចោល[២]។ បញ្ហាភាពតំណាងនៃខ្មែរ-វៀតមិញ និង ប៉ាថេតឡាវ ដែល ផាំ យ៉ាំងដុង បំផុសឡើងនេះ ធ្វើឲ្យសន្និសីទចេញពុំរួច។ ការស្រោចស្រង់លើកនេះ មកពីប្រទេសចិន។ ថ្ងៃ ៨ ឧសភា, ជូអេនឡាយ ដែលតាំងពីដើម គាំទ្រកិច្ចការរបស់ ផាំ យ៉ាំងដុង ស្រាប់តែធ្វើឲ្យគេដឹងថាគាត់បានសំរេចចិត្តយល់ឃើញដូច ហ្ស៊ែកប៊ីដូ, គឺថា បំបែកចំណោទប្រទេសវៀតណាម, ឆាកនៃចំបាំងរវាងយួនគ្នាឯង, ពីចំណោទប្រទេសលាវនិងប្រទេសកម្ពុជា ដែលបានត្រូវលុកលុយដោយ "ទ័ពបរទេស" (អានថា "ទ័ពវៀតមិញ")[៣]។ អន្តរាគមន៍នៃ ជូអេនឡាយ មិនត្រឹមតែបានធ្វើឲ្យសន្និសីទចេញរួចទេ, ថែមទាំងបានជួយកម្ពុជាឲ្យរួចខ្លួនពីការបដិវត្តន៍មួយដែលច្បាស់ជាបង្ហូរឈាមខ្លាំងដូចសព្វថ្ងៃនេះ, ការបដិវត្តន៍ដែលជាទីបារម្ភនៃរដ្ឋលេខាធិការអាមេរិកាំង ជនហ្វូសស្ទែដល្លឹស[៤]។*

*ការខ្ទាចក្រែង ខ្មែរ-វៀតមិញ លេបយកប្រទេស បានចាប់គ្រវាត់ សម្ដេចសីហនុ ទៅក្នុងរង្វង់ដៃចិន។ ហ្សឺណែវបានបង្ហើយឯករាជ្យនៃកម្ពុជា, បាន់ឌុង មួយឆ្នាំក្រោយមក (១៩៥៥) ចាប់បង្ខិតចិននិងខ្មែរឲ្យជិតស្និទ្ធគ្នា[៥]។ ពីសន្និសីទនៅ បាន់ឌុង ទៅខែមីនា ១៩៧០, ១៥ឆ្នាំកន្លងទៅ ដែលពោរពេញទៅដោយការទំនាក់ទំនងល្អរវាងចិននិងខ្មែរ, ពិតមែនតែល្អក់ពណ៌ដោយព្យុះសង្ឃរាខ្លះៗ សំរស់ច្លាស់គ្នានឹងការកំញើញ ជាអាវុធធំនៃការទូតរបស់ចិននៅអាស៊ីអគ្នេយ៍។ ព្រមគ្នានឹងការរក្សាទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលក្នុងស្រុក, ចិនមិនត្រឹមតែគាំទ្រពីក្រៅទេ ថែមទាំងចិញ្ចឹមពួកចូលព្រៃធ្វើបដិវត្តន៍ទៀត, ហើយប្រើពួកនេះសំរាប់កំញើញនិងព្រមាន — ការប្រើប្រាស់ដែល "បានការ" យ៉ាងខ្លាំង។ កិច្ចការទូតរបៀបនេះ បានត្រូវអនុវត្តន៍ក្នុងប្រទេសថៃ, ភូមា និង ម៉ាឡេស៊ី។ មានតែប្រទេសកម្ពុជាទេ ដែលផុតពីក្បួននេះ។ ដូច្នេះមែន កន្ទែងដ៏ប្រណីតសំរាប់ប្រទេសចិន ក្នុងនយោបាយក្រៅប្រទេសនៃកម្ពុជា, នយោបាយមិនទុកចិត្តរបស់ខ្មែរលើសហភាពសូវៀត និងការជាប់ទំនាក់ទំនងល្អរវាងកម្ពុជានិងសហរដ្ឋអាមេរិក (អាន "ទំនាក់ទំនងខ្មែរ-ចិន") ធ្វើឲ្យអត់អំពើដល់ការបង្កើត និងចិញ្ចឹមក្រុមចូលព្រៃធ្វើការបដិវត្តន៍ [៦]។*

*ខែមីនា ១៩៧០ បើកយុគថ្មីមួយនៃសាវតាប្រទេសកម្ពុជា ៖ យុគនៃការចុះឱនថយ, យុគនៃសេចក្ដីទុក្ខសោក បន្ទាប់ពីការងើបមុខឡើងក្នុងរយៈពេលមួយយ៉ាងខ្លី។ ស្នូរកាំភ្លើងជាលើកដំបូង, ដែលបានហៅមហាកោ*

*លាហលមួយ មកផ្តាច់ជីវិតខ្មែរទាំងលាននាក់នេះ បានត្រូវបាញ់ឡើង, ចូរយើងកុំភ្លេច, ដោយពួកយួនកុម្មុយនិស្តៗ បន្ទាប់ពីបានបង្ហូរឈាមខ្មែរ និងបំផ្លាញសម្បត្តិរដ្ឋខ្មែរ, យួនបានធ្វើឲ្យសង្គ្រាមលុកលុយរបស់ខ្លួនក្លាយទៅជាសង្គ្រាមរវាងខ្មែរគ្នាឯងៗ ល្បិចយុទ្ធសាស្ត្រដ៏ឆ្នើមនេះ ត្រូវធ្វើឡើងជា ៥ ដំណាក់ ដូចតទៅ ៖*

១- *ការវាយយ៉ាងរហ័សមួយ, ដោយក្រុម "កុម្មុំងដូ" បំផ្លាញ, កំទេចភាគច្រើននៃសំណង់ជាមូលដ្ឋានសង្គមកិច្ច—សេដ្ឋកិច្ចនៃប្រទេស ៖ ស្ពាន, ថ្នល់, មន្ទីរពេទ្យ, សាលា, រោងចក្រ ។ល។*

២- *ធ្វើឲ្យកាន់កាប់បានយ៉ាងប្រាកដនូវភូមិភាគ មេគង្គ-លើ ទាំងមូល[៧] ដោយវាយបំភ័ន្តយ៉ាងខ្លាំង ក្នុងភូមិភាគខាងត្បូង និងភាគកណ្តាលនៃប្រទេស (កំពង់ស្ពឺ, កំពត, កំពង់ធំ, កំពង់ឆ្នាំង ។ល។[៨]*

៣- *ការបោះបង់ចោលភូមិភាគ មេគង្គ-លើ ទាំងមូលដោយកងទ័ពខ្មែរ តាំងពីពេលចាប់ផ្តើមសង្គ្រាម, បើកឲ្យយួនក្តាប់ទុកប្រើប្រាស់នូវថាមពលមួយដ៏ធំខាងមនុស្ស និងខាងកសិកម្ម ដែលនឹងបង្កើតឡើងនូវកងឯកភាពលើកដំបូងនៃទ័ពខ្មែរក្រហម[៩]។*

៤- *បញ្ជូនមកមាតុភូមិវិញនូវហ្វូងពួកខ្មែរ-វៀតមិញ ដែលស្រែកឃ្លាន ១៥ ឆ្នាំមកហើយ, ហើយដែលចាំតែកំទេច និងបង្ហូរឈាមដល់ "កម្ពុជាកញ្ជះចក្រពត្តិអាមេរិកាំង"។ ពួកនេះ, ដែលសព្វថ្ងៃកាន់អំណាចមែនទែននៅកម្ពុជា, ជាអ្នកកសាងកងទ័ពខ្មែរក្រហម[១០]។*

៥- *ធ្វើឲ្យសង្គ្រាម "ទៅជាខ្មែរ" ដោយថយចេញបន្តិចម្តងៗ ដើម្បី, ជាលើកបង្ហើយ, គ្រាន់តែកាន់នាទីជាអ្នកផ្តល់អាវុធយុទ្ធភ័ណ្ឌ (មកពីស្រុកចិន កាត់តាមផ្លូវលំហូជីមិញ)[១១]។*

*ចំណែកខាងប្រទេសចិនវិញ, ដោយខ្លួន* ឃើញ *ជាងយួន២៥ ឆ្នាំ, មានតែដៃទទេ ពេលដែលព្រឹត្តិការណ៍មីនា ១៩៧០ ផ្ទុះឡើងៗ ចៃដន្យនៃព្រហ្មលិខិតបានយកសម្តេចសីហនុ ទៅបោះចោលឯប៉េកាំងៗ បានកូនអុកមួយយ៉ាងសំខាន់, ចិនខំរត់ឲ្យទាន់ពេលវេលាវិញៗ បានទៅជាឪពុកធម៌នៃការបដិវត្តន៍ខ្មែរ, ចិននិងយួនធ្វើកិច្ចតម្រូវគ្នាមួយ តាមសន្និសីទលើកទី២ នៃប្រជាជនឥណ្ឌូចិន (មេសា ១៩៧០)។ ប្រទេសចិនមានសីហនុ (ដែលមានប្រជាប្រិយភាពក្នុងប្រជាកសិករខ្មែរ និងក្នុងអន្តរជាតិ) ហើយមានអាវុធយុទ្ធភ័ណ្ឌ។ ប្រទេសយួនមានពួកខ្មែរ-វៀតមិញ ហើយឲ្យទ័ពខ្លួនធ្វើអន្តរាគមន៍ផ្ទាល់[១២]។ ចិនគាំទ្រសីហនុជាមួយនឹងរាជរដ្ឋាភិបាលរួបរួមជាតិនៃកម្ពុជា, ខ្មែរ-វៀតមិញចូលជាមួយសីហនុ, ដើម្បីបំរើប្រយោជន៍ខ្លួនបាន, ក្នុងរណសិរ្សរួបរួមជាតិនៃកម្ពុជា* (FUNK, *ស្រដៀងគ្នានឹងបងរបស់ខ្លួន,* FNUK)*។ "ព្រះអង្គគិតតែរឿងទូតទៅរួចនៅឯក្រៅចុះ, ទុកឲ្យយើងខ្ញុំធ្វើសង្គ្រាមរំដោះក្នុងស្រុក", ខ្មែរក្រហមប្រាប់សម្តេចសីហនុៗ ផ្លូវទៅកាន់ជ័យជំនះអាចនៅវែងឆ្ងាយ, ដោយមកពីចំបាំងនៅវៀតណាម និងការកាន់ក្តាប់នៃអាមេរិកាំងៗ ក្រោមសំបកក្រៅមួយ ដែលបង្ហាញការត្រូវគ្នាឥតល្អៀង, ពួកទាំងពីរក្រុម (សីហនុ និង ខ្មែរ-វៀតមិញ) រៀបចំខ្លួន ដើម្បីកំចាត់គ្នាទៅវិញទៅមកៗ*

*រឿង "វ៉ាទែហ្គេត" និងការធ្លាក់នៃ និចសុន មករុញព្រឹត្តិការណ៍ឲ្យរមៀលយ៉ាងលឿនៗ ជ័យជំនះមកដល់ឆាប់ជាងបានគ្រោងទុកៗ បីខែមុនពេលខ្មែរក្រហមចូលភ្នំពេញ, សម្តេចសីហនុ, ច្បាស់ណាស់ ជាមួយពរសព្វសាធុការនៃជូអេនឡាយ, បង្ហាញសមាសភាពនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងនៃរណសិរ្ស "ហ្វុង"ៗ សីហនុឥតបាន "ដាក់" ទេ ឈ្មោះ សាឡុត សរ, អៀង សារី, សុន សេន ។ល។.... អ្នកដឹកនាំខ្មែរក្រហម "ធ្វើនៅវៀតណាម" ៖*

*រដ្ឋមន្ត្រីទីមួយ ៖ ប៉ែន នុត*
*ឧបរដ្ឋមន្ត្រីទីមួយ, រដ្ឋមន្ត្រីការពារប្រទេស និងអគ្គមេបញ្ជាការកងកម្លាំងរំដោះ ៖ ខៀវ សំផន*
*រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, សហករណ៍និងអភិវឌ្ឍន៍សហគមន៍ ៖ ហ៊ូ យន់*
*រដ្ឋមន្ត្រីក្រសួងឃោសនាការ ៖ ហ៊ុយ នឹម*
*រដ្ឋមន្ត្រីក្រសួងការបរទេស សារិន ឆាក*
*រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងកែទំរង់តុលាការ ៖ នរោត្តម ភូរិស្សរា*
*រដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល ៖ ជួន ជឿន*
*រដ្ឋមន្ត្រីក្រសួងសាធារណការ, ទូរគមនាគមន៍ និងស្ថាបនាឡើងវិញ តូច ភឺន*
*រដ្ឋមន្ត្រីក្រសួងធម្មការនិងសង្គមកិច្ច ៖ ជូ ចេត*
*រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិនិងហិរញ្ញវត្ថុ ៖ កុយ ធួន*
*រដ្ឋមន្ត្រីក្រសួងផ្គត់ផ្គង់អាវុធយុទ្ធភ័ណ្ឌ ៖ ម៉ែន សាន*

*ឧបរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខ៖ សុក ធួក*
*ឧបរដ្ឋមន្ត្រីក្រសួងការពារប្រទេស ៖ គង់ សុផល*
*ឧបរដ្ឋមន្ត្រីក្រសួងឃោសនាការ ៖ ទីវ អុល*

*ឧបរដ្ឋមន្ត្រីការបរទេស ៖ រស់ ចិត្តធម៌*
*ឧបរដ្ឋមន្ត្រីការបរទេស ៖ វ៉ាន់ ពីនី*

## ការិយាល័យនយោបាយ នៃ រណសិរ្ស ៖

*ប្រធាន ៖ ប៉ែន នុត ។ សមាជិក ៖ ចៅ សេង, ជួង សំអុល, ចាន់ យូរ៉ាន់, ជា សាន, ហ៊ូ យន់, ហ៊ុយ នឹម, ហួត សម្បត្តិ, ខៀវ សំផន, សារិន ឆាក, ជួន មុម។*

*ការបោកចេញយ៉ាងលឿននៃអាមេរិកាំង ទុកកន្លែងកាន់អំណាចឲ្យនៅទំនេរក្នុងក្រុងភ្នំពេញ។ ដោយដឹងខ្លួនថាពុំអាចត្រួតត្រាខ្មែរក្រហមបាន, ហើយដោយខ្លាចចូលអន្ទាក់ខ្មែរក្រហមភ្លាមក្រោយពេលបានជ័យជំនះ, សីហនុ, បន្ទាប់ពីបានដឹងថា "រាជ" ធានីធ្លាក់ហើយ, សុំឲ្យចិនបញ្ជូនទ័ពស្រួចមួយកងទៅភ្នំពេញ។ ជូអេនឡាយដែលចង់លេងសន្ទឹកបៀ "សីហនុ" ខ្លួនឲ្យ "អស់ដៃ", យល់ព្រមតាមៗ ក្នុងភាពជ្រួលច្របល់នៃជ័យជំនះ, ទាហានចិនទាំងកប៉ាល់ហោះចុះដីនៅពោធិចិនតុង[១៣]។ ប៉ុន្តែខ្មែរក្រហម, ដែលប្រហែលជាបានដឹងអស់អំពីកលឧបាយទាំងឡាយ, ចាត់វិធានការណ៍បានមុនៗ ការប្រណាំងដណ្តើមអំណាច រុញខ្មែរក្រហមឲ្យធ្វើអំពើឃោរឃៅព្រៃផ្សៃទីមួយក្រោយពេលខ្លួនមកដល់ភ្នំពេញ ៖ ការជន្លៀសបណ្តាជនចេញពីរដ្ឋធានី, ហើយក្រោយមកចេញពីទីប្រជុំជនទាំងអស់[១៤]។ ពិតហើយ គឺនៅក្នុងក្រុងទាំងឡាយដែលបណ្តាជន និងអ្នកភៀសខ្លួនទាំងលាននាក់រង់ចាំទទួល "សម្តេចឪ" និងសន្តិភាពជាទីទន្ទឹងមើល, ដែលខ្មែរក្រហមអាចធ្លាក់ក្នុងអន្ទាក់វិញ។ សម្ពន្ធភាព ជូអេនឡាយ-សីហនុ ចាញ់ "ទឹក" ទីមួយ។ រដ្ឋមន្ត្រីទីមួយចិននឹងផ្លាស់ល្បិច ហើយប្រើសំរស់របស់ខ្លួនដើម្បីល្បងដាក់ សីហនុ ក្នុងអំណាចវិញ[១៥]។*

*ពេលសម្តេចសីហនុជាន់ដីភ្នំពេញវិញ នៅថ្ងៃ ៩ កញ្ញា ១៩៧៥, អតីត:បិតាឯករាជ្យជាតិ អាចតែបង្ហូរទឹកភ្នែកជោកថ្ពាល់ ដោយឃើញរាជធានីមួយអស់មនុស្សរលីង ហើយពុំកិនអស់ខ្មែររាប់ម៉ឺននាក់ដែលគេសម្លាប់យ៉ាងព្រៃផ្សៃ។ "កូនចៅជាទីស្នេហា" ឥតបាននៅទីនេះទេ ដើម្បីថ្វាយសំរែកជយោដ៏គឹកកងរំពងដូចកាលមុនៗ សុបិននឹងបានធ្វើដូចឧត្តមសេនីយ៍ ដឹហ្គោល ឥតបានទៅជាការពិតទេ។ រដ្ឋមន្ត្រីទីមួយ ជូអេនឡាយស្លាប់នៅថ្ងៃ ៧ មករា ១៩៧៦, បុរសដែលខ្លួនគាំពារ (សម្តេចសីហនុ) បាន "លាឈប់" ហើយជំនួសដោយ*

*ខៀវ សំផន នៅថ្ងៃ ៥ មេសា។ សន្ទឹកបៀ "សីហនុ" លែងលេងកើតហើយ។ ប្រទេសចិនដែលនឹងក្រាញទំ តោងប្រទេសកម្ពុជាតទៅទៀត នៅសល់តែផ្លូវមួយទេ ៖ ចូលជាមួយខ្មែរក្រហម*[១៦]*។*

---

*សំនួរទី៥ ៖ ដំណើរដ៏មានជោគជ័យនៃ ប៉ុល ពត ទៅប៉េកាំង*
*អាចជាសញ្ញានៃការបន្ទន់របបខ្មែរក្រហមឬទេ? តើថាប្រជាជន*
*ខ្មែរអាចនឹងបានស្រាកស្រាន្តខ្លះទេ?* *(នៅទំព័រ ១០៣)*

---

# អធិប្បាយ

(១) ក្រោយឆ្នាំ ១៩៤៩ ឆ្នាំនៃការប្រកាសសាធារណរដ្ឋប្រជាមានិតចិន, សង្គ្រាមនៅវៀតណាមកាន់តែឆេះឆួលខ្លាំងឡើងៗ បារាំង, ជួយដោយអាមេរិកាំង, គាំទ្របាវដាយៗ ប្លុកចិន-រុស្ស៊ី គាំទ្រហូជីមិញៗ បារាំងម្នាក់បានសរសេរថា សង្គ្រាមនោះទំពារលេបសិស្សសាលាសាំងសៀទាំងជំនាន់ៗ នៅប៉ារីស រដ្ឋាភិបាលធ្លាក់មួយឡើងមួយ បន្តបន្ទាប់គ្នា តាមល្បឿនមួយដែលគេមិនដែលឃើញៗ រីឯនៅឥណ្ឌូចិន ពួកឧត្តមសេនីយបានត្រូវផ្លាស់ប្តូរយ៉ាងរន្ថើន ៖ រ៉ីវែ (១៩៤៩), ដឺឡាត្រ (១៩៥០), សាឡង់ (១៩៥២), ណាវ៉ារ (១៩៥៣)ៗ នៅដើមឆ្នាំ ១៩៥៤, មហាអំណាចទាំង៤ អាមេរិកាំង-អង់គ្លេស-បារាំង-សហភាពសូវៀត ដែលជំនុំគ្នានៅ ប៊ែឡាំង ដើម្បីពិភាក្សារឿងធ្វើឲ្យប្រទេសអាល្លឺម៉ង់មានតែមួយវិញ និងរឿងសន្តិសុខទ្វីបអឺរ៉ុប, ឥតបានរកឃើញការដោះស្រាយអ្វីឲ្យពិតប្រាកដទេ ប៉ុន្តែសម្រេចនៅថ្ងៃ ១៨ កុម្ភៈ ថានឹងជួបគ្នាម្តងទៀតនៅ ហ្សឺណែវៗ ការជួបគ្នានេះដើម្បីជជែកពីរឿងកូរ៉េ, និងពីការធ្វើឲ្យមានសន្តិភាពឡើងវិញនៅឥណ្ឌូចិន ដោយនឹងមានហៅប្រទេសចិនទៅចូលរួមផងៗ ថ្ងៃ ១៣ មិនា, វៀតមិញវាយសម្រុកចូលមូលដ្ឋាន "ត្រង់សេ" ដៀនបៀនភូៗ កំពុងតែពេញប្រយុទ្ធដណ្តើមដៀនបៀនភូ, កងវរៈសេនាតូចវៀតមិញពីរ ចូលក្នុងប្រទេសកម្ពុជាត្រង់ខេត្តស្ទឹងត្រែង ហើយថ្ងៃ ២ មេសា, កាន់កាប់ទីប្រជុំជនវើនសៃៗ

ប៉ុន្តែតាំងពីខែវិច្ឆិកា ១៩៥៣ ប្រទេសកម្ពុជាជាប្រទេសឯករាជ្យៗ បើចំណោទខ្មែរឥស្សរៈ ដូចជាបានដោះស្រាយហើយដោយការចុះចូលនៃមេជាច្រើន (ក្នុងទិសពាយ័ព្យនៅសល់មនុស្សជាច្រើនរយនាក់ទៀត ដែលនៅជាមួយ សឺង ង៉ុកថាន់), នៅសល់ចំណោទកងទ័ពប្រជាជនខ្មែររំដោះ (APKL) និងចំណោទវៀតមិញទៀតៗ បន្ទាប់ពីការឈ្លានពានវៀតមិញលើកនេះ, ព្រះចៅ នរោត្តម សីហនុ, ដោយព្រមព្រៀងជាមួយឧត្តមសេនីយ ណាវ៉ារ, កាន់បញ្ជាការកងកម្លាំងបារាំង-ខ្មែរ ហើយសុំជំនួយផ្ទាល់ពីសហរដ្ឋអាមេរិកៗ ស្ថានការណ៍សឹកនៅ ដៀនបៀនភូ ធ្វើឲ្យអាមេរិកាំងបារម្ភៗ រដ្ឋលេខាធិការ ដល្លឹស, បុរសតួឯកនៅសម័យនោះ, ជាអ្នកចង់ជួយបារាំងដោយផ្ទាល់ៗ ប្រធានាធិបតី អាយស៊ិនហូវើ, ដោយខ្លាចប្រតិកម្មចិនដូចនៅកូរ៉េ, ស្ទាក់ស្ទើរនឹងជួយដោយផ្ទាល់ៗ ប៉ុន្តែសម្រេចទៅ, នៅថ្ងៃ ៤ មេសា ១៩៥៤, អាយស៊ិនហូវើ យល់ព្រមតាម ដល្លឹស, ឲ្យតែអ្នកនេះបបួលប្រទេសអង់គ្លេស ចូលរួមប្រយុទ្ធបាន ហើយនិងពន្យល់ប្រទេសអាស៊ីទាំងឡាយ ឲ្យព្រមរួបរួមគ្នាក្នុងសម្ពន្ធកិច្ចមួយទល់នឹងកុម្មុយនិស្តៗ ក្នុងកំឡុងតែបីបួនថ្ងៃ, ដល្លឹស សួរយោបល់ដល់តំណាងគ្រប់ប្រទេសទាំងអស់ដែលទាក់ទងនឹងការណ៍នេះ ៖ អង់គ្លេស-បារាំង-អូស្ត្រាលី-នូវែលហ្សេឡង់-ហ្វីលីពីន-ថៃ-កម្ពុជា-លាវ និងវៀតណាមៗ អង់គ្លេសមិនព្រមជ្រលក់ខ្លួនក្នុងការផ្សងព្រេងនេះ, ប្រទេសបារាំង, ដែលសេដ្ឋកិច្ចដុនដាបខ្លាំងព្រោះតែសង្គ្រាមនេះ, រកការដោះស្រាយមួយតាមកិច្ចចារៗ

ថ្ងៃ ២៦ មេសា, ដូចបានគ្រោងទុក, សន្និសីទអំពីរឿងកូរ៉េបើកឡើងនៅហ្សឺណែវៗ ថ្ងៃ ៧ ឧសភា, ក្រោយការតស៊ូចំនួន ៥៥ ថ្ងៃ, ដៀនបៀនភូ ធ្លាក់ក្នុងកណ្តាប់ដៃវៀតមិញៗ ចាប់តាំងពីថ្ងៃបន្ទាប់, ៨ ឧសភា, ការប្រជុំទីមួយអំពីឥណ្ឌូចិនក៏ចាប់ផ្តើមឡើងៗ ក្នុងនោះមានប្រតិភូនៃប្រទេសបារាំង (ប៊ីដូ រួចមក ព្យែរ ម៉ង់ដេសហ្វ្រង់), នៃប្រទេសសូវៀត (ម៉ូឡូតូវ), នៃប្រទេសអង់គ្លេស (អង់តូនី អេដែន), នៃប្រទេសចិន (ជូអេនឡាយ), នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (ផាំ យ៉ាំងដុង), នៃប្រទេសកម្ពុជា (ទេព ផន), នៃសាធារណរដ្ឋវៀតណាមនិងលាវៗ រដ្ឋាភិបាលអាមេរិកាំងបញ្ជូនអ្នក

*សន្តេតការណ៍ម្នាក់មក, បេដែលស្និទ។ ថ្ងៃ ៧ សីហា, កិច្ចព្រមព្រៀងឈប់បាញ់គ្នានៅកម្ពុជា បាន ត្រូវធ្វើឡើង។*

*(២) តបនឹង ផាំ យ៉ាំងដុង ដែលថា "ប្រជាជនខ្មែរនិងប៉ាថេតឡាវ រួបរួមយ៉ាងស្និទ្ធជាមួយប្រជាជនវៀតណាម, បានប្រយុទ្ធដោយវីរភាពដើម្បីសេរីភាព, ឯករាជ្យ, ឯកភាព, ប្រជាធិបតេយ្យ... វត្តមាននៃតំណាងប្រទេសខ្មែរ និងតំណាងប៉ាថេតឡាវ និងជាការធានាមួយថែមទៀតចំពោះជោគជ័យនៃសន្និសីទ ...", ហ្សុកប៊ីដូ ឆ្លើយថា "សេចក្តីស្នើរបស់វៀតមិញទូលំទូលាយ, ហើយក្នុងនោះហេតុការណ៍ទាំងប៉ុន្មានលាយឡំគ្នា។ លោក ដុង ចង់បង្ហាញរូបភាពទូទៅមួយដែលទាក់ទងនឹងប្រទេសទាំងបីនៃឥណ្ឌូចិន ៖ លាវ-កម្ពុជា និងវៀតណាម។ ប៉ុន្តែក្នុងបញ្ហាទាំងនេះមានមួយភាគដែលចេញពីសមត្ថកិច្ចរបស់គាត់...។ ហូជីមិញ ទាត់ចោលកាលពីឆ្នាំ ១៩៤៦ នូវសហព័ន្ធឥណ្ឌូចិន។ តើឥឡូវគាត់ចង់ដាក់សហព័ន្ធនេះមកវិញ ដើម្បីប្រយោជន៍វៀតមិញឬអ្វី? ប្រទេសបារាំងនឹងយល់ព្រមដកទ័ពខ្លួនចេញពីកម្ពុជានិងលាវ បើវៀតណាមដកទ័ពខ្លួនដែរ..." (ក្នុងសារពត៌មាន ឡឺម៉ុងដ៍ នៃថ្ងៃ ១៥ ឧសភា ១៩៥៤)។*

*(៣) បញ្ហាភាពតំណាងនៃរដ្ឋាភិបាលរបស់ សឺង ង៉ុកមិញ នៅក្នុងសន្និសីទ, ដែលបានកកាយឡើងដោយ ផាំ យ៉ាំងដុង, ធ្វើឲ្យមានការជជែកគ្នាយ៉ាងតឹងមាត់រវាងគណៈប្រតិភូខ្មែរ (លោក ទេព ផន, សម សារី, នង គិមនី) នឹងគណៈប្រតិភូសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ប្រឆាំងនឹងសំណុំរបស់លោក ផាំ យ៉ាំងដុង, លោក ទេព ផន ថ្លែងថា ៖ "រដ្ឋាភិបាលតែមួយនៃប្រទេសកម្ពុជា, ដែលត្រឹមត្រូវតាមច្បាប់ គឺរាជរដ្ឋាភិបាល, ព្រោះថាគឺរដ្ឋាភិបាលនេះដែលបានទទួលឯករាជ្យពីប្រទេសបារាំង"។ ដើម្បីទំធ្វើឲ្យបានការគាំទ្រពេញទំហឹងនៃប្លុកចិន-សូវៀត, ផាំ យ៉ាំងដុង បញ្ចេញការសំអាងអំពី "ចក្រពត្តិនិយមអាមេរិកាំង" ដែលកំពុងគំរាមកំហែងសន្តិភាពនៃអាស៊ីអាគ្នេយ៍ (ដុង តម្រង់ទៅកិច្ចរៀបចំនៃអាមេរិកាំងដើម្បីតម្លើង សេអាតូ —ដែលនឹងទទួលហត្ថលេខាបង្កើតនៅថ្ងៃ ៨ កញ្ញា ១៩៥៤)។ ចម្លើយនៃលោក ទេព ផន ៖ "គាំពារប្រទេសខ្ញុំទល់នឹងការឈ្លានពានបរទេស ជាកិច្ចត្រូវនឹងទំនៀមទំលាប់នៃអាមេរិក, អ្នកការពារសេរីភាព។ សហរដ្ឋអាមេរិកឥតចង់បង្កើតអាណាចក្រអាណានិគមមួយទេ។ គេគ្រាន់តែចង់ផ្តល់មកយើងនូវមធ្យោបាយត្រឹមត្រូវ ដើម្បីរក្សាទុកឯករាជ្យយើង, និងដើម្បីទប់ប្រទេសយើងកុំឲ្យទៅជាអាណានិគមនៃចក្រពត្តិកុម្មុយនិស្ត!"។ ម៉ូឡូតូវ "ប្រធានរួម" និង ជូ អេនឡាយ គាំទ្រសំណុំនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម, ប៉ុន្តែទាំងពីរនាក់បានព្រមគ្នានឹងគិតគូរ បំបាត់ទំនាស់នេះដោយជជែកគ្នាផ្ទាល់, ជាឯកជន"! ថ្ងៃ ១៦ មិថុនា, តាមការបោត់ថែងនៃ ជូ អេនឡាយ, កិច្ចសន្ទនាមួយរវាង ជូ និង អេដែន (ប្រធានរួម) បានធ្វើឡើងដែលនឹងពិគ្រោះអំពីអនាគតនៃកម្ពុជា។ ដោយស្នើ "ថ្នូរ" មួយជាមួយ អេដែន, ជូ ទទួលគោលគំនិតនៃការដកចេញពីកម្ពុជានូវទ័ពបរទេសទាំងអស់ (ទាំងវៀតមិញ ទាំងបារាំង), ហើយទទួលស្គាល់រាជរដ្ឋាភិបាល ជារដ្ឋាភិបាលត្រូវច្បាប់តែមួយនៃកម្ពុជា, ប៉ុន្តែបកមកវិញ, ទាមទារកុំឲ្យប្រទេសកម្ពុជា (និងលាវ) ក្លាយទៅជាមូលដ្ឋានទ័ពអាមេរិកាំងក្នុងពេលអនាគត។ ជាមួយនឹងការស្នើរបស់ ជូ, អេដែនក៏ប្រញាប់ទៅជួបប្រតិភូបារាំង ហ្សុក ប៊ីដូ។ ក្នុងរឿងនេះ, ជាការណ៍មួយច្បាស់ណាស់ ដែលប្រយោជន៍បារាំង និងប្រយោជន៍ចិន ស្របចូលជាមួយគ្នា, ព្រោះថាប្រសិនបើមានសហព័ន្ធឥណ្ឌូចិនមួយក្រោមការដឹកនាំនៃវៀតមិញ, ជាការណ៍ធម្មតាដែលបារាំងនឹងអស់ឥទ្ធិពលរបស់ខ្លួន ហើយចិនក៏ពិបាកសន្ទឹងឥទ្ធិភាពខ្លួនមកលើកម្ពុជានិងលាវដែរ។*

*ថ្ងៃ ១៨ កក្កដា, "ប្រទេសធំ" ទាំង៤ ពិភាក្សាគ្នាទៀត។ ជូ អេនឡាយ ស្នើដូចមុនម្តងទៀត ហើយទារពី អេដែន នូវការធានាយ៉ាងមធ្យត់មួយលើប្រទេសកម្ពុជា ដែលគាត់មិនចង់ឃើញទៅជា*

មូលដ្ឋានអាមេរិកាំង។ អេដែន ឲ្យការធានា "គ្រោះថ្នាក់ការ" របស់គាត់ទៅ ជូ ហើយបញ្ជាក់ថាកម្ពុជានិង ឡាវ នឹងទៅជាប្រទេសអព្យាក្រឹត ដែលនឹងត្រូវការពារដោយប្រទេសបារាំង ក្នុងក្របខ័ណ្ឌនៃសហ ភាពបារាំង។ ដល់ត្រង់នេះ, សន្និសីទក៏ជិតចប់ហើយ។ ការជួបគ្នាដើម្បីចុះហត្ថលេខាបង្ហើយបានត្រូវ សន្មត់ធ្វើនៅថ្ងៃ ២០ កក្កដា ម៉ោង ៩ យប់ ក្នុងលំនៅនៃ អង់តូនី អេដែន។ គណៈប្រតិភូខ្មែរ, ដែលមក ដល់យឺត ២ ម៉ោង (អ្នកបើកឡានបានវង្វេងផ្លូវក្នុងហ្សឺណែវ), គ្រាប់តែពុំព្រមចុះហត្ថលេខាលើកិច្ច ព្រមព្រៀងបង្ហើយ។ ទេព ផន ពុំព្រមចុះហត្ថលេខាយ៉ាងដាច់ណាត់ ដរាបណាមាត្រា ៣-៤ ដែលតាម មតិគាត់, ធ្វើឲ្យមានគ្រោះថ្នាក់ក្នុងអនាគតដល់សន្តិសុខនៃកម្ពុជា, មិនបានត្រូវកែប្រែជាមុនទេ។ ម៉ូឡូ តូវ, តឹងចិត្តស្ទើរទប់ពុំបាន, ព្រមទទួលធ្វើអាជ្ញាកណ្តាលដើម្បីបញ្ចប់បង្ហើយឲ្យបានរហ័ស។ នេះជាមា ត្រាទាំងឡាយដែលជាប់ចោទ ហើយនិងការកែប្រែ ៖

ក- កិច្ចព្រមព្រៀងបង្ហើយចែងថា ប្រទេសកម្ពុជាមានប្រភេទជាប្រទេស "អព្យាក្រឹត", ឥត ជ្រៀតជ្រែកក្នុងកិច្ចការអន្តរជាតិមួយណាឡើយ នៅពេលវេលាណាក៏ដោយ។ លើរឿងនេះ, កម្ពុជាសន្យាថានឹងមិនចូលក្នុងសម្ពន្ធកិច្ចយោធាណា ដែលមិនត្រឹមត្រូវតាមធម្មនុញ្ញនៃអង្គ ការសហប្រជាជាតិឡើយ, ប៉ុន្តែទាមទារឲ្យមានសិទ្ធិដាក់មូលដ្ឋានទ័ពបរទេស នៅពេលណា ដែលខ្លួនយល់ថាមានគ្រោះថ្នាក់។ ទោះបី ផាំ យ៉ាំងដុង តវ៉ា ប្រឆាំងយ៉ាងខ្លាំងក៏ដោយ, ម៉ូឡូតូវ ព្រមឲ្យកែមាត្រានេះ, ការណ៍ដែលធ្វើឲ្យប្រតិភូទាំងអស់ភ្ញាក់គ្រប់គ្នា។

ខ- វៀតមិញសុំឲ្យការនាំអាវុធយុទ្ធភ័ណ្ឌនិងបុគ្គលិកយោធាបរទេសចូលមកកម្ពុជា ធ្វើនៅត្រង់ កន្លែងខ្លះនៃប្រទេស, ដែលគេកំរិតទុកមុន។ កម្ពុជាចង់ឲ្យការនាំចូលនេះធ្វើនៅកន្លែងណាក៏ ដោយនៃព្រំដែនខ្លួន។ ត្រង់នេះសន្និសីទក៏យល់ព្រមតាមសំណុំខ្មែរដែរ។

គ- លើបញ្ហានៃការថយចេញនៃទ័ពវៀតមិញ និងការដកអាវុធចេញពីកងខ្មែរ-វៀតមិញ, ផាំ យ៉ាំងដុង ស្នើឲ្យពួកខ្មែរដែលបានធ្វើសហប្រតិបត្តិការជាមួយវៀតមិញនៅមានសិទ្ធិកាន់អា វុធ ហើយផ្តុំគ្នានៅក្នុងភូមិភាគកំណត់ទុកមួយ រហូតដល់ពេលបោះឆ្នោតជាតិ (ដុង ចង់ចែក កម្ពុជាជាពីរដូចដែលសន្និសីទបានធ្វើចំពោះវៀតណាម)។ បន្ទាប់ពីការតវ៉ាប្រឆាំងយ៉ាងខ្លាំង នៃគណៈប្រតិភូខ្មែរ, វៀតមិញស្នើឲ្យមានគណៈកម្មការចំរុះមួយដែលមានតំណាងនៃរាជរដ្ឋា ភិបាលនិងតំណាងនៃរដ្ឋាភិបាល សឺង ង៉ុកមិញ, ហើយដែលនឹងដោះស្រាយបញ្ហានៃការ បញ្ចូលកងខ្មែរវៀតមិញមកក្នុងសង្គមជាតិវិញ, ហើយការសំរេចទាំងឡាយនៃគណៈកម្មការ ចំរុះនេះ នឹងត្រូវត្រួតពិនិត្យដោយគណៈកម្មការអន្តរជាតិមួយខាងកិច្ចត្រួតត្រា។ ដោយឥត វេលនឹងប្រតិកម្មពេញដោយកំហឹងនៃពួកប្រតិភូវៀតមិញ, ម៉ូឡូតូវ អារកាត់ជាលើកបង្ហើយ ដោយទាត់ចោលរឿងទទួលស្គាល់រដ្ឋាភិបាលនៃ សឺង ង៉ុកមិញ។ ជាទីបញ្ចប់, កិច្ចព្រម ព្រៀងបង្ហើយបានទទួលហត្ថលេខាក្នុងពេលអធ្រាត្រជ្រៅ (ម៉ោង ២ ភ្លឺ) នៃថ្ងៃ ២១ កក្កដា ១៩៥៤។ កិច្ចព្រមព្រៀងនេះជាសញ្ញាបង្ហាញផ្លូវបត់មួយនៃដំណើរសាវតាប្រទេសកម្ពុជា ។ (លោក ហ្សង់ សូវែល, ដែលពេលនោះជារដ្ឋទូតបារាំងនៅក្រុង ប៉ែកាំង, សមាជិកនៃគណៈ ប្រតិភូបារាំង, រ៉ាយរ៉ាប់ក្នុងទស្សនាវដ្តី "អ៊ិសស្តូរីយ៉ា" (លេខពិសេស ២៥) ថា៖ "ជាលើក ទីមួយ ហើយប្រហែលជាមានតែម្តងគត់ក្នុងជីវិត ការងាររបស់គាត់ជាអ្នកធ្វើសន្និសីទ, រដ្ឋ មន្ត្រីការបរទេសនៃសហភាពសូវៀត (ម៉ូឡូតូវ), ចំពោះមុខលក្ខណៈប្រយុទ្ធខ្លាំងនៃសហការី

*គាត់ខាងកម្ពុជា, លោក សម សារី, ក៏ផ្ទាយសំណើចហើយយល់ព្រមតាមម្តងទៀតជាលើកបង្ហើយៗ”)*

(៤) *“ដរាបណាសត្រូវរួមរបស់យើង, វៀតមិញ, មិនទាន់បរាជ័យទេ —ហើយព្រះអង្គជ្រាបច្បាស់ថាវាមានសមត្ថភាពនឹងបោសកំចាត់ចោលរាជាធិបតេយ្យខ្មែរ ព្រមទាំងទំនៀមទំលាប់ដ៏ត្រកាលរបស់ប្រទេសព្រះអង្គ, អរិយធម៌ដ៏ចាស់យូរអង្វែង ហើយនិងប្រជាធិបតេយ្យដ៏ក្មេងរបស់ព្រះអង្គ— ដរាបណាគ្រោះថ្នាក់ដ៏ធំនេះ, ដែលអាចជាគ្រោះថ្នាក់ដល់ជីវិតរបស់ (ប្រទេស) ព្រះអង្គ, មិនទាន់កំចាត់ចេញបានទេ, យើងមិនអាចធ្វើឲ្យបារាំងអស់ចិត្ត អស់កម្លាំងបានឡើយៗ”, រដ្ឋលេខាធិការបរទេសអាមេរិកាំង, ដល្លឹស, ឆ្លើយទៅព្រះចៅ សីហនុ, កាលស្តេចទាមទារឯករាជ្យនៅឆ្នាំ ១៩៥៣, (មើលភាគទី៤, ទំព័រ ៦០)ៗ ការបារម្ភរបស់ដល្លឹស, ចំពោះពេលសព្វថ្ងៃនេះ, ទៅជាទំនាយមួយៗ*

(៥) *សន្និសីទនៅបាន់ឌុង (មេសា ១៩៥៥) ជាព្រឹត្តិការណ៍ខ្លាំងដែលបានធ្វើឲ្យសម្តេចសីហនុ សំរេចគូសត្រាខ្សែនយោបាយក្រៅប្រទេសនៃកម្ពុជាៗ ក្នុងកិច្ចសន្ទនាផ្សេងៗ ជាឯកជនទ្វេភាគី និងត្រីភាគី ជាមួយ ជូ អេនឡាយ និង ផាំ យ៉ាំងដុង លើអនាគតនៃប្រទេសកម្ពុជា, សីហនុបាន “បាក់ចិត្ត” លើបុរសទាំងពីរនេះ ដែលចេះគួរសមយ៉ាងប្រណីតៗ ទាំងពីរនាក់ស្នើទៅ សីហនុ នូវការប្តូរទំនាក់ទំនងគ្នា ដែលយកមូលដ្ឋានលើនយោបាយមិនជ្រៀតជ្រែកគ្នាមួយ! ការស្នើនេះចាក់ចំចំណុចខ្សោយនៃសម្តេចសីហនុ ដែល, ដោយបានបណ្ឌិត នេហរុ ខ្សឹបពន្យុះផង, កំពុងរកទេសន៍ផ្សាយបញ្ចសីលា!*

(៦) *ពីឆ្នាំ ១៩៥៨ ទៅ ១៩៦៧, ប្រទេសកម្ពុជានិងប្រទេសចិន ប្រាស្រ័យទាក់ទងគ្នាយ៉ាងមនោរម្យៗ សីហនុ ឆ្លៀតឱកាសពី “មិត្តភាពចិន” នេះ ដើម្បីកំចាត់បច្ចាមិត្រខាងឆ្វេងៗ កិច្ចនេះបានធ្វើទៅរួចដោយចិន “ធ្វើមិនដឹង”ៗ ពួកកុម្មុយនិស្តខ្មែរ, ក្នុងការរត់គេចពីការបង្ក្រាបរបស់ សីហនុ, បានតម្រង់ទៅទ្វារតែមួយដែលខ្លួននៅសល់ ៖ វៀតណាមខាងជើងៗ ការមិនរវីរវល់នៃចិនលើពួកកុម្មុយនិស្តខ្មែរ មកពីមូលហេតុសេដ្ឋកិច្ចដែរ ៖ បើក្នុងកម្ពុជាមានក្រុមកងឆ្មក់កុម្មុយនិស្ត, សម្តេចសីហនុ ច្បាស់ជាចូលជាមួយអាមេរិកាំងៗ ដូច្នេះចិនត្រូវតែជួយក្នុងពេលជាមួយគ្នាដល់រណសិរ្សបី ៖ យួន លាវ និងខ្មែរៗ ការណ៍នេះ សេដ្ឋកិច្ចចិនសម័យនោះពុំអាចទទួលបន្ទុកបានឡើយៗ ចំពោះអ្នកដឹកនាំចិន, បើកុម្មុយ-និស្តទទួលជ័យជំនះនៅវៀតណាម, ជាការណ៍ធម្មតាដែលកម្ពុជានិងលាវរអិលចូលរង្វង់សង្គមនិយមៗ គឺគ្រាន់តែបញ្ហាពេលវេលាទេៗ ការយល់ឃើញនេះក៏ស្របគ្នានឹងយោបល់សម្តេចសីហនុដែរ ដែលខំរកមិត្តភាពចិន ដើម្បីចៀសវាងការប្រទូស្តរ៉ាយក្នុងពេលខាងមុខជាមួយ “កុម្មុយនិស្តចិន—យួន” (ពាក្យហៅជាញឹកញយដោយ សីហនុ)ៗ*

(៧) *តាំងពីថ្ងៃដំបូងនៃសង្គ្រាម, ពួកយួនខាងជើងត្រួតត្រាភូមិភាគ មេគង្គ-លើ ទាំងអស់ ហើយបិទផ្លូវជាតិលេខ ៧ បាននៅត្រង់ទន្លេបិទ! ឧត្តមសេនីយ លន់ នល់ បានស្លុតចិត្តយ៉ាងខ្លាំង ពេលដែលគេប្រាប់ថាក្រចេះបានធ្លាក់ហើយៗ មេបញ្ជាការផ្នែកសឹករងក្រចេះ, ចេង សាឃុំប៊ិន, នៅមុខការវាយសំរុកយ៉ាងខ្លាំងនៃកុម្មុយនិស្ត, រត់ចោលទាហានខ្លួនដែលស្ទើរតែទាំងអស់បានត្រូវចាប់ជាឈ្លើយៗ ក្នុងពេលរង់ចាំតុលាការសឹក, សាឃុំប៊ិន បានចេញពីគុករួច ហើយទៅចូលជាមួយខ្មែរក្រហម នៅខែមេសា, ពេលដែល និចសុន ឲ្យទាហានអាមេរិកាំងចូលក្នុងដីខ្មែរ (ជំរៅ ៣០ គ.ម., តំបន់ “ផ្ទៃសន្ទូច”) ដើម្បីសំអាតទីជម្រកវៀតកុង, លន់ នល់ សុំឲ្យអាមេរិកាំងបង្ហួសការវាយចូលរបស់ខ្លួនដល់ក្រចេះ ហើយកាន់កាប់ក្រុងនេះ រហូតដល់ពេលទ័ពខ្មែររកទាហានជំនួយបានៗ ប៉ុន្តែសំណុំនេះ ឥតបានត្រូវ “គាំង” យកជាការណ៍ទេៗ*

(៨) ក្នុងភាគខាងត្បូងនឹងកណ្ដាលនៃប្រទេស, វៀតកុងវាយតាមក្រុមកុម្ម៉ង់ដូតូចៗ ទេ។ ប៉ុន្តែចំពោះនាយទាហានយើង, ដែលសុខស្រួល ១៥ ឆ្នាំមកហើយនឹងសន្តិភាពនៃបញ្ចសីលា, គឺជាការជ្រួលច្រាលយ៉ាងខ្លាំង។ ដោយភ័យស្ងួននឹងការវាយជុំវិញក្រុងភ្នំពេញ, ទីអគ្គមេបញ្ជាការស្មានតែយួនតម្រង់រកវរជ្ជធានី។ ការត្រេះរិះពិចារណាបន្តិច ប្រហែលជាបានបង្ហាញឲ្យឃើញថាយួនឥតមានប្រយោជន៍នឹង "យក" ភ្នំពេញភ្លាមដូច្នេះទេ។

(៩) តាំងពីដំណាច់ឆ្នាំ ១៩៧២, កងទាហានខ្មែរក្រហមអាចប្រយុទ្ធដល់ថ្នាក់កងពលធំ។

(១០) ក្នុងពីរឆ្នាំដំបូងនៃសង្គ្រាម, កងទាហានកុម្មុយនិស្តសុទ្ធតែយួនទាំងអស់។ សក្ខីភាពនៃបណ្ដាជន នៃភូមិភាគជាច្រើនត្រូវគ្នាទាំងអស់ ៖ ក្នុងការទៅមករបស់ខ្លួន, យួនមានក្រុមខ្មែរតូចៗ ដើរជាមួយ, ដែលក្នុងពេលនោះគេស្មានថាតែពួក "អ្នកបង្ហាញផ្លូវ"។ តែមែនទែនទៅ, គឺពួកទាំងនោះហើយដែលជាក្រុមក្របខ័ណ្ឌបញ្ជូនពីហាណូយ។ ការកែនទាហានជាលើកដំបូងបានធ្វើឡើងដោយឥតចំណោទ។ ពួកខិលខូចនិងចោរស្រុកទាំងប៉ុន្មានបានត្រូវគេឲ្យកាំភ្លើងកាន់ ហើយតែងតាំងក្នុងមួយប៉ប្រិចភ្នែកជាមេភូមិ — មេឃុំ! ការយកសីហនុមកកាន់អំណាចវិញ បានត្រូវគេនិយាយពីមាត់មួយទៅមាត់មួយ! ភូមិណាដែលទទឹងរឹងរូស បានទទួលទណ្ឌកម្មយ៉ាងសាហាវ (ការសម្លាប់រង្គាលមានរាប់មិនអស់, ដែលព្រៃផ្សៃជាងគេ គឺនៅត្រពាំងជង, ក្នុងឆ្នាំ ១៩៧១)។ ការប្រើប្រាស់កាំភ្លើងធំ គ្រាប់បែក, គ្រាប់រ៉ុកកែត, (ដំបូងរុស្ស៊ី រួចមកចិន) បានត្រូវទុកឲ្យយ៉ាងដាច់មុខដល់ពួកយួន, រហូតដល់ឆ្នាំ ១៩៧៥។

ជាមួយដំណើរថ្មីៗ នៃ ប៉ុល ពត ទៅប៉េកាំងនិងការប្រកាសខួបទី ១៧ នៃគណបក្សកុម្មុយនិស្តខ្មែរ, ពួកសារពត៌មានបស្ចឹមប្រទេសធ្វើការស្មានតែពីសតែពាសដូចសព្វដង។ ខ្លះនិយាយរហូតដល់ថា

---

## ផ្លូវជាតិយើងខ្លះ

ផ.ជ.១ = ភ្នំពេញ — អ្នកលឿង — ស្វាយរៀង — (ព្រៃនគរ)

ផ.ជ.៣ = ភ្នំពេញ — តាកែវ — កំពត

ផ.ជ.៤ = ភ្នំពេញ — កំពង់ស្ពឺ — កំពង់សោម

ផ.ជ.៥ = ភ្នំពេញ — កំពង់ឆ្នាំង — ពោធិ៍សាត់ — បាត់ដំបង — ស៊ីសុផុន — ប៉ោយប៉ែត

ផ.ជ.៦ = ព្រែកក្ដាម — ស្គន់ — កំពង់ធំ — សៀមរាប — ស៊ីសុផុន

ផ.ជ.៧ = ស្គន់ — កំពង់ចាម — ក្រែក — មេមត់ — ស្នួល

↓ ↓

(តាយនិញ) (ឡុកនិញ)

↘ ↙

(ភូមិភាគផ្ទៃសន្ទូច)

ផ.ជ.១២ = កំពង់ធំ — អន្លង់វែង — រវៀង — ផ្លូវបែកថែប/ម្លូព្រៃ — ស្រឡៅ (ទល់មុខខុង, លាវ)

ផ.ជ.១៣ = ស្នួល — ក្រចេះ — ស្ទឹងត្រែង — (ខុង, បាក់សេ, លាវ)

ផ.ជ.១៩ = ស្ទឹងត្រែង — លំផាត់ — (ផ្លេគូ, វៀតណាម)

គ្មានទំនាក់ទំនងអ្វីរវាង ខ្មែរ-វៀតមិញ នឹងពួកមេខ្មែរក្រហមសព្វថ្ងៃនេះទេ។ នេះគឺជាការប្រមាថពេញទីដល់វិញ្ញាណក្ខន្ធនៃយោធាយើង ដែលបានបូជាជីវិតនៅសមរភូមិ និងនៃបងប្អូនកសិករយើងដែលបានត្រូវគេសម្លាប់រង្គាលយ៉ាងព្រៃផ្សៃ។

(១១) ក្នុងពេលនេះមិនទាន់មានស្ថិតិច្បាស់លាស់លើចំនួនអាវុធ "កុម្មុយនិស្ត" ដែលបានត្រូវផ្តល់ឲ្យខ្មែរក្រហមទេ។ យួនច្បាស់ជាមិនបានដឹកជញ្ជូនឲ្យដោយឥតយកកំរៃឡើយ។ ដូចជាខ្មែរយើងក្នុងពេលជញ្ជូនកាំភ្លើងពីកំពង់សោមទៅឲ្យវៀតកុង, យួនប្រហែលជាបាន "បេះយក" មួយភាគដែរ។

(១២) ពួកកុម្មុយនិស្តយួន, ថ្វីដ្បិតតែគេដឹងឮគ្រប់គ្នា អំពីការត្រូវរ៉ូវគ្នា សីហនុ-ផាំយ៉ាំងដុង នៅប៉េកាំង នៅថ្ងៃ ២១-៣-៧០, បានប្រកែកក្នុងពីរឆ្នាំដំបូងនៃសង្គ្រាមថា គ្មានទ័ពខ្លួននៅកម្ពុជាទេ។ មាត្រា ២០ នៃកិច្ចព្រមព្រៀងនៅប៉ារីស នៃខែមករា ១៩៧៣ ជាការទទួលសារភាពមួយពិតៗ។ ប៉ុន្តែគ្មានប្រទេសណាមួយដាក់ទណ្ឌកម្មដល់វៀតណាមខាងជើងទេ, ដំណឹងដល់អ្នកណាដែលសង្ឃឹមលើការខ្វល់ខ្វាយរកយុត្តិធម៌ នៃសន្និសីទអន្តរជាតិទាំងពួង! តទៅនេះ <u>គឺអត្ថបទនៃកិច្ចព្រមព្រៀងនៅប៉ារីស</u> រវាងសហរដ្ឋអាមេរិកនិងវៀតណាមខាងជើង ដែលធ្វើនៅខែមករា ១៩៧៣ (វគ្គទី៧, មាត្រា២០) ៖

ក/. ភាគីដែលចូលរួមសន្និសីទនៅប៉ារីសអំពីរឿងវៀតណាម ត្រូវគោរពយ៉ាងម៉ត់ចត់ដល់កិច្ចព្រមព្រៀងហ្សឺណែវនៃឆ្នាំ ១៩៥៤ លើកម្ពុជា និងកិច្ចព្រមព្រៀងហ្សឺណែវនៃឆ្នាំ ១៩៦២ លើលាវ, កិច្ចព្រមព្រៀងដែលធ្វើឲ្យមានត្រឹមត្រូវនូវសិទ្ធិជាតិជាប្ញសគល់ នៃប្រជាជនកម្ពុជានិងលាវ, គឺឯករាជ្យ, អធិបតេយ្យភាព, ឯកភាព និងបូរណភាពទឹកដីនៃប្រទេសទាំងនេះ។ ភាគី ត្រូវគោរពអព្យាក្រឹតភាពនៃកម្ពុជានិងលាវ។ ភាគី ដែលចូលរួមក្នុងសន្និសីទនៅប៉ារីសអំពីវៀតណាមសន្យាថាមិនប្រើទឹកដីកម្ពុជានិងលាវ ដើម្បីប៉ះពាល់ទៅវិញទៅមកដល់អធិបតីភាពគ្នា និងដល់សន្តិសុខគ្នា និងដើម្បីប៉ះពាល់ដល់អធិបតីភាពនៃប្រទេសឯទៀត។

ខ/. បរទេសនឹងបញ្ឈប់សកម្មភាពទាហានទាំងអស់នៅកម្ពុជានិងលាវ, នឹងដកចេញពីប្រទេសទាំងពីរនេះនូវកងទាហានទាំងអស់, ទីប្រឹក្សាទាហានទាំងអស់, បុគ្គលិកទាហាន, អាវុធ, គ្រាប់ និងសម្ភារៈចម្បាំង ហើយនឹងមិនបញ្ចូលមកទៀតឡើយ។

គ/. កិច្ចការផ្ទៃក្នុងនៃ កម្ពុជានិងលាវ ត្រូវប្រជាជនទាំងពីរចាត់ចែងរឿងខ្លួនដោយឥតបរទេសជ្រៀតជ្រែក។

ឃ/. ចំណោទទាំងឡាយដែលជាប់ជំពាក់នឹងទំនាក់ទំនងរវាងប្រទេសនៃឥណ្ឌូចិន នឹងត្រូវដោះស្រាយដោយភាគីឥណ្ឌូចិនលើមូលដ្ឋាន នៃការគោរពទៅវិញទៅមកដល់ឯករាជ្យគ្នា, បូរណភាពទឹកដីគ្នា និងនៃការមិនជ្រៀតជ្រែកទៅវិញទៅមក ដល់កិច្ចការផ្ទៃក្នុងគ្នា។

(ចុះហត្ថលេខាដោយ ឡេឌឹកថូ និង ហិនរី គិស្សិញ្ជើ នៅថ្ងៃ ២៧ មករា ១៩៧៣) (ដកស្រង់ចេញពីសារពត៌មាន "ឡឺម៉ុង" នៃថ្ងៃ ២៦-១-៧៣)។

ការណ៍មួយដែលបានធ្វើឲ្យអ្នកសង្កេតការណ៍បរទេសងឿងឆ្ងល់យ៉ាងខ្លាំង គឺអ្នកកាន់អំណាចនៅភ្នំពេញបានបញ្ជា, គ្រាន់តែសន្និសីទនេះចប់ភ្លាម, ឲ្យកងទ័ពបញ្ឈប់ការបាញ់គ្នាជាឯកតោភាគី ហើយឲ្យធ្វើបុណ្យមួយអបអរសាទរទទួលកិច្ចព្រមព្រៀងនេះ។

(១៣) មុនពេលភ្នំពេញធ្លាក់បន្តិច, ការប្រកួតប្រជែងគ្នារវាងបក្សពួកទាំងឡាយក្នុង សាធារណរដ្ឋ ធ្វើឲ្យអាមេរិកាំងសម្រេចចិត្តយក លន់ ណុន ចេញឲ្យឆ្ងាយពីភ្នំពេញ។ "កាណុន" បានត្រូវគេឲ្យទៅធ្វើដំណើរ

មួយទៅបរទេសក្នុង "ឋាន:" ជារដ្ឋទូតត្រាច់ចរ។ ខ្មែរក្រហមធ្វើឲ្យមានពាក្យចចាមអារ៉ាមថា ក្នុងដំណើររបស់ខ្លួន លន់ ណុន បានទាក់ទងជាមួយរុស្ស៊ី។ ដោយឥតចង់និយាយថា ការដេញទូតរុស្ស៊ីចេញពីភ្នំពេញនៅខែមេសា ១៩៧៥ មកតែអំពីរឿងនេះ, យើងអាចនិយាយដោយច្បាស់ថា ខ្មែរក្រហមឥតបានដេញពួកទូតសហភាពសូវៀត ក្រោមការញុះញង់របស់ចិនឡើយ។

(១៤) នៅអាស៊ីកាគអគ្នេយ៍, ការបដិវត្តន៍ណាក៏ជាបដិវត្តន៍កសិកម្មដែរ (ខ្ញុំងណាស់លើកលែងតែចំពោះហុងកុង និង សិង្ហបុរី), ព្រោះថាមហាជនភាគច្រើនជាកសិករ។ វណ្ណៈកម្មករក្នុងក្រុង គ្រាន់តែជាលេសទេ។ ការទាក់ទាញនៃសភាព "ទើតតាយ" តែងតែធ្វើឲ្យមានជានិច្ច, ក្នុងសង្គម ក្បែរ-មូលធននិយម, នូវការចាកចេញពីស្រុកស្រែចំការមករស់នៅក្នុងក្រុងវិញ, ការណ៍នេះជាករណីយនៃកម្ពុជាដែរ។ លប់បំបាត់ក្រុងទាំងឡាយចេញ ជាគោលដៅធំមួយនៃកុម្មុយនិស្តអាស៊ីទាំងអស់ ដែលកំពុងតែឡើងកាន់អំណាច, ទោះបីខ្លួនយកទ្រឹស្តីតាមលទ្ធិណាក៏ដោយ, ទោះបីខ្លួនមានលក្ខណៈដាច់ណាត់ខ្លាំង ឬតិចក៏ដោយ។ មិនមែនតែក្នុងកម្ពុជាប្រជាធិបតេយ្យទេដែលគេលប់បំបាត់ក្រុងចោល, នៅវៀតណាម និងនៅលាវ ក៏គេធ្វើដូច្នេះដែរ, ប៉ុន្តែដោយបន្តិចម្តងៗ។ ដែលខ្មែរក្រហមដេញបណ្តាជន ចេញអស់យ៉ាងលឿនពីភ្នំពេញនិងក្រុងឯទៀតនេះ, គឺមិនមែនមកពីរឿងសេដ្ឋកិច្ច ឬដើម្បីបំពេញបំណងមនោគមវិជ្ជាអ្វីទេ។ ខ្មែរក្រហមបានធ្វើដោយអមនុស្សធម៌នេះ ព្រោះចង់ចៀសវាងអន្ទាក់៤ ដូចតទៅនេះ, ដែលអាច "កាត់មុខ" ខ្លួនបាន ៖

ក/. ក្រោយកិច្ចព្រមព្រៀងនៅប៉ារីសនៃឆ្នាំ ១៩៧៣, គេថាអាចមានកិច្ចចចារលើរឿងខ្មែរ។ សីហនុ, ជាមួយការយល់ព្រមនៃ ជូ អេនឡាយ, បោះសន្ទូចមួយទៅ ៖ រាជរដ្ឋាភិបាលរួបរួមជាតិ ព្រមធ្វើតែកិច្ចចចារ ទ្វេភាគី, ជាមួយអាមេរិកាំងតែម្តង។ សីហនុ មិនមែនចង់តែទាញ លន់ នល់ និងសាធារណរដ្ឋចេញទេ, គឺថែមទាំង —ហើយមុនអ្វីទាំងអស់— ពួកខ្មែរក្រហម "កូនសិស្ស" យួនទៀត (នៅពេលនោះ, រដ្ឋទូតបារាំងនៅក្រុងប៉េកាំង, អេដែន ម៉ាណាក់, ធ្វើជាអ្នកទាក់ទងឲ្យ)។ ចាប់តាំងពីឆ្នាំ ១៩៧៣ នៅកម្ពុជា, គេឃើញមានកងធ្លក់ "សីហនុនិយម"។ នៅក្នុងភូមិភាគខ្លះ, មានការវាយតទល់យ៉ាងខ្លាំង រវាងខ្មែរក្រហម និង "ពួកសីហនុ"។

ខ/. ពេលដែលគាត់ទៅជារដ្ឋមន្ត្រីទីមួយ, ហង្ស ធុនហាក់ បានរកចចារ, តាមរយៈបាងកក, ជាមួយក្រុម សីហនុ - ខៀវ សំផន - ហ៊ុយ និម - ហ៊ូ យន់, ការប្រឹងប្រែងដែលបានធ្វើឲ្យគាត់ បាត់មុខងារទៅ។

គ/. ស៊ុស្តែន ហ្វ៊ែរណង់ដែស, អតីតៈអគ្គមេបញ្ជាការ, ចង់ធ្វើរដ្ឋប្រហារមួយដើម្បីរំលំ លន់ នល់ ហើយយកសីហនុ (តែម្នាក់ឯង) មកវិញ។ ដោយខ្វះគុណសម្បត្តិមួយដែលបារាំងហៅថា "អ៊ីនីស្យ៉ាទីវ" (ការចេះចាត់ចែងដោយខ្លួនឯង មិនចាំបាច់មានគេបញ្ជា), ស៊ុស្តែនទៅសួរយោបល់អាមេរិកាំងសិន។ ជាការណ៍ធម្មតា, អាមេរិកាំងឆ្លើយ "ទេ", ហើយខ្លួនក៏ស្តាប់។

ឃ/. នល់ ណុន ក៏ដូចគ្នាដែរ ពុំបាននៅស្ងៀមក្នុងការប្រណាំង ដណ្តើមអំណាចទេ។ "ឧត្តមសេនីយ៍" ហែម កេតដារា និងក្រុម "ម៉ូណាស្ស៊ូ" របស់ខ្លួន, នាយទាហានពាក់ផ្កាយខ្លះ ដែលត្រូវហែបត្រូវហាបមកដាក់សោប្រវាក់នៅទ្វារចូលក្រសួងឃោសនាការ បង្ហាញឲ្យឃើញល្បិចកលទាំងឡាយនៃពេលក្រោយនោះ។

*ពិតណាស់ទៅហើយ, ខ្មែរក្រហមដឹងអស់ពីឧបាយកលទាំងនោះ។ ការណ៍ដែលគួរកត់សំគាល់ គឺពួកដើរល្បិចទាំងនេះ, ទាំងអ្នកមានសុទ្ធចិត្ត ទាំងអ្នកស្រេកបុណ្យសក្តិ, បានយល់ច្រឡំអំពីអំណាចមែនទែនលើពួកខ្មែរក្រហម។ ទាំងអស់គ្នាឥតបានយល់ដល់អត្ថន័យយ៉ាងជ្រាលជ្រៅ នៃការសម្លាប់រង្គាលព្រៃផ្សៃ នៅត្រពាំងជង, ឧដុង្គ, កំពង់ចាម ។ល។ ឡើយ។ គេស្មានតែបើមិនសីហនុ (ដែលមានយសជាប្រធាននៃរណសិរ្សនិងមានការគាំពារពីប៉េកាំង) ក៏ ខៀវ សំផន ដែរ (ជាមួយងារខ្លួនជាអគ្គមេបញ្ជាការ និងរដ្ឋមន្ត្រីការពារប្រទេស) ដែលកាន់បង្ហៀរដឹកនាំបដិវត្តន៍។ មិនគឺ ខៀវ សំផន ដែលក្នុងពេលមួយបានប្រាប់អ្នកសារពត៌មានបារាំងម្នាក់នៅក្នុងព្រៃថា ៖ "គ្រោះថ្នាក់ធំបំផុតចំពោះការបដិវត្តន៍ គឺកាលណាជ័យជំនះបានរហ័សពេក"? តើ ខៀវ សំផន ចង់ឲ្យដឹងថា មិនមែនខ្លួនទេអ្នកមានអំណាចមែនទែនឬអ្វី? ប៉ុន្តែកាលនោះ ចន្លោះឆ្នាំ ១៩៧១ និង ៧៣ ឥតមាននរណាចាប់ក្លឹកខ្លាំងឡើយ ដោយស្មានតែនិយាយពីកិច្ចការរៀបចំ។ មើលទៅ, ដោយចង់សងគំនុំ—ឈឺចាប់ លើសង្គមខ្លួន, ដោយចង់ធ្វើឲ្យទាល់តែ សីហនុ យកអំណាចវិញពុំកើត, ខៀវ សំផន, ដែលមើលងាយមេរៀនប្រវត្តិសាស្ត្រ ដូចពួក "ពុករលួយ" នៅភ្នំពេញដែរ, បានសុខចិត្តចូលជាមួយ "បន" ពួកហាណូយ។*

(១៥) *គេបាននិយាយអំពីការឲ្យខ្ចីប្រាក់ ១ ០០០ លានដុល្លារ ដែល ជូ អេនឡាយ ព្រមធ្វើ ចំពោះកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យខ្មែរក្រហមទុក សីហនុ ជាប្រមុខរដ្ឋ។*

(១៦) *មុនពេល ប៉ុល ពត ទៅស្រុកចិនបន្តិច, ទស្សនាវដ្តី "សេដ្ឋកិច្ចចុងបូព៌ាប្រទេស" ចុះអត្ថបទមួយសរសេរដោយ ណាយ៉ានចាន់ដា ក្រោមចំណងជើងថា "កម្ពុជានិងចិនមិនសូវស្និទ្ធស្នាលគ្នា", ហើយដែលថែងដូចតទៅនេះ ៖*

*"សីហនុ ៖ ប្រកពឲ្យពត៌មានជាតិអឺរ៉ុបមួយ ដែលដឹងច្រើនអំពីប៉េកាំងនិយាយថា ចិនមិនសប្បាយចិត្តទេអំពីរបៀបដែលគេថែទាំសម្តេចសីហនុ, ហើយ "ពួកបួននាក់"(*) បានត្រូវគេឲ្យទទួលខុស ដោយពុំបានខិតខំធ្វើឲ្យ សីហនុ នៅជាប្រមុខរដ្ឋ។ ប្រភពនេះយល់ថា មិនមែនជាចៃដន្យទេការណ៍ដែល សីហនុ បានត្រូវដកចេញពីតំណែងក្រោយពីមរណភាពនៃរដ្ឋមន្ត្រីទីមួយ ជូ អេនឡាយ (ដែលជាអ្នកគាំពារ សីហនុ ក្នុងរយៈពេលប្រាំឆ្នាំដែលសម្តេចនៅប៉េកាំង), ទល់នឹងពួកអ្នកជាច់ណាត់ខ្លាំងក្នុងចំណោមខ្មែរក្រហម។ ឥឡូវនេះប៉េកាំងដូចជាបានឃើញថា ការទម្លាក់សីហនុ បានធ្វើឲ្យកម្ពុជាបាត់អ្នកនាំពាក្យម្នាក់ដែលមានសមត្ថភាព, មកអំពីនយោបាយធ្វើខ្លួនឯកោអនាថា។*

*"ថ្វីដ្បិតតែទំនាស់រវាងប្រទេសចិននៃហួគួហ្វេង នឹងកម្ពុជាមិនទាន់ចេញនៅឡើយទេ, គេឃើញមានសញ្ញាថា ប៉េកាំងមិនសូវមានការស្និទ្ធស្នាលក្នុងកិច្ចទាក់ទងរបស់ខ្លួនជាមួយកម្ពុជា។ ការបរិយាយពីរឿងខ្មែរដោយទីភ្នាក់ងារពត៌មានចិនថ្មី —ប្រដាប់វាស់កំរិតមិត្តភាពមួយដែលគេទទួលស្គាល់— បានធ្លាក់ចុះមកយ៉ាងស្លួចស្លើងក្នុងឆ្នាំដែលកន្លងទៅនេះ។ ប្រដូចទៅនឹងអត្ថបទចំនួន ២២ លើកម្ពុជា ដែលទីភ្នាក់ងារពត៌មានចិនថ្មីបានចុះផ្សាយក្នុងខែកក្កដា-សីហា ១៩៧៦, ទីភ្នាក់ងារបានចុះតែបួនអត្ថបទទេក្នុងរយៈកាលដូចគ្នាឆ្នាំនេះ។*

*"សញ្ញាមួយនៃការចុះអន់នៃភាពកក់ក្តៅរបស់ប៉េកាំង គឺកំរិតមិនសូវខ្លាំងនៃភាពតំណាងរបស់ប្រទេសចិនក្នុងពិធីជប់លៀងបុណ្យខួបនៅខែមេសា។ ក្នុងពិធីជប់លៀងឆ្នាំទៅ, ដែលធ្វើឡើងមុនមរណភាពនៃ ម៉ៅ សេទុង និងការធ្លាក់នៃពួកបួននាក់, បានមកចូលរួមសមាជិកបីនាក់នៃការិយាល័យនយោបាយ ព្រមទាំងរដ្ឋមន្ត្រីការបរទេសក្នុងពេលនោះ, ជាវ គួនហួ (ក្រោយមកគេលែងរាប់រក)។ ឆ្នាំ*

*(*) ប្រពន្ធ ម៉ៅ សេទុង និងគ្នាគាត់។*

*នេះ, បានមកចូលរួមក្នុងពិធីសមាជិកម្នាក់នៃការិយាល័យនយោបាយ និងរដ្ឋមន្ត្រីការបរទេស ហួងហួ។ សុន្ទរកថារបស់ ហួងហួ ត្រូវបានជាក់ជាង ជាវ គួនហួ ដែលបានថ្លែងអំពីសេចក្តីប្រាមោជ្ជនឹងការដែលមាន "មិត្តរួមប្រយុទ្ធ" ស្មោះត្រង់ដូចខ្មែរ។"*

*"ការចុះត្រូវជាក់ នៃទំនាក់ទំនងនៃប្រទេសទាំងពីរ ប្រហែលជាមិនធ្វើឲ្យមានការដាច់ដោចខ្លាំង ឬឲ្យឃើញជាសាធារណៈ នូវសង្គ្រាមស្វាបបាក្កាដូចករណីជាមួយប្រទេសអាល់បានីទេ, ព្រោះប្រទេសទាំងពីរ **ត្រូវការគ្នា** ទៅវិញទៅមក។ ចិនមិនត្រឹមតែឲ្យខ្ចីប្រាក់យ៉ាងច្រើនសម្បើម សំរាប់ការកសាងឡើងវិញក្រោយសង្គ្រាមទេ (ប្រហែល ១ ០០០ លានដុល្លារអាមេរិកាំង, ដែលក្នុងនោះមានជំនួយជារបស់ តម្លៃ ២០ លានដុល្លារ), ថែមទាំងបាន —តាមគេស្មាន— ឲ្យបុគ្គលិកបច្ចេកទេស ១ ០០០ នាក់ មកជួសជុលផ្លូវ និងឧបករណ៍ដឹកនាំតាមអាកាស និងអយស្ម័យយាន, គ្រឿងផ្តល់អគ្គិសនីនិងរោងចក្រសំខាន់ៗ ឯទៀត ព្រមទាំងឲ្យជំបូន្មានខាងអភិវឌ្ឍន៍កសិកម្ម។ លើសពីការឲ្យអាវុធធម្មតា, ចិនបានផ្តល់កប៉ាល់សំរាប់ធ្វើល្បាត ហើយបង្ហាត់ខ្មែរឲ្យចេះប្រើប្រាស់។ អាកាសចរចិន (ក្រោយមក តាមដោយអាកាសចរយួននិងលាវ) នៅតែជាស្ពានជំដែលភ្ជាប់ប្រទេសមកពិភពលោកខាងក្រៅ។ បេសកកម្មខ្មែរខាងពាណិជ្ជកម្មដែលចេញក្រៅប្រទេសជាលើកដំបូង មកតាំងទីក្នុងធនាគារកុម្មុយនិស្តមួយនៅ ហុងកុង (ទស្សនាវដ្តី, ១០ ធ្នូ ៧៦) ហើយកិច្ចជួញដូរទាំងឡាយធ្វើតាមរយៈធនាគារនៃប្រទេសចិន។ ទោះបីកម្ពុជាបានបើកបន្តិចម្តងៗ នូវការទាក់ទងខាងពាណិជ្ជកម្មជាមួយលោកខាងក្រៅក៏ដោយ —ជាពិសេសជាមួយជប៉ុន— ពេលវេលាមួយរយៈនិងកន្លងទៅ មុននឹងភ្នំពេញអាចរឹងដៃរឹងជើងដើរតែម្នាក់ឯងបាន។"*

*"តបមកវិញ, ជាមួយនយោបាយក្រៅប្រទេសដ៏ឯករាជ្យរបស់ខ្លួន និងជំហរយ៉ាងខ្លាំងរបស់ខ្លួនប្រឆាំងនឹងសហភាពសូវៀត, កម្ពុជាធ្វើសមនឹងទឹកប្រាក់ក្នុងវិក័យប័ត្រចិនណាស់។ ថ្វីដ្បិតតែប៉េកាំងចង់ឲ្យកម្ពុជាកែប្រែជំហរជាតិនិយមលើសលុបរបស់ខ្លួន និងបំបាត់ទំនាស់ខ្លួនជាមួយប្រទេសថៃ, ភាពឯករាជ្យយ៉ាងមានះនៃកម្ពុជាបានត្រូវទទួលស្គាល់ថា ការជានាមួយទល់នឹងស្នៀតទាំងឡាយនៃមហាអំណាច ដូចតទល់នឹងការកើតឡើងនៃប្លុកឥណ្ឌូចិនឯករាជ្យមួយដែរ។ ទោះប្រទេសទាំងពីរមិនចូលចិត្តនឹងនយោបាយក្នុងគ្នាខ្លាំងយ៉ាងណាក៏ដោយ, កម្ពុជានិងចិន នឹងនៅតែដើរជាមួយគ្នាព្រោះតែមូលហេតុយ៉ាងខ្លីនេះ ៖ **ប្រយោជន៍រដ្ឋ** ។"*

*(ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ាប្រទេស ៣០ កក្កដា ១៩៧៧)*

---

*ដំណើរដ៏មានជោគជ័យនៃ ប៉ុល ពត ទៅប៉េកាំងអាចជាសញ្ញា នៃ ការបន្ទន់របបខ្មែរក្រហមឬទេ? គឺថាប្រជាជនខ្មែរអាចនឹងបានស្រាកស្រាន្តខ្លះឬទេ?*

*ទោះជាអ្នកដឹកនាំចិនប្រមូលមនុស្សមួយលាននាក់ លើទីលាន ទៀនអានម៉េន ដើម្បីធ្វើការទទួលយ៉ាងអស្ចារ្យមួយដល់ ប៉ុល ពត និងដើម្បីប្រាប់ទៅពិភពលោកថា កម្ពុជា ជា "កន្លែងសំរាំងទុក" របស់ចិនក៏ដោយ, គោលដៅនៃអ្នកដឹកនាំសព្វថ្ងៃនិងក្នុងអនាគតនៃប្រទេសវៀតណាម នៅតែឥតប្រែប្រួលឡើយ ៖ បំពេញចំណង់ ហូ ជីមិញ, គឺថា យកកម្ពុជានិងលាវ ចូលក្នុងសហព័ន្ធរដ្ឋមួយ ក្រោមការដឹកនាំនៃវៀតណាម។ មានច្រើនគ្នា អ្នកដែលចាំមើល, ដោយឆោត, ការណ៍ដែលខ្មែរក្រហមបើកយ៉ាងធំ នូវទ្វារប្រទេស ដើម្បីឲ្យ "ចៅហ្វាយ" យួនខ្លួនចូលមកយកកម្ពុជា។ នេះគឺមធ្យោបាយដែល ហូ ជីមិញ ពុំបានប្រាប់យើងទេ។ អ្នកដឹកនាំវៀតណាមមានជាច្រើនគ្នា នូវការពិសោធន៍ជាប់ ៤០ឆ្នាំ ខាងសង្គ្រាមបដិវត្តន៍។ គេបានឈមមុខ ក្នុងការតយុទ្ធយ៉ាងយូរដើម្បីឯករាជ្យប្រទេសគេទល់នឹងអាណានិគមនិយម និងចក្រពត្តិនិយម ជាច្រើន ៖ បារាំង, ចិន, ជប៉ុន, អាមេរិកាំង។ កាន់ចង្កូតប្រទេសមួយដែល —ចំពោះភ្នែកពិភពលោកទាំងមូល— ជាប្រទេសរងកម្ម, អ្នកទាំងនេះចេះ ហើយនិងនៅតែចេះ ចៀសវាងមិនឲ្យគេថាខ្លួនជាចក្រពត្តិវិញបាន។*

*តើខ្មែរក្រហមអនុវត្តន៍ឥតខ្ចោះ នូវទ្រឹស្តីបដិវត្តន៍នៃវណ្ណៈកម្មករ-កសិករ របស់ម៉ៅ(១)? ឬមួយយកគំនិតដោយឥតខុសមួយបន្ទាត់ពីលទ្ធិ ម៉ាក្ស-ឡេនីន? ឬមួយពួកនេះ "ដុសលាងឲ្យបរិសុទ្ធ" ដើម្បីធ្វើសង្គមថ្មីមួយនៅកម្ពុជា? ឥតសំខាន់ទេ ប្រភពនៃលទ្ធិដែលមេខ្មែរក្រហមយកគំនិតតាម, ការដែលត្រូវសង្កត់លើ គឺពួកនេះបានទទួលការហ្វឹកហ្វឺនខាងបច្ចេកទេសសង្គ្រាមបដិវត្តន៍នៅស្រុកយួន។ បើគ្មានជំនួយចិន(២) ការបដិវត្តន៍យួនប្រហែលជាមិនបានជ័យជំនះទេ។ ដូចគ្នាដែរ បើគ្មានជំនួយយួន មេរោគកុម្មុយនិស្ត ឥតមានកម្លាំងគ្រប់គ្រាន់នឹងកំទេច ហើយកប់ចោលនូវអរិយធម៌ខ្មែរឡើយ។ ពិតហើយ បានរៀននៅសាលាយួន មិនមែនបានន័យប្រែមកជានិច្ចថាជាខ្ញុំកញ្ជះយួន ហើយបំរើផលប្រយោជន៍យួនទេ។ ប៉ុន្តែ បើប្រទេសវៀតណាមបានធ្វើពលិកម្មយ៉ាងច្រើនដើម្បីជួយខ្មែរក្រហម គឺមកពីប្រទេសនេះឃើញថាខ្លួនអាចទាញផលប្រយោជន៍មកវិញបាន។ មកដល់ពេលនេះ អ្នកដឹកនាំយួនអាចសប្បាយរីករាយនឹងលទ្ធផលលើកដំបូងហើយ, រង្វាន់នៃការសប្បុរសរបស់ខ្លួន ៖ ប្រទេសកម្ពុជាអស់មនុស្ស ដោយការបំផ្លាញខ្លួនឯង(៣)។ ទោះយើងចង់ ឬមិនចង់ ខ្មែរក្រហមកំពុងតែធ្វើឲ្យអស់មនុស្សពីប្រទេសខ្លួនហើយ ព្រោះថា ៖*

*ក/ ថែមលើអសុកខ្មែរ ១ ២០០ ០០០ នាក់ ដែលព្រឹទ្ធសភាអាមេរិកាំងបានទទួលស្គាល់, បន្ទាប់ពីការជជែកមួយយ៉ាងត្រឹមត្រូវលើគណនេយ្យមក, និងមានមួយចំនួនទៀត, ដែលយើងមិនហ៊ាននឹងមិនចង់ប៉ាន់, នៃអ្នកស្លាប់ដោយហេតុជីវសាស្ត្រ។ ហើយយើងមិននិយាយពីការដែលទារកចាប់កំណើតពុំបាន និងពីការសម្លាប់ត្រង់ៗ ដែលនឹងនៅតែមានទៀតផង។*

*ខ/. ក្នុងអំពើឃ្លួតកំរោល និងសម្លាប់របស់ខ្លួន ខ្មែរក្រហមធ្វើឲ្យមានប្រតិកម្មទៅមក បន្តគ្នា ដែលនឹងនាំប្រទេសទៅឲ្យមានការកំទេចទាំងផងដីតមុខមួយជាទីខ្លោចផ្សារ។ គោលវិទ្យាសាស្ត្រដែលថា កម្មបង្កើតប្រតិកម្ម នឹងបង្ហាញឲ្យយើងឃើញ ៖ ការធ្វើបាបនាំឲ្យមានការបះបោរ, ការបះបោរនាំឲ្យមាន*

*ការបង្ក្រាប ហើយកង់ចក្រនេះចេះតែវិលទៅទៀតៗ ការបះបោរនេះចេញពីបណ្ដាជន ក៏ដូចជាចេញពីបក្សពួកប្រជែងៗ*

*ដើម្បីធ្វើឲ្យអស់មនុស្សពីកម្ពុជា, វៀតណាមឥតបាច់ប្រើកងទ័ពខ្លួនឡើយៗ ប៉ុន្ដែមកដល់ពេលនេះគ្រាន់តែចប់ដំណាក់មួយទេៗ អនាគតឃើញដូចជាខ្មៅងងឹតណាស់ៗ ប្រជាជនខ្មែរត្រូវប្រុងខ្លួនចាំទទួលរង់ព្យុះសង្ឃរាច្រើនទៀត ដែលបង្ហាញខ្លួននៅជើងមេឃទៅហើយៗ*

| |
|---|
| *ដូច្នេះ តើប្រជាជនខ្មែរនឹងទៅជាយ៉ាងណាក្នុងអនាគត?*<br>*តើអន្ទាក់នៅត្រង់ណា, សំណាងនឹងរស់នៅត្រង់ណា?* |

*ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០, ពេលដែលប្រទេសកម្ពុជាចូលក្នុងផ្លូវថយក្រោយពុំបាន នៃចំបាំងគ្នាឯង, លោក នួន ឃឿន, សាស្ត្រាចារ្យបរិញ្ញាប័ត្រប្រវត្តិសាស្ត្រ នៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រក្រុងភ្នំពេញ, តាមរយៈសៀវភៅមួយឈ្មោះ «ដំណើរឆ្ពោះទៅទិសខាងលិច និងឥណ្ឌូចិនក្នុងឆ្នាំ ២០០០», ឲ្យការព្រមានមួយទៅគូវិវាទទាំងពីរ ៖ "វាសនានៃប្រទេសយៀកណាមជាវាសនានៃប្រជាជាតិមួយដែលពង្រីកទឹកដីដោយសង្គ្រាម ហើយដែលត្រូវគេធ្វើសង្គ្រាមទៅអនាគតទៀតៗ"*

*ក្នុងជម្រៅ, នួន ឃឿន ចង់និយាយដូចតទៅនេះ ទៅកាន់អ្នកដឹកនាំទាំងពីរខាង ៖ ក្នុងកំរោលនិងសម្លាប់គ្នាទៅវិញទៅមក ចូរអ្នកកុំភ្លេចគ្រោះថ្នាក់យួនដែលកំពុងតែឃ្លាំមើលយើងៗ ជំបូន្មានប្រវត្តិសាស្ត្របានប្រាប់យើងរួចហើយថា គឺដោយសារចំបាំងគ្នាយើងទាំងនេះហើយ ដែលយួនឆ្លៀតឱកាសរាល់ដងដើម្បីរុញច្រានយើងចេញៗ ជាជាងកំទេចគ្នាឯង, គួរយើងខំសន្សំជីវិតខ្មែរវិញ ដើម្បីឈមមុខទល់នឹងសង្គ្រាមមួយក្នុងអនាគត ជាមួយវៀតណាមពេលណាដែលប្រទេសនេះ នឹងបានរួមមកតែមួយវិញៗ*

*ដូចជាធម្មតាទៅហើយ, ការអំពាវនាវនេះឥតបានត្រូវគេព្មឡើយៗ ការសន្និដ្ឋាននៃលោក នួន ឃឿន ឃើញថាត្រូវដូច្នេះមែន ក្នុងពេលឥឡូវនេះៗ ទើបនឹងចេញគើមៗ ពីសង្គ្រាមដ៏រន្ធត់មួយក្នុងកំឡុងប្រាំឆ្នាំ ដែលបានធ្វើឲ្យស្លាប់និងរបួសមនុស្ស ៨ ០០ ០០០ នាក់ ក្នុងបណ្ដាជន[៤], ប្រទេសកម្ពុជាចូលក្នុងជង្ហើបការបដិវត្តន៍ដ៏មានពុតត្បុត និងដ៏ព្រៃផ្សៃមួយ ដែលគាបមួលខ្លួនឲ្យហូរឈាមច្រោះស្ទើរតែអស់ទៅទៀតៗ កំពុងតែត្រូវជាបត្រដួសដោយមុខរបួសទាំងនេះ, សារពត៌មានទាំងឡាយចែងពីសញ្ញានៃសង្គ្រាមមួយទៀតរវាងកម្ពុជានិងវៀតណាម, ដែលក្នុងពេលនេះគ្រាន់តែជា "ជម្លោះរឿងព្រំដែន"ៗ ការណ៍មួយថ្មី ៖ កម្ពុជា, លើកនេះ, ទៅជា "អ្នកឈ្លានពាន" ទៅវិញ (សំនៀងនៃសុន្ទរកថារបស់ ប៉ុល ពត នៅប៉េកាំង ឲ្យគេស្មានទុកថា នឹងមានចំបាំងយ៉ាងធំមួយរវាងយួននិងខ្មែរ)ៗ អ្នកដឹកនាំខ្មែរក្រហមកំពុងតែនាំជាតិខ្មែរទាំងមូលទៅធ្វើអត្តឃាតកម្មហើយ ៖ ដើម្បីលុកលុយកម្ពុជា យួនប្រើដោយជោគជ័យនូវលេស "អាណានិគមនិយមបារាំង" (១៩៥១- ៥៤), រួចមកលេស "ចក្រពត្តិអាមេរិកាំង" (មិនា ១៩៧០), លើកនេះគ្មានអ្វីឃាត់យួនមិនឲ្យប្រើលេស "ចក្រពត្តិនិយមចិន" ទេៗ នៅខែមេសា ១៩៧៥, ពេលដែលពួកចិនចុះកប៉ាល់ហោះនៅពោធិចិនតុង, ដោយស្មានថាចិនចូលកាន់កាប់កម្ពុជា យួនបានចូលវាយជាទូទៅតាមព្រំដែន ហើយកាន់កាប់កោះខ្មែរទាំងអស់ក្នុងសមុទ្រ[៥]ៗ នេះជាការព្រមានមួយហើយ ដែលវៀតណាមបោះទៅឲ្យចិនៗ ទាល់តែមាន "ទស្សនកិច្ចជាមិត្តភាព" នៃ ឡេ ដួន[*] នៅ*

---

*(*) ឡេ ដួន ៖ លេខាធិការទីមួយនៃគណបក្ស ឡាវ-ដុងៗ ល្បីថាជាអ្នកជាច់ណាត់ខ្លាំងក្នុងចំណោមអ្នកដឹកនាំយួនៗ*

ភ្នំពេញ ទើបអធិករណ៍នេះបានត្រូវដោះស្រាយមួយពេលសិន (បន្ទាប់ពី "ទស្សនកិច្ច" នេះ, អៀង សារី បាន លេចចេញជាលើកដំបូងជាឧបរដ្ឋមន្ត្រីទីមួយ និងរដ្ឋមន្ត្រីការបរទេស, ព្រមគ្នានឹងឈ្មោះជាច្រើនទៀតដែល រហូតមកដល់ពេលនោះ នៅ "ក្រោយវាំងនន" នៅឡើយ។

ទំនាស់ ចិន-យួន ទីពីរបានចាប់ផ្តើមហើយ។ ចំពោះភ្នែកអ្នកដឹកនាំប្រទេសវៀតណាម, បើប្រទេស កម្ពុជាក្លាយទៅជាមូលដ្ឋានមួយនៃប្រទេសចិន, ឯកភាពរបស់ប្រទេសវៀតណាមត្រូវក្លាយទៅជាបញ្ហាវិញ។ ព្រោះថាយូរ ឬឆាប់ ចិនអាចបន្តកិច្ចដែល ជូ អេនឡាយ បានធ្វើមកពីមុន ៖ ទុកប្រទេសយួនឲ្យនៅតែបែកគ្នា ដោយទ្រទ្រង់ការតស៊ូយួន ទល់នឹងហាណូយ តាមមាគិនៃប្រទេសខ្មែរ។ ការមួយទៀតដែលច្បាស់គឺ បើចិន ទទួលរ៉ាប់បង្កើនអាវុធយុទ្ធភ័ណ្ឌដល់ខ្មែរក្រហម, យួនក៏នឹងទារជំនួយកាន់តែច្រើន ពីសហភាពសូវៀតដែរ។ ហើយនៅថ្ងៃដែលអ្នកដឹកនាំយួនវិនិច្ឆ័យថាជំនួយផ្លូវសឹកនៃចិនដល់កម្ពុជាបានហួសកំរិត ដែលជាគ្រោះថ្នាក់ មួយដល់វៀតណាម, កងទាហានយួននឹងទៅមុខព្រឹត្តិការណ៍ ហើយនឹងវាយលុកលុយប្រទេសខ្មែរម្តងទៀត។ តាមស្មាន, ដូចជានៅខែមីនា ១៩៧០ ដែរ, ពួកលុកលុយនឹងធ្វើសង្គ្រាមរហ័សមួយ ដោយវាយសំរុកជាមួយ កម្លាំងទាំងអស់របស់ខ្លួន ដើម្បីកំទេចទ័ពខ្មែរក្រហម។ លើកនេះ, គេអាចនឹងឃើញយួនក្តាប់ជាប់ប្រទេស កម្ពុជា ដែលអាចលែងប្រទូស្តនឹងខ្លួន ព្រោះថាបណ្តាជនខ្មែរ, ដោយបានរងទុក្ខវេទនាខ្លាំងពេក, អាចនឹង ទទួល យួន ជា អ្នករំដោះ !

អំពើអាក្រក់បានធ្វើរួចទៅហើយ, ប៉ុន្តែឥតខូចខាតទាំងអស់ទេ។

បើអ្នកដឹកនាំខ្មែរក្រហម, ប្ដីជ្រិតតែខ្លួនសាហាវព្រៃផ្សៃ និងឆ្កួតវង្វេងក្រៃណា, នៅមានការដឹងស្លាប់— ដឹងរស់នៅឡើយ— យើងចង់ថា ពួកនេះសុខចិត្តបាក់មុខជាជាងបាត់ស្រុក, ខ្លួនត្រូវចាត់វិធានការណ៍ដូចតទៅ ដែលឃើញដូចជាកិច្ចតិចបំផុតដែលត្រូវធ្វើ ដើម្បីសង្ឃឹមថានឹងឃើញប្រជាជាតិខ្មែររួចជីវិត ៖

ក) បញ្ឈប់ការកាប់សំឡាប់ស្រេចនឹងចិត្ត។ បន្ធូរការងារនៃបណ្តាជនដោយធ្វើឲ្យទៅតាមកម្លាំង មនុស្ស។

ខ) អនុញ្ញាតឲ្យក្រុមពេទ្យចូលទៅកម្ពុជា ដើម្បីព្យាបាលអ្នកជម្ងឺ, ដោយមានចំនួនគ្រប់គ្រាន់, និង ស្ថិតនៅក្នុងរយៈ វេលាដែលត្រូវការ។

គ) ឲ្យអាហារគ្រប់គ្រាន់ដល់បណ្តាជន, ដោយមាន ឬអត់ជំនួយពីខាងក្រៅ។

ឃ) ដោយមានប្រទេសចិន និងសហភាពសូវៀតជួយផង (ខ្មែរក្រហម, ហើយជាមួយខ្លួនកម្ពុជា ទាំងមូល, មានតែខាតទាំងអស់ បើនៅតែធ្វើផ្ទងនឹងសហភាពសូវៀត) កោះហៅគណៈកម្មការ អន្តជាតិខាងកិច្ចត្រួតពិនិត្យ (សេ អ៊ី សេ) មកធ្វើឲ្យគេគោរពព្រំដែនខ្មែរ (បើ សេ អ៊ី សេ នេះ អស់មានអាណត្តិ ត្រូវទាមទារឲ្យមានគណៈកម្មការរបៀបគ្នានេះ)។

ង) ធានាសន្តិសុខក្នុងផ្ទៃប្រទេស (សន្តិសុខដល់ក្រុមពេទ្យ និងក្រុមអ្នកជួយឯទៀត, ខាយាំងកុំឲ្យ មានការបេះបោរនៃបណ្តាជន — វិធានការណ៍នេះធ្វើឲ្យខ្លោចចិត្តណាស់ ប៉ុន្តែជាការចាំបាច់) ដោយហៅមកនូវទ័ពអន្តរជាតិ (ពួកមួក "ខៀវ" នៃ អ.ស.ប. ឬកងទាហានដែលមកតែពី ប្រទេសសន្តមនិយម)។

វិធានការណ៍ទាំង ៥ នេះ គឺដើម្បីបញ្ឈប់មរណកម្មក្នុងស្រុកខ្មែរតែប៉ុណ្ណោះ។ អក័យឯកសិទ្ធិនឹង ស្រែកហៅដល់ពិភពលោកខាងក្រៅ នៅក្នុងដៃអ្នកដឹកនាំខ្មែរក្រហមហើយ, ដែលនឹងនៅតែមើលខុសត្រូវក្នុង ស្រុក។ ពិតហើយពិភពលោកនៅឆ្ងាយ, ចាត់ការអ្វីដោយខ្លួនឯងពុំកើត, ប៉ុន្តែគេនឹងចូលទៅជួយប្រជាជនខ្មែរភ្លាម ពេលណាដែលរដ្ឋាភិបាលកម្ពុជា មករកគេមុន។

*ក្រោយមក វេលាដ៏សំខាន់បំផុតនឹងមកដល់, វេលាដែលប្រទេសកម្ពុជានឹងជ្រើសរើសយកនយោបាយថ្មី, វេលាដែលកងយោធាអន្តរជាតិនឹងត្រូវដកខ្លួនចេញ ដោយមិនធ្វើអ្វីឲ្យមានសង្គ្រាមរវាងខ្មែរគ្នាឯងម្តងទៀត។ ប៉ុន្តែយើងពុំទាន់ទៅដល់ដំណាក់នោះនៅឡើយទេ។ ការសំរេចជាអាយុជីវិត ការជ្រើសរើសដ៏សំខាន់បំផុត, សំរាប់ពេលភ្លាមៗ នេះ, នៅលើខ្មែរក្រហម ៖ ការបដិវត្តន៍* **ឬ** *ប្រទេស។*

---

*សំនួរទី ៧ ៖ រហូតមកដល់កម្រិតណា កម្ពុជាប្រជាធិតេយ្យ*
*អាចសង្ឃឹមលើសាធារណរដ្ឋចិនប្រជាមានិត?* *(នៅទំព័រ ១១១)*

---

# អធិប្បាយ

(១) ការបដិវត្តន៍យួនយកគំនិតតាមការបដិវត្តន៍ចិនដែរ។ ក្នុងសេចក្តីផ្តើមនៃលក្ខន្តិកៈ នៃ ដាង៍ឡាវ-ដុង (គណបក្សនៃអ្នកធ្វើការ, បង្កើតនៅខែមីនា ១៩៥១), គេអាចអាន ៖ "មូលដ្ឋាននៃគណបក្ស ឡាវ-ដុង និងគោលគំនិតទាំងឡាយដែលណែនាំគណបក្សនេះ ក្នុងសកម្មភាពទាំងអស់របស់ខ្លួនគឺ លទ្ធិនៃម៉ាក្ស, អិនហ្គែល ឡេនីន, ម៉ៅ សេទុង, សម្រួលទៅតាមសេចក្តីត្រូវការពិតប្រាកដនៃការបដិវត្តន៍"។ បើគេមើលលក្ខន្តិកៈនៃគណបក្សបដិវត្តន៍នៃកម្ពុជា, ដែលធ្វើឡើងដោយទីបញ្ជាការវៀតមិញនៅស្រុកខ្មែរ ហើយដែលគ្រាន់តែជាសេចក្តីសង្ខេបនៃលក្ខន្តិកៈគណបក្ស ឡាវ-ដុង, គេឃើញតែការពន្យុះឲ្យងប់ងងឹតមុខ, ដូចក្នុងឃ្លានេះជាដើម ៖ "បង្រួបបង្រួមប្រជាជនទាំងមូល ក្នុងរណសិរ្សខ្មែរឥស្សរៈ, ដោយធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រជាជននៃវៀតណាម និងលាវ... ហើយបន្តយ៉ាងខ្ជាប់ខ្ជួនការតយុទ្ធដើម្បីកំទេចឲ្យអស់បារាំងអាណានិគមនិយម, អាមេរិកាំងអន្តរាគមន៍និយមនិងខ្ញុំកញ្ជះវា"។ (មើលសៀវភៅ "វៀត-មិញ" របស់ ប៊ែណាហ្វល់, បណ្ណាគារ អាម៉ង់កូឡាំង ១៩៦០។ អានទំព័រ ៨៣ និង ៨៤ នៃកម្រងនេះដែរ)។

បើសិនជាអ្នកដឹកនាំយួនឥតបានមានគំនិតទុំ ច្បងនីងសរសេរ "ការឃាត់យាំងក្នុងគំនិត" មួយ ដោយដាក់លក្ខខ័ណ្ឌថា ត្រូវសម្រួលលទ្ធិកុម្មុយនិស្តទៅតាមលទ្ធភាព និងស្ថានភាពក្នុងស្រុក, ការបដិវត្តន៍យួនប្រហែលជាសាហាវព្រៃផ្សៃដូចរបស់ខ្មែរក្រហមដែរ។ ប្រយ័ត្នប៉ុណ្ណឹងម្តេច អំពើរំលោភពីសំណាក់អ្នក "ខាងក្រោម" នៅតែបានកើតមានឡើងដូចដែលអ្នកនិពន្ធ ហ្វីលីព ដឺវីល្លេ ចែងក្នុងការអធិប្បាយអំពីការឡើងកាន់តំណែងនៃវៀតមិញ ក្នុងរដ្ឋាភិបាលបណ្តោះអាសន្នទីមួយ នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ១៩៤៥ ៖

"...... ដូច្នេះមែន ការណ៍សំខាន់ក្នុងពេលនេះ មិនមែនពាក្យដែលគេនិយាយ ឬអត្ថបទដែលគេសរសេរក្នុងទីក្រុងទាំងឡាយ ដូចហាណូយ ឬ វេ ទេ។ ព្រោះថានៅទីនោះមានបេសកកម្មពួកសម្ព័ន្ធមិត្តដែលចុះ-ឡើង, ដូច្នេះរដ្ឋាភិបាលត្រូវតែ "ទុកមុខ" ខ្លួន ហើយរក្សាភាពរៀបរយ។ ការណ៍សំខាន់គឺហេតុដែលកើតមានឡើងនៅទីជនបទ។"

"ចាប់ភ្លាមឡើង ការបដិវត្តន៍តាមស្រុកស្រែ-ចំការមានលក្ខណៈផ្តាច់ការ, ដាច់ណាត់តែម្តង។ មុននឹងឧវាទផ្សេងៗ ចំពោះគណៈកម្មការទាំងឡាយនៃប្រជាជនបានត្រូវរៀបចំឡើង, ការបដិវត្តន៍, បដិវត្តន៍មែនទែន, បានចាប់ផ្តើមរួចទៅហើយ។

"នៅតាមឃុំនិងភូមិទាំងឡាយ, អ្នកមានមុខ-មាត់ និងនាម៉ឺនទាំងរយៗ នាក់ ត្រូវគេរករឿង, វាយដំប្រំផាក់, ចាប់, រហូតដល់សម្លាប់រង្គាលផង។ អ្នកនាំអាទិ៍ពួកឡើងកំហាល់ទាំងនោះ ច្រើនតែជនដែលគេមិនស្គាល់, ឯបណ្តាជនវិញ ដែលភ័យតក់ស្លុតជាទូទៅ —ប៉ុន្តែពេលខ្វះយល់ព្រមតាមដែរនោះ— ឥតមានប្រតិកម្មអ្វីឡើយ។ ពន្ធនាគារតូចធំទាំងអស់ ត្រូវគេបើកទ្វារឡើងព្រមគ្នា ហើយជះចេញមកលើប្រទេសនូវអ្នកទោស "នយោបាយ" និងអ្នកជាប់ទោសដោយបទល្មើស, ដែលស្រវឹងជោកដោយការសេងសឹក។ កោលាហល់និងភាពច្របូកច្របល់ រឹតតែស្រួលកើតមានឡើងទៅទៀត ដោយហេតុថាតាំងពីច្រើនខែមកហើយ អំណាចរបស់រដ្ឋាភិបាល, ក្រៅពីនៅក្នុងទីប្រជុំជនធំៗ, មានតែឈ្មោះទេ។"

“បន្តិចទៀតមក គេក៏រាប់លែងអស់នូវចំនួនការលួចប្លន់, ការឆែកឆេរ, ការចាប់ចងដោយស្រេចនឹងចិត្ត, ការបំបាត់ប្រាក់កាស, “ការរឹបអូសយកសម្បត្តិពួកអ្នកមានហ្វាស់ស៊ិះ និងប្រឆាំងបដិវត្តន៍”, និងឃាតកម្ម ក្រោយ (ឬគ្មាន) ការធ្វើហាក់ដូចជាកាត់សេចក្ដីដោយ “តុលាការប្រជាជន” ដែលគេបង្កើតឡើងយ៉ាងឆក់កណ្ដៀត។ ពួកអ្នកប្រឹងប្រែងធ្វើការឲ្យបក្សកុម្មុយនិស្តឥណ្ឌូចិន យល់ថាពេលវេលាមកដល់ហើយ ដែលគេត្រូវអនុវត្តន៍កម្មវិធីធ្វើ “ការបំបាត់មូលធននិយមហ្វាស់ស៊ិះ”, កម្មវិធីដែលបង្រៀនដល់ខ្លួន ក្នុងក្បួនធ្វើឲ្យកើតចលាចល។ ក្នុងទីប្រជុំជនខេត្តនិងឃុំជាច្រើន, ជាពិសេសនៅអណ្ដាមខាងជើងនិងនៅតុងកឹង, គណៈកម្មការនៃប្រជាជន បញ្ជាឲ្យបំបាត់ចោលនូវពិធីបុណ្យប្រពៃណីយផ្សេងៗ, ឲ្យធ្វើការចែកដីស្រែចំការ, ឲ្យរឹបអូសទ្រព្យសម្បត្តិពួកអ្នកមាន, ហើយដឹកនាំកិច្ចការទាំងនេះដោយផ្ទាល់។”

“គណៈកម្មការទាំងឡាយនៃប្រជាជនចូលកាន់កាប់ឃុំទាំងពួង, ហើយស្ដេចចក្រល្អឹតល្អោចទាំងឡាយដែលនៅក្នុងគណៈកម្មការទាំងនោះ ធ្វើការសង្កត់សង្កិននិងភេរវកម្ម។ នៅគ្រប់ទីកន្លែងអំណាចមែនទែននៅក្នុងដៃពួកកុម្មុយនិស្ត ដែលជាញឹកញយច្រើនតែមនុស្សក្រៅឃុំ ឬពួកដែលបង្ហាញខ្លួនជាកុម្មុយនិស្ត។”

“យ៉ាងនេះការបដិវត្តន៍ក៏មានតាំងពីដើមទីនូវលក្ខណៈជាការតយុទ្ធសង្គមយ៉ាងខ្លាំង ពុះពោរបំផុត។ ក្នុងភាគច្រើននៃភូមិភាគទាំងឡាយ ការបដិវត្តន៍នេះបញ្ជាក់ខ្លួនថាមានខ្លឹមសារជាកុម្មុយនិស្ត, ហើយធ្វើឡើងទៅតាមខ្សែបន្ទាត់ដាច់ណាត់ នៃកម្មវិធីឡេនីននិយម។”

“អំពើហួសហេតុទាំងនេះ អាចតែធ្វើឲ្យអាប់ឱនដល់ការបដិវត្តន៍, ឲ្យការនេះធ្លាក់ទៅក្នុងភាពវង្វេងវក់វី។ អ្នកដឹកនាំកុម្មុយនិស្តដឹងភ្ញាមអំពីការនេះ។ ដួងបាក់ម៉ាយ, អ្នកដឹកនាំម្នាក់, និងប្រាប់ខ្ញុំយូរក្រោយមក (នៅខែមីនា ១៩៤៧) អំពីកិច្ចដែលគាត់ខំធ្វើ, ក្នុងនាទីជាអធិការខាងកិច្ចការនយោបាយនិងរដ្ឋបាលប្រចាំភាគខាងកើតនៃណាម-បូ (កូសាំងស៊ីន), ដើម្បីបង្អង់សន្ទុះខ្លាំងក្លាខុសពេលវេលា នៃអ្នកតយុទ្ធខាងក្រោម ដោយពន្យល់ដល់អ្នកទាំងនោះថា ភារៈកិច្ចក្នុងពេលនេះ មិនមែនការធ្វើបដិវត្តន៍កម្មករ-កសិករទេ ប៉ុន្តែគឺការរំលំ “អាណានិគមនិយម” ដោយអំពាវនាវដល់ប្រជាជន ទាំងមូល ឲ្យធ្វើការតយុទ្ធទល់នឹងអាណានិគមនិយមនេះ។”

“ដូច្នេះមែន ចំពោះ ហូ ជីមិញ និងក្រុមរបស់គាត់, ការដណ្ដើមយកឯករាជ្យត្រូវធ្វើមុនអ្វីទាំងអស់។ គាត់យល់ថា ពេលវេលាបើកឱកាសឲ្យណាស់ ហើយប្រហែលជាមិនត្រឡប់មកម្ដងទៀតឡើយ។ ដូច្នេះការអ្វីទាំងអស់ត្រូវធ្វើតំរង់ទៅគោលបំណងនោះ។ ការបដិវត្តន៍ក្នុងសង្គមនៅលើផ្ទៃទីពីរទេ, ក្រោយឆ្ងាយទៅទៀត។ (...) បើការបដិវត្តន៍មានលក្ខណៈតាមមនោគមវិជ្ជា , ពួកហូជីមិញនឹងបង់ខាតទាំងអស់ហើយ។ ដោយមានតែ ៥០០០ នាក់ , ពួកនេះពុំអាចសង្ឃឹមបំបត់បំបែនមហាជនបានទេ។ (...)”

“បង្ក្រាបអំពើហួសហេតុ, រកការរួបរួមប្រជាជនឲ្យបាន ៖ គឺឲ្យទៅដល់គោលដៅទាំងពីរនេះ ដែល ហូ ជីមិញ និងក្រុមគាត់ចាប់ធ្វើការភ្លាម។ ដូច្នេះមែន ហូ ជីមិញ នៅតែជឿជាក់ថា... ការដាក់ដោយគំហុកនូវរបបសង្គមនិយមមកលើវៀតណាម ធ្វើទៅពុំរួចឡើយ។ ប្រជាជនឥតប្រុងប្រៀបនឹងទទួលរបបនេះឡើយ, ដោយមកអំពីទំនៀមទំលាប់និងសតិខ្លួនផង។ ក្នុងកំឡុងច្រើនឆ្នាំទៀត, ប្រទេសវៀតណាមត្រូវដើរយ៉ាងយឺតទៅកាន់សង្គមនិយម តាមការហាត់រៀន និងតាមការប្រព្រឹត្តប្រជាធិបតេយ្យ។ (...)”

*“ក្នុងពេលឥឡូវនេះ ការជោរហួសប្រមាណនៃ “អ្នកតយុទ្ធខាងក្រោម” បានជ្រមុជប្រទេសវៀត-ណាមទៅក្នុងកោលាហល។ ដើម្បីកាន់កាប់កិច្ចការបានវិញ ហូ ជីមិញ មានតែក្រុមមួយតូច, “ខួរ” សាម-សែសិបនាក់នៅហាណូយ, មិនទាំងច្រើនប៉ុណ្ណឹងផងនៅគ្រប់ខេត្តឯទៀត។ ការឃោសនា, ការនិយាយពន្យល់ (ព្រោះកម្លាំងអាវុធមិនទាន់មាននៅឡើយ) ជាមធ្យោបាយតែពីរ ដែលពួកនេះអាចប្រើប្រាស់បាន...”។*

*(ហ្វីលីព ដឺវីល្លែ, ក្នុង “សាវតានៃវៀត-ណាម ពី១៩៤០ ទៅ ១៩៥២”, ហាងបោះផ្សាយស៊ើយ)*

*នៅប្រទេសយួន ការតយុទ្ធវណ្ណៈធ្វើទៅជាមួយការតយុទ្ធដើម្បីឯករាជ្យ (ដំបូងទល់នឹងបារាំង, រួចមកទល់នឹងអាមេរិកាំងដើម្បីបង្រួបបង្រួមប្រទេស)។ ដូចគ្នាដែរ នៅប្រទេសចិន, ម៉ៅសេទុង, ជាមួយគ្នានឹងការតយុទ្ធវណ្ណៈ, បានតយុទ្ធពីដំបូងទល់នឹងជប៉ុន។ នៅប្រទេសកម្ពុជា មានតែការតយុទ្ធវណ្ណៈប៉ុណ្ណោះ។ បើនៅវៀតណាម ការបដិវត្តន៍បានត្រូវធ្វើឡើងដោយបញ្ញវន្ត, នៅកម្ពុជា គឺអ្នកល្ងីតល្ងង់ដែលធ្វើបដិវត្តន៍ ៖ តើមនុស្សរបៀបណាដែល ខៀវ សំផន, អៀង សារី, សាឡុត សរ ប្រើប្រាស់? ពេលណាជនទាំងបីនេះនឹងត្រូវបាត់ខ្លួនដូចអ្នកឯទៀតដែរ?*

(២) *ពីរដ្ឋាភិបាលបណ្តោះអាសន្នទីមួយនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅឆ្នាំ ១៩៤៥ ទៅ ដៀន បៀនភូ នៅឆ្នាំ ១៩៥៤, មិនត្រឹមតែការបដិវត្តន៍ចិនទេ ដែលបានជាគំរូដល់វៀតមិញ, ប៉ុន្តែបន្ទាប់ពីចាប់កំណើតនៅឆ្នាំ ១៩៤៩ ចិនប្រជាមានិតគាំទ្រយួនតាមផ្លូវសម្ភារៈទៀត។ នៅឆ្នាំ ១៩៥០ កងទ័ពចិនលេខ ២ បានធ្វើឲ្យចេញជារូបរាងនិងបង្ហាត់កងពលធំវៀតមិញលេខ ៣០៤, ៣០៨, ៣១២, និង ៣២០។ ការបដិវត្តន៍កសិកម្ម ដែលហាណូយធ្វើឡើងពីឆ្នាំ ១៩៥៣ ទៅ ១៩៥៦ គឺចម្លងឥតល្អៀងពីគំរូចិន។ ក្នុងរយៈសង្គ្រាមទី២ នៃឥណ្ឌូចិន, ចិនបានជួយយួនខាងជើងច្រើនណាស់ ឧ. ក្រោមគ្រុឝ្ចេវ, សហភាពសូវៀតឲ្យជំនួយយួនខាងជើងតម្លៃ ៣៥០ លានដុល្លារ។ ក្នុងកំឡុងពេលនោះ ជំនួយចិនមកយួនតម្លៃ ៤៥០ លានដុល្លារ។*

(៣) *ការណ៍ដែលគួរឲ្យរន្ធត់មួយទៀត គឺមនុស្សដែលនៅស្រុកខ្មែរ ក្រោយខែមេសា ១៩៧៥ និងមានមួយចំនួនធំដែលពិការ តាំងពីកំណើតនូវកាយ និងសតិដោយដើមហេតុជីវសាស្ត្រ។ តើខ្មែរបដិវត្តន៍ដ៏មហាអស្ចារ្យមួយលាននាក់ ដូចដែលបានគ្រោងទុកដោយខ្មែរក្រហម មានកម្លាំងអ្វីឈមមុខទល់នឹងយួន ៥០ លាននាក់ (៧៥ លាន នៅឆ្នាំ ២០០០!) ក្នុងសុន្ទរកថារបស់ខ្លួននៅប៉េកាំង ប៉ុល ពត បានថា “យើងត្រូវការមនុស្ស ២០ លាននាក់”។ (មើលទស្សនាវដ្តីប៉េកាំង* (Péking Review) *លេខ ៤១, ខែតុលា ១៩៧៧)។ តើ ប៉ុល ពត ចង់បើកទ្វារកម្ពុជាឲ្យ “អ្នកអន្តោប្រវេសន៍” ចិន ឬអ្វី?*

(៤) *ស្មើគ្នានឹងចំនួនអ្នករងគ្រោះដោយគ្រាប់បែកបរមាណូ ហ៊ីរ៉ូស៊ីម៉ា ប្រាំបីដង។*

(៥) *តាំងពីយូរមកហើយ យួនចង់បានកោះខ្មែរណាស់។ ការស្រេកឃ្លាននេះ មិនមែនមកតែពីកំណប់ប្រេងកាតដែលអាចមាននៅក្រោមជាយសមុទ្រនោះទេ, គឺដើម្បីបំពេញសេចក្តីត្រូវការយុទ្ធសាស្ត្រដែរ។ ដូច្នេះមែន, ពេលណាមានការវិវាទ, យួនអាចខ្ទប់ចរាចរមិនឲ្យកប៉ាល់ចូលផែកំពង់សោមបាន បើខ្លួនជាអ្នកកាន់កាប់កោះទាំងនោះ, កំពង់សោមដែលជាផែសមុទ្រតែមួយរបស់ខ្មែរ។*

*កោះខ្មែរធំៗ ពីរាមទៅពាម ហាទៀង គឺ ៖ កោះប្រឡុះ, កោះក្របី, កោះឫស្សី, កោះតាគាវ, កោះស្រមោច, កោះថ្មី, កោះសេះ, កោះត្រល់ (ភូក្វឹក), កោះអង្គ្រែង, កោះសេះមួយទៀត, កោះពោ, កោះអន្ទាយ, និងកោះពីរទៀត នៅឆ្ងាយពីឆ្នេរ ៖ កោះពូឡូវៃ និងកោះតាង។*

## របបតដល់កំរិតណា កម្ពុជាប្រជាធិបតេយ្យ អាច សង្ឃឹមលើសាធារណរដ្ឋចិនប្រជាមានិត?

ចំណាប់ដែលក្មៀកប្រទេសចិនទៅនឹងប្រទេសកម្ពុជា ក្នុងកាលៈទេសៈសព្វថ្ងៃនៃការទាក់ទង ចិន-ខ្មែរ បានត្រូវរឹតឡើងដោយតែពាក្យពីរម៉ាត់ "ប្រយោជន៍រដ្ឋ", ដូចដែលបានសរសេរដោយអ្នកឆ្លើយឆ្លងម្នាក់នៃ ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ាប្រទេស, ណាយ៉ាន់ ចាន់ដា (អានទំព័រ ១០១, លេខយោង ១៦)

នៅខែមករា ១៩៧៣ ពេលដែលសន្និសីទនៅប៉ារីសលើប្រទេសវៀតណាមកំពុងធ្វើឡើង, អនុរដ្ឋលេខាធិការអាមេរិកាំង ស៊ុល្លីវ៉ាន់ បានចោលពាក្យដូចតទៅនេះ ៖ "ប្រទេសចិនចូលចិត្តឃើញមានរដ្ឋ បួន "របៀបស្រុកបល់កង់"[(*)] ជាងឥណ្ឌូចិនតែមួយក្រោមការណែនាំនៃវៀតណាមខាងជើង ដែលនៅក្រោមឥទ្ធិពលសហភាពសូវៀត" (ស៊ិច) (មើលទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ាប្រទេស, ខែកុម្ភៈ ១៩៧៣)។ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលបញ្ចប់សន្និសីទដដែល, ហិនរី គីស្ស៊ិញជើ[(១)] បាននិយាយរបៀបនេះដែរ ទៅកាន់អ្នកការទូតចិនម្នាក់, ដោយចំអន់លេងបន្តិចផង ៖ "បើយើង, អាមេរិកាំង, ជាអ្នកចាញ់, អស់លោក, ចិន, ជាអ្នករងគ្រោះ។"

"ពាក្យលែបខាយ" នៃអ្នកទទួលខុសត្រូវខាងការបរទេសអាមេរិកាំងនេះ និយាយមិនតិចទេ អំពីទំហំនៃការវិវាទ ចិន-រុស្ស៊ី, មិនត្រឹមតែនៅឥណ្ឌូចិនទេ, ប៉ុន្តែនៅក្នុងអាស៊ីភាគអគ្នេយ៍ទាំងមូល។ សហភាពសូវៀតដែលនយោបាយក្រៅប្រទេសចំពោះរដ្ឋទាំងឡាយនៃអាស៊ីភាគអគ្នេយ៍ មិនសូវលោកលន់ប៉ុន្មាន មុនវិវាទនេះកើតឡើង[(២)], កំពុងតែលាតសន្ធឹងឥទ្ធិឫទ្ធិខ្លួនលើភូមិភាគនេះនៃពិភពលោក បន្តិចម្តងៗ ប៉ុន្តែជាក់ឡើងៗ។ តាមឧបាយនេះ រុស្ស៊ីចង់ឡោមព័ទ្ធចិន តាមរយៈប្រទេសទាំងឡាយដែលនៅក្រោមឥទ្ធិពលខ្លួន។

ក្រោយបរាជ័យនៃអាមេរិកាំងនៅឥណ្ឌូចិន, គឺដោយសារសទ្ទុះសតិប្រឆាំងយួនរបស់ខ្មែរ ដែលប្រទេសចិនអាចតោងជាប់មែកឈើកម្ពុជា, ក្នុងពេលដែលវៀត-ណាម[(៣)] និងលាវ[(៤)] ធ្លាក់ទៅក្រោមឥទ្ធិពលសហភាពសូវៀត។ ដូចជាចិនត្រូវការប្រទេសកម្ពុជាដែរ ខ្មែរក្រហមត្រូវការប្រទេសចិន។ ពួកនេះបែរទៅរកចិនមិនត្រឹមតែដើម្បីទប់ទល់នឹងកម្លាំងយួនទេ, ប៉ុន្តែដើម្បីពង្រឹងអំណាចខ្លួនដែរ ដោយធ្វើការបំបាក់ការប៉ុនប៉ងប្រឆាំងការបដិវត្តន៍។ ប៉ុន្តែគេអាចសួរថា តើក្នុងកំឡុងពេលប៉ុន្មាន ឥទ្ធិពលចិនលើកម្ពុជា នឹងនៅតែខ្លាំងដដែល? បានចាប់ផ្តើមរួចទៅហើយ ការប្រណាំងប្រជែងគ្នាយ៉ាងស្វិតស្វាញ រវាងមហាអំណាចសង្គមនិយមទាំងពីរ នៅប្រទេសថៃ, ភូមា និងម៉ាឡេស៊ី។ ទំនាស់ចិន-រុស្ស៊ីនៅឥណ្ឌូចិន ដែលបណ្តាក់គ្នាមក ក្លាយទៅជាទំនាស់ ខ្មែរ-យួន, យក "ចំណោទមុខពីរ" មួយយ៉ាងពិបាក មកឲ្យចិនដោះស្រាយ។ ដោយវៀតណាមនិងកម្ពុជានៅក្នុងសេរៀនមនោគមវិជ្ជាដូចគ្នា ប្រទេសចិនត្រូវជ្រើសរើសយកការដោះស្រាយមួយដែលមិនឃ្លោង ៖ ទៅលើមួយដែលជាប់នឹងចិនតាមលោហិត និងតាមសាវតារប់សតវត្សរ៍, ឬ ទៅលើមួយទៀត ដែលចិនការពារដើម្បីប្រយោជន៍ខ្លួនផ្ទាល់។

---

(*) សំដៅទៅរដ្ឋ ប៊ុលការី, យូហ្គោស្លាវី, និងអាល់បានី ដែលមានរបបសង្គមនិយមដូចគ្នា ប៉ុន្តែមាន "មិត្តសម្លាញ់" ខុសគ្នា។

*រឿងនេះដឹងហើយ, យើងត្រូវសំគាល់ថា សង្គ្រាមមួយទៀតរវាងកម្ពុជានិងវៀតណាមៗ ដែលឥឡូវនេះ គ្រាន់តែនៅក្នុងការស្មានទុក, អាចនឹងផ្ទុះឡើងស្អែកៗ នេះៗ ការណ៍នេះអាចកើតមានឡើងណាស់ ដូចដែលប្រវត្តិសាស្ត្រនៃអាស៊ីបានបង្រៀនដល់យើង, ប្រវត្តិសាស្ត្រដែលមានការបត់បែនជាច្រើន ដែលគេពុំអាចស្មានទុកជាមុនឡើយៗ ក្នុងករណីចំបាំងខ្មែរ–យួន, ប្រទេសចិនមានតែជំរើសបីទេ ៖*

ក) *ចិនផ្តល់ជំនួយយ៉ាងពេញលេញខាងអាវុធយុទ្ធភ័ណ្ឌដល់ខ្មែរក្រហមៗ ប៉ុន្តែពួកនេះទប់ទល់បានទេ នឹងកងទ័ពយួនដែលមានច្រើនជាងយ៉ាងលើសលុប[៥] និងអាវុធយ៉ាងទំនើបរបស់រុស្ស៊ី (ជាពិសេសអាកាសយានដែលនឹងត្រួតត្រាផ្លូវអាកាស)? ពេលណាយោធាខ្លួនស្លាប់អស់ច្រើនទៅ តើខ្មែរក្រហមបែរទៅរកនរណា? ទៅរកបណ្តាជនដែលខ្លួនយកទៅធ្វើទាសករ?*

១) *កងទ័ពខ្មែរក្រហមខ្ចាត់ខ្ចាយទៅ, តើចិនចាប់ដៃម្ចាស់ "សហព័ន្ធឥណ្ឌូចិនឬទេ? ដើម្បីនៅឲ្យស្មើមុខនឹងសហភាពសូវៀត? (គេបានឃើញរួចម្តងមកហើយ ការណ៍ដែលចិន "ត្រឡប់ក្រោយ, បែរ!" នៅមុខព្រឹត្តិការណ៍ដែលខ្លួនខាឃាំងពុំបាន គឺនៅពេលដែលខ្មែរក្រហមឈ្នះលើសីហនុ)ៗ*

គ) *តើចិនប្រកាសសង្គ្រាមទល់នឹង វៀតណាម "ដីតូច" ឬទេ, ការណ៍ដែលអាចនាំឲ្យសហភាពសូវៀតធ្វើអន្តរាគមន៍ ហើយបង្កើតផលវិបាកដែលគេស្ទើរតែមិនហ៊ាននឹកទៅដល់? ប្រទេសលាវដែលជាប់ព្រំដែនគ្នា ធ្លាក់ទៅក្នុងដៃរុស្ស៊ីទៅហើយ, តើកម្ពុជា គួរចិនធ្វើពលិកម្មឲ្យឬទេ?*

*ប៉ុន្តែគេពុំអាចស្មានទុកជាមុនបានឡើយ ថាចិននឹងមានប្រតិកម្មយ៉ាងនេះ យ៉ាងនោះៗ ដូចជាប្រទេសទាំងអស់នៅអាស៊ីដែរ (លើកលែងតែជប៉ុន?) ដែលបណ្តាជនពុំដែលបានស្គាល់ឡើយ ថាអ្វីជាប្រជាធិបតេយ្យពិតប្រាកដ, ប្រទេសចិន, មហាប្រទេសមួយដែលអារិយធម៌នៅក្នុងពពួកចាស់ជាងគេទាំងអស់ក្នុងពិភពលោក, នៅតែជាប្រទេសមួយដែលនយោបាយរដ្ឋនៅក្នុងកណ្តាប់ដៃមនុស្សតែមួយក្រុមៗ ប៉ុន្តែបើយើងបើកទំព័រប្រវត្តិសាស្ត្រយើងឡើងវិញ យើងនឹងឃើញហេតុការណ៍ខ្លះ ដែលអាចឲ្យយើងរិះគិតៗ*

*ក្នុងរយៈកាលទាំងមូលនៃអំណាចរបស់ សីហនុ, គេអាចថាប្រទេសកម្ពុជាជារណបប្រទេសចិនក៏បានដែរ (អាន "ទំនាក់ទំនងខ្មែរ–ចិន")ៗ ក្នុងគ្រប់ពេលមានទំនាស់ទឹកដីជាមួយប្រទេសជិតខាង, សម្តេចគំរាមថាចិននឹងលើកទ័ពមកជួយកម្ពុជាៗ នៅខែសីហា ១៩៦២, ក្រោយពីបានធ្វើឲ្យកោះភូក្វឹក (កោះត្រល់)[៦] ទៅជាមូលដ្ឋានជើងទឹកយ៉ាងធំបំផុតនៃប្រទេស ដើម្បីបញ្ចប់ការលួចបញ្ចូលខ្លួននៃវៀតកុង ដែលមកពីស្រុកខ្មែរតាមសមុទ្រ, វៀតណាមខាងត្បូងទាមទារកោះមួយចំនួនពីកម្ពុជា ៖ កោះថ្មី, កោះសេះ, កោះអន្ទាយ, កោះតាគាវ និងកោះពោៗ ប្រទេសទាំងពីររិះតែនឹងច្បាំងគ្នាៗ ពីក្រុងប៉េកាំង ជូអេនឡាយ គំរាមថានឹងឲ្យទ័ពចិនធ្វើអន្តរាគមន៍ៗ*

*នៅខែមីនា ១៩៦៤ លោក លន់ នល់, ដែលក្នុងកាលនោះជានាយអគ្គសេនាធិការកងទ័ព, ធ្វើទស្សនកិច្ចមួយនៅប្រទេសចិន ដែលនឹងឲ្យមកគាត់នូវអាវុធសំរាប់បីកងវរសេនាតូចៗ ក្នុងពេលនោះប្រធាន ម៉ៅ ប្រាប់ទៅគាត់ថា ៖ "យើងនឹងនៅក្បែរប្រទេសកម្ពុជាជានិច្ច ក្នុងការទប់ទល់នឹងចក្រពត្តិអាមេរិកាំងនិងបរិវារៗ" អ្នកដឹកនាំខ្មែរឡើងទឹកចិត្តនឹងការរាប់អានរបស់អ្នកដឹកនាំចិនណាស់ ហើយក៏បង្កើតរឿងមិនពិតមួយ, ប្រហែលជាដើម្បីបន្លំចិត្តពួកវិទ្ធង្សនាខាងឆ្វេង ជាងដើម្បីបំភ័យអ្នកជិតខាងដែលកោងកាច ៖ ពាក្យចចាមអារាមមួយលេចចេញនៅភ្នំពេញ រួចបន្ទាប់មកពាសពេញប្រទេសកម្ពុជា ថាកប៉ាល់ហោះចិនទាំងពាន់ ដែលគេលាបសញ្ញាទ័ពអាកាសខ្មែរ ត្រៀមខ្លួនទុករួចស្រេច នឹងធ្វើអន្តរាគមន៍ពេលណាកម្ពុជាត្រូវឈ្លានពានដោយប្រទេសជិតខាង!*

*សុន្ទរកថានៃសម្ដេចសីហនុក្នុងសមាជជាតិ នៅខែធ្នូ ១៩៦៤, ដែលប្រាប់ដល់ប្រទេសឲ្យដឹងថា ចិនសន្យាតែផ្ដល់អាវុធ មិនធានាធ្វើអន្តរាគមន៍កងទ័ពទេ ពេលណាមានការឈ្លានពាន, ក៏ធ្វើឲ្យរលាយសេចក្ដីសង្ឃឹមនោះមួយពេលទៅ។*

*ស្អាក់នៅប៉េកាំងក្រោយខែមីនា ១៩៧០, សីហនុសង្ឃឹមទាំងស្រុងលើ ជូអេនឡាយ។ ប្រធានរណសិរ្សរួបរួមជាតិនៃកម្ពុជា —ហើយស្រុកខ្មែរទាំងមូលក៏ប្រហែលជាដូច្នេះដែរ— ជាអ្នករងគ្រោះនឹងការជឿស្លុង[៧] លើចិននេះ។*

*ចំណែកខាង "មតិសាកលលោក" វិញ, ចូរយើងឈប់សង្ឃឹមផ្ដេកផ្ដួលលើទៅ។ ប្រតិកម្មនៃពិភពលោកចំពោះមុខការសម្លាប់រង្គាលអស់ខ្មែរយើងរាប់លាននាក់ បង្ហាញឲ្យយើងឃើញច្បាស់នូវប្រសិទ្ធភាពនៃ "មតិពិភពលោក" នេះ។ ករណីនៃប្រជាជាតិប៉ាឡេស្ទីន ក៏ជាឧទាហរណ៍មួយដែរ។ វាសនានៃកម្ពុជាផ្ដេកផ្ដួលទៅលើតែការប្រឹងប្រែងរបស់* ***ខេមរជន*** *ប៉ុណ្ណោះ។*

*គឺ* ***ខេមរជន*** *ទេ ដែលនឹងសំរេចថាខ្លួននឹងស្គាល់ ឬនឹងមិនស្គាល់វាសនានៃជនជាតិចាម[៨]។*

---

*សំនួរទី ៨ ៖ ដោយវាយប្រហារថៃជាច្រើនដង តើខ្មែរក្រហមចង់យកទឹកដីចាស់វិញឬទេ? ដូច្នេះគេមិនជាអ្នកជាតិនិយមខ្លាំង? (នៅទំព័រ ១១៨)*

---

# អធិប្បាយ

(១) គឺ ហិនរី គិស្សិញជើ ដែលបានបំពេញករណីយកិច្ចខ្លួនជាអាមេរិកាំង ដោយប្រានប្រទេសខ្មែរចូលក្នុកភ្លើងសង្គ្រាម ដើម្បីស្រង់ជីវិតទាហានអាមេរិកាំង។

(២) កន្ទែងសំរាប់ឥណ្ឌូចិនក្នុងនយោបាយក្រៅប្រទេស នៃសហភាពសូវៀត ក្រោម នីគីតា គ្រូឆេវ មិនសូវសំខាន់ប៉ុន្មានទេ។ ចាប់តាំងពីឆ្នាំ ១៩៦៥ អាឡេចស៊ុះ កុសស៊ីហ្គីន កែប្រែជាថ្មីនូវនយោបាយរុស្សីចំពោះវៀតណាមខាងជើង និងកូរ៉េខាងជើង។

(៣) ក្នុងពេលថ្មីៗ នេះ យ៉ា ង្វៀងយ៉ាប់ បានថ្លែងការណ៍ថា ៖ "នៅឆ្នាំ ២០០០ វៀតណាមនឹងលែងជាប្រទេសពុំសូវល្អួតលាស់ហើយ"។ ក្នុងពេលដែលអ្នកដឹកនាំខ្មែរក្រហមឲ្យសំឡាប់ពួកពេទ្យ, អ្នកបច្ចេកទេស, បញ្ញាវន្ត, ឲ្យបិទសាលានិងសាកលវិទ្យាល័យ, អ្នកដឹកនាំយួនចាត់វិធានការណ៍ផ្ទុយទៅវិញ។ ដើម្បីធ្វើឲ្យខ្លួនទំនើប វៀតណាមបែរទៅរកសហភាពសូវៀតជាពិសេស, ប៉ុន្តែបច្ចេកទេសនៃបស្ចឹមទិស ក៏យួនខំរកដែរ។

(៤) ប្រទេសលាវជាចំណីមួយ ដែលយួនស្រួលលេប ដោយហេតុថា ៖

ក- លាវមានព្រំដែនជាប់នឹងវៀតណាមខាងជើង

ខ- លើផ្ទៃដីទំហំ ២៣៦ ០០០ គ.ម², ប្រជាជនលាវមានចំនួនតែ ៣ លាននាក់ នៅឆ្នាំ ១៩៧៥ (មិនទាំងដល់ ១៣ នាក់ ក្នុង១ គ.ម² ផង, គឺថាតិចជាង ១ ជា ៣ បើប្រៀបទៅនឹងកម្ពុជាមុនខែមេសា ១៩៧៥)។ ប្រជាជនដ៏តិចនេះបែងចែកជាជនជាតិសាសន៍ផ្សេងៗ ច្រើនទៅទៀត, ជាហេតុឲ្យសង្គមអាចប្រេះឆាបានដោយស្រួល។ មួយចំណែកទៀត ពាក់កណ្ដាលប្រទេសលាវបានជ្រួតជ្រាបនឹងវប្បធម៌យួនទៅហើយ (ប៉ាថេតឡាវ, រដ្ឋមន្ត្រីទីមួយសព្វថ្ងៃ កៃសូនផុំវិហាន មានឪពុកយួន, ចំណែកប្រមុខរដ្ឋម្ចាស់សុផានុវង្ស មានប្រពន្ធយួន)។

សន្ធិសញ្ញាការពារគ្នាទៅវិញទៅមក, ដែលបានចុះក្នុងពេលថ្មីៗ នេះ ហើយដែលចងលាវនឹងវៀតណាម ក្នុងរយៈពេល ២៥ឆ្នាំ, គឺជាសាលក្រមកាត់ទោសប្រហារជីវិតលាវ។ យូរទៅ, បើគ្មានអ្វីមកធ្វើឲ្យប្រែប្រួលស្ថានការណ៍ធម្មតា, ប្រជាជនលាវនឹងក្លាយទៅជាអាណិកជនមួយក្រុម ក្នុងសមុទ្រជនជាតិយួន។

(៥) ច្បាប់មួយថ្មីៗ នៅវៀតណាម អនុញ្ញាតឲ្យរដ្ឋាភិបាលទុកទាហានទាំងអស់ បំរើកងទ័ពតទៅទៀត, ហើយដាក់ការទទួលខុសត្រូវខាងអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងដៃរដ្ឋមន្ត្រីក្រសួងការពារប្រទេស, យ៉ា ង្វៀងយ៉ាប់។ តទៅនេះ គឺតារាងប្រៀបធៀបកងទ័ពយួននិងខ្មែរ (ស្រង់ចេញពីសារពត៌មាន ឡឺម៉ុងដ៍ ថ្ងៃ ៣ មេសា ១៩៧៨) ៖

**<u>ទ័ពយួន</u>**

ទូទៅ = ទាហាន ៦១៥ ០០០ នាក់។ កងយាមព្រំដែន, យាមឆ្នេរសមុទ្រ និងកងសន្តិសុខប្រជាជន = ៥០ ០០០ នាក់។ កងប្រជារាស្ត្រកាន់អាវុធ = ១ ៥០០ ០០០ នាក់។

ជើងគោក= ១៨ កងពលធំថ្មើរជើង។ ៣ កងវរសេនាធំរថក្រោះ។ ២០ កងវរសេនាធំបាញ់កាំជ្រួចហោះ "សាម"។ ៤០ កងវរសេនាធំកាំភ្លើងបាញ់យន្តហោះ។ មានជាពិសេស ៩០០ រថក្រោះមធ្យម ធុន តេ-៣៤, តេ-៥៤ និង តេ-៥៩។

ជើងអាកាស = ១២ ០០០ នាក់ ៖ យន្តហោះចម្បាំង ១៩៨ (ជាពិសេស ១១០ មិច-១៧ និង ស៊ូខូយ-៧, ៨០ មិច-១៩ និង មិច-២១)។ យន្តហោះដឹកនាំ ៥០ ឧទ្ធម្ភាគចក្រ ២៥។

ជើងទឹក = ៣ ០០០ នាក់ ៖ នាវាអមការពារ ២។ កាណូតលឿនបាញ់កាំជ្រួចហោះ ៤។ កាណូតផ្សេងៗ ទូកឡើងគោក ៖ ៨០។ ឧទ្ធម្ភាគចក្រ ១០ ។ សំណល់ពីអាមេរិកាំង ៖ រថក្រោះ ៥០០។ យន្តហោះនិងឧទ្ធម្ភាគចក្រ ១ ១០០។

## ទ័ពខ្មែរ

ទូទៅ = ទាហាន ៨០ ០០០ នាក់។ ចែកជា ៤ កងពលធំ និង ៣ កងវរសេនាធំស្វយ័ត។

ជើងគោក = រថក្រោះស្រាលដឹកយោធា ១៧៥។ ២៦ កាំភ្លើងធំ ធុន ១៥៥ ម.ម., ២០០ កាំភ្លើងធំ ធុន ១០៥ ម.ម., កាំភ្លើងត្បាល់និងកាំភ្លើងធំមិនថយក្រោយ ធុន ១០៧ ម.ម.។ សម្ភារៈទាំងនេះធ្វើដោយចិន រុស្ស៊ី និងអាមេរិកាំង។

ជើងអាកាស = ប្រហែលជាភ្ជាប់ទៅទ័ពជើងគោក។ មានយន្តហោះចម្បាំង ១០ ធុន អាអិណា-២០, យន្តហោះដឹកនាំ ១០, យន្តហោះសំរាប់ហាត់ ៣៥, ឧទ្ធម្ភាគចក្រ ២៥។

ជើងទឹក = កប៉ាល់តូចធ្វើល្បាត ទូកឡើងគោក = ១៥០។

(៦) កោះត្រល់ត្រូវបានបារាំងឲ្យទៅយួន ក្នុងពេលភ្ជាប់ កូសាំងស៊ីន ទៅវៀតណាម នៅឆ្នាំ ១៩៤៩ (ជាមួយគ្នានឹងកោះ ប៉ារ៉ាសែល ដែលចិននិងយួនដណ្តើមគ្នាសព្វថ្ងៃ)។ បើគេមើលផែនទីឆ្នេរសមុទ្រខ្មែរ, គេអាចតែស្រងាកចិត្តនឹងអយុត្តិធម៌ពីរជាន់ នៃអាជ្ញាធរបារាំងសម័យនោះ។

(៧) ការទុកចិត្តស្លូក, ការសង្ឃឹមហួតក្លួចខ្លួន, ការជឿស្ពុងលើអ្វីមួយដែលមិនពិត មិនប្រសិទ្ធដូចស្មាន, អាចជាគ្រោះថ្នាក់មួយយ៉ាងធំដល់សង្គម បើមនុស្សក្នុងសង្គមនោះមានគុណវិបត្តិទាំងនេះច្រើនគ្នាពេក។ ឧទាហរណ៍ ៖ មានមិនតិចទេ អ្នកដែលបានយកឈ្មោះបីនេះ " ហ៊ូ យន់, ហ៊ុយ នឹម, ខៀវ សំផន" ជានិមិត្តរូបនៃការស្អាតស្អំនៃជាតិនិយមខ្មែរ, ជាសង្ឃឹមរបស់ប្រទេសកម្ពុជា។ សង្គមខ្មែរយើងប្រព្រឹត្តទំលាប់អាក្រក់មួយ ដែលបង្កើតនិងកំឡាគុណវិបត្តិខាងលើនេះ, ឬយ៉ាងហោចណាស់ ក៏សណ្តំការវាងវៃនិងសុកនិច្ច័យដែរ។ ទំលាប់អាក្រក់នេះគឺជំនឿលើអារក្សអ្នកតា ទេវតា ឥន្ទ្រព្រហ្ម ទសបារមី

*វត្តសក្តិសិទ្ធ ។ល។ មិនត្រឹមតែជនធម្មតាទេ ដែលជឿហើយធ្វើពិធីក្នុងជីវិតផ្ទាល់ខ្លួន, គឺរហូតដល់ស្តេចផែនដី (និងប្រធានាធិបតី) ដែលចាត់ការរដ្ឋតាមពិធីនោះ ៖ បួងសួងសុំទឹកភ្លៀង ឲ្យឧទ្ធម្ភាគចក្របាចខ្សាច់ "ព័ទ្ធសីមា" ជុំវិញភ្នំពេញ ។ល។*

*ក្រោយខែមេសា ១៩៧៥ នេះទៀត ក៏នៅមានអ្នកនយោបាយយើង "ចាក់គម្ពីរ" ដើម្បីគិតគូរការរំដោះជាតិ!*

(៨) *ជនជាតិចាមមានសណ្តានសាសន៍ ដូចមនុស្សដែលនៅជ្រោយម៉ាឡេស៊ី និងនៅក្នុងកោះដ៏ច្រើននៃមហាសមុទ្រប៉ាស៊ីហ្វិក (សាសន៍ម៉ាឡេយូ — ប៉ូលីណេស៊ីយែន)។ នៅដើមគ្រិស្តសករាជ, ជនជាតិនេះបានចូលមកនៅតាមជាយសមុទ្រ ដែលលាតសន្ធឹងពីទ្វារអណ្ណាមមកដល់ជ្រោយវ៉ារ៉ែឡា។ ចាប់ពីសតវត្សរ៍ទី ១០ ទៅ, ចាមបានប៉ះទង្គិចនឹងខ្មែរ ក្នុងពេលដែលខ្លួនកំពុងត្រូវយួនរុញច្រានចុះពីទិសខាងជើង។ ក្នុងកំឡុងសតវត្សរ៍ទី ១២ ទាំងមូល ចាមនឹងខ្មែរច្បាំងគ្នារហូត ដោយមានការកាន់កាប់ទឹកដីគ្នាទៅវិញទៅមក។ នៅឆ្នាំ ១១៧៧, បន្ទាប់ពីបានវាយសម្រុកអង្គរ ដោយមិនឲ្យខ្មែរដឹងខ្លួនជាមុន, ចាមកាន់កាប់រាជធានីចំនួនប្រាំឆ្នាំ។ ក្នុងឆ្នាំ ១១៨១, កូនរបស់ស្តេច ធារានិន្ទ្រាវរ្ម័នទី២ (១១៥០-១១៦០) រំដោះអង្គរវិញបាន ហើយឡើងសោយរាជ្យក្រោមឈ្មោះថា ជ័យវរ្ម័នទី៧ ។ ឆ្លើយតបនឹងការឈ្លានពានមួយរបស់ចាម នៅឆ្នាំ ១១៩០, ជ័យវរ្ម័នទី៧ វាយលុកចូលប្រទេសចំប៉ា។ ចាប់តាំងពីឆ្នាំ ១២០៣ ទៅ, ស្រុកចំប៉ាក្លាយទៅជាខេត្តមួយរបស់ខ្មែរ។ នៅឆ្នាំ ១២២៧, ស្តេចឥន្ទ្រាវរ្ម័នទី២ (១២០១-១២៤៣) ដែលជាពុទ្ធសាសនិកជនយ៉ាងជ្រះថ្លាដូចឪពុក (ជ័យវរ្ម័នទី៧) ដែរ ហើយដែលចង់អនុវត្តន៍មេត្តាករុណាធម៌, បញ្ជាឲ្យដកទ័ពចេញពីចំប៉ា។ ក្នុងឆ្នាំដដែល, អភិបាលខេត្តចំប៉ាទទួលម្កុដជាស្តេច ហើយប្រទេសចំប៉ាក៏មានរាជាធិបតេយ្យផ្ទាល់វិញ។ ប៉ុន្តែ ចេញពីអាណាចក្រខ្មែរមិនបានយូរប៉ុន្មាន, ប្រទេសចាមត្រូវយួនវាយលុកទៀត។*

*នៅសតវត្សរ៍ទី ១៨, ប្រទេសចំប៉ា បានបាត់ពីផែនទីពិភពលោក ហើយប្រជាជនចាមក៏បានស្លាប់បាត់បង់។ អ្នកដែលនៅសល់ រត់ទៅជ្រកកោនឯកម្ពុជា (អាណិកជនមួយក្រុមតូច រស់នៅក្នុងកូសាំងស៊ីន)។ ក្នុងឆ្នាំ ១៩៧០, ជនជាតិចាមនៅកម្ពុជាមានចំនួន ៨០ ០០០ នាក់ ដែលច្រើនតែរស់នៅដោយការនេសាទ។ ផ្ទុយនឹងជនជាតិចិន ដែលបានខិតខំបញ្ចូលខ្លួនក្នុងសង្គមខ្មែរ ហើយក្នុងពេលជាមួយគ្នា ធ្វើឲ្យខ្មែរជ្រួតជ្រាបនឹងវប្បធម៌ខ្លួនដែរ, ចាមតែងតែរស់នៅដាច់ដោយឡែក ក្នុងសហគមន៍ខ្លួន។ ការណ៍នេះប្រហែលជាមកពីសាសនានៃជនជាតិចាម, ហៅខ្មែរឥស្លាម (ប្រទេសចំប៉ាដែលមានវប្បធម៌យោងទៅឥណ្ឌា បានកាន់សាសនាមហាម៉ាត់ នៅសតវត្សរ៍ទី ១៥)។ ដោយខ្វល់ខ្វាយ ចង់រក្សាទុកកេរ្តិ៍មរតកវប្បធម៌និងសាសនាខ្លួន, ចំណងដែលជាសន្ទុះព្រលឹងធម្មតា របស់ក្រុមអាណិកជន, គ្រួសារចាមឲ្យកូនណាដែលពូកែ ចូលធ្វើការក្នុងរដ្ឋការនិងកងទ័ពខ្មែរ។ មន្ត្រីនិងនាយទាហានចាមទាំងនោះ មានភារៈការពារប្រយោជន៍នៃសហគមន៍ខ្លួន។ ក្នុងចំណោមនោះ, អ្នកដែលបានបំពេញមុខការនេះយ៉ាងពេញលេញ គឺ អតីតៈឧត្តមសេនីយ៍ ឡេះ កាសែម។ អ្នករៀបចំយ៉ាងសំខាន់ម្នាក់ នៃ "រដ្ឋប្រហារ" នៃថ្ងៃ ១៨ មីនា, ឡេះ កាសែម ជាដៃស្តាំមួយនៃ លន់ នល់ ក្នុងពេលដ៏យូរ។ ឧត្តមសេនីយ៍ កាសែម បានត្រូវលោក លន់ នល់ ចាត់ឲ្យបំពេញបេសកកម្មសម្ងាត់ជាច្រើន។ ជាមួយនឹងមរណភាពរបស់គាត់នៅម៉ាឡេស៊ីក្នុងពេលថ្មីៗ នេះ, គឺឃ្លាំងមួយយ៉ាងធំ នៃរឿងសម្ងាត់ក្នុងប្រវត្តិសាស្ត្រខ្មែរសព្វថ្ងៃ ដែលបាត់បង់។*

*ជាមួយនឹងការឡើងកាន់អំណាចនៃខ្មែរក្រហម, ពួកខ្មែរឥស្លាមបានស្គាល់មហាវិយោគមួយទៀត ៖ ការសម្លាប់រង្គាល ដូចដែលបានស្គាល់នឹងកំពុងតែស្គាល់ បងប្អូនយើងក្នុងស្រុកដែរ។ ចាមមួយចំនួនតូចបានចេញរួចពីកម្ពុជា, ហើយរកឃើញជំរកក្នុងប្រទេសមួយទៀត ជាពិសេសម៉ាឡេស៊ី។ ចាមបានបាត់មែនទែនហើយពីបញ្ជីមនុស្សរស់។*

*យើង, ខ្មែរ, ត្រូវទាញដំបូន្មានចេញពីសាវតាប្រទេសចំប៉ានិងប្រជាជនចាម។ អ្នកដែលយល់ថា ការព្រួយបារម្ភអំពីជីវិតប្រជាជាតិខ្មែរ ជាទុទិដ្ឋិនិយម, គួរឈប់មើលឆាយប្រវត្តិសាស្រ្ត ហើយគិតពិចារណាឡើងវិញ។*

---

*ដោយវាយប្រទេសថៃជាច្រើនដង ក្រែងខ្មែរក្រហមចង់យក ទឹកដីចាស់វិញទេឬ? ដូច្នេះគេមិនជាអ្នកជាតិនិយមខ្លាំង?*

*នៅលើដីនេះ គ្មានប្រទេសណានៅក្នុងកាលៈទេសៈភូមិសាស្ត្រនយោបាយមួយ ដែលជួបចត់ដូចប្រទេសខ្មែរទេ ៖ ការណ៍ដែលមានអ្នកជិតខាងពីរចង់ ពង្រីកទឹកដី[១]។*

*ដើមស្រល់ថៃ, ដែលល្បីថាចន្លុលយ៉ាងច្បាស់នូវការប្រែប្រួលធំៗ នៃវាយោននយោបាយអន្តរជាតិ, ដូចជាមាន, លើកនេះ, នូវការពិបាកក្នុងភាពទន់ភ្លន់របស់ខ្លួន។ សម័យថ្មីនៃអំណាចផ្តាច់ការនៃវណ្ណៈកម្មករ កសិករ, ដែលបានត្រូវគេនិយមក្នុងប្រទេសទាំងបីនៃឥណ្ឌូចិន, ធ្វើឲ្យប្រទេសថៃព្រួយបារម្ភ។ ឧទាហរណ៍ខ្មែរ រិតតែបំភ័យថៃទៅទៀត ដែលស្ទាក់ស្ទើរនឹងបែរខ្លួនទៅរកទិសដូចគ្នា។ កំពុងតែប្រែប្រួលពេញទំហឹង, ថៃរកការដោះស្រាយមួយដើម្បី "ចេញ" ខ្លួនឲ្យរួច ដោយមិនឲ្យបង់ខាតច្រើន។*

*"ក្នុងបច្ចុប្បន្ននេះ សៀមនៅទន់ខ្សោយខាងផ្ទៃក្នុង ពុំអាចលាតសន្ធឹងតទៅទៀតបានទេ បើមិនដូច្នោះឯកភាពសៀមច្បាស់ជាត្រូវទទួលការគំរាមកំហែងពីជនជាតិភាគតិច យ៉ាងធ្ងន់មិនលែងឡើយ ការលាតសន្ធឹងហួសមាឌ នឹងនាំមកឲ្យសៀមនូវភាពទន់ខ្សោយវិញទេ...។", លោក នួន ឃឿន បានសរសេរនៅឆ្នាំ ១៩៧០។ ក្នុងពេលសព្វថ្ងៃនេះ, ជាលើកទី២, ការសន្និដ្ឋានរបស់ នួន ឃឿន ឲ្យឃើញថាត្រូវដូច្នេះមែន[២]។ ដើម្បីលេបកម្ពុជា និងលាវបាន វៀតណាមត្រូវធ្វើឲ្យថៃនៅនឹងថ្កល់ ក្នុងជំហរអ្នកចាំតែការពារខ្លួន។ ការត្រួតត្រាលើលាវនឹងសំរួលយ៉ាងច្រើនដល់ការសំឡុតនេះ។ ការដែលឧប្បត្តិហេតុតាមព្រំដែនខ្មែរ-សៀម និងលាវ-សៀម បានកើតឡើងជាច្រើនក្នុងពេលជាមួយគ្នា ធ្វើឲ្យមានសំនួរនេះ ៖ តើមនុស្សដែលកាន់អំណាចមែនទែននៅកម្ពុជាសព្វថ្ងៃនេះ ជាខ្មែរ ឬមួយជាយួន (កាត់ ឬមិនកាត់) ពួនក្រោមសញ្ជាតិខ្មែរ?[៣] ព្រោះថា គេពុំអាចបដិសេធបានទេ ការណ៍ដែលពួកនេះបំរើប្រយោជន៍យួន, ទាំងក្នុងព្រំដែន ទាំងក្រៅព្រំដែន។*

*តើប្រជាជនខ្មែរ, លាវ និង វៀតណាម អាចចាំទទួលអ្វីខ្លះ បានពីលោក "សេរី", ជាពិសេសពីសហរដ្ឋអាមេរិក?*

*ក្រោយពីបានមានអំណាចយ៉ាងខ្លាំងលើឥណ្ឌូចិន ក្នុងកំឡុងពេលជាង ២៥ ឆ្នាំ, សហរដ្ឋអាមេរិកបានដកខ្លួនថយចេញ ដោយទុកតែអនុស្សាវរីយ៍យ៉ាងលាមក លប់លាងយ៉ាងណាក៏ពុំជ្រះឡើយ។ តើប្រវត្តិសាស្ត្រនិយាយត្រូវ ឬខុស បើឲ្យ "ចក្រពត្តិនិយមអាមេរិកាំង" តែម្នាក់ឯងទទួលខុសលើមហន្តរាយនៅឥណ្ឌូចិន និងលើទុក្ខវេទនាដែលបានត្រូវរងដោយមនុស្ស ពី ២ ទៅ ៣ តំណ ក្នុងប្រជាជនទាំងបី? អាចថាត្រូវក៏បាន, អាចថាខុសក៏បាន។*

*ប៉ុន្តែនៅលើដីនេះ, បើមានរដ្ឋាភិបាលមួយដែលគ្មានសិទ្ធិនិយាយពី “សិទ្ធិមនុស្ស” ហើយជាពិសេស ពីសិទ្ធិមនុស្សនៅកម្ពុជា, គឺច្បាស់ជារដ្ឋាភិបាលអាមេរិកាំងនេះឯង។ កិច្ចទាក់ទងរវាងអាមេរិកាំងនិងខ្មែរ បានប្តូរតែការមើលងាយ និងការខកចិត្ត។*

*អាមេរិករបស់ និចសុន យកកម្ពុជាប្រើប្រាស់ ដើម្បីដកខ្លួនចេញពីវៀតណាម “ជាមួយកិត្តិយស” (អានលិខិតចំហ នៃសហគមន៍ខ្មែរនៅកាណាដា ទៅប្រធានាធិបតី ការទែរ, នៅក្នុងព្រឹត្តិប័ត្រលេខ ៤, ខែកុម្ភៈ ១៩៧៧)។ ជាប់ក្នុងអន្ទាក់សង្គ្រាម, ប្រទេសនេះទម្លាក់លើកម្ពុជា, តែក្នុងកំឡុង ៤ ឆ្នាំ (១៩៦៩-១៩៧៣) នូវគ្រាប់បែកចំនួន ៥០០ ០០០ តោន!*

*អាមេរិករបស់ ហ្សេរ៉ាល់ ហ្វដ, ដោយវិលក្បុងមួយពេល, សំរេចបោះបង់ចោលសម្ពន្ធមិត្តខ្មែរ និងវៀតណាម របស់ខ្លួន ហើយរត់ចេញទៅឥតងាកក្រោយឡើយ។*

*អាមេរិករបស់ ជិម្មី ការទែរ ធ្វើជាភ្លេចរឿងហេតុទាំងអស់ ហើយប្រញាប់ប្រញាល់ទៅរកចាប់ដៃខ្មែរក្រហម ដែលទទឹកជោកនឹងឈាមខ្មែរនៅឡើយ⁽⁴⁾, ហើយទេសនាបណ្តើរៗ អំពីការ ការពារសិទ្ធិមនុស្ស!*

*ការពិសោធន៍នៃឥណ្ឌូចិន លើមិត្តភាពអាមេរិកាំង ត្រូវទៅជាដំបូន្មានដល់ប្រជាជាតិទាំងឡាយណាដែលសង្ឃឹមលើអាមេរិកដ៏ខ្លាំង, អ្នកការពារសេរីភាព!*

*ការដែលជប៉ុនវាយ ភើលហារបួ នៅឆ្នាំ ១៩៤១ បានទាញអាមេរិកចេញពីឯកោនិយមរបស់ខ្លួន។ ដោយប្រើកម្លាំងទាំងអស់ដែលខ្លួនមាន អាមេរិកវាយដណ្តើមយកបានជាច្រើន និងយ៉ាងឆ្ងាយ ហើយកន្លងផុតមហាសមុទ្រប៉ាស៊ីហ្វិកទៀត។ មកតាមក្រោយបារាំង, ហើយដូចពួកបារាំងដែរ, អាមេរិកាំងបានមកផុងខ្លួនក្នុងឥណ្ឌូចិន។ បន្ទាប់ពីបានបង្ហូរឈាមវៀតណាម, លាវ និង ខ្មែរយ៉ាងច្រើន និងបង្ហូរឈាមឯងយ៉ាងអសារឥតការ, អាមេរិកដកខ្លួនថយចេញ, បរាជ័យ, ទ្រោមទាំងខ្លួន ទ្រោមទាំងគំនិត។ ជាថ្មីម្តងទៀត អាមេរិកលូនចូលក្នុងរូងខ្លួនវិញ ៖ បន្ទាប់ពីកម្ពុជា គឺវៀតណាម, រួចមក កូរ៉េ។ មួយម្តងៗ កូន ដូមីណូ បានរលំ, ឬបើនិយាយឲ្យត្រូវ, បានត្រូវបោះបង់ចោល។*

*ប៉ុន្តែការវិលត្រឡប់វិញ នៃអាមេរិកក្នុងភាពឯកោនិយមនេះ មិនមែនបង្ហាញថាប្រទេសនេះចង់ឃើញមានសន្តិភាព និងភាពនឹងនរក្នុងពិភពលោកទេ។ ខុសឆ្ងាយទៅវិញ, ការណ៍នេះជាការសេងសឹក — ហើយយ៉ាងសាហាវ!*

*ក្នុងពេលដែលសត្រូវរួមរបស់ឥណ្ឌូចិន គឺកង បូ-ដូយ របស់ ហូជីមិញ និងសាវ័កខ្លួន កំពុងសាបព្រោះមនុស្សឃាដ និងរំលោភលើសិទ្ធិមនុស្ស ក្នុងដែនដីកំណើតរបស់ប្រជាជាតិទាំងបី, ប្រជាជនខ្មែរ, លាវ និងវៀតណាម ត្រូវរួបរួមគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបញ្ឈរណាសិរ្សមួយយ៉ាងរឹងទល់នឹងសត្រូវរួមដ៏ទមិឡ និងដ៏ព្រៃផ្សៃ។ ប្រជាជាតិទាំងឡាយនៃអាស៊ី នឹងមិនបណ្តោយឲ្យចក្រពត្តិនិយមតុងកឹង ឈ្នះបានឡើយ។*

## ចំពោះប្រទេសកម្ពុជាយើង, ចំពោះសំណល់នៃប្រជាជនយើង លើដីខ្មែរ, តើយើង ខ្មែរនៅបរទេស អាចធ្វើអ្វីជូន?

*ទោះបីយើងចង់ ឬមិនចង់ ប្រជាជនខ្មែរ ឪពុកយើង ម្ដាយយើង បងប្អូនយើង ទាំងប្រុសស្រី គង់នឹង បះបោរឡើងៗ ទោះបីយើងចង់ ឬមិនចង់ ឈាមគង់នឹងហូរទៀតនៅលើដីយើងៗ គ្មានមនុស្សណាម្នាក់ដែល អាចទ្រាំងទារុណកម្មខ្មែរក្រហម ដោយឥតបះបោរឡើយៗ ហើយបើយើង នឹកទៅដល់ត្រឹមតែគ្រួសារយើងឯ ស្រុកខ្មែរ ក៏ខ្លួនយើងគួរតែទៅដល់ទីនោះរួចស្រេចទៅហើយៗ*

*យល់ព្រមទទួលរបបខ្មែរក្រហម គឺសុខចិត្តបណ្ដោយឲ្យជាតិយើងស្លាប់ៗ ប្រទេសទាំងឡាយដែលនៅ ជាប់នឹងកម្ពុជាយើង មហាអំណាចដែលនៅឆ្ងាយមែន ប៉ុន្តែដែលឥទ្ធិពលខ្លួនទៅដល់គ្រប់ទីកន្លែង មិនគ្រាន់តែ ចាំមើលប្រទេសយើងដាច់ដង្ហើមប៉ុណ្ណោះទេៗ ខ្លះខំយកចំណេញអំពីការដែលយើងខ្សោះឈាម ខ្លះទៀតដែល យល់ថាខ្លួនមានគ្រោះថ្នាក់ កំពុងចាត់វិធានការ ការពារខ្លួនៗ មធ្យោបាយរបស់រដ្ឋទាំងនេះ បានទៅដល់ទីកន្លែង រួចទៅហើយ ឬក៏បានគ្រោងទុកហើយស្រេច ដាក់ក្នុងថតតុរបស់គេៗ នេះគឺជាការធម្មតា នេះជានយោបាយ អន្តរជាតិ ជាល្បែងអុករបស់អ្នកដឹកនាំសង្គមមនុស្សទាំងឡាយៗ*

*នៅលើទីលានប្រយុទ្ធ ឈមមុខទល់នឹងកងកម្លាំងដែលទំនើបទាន់សម័យ ហើយជាពិសេសប្រាជ្ញា យើងមានយោធា "ខ្មែរក្រហមយើង"[៥] ដែលពិតហើយ ពូកែសម្លាប់ឥតរុញរា ប៉ុន្តែឆោត មិនសូវចេះដឹង ហើយ ជាពិសេស តែឯកឯងឥតបណ្ដាជនគាំទ្រៗ នៅលើតុចចារឈមមុខទល់នឹងគូជជែកដែលចេះដឹងហើយ ឆ្លាត យើងមានមនុស្សដែលយើងមិនដែលស្គាល់ សញ្ជាតិមិនច្បាស់លាស់ ឬដែលវិលក្បួងខូចស្មារតី[៦]ៗ*

*ឃើញថា បើយើងទុកប្រទេសឲ្យនៅក្រោមតែខ្មែរក្រហមតែឯង កម្ពុជានឹងមុខតែបង់ខាតគ្រប់ជំពូកៗ ហើយមិនទាន់ទាំងទៅដល់ពេលច្បាំង និងចចារនោះផង កម្ពុជាបានបាត់បង់និងកំពុងតែបាត់បង់បណ្ដាជនរាប់ លាន ដែលជាជនរួមជាតិយើង លោហិតរបស់ជាតិយើងៗ*

*ត្រូវតែយើងទៅដល់ក្នុងទឹកដីខ្មែរដែរ! យើងដែលជាអ្នកចេះដឹងខ្មែរ ឬ បើនិយាយឲ្យត្រូវ យើងដែល ជាសំណល់អ្នកចេះដឹងខ្មែរ យើងមានករណីយកិច្ច និង កាតព្វកិច្ច យកកម្លាំងកាយនិងកម្លាំងគំនិត ទៅចូលរួម ក្នុង* ***ចលនាតស៊ូខ្មែរ****ៗ*

*បើប្រជាជាតិមួយទាំងមូលចង់រស់ ហើយតយុទ្ធដើម្បីរក្សាជីវិតខ្លួន គ្មានកម្លាំងអ្វីមួយ ក្នុងលោកនេះ ដែលអាចកិនកំទេចប្រជាជាតិនោះទេៗ ព្រោះថា ការសំខាន់ គឺការដាច់ចិត្ត ការចង់ឈ្នះដោយប្រើប្រាស់គ្រប់ សមត្ថភាពទាំងអស់ដែលខ្លួនមានៗ បញ្ហាឯទៀតៗ គ្រាន់តែជាការបន្ទាប់បន្សំទេៗ*

*ចំពោះមហន្តរាយនៃមាតុភូមិយើង យើងមិនត្រូវដាក់កំហុសទៅលើប្រទេសណាមួយទេ ប៉ុន្តែមកលើ ខ្លួនយើងៗ កាលណាប្រជាជាតិមួយបោះបង់ខ្លួនចោលហើយ ប្រជាជាតិមួយទៀតនឹងមកសង្គ្រប់លើ ហើយទំ-ពារលេបបាត់ៗ នេះគឺជាច្បាប់ធម្មជាតិ ច្បាប់នៃការវិវត្តន៍របស់អារិយធម៌ទាំងឡាយៗ*

*ពេលដែលអាណាចក្រយើងចុះអន់ថយ បន្ទាប់ពីការធ្លាក់រាជធានីអង្គរ ស្ដេចយើងទាំងឡាយបានបោះ បង់ខ្លួនចោល ប៉ុន្តែសំរាប់តែខ្លួនឯងម្នាក់ៗ*

*បុព្វការីយើង ធ្លាក់ក្នុងការផឹតផង់ បាត់ចំណងទាំងអស់ជាមួយប្រវត្តិសាស្ត្រខ្លួន ព្រោះបច្ចាមិត្រ បាន បំផ្ទិចបំផ្លាញប្រមូលយកអស់នូវក្បួនខ្នាត កាប់សម្លាប់កៀរយកទៅអស់នូវអ្នកប្រាជ្ញរាជបណ្ឌិត*[៧]។

*ជីដូនជីតាយើង ជាមួយនឹងពន្លឺព្រឹមៗ ដែលនាំមកដោយអាណានិគមនិយមបារាំង បានបើកភ្នែកភ្ញាក់ឡើង។ ប៉ុន្តែដោយទម្ងន់ រាជាធិបតេយ្យ ផ្តាច់ការសង្កត់ខ្លាំងពេក អ្នកខ្លះលែងវើរវល់ ហើយគិតតែឆ្មៀតទាញយកកំរៃឲ្យអស់ពីដៃ ដូច "ក្របីអត់ឃ្វាន ដែលស៊ីប្រទេសឯង"។ អ្នកឯទៀត ដោយ "គ្មានដឹងខ្លួនថាអស់កំឡាំងពេក" ដើម្បីឡើងឋានៈសង្គមឲ្យទាន់ពួកទីមួយ ទ្រាំនៅក្រីក្រទាំងផ្លូវសម្ភារៈ ទាំងផ្លូវគំនិតស្មារតី*[៨]។ *(អានទំព័រ ២៤ ភាគទី ៣)*។

*បងៗ យើង ក៏បោះខ្លួនចោលទៀត ខ្លះដោយមកពីតូចចិត្តព្រោះបំណងនយោបាយខ្លួនពុំបានសំរេច។ ខ្លះដោយឃើញថាការពុករលួយធ្វើឲ្យធាប់មានណាស់។ ពួកទីមួយ បិទមាត់ទំលាក់ដៃលែងតយុទ្ធ ឬបណ្តោយខ្លួនឲ្យលុះលង់ទៅតាមមនោគមវិជ្ជាបរទេស។ ពួកទី២ បាត់អស់ហើយនូវការអៀនខ្មាស់ នូវការទទួលខុសត្រូវ ហើយគិតតែពីកើបប្រមូលទ្រព្យសម្បត្តិ ៖ ចំពោះអ្នកខ្លះ "មាន" ប្រែមកថា កិត្តិយស។ ចំពោះអ្នកខ្លះទៀត ត្រឹមត្រូវហើយ "ក្រ" ប្រែមកថា ភ្លើ មិនស្ទាវឆ្លាត។*

*យើងកំពុងឃើញហើយថាការដែលសង្គមយើងទាំងមូល នាំគ្នាបោះបង់ខ្លួនចោលជាទូទៅ ហើយជារៀងរហូតមកនេះ បានធ្វើឲ្យប្រទេសយើងធ្លាក់ដល់ថ្នាក់ណា ហើយធ្វើឲ្យប្រជាជនយើង ដែលម្តងណាក៏ជាអ្នកទទួលគ្រោះដែរ រងទុក្ខសោកដល់កំរិតណា?*

*ឥឡូវនេះ នៅពេលដំណាច់សតវត្សរ៍ទី ២០ តើយើង យុវជនខ្មែរជំនាន់ថ្មី នឹងធ្វើតាមអ្នកមុនៗ យើងឬទេ? តើយើង "គ្មានសាមគ្គីធម៌តាមផ្លូវចិត្ត", "ឥតមានមនោសញ្ចេតនាជាតិបន្តិចបន្តួច", "ឥតយល់ថាមាតុភូមិជាអ្វីឡើយ" ដូចអ្នកមុនៗ យើង ឬអ្វី? (អានទំព័រ ២៣-២៤ ភាគទី ៣)។ តើយើងនឹងក្រពាត់ដៃមើលប្រជាជាតិយើងរលាយបាត់ ឬអ្វី?*

*មិនគ្រប់គ្រាន់ទេ បើគ្រាន់តែយើងនិយាយថា ខ្លួនយើងបានឆ្អែតចិត្តនឹងភាពអន់ ការពុករលួយ និងការមិនទទួលខុសត្រូវ របស់បងៗ យើង។ តើយើងបានធ្វើអ្វីហើយ ចំពោះមាតុភូមិយើង? តើយើងបានឲ្យអ្វីហើយដល់ប្រជាជនយើង?*

*ក្រោយខែមីនា ១៩៧០ យើងដែលជាពេទ្យ អ្នកអក្សរសាស្ត្រ អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស ។ល។ បានទុកចំណេះវិជ្ជាយើងសំរាប់កសាងប្រទេសឡើងវិញ ពេលណាដែលសង្គ្រាមចប់ហើយ។ ចំណេះវិជ្ជាដែលរដ្ឋកម្ពុជាបានផ្តល់មកយើង អស់រយៈពេល ២០ ទៅ ៣០ ឆ្នាំ ដោយផ្ទាល់ និងតាមរយៈប្រទេសជាមិត្ត។*

*ក្រោយខែមេសា ១៩៧៥ ចាប់ពីពេលដែលអានបន្ទាត់នេះទៅ យើងអាចគ្មានឱកាស អាចគ្មានលទ្ធភាព ហុចជូនទៅប្រជាជនយើងវិញនូវបំណុលរបស់យើង បើយើងនៅតែ ចាំ ចាំ ចាំ តទៅទៀត។*

*តើយើងធ្លាក់ទឹកចិត្ត ឬអ្វី ព្រោះការនៅស្ងៀមឥតកំរើករបស់អ្នកឯទៀត? ឬមួយយើងហួសចិត្ត ព្រោះអ្នកដែលបញ្ចេញគំនិត ចេះតែទាស់ទែងខ្វែងគំនិត បែកបាក់គ្នា? នេះជាការធម្មតាទេ នៅក្នុងសង្គមណាក៏ដូច្នេះដែរ។*

*យើងទាំងអស់គ្នាមាន ចំពោះមុខសាវតាយើង នូវការទទួលខុសត្រូវមួយ ដែលយើងត្រូវបំពេញ ៖ ការស្រោចស្រង់ជីវិតប្រទេសយើង។ បើយើងមិនប្រឹងប្រយុទ្ធធ្វើអ្វីមួយឲ្យដល់កម្ពុជាទេ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ យើងនឹងមិនមានតម្លៃហួសពីពួក "ក្របីអត់ឃ្វាន" ឬ ពួក "អស់កម្លាំង" កាលពីមុននោះទេ!*

*បងប្អូនរួមជាតិ យើងត្រូវលែងរង់ចាំកសាងប្រទេសឡើងវិញ ឬចាំបំរើត្រឹមតែជាពលរដ្ឋស៊ីវិល។ យើងត្រូវចូលរួម ចាប់ពីពេលនេះទៅ ក្នុងការតស៊ូប្រដាប់អាវុធ នៃ ប្រជាជនយើង។ លើសពីបំពង់កាំភ្លើងទៅ*

*ទៀត ការតស៊ូត្រូវការ ខួរក្បាល ដើម្បីគ្រោងផែនការ ព្យាបាល វះកាត់ រកស្បៀង បង្ហាត់អប់រំ បង្កើតក្របខ័ណ្ឌ និង ... គិត!*

*ទៅនឹងចម្ងល់ដែលថា "ក្រែងយើងធ្វើការតស៊ូមួយដែលចាញ់មុនទេដឹង?" យើងសួរទៅវិញ ថាតើយើង, ខ្មែរ, ដែលសព្វថ្ងៃនេះជាពលរដ្ឋកាណាដា អាមេរិកាំង បារាំង ។ល។ អាចរស់នៅដោយខ្ពស់មុខបានទេ បើប្រជាជាតិខ្មែររលាយបាត់? តើបងប្អូនរួមជាតិយើងដែលនៅឯនាយ មើលឃើញយ៉ាងម៉េចមកលើរូបយើង? តើជនដែលយើងនៅក្នុងប្រទេសគេ គិតឃើញយ៉ាងម្ដេចមកលើជាតិយើង?*

*បងប្អូនរួមជាតិ ចូរយើងបង្ហាញទៅពិភពលោកថា យុវជនខ្មែរជំនាន់ថ្មី ខុសពីជំនាន់មុនៗ ! ចូរយើងទាញជីវិតយើងចេញពីភាពបោះបង់ខ្លួនចោល និង ពីភាពអាម៉ាស់មុខ ហើយហុចជូនទៅប្រជាជាតិយើង! ស្លាប់ដើម្បីជាតិ ទើបជីវិតយើងកាន់តែមានន័យ!*

តុលា ១៩៧៧

# អធិប្បាយ

*(១) ក្នុងសម័យសាធារណរដ្ឋ អ្នកនយោបាយយើងខ្លះ បានប្រដូចស្ថានភាពភូមិសាស្ត្រនយោបាយនៃកម្ពុជាទៅនឹងរបស់អ៊ីស្រាអែល។ ការប្រដូចនេះ ខ្វះប្រាកដនិយមទាំងស្រុង ព្រោះថា ស្ថានភាពភូមិសាស្ត្រនយោបាយ នៃប្រទេសទាំងពីរខុសគ្នាឆ្ងាយណាស់។ លោក ឈូក ម៉េងម៉ៅ ដែលនៅក្នុងចំ-ណោមអ្នកនយោបាយទាំងនោះ បាននិយាយឲ្យកម្ពុជាមាន "គិប ប៊ុត"(@) ដូចមាននៅអ៊ីស្រាអែលដែរ។ រដ្ឋាភិបាលសាធារណរដ្ឋ ក៏បានបញ្ជូននិស្សិតនិងអ្នកសិក្សាខ្លះ ទៅប្រទេសទាំងនេះដែរ។ យកគំនិតតាមរបៀបរៀបចំអ៊ីស្រាអែលទាំងនេះ លោក លន់ នល់ បញ្ជាឲ្យរៀបចំជាផ្ទះដប់ខ្នង, ៥០ខ្នង ។ល។...*

*(@) គិប ប៊ុត ៖ ភូមិសហករណ៍នៅអ៊ីស្រាអែល ដែលជាពិសេសមានបណ្ដាជនទាំងប្រុសស្រី កាន់អាវុធការពារផ្ទាល់។*

*(២) អាណិកជននៅប្រទេសថៃ បានត្រូវបែងចែកជា ៥ ក្រុមធំៗ ៖ ចិន, ខ្មែរ, ម៉ាឡាយូ, យួន និងអ្នកស្រុកភ្នំខាងទិសឦសាន ក្រៅពីអ្នកស្រុកភ្នំសាសន៍ថៃ។ មុនពេលដែលខ្មែរយើងកៀសខ្លួន ដោយព្រឹត្តិការណ៍ថ្ងៃ ១៧ មេសា ១៩៧៥ អាណិកជនខ្មែរដែលនៅប្រទេសថៃ មានចំនួន ៤៥០ ០០០ នាក់ កាលពីឆ្នាំ ១៩៣៩ (តាមការស្ទង់ចំនួនប្រជាជនដោយ វ.អ. ក្រហាំ អតីតៈទីប្រឹក្សានៃរាជរដ្ឋាភិបាលថៃ)។ អាណិកជនខ្មែរទាំងនោះ រស់នៅក្នុងខេត្តផ្សេងៗ ដូចតទៅនេះ ៖ រដ្ឋបុរី ណាខុនចយ័ស៊ី សុភ័ណបុរី ភ្នំសាពខាំ ណាខនណាយ៉ុត ភូមិភាគខាងលិចនៃអរញ្ញ និងសុរិន្ទ។ នៅឆ្នាំ ១៩៣២ រដ្ឋាភិបាលថៃបានឲ្យបិទសាលាវត្តខ្មែរ ហើយបង្ខំអ្នករដ្ឋការដែលមានដើមកំណើតជាខ្មែរ ឲ្យនិយាយតែភាសាថៃ។ ក្រោយមក, តាមគេថា, អាណិកជនខ្មែរជំនាន់ក្រោយៗ ក៏បានជោកជាំនឹងវប្បធម៌ថៃ។*

*(៣) តាំងពីដើមកំណើតនៃប្រវត្តិសាស្ត្រយើងមក ប្រជាជនយើងបានទទួលការដឹកនាំ ឬការត្រួតត្រា, ក្នុងរយៈវេលាវែងឬខ្លី, ដោយចំ ឬ ដោយខ្មែរបណ្ដាក់, ពីសំណាក់ពួកផ្សេងព្រេងបរទេស ដែលបានចូលមកដោយដាច់តែឯង ឬដោយប្រទេសគេបញ្ជូនមក ៖ ឥណ្ឌា ចាម-ជ្វា សៀម យួន ព័រទុយហ្គេ អេស្ប៉ាញ៉ុល បារាំង ជប៉ុន ចិន និង អាមេរិកាំង។ ក្នុងរយៈ ២២ ឆ្នាំក្រោយបង្អស់, បន្ទាប់ពីឯករាជ្យនៃឆ្នាំ ១៩៥៣, អ្នកដឹកនាំយើងបានកោតក្រែង និងលើកតំកើងជនបរទេស លើសសហាសេវិកខ្មែររបស់ខ្លួន។ ការញ៉ែមនឹង "គេ" ជាប់រាប់តំណនេះ, ទំលាប់ឃើញបរទេសក្នុងកិច្ចដឹកនាំប្រទេសនេះ, បានបញ្ចូលក្នុងសតិខ្មែរយើង នូវការលែងរវីរវល់អំពីដើមកំណើត និងអតីតកាល នៃមនុស្សដែលនៅក្នុងវណ្ណៈដឹកនាំរបស់យើង។ តើប្រជាជនយើង ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស បានមានប្រតិកម្មយ៉ាងម្ដេច នៅពេលដឹងថាអ្នកដឹកនាំកម្ពុជា មានឈ្មោះដែលខ្លួនមិនដែលឮសោះ ដូចជា ៖ ទួន ជា, ង៉ួន កង, ស្វូ ភីម, ញឹម រស, ប៉ុល ពត, វ៉ន វ៉េត, យុន យ៉ាត ។ល។ ? ចុះបើមនុស្សក្រោមឈ្មោះទាំងនេះជាយួនទៅ តើប្រទេសយើងទៅជាអ្វីហើយ? ឧ. លាវ ជាមួយ កៃសូនផុំវិហាន?*

*ក្នុងពេលដែលយើងស្នាក់នៅបរទេសនេះ គួរយើងក្រឡេកមើលហើយសួរថា តើជនជាតិគេបណ្ដោយឲ្យមនុស្សដែលមានសញ្ជាតិដូចគេក៏ដោយ ប៉ុន្តែដែលទើបនឹងមកដល់ថ្មី ឡើងដល់ឋានៈដឹកនាំប្រទេស ឬភូមិ, សហគ្រាស ឬសមាគមគេតូចណាមួយទេ? នេះមិនមែនមកពីគេស្អប់ខ្ពើមបរទេសទេ ប៉ុន្តែគេការពារជាតិគេ របៀបរស់នៅរបស់គេ ការយល់ឃើញរបស់គេ។ ក្នុងយប់នៃថ្ងៃ ១៦ មេសា ១៩៧៥ លោក ឡុង បូរ៉េត, រដ្ឋមន្ត្រីទីមួយ, ពេលដែលអស់កម្លាំងយ៉ាងខ្លាំង ផាកទៅសួរអ្នកសារ-*

*ពតិមានបារាំងម្នាក់ថា ៖ "តើខ្ញុំត្រូវធ្វើដូចម្ដេច?"។ តបនឹងសំនួរអំពីមូលហេតុដែលនាំឲ្យខ្មែរក្រហមសម្លាប់រង្គាលប្រជាជនឯង, ខ្មែរម្នាក់ដែលមានចំណេះវិជ្ជាយ៉ាងច្រើនឆ្លើយថា ៖ "ខ្លួនមិនអាចឲ្យចម្លើយបានទេ មុននឹង "អិចស្ពែ័រ" អ្នកជំនាញការបស្ចឹមប្រទេសបានធ្វើវិភាគហើយសិន"។ សួរនាំអំពីប្រវត្តិសាស្ត្រ ដែលសមាគមខ្មែរមួយបានសរសេរ, អ្នកចេះដឹងដដែលឆ្លើយថា ៖ "មិនបាច់ទេគេទៅបើកសៀវភៅមើលក្នុងបណ្ណាល័យក៏បានដែរ"។ គំនិតដែលចេញមកតាមវាចាទាំងបីខាងលើនេះគួរតែអ្នកដែលមាន បោះបង់ចោល ដើម្បីអនាគតនៃប្រទេសយើង ៖ គំនិតថា ជនជាតិបរទេសគ្រាន់បើជាងជនជាតិឯង និងការស្អប់ខ្ពើមរហូតដល់គំនិតជនជាតិឯង។*

(៤) *ប្រធានាធិបតី កាកទែ បានចាប់ផ្ដើមនយោបាយក្រៅប្រទេសរបស់គាត់ ដោយសាកល្បងរកភ្ជាប់ចំណងឡើងវិញ ជាមួយប្រទេសចំនួនប្រមាណ ១៣ ដែលប្រឆាំងតិច ឬច្រើននឹងអាមេរិកាំង, ដែលនៅក្នុងនោះមាន កម្ពុជាប្រជាធិបតេយ្យ ដែរ។ ក្រសួងការបរទេសអាមេរិកាំងបានឃើញថា ខ្មែរក្រហមហាមឃាត់ខ្លួនមិនឲ្យចូលក្នុងស្រុកខ្មែរ (គណៈបេសកកម្ម វូដកុក នៅខែមីនា ១៩៧៧)។*

(៥) *ពាក្យរបស់ ប៊ីវ ផៃលៀង ក្នុងអត្ថបទឈ្មោះ "ការបំបាត់ពូជសាសន៍គួរឲ្យរន្ធត់ និងការស៊ីមនុស្សនៅប្រទេសកម្ពុជា" ចុះក្នុងព្រឹត្តិប័ត្រសហគមន៍ខ្មែរនៅកាណាដា លេខ ៩ ខែតុលា ១៩៧៧។*

(៦) *ពេលដែលសម្ដេចសីហនុ ប្រធានរណសិរ្ស "ហ្វុង" នៅក្នុងក្រុងប៉េកាំង "រដ្ឋមន្ត្រី" ជាច្រើនមិនទាំងអាចបានទៅជិត ឬទៅឃើញព្រះអង្គផង។ របៀបនេះដែរ ពេលដែលសីហនុធ្វើទស្សនកិច្ចជាផ្លូវការនៅប៉ារីស ពួកអង្គរក្សបានធ្វើយ៉ាងណាមិនឲ្យសម្ដេចទៅជិតខ្មែរដែលមកចង់ឃើញព្រះអង្គបានឡើយ។ ឯពួកអ្នកហែរហម ក៏មានកិរិយាគួរឲ្យគេមន្ទិលដែរ។ លោក តាន់ អ៊ុកណាំអៀង, អតីតអនុប្រធានរដ្ឋសភា, បានបរិយាយប្រាប់យើង អំពីអាកប្បកិរិយាបងថ្លៃគាត់ សារិន ឆាក រដ្ឋមន្ត្រីការបរទេសរបស់សម្ដេចសីហនុ នៅក្នុងចំណតអាកាសយាន ស្ហាលដឺហ្គោល ៖ "ខ្ញុំនិងកូនទាំងឡាយ ខំស្ទុះទៅរកគាត់ សារិន ឆាក ប៉ុន្តែយើងត្រូវឈប់នៅនឹងថ្កល់ ព្រោះឃើញមុខគាត់ធ្ងឹង ភ្នែកបើកតែមើលយើងអត់ឃើញ។ ទោះបីកូនពៅខ្ញុំ ដែលរលីកអឹំវ៉ាណាស់ ហើយដែលចង់យួរកាតាបឲ្យ ក៏ពុំហ៊ានទៅជិតគាត់ដែរ"។*

*ក្នុងពេលមហាសន្និបាត អ.ស.ប. នៅខែកញ្ញា ១៩៧៧ នេះ សមាជិកទាំងបីនាក់ នៃគណៈប្រតិភូខ្មែរ (ក្រោយមកមាន អៀង សារី ហើយតាមគេថា មាន ប៉ុល ពត ដែរ) គឺ ៖ ជួន ប្រសិទ្ធ ចាន់ យូរ៉ាន់ និងមនុស្សមិនស្គាល់មុខម្នាក់ ដែលគេបានឃើញមួយភ្លែតក្នុងទូរទស្សន៍នៅម៉ុងរ៉េអាល់ ពាក់អាវ-កគ្រងពណ៌ខ្មៅ ហើយមុខមាត់ដូចចិនសុទ្ធ។ ប្រភពរបស់យើងបានបញ្ជាក់ថា មនុស្សក្រោយនេះគឺចិនមែន មាននាទីជា "ទីប្រឹក្សា"! ចំណែកឯ ចាន់ យូរ៉ាន់ មិនដែលបានជាន់ដីខ្មែរវិញទេ ក្រោយថ្ងៃ ១៧ មេសា ១៩៧៥។ តើគាត់បានត្រូវខ្មែរក្រហមមែនទែន ចាត់ឲ្យបំពេញបេសកកម្មនេះទេ?*

*គឺថាហេតុការណ៍ទាំងនេះ ដែលហាក់ដូចជាចេញពីរឿងប្រលោមលោកប៉ូលីសនិងចារកម្ម ជាការណ៍ដែលបានកើតឡើងមែន។ បើដូច្នេះហើយ សំនួរមួយត្រូវតែចោទឡើង ៖ តើកម្ពុជាប្រជាធិប-តេយ្យ នឹងទៅជាយ៉ាងណា?*

(៧) *ក្នុងពេលសព្វថ្ងៃនេះ ចាប់តាំងពីខែមេសា ១៩៧៥ មិនគឺអំពើដដែល ដែលបានកើតមានឡើងវិញ? សៀវភៅក្បួន គម្ពីរ តម្រា ទាំងអស់បានត្រូវដុតចោល ជាមួយបណ្ណាល័យជាតិ។ វត្ថុបុរាណ ដែលរកតម្លៃជាក់គ្មាន ហើយដែលជាសាក្សីនៃអារិយធម៌យើង បានត្រូវកំទេចចោលអស់ ជាមួយមន្ទីរតាំងកេតនភណ្ឌជាតិ។ វត្តអារាម សាលា មហាវិទ្យាល័យ បានត្រូវបិទទ្វារ។ ពួកអ្នកចេះដឹង ចាប់តាំងពី*

*បណ្ឌិត ទៅដល់អ្នកគ្រាន់តែចេះអានចេះសរសេរ បានត្រូវគេតាមរកមុខ ហើយសំឡាប់ចោល។ ភូមិ ឃុំ ស្រុក ខេត្ត លែងមានឈ្មោះហើយ មានតែលេខ ដល់ពេលខ្មែរជំនាន់ក្រោយយើងស្លាប់អស់ទៅ នឹងលែងមានឈ្មោះខ្មែរសំរាប់ទីប្រជុំជនខ្មែរណាទាំងអស់ ព្រោះកូនក្មេងតូចៗ ដែលខ្មែរក្រហមយក ចេញពីឪពុកម្តាយខ្លួនទៅបង្ហាត់ បានត្រូវគេបង្ខឹកឲ្យប្រើតែវាក្យស័ព្ទថ្មីៗ សូម្បីតែអង្គរវត្ត ក៏បានបាត់ ឈ្មោះខ្លួនហើយ ហើយនៅត្រឹមតែ "ប្រាសាទកំពូលបី"។*

*(៨)* *នេះជាការមើលងាយពីបារាំង ក្នុងសម័យអាណានិគមនិយម។ សូមអាន* " Moeurs et coutumes des Khmers " *របស់* Guy Porée et Evelyne Maspéro (Payot, 1938.)

# ទំព័រភ្ជាប់ ៧

# ការទាក់ទងខ្មែរ-ចិន

*បើមនុស្សខំចងមិត្ត*
*ប្រទេសកុំចងសត្រូវ។*

*ប្រវត្តិសាស្ត្រនៃកម្ពុជាថ្មី គឺជាប្រវត្តិសាស្ត្រនៃការទាក់ទងខ្មែរ-បារាំង, រីឯប្រវត្តិសាស្ត្រសព្វថ្ងៃ គឺប្រវត្តិសាស្ត្រនៃការទាក់ទងខ្មែរ-ចិន(*)។ ចំណងមិត្តភាពរវាងកម្ពុជានិងចិនប្រជាមានិត គួរឲ្យយើងងាកក្រោយក្រឡេកមើលទៅម្តងទៀតដែរ។ ទោះបីមានឃើហោជា "អព្យាក្រឹត", កម្ពុជា ក៏នៅតែធ្លាក់ក្នុងភ្លើងសង្គ្រាម ដែលខ្លួនចង់ចៀសវាងបំផុត។*

*ពិតហើយ សន្តិភាព ១៥ ឆ្នាំ ដែលកម្ពុជាបានស្គាល់ក្រោយការប្រកាសឯករាជ្យ និងអព្យាក្រឹតភាព គឺមានដោយសារការប៉ិនប្រសប់នៃ សម្តេចសីហនុ ក្នុងការបត់បែនចៀសវាងើកសង្គ្រាមត្រជាក់នៃមហាអំណាច។ ការប៉ិនប្រសប់នេះ បានទទួលការសរសើរយ៉ាងច្រើនពីសំណាក់អ្នកសង្កេតការណ៍បរទេស ដែលមកពីគ្រប់ប្រកល្អកនៃពិភពលោក។ គួរឲ្យស្តាយ ដោយស្រវឹងនឹងការកោតសរសើរនេះពេក សីហនុបានភ្លេចទាំងស្រុងដល់នយោបាយក្នុងប្រទេស។ មិនគិតដោះស្រាយបញ្ហាពីគល់សង្គមឡើងតែម្តង, មិនគិតជំរឿនការអប់រំមហាជន ដើម្បីឲ្យមហាជនយល់ដល់ការទទួលខុសត្រូវរបស់ខ្លួនក្នុងសង្គម សីហនុបែរជាពង្រីកការគោរពបូជាដល់បុគ្គលខ្លួនទៅវិញ។ នយោបាយនេះ រិតតែបានត្រូវកំឡានិងថែរក្សាដោយអ្នកហែហមទៅទៀត ដោយពួកនេះរកតែទុកប្រជាជនឲ្យនៅល្ងង់ខ្លៅទៅ ដើម្បីខ្លួនស្រណុកក្តាប់។ ក្រអឺតនឹងអង្គវត្តណាស់ ប៉ុន្តែសឹងតែឥតដឹងអ្វីទាំងអស់ អំពីអតីតកាលសម័យនោះ, ពុករលួយ ប៉ុន្តែថាខ្លួនជាអ្នកកាន់ពុទ្ធសាសនា, មើលងាយតម្លៃអ្នកដទៃ ប៉ុន្តែថាខ្លួនស្រឡាញ់ជាតិ, អ្នកហែហមសីហនុទាំងនេះ —មនុស្សជដែល ដែលនឹងទៅ "បរិបុណ្ណៈ" លន់ នល់— ចិញ្ចឹមលទ្ធិកុម្មុយនិស្តខ្មែរដោយឥតដឹងខ្លួន។*

*ទុកចិត្តគេ, ឆោតឬមួយស្រវឹង, សីហនុ ឥតបានយល់ដល់ការចាំបាច់នឹងឲ្យប្រទេសមាន កងទ័ពមួយដែលខ្លាំង អាចការពារអធិបតីភាពជាតិបាន។ ដើម្បីការពារកម្ពុជា "សម្តេចឪ" ផ្តេកផ្តួលទាំងស្រុងលើប្រទេសចិន ដែលបណ្តាជន ៨០០ លាននាក់ ធ្វើឲ្យព្រះអង្គភ័យផង ទុកចិត្តផង! ការក័ន្តប្រឡំយ៉ាងមហិមានេះ ត្រូវអ្នកដឹកនាំសព្វថ្ងៃនឹងអនាគតនៃប្រទេសកម្ពុជា យកទៅពិនិត្យឡើងវិញ!*

*កិច្ចទាក់ទងខ្មែរ-ចិន ពុំមែនទើបនឹងមានក្នុងសម័យនេះទេ។ អង្គទូតខ្មែរទីមួយដែលគេដឹងថាមាននៅ*

---

*(*) គេចែកប្រវត្តិសាស្ត្រជាបួនផ្នែក ៖ សាវតាបុរាណ ពីដើមកំណើតមកដល់ គ.ស. ៣៩៥។ សាវតាយុគកណ្តាល (ត្រូវនឹងសម័យសក្តិភូមិ) ពីឆ្នាំ ៣៩៥ ដល់ ១៤៥៣ ឆ្នាំដែលពួកទួគីដណ្តើមបានក្រុង កុងស្តង់ទីណូប។ សាវតាយុគថ្មី ពី ១៤៥៣ ដល់ឆ្នាំ ១៧៨៩ (ការបដិវត្តន៍បារាំង)។ សាវតាសព្វថ្ងៃ ចាប់ពី គ.ស. ១៧៨៩ មក។ យើងអាចនិយាយដូចខាងលើបាន ព្រោះកម្ពុជាយើងទើបនឹងឃើញពន្លឺខ្លះឡើងវិញ ក្រោយការមកដល់បារាំង។*

ស្រុកចិន បានត្រូវបញ្ជូនដោយព្រះចៅស្រីមារា (ហ្វាន់ចេម៉ាន់ ក្នុងភាសាចិន) នៅ គ.ស. ២២៨ (សម័យនគរភ្នំ ឬ ហ្វូណន)។ ស្រីមារា ជាអ្នកបង្កើតងារ "វរ្ម័ន" ពាក្យសំស្ក្រឹត ដែលប្រែមកថា គ្រោះ ឬ គ្រឿងការពារខ្លួន ទូទៅ។ ងារនេះបានត្រូវបោះបង់ —រួចភ្លេចរហូតមក— ជាមួយគ្នានឹងការផុតពូជស្តេចនៃអង្គរ ក្រោមមុខលំពែងនៃ តាត្រសក់ផ្អែម (១៣៣២—១៣៤០) ស្តេចខ្មែរក្រោយបង្អស់ ដែលយកងារវរ្ម័ននេះដែរ គឺ ព្រះបាទនរោត្តម សីហនុវរ្ម័ន បន្ទាប់ពីសិលាចារឹកទាំងឡាយ បានត្រូវរកឃើញនឹងអានជាថ់ឡើងវិញ។

ដូចភាគច្រើននៃ "នគរ" ទាំងឡាយ ដែលនៅជុំវិញប្រទេសចិនដែរ, ស្រុកខ្មែរ (ហ្វូណន) បានត្រូវចិនសំគាល់ជារដ្ឋចុះចូល។ ការបញ្ជូនរាជទូតជាមួយសួយសាអាករមកប្រទេសចិន បានត្រូវធ្វើជាហូរហែរៀងមកដោយស្តេចនៃហ្វូណន (នគរភ្នំ) រួចមកនៃចិនឡា (នគរពួកកូនឥសីកម្ពុ)។ ដោយហេតុនេះ, ចាប់តាំងពីសតវត្សរ៍ទី៣ មក, អត្ថបទចិនអំពីស្រុកខ្មែរ ក៏មានមុនសិលាចារឹកខ្មែរ។ នៅឆ្នាំ ៥០៦ ភិក្ខុខ្មែរនាមសង្ឃពលា បានត្រូវស្តេចចិននៃរាជវង្សលៀង និមន្តទៅស្រុកចិនដើម្បីបកប្រែព្រះត្រៃបីដក។ ភិក្ខុនោះគង់នៅស្រុកចិន ១៦ ឆ្នាំ។ ឆ្នាំបន្ទាប់មក, ៥០៧, ព្រះចៅក្រុងចិន (វូ) ថ្វាយងារជា "មេទ័ព" បង្ក្រាបទិសទក្សិណ, ស្តេចនគរភ្នំ, ដល់ព្រះបាទជ័យវរ្ម័ន។ នៅឆ្នាំ ១០៧៦ ដោយចិនបបួលធ្វើសង្គ្រាមជាមួយនឹងតុងកឹង, ស្តេចហរស្សាវរ្ម័នទី៣ បញ្ជូនបេសកៈយោធពលមួយកង ទៅលុកលុយស្រុក ញៀ-អាន (ស្រុកហូជីមិញ!)។ នៅឆ្នាំ ១២៨៥ ជ័យវរ្ម័នទី៨ លើកសួយសាអាករ ទៅឲ្យពួកម៉ុងហ្គោល។ ក្នុង គ.ស. ១២៩៦ ស្តេចម៉ុងហ្គោល ទីមួខាន់ បញ្ជូនបេសកកម្មមួយមកកម្ពុជា ក្រោមរជ្ជកាលស្តេចឥន្ទ្រាវរ្ម័នទី៣ ហើយដែលនៅក្នុងនោះមានអ្នកប្រវត្តិសាស្ត្រ ចេវ តាក្វាន់។

ចេវ តាក្វាន់ បានសរសេរសៀវភៅចាស់ជាងគេទាំងអស់ ដែលអធិប្បាយអំពីយសោធរៈ (អង្គរ) សៀវភៅដែលជាប្រកព បើកឲ្យអ្នកប្រវត្តិសាស្ត្របារាំងស្គាល់ហើយសរសេរបាន អំពីអារិយធម៌ខ្មែរដំបូង (សៀវភៅ ចេវ តាក្វាន់ បានត្រូវបកប្រែដោយ ព. ប៉េល្លីយ៉ូ ក្នុងព្រឹត្តិប័ត្រនៃសាលាបារាំងនៅចុងបូព៌ាប្រទេស, នៅឆ្នាំ ១៩០២)។ ក្នុង គ.ស. ១៣២៧ ស្តេចឥន្ទ្រាវរ្ម័ន ផ្ទេរបល្ល័ង្កឲ្យទៅកូនដែលសោយរាជ្យក្រោមឈ្មោះថា ជ័យវរ្ម័នទី៩ បរមឥសូរ។ គឺនៅក្នុងរជ្ជកាលស្តេចនេះ ដែល "ការដូចជាបដិវត្តន៍" ទីមួយ (pseudo-révolution) បានផ្ទុះឡើង ដោយបញ្ឈប់យ៉ាងទាន់ហន់នូវឥទ្ធិពលព្រហ្មញ្ញសាសនា ហើយយកពុទ្ធសាសនា មកដាក់លើប្រទេសវិញ (ចំអកនៃព្រហ្មលិខិត, ឈ្មោះនៃជ័យវរ្ម័នទី៩ មុនពេលសោយរាជ្យគឺ សីហនុ!)។ "ការបដិវត្តន៍ក្លែង" នេះ ដំណាលគ្នានឹងការណ៍ ដែលរាស្ត្រសាមញ្ញឡើងសោយរាជ្យជាស្តេច ៖ តាត្រសក់ផ្អែម, និព្វានបាទ, លំពង់ ។ល។ ឲ្យសញ្ញានៃការចាប់ផ្តើមចុះឱនថយនៃកម្ពុជា ដែលនឹងមានរយៈប្រាំសតវត្សរ៍។ ក្នុងកំឡុង ៥០០ ឆ្នាំនោះ អាណាចក្រខ្មែរបានរបេះរិចរិល រហូតមកក្រោមការរុញច្រាន នៃពួកថៃ និង ពួកវៀត, អាណិកជនពីរសាសន៍ ដែលមានដើមកំណើតនៅស្រុកចិន។

បន្ទាប់ពីការប្តូរគ្នាខ្លះក្នុងសតវត្សរ៍ទី១៥, ប្រកពប្រវត្តិសាស្ត្រក៏បានស្ងាត់ឈឹង អំពីកិច្ចទាក់ទងខ្មែរ–ចិន។ លុះមកដល់សតវត្សរ៍ទី១៧, ទើបគេបានដំណឹងខ្លះឡើងវិញ ប៉ុន្តែអំពីការអន្តោប្រវេសន៍នៃជនជាតិចិន មកក្នុងស្រុកខ្មែរ (អានទំព័រ ៣២, លេខយោង ៣)។ នៅសតវត្សរ៍ទី១៩, ដូចជាប្រទេសកម្ពុជាដែរ, ប្រទេសចិន បានធ្លាក់ក្រោមអាណានិគមរបស់ពួកស្បែកស។ ការច្បាំងគ្នាព្រោះរឿងអាភៀន (អង់គ្លេសបាញ់គ្រាប់បែកលើកង់តុង នៅឆ្នាំ ១៨៤១) បានចប់ដោយសន្ធិសញ្ញាក្រុងណានកាំង នៅខែសីហា ១៨៤២ ដែលឲ្យហុងកុង និង កោះខ្លះទៀតទៅអង់គ្លេស។ តាមសន្ធិសញ្ញាក្រុងតៀនទ្សិន នៃឆ្នាំ ១៨៨៥, ចិនឲ្យទៅបារាំងត្រួតនូវនគរអណ្ណាម និង តុងកឹង ដែលជាស្រុកចំណុះខ្លួន។ ប្រទេសចិនទើបនឹងងើបឡើងវិញលើឆាកនយោបាយឥណ្ឌូចិន នៅឆ្នាំ ១៩៥៤ ក្នុងពេលធ្វើសន្និសីទក្រុងហ្សឺណែវ។

*ស៊ើរតែមួយសតវត្សរ៍នៃការត្រួតត្រារបស់បារាំង បានធ្វើឲ្យខ្មែរមានទំលាប់រស់នៅដោយ "មានគេការពារ"។ ក្រោយពីបានដេញចេញទាំងមិនអស់អាល័យនូវ "អ្នកការពារ" បារាំង, រាជាណាចក្រខ្មែរ, នៅមុខការប៉ុនប៉ងពង្រីកទឹកដីជាអល្ងជ្ឈីនៃអ្នកជិតខាងយួន, ខំរក "អ្នកការពារ" ម្នាក់ទៀត។ សន្ទុះទីមួយរបស់ខ្មែរ គឺតម្រង់ទៅសហរដ្ឋអាមេរិក។ នៅថ្ងៃ ១៧ តុលា ១៩៥៣ បារាំងផ្ទេរអំណាចសឹកមកកម្ពុជាវិញ។ នៅមុខទាហាន ១០ ០០០ នាក់ នៃកងទ័ពមែនទែនរបស់វៀតមិញ (បង្កប់ក្នុងខេត្ត ព្រៃវែង, ស្វាយរៀង, តាកែវ, កំពត និងបាត់ដំបង) និងមុខចំនួនដែលគេមិនដឹង នៃទាហានរបស់កងទ័ពប្រជាជនខ្មែររំដោះរបស់ សឺង ង៉ុកមិញ (APKL) កម្ពុជាមានតែ ១២ កងវរសេនាតូចថ្មើរជើង។ ថ្ងៃ ២ មេសា ១៩៥៤, កំពុងតែពេញប្រយុទ្ធនៅ ដៀន បៀនភូ, វៀតមិញចូលលុកលុយកម្ពុជាពីខាងទិសឦសាន។ ថ្ងៃ ២០ ឧសភា រាជរដ្ឋាភិបាលប្រកាសសុំជំនួយសឹកពីសហរដ្ឋអាមេរិក។ នៅហ្សឺណែវ, ឆ្លៀតឱកាសក្នុងកិច្ចពិភាក្សាជាទ្វេភាគី, រដ្ឋាភិបាលខ្មែរខំស្ទង់មើលនូវប្រតិកម្មអាមេរិកាំង ក្នុងពេលណាកម្ពុជាត្រូវលុកលុយដោយវៀតមិញ។ សហរដ្ឋអាមេរិក, ដោយចង់គោរពពាក្យសន្យារបស់ អង់តូនី អេដែន ទៅ ជូ អេនឡាយ (ដែលថានឹងមិននាំកម្ពុជាចូលក្នុងសម្ពន្ធភាពយោធា ជាមួយមហាអំណាចខាងលិចណាមួយ), ឆ្លើយដោយមិនព្រមសន្យាអ្វីឡើយ។*

*បើគេជឿតាមអ្នកនិពន្ធ រូហ្សស្មិថ ("នយោបាយក្រៅប្រទេសនៃកម្ពុជា") ដែលនាំពាក្យសំដី នៃអ្នកទទួលខុសត្រូវខ្មែរក្នុងសម័យនោះ, ប្រទេសកម្ពុជា បានសុំចូលសម្ពន្ធភាព សេអាតូ ដែរ ដែលគេកំពុងតែរៀបចំក្នុងពេលនោះ។ តាមអ្នកនិពន្ធដដែល, រដ្ឋលេខាធិការ បេដែល ស្មិថ មិនព្រមទទួលបេក្ខភាពខ្មែរដោយសំអាងថា មិនចង់បំពារបំពានលើកិច្ចព្រមព្រៀងហ្សឺណែវ, ប៉ុន្តែ សុំឲ្យកម្ពុជាទុកចិត្តថាខ្លួននឹងនៅក្រោមម្លប់ "ការពារ" របស់ សេអាតូ នេះ។ ថ្ងៃ ៨ កញ្ញា ១៩៥៤ នៅក្រុងម៉ានិល, សហរដ្ឋអាមេរិក, អង់គ្លេស, បារាំង, អូស្ត្រាលី, នូវែលហ្សេឡង់, ហ្វីលីពីន, ប៉ាគីស្ថង់ និង ថៃ ចុះហត្ថលេខាបង្កើតអង្គការនៃសន្ធិសញ្ញានៃអាស៊ីភាគអគ្នេយ៍ (សេអាតូ)។ ដូចដែលបានសន្យា, សម្ពន្ធភាពសឹកនេះ ដាក់កម្ពុជាក្នុង "ផ្ទៃការពារ" របស់ខ្លួនដែរ។ ប៉ុន្តែប្រទេសកម្ពុជា ដោយពុំសូវទុកចិត្តលើកិច្ច "ការពារ" នេះ, ក៏រកតម្រង់នយោបាយក្រៅប្រទេសខ្លួន ទៅទិសថ្មីទៀត។*

*ជាលើកទីមួយ, នៅខែវិច្ឆិកា ១៩៥៤, ព្រះចៅសីហនុបញ្ជាឲ្យឃោសនាអំពីខ្សែនយោបាយ "អព្យាក្រឹតយ៉ាងហ្មត់ចត់" មួយ, ក្រោយពេលត្រឡប់មកពីទស្សនកិច្ចនៅប្រទេសភូមានៃលោក អ៊ូ នូ។ ក្រោយបន្តិចមក លោក នេរុ មកធ្វើទស្សនកិច្ចឯភ្នំពេញ។ គឺក្នុងពេលនោះហើយ ដែលព្រះបាទសីហនុទទួលមេរៀនទីមួយខាងនយោបាយ "មិនចូលបក្សខាងណា" ពីបណ្ឌិត នេរុ, ហើយចោទសម្ពន្ធភាព សេអាតូ ថានាំមកតែបរិយាកាសអសន្តិសុខដែលផ្ទុយនឹងចំណងសន្តិភាព ដែលមហាអំណាចបានកំណត់ហើយ នៅហ្សឺណែវ។ ថ្ងៃ ២ មីនា ១៩៥៥, សម្តេចសីហនុ ដាក់រាជ្យឲ្យឪពុក, សម្តេចនរោត្តម សុរាម្រឹត។ ៣-៤ អាទិត្យក្រោយមក សីហនុសងទស្សនកិច្ចដល់ នេរុ ឯប្រទេសឥណ្ឌា។ ជាមួយរដ្ឋមន្ត្រីទីមួយឥណ្ឌា សម្តេចឧបយុវរាជសម្ភោធចំណងជើងនយោបាយ "បញ្ចសីលា" គោលគំនិតទាំងប្រាំនៃ "ការរស់នៅជាមួយគ្នាដោយសន្តិភាព"!*

*នៅខែមេសា ១៩៥៥ សន្និសីទនៅបាន់ឌុង ចាប់ធ្វើឡើង។ ជូ អេនឡាយ ឆ្លៀតឱកាសពីកិច្ចសន្ទនាជាឯកជនជាមួយសីហនុ ដើម្បីវាយសំរុកខាងផ្លូវទូត។ ក្នុងការជជែកគ្នានោះ រដ្ឋមន្ត្រីទីមួយចិន ស្នើអំពីរឿងកម្ពុជាសុំជំនួយសឹកពីសហរដ្ឋអាមេរិក។ ក្នុងរឿងនេះ សីហនុបញ្ជាក់ទៅ ជូ អេនឡាយ ថានឹងមិនមានមូលដ្ឋានទ័ពអាមេរិកាំងនៅកម្ពុជាឡើយ, ហើយកម្ពុជានឹងមិនសុំឲ្យ សេអាតូ ការពារទេ។ ជឿមែនទែន, ជូ អេនឡាយ ប្រាប់សម្តេចសីហនុឲ្យទុកចិត្តថា ចិននឹងមិនជ្រៀតជ្រែកក្នុងរឿងផ្ទៃក្នុងនៃកម្ពុជាឡើយ។ ថ្ងៃ ១៦ ឧសភា ១៩៥៥, កម្ពុជានិងសហរដ្ឋអាមេរិក ចុះហត្ថលេខាអំពីជំនួយខាងផ្លូវទ័ព។ បន្ទាប់មក បេសកកម្មយោធាអាមេរិ-*

កាំងមួយ (MAAG) ក៏មកតាំងទីឯភ្នំពេញ។ ថ្ងៃ ១១ កញ្ញា ការបោះឆ្នោតឲ្យជ័យជំនះទៅ គណបក្សសង្គមរាស្ត្រនិយម។ អស់កង្វល់ពីទំនាស់ខាងក្នុង, ជឿជាក់ថា អំណាចនឹងនៅតែក្នុងដៃខ្លួនម្នាក់, សម្តេចសីហនុដូរយ៉ាងរហ័សនូវនយោបាយក្រៅប្រទេស ការណ៍ដែលនឹងធ្វើឲ្យអាមេរិកាំងមិនពេញចិត្តយ៉ាងខ្លាំង។ នៅខែកុម្ភៈ ១៩៥៦, តបនឹងសេចក្តីអញ្ជើញរបស់ ប្រធានាធិបតីហ្វីលីពីន ម៉ាក់ សាយសាយ, សីហនុធ្វើទស្សនកិច្ចជាផ្លូវការនៅក្រុងម៉ានិល។ នៅទីនោះ, ហេតុដែលធ្វើឲ្យគេភ្ញាក់ផ្អើលគ្រប់គ្នា, នាយករដ្ឋមន្ត្រីខ្មែរ (កាលនោះមិនទាន់តាំងខ្លួនជាប្រមុខរដ្ឋនៅឡើយ) ថ្លែងការណ៍ថា កម្ពុជាឥតត្រូវការកិច្ចការពារនៃ សេអាតូ ទេ។ ថ្ងៃ ១៣ ខែដដែល សម្តេចធ្វើទស្សនកិច្ចជាផ្លូវការទីមួយនៅប្រទេសចិន ដែលនៅទីនោះប្រធានម៉ៅបានទទួល។ នៅប៉េកាំង, ជាថ្មីម្តងទៀត, សីហនុ ទាត់ចោលកិច្ចការពារ សេអាតូ។ ដោយឆ្លល់នឹងប្រតិកម្មសម្តេចសីហនុ, រដ្ឋលេខាធិការ ហ្វសស្ទែរ ដល្លឹស ផ្ញើលិខិតមួយមករដ្ឋមន្ត្រីការបរទេសខ្មែរ តាមរយៈលោក នង គិមនី, រាជទូតលើកដំបូងនៅប្រចាំ ស.រ.អា., លិខិតចុះថ្ងៃ ១៩ មេសា ហើយដែលការដកស្រង់មានដូចតទៅ ៖

"លោករដ្ឋមន្ត្រី, ខ្ញុំមានសេចក្តីបារម្ភដោយដឹងថា សេចក្តីថ្លែងការណ៍ក្នុងពេលថ្មីៗ នេះ ដែលចេញពីមជ្ឈដ្ឋានផ្សេងៗ បានធ្វើឲ្យឮកាន់តែខ្លាំងថា សហរដ្ឋអាមេរិកប៉ុនប៉ងបង្ខំប្រទេសកម្ពុជា ឲ្យចូលក្នុងសម្ពន្ធភាពសេអាតូ បើមិនព្រម នឹងឈប់បានជំនួយសេដ្ឋកិច្ច, ហើយថា សហរដ្ឋអាមេរិកបានបង្ខំប្រទេស វៀតណាម និង ថៃ ជាមិត្តនិងប្រកបដោយឯករាជ្យ ឲ្យចាត់វិធានការជាសង្គ្រាមសេដ្ឋកិច្ចទល់នឹងកម្ពុជា ក្នុងគោលបំណងដូចបានឮមកហើយនេះ។

"នៅថ្ងៃ ២ មេសា រដ្ឋទូតអាមេរិកាំង បានថ្វាយដំណឹងជាផ្លូវការដល់ព្រះមហាក្សត្រិយ៍ ទាំងពីរអង្គនៃកម្ពុជាថា សហរដ្ឋអាមេរិកពុំដែលបានថ្លែងជាផ្លូវការ និងជាសាធារណៈក្នុងពេលណាម្តងឡើយ នូវការយល់ឃើញរបស់ខ្លួនលើនយោបាយក្រៅប្រទេសនៃកម្ពុជា។ នយោបាយសហរដ្ឋអាមេរិកក្នុងកម្ពុជា យកមូលដ្ឋានលើបទបញ្ញាមួយយ៉ាងខ្លី ៖ សហរដ្ឋអាមេរិក, តាមរយៈកម្មវិធីជំនួយ យោធានិងសេដ្ឋកិច្ច របស់ខ្លួនរកជួយដល់រដ្ឋាភិបាលខ្មែរ ក្នុងការប្រឹងប្រែងជាអលជ្ជី ដើម្បីរក្សាទុកឯករាជ្យ អធិបតី នៃរាជាណាចក្រ។ ជំនួយនេះបានត្រូវផ្តល់ តែតាមចំណង់នៃរាជរដ្ឋាភិបាលខ្មែរទេ ដែលបានសុំជាផ្លូវការនូវជំនួយយោធា ក្នុងថ្ងៃ ២០ ឧសភា ១៩៥៤ និង ជំនួយយោធាផង ជំនួយសេដ្ឋកិច្ចផង នៅថ្ងៃ ១ កញ្ញា ១៩៥៤។

"ទោះបី សហរដ្ឋអាមេរិកជឿថា ប្រជាជាតិសេរីទាំងឡាយអាចទប់ទល់បានយ៉ាងប្រត្យក្សជាង និងគ្រោះថ្នាក់នៃការឈ្លានពានកុម្មុយនិស្ត តាមរយៈកិច្ចការពាររួមគ្នា, ក៏នយោបាយអាមេរិកាំងទទួលស្គាល់ថាប្រទេសខ្លះចូលចិត្តមិនចូលរួមក្នុងកិច្ចរៀបចំសន្តិសុខតាមភូមិភាគ ប្តីត្បិតតែប្រទេសទាំងនោះបានសម្រេចចិត្តការពារខ្លួន ទល់នឹងការឈ្លានពាន ឬវិទ្ធង្សនា លើឯករាជ្យខ្លួន។ ការជ្រើសរើសនេះ យើងគោរព។ សហរដ្ឋអាមេរិក មិនរកចំណងនៃការការពារគ្នាទៅវិញទៅមក ជាមួយប្រទេសណាឡើយ បើប្រទេសនេះមិនជឿថា ឯករាជ្យខ្លួននឹងស្រួលរក្សាទុកជាង ដោយអនុវត្តន៍គោលគំនិតនៃសន្តិសុខរួមនេះ"។ (ក្នុង "ព្រឹត្តិប័ត្រនៃក្រសួងការបរទេសអាមេរិកាំង", ៣០ មេសា ១៩៥៦, ទំព័រ ៧២៧)

នៅខែមិថុនា ១៩៥៦ កម្ពុជានិងចិន ចុះកិច្ចព្រមព្រៀងទីមួយខាងពាណិជ្ជកម្ម និងលើជំនួយមួយមានតម្លៃ ២២ លាន ៤ សែនដុល្លារ។ ថ្ងៃ ២៧ វិច្ឆិកា ឆ្នាំដដែល ជូ អេនឡាយ មកធ្វើទស្សនកិច្ចនៅកម្ពុជា, ដែលជាទស្សនកិច្ចទីមួយនៃ អ្នកមុខអ្នកការចិនកុម្មុយនីស្ត។ ក្នុងឱកាសនោះ ជូ អេនឡាយ បានប្រកាសដល់អាណិកជនចិនដែលរស់នៅក្នុងកម្ពុជា ឲ្យបញ្ចូលខ្លួនក្នុងសង្គមខ្មែរ ហើយគោរពច្បាប់នៃប្រទេសខ្មែរ។

ខែមិថុនា ១៩៥៨ កងវរសេនាតូចយួនខាងត្បូងពីរកង របស់ ង៉ោ ឌិនយៀម ចូលរំលោភក្នុងខេត្តស្ទឹងត្រែង ហើយបង្ខិតបង្គោលព្រំដែន។ សម្តេចសីហនុ ហៅសហរដ្ឋអាមេរិកឲ្យធ្វើអន្តរាគមន៍។ មួយខែបន្ទាប់ពី

*ឧប្បត្តិហេតុនេះ ប្រទេសកម្ពុជាទទួលស្គាល់តាមផ្លូវច្បាប់ដល់ សាធារណរដ្ឋចិនប្រជាមានិត ហើយប្តូររដ្ឋទូតគ្នា។ កិច្ចទាក់ទងជាផ្លូវទូតជាមួយចិននេះ បានធ្វើឲ្យអាមេរិកាំងភ្ញាក់ជាខ្លាំង ដោយឥតបានដឹងមុនឡើយ។ វ៉ាស៊ីងតោន ហៅរដ្ឋទូតខ្លួន (ខលស្រ្តុម) ទៅសួរពិគ្រោះ។ ដោយសំគាល់កាយវិការសម្តេចសីហនុ ជាការរករឿង, សហរដ្ឋអាមេរិករៀបចំគំរោងការណ៍ដើម្បីទម្លាក់សីហនុ (បានជាមានការក្បត់របស់ ដាប ឈួន មួយឆ្នាំបន្ទាប់មក)។ ២ ខែក្រោយការទទួលស្គាល់នេះ នៅក្នុងមហាសន្និបាតទី ១៣ នៃអង្គការសហប្រជាជាតិ, កម្ពុជាគាំទ្រការរត់កិច្ចការ ដើម្បីឲ្យចិនចូលក្នុង អ.ស.ប.។ ប៉ុន្តែ កិច្ចទាក់ទងជាលើកដំបូងរវាងខ្មែរនិងចិននេះ ពុំមែនបានធ្វើទៅដោយល្អឥតខ្ចោះទេ។ ដូច្នេះមែន, បន្ទាប់ពីការប្តូររដ្ឋទូតរវាងប្រទេសទាំងពីរមក, បេសកកម្មសេដ្ឋកិច្ចចិនមួយមកតាំងទីនៅភ្នំពេញ។ គណៈបេសកកម្មនេះ ជួយជាប្រាក់កាសដល់សារពត៌មានខាងឆ្វេងខ្លះ ហើយកាន់កាប់សាលាចិននៅស្រុកខ្មែរ។ ពីរឆ្នាំក្រោយមក, ១៩៦០, ជនជាតិចិនជាច្រើននាក់ បានត្រូវចាប់ដោយអាជ្ញាធរខ្មែរ ព្រោះសកម្មភាពវិទ្ធង្សនា។ នៅខែឧសភា, ក្នុងឱកាសទស្សនកិច្ចទីពីររបស់ ជូ អេនឡាយ, ចិនប្រមាណ ៦០ នាក់បានត្រូវចាប់បញ្ជូនទៅប្រទេសចិនវិញ។ បន្ទាប់ពីឧប្បត្តិហេតុទាំងនេះ ប្រទេសចិនពិនិត្យឡើងជាថ្មី នូវនយោបាយខ្លួនចំពោះកម្ពុជា។*

*នៅខែធ្នូ ១៩៦០ លីវ ចាវជី ធ្វើទស្សនកិច្ចនៅកម្ពុជា ដែលនៅទីនោះ ប្រធានាធិបតីចិនចុះសន្ធិសញ្ញាមួយលើមិត្តភាពនិងលើការមិនឈ្លានពាន ជាមួយរាជរដ្ឋាភិបាល។ សមាគមមួយឈ្មោះ "សមាគមមិត្តភាពចិន - ខ្មែរ" បានត្រូវបង្កើតឡើង ហើយដែលតាំងទីស្នាក់ការនៅក្រុងប៉េកាំង (គឺក្នុងឆ្នាំ ១៩៦០ នោះហើយដែល, តាមសំដី ប៉ុល-ពត នៅប៉េកាំងក្នុងពេលថ្មីៗ នេះ, គណបក្សកុម្មុយនិស្តខ្មែរបានកើតឡើង)។ តបគុណនឹងនយោបាយចិនដែល "គាំទ្រដោយឥតលក្ខខ័ណ្ឌ " និងដែល "មិនជ្រៀតជ្រែក", កម្ពុជា តំរង់ខ្លួនតាមខ្សែនយោបាយក្រៅប្រទេសរបស់ចិន (ក្នុងពេលដែលវៀតណាមខាងជើង, ថ្វីត្បិតតែខ្លួនស្និទ្ធណាស់ជាមួយចិនកាលសម័យនោះ, បានមាននយោបាយប្រយ័ត្នជាង!)។ នៅខែកញ្ញា ១៩៦២ រាជរដ្ឋាភិបាលខ្មែរទទួលស្គាល់ប្រទេស អាល់បានី (មួយឆ្នាំក្រោយមក, នៅខែតុលា ១៩៦៣, កម្ពុជានិងអាល់បានី ដាក់ការសម្រេចចិត្តមួយនៅ អ.ស.ប. ដើម្បីដេញតៃវ៉ាន់ចេញ ហើយទទួលចិនប្រជាមានិតវិញ ក្នុងមហាសន្និបាត)។ នៅខែធ្នូ ១៩៦២, ក្នុងសន្និសីទនៅកូឡុំបូ ដែលនេរុបានកោះហៅ ដើម្បីដោះស្រាយទំនាស់ព្រំដែនចិន-ឥណ្ឌា, សីហនុ រើសយកការបចារផ្ទាល់រវាងគូវិវាទទាំងពីរ ហើយទាត់ចោលសេចក្តីស្នើនៃអេហ្ស៊ីប ដែលចង់ឲ្យបង្កើតមណ្ឌលឥតទ័ពមួយ —ការដោះស្រាយដែលចិននឹងមិនទទួលឡើយ។ នៅខែតុលា ១៩៦៤, ពេលដែលចិនពិសោធគ្រាប់បែកបរមាណូទីមួយរបស់ខ្លួន, សម្តេចសីហនុ ជាប្រមុខរដ្ឋតែម្នាក់ឯងគត់ ដែលបានផ្ញើសំបុត្រគាំទ្រទៅចិន, ក្នុងពេលដែលប្រទេសនៃប្លុកសង្គមនិយម —យួនខាងជើងក៏ដែរ— បានប្រកាន់ការនៅស្ងាត់ស្ងៀម ជាសញ្ញានៃការមិនយល់ទាស់របស់ខ្លួន....*

*សីហនុ ប្រើការជិតស្និទ្ធជាមួយចិននេះ ដើម្បីកំចាត់ពួកខាងឆ្វេងដែរ ដែលនៅតែខ្លាំង។ នៅដើមឆ្នាំ ១៩៦២, សមាជិក ១៥ នាក់នៃគណបក្សប្រជាជន (នៅក្នុងនោះមាន នង-សួន អគ្គលេខាធិការ) បានត្រូវចាប់ឃុំឃាំង។ ជាការណ៍ធម្មតា នយោបាយសីហនុនេះ បង្កើតកំហឹងអាមេរិកាំងដែលពន្យុះដោយចំ ឬមិនចំ ដល់រណបខ្លួនទាំងពីរ (សៀម និង យួន) ឲ្យបង្កឧប្បត្តិហេតុតាមព្រំដែន (នេះបើមិននិយាយពីការរកសម្លាប់សីហនុទៀត)។ តាំងពីពេលដែលសន្និសីទនៅហ្សឺណែវអំពីប្រទេសលាវក្នុងឆ្នាំ ១៩៦២ បានចាប់ធ្វើឡើង, សម្តេចសីហនុសុំឲ្យមហាអំណាចនិងរណបរបស់ខ្លួន ពង្រីកការជដែកដល់កម្ពុជា ដើម្បីដោះស្រាយឲ្យអស់តែម្តង នូវចំណោទព្រំដែនរវាងកម្ពុជានិងអ្នកជិតខាង។ ប្រធានាធិបតី កេណ្ណឺឌី ប្រកែកដោយគួរសមតាមសំបុត្រមួយចុះថ្ងៃ ៣១ សីហា ១៩៦២។ ចំណែកឯ ង៉ោ ឌិនយៀម ទាត់ចោលសំណើនេះយ៉ាងដាច់អហង្ការ ហើយ*

ទាមទារឲ្យមានការត្រួតត្រាព្រំដែនជាទ្វេភាគី (យៀម ចោទកម្ពុជាថាឲ្យជំរកដល់យៀកកុង)។ ប្រទេសថៃ, កំពុងតែពេញជម្លោះរឿងព្រះវិហារ, ខ្ញុំប់ត្រចៀកធ្វើថ្លង់ ជាការណ៍ធម្មតា។ រីឯប្រទេសចិនវិញ គាំទ្រទាំងស្រុងនូវសំណើរខ្មែរ!

នៅខែឧសភា ១៩៦៣ (*) លីវ ចាវជី មកទស្សនាកម្ពុជាម្តងទៀតជាលើកទី២។ មុនពេលគាត់មកដល់បន្តិច, វៀតណាមខាងជើង ដែលបានទាមទារយកកោះខ្មែរដូចយួនខាងត្បូងដែរ កាលពីឆ្នាំ ១៩៦២, ដកការទាមទារខ្លួនទៅវិញ។ ខែវិច្ឆិកា ១៩៦៣, អាមេរិកាំងឲ្យស្ថានីយវិទ្យុផ្សាយសម្លេងមួយ ទៅពួកខ្មែរសេរី។ តបនឹងអំពើនេះ, សីហនុដេញគណៈបេសកកម្មជំនួយអាមេរិកាំងចេញ។ មួយខែក្រោយមក, នៅខែធ្នូ, កម្ពុជានិងចិនចុះកិច្ចព្រមព្រៀងលើកទីមួយ ខាងជំនួយយោធា។ នៅលើផ្ទៃក្នុង សម្តេចសីហនុកាន់តែរុញទៅមុខខ្លាំងនូវផែនការ “សង្គមកម្ម” ដោយយកជំនួញនាំចូល-ដឹកចេញ មកឲ្យជាតិធ្វើ (អាហរណ៍-នីហរណ៍)។

ខែសីហា ១៩៦៤, ឧប្បត្តិហេតុនៃឈូងសមុទ្រតុងកឹង ឲ្យសញ្ញានៃការចាប់ផ្តើមសង្គ្រាមទី២នៃឥណ្ឌូចិន (ការបាញ់នាវាពិឃាដ “ម៉ាដ់ដុក្ស” ឲ្យលេសទៅអាមេរិកាំង ដើម្បីទំលាក់គ្រាប់បែកលើហាណូយ)។ ការកើនក៏រិតសង្គ្រាមនៃអាមេរិកាំង ធ្វើឲ្យយួនខាងត្បូងកាន់តែកោងកាចឡើង។ មួយអន្លើទៀត កម្ពុជាបានផ្តាច់ចំណងទូតជាមួយប្រទេសនេះ តាំងពីខែសីហា ១៩៦៣ មកហើយ (ង៉ោ ឌិនយៀម បានត្រូវគេរំលំនៅថ្ងៃ ១ វិច្ឆិកា)។ ចាប់តាំងពីខែកុម្ភៈ ១៩៦៤, បន្ទាប់ពីបានចោទកម្ពុជាថា ដឹកអាវុធឲ្យយៀកកុង, អាជ្ញាធរយួនខាងត្បូង បញ្ជាឲ្យកងទាហានខ្លួនដេញតាមវៀតកុងក្នុងទឹកដីខ្មែរ។ ការរំលោភលើព្រំដែននេះ ធ្វើឲ្យស្លាប់និងរបួសដល់ខ្មែរឥតទោស ជាច្រើននាក់។ កម្ពុជា ចោទសហរដ្ឋអាមេរិកថា ទាញខ្សែញាក់ការវាយចូលទាំងនេះ។ បណ្តឹងមួយបានត្រូវដាក់នៅ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដែលបញ្ជូនគណៈកម្មការស៊ើបអង្កេតមួយមក ប៉ុន្តែឥតបានការអ្វីឡើយ។ ចំណែកខាងគណៈកម្មការអន្តរជាតិខាងកិច្ចត្រួតត្រាវិញ (សេ.អ៊ី.សេ.) ប្រកែកមិនព្រមធ្វើអាជ្ញាកណ្តាល តាមសម្លេងមិនព្រមដាក់អហង្កា (véto) នៃប្រតិភូកាណាដា ដែលសំអាងថា រឿងនេះចេញពីសមត្ថកិច្ចគណៈកម្មាការ (សេ.អ៊ី.សេ. បានត្រូវបញ្ឈប់ដោយឥតមានកំណត់ថ្ងៃ-ខែ sine die ដោយសម្តេចសីហនុ នៅដំណាច់ឆ្នាំ ១៩៦៩)។ ការមិនសូវត្រូវគ្នារវាងខ្មែរនិងអាមេរិកាំង មានកាន់តែខ្លាំងឡើង ស្របគ្នានឹងការរំលោភព្រំដែនដោយយួនខាងត្បូង។ រដ្ឋាភិបាលទាំងពីរព្រមចាប់ធ្វើការចចារដើម្បីរកការដោះស្រាយនៃចំណោទនេះ។ ថ្ងៃ ៨ ធ្នូ ១៩៦៤ នៅក្រុងញូវដែលី, លោក សឺន-សាន ជួបប្រាស្រ័យនឹងរដ្ឋទូតអាមេរិកាំងបុនសាល។ អាមេរិកាំងខំញាត់ “ត្រចៀក” អ្នកទទួលខុសត្រូវខ្មែរថា សហរដ្ឋអាមេរិកឥតមានមធ្យោបាយអ្វីដើម្បីបង្ខិតបង្ខំអាជ្ញាធរយួនបានទេ ចំពោះអាជ្ញាធរសៀមក៏ដែរ!

មួយចំណែកទៀត ទំនាស់ចិន-សូវៀត ដែលកាន់តែខ្លាំងឡើងរៀងរាល់ឆ្នាំ ក៏ជម្រុះឥទ្ធិពលមកលើឥណ្ឌូចិនដែរ។ ទំនាស់ទ្វេភាគីរវាង សហរដ្ឋអាមេរិក និងប្លុកចិន-សូវៀត បានក្លាយបន្តិចម្តងៗ ជាការប្រជែងត្រីភាគី។ ដោយរកការត្រូវរ៉ូវគ្នាពុំបានជាមួយ សម្ពន្ធភាពអាមេរិក-យួនខាងត្បូង-សៀម, សម្តេចសីហនុ, ដោយ “ចាក់” លើបរាជ័យអាមេរិកាំង, រកចចារជាមួយសម្ពន្ធភាពម្ខាងទៀត (រណសិរ្សយៀកកុង, យួនខាងជើង, ប៉ាថេតឡាវ និងរណសិរ្សស្នេហាជាតិថៃ) លើ “ការទទួលស្គាល់ព្រំដែនកម្ពុជា” (!)។ លើបញ្ហានេះ សម្តេចសីហនុបានធ្វើកំហុសមួយធំណាស់ អំពីនយោបាយក្រៅប្រទេស ព្រោះថា គឺ ប្រមុខរដ្ឋខ្មែរតែម្តងដែល

---

(*)- បើគេជឿតាមដំណឹងដែលបង្ហើបដោយ ប៉ុល-ពត នៅប៉េកាំងក្នុងពេលថ្មីៗនេះ, គឺក្នុងឆ្នាំ ១៩៦៣ ដែល សីហនុ, ក្នុងល្បិចមួយ ដើម្បីបង្អាប់ពួកខាងឆ្វេង, ហៅពួកឆ្វេង ៣៤ នាក់ដែលនគរបាលស្គាល់ ឲ្យមកចូលរួមក្នុងរាជរដ្ឋាភិបាល។ បកប្រែ “ការអញ្ជើញ” នេះ មកជាសញ្ញានៃការចាប់ផ្តើមបង្ក្រាបមួយថ្មីទៀត, ប៉ុល-ពត (សាឡុត-សរ) ជ្រើសរើសយកផ្លូវដែលនាំទៅព្រៃ។

*បានបង្កើតបញ្ហា "ព្រំដែនដែលគេទទួលស្គាល់" នេះ ហើយសើយបង្ហាញទៅអ្នកជិតខាង នូវចំណុចខ្សោយនៃប្រទេស ៖ ការគ្មានសមត្ថភាព និង ការគ្មានចំណង់ការពារឲ្យខាងតែបាននូវព្រំដែនខ្លួន! យើងនឹងឃើញក្នុងពេលបន្តិចទៀតនេះ នូវរបៀបយួនប្រើប្រាស់ភាពខ្សោយរបស់ខ្មែរ។*

*នៅខែកញ្ញា ១៩៦៤ ក្នុងពេលធ្វើទស្សនកិច្ចនៅប៉េកាំង, សម្តេចសីហនុ, ជាមួយការជួយខ្វាយខ្វល់នៃរដ្ឋាភិបាលចិន, ជួបដំណាងនៃវៀតណាមខាងជើង, នៃរណសិរ្សយៀកកុង(*) និងនៃប៉ាថេតឡាវ។ សេចក្តីថ្លែងការណ៍បញ្ចប់ដែល លីវ ចាវជី អាននៅថ្ងៃ ៥ តុលា ធ្វើឲ្យឡើងទឹកចិត្តណាស់ ៖ "ពេលណាមានការឈ្លានពានតាមកងទ័ព ប្រទេសកម្ពុជាអាចរង់ចាំទទួលការគាំទ្រយ៉ាងពេញកម្លាំងនៃប្រជាជនចិន"។ ប៉ុន្តែ លទ្ធផលនៃកិច្ចសន្ទនាជាមួយតំណាងកុម្មុយនីស្តទាំងឡាយនៃឥណ្ឌូចិន មិនសូវជាថ្លៃថ្លាទេ។ ពួកទាំងនេះយល់ព្រមគ្រប់គ្នាទទួលស្គាល់និងគោរពតាមមាត់ នូវព្រំដែនខ្មែរ, ប៉ុន្តែទាំងអស់គ្នា ប្រកែកមិនព្រមចុះហត្ថលេខាជាលាយល័ក្ខអក្សរឡើយ! (ការជជែកគ្នានៃអ្នកទទួលខុសត្រូវបានបន្តទៅទៀត នៅខែវិច្ឆិកា និងនៅខែមករា ១៩៦៥ ក្រោមក្អែកជំទន់នៃ ចេន-យី រដ្ឋមន្ត្រីការបរទេសចិន)។ ជាលើកដំបូងបង្អស់ សម្តេចសីហនុដឹងខ្លួនថា បានឲ្យតម្លៃហួសពេក ដល់ឥទ្ធិពលចិនលើពួកកុម្មុយនិស្តយួន ឥទ្ធិពលដែលរហូតមកដល់ពេលនេះ, ពិតហើយ, បានបង្ហាញប្រសិទ្ធភាពពីរដង ៖ នៅឆ្នាំ ១៩៥៤ ក្នុងសន្និសីទនៅហ្សឺណែវ និងនៅខែឧសភា ១៩៦៣ ពេលដែលវៀតណាមខាងជើងទាមទារយកកោះខ្មែរ។*

*ពេលត្រឡប់មកភ្នំពេញវិញ សម្តេចសីហនុ, ដោយចង់ដឹងប្រតិកម្មចិន, ថ្លែងសុន្ទរកថាមួយនៅថ្ងៃ ៨ តុលាថា ការខិតខំធ្វើឲ្យអ្នកដឹកនាំចិនព្រមចុះសន្ធិសញ្ញាការពារគ្នាទៅវិញទៅមក មិនបានសំរេចឡើយ ចិនសំអាងថាប្រទេសកម្ពុជា មិននៅក្នុងប្លុកសង្គមនិយមដូចប្រទេសយួនខាងជើង។ ប៉ុន្តែប្រទេសចិន, សីហនុបន្តទៅទៀត, សន្យាតាមមាត់ ថានឹងធ្វើដូចខ្លួនបានធ្វើនៅកូរ៉េ (គឺបញ្ជូនទ័ពចិនមក) ពេលណាកម្ពុជាត្រូវឈ្លានពានដោយសហរដ្ឋអាមេរិកនិងបរិវារ។ ៣-៤ ថ្ងៃក្រោយមក សម្តេចសីហនុពន្ទើសទំហំនៃជំនួយចិនមកកម្ពុជាដោយថ្លែងការណ៍ថា ចិនបានសន្យាឲ្យមកខ្មែរនូវអាកាសយានធុន មិច-១៩! ទ្រាំលែងបាន ប៉េកាំងបញ្ជូនសេនាប្រមុខ ចេន-យី មកកម្ពុជា នៅខែវិច្ឆិកា ដើម្បីកែតម្រូវឡើងវិញ។ ក្នុងឱកាសនោះ ឧត្តមសេនីយ៍ លន់-នល់, ដោយចង់ដឹងដែរថា រហូតដល់កំរិតណា កម្ពុជាអាចសង្ឃឹមលើជំនួយចិន, និយាយទៅ ចេន-យី ថា ៖ "ប្រទេសចិន និងប្រជាជនចិន នៅពេលថ្មីៗនេះ (ដៀងទៅ សេចក្តីថ្លែងការណ៍បញ្ចប់នៃ លីវ ចាវជី នៅថ្ងៃ ៥ តុលា) បានបញ្ជាក់ប្រាប់យើងម្តងទៀតថា បើពួកចក្រពត្តិនិយមធ្វើកិច្ចឈ្លានពានយ៉ាងខ្លាំងដល់ទឹកដីយើង ប្រទេសចិននិងប្រជាជនចិននឹងគាំទ្រយើងដោយឥតលក្ខខ័ណ្ឌ"។ ចេន-យី បញ្ជាក់សារជាថ្មីដល់ឧត្តមសេនីយ៍ លន់-នល់ នូវ "ការគាំទ្រយ៉ាងពេញកម្លាំងនៃប្រជាជនចិន" ប៉ុន្តែបន្ថែមថា "ក្នុងការតយុទ្ធដ៏ត្រឹមត្រូវ នៃរដ្ឋាភិបាលនិងនៃប្រជាជនខ្មែរ ដើម្បីការពារអធិបតីភាព និងបូរណភាពទឹកដី.... ប្រទេសចិនជឿថា ប្រទេសកម្ពុជា, ជាមួយប្រមុខរដ្ឋដ៏ក្លាហានរបស់ខ្លួន, គំនិតជាតិនិយមរបស់ខ្លួន និង ឯកភាពរបស់ខ្លួន អាចឈ្នះសត្រូវទាំងអស់ដោយប្រើ <u>**កម្លាំងខ្លួនផ្ទាល់**</u>"។ (ក្នុង "ទីភ្នាក់ងារពត៌មានចិនថ្មី" វិច្ឆិកា ១៩៦៤)។*

*សម្តេចសីហនុ និង ឧត្តមសេនីយ៍ លន់-នល់ យល់ច្បាស់ថា ចេន-យី ចង់និយាយយ៉ាងម្តេច។ ទោះយ៉ាងនេះក៏ដោយ សីហនុក៏នៅតែផ្អែកខ្លួនលើចិន ហើយនៅតែចចេសទារ ការធានាជាលាយល័ក្ខអក្សរពីពួកមហាអំណាច លើការទទួលស្គាល់ព្រំដែននៃកម្ពុជា។ នៅខែកុម្ភៈ ១៩៦៥, ក្រោមការចាត់ចែងនៃកម្ពុជា, សន្និសីទមួយ នៃប្រជាជនឥណ្ឌូចិន ធ្វើឡើងនៅទីក្រុងភ្នំពេញ។*

---

*(*) – រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (FNL) បានត្រូវបង្កើតនៅថ្ងៃ ២០ ធ្នូ ១៩៦០ ដោយមាន ង្វៀន ហ៊ូថូ ជាប្រធាន។*

## *ទំព័រភ្ជាប់ ២*

# ទិដ្ឋភាគចុងក្រោយ

*ជាមួយការចែចូវ*
*ខ្មែរថ្មីត្រូវមានទាំងពុត មានទាំងក្បួន។*

*រហូតមកដល់ខែមករា ១៩៧៨ —ពេលដែលពិភពលោកដឹងថា ខ្មែរក្រហមនិងយួនក្រហម ច្បាំងគ្នាយ៉ាងខ្លាំង— កម្ពុជាប្រជាធិបតេយ្យ បានសំងំលាក់ខ្លួនយ៉ាងស្ងៀមៗ ខ្មែរអ្នកកៀសខ្លួនរាប់ម៉ឺននាក់ និយាយត្រូវគ្នាទាំងអស់ថា ប្រជាជនកម្ពុជាកាន់តែស្ទើគ្នាហើយ ប៉ុន្តែចំនួនក៏កាន់តែចុះថយទៅដែរៗ រីឯការឃោសនាជាផ្លូវការវិញ ប្រកាសជោគជ័យគ្រប់ជំពូក នៃមហាបដិវត្តន៍ដ៏មហាលោតផ្លោះ មហាអស្ចារ្យៗ*

*ពិភពលោកបានឃើញការណ៍ពិត ចាប់ពីខែមករា ១៩៧៩ មកៗ*

*តទៅនេះ យើងនាំគ្នាពិនិត្យរឿងហេតុទាំងឡាយ ដែលបានកើតឡើងក្រោយខែកញ្ញា ១៩៧៧ មក គឺពេលដែល ប៉ុល-ពត ទៅទស្សនាប្រទេសចិនប្រជាមានិត ហើយបានធ្វើឲ្យគេដឹងថា "អង្គការ" នៅស្រុកខ្មែរ គឺ គណបក្សកុម្មុយនិស្តខ្មែរ ដែលគេបង្កើតឡើង "តាំងពីឆ្នាំ ១៩៦០" មកៗ*

## ១៩៧៧

*<u>តុលា :</u>* *មុននឹងចេញពីប៉េកាំងនៅថ្ងៃទី ៤, ប៉ុល ពត ប្រាប់អ្នកធ្វើសម្ភាសន៍ថា "ក្រុមចារកម្មខ្មាំង ដែលលាក់ខ្លួនក្នុងប្រទេសយើង មានសភាពស្អិត ហើយពិបាករំលើងណាស់"ៗ ប៉ុល-ពត បាននិយាយ បញ្ជីតបញ្ចៀងពី "ឧប្បត្តិហេតុជាច្រើនតាមព្រំដែន"ៗ*

*គេឮថា សម្តេចសីហនុ រស់នៅជាមួយអ្នកម្នាងជិតក្រុងភ្នំពេញ ប៉ុន្តែមិនអាចអ្នកណាទៅជួបបានឡើយៗ*

*ប្រទេសកម្ពុជា បានសងបំណុលរបស់ខ្លួន ទៅអង្គការសហប្រជាជាតិ (៣៧ ពាន់ដុល្លារ ឬ ១៨០ ពាន់ហ្វ្រង់) ហើយក៏អាចបោះឆ្នោតក្នុងមហាសន្និបាតទាំងឡាយៗ*

*ក្នុងសារពត៌មាន ឡឺម៉ុង (Le Monde) ថ្ងៃ ៦ ៖ ហាណូយបានប្រកាសពីរជងទៅភ្នំពេញនូវសេចក្តីមួយដែលគេអាចថាជា ការព្រមានក៏បាន ថាជាការហៅឲ្យចចារក៏បានៗ មានការបង្ហូរឈាមខ្លះតាមព្រំដែន កាលពីខែសីហាៗ*

*ថ្ងៃ ៧ ៖ ក្រសួងពិសេសអាមេរិកាំង និយាយអំពីការប្រយុទ្ធគ្នាតាមព្រំដែនខ្មែរ-យួន ក្នុងដំណាច់ខែកញ្ញាៗ យួនបានប្រើឯកភាព ដែលមកពីកងពលធំជាច្រើន និង ប្រើយន្តហោះប្រដេញ-ទំលាក់គ្រាប់បែក ដើម្បីវាយខ្មែរក្រហម ដែលចូលទៅក្នុងខេត្ត តាយនិញ (រោងដំរី)ៗ*

*ការមកដល់យ៉ាងច្រើន នៃអ្នកភៀសខ្លួនតាមសមុទ្រ ធ្វើឲ្យប្រទេសថៃបារម្ភ។ ក្នុងសមុទ្រមានកប៉ាល់ជំនួញជាច្រើន ដែលមិនព្រមជួយស្រង់អ្នកភៀសខ្លួន។*

*សារពត៌មាន ឡឺម៉ុង ថ្ងៃ ១៤ ៖ ឃើញដូចជាមានការផ្សះផ្សារ វៀតណាម ឥណ្ឌូចិន និង ប្រទេសមិនកុម្មុយនិស្តទាំងឡាយ នៃអាស៊ីអាគ្នេយ៍។*

*កាសែត ឡឺម៉ុង ថ្ងៃ១៨ ៖ តាមប្រកពទូតនៅហាណូយ ខ្មែរភៀសខ្លួននៅវៀតណាមមាន ៦០ ០០០នាក់ ហើយច្រើននៅជុំវិញព្រៃនគរ និង តាមខេត្តជាប់ព្រំដែន។*

*ថ្ងៃ ២០ ៖ កងទ័ពថៃឡើងកាន់អំណាច ហើយទំលាក់រដ្ឋាភិបាល ថានិនក្រៃវិជាន។ ឈ្មោះពីរលេចចេញមក ៖ ឧត្តមសេនីយ៍ គ្រៀងសាក់ ចមាននូ និង ឧត្តមសេនីយ៍ សាងាត ចលោយូ។*

*កាសែត ឡឺម៉ុង ថ្ងៃ ២២ ៖ យួនរាប់រយនាក់ បានត្រូវសម្លាប់ដោយខ្មែរក្រហម នៅដើមឆ្នាំនេះ។ ខ្មែរក្រហមបានវាយភូមិប្រមាណ ៤០ ជិត តាយនិញ (រោងដីរ៍) និង ចូដុក (មាត់ជ្រូក)។*

<u>*វិច្ឆិកា :*</u> *វិធានការថៃ ដើម្បីត្រួតពិនិត្យការចូលមកនៃជនភៀសខ្លួន ធ្វើឲ្យបារម្ភដល់អគ្គស្នងការដ្ឋានចំពោះជនភៀសខ្លួននៃ អ.ស.ប.។*

*ថ្ងៃ ១១ ៖ កម្ពុជា ដាក់កំហុសលើថៃ អំពីឧប្បត្តិហេតុតាមព្រំដែន (ខ្មែរ-ថៃ) ហើយស្នើការជជែកគ្នាទ្វេភាគី។ ក្នុងឆ្នាំនេះ ឧប្បត្តិហេតុប្រមាណ ៤០០ បានកើតមានឡើង។ ឧត្តមសេនីយ៍ គ្រៀងសាក់ ចមាននូ បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រីទីមួយ។*

*ស្ថានទូតអូស្ត្រាលីនៅក្រុងប៉ារីស ប្រាប់ឲ្យដឹងថា ជនភៀសខ្លួនមកពីឥណ្ឌូចិន មានចំនួន ៤ ៣២០ នាក់ នៅអូស្ត្រាលី។ ប្រទេសបារាំង បានទទួល ៤០ ០០០ នាក់ ក្នុងអំឡុង ២ ឆ្នាំកន្លះ។ សហរដ្ឋអាមេរិក បានទទួល ២០០ ០០០ នាក់។*

*លោក នេវិន ប្រធានាធិបតីភូមា ទស្សនាកម្ពុជា ពីថ្ងៃ ២៧ ទៅ ២៩។ គឺជាប្រមុខរដ្ឋបរទេសទី១ ដែលមកមើលស្រុកខ្មែរក្រហម។ ប្រទេសចិន បានឲ្យយោបល់ទៅខ្មែរក្រហមថា ត្រូវចេញពីភាពឯកោអនាថារបស់ខ្លួន។*

*ក្នុងកំឡុងខែវិច្ឆិកានេះ អ្នកភៀសខ្លួនតាមសមុទ្រ ២ ០០០ នាក់ បានមកដល់ប្រទេសសៀម ថ្វីដ្បិតតែមានវិធានការខាយ៉ាង។*

<u>*ធ្នូ :*</u> *ថ្ងៃ ២ ៖ បាងកក និង ហាណូយ សំរេចថានឹងប្តូររដ្ឋទូតគ្នា។ គេរកការផ្សះផ្សារ ការធ្វើឲ្យទំនាក់ទំនង មានភាពធម្មតាឡើងវិញ។*

*ថ្ងៃ ៣១ ៖ ការដាច់ចំណងទូតវាង កម្ពុជា និង វៀតណាម។ វៀតណាម ដាប់ចោទជាអ្នកឈ្លានពាន។ ភ្នំពេញ ស្រែកថ្កោលដល់ការវាយលុកកម្ពុជា ដោយកងពលធំយួនជាច្រើន។*

## ១៩៧៨

<u>*មករា :*</u> *សំនួរមួយផុះឡើងជុំវិញពិភពលោក ៖ "សង្គ្រាមទី ៣ នៃឥណ្ឌូចិន បានផុះហើយឬ?" "ពួកកុម្មុយនីស្តច្បាំងគ្នាឯង!" គេឮនៅកន្លែងខ្លះទៀត។ ប៉ុន្តែកាំងបានធ្វើការជ្រើសរើសហើយ គឺកាន់ជើងខាងខ្មែរ។*

ភ្នំពេញមិនព្រមចចារ ដរាបណាមានយោធាយួនក្នុងស្រុកខ្មែរ។ ការប្រយុទ្ធដូចជានៅតែក្នុងភូមិភាគ "ចំពុះទា" ស្វាយរៀង។ វិទ្យុភ្នំពេញផ្សាយសេចក្ដីសំបុត្រសម្ដេចសីហនុ ទៅ ប៉ុល-ពត។ ខ្មែរក្រហមអញ្ជើញទូតមួយចំនួន ប្រចាំក្រុងប៉េកាំង ឲ្យទៅទស្សនាកម្ពុជា។ ភ្នំពេញថ្កោល "ភាពកំហូចគួរឲ្យហួសចិត្ត" នៃ "ពួកលុកលុយ"។

ថ្ងៃ ៦ ៖ ភ្នំពេញប្រកាស "ជ័យជំនះពេញទី" ដែលគេពុំសូវជឿ នៅបស្ចឹមប្រទេស។

សារពត៌មាន ឡឺម៉ុង ថ្ងៃ ១០ ៖ វៀតណាម រកបន្ធិតខ្លួនមកជិតប្រទេសនៃសមាគមអាស៊ាន។ ង្វៀង ឌុយទ្រិញ រដ្ឋមន្ត្រីការបរទេស និង យ៉ា ដុងយ៉ាង ឧបរដ្ឋមន្ត្រី ទស្សនាប្រទេសអាស៊ាន ហើយនិយាយថា ចង់ចចារ។ ប្រហេហ្សហ្សីនស្គី ទីប្រឹក្សារបស់ប្រធានាធិបតី ការទែរ ខាងរឿងអន្តរជាតិថា ចំបាំងខ្មែរ-យួន ជា "ឧទាហរណ៍ទីមួយ នៃសង្គ្រាមមិនចំពោះរវាងចិន និង សហភាពសូវៀត"។

កាសែតដដែល ថ្ងៃ ១២ ៖ ការប្រយុទ្ធគ្នា ដូចជាបានឈប់ហើយ។

ថ្ងៃ ១៥ ៖ អៀង-សារី ប្រកាសថា កម្ពុជាចង់ "រក្សា និង ការពារ បូរណភាព សិទ្ធិ និងផលប្រយោជន៍ នៃសមុទ្រដែនដីរបស់ខ្លួន ចម្ងាយ ១២ ម៉ៃល៍ នៃមណ្ឌលសេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន ២០០ ម៉ៃល៍ និងនៃបាតសមុទ្ររបស់ខ្លួន។

ហាណូយ និង ភ្នំពេញ ដូចជាបានបញ្ជូនពលថ្មីបន្ថែម ទៅព្រំដែនទៀតហើយ។ សុន្ទរកថា ប៉ុល-ពត ថ្ងៃ ១៧ ៖ កងទ័ពបានទទួល "ជ័យជំនះថ្មីទៀត" ដោយបានកំចាត់កងពលធំយួន ៥។ ប្រទេសលាវប្រកែកថា កងទាហានយួនឥតបានឆ្លងកាត់ទឹកដីលាវទេ ដើម្បីចូលវាយខ្មែរ ហើយបញ្ជាក់ម្ដងទៀត នូវអព្យាក្រឹតភាពរបស់ខ្លួន ក្នុងការវិវាទនេះ។ លោកស្រី តេង ចាវ ភរិយា ជូ អេនឡាយ ទស្សនាកម្ពុជា ពីថ្ងៃ ១៨។

កាសែត ឡឺម៉ុង ថ្ងៃ ២៦ ៖ ជំហររបស់ហាណូយ និង ភ្នំពេញ នៅតែឥតផ្សះផ្សាបាន។ អ្នកសារពត៌មានជាច្រើន ទទួលស្គាល់ ដោយមិនចាំ ថាទាហានវៀតណាមចូលទៅក្នុងស្រុកខ្មែរមែន។

កុម្ភៈ : រាល់ខែ ចំនួនអ្នកភៀសខ្លួនពីឥណ្ឌូចិន ដែលចេញទៅប្រទេសបារាំង មានចំនួន ១ ០០០នាក់។

ថ្ងៃ ២ ៖ បន្ទាប់ពីទស្សនកិច្ចចំនួន ៤ ថ្ងៃនៅកម្ពុជា ឧបឌឹត បច្ចារយន្តល រដ្ឋមន្ត្រីការបរទេសថៃ ថ្លែងថា បាងកក និង ភ្នំពេញ បានព្រមព្រៀងធ្វើការប្ដូររដ្ឋទូតគ្នា។

សារពត៌មាន ឡឺម៉ុង ថ្ងៃ ៤ ៖ ការប្រយុទ្ធ ដូចជាបានត្រូវផ្អាកមួយពេល ប៉ុន្តែមានការជេរអាក្រោសគ្នាទៅវិញទៅមក។ ហាណូយអំពាវនាវរកខ្មែរជំទាស់។ ក្នុងសម្ភាសន៍ជាមួយទីភ្នាក់ងារវៀតណាមផ្ដល់ពត៌មាន (អា.វេ.អ៊ី.) នៅថ្ងៃ ២៦ មករា ឈ្លើយសង្គ្រាមម្នាក់ឈ្មោះ ញូន សារ៉ាន់ នាយទាហានរង និយាយថា "ខ្ញុំប្រាថ្នាយ៉ាងក្លៀវក្លា ឲ្យប្រជាជនខ្មែរអាចរស់នៅក្នុងសេរីភាពដោយពេញលេញ ក្រោមការដឹកនាំនៃអង្គការបដិវត្តន៍មួយដ៏ភ្លឺស្វាង និង យុត្តិធម៌ ដែលរក្សាទំនាក់ទំនងដ៏ជិតស្និទ្ធ ជាមួយប្រទេសវៀតណាម"!។

ថ្ងៃ ៥ ៖ ហាណូយស្នើទៅភ្នំពេញ នូវផែនការមួយដើម្បី "ដោះស្រាយចំណោទរឿងព្រំដែន"។ អ្នកសារពត៌មាន ប៉ាទ្រីស ដឺបៀ ៖ គេគួរសំគាល់ថា ជាលើកទីមួយដែលវៀតណាមស្នើ "ការធានា និងការត្រួតពិនិត្យអន្តរជាតិ"។ រហូតមកដល់ពេលនេះ វៀតណាម តែងតែមិនព្រមឲ្យមាន អន្តរាគមន៍ ឬការធ្វើអាជ្ញាកណ្ដាល ពីបរទេសឡើយ។ ប្រទេសចិនធ្វើការវាយសំរុកផ្លូវទូត។ អ្នកដឹកនាំចិន ចេញទៅធ្វើទស្សនកិច្ចនៅប្រទេសអាស៊ីទាំងឡាយ។

យ៉ា យ៉ាំងស៊ីង រដ្ឋទូតយួននៅប៉ារីស ថ្កោល "ការបោសសំអាតផ្ទៃក្នុងយ៉ាងសាហាវ" នៅកម្ពុជា។ ហើយបង្ហាញសំណើវៀតណាម អំពីផែនការធ្វើឲ្យមានសន្តិភាព និង ដោះស្រាយបញ្ហាព្រំដែន។

ថ្ងៃ ៨ ៖ ភ្នំពេញ ទាត់ចោលសំណើដោះស្រាយរឿងព្រំដែន ដែលខ្លួនឲ្យឈ្មោះថាជា "កាយវិការឃោសនា ដើម្បីបំភ័ន្តមតិអន្តរជាតិ" ក្នុងពេលដែលវៀតណាម ធ្វើការវាយសំរុកថ្មីទៀត ដោយប្រើរថក្រោះ និង យន្តហោះ ចូលរហូតដល់ចម្ងាយពី ៤ ទៅ ៧ គ.ម. ក្នុងទឹកដីខ្មែរ។

ថ្ងៃ ៩ ៖ ទីភ្នាក់ងារពត៌មានចិនថ្មី ចោទម៉ូស្គូថាជា "ដើមហេតុនៃស្ថានភាពតានតឹង" នៅព្រំដែនកម្ពុជា-វៀតណាម។ វិមានក្រឹមឡាំង ផ្ដន្ទាទោសដល់នយោបាយរបស់ភ្នំពេញ។

ថ្ងៃ ១២ ៖ វិទ្យុខ្មែរក្រហមសុំឲ្យ "បណ្ដាជននៅភ្នំពេញ" ការពាររដ្ឋធានី។ អ្នកសង្កេតការណ៍សួរថា នេះជាវិធានការចិត្តសាស្ត្រ ឬមួយ ជាដំណឹងថាទាហានយួនជិតមកដល់ភ្នំពេញហើយ? នៅថ្ងៃ ១៣ វិទ្យុដដែល ចោទការវាយលុកម្ដងទៀតរបស់យួន ក្នុងខេត្តស្វាយរៀង និង រតនគិរី ហើយផ្សាយចម្លើយរបស់ឈ្លើយសង្គ្រាមម្នាក់ វរសេនីយ៍ត្រី ត្រឹង យ៉ាំងហៀង មេបញ្ជាការរងវរសេនាធំលេខ ១៨ នៃកងពលធំលេខ ៩ ដែលថាខ្លួនបានដឹងតាំងពីឆ្នាំ ១៩៧២ នូវផែនការធ្វើសហព័ន្ធឥណ្ឌូចិន។

កាសែត ញ៉ាងដាង អង្វរភ្នំពេញឲ្យឆ្លើយតបនឹងសំណើសន្តិភាពរបស់យួន ឬមួយ "ចាត់ការអ្វីផ្សេងទៀត ដែលអាចកសាង"។

ថ្ងៃ ២១ ៖ វៀតណាមប្រាប់ចិនឲ្យប្រយ័ត្ន ដោយចោទយ៉ាងច្បាស់ ថ្វីដ្បិតតែមិនចំពោះ ថាទាញដៃទាញជើងភ្នំពេញ។

<u>មិនា :</u> សារពត៌មាន ឡឺម៉ុង ថ្ងៃ ២០ ៖ តាមអ្នកមុខការក្រសួងការបរទេសខ្មែរ ដែលបានទទួលអ្នកឆ្លើយឆ្លង ទីភ្នាក់ងារពត៌មានយូហ្គោស្លាវ តានយូគ ភ្នំពេញប្រាថ្នាចាប់ផ្ដើមធ្វើជាមួយ ហាណូយ នូវការចចារដើម្បីបញ្ចប់ការវិវាទ។

ខ្មែរក្រហមសម្លាប់យួនវង្គាលនៅ ហាទៀង (ពាម)។ ហាណូយ ចាប់រៀបចំការវាយសំរុកយ៉ាងធំ ៖ កាំភ្លើងធំ រថក្រោះ និង កងផ្គត់ផ្គង់កស្តុការឡើងទៅកាន់ព្រំដែន។

ថ្ងៃ ២២ ៖ អ្នកបើកយន្តហោះពីរនាក់ នៃទ័ពអាកាសយួន ចុះកប៉ាល់ហោះ ដេសេ-៣ មួយនៅសឹង្ហបុរី ហើយសុំសំចតទំរាំបានទទួលឲ្យចូលរស់នៅ ពីប្រទេសទី ៣។

វិទ្យុហាណូយផ្សាយដំណឹងថា សហគ្រាសឯកជនទាំងអស់ ត្រូវបានរំលាយចោល ក្នុងមួយចំហៀងខាងក្រោម នៃប្រទេសវៀតណាម។

អ្នកសារពត៌មានបស្ចឹមប្រទេសជាច្រើន បានទស្សនាតំបន់ព្រំដែន ខាងស្រុកយួន។ ប៉ុន្តែភ្នំពេញ បើកទ្វារប្រទេស ឲ្យទៅតែអ្នកសារពត៌មាន យូហ្គោស្លាវ។

ថ្ងៃ ៣០ ៖ អង្គការ "អន្តរជាតិលើកលែងទោស" (Amnesty International) អំពាវនាវម្ដងទៀត ដល់រដ្ឋាភិបាលខ្មែរ អំពីការប្រហារជីវិតមិនបាច់កាត់ទោស ដែលមានមកតាំងពីខែមេសា ១៩៧៥។

បន្ទាប់ពីការវាយសំរុករបស់យួននៅ ខែធ្នូ និង មករា ជនភៀសខ្លួនខ្មែរនៅវៀតណាមមានចំនួន ២ សែន នាក់។ ទាំងស្នងការដ្ឋាន អ.ស.ប. ចំពោះជនភៀសខ្លួន ទាំងក្រុមកាកបាទក្រហម ទាំងមូលនិធិ អ.ស.ប. សង្គ្រោះកុមារ ឥតបានត្រូវវៀតណាមហៅឲ្យចូលទៅជួយអ្នកភៀសខ្លួនខ្មែរទាំងនោះទេ។

ឧត្តមសេនីយ៍ គ្រឿងសាក់ ធ្វើទស្សនកិច្ចនៅប៉េកាំង។

វិទ្យុភ្នំពេញ ប្រាប់អំពីការបើកឡើងវិញនូវផ្លូវអយស្ម័យយានភ្នំពេញ-កំពង់សោម ដែលបានត្រូវខូចខាតព្រោះយួន ក្នុងខេត្តតាកែវ និងកំពត។ គណៈប្រតិភូ កម្មករផ្លូវរទេះភ្លើងចិនមួយក្រុម បានមកកម្ពុជាតាំងពីដើមខែមីនា។

<u>មេសា :</u> ភ្នំពេញ ធ្វើការបោសសំអាត កំចាត់ពួកខ្មែរលំអៀងខាងយួនៗ ហាណូយ អប់រំបង្កើតក្របខ័ណ្ឌខ្មែរថ្មីៗទៀត ៖ ពួកឈ្លើយសង្គ្រាម បានត្រូវគេថែទាំព្យាបាល ហើយអប់រំឡើងវិញៗ អ្នកកាសែតឈ្មោះ រ៉ូឡង់-ព្យែរ ប៉ាក់ងហ្គោ ក្នុងសារពត៌មាន ឡឺម៉ុង ថ្ងៃ ១ ៖ ហាណូយមិនកំពុងតែបង្កើតក្របខ័ណ្ឌខ្មែរ ដើម្បីជំនួសពួកភ្នំពេញទេឬ?

វិទ្យុភ្នំពេញ ចោទថា កងទាហានយួនធ្វើប្រតិបត្តិការផ្លូវគោក និងផ្លូវទឹក ក្នុងខេត្តតាកែវ និងកំពតៗ

ថ្ងៃ ៣ ៖ វិទ្យុហាណូយ ជាកាសាខ្មែរចាប់នៅបាងកក ៖ "យោធាខ្មែរជាទីស្រឡាញ់ នៅក្នុងជួររបស់អ្នកមិត្តអ្នកជាច្រើនបានបង្វែរកាំភ្លើងមកបាញ់មេរបស់ខ្លួនវិញៗ នេះជាសញ្ញានៃការភ្ញាក់រលឹកហើយ"ៗ "មិត្តអ្នកជាច្រើនបានស្លាប់យ៉ាងអាសារឥតការ ក្នុងទំនាស់រឿងព្រំដែនរវាង យើងទាំងពីរ"ៗ

ហាណូយ ផ្សាយជាសាធារណៈនូវឯកសារពីរ មួយលើទំនាស់រឿងព្រំដែន មួយទៀតអះអាងថា "សហព័ន្ធឥណ្ឌូចិន ជារឿងចាស់ ដែលគេភ្លេចបាត់ទៅហើយ"ៗ

វិទ្យុភ្នំពេញ ចោទហាណូយថា បានមកយាយីជាថ្មីទៀតៗ

នៅប៉ារីស អ្នកការទូតយួនម្នាក់ធ្វើសន្និសីទពត៌មាន ៖ វៀតណាម មានចំណង់រកដោះស្រាយតាមកិច្ចចចារ ហើយចោទជាថ្មីទៀតដល់ អំពើយង់ឃ្នងនៃអ្នកដឹកនាំនៅភ្នំពេញៗ

ថ្ងៃ ១៣ ៖ តាមរយៈ វិទ្យុភ្នំពេញ ប៉ុល-ពត ធ្វើការ "អំពាវនាវដល់ រដ្ឋាភិបាល និង ប្រជាជនវៀតណាម ឲ្យទទួលមិត្តភាពដ៏រក់ទាក់នៃប្រជាជនកម្ពុជា នឹងដើម្បីឲ្យទំនាក់ទំនង រវាងរដ្ឋាភិបាលទាំងពីរ បានល្អឡើងវិញ"ៗ

ថ្ងៃ ១៤ ៖ សាធារណជននៅយូហ្គោស្លាវី ឃើញស្រុកខ្មែរលើផ្ទាំងទូរទស្សន៍ ៖ ទីក្រុងដែលស្ងាត់ឈឹងគ្មានជីវិត និង បណ្តាជន-អ្នកទោស-គូលី ក្នុងការដ្ឋានៗ

អ្នកកាសែតស៊ុយអែដ និយាយពីឧប្បត្តិហេតុរវាងទាហានយួន និងទាហានចិន នៅព្រំដែន យួន-ចិនៗ

សម្ដេចប្រទេសកម្ពុជា ៖ ក្រសួងសម្ងាត់យួន ជួលពួកស្រីពេស្យាឲ្យមកស៊ើបការណ៍នៅស្រុកខ្មែរៗ

ប្រធានាធិបតី ការទែរ អំពាវនាវដល់ "ប្រជាជាតិទាំងអស់" ឲ្យផ្តន្ទាទោសដល់ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាៗ

ថ្ងៃ ២៣ ៖ នៅក្រុង អូស្លូ ប្រទេសន័រវែស៍ មានធ្វើឡើងនូវ ការស្តាប់សក្ខីភាពអំពីប្រទេសកម្ពុជាៗ អង្គប្រជុំបានទទួលស្គាល់ថា ខ្មែរក្រហមបានធ្វើឲ្យស្លាប់ជនានុជនខ្មែរកន្ទះលាននាក់ៗ

ជនជាតិអាមេរិកាំង ៤ នាក់ ដែលកាន់លទ្ធិកុម្មុយនិស្តម៉ៅនិយម ទស្សនាកម្ពុជាៗ

អ្នកកាសែតយូហ្គោស្លាវម្នាក់ ដែលទើបនឹងមកពីកម្ពុជា កត់សំគាល់ថា ក្នុងឯកសារជាផ្លូវការទាំងឡាយ ខ្មែរក្រហមនិយាយតែពីពួក "កសិករ" "កម្មករ" និង "អ្នកធ្វើការឯទៀត" ប៉ុន្តែឥតមាននិយាយពីពួក "បញ្ញាវ័ន្ត ជឿនលឿន" ទេ (Intelligentsia progressiste) ៗ

ប៉េកាំង ធ្វើការព្រមានមួយទៅហាណូយ អំពីការមកដល់យ៉ាងច្រើននៃជនជាតិចិន ដែលធ្លាប់រស់នៅឯព្រៃនគរ ព្រោះការលុបបំបាត់សហគ្រាសឯកជនៗ

<u>ឧសភា :</u> កម្ពុជា រកទាញខ្លួនចេញពីភាពឯកោអនាថាផ្លូវទូតៗ អៀង-សារី ប្រាប់ពួកម៉ៅនិយមអាមេរិកាំង ៖ "ប្រជាជនកម្ពុជាប្រាថ្នា ចង់ស្ពានមានមេត្រីជាមួយប្រជាជនអាមេរិកាំង"ៗ

ប៉េកាំង ចង់បានសម្ភារៈសឹកពី បារាំង និង អង់គ្លេសៗ

ក្នុងសារពត៌មាន ឡឺម៉ុង ថ្ងៃ ១៨ ៖ ពាក្យបញ្ជាមួយតាមវិទ្យុភ្នំពេញ ៖ "ខ្មែរម្នាក់ៗ ត្រូវសម្លាប់យួន ៣០ នាក់....."។

ការរត់ចេញពីស្រុកយួន នៃជនដើមកំណើតចិនធ្វើឲ្យខ្លាំងឡើង ដល់ស្ថានភាពតានតឹងរវាងប៉េកាំង និង ហាណូយ។

តូក្យូ នៅតែមិនព្រមទទួល ជនភៀសខ្លួនពីឥណ្ឌូចិន ឲ្យស្នាក់នៅប្រទេសជប៉ុន។

<u>*មិថុនា :*</u> ថ្ងៃ ២ ៖ "កម្ពុជាត្រៀមខ្លួនចាំជែដែកជាមួយវៀតណាមក្នុង ៧ ខែទៀត បើក្នុងកំឡុងពេលនោះ ហាណូយបញ្ឈប់ការប្រទុស្តរ៉ាយទាំងអស់ ទល់នឹងភ្នំពេញ" គេឃើញក្នុង កំណត់ហេតុរបស់ រដ្ឋាភិបាលខ្មែរ ចុះថ្ងៃ ១៥ ឧសភា ដែលបានត្រូវបញ្ជូនទៅវៀតណាម ដោយស្ថានទូតលាវនៅ ភ្នំពេញ។ គេដឹងដំណឹងនេះតាមប្រភពទូត។

អគ្គស្នងការដ្ឋាន អ.ស.ប. ចំពោះជនភៀសខ្លួន និងធ្វើសហប្រតិបត្តិការជាមួយ រដ្ឋាភិបាលវៀតណាម ដើម្បីរកទីសំណាក់អាស្រ័យឲ្យខ្មែរ ១៥០ ពាន់នាក់ ដែលបានភៀសខ្លួនទៅវៀតណាមខាងត្បូង។

អៀង-សារី ធ្វើទស្សនកិច្ចនៅក្រុងតូក្យូពីថ្ងៃ ១១ ទៅ ១៣។

ស្ថានការណ៍កាន់តែតានតឹងឡើងរវាង ប៉េកាំង និង ហាណូយ។

សារពត៌មាន ឡឺម៉ុង ថ្ងៃ ១៧ ៖ អាស៊ីភាគអគ្នេយ៍ ក្រពុលមុខឈឺព្រោះជនភៀសខ្លួនរបស់ខ្លួន។

ប៉េកាំង បានបញ្ជូនកប៉ាល់សមុទ្រពីរ ដើម្បីដឹកជនជាតិចិន ចេញពីស្រុកយួន។

ថ្ងៃ ២៥ ៖ វិទ្យុភ្នំពេញ ប្រាប់ឲ្យដឹងអំពីការប៉ុនប៉ងរំលំរដ្ឋាភិបាលកម្ពុជា ដែលគេកំចាត់បានកាលពីខែ ឧសភាមុន។ វិទ្យុថា ការប៉ុនប៉ងនេះបានត្រូវរៀបចំឡើងដោយ "បក្សកុម្មុយនិស្ត និង រដ្ឋាភិបាលយួន ដោយ មានក្រុម សេ.អ៊ី.អា. ចូលរួមផង។

ប្រទេសឥណ្ឌូនេស៊ី បានអញ្ជើញ អៀង-សារី ឲ្យធ្វើទស្សនកិច្ចជាផ្លូវការ នៅ ជ្យាការតា។

កាសែត ឡឺម៉ុង ថ្ងៃ ២៨ ៖ តាមក្រសួងសម្ងាត់អាមេរិកាំងនិងថៃ ទាហានយួន ៥០ ពាន់នាក់ កំពុង វាយលុកចូលក្នុងទឹកដីខ្មែរ។ គឺជាការវាយលុកធំមួយ ដែលសកម្មកិច្ចខ្លះមានរហូតដល់ក្នុងជំរៅរាប់សិបគ.ម. ក្នុងទឹកដីខ្មែរ។ ទាំងហាណូយ ទាំងភ្នំពេញ ឥតបានបញ្ជាក់ថា ពត៌មាននេះត្រឹមត្រូវទេ។ ប៉ុន្តែ គឺជាប់រាប់ខែមក ហើយ ដែលខ្មែរនិងយួន ចោទគ្នាទៅវិញទៅមកថាបាន "ឈ្លានពាន" និង "បញ្ជូនភ្នាក់ងារ" ក្នុងទឹកដីគេ។

ថ្ងៃ ២៩ ៖ ហាណូយ ប្រកាសចូលរួមក្នុងអង្គការ "កូមេកុន" (COMECON) ផ្សាររួមរបស់ប្លុកសូវៀត។

<u>*កក្កដា :*</u> ថ្ងៃ ៣ ៖ ប៉េកាំង ប្រកាសបញ្ឈប់ជំនួយទាំងអស់ដល់វៀតណាម។

ហាណូយ ប្រាប់អាស៊ីភាគអគ្នេយ៍ឲ្យប្រយ័ត្នខ្លួនទល់នឹង "រីកខ្លួននិយម" ចិន។ តាមរយៈ កាសែតប្រក្រតីទិនប្រជាជន ប្រទេសចិនប្រាប់សមាគមអាស៊ានឲ្យប្រុងខ្លួនទល់នឹង "ត្រួតត្រា និយម" យួន ហើយចោទវៀតណាមថា ចង់ក្តាប់យកកម្ពុជាក្នុងសហព័ន្ធឥណ្ឌូចិន។

ថ្ងៃ ១៥ ៖ គ្រឿងសាក់ សន្ទនាជាមួយ អៀង-សារី ដែលធ្វើទស្សនកិច្ចនៅបាងកក។ ទាំងពីរនាក់ សំរេចចាត់វិធានការ ដើម្បីសំរួលការទាក់ទងរវាងប្រទេសទាំងពីរ ៖ ការប៉ុនប៉ងបើកខ្សែទូរលេខផ្ទាល់ និងការ ប្តូរគណៈប្រតិភូពាណិជ្ជកម្ម។ អៀង-សារី ចោទវៀតណាមថាចង់ "ត្របាក់លេបកម្ពុជា"។

ថ្ងៃ ២៥ ៖ សន្និសីទពួករដ្ឋមន្ត្រីការបរទេស នៃប្រទេសមិនចូលបក្សខាងណា បើកឡើងនៅក្រុង បែលហ្គ្រាដ។ កម្ពុជា ជាសមាជិកពេញសមត្ថភាព។ អៀង-សារី ចូលរួមក្នុងសន្និសីទ ហើយសុំឲ្យគេដេញ វៀតណាម ចេញពីចលនាប្រទេសមិនចូលបក្សខាងណា។

<u>សីហា :</u> កាសែតបាងកកប៉ុស្ដិ៍ ថ្ងៃ ១ ៖ កងទ័ពថៃនឹងទិញគ្រឿងសព្វាវុធថ្មី អស់តម្លៃ ១ ០០០ លាន ដុល្លារ មុនដំណាច់ឆ្នាំនេះ ៖ រថក្រោះ ៣៥០ ធ្វើនៅអាមេរិកនិងអង់គ្លេស យន្តហោះប្រដេញ និងយន្តហោះពិនិត្យការណ៍ និង កាណូតបាញ់កាំជ្រួចហោះ ៣។

កាសែត ឡឺម៉ុង ថ្ងៃ ៣ ៖ តាមក្រសួងសម្ងាត់អាមេរិកាំង យន្តហោះយួនទំលាក់គ្រាប់បែកយ៉ាងច្រើន សំបើម ដើម្បីបំបាក់ការទប់ទល់ "យ៉ាងមានះ" របស់ខ្មែរក្រហម។ ការទំលាក់នេះ ខ្លាំងលើសពីពេលមុនៗ ទាំងអស់។ យន្តហោះ គឺរបស់អាមេរិកាំងចោលពីឆ្នាំ ១៩៧៥ ៖ ធុនអេហ្វ-៥ ប្រតិកម្ម និង ធុនអា-៣៧។ ការ ទំលាក់ធ្វើឡើងរហូតដល់ចម្ងាយ ៦០ គ.ម. ក្នុងទឹកដីខ្មែរ ៖ កំពង់ចាមៗ មានមនុស្សស្លាប់ជាច្រើន។ ភ្នំពេញ ដកទ័ពពីទិសខាងលិចបញ្ជូនទៅសមរភូមិ ជាហេតុបើកឲ្យចំនួនអ្នកភៀសខ្លួន មានកាន់តែច្រើនឡើង។ ហា ណូយ កែនមនុស្សអាយុពី ១៦ ទៅ ៣៥ឆ្នាំ បញ្ចូលក្នុងកងទ័ព ហើយកោះហៅមកវិញនូវទាហានដែលឈប់ពី ឆ្នាំ ១៩៧៥។

ចេញពីបែលហ្ក្រាដ អៀង-សារី ទៅប៉េកាំង។ សុន សេន ឧបនាយករដ្ឋមន្ត្រីទីមួយទទួលបន្ទុកខាងការពារ ប្រទេស មកដល់ប៉េកាំងដែរជាមួយនឹងគណៈប្រតិភូមួយក្រុម។ "ទង់ជ័យក្រហម" កាសែតផ្សាយលទ្ធិក្រហម របស់បក្សចិន ឲ្យឈ្មោះវៀតណាមជាកូនអុក (cheval de Troie) របស់វិមានក្រឹមឡាំង និង ប្រទេសគុយបា របស់អាស៊ី។

វៀងចន្ទន៍ ដូចជាកាន់ជើងខាងវៀតណាម។

តាមទស្សនាវដ្ដីសេដ្ឋកិច្ចចុងបូព៌ាប្រទេស មេតស៊ូទល់នឹងប៉ុល-ពត ដូចជា សូ-ភឹម អតីតអនុប្រធា- នាធិបតី។

កម្ពុជា និង ឥណ្ឌូនេស៊ី សំរេចដាក់ចំណងទូតថ្នាក់រដ្ឋទូត ចាប់ពីថ្ងៃ ៧ សីហា ទៅ។

តាមមន្ទីរអាមេរិកាំងខាងជនភៀសខ្លួន និងខាងអន្តោប្រវេសន៍នៅវ៉ាស៊ីងតោន ក្នុងមួយខែៗ យួនពី ៥ ទៅ ៦ពាន់នាក់ភៀសខ្លួនតាមទូក ពី ២ ទៅ ៣ពាន់នាក់ទៀតតាមព្រំដែនផ្លូវគោក។

ក្រុងប៊ែន ប្រកាសថា ស្វ៊ីសនិងកម្ពុជា បានសំរេចដាក់ចំណងទូតរវាងប្រទេសទាំងពីរ។

ថ្ងៃ ១២ ៖ ចិននឹងជប៉ុន ចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនិងមិត្តភាព។

ខ្មែរដែលភៀសខ្លួនមកដល់ប្រទេសថៃ មានចំនួនកាន់តែច្រើនឡើង។ តាមអគ្គស្នងការដ្ឋានចំពោះជន ភៀសខ្លួន "ស្ថានការណ៍កំពុងតែប្រែប្រួលមែនទែនហើយ" បើប្រៀបធៀបទៅនឹងស្ថានភាពកាលពី ៦ ខែមុន។

សារពត៌មាន ឡឺម៉ុង ថ្ងៃ ២៦ ៖ តាមប្រភពយួន ខ្មែរដែលប្រឆាំងនឹងប៉ុល-ពត កាន់កាប់តំបន់ព្រំដែន ដែលជួនកាលជាទីជំរកវៀតកុងពីដើម។ ពួកខ្មែរទាំងនេះ ប្រហែលជាមានរដ្ឋការមួយ កងទ័ពមួយ និងទីបញ្ជា ការមួយ។ ភ្នំពេញ ទទួលស្គាល់ដោយមិនចំពោះ ដោយចោទវៀតណាមថា បានតាំងឡើង "រដ្ឋការអាយ៉ង" មួយ ហើយប៉ុនប៉ងរំលំរបបភ្នំពេញតាមវិទ្ធង្សនា និងការឃុបឃិតក្បត់។

<u>កញ្ញា :</u> ថ្ងៃ ២ ៖ គណៈប្រតិភូយ៉ាងធំរបស់ខ្មែរ —គណៈទីពីរក្នុងរយៈពេលតិចជាងមួយខែ— មកដល់ ប៉េកាំង ដឹកនាំដោយ នួន-ជា ប្រធានរដ្ឋសភា។ ចំណែកឯ ផាំ យ៉ាំងដុង វិញ ក៏រៀបចេញទៅ ទស្សនា រដ្ឋធានីផ្សេងៗ នៃអាស៊ីអាគ្នេយ៍ដែរ។

ថ្ងៃ ២ ដដែល ៖ វិទ្យុហាណូយអំពាវនាវ ឲ្យខ្មែរទាំងអស់បះបោរឡើង ក្នុងនាមនៃ "កងកំលាំងស្នេហា ជាតិ និងបដិវត្តន៍ពិតប្រាកដនៃរណសិរ្ស ២០៣"។

*កាសែត ឡឺម៉ុង ថ្ងៃ ២៣ ៖ សីហនុ ឥតចង់ជួបគណៈប្រតិភូជប៉ុន ដែលពេលនោះធ្វើទស្សនកិច្ចនៅភ្នំពេញ។*

*<u>តុលា :</u>* *សារពត៌មាន ឡឺម៉ុង ថ្ងៃ ២ ៖ វៀតណាមធ្លង់កាត់ស្ថានភាពមួយដែលពិបាកណាស់។ អាជ្ញាធរបញ្ជាក់ថា តាំងពីដើមខែកញ្ញា ទឹកជំនន់ធ្វើឲ្យរង់គ្រោះដល់មនុស្សជាង២លាននាក់។ ស្រូវ និងសត្វពាហនៈ បានខូចបង់ច្រើនណាស់។ មួយចំណែកទៀត ប្រទេសយួនដែលមិនទាន់ទាំងងើបផុតពីមហន្តរាយសង្គ្រាម ៤៦-៧៥ ផង កំពុងរៀបចំធ្វើសង្គ្រាមជាថ្មីទៀត ដោយហេតុមានទំនាស់ពីរជាមួយនឹងចិន និងជាមួយកម្ពុជា។ នៅផ្នែកខាងត្បូង បណ្តាជនឥត "តាម" ទេ។ ការអំពាវនាវឲ្យស្នេហាជាតិធ្វើឡើងដោយឥតឈប់ឈរ។*

*នៅតាមព្រំដែនយួន-ចិន ទាហានយួនប្រដាប់អាវុធនិងស្បៀង ដឹករណ្តៅត្រង់សេ។*

*នៅប្រទេសលាវ គេឮថា កងទ័ពប្រើឧស្ម័នពុល ទល់នឹងអ្នកស្រុកភ្នំជាតិម៉ុង។*

*ថ្ងៃ ២៥ ៖ នៅបាងកក តេង ស្យាវពីង និយាយនៅមុខអ្នកផ្សាយពត៌មាន ៖ ការយកបានភ្នំពេញដោយពួកយួន នឹងបង្ហាញបំណងពិតប្រាកដរបស់ហាណូយ។*

*<u>វិច្ឆិកា :</u>* *ជនភៀសខ្លួនតាមសមុទ្រ កាន់តែទៅជារឿងបច្ចុប្បន្នភាព រឿងអន្តរជាតិ។*

*<u>ធ្នូ :</u>* *ថ្ងៃ ២ ៖ តាមមណ្ឌលទូតនៅបាងកក វៀតណាម ត្រួតត្រាបានទឹកដីខ្មែរជាច្រើនកន្លែងទៀតក្នុងកំឡុងពីរអាទិត្យមុននេះ។ នៅវ៉ាស៊ីងតោន ក្រសួងសម្ងាត់អះអាងថា ទ័ពខ្មែរបានទទួលការបង់ខាតដ៏ធ្ងន់បំផុត ក្នុងរយៈពេល ១៨ ខែនេះ។*

*ថ្ងៃ ៣ ៖ វិទ្យុហាណូយផ្សាយថា នៅទីកន្លែងមួយក្នុងតំបន់រំដោះនៅកម្ពុជា រណសិរ្សរួបរួមស្រោចស្រង់ជាតិ បានកើតឡើង។ ហេង-សំរិន ជាប្រធាន តែងតាំងឡើងដោយសមាជបង្កើតរណសិរ្ស។*

*កាសែត ឡឺម៉ុង ថ្ងៃ ១១ ៖ វិទ្យុហាណូយ ដែលដើរតួជាប្រកពឲ្យដំណឹងពីការបះបោរខ្មែរ ផ្សាយពីការបះបោរថ្មីទៀត ក្នុងខេត្តកំពង់ចាមដែលលើកគ្នាតំរង់មកទន្លេមេគង្គ។ ក្នុងពេលជាមួយគ្នា ប្រភពផ្សេងៗនៅបាងកក និយាយអំពីការវាយរុញច្រានរបស់យួន តំរង់មកទន្លេមេគង្គ ដើម្បីបណ្តាច់ចេញពី ភ្នំពេញ នូវខេត្តទាំងឡាយនៃទិសឦសាន្ត ហើយឲ្យទីជំរកមួយទៅរណសិរ្ស ហេង-សំរិន។ តាមអ្នកឆ្លើយឆ្លងម្នាក់នៅបាងកករបស់កាសែត ញូវយ៉កថែម ពួកយួននៅត្រឹមតែ ៤០ គ.ម. ពីក្រចេះទេ។ កាលពីថ្ងៃ ៩ វិទ្យុភ្នំពេញចោទរណសិរ្ស ហេង-សំរិន ជាអង្គការយួនដែលមានឈ្មោះខ្មែរ ប៉ុន្តែដឹកនាំដោយយួន ហើយមានទីស្នាក់ការនៅព្រៃនគរ។*

*សារពត៌មាន ឡឺម៉ុង ថ្ងៃ ២២ ៖ ក្រៅពីការចោទផ្សេងៗ ដល់វៀតណាម រដ្ឋាភិបាលភ្នំពេញនៅតែផ្សាយពត៌មានសុទិដ្ឋិនិយម អំពីស្ថានភាពក្នុងប្រទេស។ បើគេជឿពត៌មានទាំងនេះ កម្ពុជា កសាងបានយ៉ាងរហ័សនូវ សង្គមប្រជាធិបតេយ្យមួយ ហើយសេដ្ឋកិច្ចខ្លួនកំពុងរីកចំរើន។*

*ដោយសុំចូលស្រុកខ្មែរមិនបាន អ្នកឆ្លើយឆ្លងនៅបាងកករបស់កាសែត ឡឺម៉ុង នេះ ស្វែងរកពត៌មានពីកម្ពុជាក្នុង.... ជំរំអ្នកភៀសខ្លួន។*

*ថ្ងៃ ២៣ ទៅ ២៥ ៖ ស្ថានការណ៍កាន់តែតានតឹងឡើងនៅតាមព្រំដែនចិន-យួន។*

*ថ្ងៃ ២៧ ៖ ខ្មែរក្រហមបើកប្រាសាទអង្គរវត្តឲ្យអ្នកសារពត៌មានបរទេសមើល បន្ទាប់ពីសង្គ្រាមនិង បដិវត្តន៍អស់ពេល ៩ ឆ្នាំ។*

*o*

*o o*

*ថ្ងៃ ៧ មករា ១៩៧៩ ប្រទេសកម្ពុជាបានរបូតចេញពីចង្កូម **ខ្មែរក្រហម** ហើយធ្លាក់ទៅក្នុងកណ្ដាប់ដៃ ប្រទេសវៀតណាម។ ការៈធ្វើឲ្យស្រុកខ្មែរ និងប្រជាជនខ្មែរមានសេរីភាពឡើងវិញ នៅលើស្មាយើង រាល់គ្នាហើយ។*

*ខែ មេសា ១៩៨២*

# ទំព័រភ្ជាប់ ៣

# ផែនទី




*ពីរភាគបីនៃផ្ទៃដីវៀតណាម មានសុទ្ធតែព្រៃភ្នំក្រំថ្មដែលគេពុំអាចដាំអ្វីដុះ។ យួនរស់យ៉ាងចង្អៀតចង្អល់នៅលើដីវាលរាប ដែលខ្លួនអាចធ្វើស្រែចំការបាន។ មួយភាគបីនៃផ្ទៃដីដែលអាចដាំស្រូវបាន គឺវាលត្រីកោណពីរដែលទន្លេមេគង្គ និង ទន្លេក្រហមហូរកាត់។ ផ្ទៃដីដែលដាំដុះនេះមានទំហំតូចជាងកម្ពុជាទៅទៀត ហើយត្រូវចិញ្ចឹមបណ្ដាជន ៥០ លាននាក់ (នៅឆ្នាំ ២០០០ បណ្ដាជននេះនឹងកើនឡើងដល់ ៧៥ លាន!)។*




បើគេមើលប្រទេសនៅឥណ្ឌូចិនមួយម្តងៗ ដាច់ពីគ្នា ប្រទេសទាំងនោះពុំសូវមានទេ។ ប៉ុន្តែបើគេដាក់បូកចូលគ្នានូវធនធានខាងរ៉ែ ខាងកសិកម្ម និង ខាងទឹក ប្រទេសទាំងបីមានសភាពជា "ប្រទេស" មួយដែលមាន ហើយច្បាស់ជាស្ថិតនៅក្នុងចំណោមប្រទេសដែលសំបូរជាងគេនៅអាស៊ីភាគអគ្នេយ៍។



កំរាល់ប្រជាជននៅឥណ្ឌូចិន




លំដាប់ពេលវេលានៃការនិគមកម្មបារាំងលើឥណ្ឌូចិន



គំរោងការលើទន្លេមេគង្គផ្នែកខាងក្រោម



ភាសានៅឥណ្ឌូចិន




*សន្ធិសញ្ញាឆ្នាំ ១៨៦៣ រវាង ព្រះបាទនរោត្តម និង ឧត្តមនាវី ដឺឡាក្រង់ឌ្យែរ, “គូវែន័រ, ចៅហ្វាយ” ទីមួយនៃ កូសាំងស៊ីន, សន្ធិសញ្ញាដែល ព្រះបាទនរោត្តម ទទួលការគាំពារ, “ប្រតិកតូរ៉ា” ពីបារាំង។*

*សន្ធិសញ្ញាឆ្នាំ ១៨៦៧ បានធ្វើឡើងដោយលួចលាក់រវាងបារាំងនិងសៀម។ តាមសន្ធិសញ្ញានេះ សៀមឈប់ទារសួយអាករពីខ្មែរ ប៉ុន្តែត្រូវដូរជាមួយនឹងខេត្តបាត់ដំបង សៀមរាប (អង្គរក៏ត្រូវបានទៅសៀមដែរ) ស៊ីសុផុន ទន្លេរពៅ និងម្លូព្រៃ ត្រូវឲ្យទៅសៀម។ ដល់ពេលហ្វូងនរោត្តមដឹង, ដឺឡាក្រង់ឌ្យែរ ចចារបាន មកពីសៀមវិញតែមាត្រាបន្ថែមមួយប៉ុណ្ណោះ ៖ ខ្មែរអាចចាប់ត្រីក្នុងបឹងទន្លេសាបបានដូចសៀម!*




*កិច្ចសន្យាឆ្នាំ ១៩០៤ ៖ កំពង់ផែត្រាត ហើយនិងទឹកដីនៅទិសខាងត្បូង ព្រមទាំងកោះទាំងឡាយ ដែលនៅជិតឆ្នេរចាប់ពីជ្រោយឡាំស៊ីងទៅ បានត្រូវប្រគល់មកឲ្យឥណ្ឌូចិនវិញ។ ខេត្តម្លូព្រៃ និង ទន្លេរពៅ ទើបនឹងបានមកឥណ្ឌូចិនវិញតាមរយៈកិច្ចសន្យាឆ្នាំ ១៩០២។*




<u>កិច្ចសន្យាឆ្នាំ ១៩០៧</u> ៖ តាមកិច្ចសន្យានេះ ខេត្តសៀមរាប បាត់ដំបង និង ស៊ីសុផុន បានត្រឡប់មកខ្មែរវិញ ដោយដូរគ្នាជាមួយនឹងទឹកដីសៀម គឺដានសៃ, ត្រាត និងកោះទាំងឡាយនៅខាងត្បូងជ្រោយឡាំស៊ីង។




កិច្ចព្រមព្រៀងសន្តិភាពឆ្នាំ ១៩៤១ រវាងបារាំង និង ថៃ (សៀមបានដូរឈ្មោះទៅជាថៃចាប់តាំងពីឆ្នាំ ១៩៣៩ មក) បានធ្វើឲ្យខ្មែរបាត់បង់ជាលើកទីពីរ នូវខេត្តស៊ីសុផុន បាត់ដំបង ស្ទឹងត្រែង កំពង់ធំ និង សៀមរាប (លើកលែងតែបរិវេណអង្គរ)។



▲ មហាណាចក្រខ្មែរ នៅដំណាច់សតវត្សរ៍ទី ១២

▼ រាជធានីចាស់ៗ នៃអតីតៈមហាណាចក្រខ្មែរ






ឥណ្ឌូចិននៅក្នុងកំឡុង គ.ស. ៩៦០




D'après Foursereau, Le Siam ancien.

Carte de la péninsule indochinoise, par lés frères Van Langren, 1595.

*ផែនទីនៅក្នុងទំព័រនេះ និងក្នុងទំព័រខាងក្រោយ គឺលទ្ធផលនៃការស្រាវជ្រាវ និងរុករកនៃជនជាតិអឺរ៉ុប រហូតមកដល់សតវត្សរ៍ទី ១៧។ ផែនទីទាំងនេះច្រើនតែឃ្លាតឆ្ងាយពីភាពត្រឹមត្រូវខាងខ្នាតភូមិសាស្ត្រ។ ក៏ប៉ុន្តែតាមរយៈឯកសារទាំងនេះ យើងអាចទាញយកពត៌មានជាច្រើន ដូចជាការវិវត្តន៍នៃទឹកដីខ្មែរ ប្រភពនៃឈ្មោះ "កូសាំងស៊ីន" ជាដើម។*




Les Indes Orientales de Mercartor (Edition de 1607).

នៅរវាងគ.ស. ១២៨០ អ្នករុករកជាតិអ៊ីតាលី ម៉ារកូ ប៉ូឡូ ឈប់សំចតនៅតុងកឹង ហើយឲ្យឈ្មោះវាលត្រីកោណដែលទន្លេក្រហមហូរកាត់ចាក់ចូលទៅក្នុងសមុទ្រនោះថា “កៅជីហ្គូ” (Caugigu)។ ពួកដើរសំពៅជាតិចាមផ្លាប្រើក្លាយជា “គុតជី” រួចមកពួកជប៉ុនជា “កូឈី”។ ក្រោយមកបារាំងប្រើជា “កូសាំង” (Cochin) ដោយបន្ថែមពាក្យ “ស៊ីន” (Chine) នៅខាងចុង ដើម្បីបញ្ជាក់ថា កូសាំង ដែលនៅខាងចិន (មិនមែនកំពង់ផែនៅឥណ្ឌាទេ) យើងអាចឃើញច្បាស់នៅលើផែនទីនេះថា កូសាំងស៊ីន នៅខាងលើប្រទេសចំប៉ា។ បារាំងប្រឡំមួយជាន់ទៀតដោយចង្អុលវាលត្រីកោណក្រោមបង្អស់ គឺវាលត្រីកោណនៃទន្លេមេគង្គថាជា “កូសាំងស៊ីន”។




Carte du Tonkin et de l'Annam, par le Père de Rhodes, 1633.




Carte de la péninsule indochinois, par P. du Val, 1686.




Librairie Classique d'Eugène BELIN à Paris.




L'Inde transgangétique de l'Atlas de Leide (chez Pierre vander Aa.... 1695)



*ផែនទីបង្ហាញឈ្មោះទីក្រុង ខេត្ត ភូមិ ស្រុក ដែលយួនបានផ្លាស់*
*ទៅជាយួនតាំងពីឆ្នាំ ១៨៣៨ (គឺឆ្នាំ ១៨៣៨!) ម្ល៉េះ ឬមុននេះផង។*




*ផែនទីឥណ្ឌូចិនដែលរៀបរៀងឡើងដោយអ្នកតំណាងរាស្ត្របារាំង ហ្វ្រង់ស្វ័រ ដឺឡុងក្លឺ ក្នុងឆ្នាំ ១៨៨៩ ហើយដែលយកលំនាំតាមផែនទីនានានៃផ្នែកក្រសួងភូមិសាស្ត្រនៃកងទ័ពបារាំងនៅឥណ្ឌូចិន តាមឯកសារជាផ្លូវការនានានៃប្រទេសអណ្ណាម ភូមា ថៃ (ពេលនោះឈ្មោះសៀមនៅឡើយ) និងចិន ព្រមទាំងតាមការរុករកតាមដំណើរ និងតាមបេសកកម្មនានា ដែលបានធ្វើឡើងក្នុងពេលចុងក្រោយបំផុតនៅជំនាន់នោះ។*

## ទំព័រភ្ជាប់ ៤

# លំដាប់ពេលនៃការពង្រីកទឹកដីយួន



*ជាតិយួនចាប់ផ្ដើមប្រវត្តិសាស្ត្រខ្លួននៅតុងកឹង ហើយមានឈ្មោះថា ៖ យ៉ាវ-ជី។ ជាតិយួនជាលទ្ធផលនៃការបង្កាត់សាសន៍ឥណ្ឌូណេស៊ីយែន និង ម៉ុងហ្គោល នៅសម័យបុព្វប្រវត្តិសាស្ត្រ។ ការលាយចូលគ្នាជាមួយចិន មានឡើងនៅពេលក្រោយមកហើយទេ។*

*នៅឆ្នាំ ២៣២ មុនគ្រិស្តសករាជ អធិរាជ តាន់ នៃប្រទេសចិន បានបញ្ជូនទ័ពចំនួន ៥សែននាក់ ដែលបញ្ជាដោយមេទ័ពឈ្មោះ ញ៉ាម-ផាំ និង ទ្រៀវ-ដា មកច្បាំងដណ្ដើមយកស្រុក យ៉ាវ-ជី។ ឆ្លៀតឱកាសក្នុងពេលដែលមានចលាចលនៅស្រុកចិន ទ្រៀវ-ដា ក៏ប្រកាសខ្លួនជាស្ដេចនៃរាជាណាចក្រ ណាម-យេះ (ណាម - វៀត ក្នុងភាសាយួន) នៅឆ្នាំ ២០៨ មុន គ.ស.។ ការកាន់កាប់ទឹកដី និង ចិនូបនីយកម្ម នៃពួក យ៉ាវ-ជី ដែលពីមុនចិនចាត់ទុកជាជាតិសាសន៍ព្រៃផ្សៃ ក៏បានឡើងឋានៈស្មើនឹងចិនដែរ ហើយអាចធ្វើការ ព្រមទាំងអាចទទួល*

ផែនទីទំព័រនេះ បង្ហាញពីការវិវត្តន៍នៃភូមិសាស្ត្រប្រទេសឥណ្ឌូចិនពីសតវត្សរ៍ទី ២ ដល់ទី ១៩។






*ហានន្តរសក្តិស្មើនឹងចិន ចាប់តាំងពីដើមសតវត្សរ៍ទី ៣ ដែលនៅក្រោមរជ្ជកាលស្តេចចិន ស៊ីវ-វួង មក។ ប៉ុន្តែ ស៊ីវ-វួង បញ្ជាឲ្យពួក យ៉ាវ-ជី រៀន ព្រមទាំងប្រើអក្សរនិងភាសាចិន។ គឺតាមរបៀបនេះហើយ ដែលពួក យ៉ាវ-ជី ទទួលឥទ្ធិពលនៃវប្បធម៌ និង របៀបគិត ព្រមទាំងរបៀបរៀបចំសង្គមទៅតាម កុង-ហ្វូយស្យុស* (Confucius) *និង តាវអ៊ី* (Taoïsme) *ហើយដែលថ្ងៃក្រោយមក នឹងប្រើអាវុធនេះសំរាប់រំដោះខ្លួនចេញពីចិនវិញ។*

*នៅឆ្នាំ ២៦៣ (ក្រោយ គ.ស.) ឈ្មោះ "អាន-ណាំ" បានត្រូវគេប្រើជាលើកទី១ ដើម្បីសំគាល់ទឹកដីនៅខាងត្បូង (ស្រុកចិន) ដែលបានទទួលសន្តិភាព។*

*នៅឆ្នាំ ៣៥៣ ពួក យ៉ាវ-ជី (ឬយួន) តបទៅនឹងការវាយលុកលើទឹកដីខ្លួនពី ចាម ក៏វាយនគរចំប៉ាជាលើកទី១។*

*ជាសាសន៍ឥណ្ឌូណេស៊ីយែន, ជាតិចាមបានមករស់នៅតាំងពីយូរមកហើយ នៅលើទឹកដីដែលជា វៀតណាម កណ្តាលសព្វថ្ងៃ ចាប់តាំងពី "ទ្វារអណ្ណាម" រហូតដល់ជ្រោយ វ៉ារែលឡា។ នៅឆ្នាំ ១៣៧ ចិនឈ្មោះ ជូលៀន សំឡាប់ម្ចាស់ស្រុក លិន ជី (ដែលនៅក្រោមអំណាចចិនដែរ) ហើយប្រកាសខ្លួនជាស្តេចនៃស្រុក លិនជី (ឡាម-អាប ក្នុងភាសាយួន)។ គឺដូច្នេះឯងដែលនគរចំប៉ាកើតឡើង ហើយស្វាហាប់ណាស់។*

*នៅសតវត្សរ៍ទី២ និង ទី៣ ក្នុងពេលដែលខ្លួនលាតសន្ធឹងទឹកដី នគរចំប៉ាកំពុងទទួលឥទ្ធិពលយ៉ាងខ្លាំងពីឥណ្ឌា។ គឺប្រហែលជាតាមឈ្មួញសមុទ្រ ញ៉ា ត្រាង ដែលពួកឥណ្ឌាបញ្ចូលខ្លួនទៅក្នុងនគរចំប៉ា ហើយនាំចូលទៅឲ្យចាមនូវព្រហ្មញ្ញសាសនា និងអក្សរ។ ខ្លួនទទួលឥទ្ធិពលពីឥណ្ឌាមែន ប៉ុន្តែដោយមកពីបុព្វហេតុខាងយុទ្ធ-សាស្ត្រ ចំប៉ាចងសម្ពន្ធគ្នាជាមួយចិន ដើម្បីវាយអណ្ណាម។ គេពុំដឹងថាមកពីហេតុអ្វីពិតប្រាកដ ដែលបណ្តាលឲ្យចាមវាយស្រុកអណ្ណាមទេ។ ក៏ប៉ុន្តែគេពុំត្រូវភ្លេចទេថា ចិនបានភ្ជាប់ស្រុករបស់ពួក យ៉ាវ-ជី ទៅនឹងស្រុកចិន។ ប្រហែលក្នុងពេលធ្វើដំណើរឆ្ពោះមកទិសខាងត្បូងនេះហើយ ដែលចិនជាន់ប៉ះលើទឹកដីរបស់ជាតិដែលមានដើមកំណើតជាសាសន៍ឥណ្ឌូណេស៊ីយែន។*

*ដោយសារសង្គ្រាមមិនឈប់ឈររវាងរាជវង្សចិនទាំងឡាយ អាណាចក្រចិនក៏ត្រូវបង្ខំខ្លួនបន្ថយឥទ្ធិពលមកលើស្រុកអណ្ណាម។ នៅសតវត្សរ៍ទី១០ អធិរាជចិនឈប់មានអំណាចអ្វីពិតប្រាកដ ទៅលើអណ្ណាមហើយ។ នៅឆ្នាំ ៩៣៩ ការបះបោរមួយបានធ្វើឲ្យអណ្ណាមបានទទួលឯករាជ្យចេញពីចិន។*

*បន្ទាប់ពីបានស្គាល់អនាធិបតេយ្យ អស់រយៈមួយសតវត្សរ៍ រាជវង្ស លី បានពង្រីងជំហរនគរអណ្ណាមដែលលាតសន្ធឹងខ្លួនមកទិសខាងត្បូង ដោយលេបយកទឹកដីនគរចំប៉ា។ ស្តេចចំប៉ា ក៏លើករាជធានី ឥន្ទ្របូរៈ (ដុងដួង សព្វថ្ងៃ) ទៅនៅឯ វិជ័យ (ប៊ិញឌិញ សព្វថ្ងៃ)។*

*សង្គ្រាមខ្យោះឈាមជាមួយយួន ពីខាងជើង បានបង្ខំចាមដែលខំរកទឹកដីថ្មីសំរាប់នៅ និងចិញ្ចឹមជីវិតជំរុញដំណើរមកទិសខាងត្បូង ហើយក៏ប៉ះនឹងខ្មែរ។ សង្គ្រាមរវាងខ្មែរនិងចាមមានរយៈពេលរាប់រយឆ្នាំ។ ឆ្លៀតឱកាសដែលខ្មែរនិងខ្មែរឈ្លោះបែកបាក់គ្នា ចាមទាំងក្រុមៗ សាកល្បងមកតាំងទីនៅលើវាលរាបនៃដងទន្លេមេគង្គ។ ចាមវាយយកឆ្នេរសមុទ្រ ចូលប្ញន់ស្រុកភូមិខ្មែរ ព្រមទាំងចាប់យកខ្មែរធ្វើជាទាសករផង។ លុះមកឆ្នាំ ១១២៣ ក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី២ ទើបខ្មែរអាចដេញកំចាត់ចាមទៅវិញ រហូតដល់ព្រំដែននគរអណ្ណាម។ តែស្តេចយួន លី ញ៉ាំង តុង (១០៧២-១១២៨) ជួយគាំពារចាមដែលបាក់ទ័ពរត់ចូលទៅក្នុងនគរអណ្ណាម។ សុរិយាវរ្ម័នទី២ ក៏ប្រកាសសង្គ្រាមជាមួយយួន។ ស្តេចខ្មែរនាំទ័ពពីរម៉ឺននាក់ និងកងនាវាចរដែលមានទូក ៧០០ ទៅវាយយួន។ ជាលើកទី១ ដែលសម្ពន្ធភាពខ្មែរ-ចិន-ចាម កើតឡើងដើម្បីវាយយួន។ ប៉ុន្តែឥតបានឈ្នះទេ។ នៅឆ្នាំ ១១៣៦ ស្តេចចាមជយឥន្ទ្រវរ្ម័នទី៣ ក៏ដកខ្លួនចេញពីសម្ពន្ធភាពនេះ ហើយយកនគរខ្លួនទៅដាក់ក្រោមទាសភាពស្តេចអណ្ណាម លី ថាន់ តុង (១១២៨-១១៣៩)។ សុរិយាវរ្ម័នទី២ ស្បថថានឹងសងសឹកចាម*

*វិញ។ ឆ្នាំ ១១៨៥ ខ្មែរវាយចំប៉ា ដណ្តើមយករាជធានី វិជ័យ បាន ហើយកាន់កាប់នគរចាមទាំងមូលអស់រយៈពេល ៥ ឆ្នាំ។ ពេលព្រះបាទសុរិយាវរ្ម័នទី២ សុគត ចាមក៏រើបំរះខ្លួនរួចវិញ។ ធរនិន្ទ្រវរ្ម័នទី២ (១១៥០-១១៦០) ប្អូនជីដូនមួយនៃព្រះបាទសុរិយាវរ្ម័នទី២ ដែលសោយរាជ្យបន្ត ក៏ចេះតែច្បាំងរប៉េះរប៉ោះតទៅទៀតជាមួយនឹងចាម។*

*អនាគតព្រះបាទជ័យវរ្ម័នទី៧ កូនរបស់ព្រះបាទធរនិន្ទ្រវរ្ម័នទី២ នាំទ័ពទៅវាយចាមនៅចំប៉ា ផ្នែកកណ្តាលអស់រយៈពេលជប់ឆ្នាំ។ កំពុងតែវាយរាជធានីវិជ័យ (ឆ្នាំ១១៦០) ជ័យវរ្ម័នទី៧ ទទួលដំណឹងថាបិតាខ្លួនចូលទីវង្គត ហើយ យសោវរ្ម័នទី២ (១១៦០-១១៦៥) ឡើងសោយរាជ្យបន្ត។ ខកចិត្ត ជ័យវរ្ម័នទី៧ ក៏ត្រឡប់មកស្រុកវិញ ហើយឈប់ធ្វើសកម្មភាពអ្វីទាំងអស់។ សោយរាជ្យបាន ៥ ឆ្នាំ យសោវរ្ម័នទី២ ក៏ត្រូវ បុរណ-ទិតយវរ្ម័ន ធ្វើគតហើយឡើងសោយរាជ្យបន្ត។ គឺក្នុងរាជ្យស្តេចនេះហើយ ដែលចាមវាយយកអង្គរម្តងទៀត (ឆ្នាំ១១៧៧) ហើយកាន់កាប់ស្រុកខ្មែរអស់រយៈពេល ៥ ឆ្នាំ។*

*ពេលចាមកាន់កាប់ស្រុក ជ័យវរ្ម័នទី៧ ងើបឡើងបង្កើតទ័ព ហើយរំដោះកម្ពុជាចេញពីនឹមចាមវិញបាន ហើយក៏ឡើងសោយរាជ្យ (១១៨២-១២០១)។ ដោយចាមនៅតែរុកគួនខ្មែរទៀត ព្រះបាទជ័យវរ្ម័នទី៧ ក៏វាយកំទេចចាម ហើយយកចំប៉ាជាចំណុះម្តងទៀត។ ពីឆ្នាំ ១២០៣ ដល់ឆ្នាំ ១២២០ ចំប៉ាក្លាយទៅជាខេត្តមួយរបស់ខ្មែរទៅហើយ។ នៅឆ្នាំ ១២០១ ជ័យវរ្ម័នទី៧ ស្តេចខ្មែរដ៏ពូកែល្បីល្បាញចុងក្រោយបង្អស់ ចូលទីវង្គត ហើយ ឥន្ទ្រវរ្ម័នទី២ ជាកូន ឡើងសោយរាជ្យបន្ត (១២០១- ១២៤៣)។*

*ជាអ្នកកាន់ព្រះពុទ្ធសាសនាមហាយាន យ៉ាងខ្ជាប់ខ្ជួនដូចបិតាខ្លួនដែរ ឥន្ទ្រវរ្ម័នទី២ ប្រកាន់អហឹង្សាធិម ដោយចង់បង្ហាញមេត្តាធិម ក៏ស្រាប់តែបញ្ជាជាឯកតោភាគី ឲ្យដកកងទ័ពចេញពីស្រុកចំប៉ា (១២២៦) កាយវិការដែលគេពុំសូវដែលបានឃើញឡើយ នៅក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិណាក៏ដោយ។ មហន្តរាយនឹងធ្លាក់មកដល់ប្រជាជាតិខ្មែរដោយកាយវិការនេះ។ ពិតដូចនេះមែន ដោយធ្វើឲ្យបាត់រដ្ឋមួយជាទ្រនាប់* (Etat tampon) *កាយវិការនេះបើកផ្លូវឲ្យយួនក្នុងដំណើរមកទិសខាងត្បូង។ ក្នុងពេលដែល ខ្មែរ និង ចាម ច្បាំងគ្នារាប់រយឆ្នាំ អណ្ណាមពុំអាច ឬ ពុំចង់ចូលមកលូកលាន់ក្នុងសង្គ្រាមឡើយ។ ព្រោះក្រោយរាជ្យស្តេច លី អាញ់តុង (១១៣៩-១១៧៦) មក អណ្ណាមធ្លងកាត់អនាធិបតេយ្យពេញទី ដោយមកពីចំបាំងដណ្តើមរាជ្យគ្នា។ ពេលឃើញអណ្ណាមចុះទន់ខ្សោយ និងឃើញជម្លោះមិនចេះចប់មិនចេះហើយ រវាងស្តេចទាំងឡាយនៃរាជវង្ស លី, ចាមឆ្លៀតឱកាសសុំឲ្យអណ្ណាមប្រគល់ទឹកដីដែលយួនបានក្តាប់ទៅអណ្ណាមមកឲ្យខ្លួនវិញ។ ការប្រទូស្តរ៉ាយរវាងចាមនិងយួនក៏ចាប់ផ្តើមឡើងវិញ។ សង្គ្រាមបួនលុកលុយយ៉ាងយូរ (ជាង៣០ឆ្នាំ) នៃពួកម៉ុងហ្គោលមកលើអណ្ណាមផង មកលើចំប៉ាផង គ្រាន់តែមកផ្អាកមួយពេលប៉ុណ្ណោះ នូវដំណើររបស់យួនមកទិសខាងត្បូង។ ការលាតសន្ធឹងទឹកដីរបស់យួនក៏ចាប់បន្តទៅទៀត នៅពេលចប់សង្គ្រាមជាមួយពួកម៉ុងហ្គោល។ ស្តេចយួន ត្រាន់ អាញ់តុង (១២៩៣ -១៣១៤) លើកបុត្រីខ្លួន (ហៀន ត្រាន់) ឲ្យរៀបការជាមួយស្តេចចាម ចេ ម៉ាន ដែលលើកខេត្តរ៉ើ ទៅឲ្យយួន!។ ឌាន់ ញូហាយ រាជទូតយួនប្រចាំនគរចំប៉ា ដឹកនាំហើយចាក់រុកឲ្យចៅហ្វាយខេត្តចាមម្នាក់ ធ្វើរដ្ឋប្រហារ ហើយចាប់ស្តេចចាម (ចែ ជី)(*) ទៅ ហាណូយ (កាលនោះឈ្មោះ កែ ជោ)។ ស្តេចចាម ចេ ណាង ខំសាកល្បងរំដោះខេត្តរ៉ើពីយួនមកវិញដែរ តែពុំបានសំរេច។*

*ក្នុងពេលដែលខ្លួនលាតសន្ធឹងទឹកដីទៅទិសខាងត្បូង អាណាចក្រអណ្ណាមក៏ពុំភ្លេចវាតទីទៅទិសខាង*

---

*(*) គេពុំបានដឹងឲ្យបានពិតប្រាកដថាពេលណាទេ ដែលសាសនាអ៊ីស្លាមបានចូលទៅនគរចំប៉ា ប៉ុន្តែបើគេពិនិត្យមើលតាមឈ្មោះស្តេចចាមទាំងឡាយ គេអាចនឹងដឹងថាប្រហាក់ប្រហែលពីពេលដែលមានការផ្លាស់ប្តូរនេះ ពីចំប៉ាដែលកាន់ព្រហ្មញ្ញសាសនា ទៅ ចំប៉ាដែលកាន់សាសនាអ៊ីស្លាម។*

លិចដែរ។ នៅក្រោមរាជ្យ ត្រាន់ ហៀនតុង (១៣៣០-១៣៤២) ទ័ពយួនដែលដឹកនាំដោយ ឌាន់ ញហាយ ចាប់លុកលុយប្រទេសលាវ (អៃ ឡាវ ក្នុងភាសាយួន) តែត្រូវលាវ វាយរុញច្រានចេញមកវិញ ហើយសម្លាប់មេទ័ពនេះ ដែលមានគំនិតចង់វាយដណ្តើមយកលាវឲ្យបានសិន ហើយបន្ទាប់មកចុះមកតាមដងទន្លេមេគង្គ ដើម្បីវាយដណ្តើមយកទឹកដីរបស់ពួកម៉ូយ (ក្នុងភាសាយួនពាក្យនេះមានន័យថា "ពួកព្រៃផ្សៃ") និងទីបំផុតវាយដណ្តើមយក កម្ពុជា !។

នៅចុងសតវត្សរ៍ទី១៤ ស្តេចចាម ចេ ប៉ូណាហ្គា (១៣៦០-១៣៩០) ឆ្លៀតឱកាសដែលមានទុរភិក្សនៅតុង កឹង បញ្ជូនទ័ពទៅលុកលុយអណ្ណាម ក្នុងឆ្នាំ ១៣៦១ ហើយដកខ្លួនមកវិញ ដោយនាំទាំងឈ្លើយសង្គ្រាមយួនជាច្រើនមកជាមួយផង។ ជាអ្នកចំបាំងម្នាក់យ៉ាងពូកែ វីរបុរសនៃចំប៉ា ស្តេចប៉ូណាហ្គា ដាស់ចំប៉ាឲ្យក្រោកងើបឡើង វាយអណ្ណាមកាន់តែខ្លាំង ស្ទើរតែសង្គ្រប់យកអណ្ណាមបាន។ ជាច្រើនលើកជាច្រើនសា ស្តេចប៉ូណាហ្គា វាយឈ្នះយួន រហូតដល់ពេលមួយដែលមានចាមម្នាក់ក្បត់ស្តេចខ្លួន ចង្អុលទូកដែលស្តេចខ្លួនជិះប្រាប់យួនក្នុងពេលកំពុងប្រយុទ្ធគ្នាជាមួយយួននៅលើទន្លេ ហៃ ត្រៀវ។

រាជវង្ស ត្រាន់ បានត្រូវបញ្ចប់ដោយនាម៉ឺនម្នាក់ ដែលមានដើមកំណើតជាចិនឈ្មោះ ឡេ គី លី។ ឡេ គី លី ឡើងសោយរាជ្យ ហើយយកឈ្មោះដើមខ្លួន ហូ គី លី វិញ។ ដាក់រាជ្យនៅឆ្នាំ ១៤០២ ហូ គី លី ប្រគល់រាជ្យទៅឲ្យកូនច្បងរបស់ខ្លួន ហូ ហាន់ ធួង (១៤០២-១៤០៧) ដែលប្រកាសសង្គ្រាមជាមួយចំប៉ា។ ស្តេចចាម ជ័យ ស៊ីមហាវរ្ម័ន ដោយខ្លាចយួនវាយ ក៏បញ្ជូនមារបស់ខ្លួនឈ្មោះ បូ ដៀន ទៅសុំសេចក្តីសុខពីយួន ដោយប្រគល់ខេត្ត អមរាវតី (ក្វាងណាម សព្វថ្ងៃ) ទៅឲ្យយួន។ តែចាមខកចិត្តឥតប្រមាណ យួននៅតែលុកលុយចំប៉ាទៀត។

ឯប្រទេសចិននៃស្តេច មិញ (រាជវង្សដែលបានកំចាត់ពួកម៉ុងហ្គោល) ក៏ធ្វើអន្តរាគមន៍ជួយខាងចំប៉ា)។ ឆ្នាំ ១៤០៦ ចិនយកអណ្ណាមបានជាចំណុះ។ ហូ ហាន់ធួង ត្រូវចិនចាប់ជាឈ្លើយហើយក៏សម្លាប់ខ្លួនឯងទៅ។ ចិនដាក់មន្ត្រីពីរនាក់ឲ្យត្រួតត្រាអណ្ណាម។ ក្រោយឆ្នាំ ១៤១២ ចិនបង្ខំយួនឲ្យប្រកាន់យកទំនៀមទំលាប់របស់ខ្លួន ៖ ទុកសក់វែង ហាមមិនឲ្យយួនសាក់ខ្លួន ។ល។ តែយួនពុំព្រមចុះញ៉មឡើយ។ ដឹកនាំដោយ ឡេ ឡូយ យួនចាប់ច្បាំងរំដោះ រំខ្លួនពីឆ្នាំ ១៤១៨។ នៅឆ្នាំ ១៤២២ លាវចូលដៃជាមួយចិន ហើយបញ្ជូនទ័ព ៣០ ០០០ នាក់ទៅច្បាំងទល់នឹង ឡេ ឡូយ តែត្រូវយួនរុញច្រានឲ្យថយមកវិញ។ ឆ្នាំ ១៤២៨ ឡេ ឡូយ រំដោះយួនចេញផុតពីនឹមចិន ហើយប្រកាសខ្លួនឡើងសោយរាជ្យនៅ កែ ជោ (ហាណូយ) ហើយប្តូរឈ្មោះ អណ្ណាម ទៅជា ដាយ វៀត។ ឡេ ឡូយ ដែលបង្កើតរាជវង្សមួយទៀត គឺរាជវង្ស ឡេ ក៏ដោះលែងឈ្លើយសង្គ្រាមចិនឲ្យទៅស្រុកវិញ ហើយប្រកាសសន្តិភាព ឈប់ប្រទូស្តរ៉ាយគ្នាជាមួយចិន។

នៅក្រោមរាជ្យ ឡេ ញ៉ង តុង (១៤៤៣-១៤៦០) (ចៅរបស់ ឡេ ឡូយ) អណ្ណាមវាយយកបានរាជធានីវិជ័យ ចាប់ស្តេចចាម មហាវិជ័យ និង រាជវង្សានុវង្សទាំងអស់ទៅតុងកឹង ហើយចូលលុកលុយនគរចំប៉ា។ យួនបន្តុបចាមម្នាក់ដែលក្បត់លើរាជបល្ល័ង្កនគរចំប៉ា។ ពេលវេលាបានខិតមកដល់ទឹកបង្ហើយ ដែលយួនត្រូវលេបត្របាក់យកនគរចំប៉ាឲ្យអស់។ ស្តេចយួន ឡេ ថាញ់ តុង (ប្អូនរបស់ ញ៉ុន តុង) (១៤៦០-១៤៩៨) ដោយយកលេសថាចាមវាយរុកគួនយួននៅខេត្ត ហាវចាវ កែនទ័ព ២៦០ ០០០នាក់ ដើម្បីកំទេចចំប៉ា។ ឆ្នាំ ១៤៧១ ឡេ ថាញ់តុង វាយយករាជធានី វិជ័យ បាន។ ស្តេចចាម បនឡាត្រាទាន់ ត្រូវយួនចាប់បាន ហើយចាម ៦ ម៉ឺននាក់ត្រូវយួនសម្លាប់ ៣ ម៉ឺននាក់ទៀតចាប់ជាឈ្លើយ។ គឺជាអវសានកាលរបស់នគរចំប៉ា។ អណ្ណាមកាន់កាប់នគរចំប៉ាទាំងមូលរហូតដល់គោតរៈ (ជ្រោយវ៉ារែលឡា) ហើយដាក់ទឹកដីខាងត្បូងជាទឹកដីចំណុះ ដោយបន្តុបស្តេចចាមល្អិតល្អោចនានាឲ្យដឹកនាំរដ្ឋាភិបាល។ ក្រោយមកស្តេចត្រាញ់ខាងត្បូង (ខៀវង្វៀង) ពង្រីកអាណាចក្រខ្លួន

*រហូតដល់ព្រៃក ផាន់រ៉ាំង ក្នុងឆ្នាំ ១៦៥៣ ហើយចូលកាន់កាប់ ផាន់រី ក្នុងឆ្នាំ ១៦៩២។ នៅឆ្នាំ ១៨២២ អធិរាជយួន មិញ ម៉ាំង បញ្ជាឲ្យបំបាត់ពូជស្តេចចាម ផាន់ឌុរង្គា។ គឺរបៀបនេះឯងហើយ ដែលនគរចំប៉ាត្រូវយួនលេប ហើយលុបបំបាត់ចេញពីផែនទីពិភពលោក។*

*បន្ទាប់ពីបានដេញចិនចេញ សម្លាប់បំផុតពូជចាម និង កាន់កាប់ទឹកដីមួយផ្នែករបស់លាវមក (ឆ្នាំ ១៤៨០) នគរ ដាយ វៀត ទទួលស្គាល់កោលាហលដ៏យូរ ៖ ចំបាំងក្នុងស្រុកដណ្តើមរាជ្យគ្នា ទុរភិក្ស ព្រមទាំងសង្គ្រាមស៊ីវិល ដែលមួយសតវត្សរ៍ក្រោយមកបំបែកអណ្តាមជាពីរ សត្រូវនឹងគ្នាស៊ីសាច់ គឺ អណ្តាមខាងជើង និង អណ្តាមខាងត្បូង។ គឺក្នុងសម័យនេះនៃប្រវត្តិសាស្ត្រយួន ដែលមេក្រុមនានាកើតឡើង ហើយសោយរាជ្យដូចស្តេច (ក្នុងភាសាយួនហៅថា “ជួ (Chua)”)។ ស្តេច វួ (Vua) មានកិត្តិយសធំបំផុតក្នុងរាជាណាចក្រ។ ដើម្បីគ្រាន់តែជានិមិត្តរូប កិច្ចការរដ្ឋាភិបាលទាំងអស់ សុទ្ធតែធ្វើឡើងក្នុងនាមនៃស្តេច ទោះបីខ្លួនមិនបានចូលរួម ឬមិនបានដឹងក៏ដោយ។ បន្ថែមពីលើនេះ ស្តេចក៏ជាអ្នកមានសម្បត្តិស្តុកស្តម្ភទៀត។ ឯស្តេចត្រាញ់ (ជួ) វិញ ជាអ្នកកាន់កាប់ទ័ព ដកហូតពន្ធដារអាករ ចែកចាយបុណ្យសក្តិ គឺថាជាអ្នកចាត់ចែង គ្រប់គ្រង កិច្ចការរដ្ឋ។*

*នៅខាងជើង ស្តេចនៃរាជវង្ស ឡេ ដែលសោយរាជ្យជាមួយនឹងស្តេចត្រាញ់នៃត្រកូល ទ្រិញ រវល់ជាប់ដៃតែនឹងបង្ក្រាបការបះបោរ។ ជាងមួយសតវត្សរ៍ រាជវង្ស ឡេ ដោយមានគ្រួសារទ្រិញជួយផង នៅតែពុំអាចបង្ក្រាបការបះបោរបាន ប៉ុន្តែឲ្យតែមានឱកាសទំនេរដៃ ក៏ខំឆ្លៀតមកវាយស្តេចត្រាញ់ត្រកូល ង្វៀង នៅអណ្តាមខាងត្បូង។*

*ឆ្លៀតឱកាសដែលមានសង្គ្រាមស៊ីវិលនៅអណ្តាមខាងជើង ស្តេចត្រាញ់ត្រកូល ង្វៀង នៅអណ្តាមខាងត្បូង ពង្រីករាជាណាចក្ររបស់ខ្លួន មុនដំបូងនៅលើទឹកដីដែលយកបានមកពីចាម បន្ទាប់មក បានមកពីខ្មែរ។ គឺពូជ “ង្វៀង” ដដែល ដែលខាំត្របាក់យកកម្ពុជាក្រោម ទឹកដីដូនតាយើង ដែលសព្វថ្ងៃក្លាយទៅជាវៀតណាមខាងត្បូង។ គឺពូជ “ង្វៀង” នេះទៀត ដែលសម្លាប់បំផុតពូជចាម ជនជាតិភាគតិចនៅលើខ្ពង់រាបនៃវៀតណាមកណ្តាល ព្រមទាំងខ្មែរផង។ ពូជង្វៀងនេះបានតាំងរាជធានីនៅ “វ៉េ”។ គឺស្តេច យ៉ា-ឡុង (១៧៧៩-១៨២០) ដែលបានបង្រួបបង្រួមយួនទាំងពីរឲ្យចូលគ្នា ហើយឲ្យឈ្មោះថ្មីថា វៀត-ណាម ដែលសរសេរក្លាយមកសព្វថ្ងៃជា* វៀតណាម ។

ᨒᨒᨒᨒᨒᨒᨒᨒᨒᨒ

*ចប់*

# មូលប័ណ្ណ


- ភាសាខ្មែរ ការសាកល្បងពិនិត្យដោយរកហេតុផល ដោយ អៀវ-កើស បណ្ណាគារ មិត្តសេរី ភ្នំពេញ ១៩៦៧។
- Histoire du Cambodge, par A. Dauphin Meunier, Que sais-je, 1960.
- Histoire du Vietnam, par André Masson, Que sais-je, 1972.
- L'Indochine,par Henri Gourdon, Larousse Copyright, 1931.
- The Far East, par Nathaniel Tesser, Claude A. Buss Copyright, 1968.
- Histoire de l'Extrême-Orient, par R. Gousset, Librairie Orientaliste Paul Gauthier, 1929.
- L'Indochine française, par Paul Doumer, Vuibert et Nony, 1905.
- L'Indo-chine, par E. Bonhoure, Editeur Augustin Challamel, 1900.
- Moeurs et coutumes des Khmers, par Guy Porée et Eveline Maspero, Payot, Paris, 1938.
- Histoire du Laos, par Paul Lévy, Que sais-je, 1974.
- Cambodia – The widening war in Indochina, Jonathan S. Grant, Laurence A.G. Moss et Jonathan Viager Copyright, 1971.
- Les races humaines, par Henri V. Vallois, Que sais-je, 1971.
- Les Etats Hindouisés d'Indochine et d'Indonésie, par G. Coedès, E. de Boccard Editeur, Paris, 1948.
- L'Indochine française, Encyclopédie par l'image, Librairie Hachette, 1931.
- Les peuples de la péninsule Indochinoise, par G. Coedès, Dunod.
- Indochine, Documents officiels, Paris, Sociétés d'Editions géographiques, maritimes et coloniales, tome I et II, 1931.
- French Indochina, par Virginia Thompson, Georges Allen and Unwin Ltd, Londres, 1937.
- Un Empire Colonial Français, par Georges Maspero, Les Editions G. Van Oest, Paris et Bruxelles, 1929.
- Guides Madrolle, Indochine du Sud, Librairie Hachette, 1926.
- Cambodge et Cambodgiens, par Paul Marie Alexandre Collard, Société d' Editions Géographiques, maritimes et coloniales, 1925.
- Le Développement économique de l'Indochine française, par Auguste Grandel, Imprimerie C. Ardin, Saigon, 1936.
- Merveilleux Cambodge, par Claude Fillieux, Société continentale d' éditions modernes illustrées, 1962.
- Histoire de l'Indochine, par André Masson, Que sais-je, 1950.
- Institutions constitutionnelles et politiques du Cambodge, par Claude Gilles Gour, Librairie Dalloz, Paris, 1965.
- Cambodia's Forreign Policy, par Roger M. Smith, Cornell University Press, Ithaca, New York, Copyright, 1965.
- Sihanouk, la fin des illusions, par André Tong, Editions de la Table Ronde, 1972.
- Politics and Powers in Cambodia, Milton Osborne, Edition Longman, 1973.
- Cambodia, its people, its society, its culture, par David J. Steinberg, Editions Fitzsimmons Copyright, 1959.
- Southeast Asia's Chinese minority, par Mary F. Somers Heidhues, Edition Longman, 1974.

- La situation internationale de la Thaïlande en Asie du Sud-Est, Thèse de Paturaya Boonyanant, Université de Montpellier, 1971.
- ស្រណោះព្រលឹងខ្មែរ ដោយ អ៊ិត សារិន ភ្នំពេញ។
- ដំណើរឆ្ពោះទៅទិសខាងលិច និង ឥណ្ឌូចិនឆ្នាំ ២០០០ ដោយ នួន ឃឿន។
- Khmer, par l'Association pour le maintien de la Culture Khmère, Paris, 1978.
- Histoire du XXème siècle, L'Asie du Sud-Est, par Philippe Devillers, Pièrre Fistié, Lê Thanh Khoi, Sirey, 22 rue Soufflot, Paris 1971.
- Conflict and Stability in Southeast Asia, par Mark W. Zacher and R. Stephen Milne, Anchor books, 1974.
- The Dimensions of Conflict in Southeast Asia, par Bernard K. Gordon, Prentice-Hall Inc., Eaglewood Cliffs, New Jersey Copyright, 1966.
- Geneva 1954, par Robert F. Randle, Princeton University Press, 1969.
- Tradition et Révolution au Vietnam, par Georges Boudarel et Daniel Hemery, sous la direction de Jean Chesneaux, Editions Anthropos, Paris.
- La Chine et le Tiers Monde (1949-1969), par Philippe Richer, Payot, 1971.
- Our President Ho Chi Minh, Foreign Languagues Publishing House, Hanoi, 1970.
- Area Handbook Thailand, co-auteurs: Harvey H. Smith, Donald W. Bernier, Frederica M. Bunge, Frances Chadwick Rintz, Rinn-Sup Shinn, Suzanne Teleki, Printing Office, Washington D.C. 20402, September 1968.
- Vietnam and China 1938-1954, par King C. Chen, Princeton University Press, 1969.
- Vietnam 45-72, par Jacques Suant, Editions Arthaud 1972.
- Communism in North Vietnam, its role in the sino-soviet dispute, par P. J. Honey, Greenwood Press Publishers, copyright 1963.
- De sang et de larmes, par Bernard Hamel, Editions Albin Michel, 1977.
- Témoignages sur le Génocide du Cambodge, par Bernard Hamel et Soth Polin, Série ITEM, S.P.L., Paris, 1976.
- Journal Le Monde à partir de 1945.
- Revues: Historia, National Geographic, Science et Vie, etc.


*

*   *


វាយអក្សរសាឡើងវិញ: ឃុន-ពីម៉ូច
កែនិងអនុញ្ញាតផ្សាយ: ប៉ែន នារី
កាណាដា, សហរដ្ឋអាមេរិក, ២០០៤